ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ៥ ខែឧសភា

ព.ស. ២៥០៤ គ.ស. ១៩៦១

- ភ្នំពេញ -

NATIONALE
DU CAMBODGE
P.K_1
1961_5

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

---

*ផ្នែកសាសនា* បញ្ជីរឿង *ទំព័រ*

- វិបារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា (ត) លោក ផល-ទិត្យ រៀបរៀង ៤៧៧
- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៤៩០
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក (តមក) លោក ប៊ូ-ប៉ូ រៀបរៀង . . . ៤៩៨
- មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះ ញ.ញ.ឈើង ពិនិត្យ . . ៥០៧
-មហោសថជាតក(ត)លោកអ៊ុម-ភនបម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-ត្រូវពិនិត្យ . ៥១៦

*ផ្នែកអក្សរសាស្ត្រ*

- វប្បធម៌ខ្មែរ (តមក) លោក លី-ធាមតេង រៀបរៀង . . . ៥២៤
- ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ (តមក) . . . . . ៥១៨
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៥២៩
- ដើមកំណើតប្រាសាទអង្គរ លោក ល៊ីហ្វ៊ីណូត៍រៀបរៀង ក្រមការ ផ៊ុ-មៅ ប្រែ· ៥៣០
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . ៥៣៩
- រឿងមនុស្សចិត្តប្រែប្រួល (តមក) លោកប៊ូ-ប៉ូ រៀបរៀង . . ៥៤៨
- រឿងព្រេងប្រទេសស៊ីរី ភិក្ខុ ម៉ែន-រៀម ប្រែបាកភាសាអង់គ្លេស . . ៥៥៩
- រឿងមាណពមិនបេះដឹកប្រជ្រៀតលោក ញូង-សឿន រៀបរៀង ៥៦៧

*ផ្នែកកំណត់នឹងប្រវត្តិការណ៍*

- បុណ្យទមស្កាវព្រះសក្យមុនីចេតិយ លោក ស្ដើង ជួរ រៀបរៀង . . . ៥៨៤

---

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជារ ២៣០ ៛០០

33e Année — No 5 — Mai 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Pages

— Editorial "Les principes du Bouddhisme" (suite) par *M. PHAL-TITH* . . . 477

— La Vie du Buddha (suite) par Vèn. *PANG-KHAT* . . . . 490

— Prah Abhidhammapitaka, Kampi prah Yamaka (suite) par *M. BOU-FO* . . . . . 498

— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita *LOUIS-EM*, revu et corrigé par Vèn. *NHÉAN-CHHOEUN* . . . . 507

— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM-PHON*, revu et corrigé par Vèn. *KEM-TO* . . . . 516

### Partie littéraire

— La Culture Khmère (suite) par *M. LY-THEAM-TENG* . . 524

— Activités de la Commission Culturelle (suite) . . . . . . . . . . 528

— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 529

— Origine d'Angkor par Louis Finôt traduite par *M. CHUM-MAU* 530

— Histoire de Sam-Kok (suite) traduite par Oknha *NOU-KAN* . . . . . . 539

— L'homme au coeur changeant (suite) par *M. BOU-FO* . . . . . . 548

— Légendes de Syrie traduites de l'anglais par le bonze *MEN-RIEM*. 559

— Légende d'un jeune homme qui s'ennuit en dormant par *M. NHOUNG-SOEUNG* . . 567

### Notes et chroniques

— La fête de Namaskar Prah Sakyamuni Cettéy par *M. SDŒUNG-CHHO* . 584

Prix d'abonnement annuel (comprenant 12 numéros): 23o|oo

**ផ្នែកសាសនា**

## វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

លោក ដល-ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ព្រះមុនីកោសល ស្សូរ-ហាយ ពិនិត្យ

---

លើកមុន ខ្ញុំបានពណ៌នាយ៉ាងសង្ខេបអំពីរឿងកកើតឡើងនៃមនុស្ស ហើយខ្ញុំបានសូមអស់លោក-អ្នកថា ឲ្យរង់ចាំពិនិត្យគោលសំខាន់ក្នុងបញ្ហា មនោធាតុ ដែលបានមកជាមនុស្សហើយនេះតទៅទៀត ប៉ុន្តែ មុននឹងកយដំណើរទៅមុខនោះ ខ្ញុំបង្វែរមកពន្យល់ពីរឿងថា មនោធាតុ យ៉ាងតូច អាចក្លាយទៅជា មនោធាតុ យ៉ាងធំ សាឡើងជា ប៊ីម្ពង់ទៀត ។

តើយើងគួរជឿបានឬទេ ថា មនោធាតុ មនុស្ស រីកចេញចាក មនោធាតុ សត្វតិរច្ឆានធំៗ មនោធាតុ សត្វតិរច្ឆានធំៗ រីកចេញចាកសត្វតិរច្ឆានតូចៗ មនោធាតុ សត្វតិរច្ឆានតូច រីកចេញចាក មនោធាតុ សត្វតិរច្ឆានតូចល្អិតទៅទៀត តាមលំដាប់ហូរហែ ហើយ មនោធាតុ នៃសត្វតិរច្ឆានតូចល្អិតបំផុតនោះ ក៏រីកចេញចាករុក្ខជាតិ តិណជាតិជាដើម, ឯពួក មនោធាតុ នៃរុក្ខជាតិ តិណជាតិជាដើមនោះ ក៏រីកចេញចាកធម្មជាតិដើម គឺ ដី-ទឹក-ភ្លើង-ខ្យល់-អាកាស (អវិជ្ជា)

ដែលពួកផ្គុំប្រជុំគ្នាឡើង (សង្ខារ) ។ រឿងនេះ បើបញ្ជាក់តាមឧទាហរណ៍ ឲ្យឃើញច្បាស់គឺ អ្នកណាក៏ធ្លាប់ឃើញ ឬធ្លាប់ឮដែរថា សត្វអន្ទង់ខ្លះកើតពីដើមត្រស់, ហើយមានសត្វស្កាវខ្លះក្លាយពាកសត្វអន្ទង់, សត្វមមង់កើតចេញមកពីផ្លែល្វា, ដង្កូវទឹក កើតចេញមកពីទឹកភ្លៀងដែលធ្លាក់ពីលើអាកាស នាំយក មហាធាតុ ហើរប៉ុងលើអាកាសមកផ្សំ ឬកើតពីទឹកស្អុយដែលស្រូបយក មហាធាតុ គ្រប់ទិសមកបង្កើត, ចាបចៀបកប្បាស ក្លាយមកពីដង្កូវដែលកើតចេញពីដើមកប្បាស, ដង្កូវដូង កើតចេញមកពីដើមឈើ, កណ្ដូប កើតពីស្លឹកតៀប ឬស្លឹកឈើផ្សេងទៀតជាដើម ។ ទាំងនេះ មិនបញ្ជាក់ឲ្យឃើញថា "ដើមឈើអាចក្លាយទៅជាសត្វបាន" ឬអ្វី? ។ តាមពិត វយ៉ាងហ្នឹងឯង គឺសូម្បីក្នុងខណៈដែលដើមឈើ ឬសត្វកំពុងរស់ ក៏វាអាចក្លាយខ្លួនទៅជាអ្វីមួយផ្សេងទៀតបានដែរ មិនបាច់ចាំងាប់សិន ឬស្លាប់សិនទើបឲ្យ មហាធាតុ ហុយហើរទៅទីណាឡើយ ។ ចំពោះដើមឈើ ឬសត្វដែលស្លាប់ហើយវិញក៏វាអាចផ្សាយ មហាធាតុ របស់វាឲ្យទៅធ្វើសម្បយោគជាមួយនឹងធាតុឯទៀត បង្កើតទៅជាអ្វីមួយផ្សេងដោយកំលាំងជាងរស់នៅទៅទៀត ព្រោះឈើជាដើមដែលងាប់ វាងាប់តែដើមវាទេ ឯ មហាធាតុ របស់វាដែលផ្សំឡើងពី មហាធាតុ វាមិនរលាយក្លាយទៅវិញឡើយ គឺវានៅជាធាតុផ្សំមួយប៉ុនចេញទៅជាធម្មតា ដូចជាសម័យសព្វថ្ងៃ ដែលគេប្រើ

វត្ថុបរមាណូជាគ្រឿងយុទ្ធភណ្ឌ សូម្បីគេល្បងនៅស្រុកជើងមេឃឯណោះ សោះ ប៉ុន្តែ ជាតិបរមាណូដែលគេផ្ទុះហើយនោះ វាមិនរលាយអស់ភ្លាម ទៅក្នុងអាកាសទេ គឺវានៅជាដុំផ្សាយប៉ើងលើអាកាស ទៅបំផ្លាញផល ប្រយោជន៍ និងសុខភាពពិភពលោកបានយ៉ាងឆ្ងាយទៀត យ៉ាងណាមិញ, មូលធាតុ ដែលផ្សំគ្នាបង្កើតជា មហាធាតុ យ៉ាងនេះហើយ ក៏ មហាធាតុ នោះវាមិនរលាយទៅភ្លាមយ៉ាងនោះដែរ ។ ដូច្នេះ កាលបើ មហាធាតុនោះ ប៉ើងហើរទៅប៉ះជាប់នឹងធាតុអ្វីមួយទៀត ក៏វាចាប់ធ្វើ សំយោគជាមួយនឹងធាតុក្រោយនេះ កកើតឡើងជាអ្វីថ្មីមួយទៀត ដូចជា ប៉ើងទៅជាប់នឹងទឹកកកើតជាដង្កូវទឹក, ប៉ើងទៅជាប់នឹងដី កកើតជាដង្កូវ-ជន្លេនជាដើម ។ ប៉ុន្តែ យើងឃើញយ៉ាងជាក់ថាកាលដំបូង មូលធាតុ គឺ ដី ទឹក ភ្លើង ខ្យល់ អាកាស វាជាធាតុគ្មានជីវអ្វីបន្តិចបន្តួចទាល់តែសោះ លុះ មូលធាតុនេះ ផ្សំគ្នាកើតទៅជារុក្ខជាតិ ស្រាប់តែវាចេះគ្រាន់បើជាង មុនបន្តិច គឺចេះរស់រានមានជីវិត ចេះរុករកដីជាតិអាហារមកចិញ្ចឹមខ្លួនបាន, លុះរុក្ខជាតិនោះក្លាយទៅជាសត្វ ដូចជាអន្ទង់ ឬ ចាប ឬក៏ដង្កូវជាដើម ក៏ឃើញថា អន្ទង់ ចាប ដង្កូវ ដង្កូវទឹកជាដើមនោះ មានដំណើរចេះដឹង ជាងរុក្ខជាតិនោះទៅទៀត ។ លុះបើអន្ទង់នោះ វាក្លាយទៅជាស្ការ, ស្ការ នោះ វាក្លាយទៅជាស្វា, ស្វានោះវាក្លាយជាមនុស្សព្រៃ ហើយមនុស្ស ព្រៃនោះ វាក្លាយទៅជាមនុស្សស្រុក តើយើងមិនហ៊ានថា "មនុស្ស

ស្រុក មានដំណើរបេះដឹងជាងមនុស្សព្រៃ ៗ បេះដឹងជាងស្វា ៗ បេះដឹងជាងស្ការ ៗ បេះដឹងជាងអន្ទង់ " យ៉ាងនេះទៀតឬ ?

សូមអ្នកអានពិនិត្យឲ្យល្អិតទៅចុះ ៗ ចំពោះធាតុដែលប៉ុងទៅកើតនឹងធាតុឯទៀតនោះ ក៏ដូចគ្នា គឺវាបេះតែកែប្រែ មនោធាតុ ក្នុងការបេះដឹងតាមលំដាប់ជាតិជាហូរហែទៅដែរ ប៉ុន្តែ សូមជ្រាបថា កាលដំបូង មនោធាតុ នៃរុក្ខជាតិដែលប៉ុងហើយទៅនោះ វាប៉ុងហើយទៅជាដុំជាកង់យ៉ាងគ្រោតគ្រាតដូច្នោះមែន ព្រោះពួករុក្ខជាតិមានតែ មនោ-ធាតុ យ៉ាងទន់ល្អិត គឺវាមិនទាន់មាន ចិត្ត វិញ្ញាណ នៅឡើយទេ តែលុះ មនោធាតុ នោះ វាបេះដឹងក្លាយទៅជា ចិត្ត វិញ្ញាណ បានហើយ វាក៏ផ្លាស់របៀបចម្លងកំណើតពីមួយទៅមួយ យ៉ាងល្អិតសុខុមទៅវិញ គឺវាចម្លងដោយការប៉ុងបង្ហើរខ្យល់ បដិសន្ធិចិត្ត ឲ្យទៅផ្គួបចាប់កំណើតជាមួយនឹងសម្បយុត្តធាតុផ្សេងទៀតកកើតជារូបថ្មីឡើង, ដូចជាសត្វចាប បើស្លាប់ហើយទៅកើតជាសត្វក្អែកឬសត្វអ្វីមួយនោះ ព្រោះតែកាលពីចាបនៅរស់ជិតនឹងស្លាប់ វាបានប៉ុងបង្ហើរខ្យល់ បដិសន្ធិចិត្តផ្តោតទៅរកក្អែក ឬសត្វអ្វីមួយនោះឯង បានជាវាទៅកើតជាសត្វក្អែក ឬសត្វអ្វីមួយនោះ ៗ រួមសេចក្តីមកថា ពួករុក្ខជាតិ តិណជាតិជាដើមនេះ បានជាមានដំណើរពិសេសទាបជាងមនុស្ស-សត្វ ព្រោះពួករុក្ខជាតិជាដើមនេះ វាមិនទាន់មាន ចិត្ត វិញ្ញាណ នៅឡើយទេ វាមានត្រឹម

តែ មនោធាតុ យ៉ាងស្តួចស្តើងណាស់ទៅទៀត ចំណែកខាងសត្វ ទោះល្អិតក្តី ទោះតូចធំក្តី វាចាប់មានផ្តួចកើត ចិត្ត វិញ្ញាណ ហើយ គឺវាមានការទទួលដឹងដំណើរឈឺចាប់ក្តៅត្រជាក់ ស្រេកឃ្លាន សុខទុក្ខ ជាដើមពិតមែនហើយ ប៉ុន្តែ មិនទាន់ដឹងច្បាស់លាស់ជាមនុស្សទេ ព្រោះ មនុស្សយើង មានកម្លាំង ចិត្ត វិញ្ញាណ ចាស់ក្លាជាងពួកវាទាំងនោះ ៗ មនោធាតុ ដែលកែចំរើនចាកជាតិមួយទៅជាតិមួយ រហូតដល់ មានកម្លាំងការចេះដឹងពេញលេញ បានមកកើតជា មនោធាតុ របស់ មនុស្សដូចរៀបរាប់មកនេះ វាជាធម្មតាសម្រាប់ពិភពលោកយើង ដូច្នេះ បានជាមនុស្ស សត្វ ចេះតែមានការកើតឡើងជាច្រើនចំនួនក្នុងពិភពលោក យើងនេះជាលំដាប់ ព្រោះសភាពលោកនេះ មានការផ្តួចផ្តើមកំណើត ចាក មនោធាតុ ពីមួយទៅមួយ ដូចជាពី មូលធាតុ ទៅជាដើមឈើ វល្លិ ស្មៅ, ពីដើមឈើ វល្លិ ស្មៅ ទៅជាសត្វល្អិតល្អោច, ពីសត្វល្អិត ល្អោច ទៅជាសត្វកណ្តាល, ពីសត្វកណ្តាល ទៅជាសត្វធំ ៗ , ពីសត្វ ធំ ៗ ទៅជាមនុស្ស យ៉ាងនេះ គ្រប់វិនាទី ឥតមានចន្លោះម៉ោងឡើយ ៗ

កាលបើបានមកកើតជាមនុស្ស ដូច្នេះហើយ មនុស្សក៏ត្រូវចិញ្ចឹម ជីវិតដោយធម្មជាតិ ដូចជាបរិភោគបាយ - ទឹកជាដើម ហើយលុះដល់ មនុស្សនេះ ចាស់ជរាខ្លាំង ឬមានរោគាពាធអ្វីមួយមកញាំញីធ្វើឲ្យកម្លាំង ខ្សោយ មិនអាចរក្សាទ្រទ្រង់ (ភ្លើងធាតុ) ក្នុងខ្លួនបានហើយ មនុស្ស

នោះក៏ត្រូវទទួលមរណៈ គឺសេចក្ដីស្លាប់ទៅវិញ ។ ចុះ មនោ ចិត្ត វិញ្ញាណ របស់មនុស្សស្លាប់នោះ តើត្រូវទៅឯណា ? ឬក៏សូន្យ ?

ប្រស្នានេះ យើងអាចឃើញបានភ្លាមថា ជាបញ្ហា ដែលយើងប្រៀបធៀបនឹងដោះស្រាយហ្នឹងឯង ។ រីឯអត្ថាធិប្បាយ ដែលយើងបានធ្វើមកប៉ុណ្ណោះទៀតសោត ក៏គឺដើម្បីនឹងពាំនាំភស្តុតាងជាក់លាក់ហ្នឹងឯង ហើយផ្លូវនេះ យើងបានភ្លឺខ្លះហើយ ព្រោះអត្ថបទតាំងពីខាងដើម រហូតមកដល់ត្រឹមនេះ យើងអាចស្ដាប់យកជាគោលសង្ខេបបាន គឺ

១– អ្វីក៏ដោយ ដែលកើតមកក្នុងពិភពលោកនេះ ទោះជាមនុស្សក្ដី តិរច្ឆានក្ដី ពួករុក្ខជាតិ តិណជាតិជាដើមក្ដី សុទ្ធតែកើតចេញពាកធម្មជាតិ គោលគឺ ដី ទឹក ភ្លើង ខ្យល់ អាកាស (អវិជ្ជា) ដែលធ្វើសម្បយោគនឹងគ្នា (សង្ខារ) ទាំងអស់, មិនមែនព្រះអាទិទេពណាមកសាងឲ្យឡើយ ។

២– មនុស្ស តិរច្ឆាន នឹងរុក្ខជាតិ ដែលផ្សេងប្លែកពីគ្នា, ក៏ព្រោះតែ មនោ ចិត្ត វិញ្ញាណ មានការចេះដឹងខុសគ្នា ព្រោះមនុស្សក្ដី តិរច្ឆានក្ដី រុក្ខជាតិជាដើមក្ដី កើតរូបចេញពាកធម្មជាតិដូចគ្នាក៏ពិតមែន ប៉ុន្តែ មនោ ចិត្ត វិញ្ញាណ មានដំណើរផ្សេងគ្នា គឺពួករុក្ខជាតិជាដើមនោះ មិនទាន់មាន ចិត្ត នឹង វិញ្ញាណ នៅឡើយទេ មានត្រឹមតែ មនោធាតុ យ៉ាងស្ដួចស្ដើងដែលមិនទាន់កប់ចូលជា មនោ

ផងប៉ុណ្ណោះ, ឯសត្វតិរច្ឆាន ដើមមាន មនោ ចិត្ត វិញ្ញាណ ឡើងហើយ តែការរេះដឹងមានខ្លាំងខ្សោយជាងគ្នាតាមប្រភេទ ដូចជាសត្វឆ្មា ឆ្កែមានការរេះដឹងច្រើនជាងដទៃ - ជាខ្លួនជាដើមដូច្នោះ ប៉ុន្តែ បើទុកជាយ៉ាងណាក៏ដោយ គង់នៅតែល្ងិតល្ងង់ជាងពួកមនុស្សយ៉ាងច្រើនទៅទៀត គឺមនុស្សមានការរេះដឹងច្រើនជាងពួកសត្វតិរច្ឆានទាំងអស់ ។

៣– មនោ ចិត្ត វិញ្ញាណ របស់មនុស្សយើង មិនមែនផុតចេញចាកធម្មជាតិតែម្ដងមកបានស្រេចភ្លាមទេ គឺត្រូវកចេញចាកធម្ម-ជាតិយឺតយូរបំផុតតាមលំដាប់មក លុះត្រាតែ មនោ ចិត្ត វិញ្ញាណ មានការរេះដឹងចាស់ក្លាហើយ ទើបមកកើតជា មនោ ចិត្ត វិញ្ញាណ របស់មនុស្សបាន ។ ប្រសិនជាមនុស្សយើងមាន មនោ ចិត្ត វិញ្ញាណ ផុសឡើងថ្មីតែម្ដង ដូចជាពួករុក្ខជាតិដែរនោះ សេចក្ដីវិសេសប្លែកនៃមនុស្ស តិរច្ឆាន និងរុក្ខជាតិក៏គ្មានដែរ គឺពិតជាមនុស្ស តិរច្ឆាន រុក្ខជាតិ មានការរេះដឹងស្គាល់ប៉ុនគ្នាទៅហើយ ព្រោះសុទ្ធតែកើតចាកធម្មជាតិដូចគ្នា ។

៤– ការពង្រីង ពង្រីក មនោ ចិត្ត វិញ្ញាណ ជាការចាំបាច់នៃមនុស្ស ។ ព្រោះថា មនុស្ស បើមិនប្រឹងពង្រីង ពង្រីក មនោ ចិត្ត វិញ្ញាណ របស់ខ្លួនឲ្យនៅនឹង ឬឲ្យចំរើនឡើងទៀតទេ មនោ ចិត្ត វិញ្ញាណ របស់ខ្លួននោះ ក៏នឹងថយការរេះដឹងទៅជាល្ងិតល្ងង់ទន់ខ្សោយវិញ, កាលបើថយទៅជាល្ងិតល្ងង់វិញហើយ វាក៏មិនប្លែកអ្វីពី

សត្វតិរច្ឆានដែរ គឺបើ មនោ ចិត្ត វិញ្ញាណ របស់ខ្លួន វាដូចជាសត្វតិរច្ឆានស្រេចទៅហើយ, ក៏នឹងក្លាយខ្លួនជាសត្វតិរច្ឆានទាំងរូបប្រាណទៅវិញដោយចាប់ បដិសន្ធិ កើតក្នុងកំណើតនោះមិនខាន ។

ចុះអ្វីដែលហៅថា មនោ-ចិត្ត-វិញ្ញាណ ?

ពាក្យថា មនោក្តី ចិត្តក្តី វិញ្ញាណក្តី ទាំង ៣ ម៉ាត់នេះ ជាពាក្យហៅរបស់តែមួយប៉ុណ្ណោះ គឺជាឈ្មោះ ធម្មជាតិ ម្យ៉ាងដែលកើតចេញពី មូលធាតុ (អវិជ្ជា) សម្រាប់ទទួលដឹង-ស្គាល់ដំណើរ ទាំងវត្ថុក្នុងពិភពលោក ដូចជាខ្ញុំរាប់រៀបដោយហូរហែមកហើយ ប៉ុន្តែ គួរឲ្យឆ្ងល់ខ្លះដែរ ព្រោះថា បើជាឈ្មោះរបស់ ធម្មជាតិ តែមួយទេ ចុះហេតុអ្វី ក៏បានជាហៅឈ្មោះដល់ទៅ ៣ ម្ល៉េះ? សូមជ្រាបថា បានជាមានឈ្មោះដល់ទៅ ៣ នោះ ព្រោះលោកហៅទៅតាមដំណើររបស់វា គឺថា ធម្មជាតិ តែមួយនេះ វាមិនចេះនៅស្ងៀមទេ វាចេះតែចង់ឃើញ-ចង់ឮ - ចង់ហិតក្លិន - ចង់ដឹងរសជាតិ - ចង់ស្ទាបប៉ះ - ចង់នឹកគិតជានិច្ច ម្ល៉េះ ហើយវាចេះតែរេទៅរកអារម្មណ៍ផ្លុបចុះផ្លុបឡើងជាអប្រមាណមិនចេះឈប់ឈរសោះ ដូច្នេះ បានជា គេហៅវាថា មនោ ដោយកំណត់យកត្រង់ដំណើរ ដែលចេះតែរេចុះរេឡើង ៗ មួយទៀត វាតែងតែនឹកគិតជាធម្មតា ដូចជាយើងតែងនឹកគិតទៅនេះទៅនោះ ឬត្រិះរិះពីអារម្មណ៍អ្វីមួយនៃរូបជាដើម ដូច្នេះ បានជាគេហៅវាថា ចិត្ត ដោយកំណត់

យកដំណើរ ដែលចេះនឹកគិត ៗ ម្យ៉ាងទៀត វាតែងទទួលឃើញ ទទួលឮ - ទទួលធុំក្លិន - ទទួលដឹងរសជាតិ - ទទួលដឹងសម្ផស្សដែលប៉ះត្រូវ ទទួលដឹងគំនិតដែលគិតឃើញជាប្រក្រតី ដូចជារូប កាលណាភ្នែកយើងមើលទៅចំ ក៏យើងឃើញភ្លាម តើឃើញដោយសារអ្វី? គឺឃើញដោយសារធម្មជាតិ មួយហ្នឹងឯង, ប្រសិនជាគ្មាន ធម្មជាតិ មួយនេះជាអ្នកទទួលឃើញទេ ទុកជារូបនោះដល់នឹងភ្នែក ក៏ភ្នែកនោះមិនអាចមើលឃើញបាន (រូបំ ចក្ខុ ច បស្សតិ អចិត្តកតា ចិត្តម្បិ ច បស្សតិ អចក្ខុកតា) ដូចជារូបតុក្កតាដែលគេធ្លាក់ឲ្យមានភ្នែក ត្រចៀក ប្រមុះ ដូច្នោះ មកពីវាគ្មានធម្មជាតិមួយនេះនៅក្នុងខ្លួនវា បានជាវាមិនចេះឃើញ មិនចេះឮ មិនចេះដឹងអ្វីទាំងអស់ ដូច្នេះ បានជាគេហៅវាថា វិញ្ញាណ ដោយកំណត់យកត្រង់ដំណើរ ដែលឃើញ - ឮ - ដឹងក្លិន - ដឹងរស - ដឹងសម្ផស្ស - ដឹងគំនិតហ្នឹងឯង ៗ រួមសេចក្ដីមកថា ធម្មជាតិ មួយបែបនេះ វាចេះតែទៅរកអារម្មណ៍ផង ចេះត្រិះរិះគិតនូវអារម្មណ៍ផង ចេះដឹង - ស្គាល់នូវអារម្មណ៍ផង ព្រោះហេតុនោះ ទើបលោកឲ្យឈ្មោះវាថា មនោ ផង ចិត្ត ផង វិញ្ញាណ ផង ៗ ដោយដំណើរនេះ យើងយល់បានថា មនោ ចិត្ត វិញ្ញាណ ជាធម្មជាតតែមួយទេ ប៉ុន្តែមានឈ្មោះដល់ទៅ ៣ តាមដំណើររបស់វា ៗ ការហៅឈ្មោះជា ៣ យ៉ាងបែបនេះ បើប្រៀបធៀប ដូចជាមនុស្សម្នាក់ធ្វើស្រែផង ធ្វើជំនួញ

ផង ធ្វើជាងផង ។ ពិតមែនតែតួរូបមនុស្សម្នាក់ កំប៉ុន្តែ គេនឹងហៅមនុស្សនោះថា កសិករ ក៏បាន, ថា ពាណិជ្ជករ ក៏បាន, ថាសិល្បករ ក៏បាន យ៉ាងណាមិញ, ធម្មជាតិតែមួយ មានឈ្មោះដល់ទៅ ៣ យ៉ាងក៏យ៉ាងនោះដែរ ។

ពួកមនុស្ស មានការប្លែកពីសត្វតិរច្ឆាន នឹងពួករុក្ខជាតិជាដើម ព្រោះពួកមនុស្ស មានរូបកាយផង មាន មនោ ចិត្ត វិញ្ញាណ យ៉ាងពេញលេញផង ។ រូបកាយ ប្រសិនជា មនោ ចិត្ត វិញ្ញាណ នេះ រលត់ចេញផុតហើយ ក៏វាមិនខុសអ្វីពីគល់ឈើដែរ ព្រោះវានៅស្ងួកស្ងឹង មិនចេះកំរើក មិនចេះដឹងស្គាល់អ្វីទាំងអស់ដូចគ្នាសុទ្ធសាធ ។ ដូច្នេះ រូបកាយ វាគ្រាន់តែជាផ្ទះលំនៅរបស់ មនោ ចិត្ត វិញ្ញាណ ប៉ុណ្ណោះ គ្មានចេះដឹងស្គាល់អ្វីឡើយ ។ ឯ មនោ ចិត្ត វិញ្ញាណ វិញ ពិតមែនតែមាននាទីទទួលចេះដឹងស្គាល់បានគ្រប់យ៉ាង ប៉ុន្តែ បើគ្មានផ្ទះលំនៅ គឺរូបកាយនេះនៅអាស្រ័យទេ ក៏វាមិនអាចសម្រេចកិច្ចការគ្រប់យ៉ាងបានដែរ ។ ហេតុនេះ របស់ទាំងពីរត្រូវពឹងអាស្រ័យនូវគ្នានឹងគ្នា ទើបមនុស្សយើងប្រព្រឹត្តទៅបានដូចសព្វថ្ងៃ ។

ឯសត្វតិរច្ឆាន បើនិយាយឲ្យឃើញច្បាស់ ថាវាមានដំណើរដូចមនុស្សសុទ្ធសាធ គឺវាកើតចេញពាកធម្មជាតិដូចគ្នា រស់នៅដោយអាហារដូចគ្នា មាន មនោ ចិត្ត វិញ្ញាណ ដូចគ្នា មាន កាម កិលេស

តណ្ហា ឧបាទាន ជាដើមដូចគ្នា ប៉ុន្តែ វាមានចំណុចប្លែកខ្លះគឺត្រង់មានការចេះដឹងទន់ខ្សោយជាងពួកមនុស្សច្រើនណាស់ ៗ សត្វធំ ៗ ដូចជាដំរី ស្វា ផ្គែជាដើម ឃើញថា វាមានដំណើរចេះដឹងគ្រាន់បើក្បែរៗនឹងមនុស្សដែរ បំណែកសត្វល្អិតល្អោច ដូចជាដង្កូវ ជន្លេនជាដើមវិញ ឃើញថា វានៅល្ងិតល្ងង់ឆ្ងាយពីមនុស្សខ្លាំងណាស់ ស្ទើរតែឲ្យឈ្មោះថា "គ្មានដឹងអ្វី" ក៏បាន ៗ យ៉ាងនេះហើយ បានជាលោកពន្យល់ថា:

អាហារនិទ្រា ភយមេថុនំ ច
សាមញ្ញមេតំ បសុភិនរានំ !
ធម្មោ ហិ តេសំ អធិកោ វិសេសោ
ធម្មេន ហីនះ បសុភិនរានះ !!

មនុស្សនឹងតិរច្ឆាន ឥតខុសគ្នា ព្រោះចេះនិទ្រា ចេះភ័យភិត
ចេះរួមសេសេព មេថុនសិទ្ធ ចេះស៊ីលេបលិទ្ធ គ្រប់អាត្មា ៗ
មានតែព្រះធម៌ ដ៏វិសេស ចែកសត្វទាំងនេះ ឲ្យប្លែកគ្នា
ប្រសិនសត្វណា ប្រាសធម្មា នោះពិតឈ្មោះថា ឆាតែកប្ប ៗ

ព្រះធម៌ក្នុងទីនេះ សំដៅការចេះដឹងល្អអាក្រក់ បុណ្យ បាប ពិត មិនពិត ឬហេតុផល ជាដើមហ្នឹងឯង ៗ ព្រះធម៌ នេះ ជាសភាពទាក់ទងនឹង មនោ ចិត្ត វិញ្ញាណ គឺថា បើ មនោ ចិត្ត វិញ្ញាណ នេះ មានការចេះដឹង ស្គាល់ខ្មៅ ស ល្អ អាក្រក់ បាប បុណ្យ គុណ

ទោស ហេតុផលជាដើមច្រើន, មនោ ចិត្ត វិញ្ញាណ នោះ លោកហៅថា មានធម៌, បើ មនោ ចិត្ត វិញ្ញាណ នេះនៅទន់ខ្សោយការចេះដឹង បាប បុណ្យ គុណ ទោស ហេតុ ផលជាដើមនេះ, មនោ ចិត្ត វិញ្ញាណ នោះ លោកហៅថា គ្មានធម៌ ទៅវិញ ។

ពួកមនុស្ស ជាសត្វមាន ធម៌ ព្រោះមាន មនោ ចិត្ត វិញ្ញាណ មានការចេះដឹងច្រើន ។ ឯពួកតិរច្ឆាន ជាសត្វ គ្មាន ធម៌ ព្រោះវាខ្សោយការចេះដឹងណាស់ ។ ដូច្នេះ ឃើញថា ពួកមនុស្ស នឹងពួកសត្វតិរច្ឆាន មានការប្លែកគ្នាត្រង់ ព្រះធម៌ គឺសេចក្ដីចេះដឹងហ្នឹងឯង ។

ចំណែកខាងពួករុក្ខជាតិជាដើមវិញ ជាធម្មជាតិឥតមាន មនោ ចិត្ត វិញ្ញាណ អ្វីទេ មានតែ មនោធាតុ យ៉ាងល្អិតក្រៃលែងបន្តិចបន្តួចដូចខ្ញុំពណ៌នារួចហើយប៉ុណ្ណោះ ។ ហេតុនោះ បានជាពួករុក្ខជាតិជាដើមនេះវាមិនចេះទទួលការឈឺ-ចាប់ មិនចេះទទួលកំដៅ-ត្រជាក់ជាដើមឡើយ ទោះជាគេយកកាំបិត ពូថៅទៅកាប់ចាំង ឬយកភ្លើងទៅដុតពេលយ៉ាងណាក៏ដោយ ។ វារស់នៅមានត្រឹមតែជីវិតដោយសន្តតិប៉ុណ្ណោះ វាគ្មានការកសាងល្អ-អាក្រក់ ឬបុណ្យ-បាប ដូចជាមនុស្ស នឹងសត្វតិរច្ឆានទេ ព្រោះវាគ្មាន ចិត្ត នឹងគិតត្រិះរិះ, គ្មាន វិញ្ញាណ នឹងដឹងញ្ញអ្វីឡើយ ។

ការប្លែកគ្នានៃពួកមនុស្ស, សត្វតិរច្ឆាន នឹងរុក្ខជាតិជាដើមនេះ លោកបានចែកយ៉ាងច្បាស់លាស់ជា ២ ចំណែក គឺជា ឧបាទិន្នកសង្ខារ ១

ជា អនុបាទិន្នកសង្ខារ ១ ។ ពួកមនុស្ស និងតិរច្ឆាន ជាឧបា-
ទិន្នកសង្ខារ, ឯពួករុក្ខជាតិជាដើម ជា អនុបាទិន្នកសង្ខារ ។
បានសេចក្តីថា ពួកមនុស្ស និងតិរច្ឆាន ព្រមទាំងពួករុក្ខជាតិជាដើម
លោកឲ្យឈ្មោះថា ជា សង្ខារ ទាំងអស់ ព្រោះវាទាំងនេះ ត្រូវ
មូលធាតុ គឺ ដី ទឹក ភ្លើង ខ្យល់ អាកាស (អវិជ្ជា) ធ្វើ
សំយោគគ្នា (សង្ខារ) បង្កបង្កើតឡើង ។ ពួកមនុស្ស និងពួកតិ-
រច្ឆាន បានជាលោកហៅថា ជា ឧបាទិន្នកសង្ខារ ព្រោះវាទាំង
នេះ មាន ចិត្ត វិញ្ញាណ នៅអាស្រ័យក្នុងរូបប្រាណ, ឯពួក
រុក្ខជាតិជាដើមវិញ វាគ្មាន ចិត្ត វិញ្ញាណ នៅអាស្រ័យក្នុងរូបរបស់
វាទេ ទើបលោកឲ្យឈ្មោះថា ជា អនុបាទិន្នកសង្ខារ ។

ការពណ៌នាមកប៉ុណ្ណោះ ហាក់ដូចជាបញ្ជាក់សេចក្តីដដែល ៗ ក៏
ប៉ុន្តែ ខ្ញុំយល់ថា អស់លោក-អ្នកអាន ប្រហែលជាបានទទួលលទ្ធផល
គឺការយល់យ៉ាងច្បាស់លាស់ក្នុងរឿងនេះមិនខាន ។

ហេតុនេះ បើយល់ច្បាស់ហើយ យើងត្រូវដោះស្រាយបញ្ហាមនុស្ស
កើត-ស្លាប់ តាមពាក្យចោទ-ឆ្លើយ ដូចតទៅខាងក្រោមនេះ៖

(នៅមានត)

## ពុទ្ធជីវប្រវត្តិ

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

(តមក)

# សង្ខេបនិទានធម្មបក្កបឋាទី ១១

១- ទ្រង់ប្រោសបញ្ចវគ្គិយ ២- ទ្រង់ប្រទានព្រះបឋមទេសនា ៣- ទ្រង់ប្រទានធម្មចក្រនៅឥសិបតនមិគទាយវ័ន ៤- អវសានបឋមទេសនា ៥- សេចក្ដីអស្ចារ្យក្នុងពេលប្រទានធម្មចក្រ ៦- កោណ្ឌញ្ញបព្វជ្ជា ៧. ព្រះអរហន្ត ៦ អង្គមុនបង្អស់ក្នុងលោក ។

## ១- ទ្រង់ប្រោសបញ្ចវគ្គិយ

ព្រះបរមសាស្ដាស្ដេចពុទ្ធដំណើរទៅកាន់ចារិក តាមលំដាប់ ហើយចូលទៅកាន់ក្រុងពារាណសី ស្ដេចដល់ហើយ សំដៅឆ្ពោះព្រះភ័ក្ត្រទៅឥសិបតនមិគទាយវ័នជាទីឋានដែលបញ្ចវគ្គិយអាស្រ័យនៅ ៗ បញ្ចវគ្គិយបានឃើញព្រះអង្គពីចម្ងាយហើយ ប្រជុំគ្នាថា សមណគោតមនេះប្រតិបត្តិដើម្បីលោក ឃ្លាតចាកព្យាយាមស្រឡះហើយ វិលត្រឡប់មកដើម្បីភាពជាអ្នកលោកវិញហើយ ឥឡូវលោកនិមន្តមកដល់ យើងទាំងអស់គ្នាមិនគួរថ្វាយបង្គំទេ មិនគួរក្រោកទទួលទេ មិនគួរទទួលបាត្រចីវរលោកទេ យើងគ្រាន់តែក្រាលអាសនៈខ្លះទុកបម្រុង បើលោកត្រូវការ ក៏គង់ចុះ ៗ បញ្ចវគ្គិយទាំងនោះ លុះព្រះពិជិតមារស្ដេចមកដល់ហើយ ក៏ភ្លេចពាក្យប្រជុំរបស់ខ្លួនអស់ បែរជាក្រោកឡើងស្ទុះស្ទាទៅទទួល ខ្លះ

*ទទួលបាត្រចីវរ ខ្លះក្រាលអាសនៈ ខ្លះយកទឹកលាងព្រះបាទ; ហើយហៅព្រះអង្គចំឈ្មោះព្រះអង្គថា គោតម ផង ថា អាវុសោ ផង ដូចព្រះតម្រាស់ដែលត្រាស់ចំពោះពោធិរាជកុមារ ថា*(១)

ម្នាលរាជកុមារ! បញ្ចវគ្គិយតាបស ហៅតថាគតយ៉ាងនេះហើយ តថាគតពោលតបទៅវិញថា ម្នាលអ្នកទាំងឡាយ! អ្នករាល់គ្នាកុំហៅតថាគតចំឈ្មោះ កុំហៅតថាគត "អាវុសោ" ដូច្នេះទៀត តថាគតជាអរហន្តសម្មាសម្ពុទ្ធ ហើយអ្នកទាំងឡាយប្រុងសោតប្រសាទចុះ តថាគតនឹងប្រៀនប្រដៅអមតធម៌ដែលតថាគត ត្រាស់ដឹងហើយ ដល់អ្នកទាំងឡាយ ដើម្បីប្រយោជន៍អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិតាមពាក្យប្រៀនប្រដៅតថាគតហើយ ពុំយូរឡើយមុខជានឹងបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ចំពោះអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។

ម្នាលរាជកុមារ! កាលតថាគត ពោលយ៉ាងនេះហើយ បញ្ចវគ្គិយតាបស ក៏ពោលពាក្យនឹងតថាគតដូចមុនជាគម្រប់

---

១ - ពោធិរាជកុមារសូត្រ ម.ម. សៀវភៅ ២៥ ទំព័រ ៤០២ ( មហាវិគ្គបឋមភាគ មបក១ទ្ទក: សៀវភៅ ៦ ទំព័រ ២៥ ) ។

ទី ២ គម្រប់ទី ៣ ផង ។ កាលបញ្ចវគ្គិយតាបស ពោលពាក្យយ៉ាងនេះហើយ តថាគត ក៏ពោលពាក្យតបទៅវិញទៀតថា ម្នាលអ្នកទាំងឡាយ! អ្នកទាំងឡាយចាំបានដែរឬទេ? ពាក្យមានសភាពយ៉ាងនេះ ជាពាក្យដែលតថាគតធ្លាប់បានពោលមកពីមុនដែរឬទេ? បញ្ចវគ្គិយតាបស ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន! ពាក្យហ្នឹងព្រះអង្គមិនដែលបានពោលទេ ។

ម្នាលរាជកុមារ! តថាគតញ៉ាំងបញ្ចវគ្គិយតាបសឲ្យយល់ច្បាស់ក្នុងពេលនោះបាន ។ តថាគតបានប្រៀនប្រដៅតាបស ២ រូប តាបស ៣ រូបនាំគ្នាទៅបិណ្ឌបាត្រ បានអាហារល្មមយើង ៦ នាក់ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។

ម្នាលរាជកុមារ! បញ្ចវគ្គិយតាបស កាលបើតថាគតទូន្មានហើយ ប្រៀនប្រដៅហើយ កុលបុត្រទាំងឡាយចេញចាកផ្ទះបួសទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ពុំយូរឡើយ ក៏បានត្រាស់ដឹងដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ បាន ។

## ២- ទ្រង់ប្រទានព្រះបឋមទេសនា

*លុះគ្រាជាខាងក្រោយ បញ្ចវគ្គិយតាបស តាំងចិត្តស្តាប់ព្រះមានព្រះភាគ ផ្ទៀងនូវសោតប្រសាទ ហើយផ្ចង់ចិត្តដើម្បីស្តាប់នូវព្រះពុទ្ធដីកា ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា (១)*

ម្នាលភិក្ខុទាំងឡាយ ធម៌អមខាងទាំងពីរប្រការនេះបព្វជិតមិនគួរសេពគប់ទេ គឺ

១- កាមសុខល្លិកានុយោគ ការប្រកបរឿយៗ នូវសេចក្តីជាប់ជំពាក់ដោយកាមសុខទាំងឡាយណា ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ។

២- អត្តកិលមថានុយោគ ការប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក តែងនាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់អរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ ។

ម្នាលភិក្ខុទាំងឡាយ! មជ្ឈិមាបដិបទា គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល មិនប៉ះពាល់នឹងធម៌អមខាងទាំងពីរនោះ គឺជា-

---

១- មហាវគ្គ បឋមភាគ មហាខន្ធកៈសៀវ. ៦ ទំព័រ ៩៨ ។

គតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ គឺធ្វើឲ្យកើតសេចក្តីចេះដឹង ប្រព្រឹត្តទៅ ដើម្បីសេចក្តីរម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយ-សច្ច ដើម្បីនិព្វាន ។

### ៣– ទ្រង់ប្រកាសធម្មចក្រនៅឥសិបតនមិគទាយវ័ន

*ព្រះមានព្រះភាគប្រកាសធម្មចក្រ ដែលឥតមាននរណាមួយធ្វើបដិ-វត្តឡើយ ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះបញ្ចវគ្គិយភិក្ខុទាំងឡាយថា*(១)

ម្នាលភិក្ខុទាំងឡាយ៖ ធម្មចក្រដ៏ប្រសើរ ដែលតថាគតអរហន្តសម្មាសម្ពុទ្ធ ឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ័នជិតក្រុងពារាណសី ជាធម្មចក្រដែលសមណៈក្តី ព្រាហ្មណ៍ក្តីទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តី ក្នុងលោកឲ្យបដិវត្តទៅមិនបាន គឺការប្រាប់ ការសំដែង ការបញ្ញត្តិ ការតែងតាំង ការបើក ការចែក និងការធ្វើឲ្យងាយយល់នូវអរិយសច្ចទាំង ៤, អរិយសច្ចទាំង ៤ នោះតើដូចម្តេច?

ការប្រាប់ ការសំដែង ការបញ្ញត្តិ ការតែងតាំង ការ

---

១ សច្ចវិភង្គសូត្រ វិភង្គវគ្គ ម.ឧ. សៀ. ២៣ ទំ. ៤០០ ។

បើក ការបែកនឹងការធ្វើឲ្យងាយនូវអរិយសច្ច ១ នូវទុក្ខសមុទយអរិយសច្ច ១ នូវទុក្ខនិរោធអរិយសច្ច ១ នូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

## ៤ - អវិសានបឋមទេសនា

*កាលចប់ព្រះបឋមទេសនា ព្រះកោណ្ឌញ្ញត្ថេរចាស់ជាងគេ បានត្រាស់ដឹងអនុត្តរធម៌មុន ដូចព្រះពុទ្ធដីកាដែលត្រាស់ចំពោះកោណ្ឌញ្ញត្ថេរថា:(១)*

អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អើហ្ន៎! កោណ្ឌញ្ញបានត្រាស់ដឹងពិតហើយ អើហ្ន៎! កោណ្ឌញ្ញបានត្រាស់ដឹងហើយ ។

*អាស្រ័យហេតុនេះហើយ បានជាព្រះកោណ្ឌញ្ញត្ថេរ បាននាមប្រាកដថា អញ្ញាកោណ្ឌញ្ញ តាំងពីកាលនោះមក ។*

## ៥- សេចក្ដីអស្ចារ្យក្នុងពេលប្រកាសធម្មចក្រ

ព្រហ្មទាំងឡាយក៏បន្លឺនូវសូរស័ព្ទថា(២) ព្រះធម្មចក្រនេះ មិនមានចក្រដទៃក្រៃលែងជាងទេ ទោះបីសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី ជនណាមួយក្ដីក្នុងលោក មិនអាចបដិវត្តបានឡើយ គឺឲ្យព្រះមានព្រះភាគ ទ្រង់បាន

---

១- មហាវគ្គ បឋមភាគ មហាខន្ធកៈ សៀ. ៦ ទំព័រ ៣៦ ។ ២ មហាវគ្គ បឋមភាគ មហាខន្ធកៈ សៀ. ៦ ទំព័រ ៣៦ ។

បវត្តិបានហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពា. រាណសី ។ សំឡេងក៏លាន់ឮឡើងជាជរាបដល់ព្រហ្មលោក ក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយប្រការដូច្នេះ ។ រីឯលោកធាតុទាំងមូលមុន ក៏កក្រើករំភើបញាប់ញ័រ ទាំងពន្លឺភ្លឺធំទូលាយប្រមាណមិនបាន កន្លងលើសអានុភាពនៃទេវតាទាំងឡាយ កើតប្រាកដឡើងក្នុងលោក ។

### ៦- កោណ្ឌញ្ញទទួលបព្វជ្ជា

*កាលព្រះកោណ្ឌញ្ញបានឃើញព្រះអរិយសច្ចធម៌ហើយ ទើបក្រាបទូលព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស! ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា*

"ឯហិ ភិក្ខុ អ្នកចូរមកជាភិក្ខុចុះ! ហើយមានព្រះពុទ្ធដីកាថា សាសនធម៌ តថាគតបានពោលល្អហើយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃកងទុក្ខដោយប្រពៃចុះ" ។

*ព្រះពុទ្ធដីកានេះឯងជាឧបសម្បទារបស់អញ្ញាកោណ្ឌញ្ញត្ថេរនោះ ។ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរនេះជាបព្វជិតទី ១ មុនដំបូងក្នុងព្រះពុទ្ធសាសនា ។*

លំដាប់តទៅ ព្រះមានព្រះភាគ ទ្រង់ពោលទូន្មានប្រដៅតាបសដ៏សេស ក្រៅពីអញ្ញាកោណ្ឌញ្ញដោយធម្មីកថា ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិល កើតដល់ព្រះវប្បៈនិងព្រះភទ្ទិយៈ ។ តាបសទាំងពីររូបនេះសូមបព្វជ្ជាទៀត ។ តទៅមហានាមនិងអស្សជិ បានធម្មចក្ខុទៀត ហើយសូមបព្វជ្ជា ។

## ៣- ព្រះអរហន្ត ៦ អង្គមុនបង្អស់ក្នុងលោក

កាលព្រះមានព្រះភាគត្រាស់ទេសនា អនត្តលក្ខណសូត្រចប់ហើយ បញ្ចវគ្គិយភិក្ខុទាំងឡាយ បានសម្រេចអរហត្តផល ជាព្រះអរហន្តក្នុងលោក ដូចសេចក្ដីដែលទ្រង់ត្រាស់ទុកថា (១)

ព្រះមានព្រះភាគបានសំដែងអនត្តលក្ខណសូត្របប់ហើយ បញ្ចវគ្គិយភិក្ខុទាំងឡាយ មានចិត្តរីករាយបំពោះភាសិតនៃព្រះមានព្រះភាគ កាលដែលព្រះមានព្រះភាគកំពុងត្រាស់សំដែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង ៥ បានរួចស្រឡះហើយចាកអាសវៈទាំងឡាយព្រោះមិនប្រកាន់មាំហឹអញ ហឹយើងឡើយ ។

ក្នុងសម័យនោះឯងមានព្រះអរហន្ត ៦ អង្គ នៅក្នុងលោកជាដំបូង (រាប់ទាំងអង្គព្រះមានព្រះភាគផង ) ។

---

១ មហាវគ្គ បឋមភាគ មហាខន្ធកៈ លេ. ៦ ទំព័រ ៤៣ ។

(នៅមានត)

ព្រះអភិធម្មបិដក

# គម្ពីរព្រះយមក

លោកប៊ូ - ប៊ូ ប្រែរៀបរៀង

(តមក)

វត្ថទោ វណ្ណទោ អ្នកឲ្យសំពត់ជាទាន ឈ្មោះថាឲ្យនូវវណ្ណពណ៌សម្បុរស្បែកជាទាន ព្រោះមនុស្សបានស្លៀកដណ្ដប់សំពត់ហើយ ទើបមានពណ៌សម្បុរស្រស់ថ្លាល្អ ។

ទីបទោ ចក្ខុទោ អ្នកបានឲ្យប្រទីបអគ្គី ឈ្មោះថាឲ្យចក្ខុជាទាន កើតក្នុងអនាគតកាលនឹងមានចក្ខុជាទិព្វ មានចក្ខុបរិសុទ្ធស្អាត ប្រាសចាកងងឹតអន្ធការ ។ សេចក្ដីនេះ សម្ដេចព្រះបរមទសពលប្រ-ទានព្រះសទ្ធម្មទេសនាទុកក្នុងសុត្តន្តបរិយាយថា បុគ្គលអ្នកបំពេញទាននឹងប្រាសចាករោគទុក្ខភ័យ នឹងភ័យទាំងពួង ព្រោះហេតុទាននោះ បុគ្គលអ្នកលះបង់បាយនឹងភោជនាហារដែលខ្លួនបរិភោគ នឹងសំពត់អាវស្លៀកបំពាក់ឲ្យទៅអ្នកដទៃ ឲ្យបានសះជារោគគឺ ឃ្លានបាយ ស្រេកទឹក ។ ការឃ្លានបាយស្រេកទឹកនេះ ជារោគយ៉ាងធ្ងន់ក្រៃលែង សមតាមព្រះពុទ្ធដីកាថា ជិឃច្ឆា បរមា រោគា រោគគឺឃ្លានបាយ ស្រេកទឹក ជារោគធ្ងន់លើសរោគទាំងពួង ព្រោះថារោគឯទៀត រោគខ្លះមើលឆាប់ជា រោគខ្លះមើលយូរក្រជា ដូចជាឈឺក្អកដាក់ថ្នាំមិនជា ទាល់តែ

បែកកែកក្រែកខ្ទាក់ទៅ ចិត្តអ្នកខ្ទាក់កែកនោះ ក៏ឥតអាល័យស្តាយដែរ ព្រោះបានថែរក្សាអស់ចិត្តអស់ថ្លើមហើយ ។ មិនជា រោគបែបនេះ មិនបាត់ជាធូរទេ ។ ឯរោគឃ្លានបាយស្រេកទឹក បាត់ជាធូរបំផុត ព្រោះត្រូវរកថ្នាំគឺបាយទឹករក្សាគ្រប់ពេលវេលា សូម្បីខ្លួនជាគ្មានជម្ងឺសោះ ក៏ត្រូវតែដាក់ថ្នាំថែរក្សារោគឃ្លានបាយស្រេកទឹកជានិច្ចទៅ នឹងឈប់ខានមិនបានឡើយ តែខានស៊ីខានផឹកហើយ មុខជាស្លាប់ដោយរោគស្រេកឃ្លាននោះឯង ហេតុនោះ សម្តេចព្រះបរមគ្រូត្រាស់ថា រោគស្រេកឃ្លាននេះជារោគធ្ងន់យ៉ាងក្រៃលែង គ្មានរោគឯណាធ្ងន់ស្មើឡើយ ។

អ្នកថែរក្សាជម្ងឺឈឺចាប់ឲ្យសះជា ព្រោះតែបានឲ្យមានភោជនាហារ ។ អ្នកថែរក្សាវិញរោគដែលកើតក្នុងខ្លួនឲ្យសះជា ព្រោះតែបានឲ្យមានភេ-សជ្ជៈនិងអដ្ឋបាន នឹងអាចញុំាងរូបកាយឲ្យគ្មានរោគ ។ អ្នកបរិភោគមានលះកាត់សេចក្តីកំណាញ់ស្តាយ ក៏អាស្រ័យតែចិត្តមិនលោភ បើចិត្តឥតលោភហើយ ក៏រេះតែគិតឲ្យមានជានិច្ច ។ ឯអលោភចេតសិកនេះ បើកើតមានហើយ ប៉ុន្តែ មិនទាន់ចាស់ក្លា គ្រាន់តែគិតថាឲ្យៗ ប៉ុណ្ណោះ បើមិនបានឲ្យទេ ក៏គ្រាន់តែជួយធ្វើអនុមោទនាទានរបស់អ្នកដទៃ បើអលោភៈកើតចាស់ក្លាបន្តិច ក៏ហ៊ានឲ្យរបស់ដែលខ្លួនស្រឡាញ់បាន លុះអលោភៈកើតចាស់ក្លាខ្លាំងហើយ ក៏ហ៊ានឲ្យរបស់ដែលតែតែល្អប្រសើរលើសលុបទៅទៀត ។ បើរេះតែឲ្យ ទាល់តែអស់ទ្រព្យសម្បត្តិលើង

ពីខ្លួនហើយ ហ៊ានលក់បញ្ចាំរូបកាយខ្លួនឲ្យគេ យកប្រាក់កាសមក
បំពេញទានទៀត ដូចជាមហាតិស្សឧបាសក យកកូនស្រីរបស់ខ្លួនទៅ
លក់បញ្ចាំឲ្យគេបានប្រាក់ ១២ រៀល យកមកធ្វើសង្ឃទានថ្វាយព្រះភិក្ខុ
សង្ឃ ហើយខ្លួនឯងទៅស៊ីឈ្នួលគេ បានប្រាក់ត្រឡប់មកផ្ទះវិញ ប្រុង
នឹងលោះកូនស្រីឲ្យរួចជាអ្នកជា ដើរមកជួបនឹងព្រះមហាថេរកណ្ដាលផ្លូវ
ដឹងថាលោកខ្វះខាតចង្ហាន់ ក៏ទិញចង្ហាន់ប្រគេនលោក ទាល់តែអស់ប្រាក់
រលីងខានទៅលោះកូនស្រី នេះមកពីមហាតិស្សឧបាសកមានអលោភ-
ចេតសិកដ៏ខ្លាំងក្លាក្នុងសន្ដាន ។

ចំណែកកិរិយានឹងធីតារបស់ឧបាសក បានដឹងរឿងនោះ ក៏មាន
ចិត្តសោមនស្សជ្រះថ្លា ទទួលអនុមោទនាការកុសល ខាងក្រោយមក
ព្រះមហាក្សត្រទៅប្រទេសនោះ ទ្រង់បានជ្រាបប្រព្រឹត្តិហេតុកុសលរបស់
មហាតិស្សឧបាសក ទើបទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទ្រព្យធនជា
ច្រើនដល់ឧបាសកនោះ ក្នុងបច្ចុប្បន្នទាន់ភ្នែកឃើញ ។ ឧបាសកបំពេញ
ទានយ៉ាងនេះបាន ក៏អាស្រ័យតែអលោភៈ គឺចិត្តឥតលោភកើតខ្លាំង
ក្លាក្នុងសន្ដាន ។

ចំណែកខាងមហាឧបាសិកាវិញ បានដល់ព្រះឧប្បលវណ្ណាថេរី
កាលដើមដំបូងនៅកំពុងអន្ទោលទៅមកក្នុងសង្សារវដ្ដ បានស៊ីឈ្នួលគេ
ចំនួនបីឆ្នាំ បានសំពត់ពណ៌មួយផ្ទត់មក ហែកមួយកំណាត់ប្រគេនភិក្ខុ

មួយរូប ដែលចោរលួចយកស្បង់ចីពរអស់ទៅ លោកស្លៀកស្លឹកឈើ, ខាងក្រោយ នាងឃើញលោកស្លៀកសំពត់ដែលខ្លួនប្រគេននោះសមរម្យ ក៏កើតចិត្តជ្រះថ្លាខ្លាំង យកសំពត់ដែលខ្លួនហែកមួយកំណាត់ទុកប្រើនោះ ទៅប្រគេនលោកទៀត លុះនាងលះបញ្ចក្ខន្ធ បានទៅកើតក្នុងឋានសួគ៌ ច្យុតពីឋានសួគ៌ ចុះមកកើតជានាងឧម្មាទន្តី ។ នាងនេះបើប្រុសណា ឃើញ ប្រុសនោះទៅជាវង្វេងស្មារតីក្នុងលីលាលែងដឹងខុសត្រូវ ព្រោះតែស្រឡាញ់នាងខ្លាំងហួស លុះដល់ព្រះពុទ្ធសាសនានៃព្រះពុទ្ធជាម្ចាស់យើងនេះ នាងបានមកកើតជានាងឧប្បលវណ្ណាថេរី អាស្រ័យអលោភៈមានក្នុងសន្តាន ហេតុនោះ អលោភៈទើបរាប់បញ្ចូលក្នុងមូលនៃកុសលក្នុងមូលយមកនេះ ។

## អទោសោ

អលោភានន្តរំ អទោសោតិ ឯត្ថ អត្តនោ វា បរេសំ វា ន ទុស្សតីតិ អទោសោ, អថវា បរសន្តោ បរត្តោតិ អទោសោ, ន ទោសោ អទោសោតិ វុច្ចតិ សោ កុសលមូលន្តិ វេទិតព្វោ សោ កុសលស្ស បតិដ្ឋានំ មូលន្តិ កុសលមូលន្តិ ។

លំដាប់នេះ ពណ៌នាក្នុងមូលកុសលដែលសម្តេចព្រះបរមទសពល ត្រាស់សំដែងអទោសោ លំដាប់ពីអលោភោតទៅ មានបទវិគ្រោះដែល

ព្រះអដ្ឋកថាចារ្យពោលទុកថា ឧ ទុស្សតិ សភាវៈឯណាមិនបានប្រទូសព័យនឹងបុគ្គលទាំងឡាយដទៃ សភាវៈនោះឯងឈ្មោះថា អទោសោ ។

ន័យមួយទៀត គំនិតដែលមិនគិតប្រទូសព័យទ្រព្យរបស់ខ្លួននឹងទ្រព្យរបស់អ្នកដទៃ ឈ្មោះថា អទោសោ ។ នោះ មានអត្ថាធិប្បាយថា ចិត្តមិនក្រោធ ឈ្មោះថា អទោសោ ។ នោះជាមូល, ជាទីតាំង, ជាឫសគល់, ជាដើមបមនៃកុសលធម៌ទាំងពួង ។

អទោសោ នេះ មានក្នុងសន្តានចិត្តអ្នកណា ជាហេតុនឹងឲ្យអ្នកនោះរក្សាសីលបានបរិសុទ្ធល្អ សមនឹងព្រះពុទ្ធភាសិតថា អទោសោ សីលហេតុ អទោសោនេះ ជាហេតុនឹងឲ្យរក្សាបានខ្ជាប់ខ្ជួនបរិសុទ្ធ ។ កាលបើរក្សាសីលបរិសុទ្ធហើយ ជាហេតុនឹងញ៉ាំងខ្លួនឲ្យចំរើនក្នុងជាតិនេះ នឹងជាតិមុខ ហេតុនោះ បានជាថាអទោសោជាមូលនៃកុសល ។ ឯមនុស្សជាបុថុជ្ជនតែងមានទោសោដូចគ្នាទាំងអស់ តែខ្លះម្នាក់នោះ មានតែអ្នកប្រាជ្ញបណ្ឌិតជាតិប្រកបដោយប្រាជ្ញាល្អ សូម្បីមានទោសោកើតក្នុងចិត្តលោកហើយ លោកខំសង្កត់សង្កិនបានបន្តិចម្តង ៗ នឹងកាត់លះឲ្យដាច់ស្រឡះពុំទាន់បាន ។ ឯការដែលនឹងកំចាត់ទោសោឲ្យដាច់ជ្រះស្រឡះនោះ មានតែវិស័យព្រះអរិយបុគ្គលប៉ុណ្ណោះ ។ បុថុជ្ជនយើងលះមិនដាច់ស្រឡះទេ បើខំណាស់ បានគ្រាន់តែសង្កត់ទុក ដូចយកថ្មសង្កត់ស្មៅប៉ុណ្ណោះ ក៏ចាត់ថាជាការវិសេសណាស់ទៅហើយ ។ ការលះទោសោ

បាន អាស្រ័យចំរើនមេត្តានឹងដំកល់ខ្លួនឲ្យតាំងនៅក្នុងខន្តី ក៏អាស្រ័យចំរើនមេត្តា, លុះត្រាតែលះទោសោបានហើយស្ថិតនៅក្នុងខន្តី ទើបឈ្មោះថាដំកល់ខ្លួនទុកក្នុងអទោសោ មានអទោសោបរិបូណ៌ក្នុងសន្តាន បើបុគ្គលប្រកបដោយអទោសោហើយ ក៏នឹងបាននូវខន្តី លុះបានខន្តីហើយក៏ប្រកបដោយអានិសង្សច្រើនពន់មិនអស់ កាលបានខន្តីហើយ ក៏ចាត់ថាបានគបស្នងព្រះពុទ្ធដីកា ដែលទ្រង់ប្រោសប្រទានត្រាស់ព្រះសទ្ធម្មទេសនាទុកថា ខន្តីបរមំ តបោ តីតិក្ខា ខន្តីគឺសេចក្តីអត់សង្កត់ចិត្ត ឈ្មោះថាជាតបៈយ៉ាងក្រៃលែងយ៉ាងឧត្តម តថាគតត្រាស់ហៅនូវបុគ្គលដែលបានខន្តីនោះថាជាខីណាសវព្រាហ្មណ៍ គ្មានទីពឹងអ្វីដទៃប្រសើរជាងខន្តីទេ គឺដោយសារតែអានិសង្សនៃខន្តី ហើយទើបបាននូវមេត្តា លុះបានមេត្តាហើយក៏ប្រកបដោយអានិសង្ស ១១ ប្រការ សមតាមក្រសែព្រះពុទ្ធបរិហារ ប្រទានព្រះសទ្ធម្មទេសនាទុកក្នុងបឋមកាណ្ឌៈ ដែលព្រះអដ្ឋកថាចារ្យពោលទុកក្នុងគម្ពីរសារត្ថសមុច្ច័យថា ព្រះមានព្រះភាគត្រាស់ទេសនាថា បុគ្គលប្រកបដោយមេត្តាភាវនាមានអានិសង្ស ១១ ប្រការ គឺ

១– សុខំ សុបតិ ដេកលក់ជាសុខ មិនយល់សប្តិឃើញអាក្រក់ ដូចឃើញដំរីព្រៃចោរប្រហារជាដើម ។

២– សុខំ បដិពុជ្ឈតិ ភ្ញាក់ពីលក់ក៏ជាសុខ ។

៣– ជាទីស្រឡាញ់របស់មនុស្សនិងទេវតា ។

៤– នៅក្នុងប្រទេសណាហើយចេញពីទីលំនៅរបស់ខ្លួនចូលទៅក្នុងស្រុកនិគមជនបទណា ៗ ទេវតាទាំងឡាយនឹងរក្សាការពារមិនឲ្យមានអន្តរាយដល់ខ្លួន ។

៥– បុគ្គលស្អប់ខឹងនឹងដាក់ថ្នាំពិសឲ្យផឹកឲ្យស៊ី នឹងដុតដោយភ្លើង នឹងប្រហារដោយគ្រឿងសាស្ត្រាវុធ ក៏រួចផុតចេញបាន មិនត្រូវគ្រោះថ្នាក់ទាំងនោះឡើយ ។

៦– ចិត្តតាំងមាំជាសមាធិយ៉ាងឆាប់រហ័ស ។

៧– មានពណ៌សម្បុរស្បែកជ្រះថ្លាបរិសុទ្ធ ដូចរស្មីព្រះចន្ទពេញបូណ៌មីនៃខែកត្តិក ប្រាសចាកពពក ។

៨– អសម្មុឡ្ហោ កាលំ ករោតិ អ្នកប្រកបដោយមេត្តាដល់វេលាជិតស្លាប់ មិនវង្វេងភ្លេចគុណព្រះរតនត្រ័យ ភ្លេចសីលទានឡើយ ។

៩– ស្លាប់ហើយបានទៅកើតនៅស្ថានសួគ៌ ។

១០– បើមិនទាន់បានសម្រេចមគ្គផលទេ វេលាស្លាប់ហើយតែងទៅកើតក្នុងព្រហ្មលោក ដោយអំណាចបានចំរើនមេត្តា ។

១១–អ្នកបានចំរើនមេត្តាព្រហ្មវិហារ តែងលះបង់ទោសោចេញបាន ដំកល់ខ្លួនទុកក្នុងអទោសោបាន នឹងតាំងនៅក្នុងខន្តី ។

ការចំរើនមេត្តាព្រហ្មវិហារនោះ បុគ្គលមិនងាយនឹងចំរើនបានទេ លុះតែបានពិចារណាឲ្យឃើញទោសរបស់ទោសោ នឹងចារណាឲ្យឃើញ

អានិសង្សរបស់ខន្តី ទើបអាចចំរើនមេត្តាភាវនាបាន ។

បើចំរើនមេត្តាភាវនា ត្រូវនឹករឭកដល់មនុស្សដែលជាទោស ជាសត្រូវនឹងខ្លួនយើងឲ្យឃើញថា មនុស្សនេះៗ មិនគួរអញនឹងផ្សាយមេត្តាទេ លុះឃើញមនុស្សមិនគួរផ្សាយមេត្តាហើយ ក៏កុំផ្សាយមេត្តាទៅលើអ្នកនោះ ។

បុគ្គលដែលមិនគួរផ្សាយមេត្តានោះ គឺបុគ្គលមិនជាទីស្រឡាញ់មួយពួក មិនជាទីស្រឡាញ់ជិតស្និទ្ធនឹងខ្លួនយើងមួយពួក មិត្តសំឡាញ់នៃខ្លួនទៅជាកណ្តាលៗ មិនស្រឡាញ់ពេក មិនស្អប់ពេកមួយពួក បុគ្គលមានពៀរមួយពួក បុគ្គល ៤ ពួកនេះ កុំគប្បីផ្សាយមេត្តាទៅដល់មុន ។

បុគ្គលមិនគួរផ្សាយមេត្តាទៅកាន់អារម្មណ៍មិនស្មើ គឺកុំផ្សាយទៅកាន់ភេទស្រី នឹងកុំផ្សាយទៅកាន់សាកសពដែលស្លាប់ហើយ ។

មានពាក្យបុច្ឆាថា តើការណា ព្រោះហេតុអ្វីបានជាមិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គល ៤ ពួកជាមុន នឹងទៅកាន់ភេទស្ត្រី នឹងកាន់សាកសពដូច្នោះ ?

មានពាក្យវិសជ្ជនាថា អប្បិយំ ហិ បិយដ្ឋានេ ឋបេន្តោ ការដែលលោកហាម មិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គលមិនជាទីស្រឡាញ់នោះ ព្រោះហេតុថាបុគ្គលនឹងតាំងបុគ្គលដែលខ្លួនមិនស្រឡាញ់ទុកកន្លែងទីជាទីស្រឡាញ់នោះក[illegible]ាំងបានណាស់ តែនលំបាកចិត្តៗ ដែលលោកហាមមិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គលដែលខ្លួនស្រឡាញ់ខ្លាំង តែង

លំបាកនឿយព្រួយចិត្ត កាលបើសំឡាញ់ជិតស្និទ្ធរបស់ខ្លួននោះមានទុក្ខ តែបន្តិចបន្តួច ក៏ជួយព្រួយចិត្តយំសោក មិនអាចនឹងតាំងចិត្តឲ្យស្ថិតនៅជាកណ្ដាលបាន ។ ហេតុដូច្នោះ ទើបមិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គលដ៏ជាសហាយជាទីស្រឡាញ់មុន ។

ការដែលនឹងផ្សាយមេត្តាៈទៅកាន់បុគ្គលជាទីស្រឡាញ់កណ្ដាលៗ គឺមិនស្រឡាញ់ពេក មិនស្អប់ពេកនោះ នឹងតាំងទុកក្នុងទីគោរពក៏លំបាកនឹងតាំងទុកក្នុងទីស្រឡាញ់ ក៏កម្រនឹងតាំងបាន, ហេតុនោះ មិនឲ្យផ្សាយមេត្តាទៅកាន់សំឡាញ់កណ្ដាល ១ ជាមុន ។

ឯអនុស្សរណៈ យោគាវចរកុលបុត្រ កាលរឭករឿយៗ នូវបុគ្គលដែលមានពៀរនឹងខ្លួននោះ រមែងកើតសេចក្ដីក្រោធខឹង ហេតុនោះ ទើបលោកហាមមិនឲ្យផ្សាយមេត្តាទៅកាន់បុគ្គលដែលមានពៀរនឹងខ្លួន ។

ការវេទ្ធស្ស កាលភិក្ខុចំរើននូវមេត្តា ក្នុងអារម្មណ៍ជាវិសភាគារម្មណ៍ដោយអំណាចនៃភេទ គឺផ្សាយមេត្តាទៅកាន់ភេទស្រី ក៏កើតរាគៈ (សេចក្ដីតម្រេក) ឡើង មេត្តាមិនចំរើន ត្រឡប់ជាធ្លាក់ទៅខាងតម្រេកវិញ ដូចជាបុត្រអមាត្យម្នាក់ មានសេចក្ដីដំណាលថា ៖

(នៅមានត)

មង្គលសារវិចារណី

សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឺន ពិនិត្យ

( តមក )

---

# កាញ្ចនទេវីវត្ថុកថា

សំដែងរឿងនាងកាញ្ចនទេវីតទៅទៀតដោយបាលីថា :

ជម្ពុទីបេ កិរ ទេវបុត្តំ នាម ឧស្សន្ធិយំ
ឯកំ នគរំ អហោសិ ដូច្នេះជាដើម ។

អធិប្បាយថា: ដូចបានឮរឿង ១ មកថា : មាននគរមួយគួរជាទីគយគន់មើលដល់ប្រជុំជន ឈ្មោះ "ទេវបុត្តនគរ" ក្នុងជម្ពូទ្វីបនេះឯង ។

កាលនោះ មនុស្សទាំងឡាយបានបាត្រកែវដែលជាគ្រឿងបរិភោគនៃព្រះមានព្រះភាគ ហើយនាំបែងហេងមហោស្រព ធ្វើពិធីបូជាបាត្រកែវរបស់ព្រះសម្មាសម្ពុទ្ធជាអនេក នឹងគណនារាប់ពុំបានឡើយ ទើបពិធីនោះបានឈ្មោះថា មហាបត្តវិធីបូជាបាត្រ ដោយពិត ។

សម័យនោះឯង ព្រះបរមក្សត្រិយ៍ក្នុងទេវបុត្តនគរ ព្រះអង្គបាត់សេវកាមាត្យទាំងឡាយ ឲ្យសំអាងកាយរបស់ដោយគ្រឿងអលង្ការទាំងពួង ហើយស្ដេចត្រាស់បង្គាប់ឲ្យទឹមសេះសិន្ធពបួន មានសម្បុរដូចស្លឹកក្រមុំ (១)

---

១ ផ្កាត្របកផ្កាក្រមុំ ក៏បាន ។

រួចស្តេចឲ្យធ្វើប្រដាប់បាត្រកែវ ដែលព្រះបរមសាស្តាតែងប្រើប្រាស់ លើចុងឫស្សីមានកំពស់ប៉ែតសិបហត្ថ ដែលជាងអ្នកចេះស្ទាត់បានវិចិត្រ សំរេចដោយកែវទាំង ៧ ប្រការ លើកឡើងចងភ្ជាប់នឹងចុងឫស្សី ហើយឲ្យលើកឫស្សីឡើងបញ្ឈរលើរថ ស្រេចស្តេចត្រាស់ឲ្យធ្វើប្រដាប់តាក់តែងព្រះនគរដ៏ល្អបីដូចជាទេវនគរ ឲ្យលើកឡើងនូវទង់ជ័យ ទង់ជ្រុងទាំងឡាយ ហើយឲ្យដម្កល់នូវក្អមទឹកអប់ទាំងឡាយផង នូវផ្កាកម្រងទាំងឡាយផង ហើយស្តេចចាត់ឲ្យសេវកាមាត្យព្រមទាំងមហាជនទាំងឡាយ ដង្ហែប្រទក្សិណជុំវិញព្រះនគរ ដោយវិធីបូជាដ៏ឧឡារិកអធិកច្រើនជាអនេក រួចដង្ហែចូលមកក្នុងព្រះនគរវិញ ឲ្យដម្កល់នូវព្រះបត្តធាតុ ក្នុងមណ្ឌបកែវដែលបុគ្គលតាក់តែងដោយប្រពៃក្នុងកណ្តាលព្រះនគរ រួចហើយស្តេចត្រាស់បង្គាប់ឲ្យធ្វើមហាសទ្ធម្មស្សវនកិច្ច ឃោសនាឲ្យប្រជុំគ្នាស្តាប់ព្រះធម៌ទេសនាកំណត់ ៧ ថ្ងៃ ទើបឈប់ ។

កាលនោះ មនុស្សជាច្រើនដែលនៅក្នុងជនបទនោះក្តី ទេវតាទាំងឡាយក្តី យក្សអារក្សទឹកនាគគ្រុឌទាំងឡាយក្តី សឹងចូលមកប្រជុំគ្នាដោយច្រើនក្រៃពេក ដោយហេតុមនុស្សអ្នកក្រុងប្រជុំគ្នានោះ ។

ឯវិធីបូជាព្រះបត្តធាតុរបស់ព្រះបរមគ្រូសាស្តាចារ្យជាអម្ចាស់នៃយើង ជាអស្ចារ្យមានសភាពដូច្នេះឯង ។

គ្រានោះ មានស្តេចនាគមួយមានមហិទ្ធិឫទ្ធិ មានអានុភាពច្រើន

បានចូលមកកាន់ទីប្រជុំ ស្ដាប់ព្រះធម្មទេសនាដែរ ក៏បានឃើញនាងកុមារិកាម្នាក់មកពីទិសខាងកើត មានរូបឧត្ដមសមរម្យល្អ អង្គុយនៅក្នុងបំណោមបរិស័ទនោះ ស្ដេចនាគក៏មានចិត្តបដិពទ្ធស្នេហាស្រឡាញ់ចង់បាននាងកុមារិកានោះធ្វើជាភរិយានៃខ្លួន បាននិយាយលួងលោមនាងកុមារិកានោះដោយការប្រលោមផ្សេង ៗ ជាច្រើនដង ច្រើនគ្រា កាលបើពុំបានសម្រេចសេចក្ដីព្រមព្រៀងអំពីនាងកុមារិកានោះសោះ ក៏ដល់នូវការក្រោធខឹងយ៉ាងខ្លាំង បញ្ចេញខ្យល់ពិសពីប្រមុះ បំប៉ុនទៅ ដោយគិតថា អាត្មាអញនឹងសម្លាប់នាងកុមារិកានេះឲ្យស្លាប់ឥឡូវនេះឯង ។

ទោះបីនាគពជនោះខំព្យាយាមយ៉ាងណា ក៏គង់ពុំអាចនឹងធ្វើនាងកុមារិកានោះឲ្យកម្រើកបានឡើយ ដោយកម្លាំងសទ្ធារបស់នាងនោះឯង ។

លំដាប់នោះ នាគពជខឹងខ្លាំងពន់ពេក ទើបពេនខ្លួនព័ន្ធព័ទ្ធនូវសរីរៈទាំងអស់នៃនាងកុមារិកានោះ តាំងពីបាទ ដីងដរាបដល់ក្បាលជាទីបំផុត ហើយដកពពារគ្របពីលើក្បាល ញុំាងនាងកុមារិកានោះឲ្យភ័យខ្លាច ស្ថិតនៅក្នុងទីនោះឯង ។

ឯនាងកុមារិកានោះសោត នាងមានចិត្តពុំបានភយមាយឡើយ ដោយតេជះកម្លាំងដែលនាងប្រុងស្ដាប់ព្រះធម្មទេសនា ដោយគោរពនោះ សូម្បីតែសេចក្ដីទុក្ខលំបាកតិចតួចក៏ពុំមានដល់នាងឡើយ ។

លុះរាត្រីភ្លឺច្បាស់ ព្រះអរុណរះឡើង មនុស្សទាំងឡាយបាន

ឃើញហេតុគួរជាទីអស្ចារ្យនោះហើយ សួរថា ម្នាលនាងដ៏ចំរើន ! ការណ៍នេះជាហេតុដូចម្ដេច ? ។

ទើបនាងកុមារិកាបានសំដែងប្រាប់ហេតុនោះ ដល់ពួកមនុស្សដែលពុំបានដឹងដោយសព្វគ្រប់ហើយ ក៏ពោលជាបទព្រះគាថាដូច្នេះថា:

ព្រហ្មចារី អហោ សាហំ សញ្ញតា ឥធ មានុសេ
តេន សច្ចេន មំ ជាតោ ខិប្បមេវ បមុញ្ចតុ ។

អធិប្បាយថា: ឱហ្ន៎គួរអស្ចារ្យណាស់ ខ្ញុំព្រះករុណាបានកើតក្នុងជាតិជាមនុស្ស ហើយបានប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺបានស្ដាប់ធម្មទេសនាដោយគោរព, ដោយពាក្យសច្ចធម៌នោះ សូមនាគពជដែលមានពិសដ៏ពន្ទឹកលែងខ្ញុំឲ្យបានរួចផាប់ដោយពិត ។

កាមតុរស្ស ជាតស្ស នាភិសមការិយតោ
តេន សច្ចេន មំ ជាតោ ខិប្បមេវ បមុញ្ចតុ ។

ខ្ញុំព្រះករុណាពុំបានធ្វើនូវឱកាស (គឺការស្នេហា) ដល់នាគពជអ្នកត្រៀវគ្នាដោយកាមគុណ, ដោយពាក្យសច្ចធម៌នោះ សូមនាគពជដែលមានពិសដ៏ពន្ទឹកលែងខ្ញុំឲ្យបានរួចផាប់ដោយពិត ។

និស្សាន កត្វប្បិតំ ជាតិំ កត្វប្បិតសេដ្ឋា តេសទ្ធហំ
អក្កុទ្ធា តេន សច្ចេន សោ មំ ខិប្បំ បមុញ្ចតុ ។

ខ្ញុំព្រះករុណាបានឃើញនាគពជ ក្រោធខឹងហើយ ពុំបានទឹងគប

ដល់ពស់នាគរាជដែលក្រោធខឹងខ្លាំងវិញឡើយ , ដោយតេជះសច្ចធម៌នោះ នាគរាជនោះ សូមលែងខ្ញុំឲ្យឆាប់ ។

សទ្ធម្មំ សុណាមានាហំ គរុការំ សមាធិយំ
អស្សោសឹ តេន សច្ចេន ចិប្បមេវ បមុញ្ចតុ ។

ខ្ញុំព្រះករុណាកំពុងប្រុងស្តាប់ព្រះសទ្ធម្មហើយ អាចអត់ធន់នូវការ. ជាមុន បានស្តាប់ដរាបដល់ចប់, ដោយតេជះសច្ចធម៌នោះ សូមនាគរាជដែលមានពិសដ៏ពន្លឹកលែងខ្ញុំឲ្យរួចដោយឆាប់ ។

ន អត្ថំ ធានំ ភជិ វិនាសេត្តិ យតោហំ
អស្សោសឹ តេន សច្ចេន ចិប្បំ នាគោ បមុញ្ចតុ ។

ខ្ញុំព្រះករុណាពុំបានញុំាងអត្ថៈនឹងបាទឲ្យវិនាសបាត់បង់ឡើយ ខ្ញុំប្រុងស្តាប់ព្រះសទ្ធម្មដោយគោរព, ដោយសតេជះសច្ចធម៌នោះ សូមនាគរាជដែលមានពិសដ៏ពន្លឹកលែងខ្ញុំឲ្យឆាប់រហ័ស ។

សច្ចកិរិយាវសានេ កាលបើនាងកុមារិកាបានធ្វើសច្ចកិរិយាចប់ស្រេចហើយ នាគរាជក៏មានចិត្តជ្រះថ្លាពន់ពេកដល់នាងកុមារិកានោះ ទើបរំសាយខ្លួនដែលពេនព័ទ្ធនាងកុមារិកាចេញមួយរំពេច ហើយនិម្មិតជាពពារមួយឲ្យនាងកុមារិកាអង្គុយលើពពារនោះ ហើយធ្វើនូវកិរិយាបូជាលើខ្នងទឹកជាមួយនឹងនាគមាណពទាំងឡាយ មានប្រមាណច្រើនក្នុងកាលនោះឯង ។

ឯមនុស្សជាច្រើនដែលនៅក្នុងនគរ លុះបានឃើញហេតុនោះហើយ ក៏កើតសេចក្តីស្ញើបអស្ចារ្យក្នុងចិត្តដ៏ក្រៃលែង បានបូជានាងកុមារិកានោះ ដោយទ្រព្យចំនួន ១៨ កោដិក្នុងវេលានោះហោង ៗ

សេចក្តីពិតដូច្នោះ បានជាព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាថា :

នត្ថិ សទ្ធា សមោ លោកេ សុរភិ សព្វកាមទោ
បស្សថ សទ្ធា ពលំ សទ្ធា បូជេន្តិ (ភា) នរោ នារោ ៗ

អធិប្បាយថា: សភាពគ្រឿងអប់ដែលមានក្លិនក្រអូប អាចឲ្យនូវសម្បត្តិទាំងពួង ប្រាកដស្មើដោយសទ្ធាក្នុងលោកពុំមានឡើយ ៗ អ្នកទាំងឡាយចូរមើលនូវកម្លាំងសទ្ធារបស់នាងកុមារិកានោះចុះ ទោះនរជនក្តី នាគភពក្តី បានបូជាសម្បត្តិទាំងពួង (ដល់នាងកុមារិកានោះ ) ៗ

ឥហ លោកេ វស្សា លទ្ធំ ភវភោគមនប្បកំ
តស្មា សទ្ធេន កាតព្វំ រតនត្តយ គារវំ ៗ

ភោគសម្បត្តិក្នុងភពដ៏ច្រើនរាប់ពុំបានឮដ៏មនុស្សលោកនេះ ដែលនាងកុមារិកានោះបានហើយដោយពិត ៗ

ព្រោះហេតុដូច្នោះ បុគ្គលអ្នកមានសទ្ធា គួរធ្វើសេចក្តីគោរពក្នុងគុណព្រះរតនត្រ័យសព្វ ៗ កាល ៗ

លុះនាងកុមារិកាបានសម្បត្តិច្រើនយ៉ាងនេះហើយ ក៏បានប្រព្រឹត្ត

នូវកុសលធម៌ដ៏ប្រសើរដែលបានដល់អស់អាយុ ហើយធ្វើមរណកាលទៅចាប់បដិសន្ធិកនុងផ្ទៃព្រះអគ្គមហេសីនៃព្រះបរមក្សត្រិយ៍ក្នុងនគរនោះឯង ។

លុះនៅក្នុងព្រះឧទរគ្រប់ ១០ ខែបរិបូណ៌ហើយ ក៏បានប្រសូតិចេញចាកព្រះឧទរនៃព្រះមាតានោះដោយសួស្តិភាព ។

ខណៈដែលនាងធីតាបានប្រសូតិចេញចាកព្រះឧទរ នៃព្រះមាតាមកនោះក៏បង្កើតជាអស្ចារ្យ បណ្ដាលឲ្យមានភ្លៀងកែវ ៧ ប្រការបង្អុរធ្លាក់ចុះមកក្នុងទេវបុត្តនគរទាំងមូល ព្រោះហេតុដូច្នោះ បានជាព្រះវររាជបិតាព្រះវររាជជននីនាថ ព្រមទាំងព្រះរាជវង្សានុវង្ស បានសន្មតព្រះនាមធីតានោះថា "កាញ្ចនទេវី" ដោយពិត ។

ឯនាងកាញ្ចនទេវីនោះ នាងមានរូបឆោមលោមពណ៌ល្អប្រៀបដូចស្រីទេពអប្សរជាទីនាំមកនូវសេចក្ដីជ្រះថ្លា ត្រេកអរដល់ប្រជុំជន នាងមានក្លិនក្រអូបដូចផ្កាឧប្បល ផ្សាយចេញអំពីមាត់ផង មានក្លិនក្រអូបដូចខ្លឹមចន្ទន៍ផ្សាយចេញអំពីសរីរៈផង នឹងមានពន្លឺរស្មីភ្លឺស្វាងរុងរឿង ដូចពន្លឺព្រះអាទិត្យពេញកម្លាំងផ្សាយចេញអំពីសរីរៈទាំងអស់ផង ។

កិច្ចដែលត្រូវអុជគោមប្រទីបផ្កាលាក្នុងល្វែងប្រមាណបួនហត្ថ នៅវេលាយប់ពុំមានសោះឡើយ ឯល្វែងទាំងពួងសឹងមានពន្លឺស្វាងរុងរឿងតែមួយដោយពន្លឺរស្មីនៃនាងកាញ្ចនទេវីនោះឯង ។

ទាំងរូបសម្បត្តិរបស់នាងកាញ្ចនទេវីនោះទៀត ក៏ល្បីខ្ចរខ្ចាយ

សាយសព្ទទៅប្រាកដក្នុងជម្ពូទ្វីបទាំងអស់ ដោយផលានិសង្សដែលនាងមានសទ្ធាមាំបានស្ដាប់ព្រះធម្មទេសនាដោយគោរពនោះឯង ។

គ្រានោះ ព្រះរាជាទាំងឡាយ ដែលសោយរាជ្យនៅក្នុងជម្ពូទ្វីបបានជ្រាបពត៌មាននោះ ហើយក៏បញ្ជូននូវគ្រឿងបណ្ណាការជាច្រើន ទៅថ្វាយព្រះបរមក្សត្រិយ៍ជាព្រះវររាជបិតា ដើម្បីប្រយោជន៍នឹងដណ្ដឹងយកនាងកាញ្ចនទេវីនោះមកអភិសេកជាព្រះអគ្គមហេសីនៃខ្លួនទៅ ៗ ដោយលោភតណ្ហានោះឯង ។

ចំណែកឯនាងកាញ្ចនទេវីនោះសោត នាងពុំមានចិត្តជាប់ជំពាក់ក្នុងកាមគុណទាំងប្រាំឡើយ ហើយនាងសូមអង្វរព្រះវររាជបិតា សូមព្រះរាជានុញ្ញាត ថ្វាយបង្គំលាចេញទៅកាន់សំណាក់នាងភិក្ខុនី ហើយសូមផ្នួសបួសជាភិក្ខុនី បានចំរើននូវវិបស្សនាកម្មដ្ឋានដរាបដល់បានសម្រេចព្រះអរហត្ត កំចាត់បង់នូវកិលេសទាំងពួង ព្រមទាំងបដិសម្ភិទាញាណទាំងបួន មាននាមប្រាកដថា "កាញ្ចនថេរី" លុះអស់ព្រះជន្មាយុក៏បានចូលព្រះនិព្វានទៅហោង ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយអ្នកតែងគម្ពីរនេះ លោកពោលជាបទព្រះគាថាដូច្នេះថា :

សុត្វាន សាគរសេន កុមារិកោ
ធម្មំ ហិ សីលមមលម្បិ ធារយន្តី

លទ្ធាន ភោគវិភវំ ទិវំ បយាតា

មា ភោ បមជ្ជថ សទា កុសលប្បយោគេ ។

អធិប្បាយថា: នាងកុមារិកានោះឯង នាងបានស្តាប់ធម្មទេសនាដោយសេចក្តីគោរពល្អ ហើយបានរក្សានូវសីលប្រាំសីលប្រាំបីដ៏ស្អាតល្អបរិសុទ្ធ មិនមានសៅហ្មងឡើយ នាងបាននូវសម្បត្តិច្រើនជាអនេកនឹងគណនារាប់ពុំបាន ព្រមទាំងបានសម្រេចនូវសម្បត្តិព្រះនិព្វានទៀត ព្រោះលះបង់អំពើអកុសលដោយពិត ។

បពិត្រអ្នកទាំងឡាយដ៏ចំរើន ! អ្នកទាំងឡាយមិនត្រូវប្រមាទប្រហែសធ្វេសក្នុងការប្រកបព្យាយាមសន្សំនូវកុសលធម៌ឡើយ ត្រូវតែខំស្អាងទានសីលភាវនាឲ្យមាំមួនសព្វ ៗ កាលតទៅជាដរាប ។

សំដែងរឿងនិទាននាងកាញ្ចនទេវី ជាគំរប់បួន ក្នុងវគ្គទីពីរ ក៏ចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង ។

(នៅមានត)

## មហោសថជាតក

# លោក អ៊ុម-ភង បម្លែងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កិម-គួរ ពិនិត្យ

(តមក)

ស្ដេចស្ដាប់ពាក្យអាចារ្យសេនកស្រដីដូច្នោះហើយ ស្ដេចមានព្រះបន្ទូលទៅនឹងពោធិសត្វថា តាត មហោសថ ម្នាលបាមហោសថអើយ រីអាចារ្យសេនកស្រដីថាដូច្នេះ តើបាយល់ដូចម្ដេច ? ពោធិសត្វទូលថា បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ ! រីអាចារ្យសេនកពោះកំប៉ោងនេះ តើគាត់ចេះដឹងអ្វីព្រះអង្គ ! សូមអញ្ជើញស្ដេចស្ដាប់ខ្ញុំនឹងសំដែងថ្វាយ ទើបពោធិសត្វសូត្រនូវព្រះគាថាដូច្នេះថា :

ន សាធុ ពលវា ពាលោ
សាហសំ វិន្ទតេ ធនំ
កន្ទន្តមេតំ ទុម្មេធំ
កឌ្ឍន្តិ និរយំ ភុសំ
ឯតម្បិ និស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះមហារាជអើយ ! រីអ្នកកំឡៅប្រកបដោយកំឡាំងច្រើននោះ ពុំប្រពៃទេឡើយ ; រីអំពើនឹងបង្កើតទ្រព្យនោះ សឹងធ្វើដោយនូវអំណាច

សោះសា កាលណាបើស្លាប់ទៅហើយ, រីយមបាលជានាយនរក ក៏នឹងយកទុសនៃអ្នកកំឡៅនោះ បោះចោលទៅក្នុងភ្លើងនរក នឹងយំជាទុក្ខ-ពន្ទឹកមហិមា, ហេតុនោះ ខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញានោះប្រ-សើរ, ឯអ្នកកំឡៅមានយសនោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ហើយ មានព្រះបន្ទូលទៅនឹងអាចារ្យសេនកថា ម្តេចទៅអាចារ្យ ឥឡូវនេះចៅមហោសថថាដូច្នេះ, អាចារ្យឯងតើថាដូចម្តេច? អាចារ្យសេនកស្តាប់ហើយទូលព្រះមហាក្សត្រសូត្រនូវបទគាថាដូច្នេះថា :

យា កាចិ នជ្ជោ អភិសវន្តិ គង្គំ
សព្វា តា នាមគោត្តំ ជហន្តិ
គង្គា សមុទ្ទំ បដិបជ្ជមានា
ន ខាយតេ ឥទ្ធិវេ ហិ លោកេ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ វិហីនោ សិរិយាវ សេយ្យោតិ ។

បពិត្រព្រះមហារាជអើយ! រីស្ទឹងទាំងឡាយ សឹងហូរទៅកាន់គង្គា-ទី ស្ទឹងតូចផងនោះ ក៏លះបង់ឈ្មោះកំណើត ហៅជាស្ទឹងធំវិញ, រីស្ទឹងធំនោះក៏ហូរទៅកាន់សមុទ្ទ សឹងលះបង់ឈ្មោះកំណើត ហៅថាសមុទ្ទវិញ មាប្រការដូចម្តេចមិញ, រីអ្នកមានប្រាជ្ញាប្រសើរ តែឥតសម្បត្តិព្វដ៏ណេកនេះ, បើកាលណាទៅជាអ្នកមានសម្បត្តិហើយ ពុំយល់ប្រាកដ

ឡើយ; ឧបមាដូចស្ទឹងបឹងហូរទៅកាន់សមុទ្រនោះហោង, ហេតុនោះខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញា តែឥតសម្បត្តិពុំប្រសើរឡើយ, រីឯអ្នកមានប្រាជ្ញាហើយប្រកបដោយសម្បត្តិផងនោះទើបប្រសើរ ។

ស្តេចស្តាប់ហើយ មានព្រះបន្ទូលដណ្តឹងទៅពោធិសត្វវិញថា ម្នាលចាមហោសថអើយ! ចានឹងឆ្លើយដូចម្តេច? រីព្រះមហោសថស្តាប់ហើយទូលថា បពិត្រក្សត្រថ្លៃប្រសើរអើយ! សូមអញ្ជើញស្តេចស្តាប់ ទើបពោធិសត្វសូត្រនូវគាថានេះថា :

យមេតមក្ខា ឧទធឹ មហន្តិំ
បយន្តិ នជ្ជា សព្វកាលំ អសំខ្យំ
សោ សាគរោ និច្ចមុឡារវេគោ
វេលំ នាច្ចេតិ សោ មហាសមុទ្ទោ ។
ឯវម្បិ ពាលស្ស បជប្បិតានិ
បញ្ញំ នាច្ចេតិ សិរី កទាចិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញាវសេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ! រីអាចារ្យសេនកស្រីថា ទឹកសមុទ្រនោះធំហើយ, ស្ទឹងតូចទាំងឡាយសឹងហូរទៅកាន់សមុទ្រឥតរាប់ពុំបានឡើយ, បពិត្រមហារាជអើយ! រីសមុទ្រនោះសាគរទោះបើន

រលកបែកខ្ទេចខ្ចាយយ៉ាងណាក្តី ក៏ពុំដែលកន្ទងប្រាំងនោះបានឡើយ, មានប្រការម្តេចមិញ, រីអ្នកពាលទាំងឡាយ មានសម្បត្តិច្រើនអម្បាលមាណក្តី ក៏ពុំអាចដើម្បីនឹងកន្ទងអ្នកប្រាជ្ញនោះបាន មានសភាពដូចរលកពុំដែលកន្ទងប្រាំងបានដូច្នោះ ខ្ញុំយល់ហេតុនោះហើយបានជាខ្ញុំថា អ្នកប្រាជ្ញនោះប្រសើរ, រីអ្នកខ្លៅមានយសសម្បត្តិនោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ពាក្យនោះហើយ មានព្រះបន្ទូលដណ្តឹងទៅថា សេនកអាចារ្យសេនកអើយ! អ្នកថាដូចម្តេចទៀត ? ។ អាចារ្យសេនកទូលព្រះមហាក្សត្រ សូត្រជាបទគាថាដូច្នេះថា:

អសញ្ញតោ ចេបិ បរេសមត្តំ
ភណាតិ សណ្ឋានគតោ យសស្សី
តស្សេវ តំ រូហតិ ញាតិមជ្ឈេ
សិរី ហិ នំ ការយតេ ន បញ្ញា
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញា វិហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រព្រះមហារាជអើយ! រីអ្នកខ្លៅហើយមានយសបរិវារ បើអង្គុយនាឋានតិចណា ទោះយោបល់ស្រដីពីអាថ៌សេចក្តីអ្វីមួយនឹងអ្នកដទៃក្រៅនៃមណ្ឌលក្រុមជំនុំ, រីពាក្យអ្នកនោះយល់ថ្កើងរុងរឿងប្រពៃឮដល់កណ្តាលជំនុំនៃញាតិផង, រីអ្នកមានប្រាជ្ញាថយលែងនឹងឥស្សរសម្បត្តិ ក៏ធ្វើការយល់

ជាពុំច្រើនវេនវៀនក្នុងកណ្តាលជំនុំញាតិផងឡើយ ខ្ញុំយល់នូវហេតុនោះ ហើយបានជាខ្ញុំថា អ្នកមានសិរីសម្បត្តិនោះប្រសើរ, អ្នកមានប្រាជ្ញា ថយលែងសម្បត្តិនោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ហើយ ដណ្តឹងទៅពោធិសត្វថា ម្នាលមហោសថអើយ! អ្នកនឹងថាដូចម្តេច? ពោធិសត្វទូលថា បពិត្រក្សត្រប្រសើរអើយ ! រីអាចារ្យសេនកកំឡៅនេះ នឹងដឹងអ្វី សូមអញ្ជើញស្តេចស្តាប់ខ្ញុំ ទើបពោធិសត្វសូត្រនូវគាថានេះថា:

បរស្ស វា អត្តនោ វាបិ ហេតុ
ពាលោ មុសា ភាសតិ អប្បបញ្ញោ
សោ និន្ទិតោ ហោតិ សភាយ មជ្ឈេ
បច្ឆាបិ សោ ទុគ្គតិគាមី ហោតិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សិ ពាលោតិ ។

បពិត្រព្រះមហាក្សត្រប្រសើរអើយ ! រីអ្នកកំឡៅឥតប្រាជ្ញា ស្រដីនូវពាក្យមុសាវាទ ព្រោះតែបានប្រយោជន៍នៃអាត្មាឯងក្តី ហេតុប្រយោជន៍អ្នកដទៃនោះក្តី, អ្នកដ៏មានធម៌សប្បុរសផងទាំងឡាយ សឹងរិះគន់ដៀលក្នុងកណ្តាលជំនុំ, លុះចំណេរទៅឯក្នុងអ្នកសោក នឹងនាំអាត្មាទៅកាន់ចតុរាបាយ មាននរកជាដើម, ខ្ញុំយល់ហេតុនោះហើយបានជាខ្ញុំថា អ្នកមាន

ប្រាជ្ញានោះប្រសើរ រីឯអ្នកកំឡៅមានយសសម្បត្តិនោះពុំប្រសើរឡើយ ។

លំដាប់នោះ, អាចារ្យសេនកស្តាប់ហើយ ទូលព្រះមហាក្សត្រ សូត្រនូវបទគាថាដូច្នេះថា :

អត្ថម្បិ វេ ភាសតិ ភូរិបញ្ញោ
អនាលយោ អប្បធនោ ទលិទ្ទោ
ន តស្ស តំ រូហតិ ញាតិមជ្ឈេ
សិរីបញ្ញាណវតោ ច ន ហោតិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ វិហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រព្រះមហាពជអើយ! អ្នកមានប្រាជ្ញាច្រើន ហើយឥតសម្បត្តិទ្រព្យ ខ្សត់ទុគ៌ត កាលណាបើស្រដីនូវអាថ៌សេចក្តីជាប្រយោជន៍ព្ធដ៏កណ្តាលពពួកញាតិផងទាំងឡាយក្តី ក៏ពុំចើងរុងរឿងឡើយ, មួយទៀតទោះយាប់អ្នកនោះនឹងទៅកាន់អ្នកដ៏មានឥស្សរសម្បត្តិនោះក្តី ក៏ពុំយល់ប្រាកដ, ទុបមាប់ដូចអំពិលអំពៅកត្រូវពន្លឺព្រះអាទិត្យដែលទទ័យឡើងនោះហោង; ខ្ញុំយល់ហេតុនោះហើយបានជាខ្ញុំថា អ្នកមានសម្បត្តិនោះប្រសើរ, រីអ្នកប្រាជ្ញាចយលែងសម្បត្តិនោះពុំប្រសើរឡើយ ។

ស្តេចស្តាប់ហើយ ទ្រង់ដណ្តឹងពោធិសត្វថា ម្តេចទៅបាមហោសថ ? ពោធិសត្វពោលតបថា បពិត្រព្រះមហាពជអើយ! រីសេនកនេះ

ជាអ្នកកំឡៅនឹងដឹងអ្វី ? គាត់មើលយល់តែលោកិយនេះឯង, គាត់មើលបរលោកពុំយល់ឡើយ ហើយពោធិសត្វសូត្រនូវគាថានេះថា :

បរស្ស ច អត្តនោ ចាបិ ហេតុ
ន ភាសតិ អលិកំ ភូរិបញ្ញោ
សោ បូជិតោ ហោតិ សភាយ មជ្ឈេ
បច្ឆាបិ សោ សុគតិគាមី ហោតិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញាវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រមហារាជអើយ ! អ្នកមានប្រាជ្ញាច្រើន មិនដែលស្រដីនូវពាក្យកុហកលេះលោះ ដ្បិតនឹងហេតុបង់បានជាប្រយោជន៍អាត្មខ នឹងជាប្រយោជន៍អ្នកដទៃ, អ្នកមានប្រាជ្ញាច្រើននោះ លោកផងសឹងបូជាឰដ៏កណ្ដាលជំនុំ, លុះបំណោរទៅសោត នឹងបានទៅសោយសុខកិរម្យឰដ៏សួគ៌ទេវលោកនាយ, ហេតុនោះ ខ្ញុំយល់ហើយខ្ញុំថា អ្នកមានប្រាជ្ញានោះប្រសើរ, អ្នកកំឡៅអន្ធពាលឥតប្រាជ្ញានោះពុំប្រសើរឡើយ ។

លំដាប់នោះ; អាចារ្យសេនកស្ដាប់ពាក្យពោធិសត្វហើយ ទូលព្រះមហាក្សត្រ សូត្រជាបទគាថា ដូច្នេះថា :

ហត្ថី គវស្សា មណិកុណ្ឌលា ច
នារិយោ ច ឥទ្ធេសុ កុលេសុ ជាតា

សព្វាវៈ តា ឧឃកោតា ករវត្តិ
ឥទ្ធស្ស ទោសស្ស អធិទ្ធិមន្តោ
ឃតម្បិ ធិស្វាន អហំ វទាមិ
បញ្ញា វិហីនោ សិរិមាវៈ សេយ្យោតិ ។

បពិត្រព្រះមហាពជអើយ! ដំរី សេះ គោ ក្របី ផងទាំងឡាយក្តី ស្រីទាំងឡាយមានរូបល្អក្តី មណីរ័តន៍មកុដកុណ្ឌលទាំងឡាយក្តី សឹងកើតមានញដ៏ត្រកូលទាំងឡាយ ដ៏មានសម្បត្តិច្រើន, រីអ្នកផងទាំងឡាយដ៏ឥតសម្បត្តិ សឹងទៅបំរើអ្នកដ៏មានសម្បត្តិនោះ, ហេតុនោះហោងខ្ញុំថា អ្នកដ៏មានសម្បត្តិប្រសើរ, រីអ្នកមានប្រាជ្ញាឥតសម្បត្តិពុំប្រសើរឡើយ ។

លំដាប់នោះ, ពោធិសត្វស្តាប់ហើយ ទូលព្រះមហាក្សត្រថា រីអាចារ្យសេនកនោះដឹងអ្វីព្រះអង្គ ហើយពោធិសត្វនាំនូវហេតុមួយមកសំដែងសូត្រជាបទគាថាដូច្នេះថា :

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

## វប្បធម៌ខ្មែរ

# អក្សរសាស្ត្រជាសាខាសំខាន់នៃវប្បធម៌

លោក លី · ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

---

ដូចបានរាប់រៀបក្នុងអត្ថបទមុន ៗ រួចមកហើយថា "អក្សរសាស្ត្រជាសាខាសំខាន់ជាងគេក្នុងវប្បធម៌" ព្រោះអក្សរសាស្ត្រជាមេគំនិតបង្កបង្កើតនូវបញ្ហាត្រិះរិះគ្រប់បែបទាំងអស់ ៗ ដើម្បីបកស្រាយបញ្ហានេះឲ្យបានច្បាស់លាស់ យើងល្បងធ្វើសេចក្ដីវែកញែករកហេតុផលឲ្យល្អិតល្អន់បន្តិចដូចតទៅ ៖

១– អក្សរសាស្ត្រជាមេប្រាជ្ញា.– គ្រប់តែប្រទេស គេតែងទុកដាក់ការសិក្សាពីអក្សរសាស្ត្រជាចំបងគេបំផុត ព្រោះថាបើកាលណាគេជ្រួតជ្រាបសព្វសព្វគ្រប់ក្នុងអក្សរសាស្ត្រហើយ នោះគេនឹងមានស្មារតីប្លែកមួយ គឺស្មារតីវាងវៃ ឆ្លៀវឆ្លាស ប៉ិនប្រសប់គ្រប់វិធីដោះស្រាយបញ្ហាអ្វី ៗ សព្វបែបសព្វយ៉ាងគ្មានសល់បន្ទោះ ៗ ហេតុដែលនាំឲ្យដូចនេះ ដ្បិតនៅក្នុងស្នាដៃនិមួយ ៗ ដែលប្រឌិតឡើងដោយសារ

អ្នកនិពន្ធណាមួយ អ្នកនិពន្ធនោះរមែងផ្ដិតភ្ជាប់នូវគោលគំនិត, សេចក្ដីយល់ឃើញជានិក្ខេបបទរបស់ខ្លួនឲ្យនៅជាប់ក្នុងនោះ សំរាប់ជូនជាបញ្ហាដល់អ្នកអានជួយត្រិះរិះពិចារណារកហេតុផល និងជួយដោះស្រាយបញ្ហានោះតាមវិធីគ្រប់បែបគ្រប់យ៉ាងមានគតិបណ្ឌិតជាដើម ។ អាស្រ័យហេតុនេះ ឃើញថាអ្នកអក្សរសាស្ត្រ ពិតជាមគ្គុទ្ទេសក៍យ៉ាងសំខាន់ ក្នុងការរៀបចំដោះស្រាយសង្គមជាតិនីមួយ ៗ, បានសេចក្ដីថា បើអ្នកអក្សរ-សាស្ត្របណ្ដុះគំនិតអាក្រក់ មានរឿងស៊ីផឹក, លួចប្លន់ឬកាប់សម្លាប់គ្នាជាដើមអ្នកអានចំនួនច្រើនដែលមាននិស្ស័យនៅទន់ខ្ចី ប្រាកដជានឹងយល់ថាអំពើលាមកទាំងនោះជាការចាំបាច់ដែរ ហើយគេនឹងក្មាត់ស្មៀតប្រព្រឹត្តតាមនោះខ្លះ ៗ ជាហេតុនាំឲ្យមានការល្អក់ខ្វល់ក្នុងសង្គមជាតិជាពុំខាន ។ ផ្ទុយទៅវិញ បើអ្នកអក្សរសាស្ត្រស្គាល់ជាទីស្គាល់ភារៈខ្លួនច្បាស់ ដឹងប្រាកដថាខ្លួនជាអ្នកដឹកនាំមតិមហាជនឲ្យត្រាច់ទៅកាន់ផ្លូវល្អប្រពៃ ដើម្បីកសាងសង្គមជាតិខ្លួននោះ សេចក្ដីចំរើនក៏ចេះតែមានទ្វេឡើង ៗ ជាលំ-ដាប់ ឧត្ដមគតិយ៉ាងត្រកាល ៗ ក៏ចេះតែផុះពន្លកក្នុងខួរក្នុងស្មារតីនៃពល-រដ្ឋមជាតិគ្រប់ ១ រូបទៅដែរ ។ ដូចនេះ ឃើញថា សូម្បីតែគ្រោះថ្នាក់ផ្សេង ៗ ដែលនឹងកើតមានឡើងក្នុងដំណើរជីវិតអ្នកស្រុកអ្នកភូមិ ក៏អាចទ្រុឌទ្រោមសាបរលាបទៅវិញបានជាពុំខាន ព្រោះដោយសារតែអ្នកស្រុកអ្នកភូមិគ្រប់គ្នាផុះដាលបញ្ញាស្មារតី ចេះនាំគ្នាទុកដាក់ប្រាជ្ញាជាធំក្នុងការ

ប្រព្រឹត្តទៅនៃជីវិតរបស់រៀង ៗ ខ្លួន ៗ ។ សំខាន់ម្យ៉ាងទៀត ត្រង់ដែល អំពើល្អកើតឡើងអំពីផលនៃការណែនាំរបស់អ្នកអក្សរសាស្ត្រនេះ អាចទុកទៅបានជាមតិកដ៏គាប់ប្រសើរ ដល់កូនចៅជំនាន់ទៅមុខឆ្ងាយ ៗ ទៀត ៗ

២– អក្សរសាស្ត្រជាមេការសិក្សា – ចំពោះចំណុចនេះ យើងគេឃើញថា ចំណេះវិជ្ជាអ្វីផងទាំងពួង ដែលនឹងកើតមានឡើងបាន គឺអាស្រ័យដោយអក្សរសាស្ត្រជាអ្នកបើកផ្លូវ ៗ បានសេចក្ដីថា មុននឹងអ្នកប្រាជ្ញរាវរកកសាងវិជ្ជាចំណែកអ្វីមួយបាន អ្នកប្រាជ្ញត្រូវយកវិជ្ជាអក្សរសាស្ត្រ ជាស្ពានសំរាប់ឆ្លងទៅកាន់គោលបំណងរបស់ខ្លួនឲ្យបានសម្រេចតាមប្រាថ្នា ៗ បើយើងពោលមួយផ្នែកទៀតថា អក្សរសាស្ត្រជាបឋមវិជ្ជា ឬមេវិជ្ជាដែលត្រូវសិក្សាជាដំបូងគេបំផុតក៏បាន ដ្បិតអ្វី ៗ ផងទាំងពួងសុទ្ធតែចារឹកជាអក្សរធ្វើជាលក្ខណ៍ ទុកសំរាប់កេងកាពក្នុងការសិក្សា ៗ តែមានវិជ្ជាបច្ចេកទេសខ្លះដែរ ដែលពុំបាច់ឆ្លងតាមស្ពានអក្សរសាស្ត្រ ព្រោះគេបង្កើតបានដោយការសំគីតិសោធរឿយ ៗ ក្នុងការងារផ្ទាល់របស់គេ ក៏ប៉ុន្តែជាករណីពិសេសហួស ដែលកម្រនឹងចែកចាយឲ្យសាយភាយវិជ្ជានោះឲ្យសុសសាយទៅបានដូចជាគេយកស្ពានអក្សរសាស្ត្រទៅប្រើ ៗ

៣– អក្សរសាស្ត្រជាមេនៃសិល្បៈ – បើយើងពោលថា អក្សរសាស្ត្រជាសិល្បៈវិញក៏បាន ព្រោះវិជ្ជាទាំងនេះ រមែងនៅរួមជាប់ជាមួយគ្នាជានិច្ច ប៉ុន្តែ យើងចាត់ទុកអក្សរសាស្ត្រជាមេ ព្រោះអក្សរសាស្ត្រ

មាននាទីដឹកនាំ ឬកត់ត្រាដៅសំគាល់ជានិច្ចនូវក្បួនខ្នាត នូវផ្ទៃរឿងរ៉ាវ នូវសម្រស់លំអនៃសិល្បៈនិមួយ ៗ ចាប់តាំងពីការរាំច្រៀង ចម្លាក់រចនាឡើងទៅ ៗ បើកាលណាគេសិក្សាពីសិល្បៈ ក៏ត្រូវសិក្សាពីអក្សរសាស្ត្រផងដែរ គេពុំអាចបំបែកឲ្យឃ្លាតចេញពីគ្នាដាច់ស្រឡះបានទេ ៗ ហេតុផលដែលពោលមកត្រួស ៗ នេះហើយ ដែលយើងសំគាល់បានថា " អក្សរសាស្ត្រជាមេនៃសិល្បៈ " ៗ

សរុបសេចក្តីទៅ អក្សរសាស្ត្ររបស់ជាតិណា ប្រាកដជាសាខាយ៉ាងធំរបស់វប្បធម៌ជាតិនោះ ៗ ឯខ្មែរយើង ដែលជាជាតិច្បងមួយធ្លាប់មានវប្បធម៌ឆើតឆាយដាច់គេក្នុងចំណោមជនជាតិនៅលើជ្រោយសុវណ្ណ-ភូមិតាំងពីបុរាណកាលមកនោះ យើងនៅគង់ទ្រង់ច្បាស់ក្រឡៅខាងលក្ខគោលអក្សរសាស្ត្រសម្រាប់ទុកជាមេគំនិត មេបញ្ញា មេវិជ្ជាទាំងពួងដល់ជនជាតិយើងតាំងពីព្រេងនាយរៀងរបមកដល់បច្ចុប្បន្ន ៗ ហេតុនេះយើងជាកុលបុត្រខ្មែរ ដែលបានស្គាល់នូវតម្លៃមុខវិជ្ជានេះច្បាស់លាស់ហើយ គប្បីតែយើងនាំគ្នារក្សាកេរ្តិ៍មតិកនេះឲ្យគង់វង់ល្អ ព្រមទាំងនាំគ្នាជួយពង្រីក ឲ្យបានសាយភាយសមតាមឋានៈ នៃប្រទេសយើងឯករាជ្យចំរើនផង ៗ

## ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Chef de quart | | នាយវេន |
| Médecin de garde en chirurgie | | គ្រូពេទ្យយាមខាងសល្យសាស្ត្រ |
| Médecin de garde en médecine générale | | គ្រូពេទ្យយាមខាងវេជ្ជវិជ្ជាទូទៅ |
| Bloc opératoire | | សល្យាការ |
| Attelle | *n. f.* | ព្រួលស្ទប |
| Joncacées | *n. f.* | ប្រនាលជាតិ |
| Palmier | *n. m.* | តាលជាតិ |
| Nymphéacée | *n. f.* | បទុមជាតិ |
| Liliacée | *n. f.* | បលាណ្ឌជាតិ |
| Iridacée | *n. f.* | កេសរជាតិ |
| Orchidacée | *n. f.* | បិនសីថជាតិ |
| Apétales | *n. cl a* | អទលី |
| Dialypétales | *n. cl o* | វិយុត្តទលី |
| Gamopétales | *n. cl a.* | យុត្តទលី |
| Cupulifères | *n. cl. a.* | ចលកជាតិ |
| Urticacées | n. *f.* | កច្ឆជាតិ |
| Crucifères | *n. m.* | សោត្ថិកជាតិ |
| Moracées | *n. f.* | ឧទុម្ពរជាតិ |
| Ampélidacées | *n. f.* | ជិញ្ឈកូល |
| légumineuses | *n. f* | សិម្ពិកូល |
| Rosacées | *n.* f. | គុលាពកូល (គុឡាព) |
| Ombellifère | *n. f.* | ឧច្ឆត្តកូល |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត.ខ្មែរ

*ព្រះមហា ប៉ាង់ - ខាត់ រៀបរៀង*

(តមក)

អតិភទ្រតា ស្ត្រី. ភាវនៃ . . . ចំរើនក្រៃលែង, ភាវនៃ . . . ប្រសើរក្រៃលែង ។

អតិភយ នបុំ. ភ័យក្រៃលែង; ភ័យធំ ។

*អតិភយាបក*, គុ. ដែលគួរស្ញើមក្រៃលែង ។

អតិភរ បុំ. ភារៈក្រៃលែង, ភារៈធ្ងន់ ។

អតិភា ធាតុ. ភ្លឺក្រៃលែង, ភ្លឺព្រោងព្រាយ ។

អតិភានុ បុំ បុត្រានៃក្ឫស្ណ ។

អតិភារ បុំ. ភារៈក្រៃលែង, ភារៈធំ ។

អតិភារី បុំ. អតិភាព ។

អតិភីរុតា ស្ត្រី. ភាវនៃសេចក្ដីខ្លាចក្រៃពេក ។

អតិភីឞណ គុ. ដែលខ្លាចក្រៃពេក ។

អតិភុត្ត គុ. ដែលបរិភោគក្រៃពេក ។ នបុំ. កិរិយាបរិភោគក្រៃពេក ។

អតិភូ ធាតុ កើតក្រៃលែង, កើតប្រសើរ ។

អតិភូ បុំ. ព្រះវិស្ណុ ។

(នៅមានត)

ដើមកំណើតប្រាសាទអង្គរ

# លោក ល្វីហ្វីណូត៍ រៀបរៀង

ក្រមការ ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ

លោក ញ៉ែម-ខឹម ពិនិត្យ

នឹងកែសម្រួលជាថ្មី

## សេចក្តីបញ្ជាក់

យើងសូមបញ្ជាក់ថា រឿងដើមកំណើតប្រាសាទអង្គរនេះ លោក ល្វីហ្វីណូត៍ សាស្ត្រាចារ្យនៃអនុវិទ្យាល័យ ប្រទេសបារាំង នឹងជាអតីតចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស បានតែងជាភាសាបារាំង ហើយលោកក្រមការ ជុំ-ម៉ៅ បានប្រែមកជាភាសាខ្មែរ នឹងបានចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយាយើងកាលពីឆ្នាំ ១៩២៨ រួចម្តងមកហើយ ៗ ប៉ុន្តែ, ដោយកាលសម័យនោះ ប្រទេសកម្ពុជាយើង ស្ថិតនៅក្រោមអាណាព្យាបាលបរទេស, ប្រទេសនានាក្នុងសាកលលោក គេឥតស្គាល់ឈ្មោះប្រទេសយើងទេ គេស្គាល់តែឈ្មោះឥណ្ឌូចិន ៗ ដូច្នេះប្រាសាទអង្គរយើង ដែលជាអច្ឆរិយវត្ថុមួយ ក្នុងបណ្តាអច្ឆរិយវត្ថុឯទៀតនៅក្នុងសាកលលោកដែរ ក៏ត្រូវបាត់ឈ្មោះបាត់សំឡេងមកអស់ពេលជាយូរ ៗ

លុះមកដល់បច្ចុប្បន្នសម័យនេះ ដែលប្រទេសយើងបានទទួលឋានៈជាប្រទេសឯករាជ្យពេញបរិបូណ៌ឡើងវិញ ដោយសារស្នាព្រះហស្តនៃសម្តេចព្រះប្រមុខរដ្ឋ, ប្រាសាទអង្គរយើងក៏បានលេចព្រន្លឺកេរ្តិ៍ឈ្មោះពេញ

ទាំងសាកលលោក ។ ក្នុងមួយឆ្នាំ ៗ អ្នកទេសចរណ៍ជាច្រើនពាន់នាក់ បានមកទស្សនាប្រាសាទអង្គរយើង, ហើយបានពោលសរសើរពីបុរាណវត្ថុនេះ និងអំពីសិល្បករខ្មែរយើងពីសម័យបុរាណជាច្រើនក្រៃលែង ។

អាស្រ័យហេតុនេះ ខ្ញុំយល់ឃើញថា គួរយករឿងដើមកំណើតប្រាសាទអង្គរនេះ មកចុះផ្សាយម្តងទៀត ដើម្បីទុកជាទីពិចារណាដល់លោកអ្នកអានទូទៅ, ព្រោះយើងជាម្ចាស់ស្រុក ត្រូវស្គាល់ស្រុកយើងជាងជនបរទេស ដើម្បីទុកជាឯកសារដ៏សំខាន់សម្រាប់អ្នកប្រាជ្ញខ្មែរយើងខាងបុរាណវត្ថុ, ជាពិសេសសម្រាប់និស្សិតខ្មែរយើង ដែលត្រូវការសិក្សាពីប្រាសាទអង្គរយើងនេះ ។

ញ. ១.

## ដើមកំណើតប្រាសាទអង្គរ

តាមជំនឿដែលគេតែងមានដកពដល់មកសព្វថ្ងៃនេះថា អង្គរធំនឹងបាយ័ន គឺព្រះបាទយសោវរ្ម័នទ្រង់ព្រះនាមថា បរមសិវលោក ទ្រង់ពង្សពីគ្រិស្តសករាជ ៨១១ ទៅដល់ ៨៣២ បានកសាងក្នុងគ្រិស្តសករាជ ៨៨៩ ទៅ ៩១០ ។

## តើបានអ្វីនឹងបញ្ជាក់ក្នុងរឿងនេះ ?

កាលដើម ឈ្មោះចាស់របស់ទីក្រុងហៅថា យសោធរបុរៈ គឺក្រុងនៃយសោធរៈ ។ ក្នុងដំបន់អង្គរគេឃើញមានប្រាសាទជាច្រើន ដែល

មានឈ្មោះរបៀបតែមួយដូចជាឈ្មោះយសោធរតដាក ប្រែថា "ត្រពាំងនៃយសោធរៈ" ឯត្រពាំងនោះគឺបារាយណ៍ខាងកើត; យសោធរេស្វរ ប្រែថា "ឥស្វរនៃយសោធរៈ" គឺភ្នំបាខែង; យសោធរាស្រម គឺអាស្រមនៃយសោធរៈឈ្មោះត្រង់នេះមិនប្រាកដទៅលើអ្វីឡើយ ព្រោះខាងក្រោយអាស្រមនេះមានកន្លែងមួយឈ្មោះយសោធរគិរី ប្រែថា ភ្នំនៃយសោធរៈ គឺជាភ្នំបាយ័ននោះឯង ។ ពាក្យយសោធរៈនេះ ប្រែថា "កាន់នូវជ័យជំនះ" ជាពាក្យបំបែករបស់ស្ដេចយសោវរ្ម័នអំពីកប៉ាល់ជ័យមក ឯពាក្យយសោធរបុរៈគឺជាឈ្មោះទីក្រុងរបស់យសោវរ្ម័ននោះឯង ។

ម្យ៉ាងវិញទៀត មានប្រាសាទជាច្រើនផ្សេង ៗ ទៀត ដែលមានឈ្មោះថាយសោធរៈដែរ ហើយដែលព្រះបាទយសោវរ្ម័នបានសាង ក៏គួរតែសន្និដ្ឋានបានថា ពាក្យដែលថាទីក្រុងរបស់យសោវរ្ម័ននោះ គឺជាក្រុងដែលព្រះបាទយសោវរ្ម័នបានសាងវិញ ។

មកដល់ត្រង់នេះ យើងសូមដំណាលពីប្រវត្តិស្ដេចអង្គនេះបន្តិចសិន ព្រោះរឿងរ៉ាវរបស់ព្រះអង្គនេះ មិនមែនឥតប្រយោជន៍ឡើយ ។ យើងបានដឹងខ្លះ ៗ ថា ព្រះអង្គជាព្រះរាជបុត្រព្រះបាទឥន្ទ្រវរ្ម័ន ទ្រង់បានកសាងប្រាសាទបាគោនិងបាគង ទ្រង់បានឡើងគ្រងរាជ្យតាំងពីកុមារ ហើយគ្រងរាជសម្បត្តិបាន ២០ ឆ្នាំ គិតតាំងពីគ្រិស្ដសករាជ ៨១១ ។ ស្ដេចយសោវរ្ម័នអង្គនេះ អាចចាត់ទុកជាពួកស្ដេច ដែលមានឥទ្ធិឫទ្ធិ

ខាងផ្លូវចម្បាំងបាន ដ្បិតមានល្បីថា ទ្រង់ប្រសប់ខាងបាញ់ធ្នូដោយព្រះហស្តខាងណាក៏បាន ទ្រង់មានកំឡាំងអាចទប់ទល់នឹងដំរីសាដ៏សាហាវៗ ហើយអាចសំឡាប់ដំរីនោះតែ ១ ព្រះខ័នដោយព្រះហស្តឆ្វេងផង, ទ្រង់អាចតយុទ្ធជាមួយនឹងអ្នកចម្បាប់ ១០ នាក់ ហើយផ្តួលបានទាំងអស់ដោយស្រួល ៗ តេជានុភាពរបស់ស្តេចអង្គនេះ បណ្តាលឲ្យអ្នកសរសើរហ៊ានប្រដូចថា ទ្រង់អាចកាប់ដែកមូលមួយវែងធំ ហើយរឹងតែ ១ ព្រះខ័នឲ្យដាច់ជា ៣ កំណាត់ ហាក់ដូចជាផ្ទួនដែកនោះមិនឲ្យមកប្រកួតប្រឡងនឹងព្រះបេស្តា មិនតែប៉ុណ្ណោះសោត មានសេចក្តីសរសើរខ្លះទៀតថា ស្តេចអង្គនេះទ្រង់ឆ្លៀវឆ្លាតខាងភ្លេង ទ្រង់ជាគ្រូរបាំយ៉ាងប៉ិនប្រសប់ ជាអ្នកប្រាជ្ញខាងបរមត្ថ ជាអ្នកនិពន្ធវេយ្យាករណ៍, នឹងសេចក្តីអធិប្បាយអំពីមហាភាស្យរបស់បតញ្ជលី ។

---

---

គេបានឃើញចម្ងាយ ២៥ គីឡូម៉ែត្រ ខាងទិសពាយ័ព្យនៃស្រុកស៊ីសុផុន នៅកន្លែងមួយដែលហៅថាស្តុកកក់ធំ, គោលថ្ម ១ ចារឹកជាពាក្យខ្មែរនឹងពាក្យសំស្ក្រឹត ដែលមានសេចក្តីប្លែកពីសិលាចារឹកទាំងឡាយក្នុងស្រុកខ្មែរ ហើយមានសេចក្តីល្អ ៗ ជាច្រើន ៗ គោលនេះបានចាប់ធ្វើក្រោយគ្រិស្តសករាជ ៩៧៤ បន្តិច គឺក្នុងគ្រិស្តសករាជ ១០៥២ មាន

ឈ្មោះសុទាសិវ ជាបុរោហិតរបស់ស្តេចជាអ្នកសរសេរ បុរោហិតនេះបានទទួលមុខងារបន្តពីបុរោហិតមុន ហើយដែលបានកាន់កាប់មុខក្រសួងពីតឪពុកម្តាយ គឺជាពង្សាវតារនៃពួកបុរោហិតក្នុង ២៥០ ឆ្នាំ ពីគ្រិស្តសករាជ ៧២៤ ទៅដល់ ៩៧៤ ត្រូវនឹងគ្រិស្តសករាជ ៨០២ ទៅដល់ ១០៥២ ។ ពង្សាវតារនេះមានកត់ត្រាឈ្មោះបុរោហិតធំ ៗ ទាំងអស់ដែលបានគោរពប្រតិបត្តិក្នុងការរាជការ ព្រមទាំងព្រះនាមស្តេច ដែលបុរោហិតមួយ ៗ នៅធ្វើរាជការគាល់បំរើ, ងារការនឹងទ្រព្យរបស់ដែលបានទទួល, ភូមិនឹងប្រាសាទដែលបានកសាង ។ សេចក្តីទាំងនេះសុទ្ធតែជាការពិតមិនគួរសង្ស័យឡើយ ព្រោះពង្សាវតារនេះមានកស្តុតាងដ៏ច្បាស់ណាស់ នេះហើយដែលយើងមើលឃើញក្នុងសិលាចារឹកខ្មែរ ចែងពីរឿងព្រះបាទយសោវរ្ម័ន ដែលក្រោយមកមានព្រះនាមថា បរមសិវលោក ។

សេចក្តីប្រែខាងក្រោមនេះ គ្រាន់តែជាការជួយណែនាំអ្នកប្រែសិលាចារឹកនោះចេញពីថ្ម ។

មនវ្រះបាទ បរមសិវលោក ចតនគរស្រី យសោ-ធរបុរ នាំកម្រតេង៍ជគតតករាជអិវ ហរិហរាលយ យកធុកនគរនោះមនវ្រះបាទ បរមសិវលោក ស្ថាបនា វិក្រាន្តាល កម្រតេង៍ សិវាស្រម ស្ថាបនា ព្រះលិង្គអៀ

កណ្ដាល ។

ប្រែថា ព្រះបាទបរមសិវលោកសាន(បត)ក្រនយសោធរបុរៈហើយ នាំនូវស្ដេចទេវតា (គម្រតេនជគតគពជ) ចេញពីហរិហរាលយ ទៅដំកល់ ទុកកន្ទក្រនោះ រួចពីនោះព្រះបាទបរមសិវលោកបានសាងភ្នំកណ្ដាល (ភ្នំកណ្ដាល) គឺព្រះគម្លែងសិវស្រមយកព្រះលិង្គទៅដាក់ជាកណ្ដាល ។

ឯភ្នំកណ្ដាល ដែលពាក្យសំស្រ្កឹតហៅថាយសោធគិរី គឺភ្នំយសោ-ធរៈនោះ គ្មានភ្នំឯណាក្រៅពីប្រាសាទបាយ័នទោះឡើយ ។ គេឲ្យឈ្មោះ ថាភ្នំប្រាសាទយ៉ាងនេះដោយភ្នំនេះសាងនៅកណ្ដាលកំផែង ឬកណ្ដាលទី ក្រុងដើម្បីជាតំណាងភ្នំមេរុ ដែលជាភ្នំនៅកណ្ដាលទ្វីប ។ តាមទិទានកន្ទ ក្សនវិជ្ជាផ្សេង ៗ ក្នុងស្រុកឥណ្ឌាថា គឺប្រាកដជាកន្លែងប្រាសាទបាយ័ន ទៅសព្វថ្ងៃនេះហើយ ដែលជាកន្លែងខ្សែបន្ទាត់ដឹកក្រូងដើងក្អែកពីជ្រុង ទាំង ៤ មកជួបគ្នា ។

បើប្រែតាមអក្សរបាលីកនៅស្តុកកក់ធំ បានសេចក្ដីថា ព្រះបាទយសោ-វរ្ម័នបានកសាងអគ្គរធំនឹងបាយ័ន ។

សួរថាចុះព្រះ ដែលព្រះអយ្យកោអយ្យិកាសទាសិវ ធ្លាប់គោរព ប្រតិបត្តិនៅប្រាសាទបាយ័ននោះ តើជាព្រះអ្វី ? ឆ្លើយថាគឺជារូបលិង្គ ។ ត្រង់នេះយើងមិនបាច់ទៅស្រាវជ្រាវរកដើមហេតុឯណា ឲ្យវែងឆ្ងាយទេ ដែលជាការនាំឲ្យស្តុគស្មាញឥតប្រយោជន៍ ព្រោះលិង្គនេះឃើញមានគំរូ

ជាច្រើនណាស់ក្នុងស្រុកបម្យ៉ានិងស្រុកខ្មែរ ។ យើងត្រូវកត់ចំណាំដូច្នេះថា កាលពីយូរមកហើយនោះ មានកាន់សាសនាគោរពប្រតិបត្តិលិង្គដរាបមក វេលានេះ មិនឃើញមានអ្វីជាទីទាស់នឹងសំអាងទាំងនេះឡើយ ។ ប៉ុន្តែ នៅមានកន្លែងមួយទៀត បើមិននាំឲ្យសង្ស័យក៏ហាក់ដូចជាប្លែកបន្ទោះ ដែរ គឺនៅលើសសរថែវបាយ័ន គេឃើញមានរូបព្រះពុទ្ធហើយមាន ថែមពុកចង្ការស្រួចដូចជាឥសី ។ ការណ៍ត្រង់នេះធ្វើឲ្យគេជឿបានថា ក្នុងវេលានោះ ស្តេចដែលសាងប្រាសាទបាយ័ន បានយកជាងដែលកាន់ ព្រះពុទ្ធសាសនាមកជួយសង់ប្រាសាទផង ហើយជាងទាំងនេះក៏បានរចនា នៅទីបន្ទាប់បន្សំនៃប្រាសាទនោះ ជារូបដែលខ្លួនរាប់អាន ក៏ដូចជាស្តេច ដែលចូលចិត្តតុបតែងប្រាសាទព្រះអង្គ ជាបែបដែលព្រះអង្គបានរាប់អាន នោះដែរ ។ លុះយូរក្រោយមក ព្រះទ័យរបស់ស្តេចយសោវរ្ម័ន ដែល ធ្លាប់ប្រកបដោយអធ្យាស្រ័យ ក៏ផ្លាស់ទៅជាព្រះទ័យចង់បំផ្លាញទៅវិញ ដោយព្រះអង្គទ្រង់សព្វព្រះទ័យ តែនឹងរូបតំណាងសាសនាដែលព្រះអង្គ ចូលចិត្តហើយទ្រង់មិនចង់ឃើញមានរូបព្រះពុទ្ធជាប់នឹងប្រាសាទ ក៏តាំង ខំធ្វើបំបាត់រូបទាំងនោះចេញ ។ កន្លែងត្រង់នេះហាក់ដូចជាពិតគ្រាន់បើ ។

ប៉ុន្តែក្នុងឆ្នាំ ១៩២៣ ក៏កើតមានរឿងមួយថ្មីទៀត ជាការថែមទម្ងន់ ទៅលើសេចក្តីសង្ស័យដែលមានស្រាប់មកនោះ ។ ប៉ុន្តែដើម្បីឲ្យងាយ យល់ដល់រឿងនោះ យើងត្រូវបរិយាយបន្តិចអំពីផែនទីប្រាសាទបាយ័ន ។

ប្រាសាទបាយ័នមានរាង ៤ ជ្រុង ធំក្រោមតូចលើ មាន ៣ ថ្នាក់ ថ្នាក់ ២ នៅខាងក្រោម ហើយថ្នាក់ ១ ដែលខ្ពស់ជាងគេនោះមានកំពូលបន្តទៅទៀត ដែលជាកន្លែងសម្រាប់ធ្វើសន្និបាត ។ ប៉ុន្តែកំកណ្ដាលនេះ ទាំងខាងក្រោមទាំងកំពូល មិនធ្វើឲ្យដូចជាផែនទីដំបូងនោះទេ, តាមផែនទីដើម ថែវនៃថ្នាក់ទី ២ នោះត្រូវសង់ព័ទ្ធជុំវិញធ្លាមួយកែងជាជើងក្អែក ហើយត្រូវជាប់ទៅថ្នាក់ក្រោមនៃប្រាសាទនោះ ឯវិសន្និបាតកណ្ដាលនោះ មានទំហំល្មម ។ គ្រប់ទាំងកំពូលថែវទាំងនោះ មានក្លោងទ្វារធ្លាក់ក្បាច់ដំផិតផង នៅកន្លែងកលទីងមានពន្លឺពេញ ។ សព្វថ្ងៃនេះ ក្លោងទ្វារទាំងនោះមើលមិនឃើញឡើយ ។ ចុះដោយហេតុអ្វីបានជាមើលមិនឃើញ គឺថាក្រោយមក ថ្នាក់ខាងលើបានបន្ថែមខ្ពស់ ទីងពង្រីកឲ្យទូលាយ ឡើងទូលាយទៀបទីងប៉ះថែវខាងក្រោមមក គាំទីងក្លោងទ្វារដែលចូលខាងក្រៅ ។ ក្លោងទ្វារទាំងនេះបាត់អស់មើលមិនឃើញ ដោយអំណាចប៉ះផ្ទិតជាប់ទាំងអស់ ឯប៉ះនោះដួនកាលទុករបស់ចាស់ឲ្យនៅ ដួនកាលកាត់ខ្ទះចេញ តាមដោយរបស់ទាំងនោះនៅទាបជាង ឬខ្ពស់ជាងបន្ទាត់ដែលគេប៉ះគ្នានេះ ។

កាលក្នុងឆ្នាំ ១៩២៣ គេបានជីករើកកកាយប្រាសាទបាយ័នតែប៉ុណ្ណោះលុះដល់លោក ប៉ារមង់ទេ ជាអ្នកពិនិត្យប្រាសាទបាយ័ន ចង់មើលក្លោងទ្វារមួយឲ្យច្បាស់ទីងពន្លឺថ្ងៃ ក៏បានឲ្យគេគាស់បំណះដែលប៉ះនៅ

ថ្នាក់ខាងលើដែលបាំងនោះចេញ ហើយក៏បានឃើញទេវតា ១ អង្គឈរលើគ្រួបកណ្ដូក ដៃទាំង ៤ កាន់នូវផ្កា, សៀវភៅ, ផ្កាឈូក និងគ្រឿង ១ ទៀតបាក់ដាច់ប្រហែលដូចជាដប ១ នៅកំពូលមកុដខាងមុខមានព្រះពុទ្ធរូប ១ ។ រូបនេះគ្មានអ្វីធ្វើឲ្យមានការសង្ស័យទេ គឺជារូបពោធិសត្វលោកេស្វរៈ ឬអវលោកេតេស្វរៈ ជាអ្នកទ្រទ្រង់នូវមនុស្សជាតិនិងជាអ្នកធ្វើឲ្យជាជម្មី ។

សួរថាតើក្លោងទ្វារនេះ ឬកតែឯងពីក្លោងទ្វារឯទៀតនៅតជុំវិញកំពូលកណ្ដាលនោះឬអ្វី ? ឆ្លើយថាមិនមែនដូច្នោះឡើយ ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៤

ឧកញ៉ាវិបុលរាជសេនា ង៉ួ-កន ប្រែរៀបរៀង

( តមក )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះខួរបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឡេវហៀនក៏ទូលពាក្យថា ខ្ញុំបាទនឹងនាំបិតាមកជួបនឹងលោកជាក្រោយ ទុងបេងក៏បើកលែងឲ្យឡេវហៀនចូលទៅក្នុងស្រុកវិញ ហើយគេនិយាយសេចក្តីឲ្យបិតាស្តាប់គ្រប់ប្រការ រួចថាឯចិត្តឡេវពីនឹងទុងបេងនេះជាមនុស្សល្អសុភាពរៀបរយគួរសមណាស់ ឡេវគៅបានស្តាប់សព្វគ្រប់ក៏យកទង់សលើកឡើងដោតលើសើនបន្ទាយសំគាល់ថា ស្រុកចំណុះហើយបើកទ្វារគ្រប់ទិសចំហ រួចក៏រៀបចំយកទ្រព្យរបស់ជាបណ្ណាការ នឹងត្រាសម្រាប់ងារ នាំឡេវហៀនជាបុត្រនឹងបណ្តាពួកអ្នកស្រុកទាំងពួងចេញទៅគំនាប់ឡេវពី ទុងបេងក៏យកត្រាសម្រាប់ងារបង្វិលឲ្យឡេវគៅ ហើយថាយើងនឹងឲ្យអ្នកធ្វើជាចៅហ្វាយស្រុកនៅដដែល តែឡេវហៀនជាបុត្រ

នៅក្មេងសេចក្ដីយើងនឹងយកទៅស្រុកកេងដីវជាមួយ នឹងបានជួយធ្វើការតទៅ ខុនបេងក៏នាំឡៅពីនឹងទាហានទាំងពួងចូលទៅស្រុកឡេងឡេង ។

ឡៅពីក៏ប្រាស្រ័យប្រាប់ប្រោមរំលឹក ប្រដៅបណ្ដាពស្រុកនិងស្រុកឲ្យនៅជាសុខតាមប្រក្រតី ហើយថាដែលយើងលើកទ័ពមកនេះក៏បានស្រុកឡេងឡេងហើយ ឯស្រុកហ៊ុយអៀងនោះនរណានឹងអាចយកអាសាចេញទៅវាយឲ្យបាន ជូឡុងក៏ឆ្លើយទទួលសុំអាសា ទៀវហ៊ុយក៏ថា សូមឲ្យលោកប្រើខ្ញុំបាទទៅវិញកុំឲ្យជូឡុងទៅឡើយ ជូឡុងថា ខ្ញុំសុំសរសេរសំបុត្រសញ្ញាទុកជូន នឹងសុំតែទាហាន ៣ ពាន់លើកទៅវាយយកស្រុកហ៊ុយអៀងឲ្យបាន បើមិនបានទេ សុំឲ្យលោកកាត់ក្បាលខ្ញុំបាទវិញចុះ និយាយហើយក៏សរសេរសំបុត្រសញ្ញាជូនទៅឲ្យខុនបេង ខុនបេងក៏ប្រគល់ទាហាន ៣ ពាន់ឲ្យជូឡុង ។

ទៀវហ៊ុយថា ឯសំបុត្រសញ្ញានោះ ខ្ញុំបាទក៏ហ៊ានធ្វើទុកជូនដែរ តែសុំឲ្យលោកប្រើខ្ញុំបាទទៅវិញចុះ បើមិនបានស្រុកហ៊ុយអៀងទេ ខ្ញុំបាទសុំឲ្យលោកសម្លាប់ខ្ញុំបាទចុះ ឡៅពីក៏ស្រែកគំហកឲ្យទៀវហ៊ុយថា កាលជូឡុងព្រមទទួលយកអាសាហើយ បានទាំងសរសេរសំបុត្រទុកជាស្រេច ហេតុម្ដេចក៏មកដែកដណ្ដើមគេដូច្នេះ ទៀវហ៊ុយក៏មិនឆ្លើយតបថាម្ដេច ជូឡុងក៏លាឡៅពី, ខុនបេងលើកទាហាន ៣ ពាន់ចេញទៅច្បាំងយកស្រុកហ៊ុយអៀង ឯបំរើសេះលុះឃើញកងទ័ពលើកមក ក៏នាំ

យកសេចក្តីទៅប្រាប់ទៀវហាមចៅហ្វាយស្រុកហើយអៀនថា ឥឡូវជូឡុង ទាហានឡៀវពីលើកកងទ័ពមកនឹងច្បាំងយកស្រុកយើង ៗ

ទៀវហាមបានឮដូច្នោះ ក៏ប្រឹក្សានឹងទាហានទាំងពួងថា យើងនឹងគិតប្រការម្តេច តនអេងនឹងចៅឡុងនាយទាហានឆ្លើយថា ដែលឡៀវពីលើកទ័ពមកនេះ ខ្ញុំនឹងសុំយកអាសាលើកទាហានចេញទៅច្បាំងកំនត់ទល់មិនឲ្យរវល់ដល់អន្តរាយស្រុកឡើយ ទៀវហាមតបថា អ្នកកុំអាលមើលងាយប្រមាថឡៀវពីដូច្នោះ ព្រោះឡៀវពីនោះជាពូជព្រះវង្សព្រះចៅហៀនតេ មានតម្រិះប្រាជ្ញាជាសុចរិតពិតត្រង់ល្អណាស់ ទាំងគួនអ៊ូ, ទៀវហ៊ុយ, ជូឡុងក៏មានប្ញទ្ធិដៃខ្លាំងពូកែជាទាហានឯក, ឥឡូវឡៀវពីប្រើជូឡុងឲ្យលើកកងទ័ពមកនឹងយកស្រុកយើង ឯជូឡុងនោះក៏មានកំឡាំងខ្លាំងពូកែណាស់ គ្រាបូជូលើកទាហានប្រមាណ ១០០ ម៉ឺនមកដល់ពលទៀនបាន់ប៉ោ ជូឡុងបានតច្បាំងទំលាយកងទ័ពចូលចេញដោយស្រួលហាក់បីដូចនៅកណ្តាលពលគ្មានទាហានសោះ ដែលអស់អ្នកនឹងអាចហ៊ានចេញទៅតស៊ូនោះមុខជាមិនបាន ព្រោះទាហានយើងក៏តិចផង យើងត្រូវគិតគ្នាចេញទៅអង្វរលេនតួសុំចុះចូល ទើបនឹងបានសេចក្តីសុខតទៅ តនអេងឆ្លើយថា ខ្ញុំបាទនឹងសុំយកអាសាចេញទៅច្បាំងមើលម្តងសិន បើតទល់មិនឈ្នះសឹមចេញទៅចំណុះចុះចូលជាក្រោយ ទៀវហាមតបបណ្តោយថា តាមចិត្តចុះ តនអេងក៏ចាត់ចែងទាហានលើកចេញទៅជិតបន្ទាយជូឡុង ៗ

ឯដូឡុងឃើញដូច្នោះ ក៏ជិះសេះកាន់លំពែងចេញទៅឃាត់មុខទា-ហាន ហើយស្រែកថា ខ្លួនអញជាទាហានឡៅពី ៗ នោះជាពូជព្រះវង្ស ហើយក៏ជាប្អូនឡៅតៀវដែលទើបស្លាប់ គ្រានេះឡៅពីទំនុកបំរុងឡៅគីជាក្មួយ ហើយប្រើអញលើកកងទ័ពមកប្រាបប្រាមស្រុកហ៊ុយអៀងដែលត្រូវឡើងស្រុកកេងជីវ ហេតុម្តេចក៏ឯងចេញមកតស៊ូនឹងអញដែលមានថ្វីដៃនេះ ឯងមិនខ្លាចសេចក្តីស្លាប់ទេឬ ? ត័នអេងឆ្លើយតបថា ឯស្រុកហ៊ុយអៀងនេះត្រូវឡើងដល់ស្រុកកេងជីវក៏មែន តែឥឡូវឡៅតៀវក៏ស្លាប់ទៅហើយ ទៀវហាមចៅហ្វាយអញទើបលើកស្រុកនេះទៅប្រគល់ឲ្យចូឆូ ឯងកុំអួតថាមានថ្វីដៃនោះអញមិនកោតខ្លាចនឹងទៅចំណុះចុះចូលឡៅពីនោះទេ ដូឡុងឮដូច្នោះក៏ខឹងណាស់ បរសេះរាំលំពែងចូលច្បាំងនឹងត័នអេងបាន ៤ ភ្លែង ត័នអេងទ្រកំឡាំងនឹងដូឡុងមិនបានក៏ញាក់សេះថយរត់ ដូឡុងក៏បំផាយសេះតាមទៅទាន់ចាប់ខ្លួនត័នអេងបាន ឲ្យទាហានចងទុក ឯទាហានត័នអេងរត់បែកខ្ញែកទៅអស់ ដូឡុងឲ្យស្រាយចំណងចេញ ហើយនិយាយនឹងត័នអេងថា យើងមិនសម្លាប់ជីវិតខ្លួនទេ យើងលែងឲ្យខ្លួនវិលទៅយក សេចក្តីចូលទៅប្រាប់ទៀវហាមចៅ-ហ្វាយស្រុក ឲ្យប្រញាប់ចេញមកអង្វរលន់តួចំណុះយើងដោយល្អចុះ បើរឹងទទឹងហើយ តែយើងចូល ទៅក្នុងស្រុកបានកាលណា យើងនឹងសម្លាប់ឲ្យអស់ទាំងបុត្រភរិយា ត័នអេងមានសេចក្តីត្រេកអរណាស់ ទទួលពាក្យ

ជូឡុងហើយក៏គំនាប់លាត្រឡប់ទៅវិញ ទើបយកសេចក្ដីនោះទៅអធិប្បាយឲ្យទៀវហាមស្ដាប់ ទៀវហាមថា យើងបានហាមប្រាមហើយ អ្នកក៏មិនព្រមស្ដាប់ពាក្យយើង ចំតែចប៉េងនាំទាហានចេញទៅតស៊ូនឹងជូឡុងទាល់តែបានសេចក្ដីដូនជាបរាជ័យសដូច្នេះ ហើយទៀវហាមក៏រៀបចាត់ចែងរបស់មាសប្រាក់ជាបណ្ណាការ នឹងត្រាសម្រាប់ងារឲ្យទាហានប្រមាណ ១៤ នាក់ នាំចេញទៅគំនាប់ជូឡុង ៗ ក៏ទទួលយករបស់នឹងត្រាទុកហើយអញ្ជើញទៀវហាមឲ្យឡើងតុបរិភោគអាហារ ៗ

ខណៈកាលកំពុងបរិភោគផឹកស្រានោះ ទៀវហាមក៏និយាយថា លោកនឹងខ្ញុំជាសែជាមួយគ្នា ហើយក៏ជាអ្នកស្រុកជិនតែងដូចគ្នា ដែលខ្ញុំបានធ្វើលើសខុសធ្ងន់ប៉ុណ្ណោះ សូមកុំប្រកាន់ទោសខ្ញុំឡើយ ខ្ញុំសូមលោកទុកជាបងប្អូននឹងគ្នាតាមសែតទៅ ជូឡុងមានសេចក្ដីត្រេកអរណាស់ ក៏សួរសាកខែឆ្នាំកំណើតនឹងអាយុ ជូឡុងក៏ឃើញថាចាស់ជាងទៀវហាម ៤ ខែ ទៀវហាមក៏ហៅជូឡុងថាបង លុះវេលាព្រឹកឡើង ទៀវហាមក៏នាំជូឡុងនឹងទាហានជូឡុងប្រមាណ ១០ នាក់ចូលទៅក្នុងស្រុក ជូឡុងនិយាយប្រាប់ប្រាមទូន្មានប្រដៅអស់បណ្ដាអ្នកស្រុក ឲ្យនៅជាសុខក្សេមក្សាន្តតាមប្រក្រតី ទៀវហាមក៏អញ្ជើញជូឡុងចូលទៅបរិភោគអាហារខាងល្ងងក្នុង ខណៈកាលកំពុងសេពសុរានោះទៀវហាមក៏ហៅបងថ្លៃស្រីចេញមកគំនាប់ជូឡុង ៗ ឃើញស្រីនោះមានរូបរាងល្អ ក៏សួរថា នាងនេះឈ្មោះអ្វី?

ត្រូវជាម្តេចនឹងអ្នក? ទៀវហមឆ្លើយថា ស្រីនេះឈ្មោះនាងហួនស៊ីជាភរិយា ទៀវហ័បបងខ្ញុំបាទ ឥឡូវបងខ្ញុំស្លាប់ហើយ ដូឡុងថាបងថ្លៃអ្នកជាធំដែល នឹងឲ្យមកគំនាប់ខ្ញុំមិនគួរ ហើយដូឡុងក៏និយាយឲ្យនាងហួនស៊ី វិលចូលទៅក្នុងវិញ នាងហួនស៊ីក៏លាចូលទៅវិញ ទៀវហមក៏និយាយនឹងដូឡុងថា ទៀវហ័បបងខ្ញុំបាទស្លាប់ ៣ ឆ្នាំទៅហើយ ខ្ញុំបាទបាននិយាយប្រាប់នាងហួនស៊ីឲ្យមានប្តីថ្មី នាងហួនស៊ីថា បើមានអ្នកណារូបស្អាតល្អ ហើយមានតម្រិះប្រាជ្ញាប្រការ ១, មានថ្វីដៃខ្លាំងពូកែល្បីល្បាញប្រការ ១, ជាសែជាមួយនឹងខ្មោចស្វាមីមុនប្រការ ១, បើបានព្រមទាំង ៣ ប្រការនេះទើបនាងហួនស៊ីព្រមយកធ្វើជាស្វាមី ឥឡូវខ្ញុំបាទឃើញលោកមានលក្ខណៈព្រមទាំង ៣ ប្រការ ដូចសេចក្តីប្រាថ្នានាងហួនស៊ីប្តេជ្ញាទុកមកហើយ លោកក៏មិនទាន់មានភរិយា បានជាខ្ញុំបាទឲ្យចេញមកគំនាប់ ប្រាថ្នានឹងលើកជូនជាភរិយានៃលោក ដូឡុងឮដូច្នោះក៏ខឹងណាស់ ក្រោកឡើងស្រែកគំហកហើយថា ខ្លួនអ្នកនឹងខ្ញុំរាប់អានគ្នាថាជាបងប្អូនព្រោះសែជាមួយ ឯនាងហួនស៊ីជាបងថ្លៃនៃអ្នកស្រាប់មកហើយ ក៏ដូចជាបងថ្លៃខ្ញុំដែរ ហេតុម្តេចអ្នកមកគិតធ្វើដូច្នេះនឹងមិនខុសទម្លាប់ទំនៀមទេឬ? ទៀវហមបានឮដូច្នោះក៏មានសេចក្តីអៀនខ្មាសក្នុងចិត្តណាស់ ទើបញាក់មុខឲ្យទាហានដែលបំរើជិតខាងនោះគិតធ្វើអន្តរាយដល់ដូឡុង ។ ឃើញដូច្នោះក៏រឹតតែខឹងណាស់ទៅទៀត ស្ទុះទៅទាត់ទៀវហមដួលសន្លប់ទៅ ហើយ

ជូឡុងក៏ចេញមកឡើងសេះនាំទាហានប្រមាណ១០នាក់ត្រឡប់មកបន្ទាយ ទៀវហាមប្រឹក្សានឹងតន់អេង, ចៅឡុង ថា ឥឡូវជូឡុងទឹងនឹងខ្ញុំ បើខ្ញុំនឹងលើកទាហានទៅតស៊ូជាសង្គ្រាម ជូឡុងក៏មានថ្វីដៃខ្លាំងពូកែណាស់ ឃើញថានឹងតស៊ូគេពុំបានទេ អ្នកទាំង ២ នឹងយល់ឃើញថាប្រការម្ដេច? តន់អេង, ចៅឡុងថា ខ្ញុំបានសុំលើកទាហាន ៥០០ ធ្វើជាចូលទៅនៅនឹងជូឡុង រួចឲ្យលោកលើកទ័ពចេញទៅ បើជូឡុងនឹងលើកទ័ពមកច្បាំងនឹងលោក ខ្ញុំបាទទាំង ២ នឹងចាប់ជូឡុងសម្លាប់ចេញ ទៀវហាមយល់ឃើញត្រូវ តន់អេង, ចៅឡុងក៏លើកទាហាន ៥០០ទៅដល់បន្ទាយ ហើយប្រាប់ទាហានជូឡុងថា យើងទាំង ២ នឹងសុំចូលទៅគំនាប់ជូឡុងទាហានក៏ចូលទៅជំរាបជូឡុង ។ ជូឡុងក៏គិតថា តន់អេង, នឹងចៅឡុងមកនេះ ប្រាថ្នាប្រឹងបញ្ឆោតយើងតែត្រូវយើងឲ្យចូលមកចុះ សឹមយើងរិះគិតចាប់ខ្លួនសម្លាប់ចេញឲ្យបាន ហើយជូឡុងឲ្យទាហានទៅហៅខ្លួនតន់អេង, ចៅឡុងចូលមក ឈ្មោះទាំង ២ ក៏ចូលទៅគំនាប់ជូឡុង ហើយថាយើងទាំង ២ ឃើញទៀវហាមធ្វើសេចក្ដីមិនគួរសមដល់លោក បើខ្ញុំបាទនឹងនៅស្ងៀមក្នុងស្រុកក៏ឃើញថាស្លាប់ជាមួយគ្នា បានជាខ្ញុំនាំគ្នាចេញមកគំនាប់លោក ប្រាថ្នានឹងនៅពឹងបុណ្យធ្វើជាបាវលោកតទៅ ជូឡុងឮហើយធ្វើជាត្រេកអរពេះកាយ យកសំពត់ព្រែ១អាវឲ្យតន់អេងនឹងចៅឡុងជាបំណាច់ ហើយឲ្យតែងតុលៀងអាហារផឹកស្រា ខណៈនោះ

ត័នអេង, ចៅឡុងជាមនុស្សមិនសូវចេះគិត ផឹកស្រាស្រវឹងហួសលើសកំឡាំងដេកលក់ទៅ ជូឡុងក៏ឲ្យទាហានចាប់ចងទាំងពីរនាក់ ហើយឲ្យចាប់ពួកទាហានទាំង ៥០០ ចង ហើយកំហែងសួរថា ដែលនាយឯងទាំងពីរនាក់ចូលមករកអញពេលានេះថាមកដោយជា ឬកាច វៀច ឬត្រង់ប្រការម្តេច ឲ្យឯងឆ្លើយឲ្យត្រង់ បើកុហកអញ ។ នឹងសម្លាប់ទាំងអស់គ្នា ទាហានទាំងអស់ភ័យខ្លាចក៏ឆ្លើយថាជាកលឧបាយវៀចទេ ។

ជូឡុងឮដូច្នោះ ក៏ឲ្យយកខ្លួនត័នអេង, ចៅឡុងទៅប្រហារជីវិត ហើយឲ្យស្រាយចំណងពួកទាហានទាំងអស់ចេញទុកឲ្យនៅធ្វើការជាមួយ ហើយនិយាយថា ដែលត័នអេង, ចៅឡុងមកប៉ងនឹងប្រទូសរ៉ាយយើង ។ ក៏ឲ្យសម្លាប់ចេញហើយ តែអ្នកពល់គ្នាជាអ្នកតូច តាមមកដោយស្តាប់បង្គាប់គេ យើងក៏ទុកជីវិតឲ្យរស់, ត្រូវវិលទៅកាន់បុត្រករិយាវិញចុះ បើអ្នកពល់គ្នាវៀចនឹងយើងៗ ឲ្យសម្លាប់ចេញទាំងអស់ ពេលយប់នេះយើងលើកពួលទៅលុកយកស្រុកហ៊ុយអៀង ត្រូវអ្នកពល់គ្នាចេញទៅជាទ័ពស្រួច ហៅអ្នកចាំទ្វារឲ្យបើកទទួលជាបានឬទេ? ពួកទាហានទាំងនោះក៏ត្រេកអរសាទរនាំគ្នាទទួលតាមពាក្យជូឡុង លុះពេលកណ្តាលយប់ ជូឡុងក៏លើកទាហានចូលទៅជិតជើងកំផែងស្រុកហ៊ុយអេង ឯពួកទាហានទាំង៥០០ ក៏នាំគ្នាស្រែកហៅអ្នកចាំទ្វារថា ត័នអេង, ចៅឡុងចាប់ជូឡុងបានសម្លាប់ទៅហើយ ឲ្យប្រញាប់បើកទ្វារនឹងចូលទៅវិញ ដើម្បីនឹង

យកសេចក្តីទៅដំកបទៀវហាមឲ្យជ្រាប ។

ឯទាហានលើសើនបន្ទាយ បានឮសំឡេងច្បាស់ ក៏បំភ្លឺភ្លើងមើលមុខឃើញថា ជាពួកទាហានខាងខ្លួនដែលចេញទៅជាមួយនឹងតាន់អេង, ប៉ៅឡុង ក៏មានចិត្តត្រេកអរព្រោះមិនដឹងកលជូឡុង ក៏នាំគ្នាទៅដំកបទៀវហាម ។ ឮដូច្នោះក៏នាំទាហានចេញទៅទទួលតន់អេង, ប៉ៅឡុង ជូឡុងក្រឡេកឃើញក៏បរសះចូលទៅចាប់ខ្លួនទៀវហាមបាន ឲ្យទាហានចងបំណងទុកហើយលើកចូលទៅប្រកាសប្រាប់បណ្តាពស្ត្រក្នុងស្រុក កុំឲ្យកិតភ័យថាយើងមិនបានធ្វើអ្វីឲ្យអន្តកាយទេ លុះវេលាព្រឹកឡើង ជូឡុងក៏ឲ្យធ្វើសំបុត្របកប្តឹងទៅដល់ឡៅពី, ខុងបេង ។ ដឹងក្នុងសំបុត្រសព្វគ្រប់ ក៏ត្រេកអរណាស់ ចាត់ចែងទាហានហើយក៏លើកទៅឯស្រុកហ៊ុយអេង ជូឡុងក៏ចេញមកទទួលឡៅពី ខុងបេងចូលទៅក្នុងស្រុក ហើយឲ្យនាំខ្លួនទៀវហាមមកជូនឡៅពី ។

(នៅមានត)

## រឿងមនុស្សចិត្តប្រែប្រួល

## ឃុនបណ្ណានុរក្ស ប៊ូ - ប៉ូ រៀបរៀង

(តមក)

---

អ្នកតាកើត- អើ! ឪអរតែឯងមិនយកប្រពន្ធ, ប៉ុន្តែក្រែងដូចពាក្យចាស់លោកថា ស្វាស្លាប់ព្រោះធ្លាក់ពីចុងឈើ ក្រពើស្លាប់ព្រោះលង់ទឹក យ៉ាងនេះដឹង? មួយទៀតកាលអញនៅបួសនៅឡើយ អញបានមើលរឿងមួយក្នុងគម្ពីរនិបាតជាតកបាលី និយាយពីប្រុសស្អប់ស្រី មិនព្រមឲ្យស្រីណាប៉ះពាល់ដល់សាច់សោះ កាលនៅពីក្មេងតូច សូម្បីតែម្ដាយបីពក៏មិនបានដែរ ស្រាប់តែខាងក្រោយប្រែចិត្តស្រឡាញ់ស្រីវិញ ស្រឡាញ់ខ្លាំងណាស់ ទាល់តែវង្វេងស្មារតី បើឯងចង់ស្ដាប់រឿងនេះ អញដំណាលឲ្យស្ដាប់តាមចាំមក ។

ដីប្រែ- បាទ! ខ្ញុំចង់ស្ដាប់ដែរ ឪដំណាលទៅចុះ ។

អ្នកតាកើត- ចាប់និយាយអំពី ៖

## ២- រឿងប្រុសស្អប់ស្រី

កាលកន្លងរំលងទៅជាយូរអង្វែងហើយ មានព្រះមហាក្សត្រាធិរាជមួយអង្គ ព្រះនាមព្រះបាទព្រហ្មទត្តគ្រប់គ្រងនគរពារាណសី ព្រះអង្គគ្មានព្រះរាជបុត្រាបុត្រីមួយអង្គតព្រះរាជវង្សសោះ ទើបទ្រង់ត្រាស់ប្រាប់ព្រះអគ្គមហេសីនិងស្រីស្នំក្រមការផងទាំងពួង ឲ្យរៀបគ្រឿងសក្ការបូជាព្លីការបួងសួងទេវតាសុំបុត្រ ៗ ព្រះអគ្គមហេសីនិងស្រីស្នំទាំងអស់ មាន

សេចក្តីកេកយណាស់ ព្រោះសុទ្ធតែចង់បានបុត្រដូចគ្នា ក៏ចាត់ចែងពីការបួងសួងទេវតាសុំបុត្រ ៗ

គ្រានោះ ព្រះបរមពោធិសត្វច្យុតពីព្រហ្មលោកមកចាប់បដិសន្ធិក្នុងផ្ទៃព្រះអគ្គមហេសី លុះគ្រប់ទសមាសហើយ ប្រសូតមកជាទារក កាលលាងទឹកដុសសំអាតមន្ទិលរួចស្រេច ស្រីស្នំក្រមការទទួលយកទៅបីបមថ្នមរក្សា ៗ ព្រះរាជកុមារទ្រង់ព្រះកន្សែងយ៉ាងខ្លាំង សូម្បីព្រះវរមាតាយកទៅបី ក៏រឹតតែស្រែកខ្លាំងឡើងទៀត ស្រីណាបីក៏មិនស្ងៀមសោះ ទាល់តែប្រគល់ឲ្យពួកអាមាត្យប្រុស ៗ បីវិញទើបស្ងៀម ៗ ព្រះវរបិតាទ្រង់ជ្រាបច្បាស់ថា កុមារនេះមិនព្រមឲ្យស្រីចាប់ពាល់ដល់សាច់ខ្លួនទេ សូម្បីតែម្តាយខ្លួនក៏បីមិនបានដែរ បានជាចេះតែស្រែកយំលួងមិនស្ងៀមសោះ ទាល់តែឲ្យទៅពួកប្រុស ៗ បីទើបស្ងៀមឈឹង ទ្រង់យល់យ៉ាងនេះហើយ ទើបសន្មតនាមព្រះរាជបុត្រថា អនិត្ថិគន្ធកុមារ បានសេចក្តីថា កុមារមិនចង់ឲ្យធុំក្លិនស្រ្តី ឬថាកុមារស្អប់ស្រី ៗ ចាប់តាំងពីថ្ងៃនោះមក ទ្រង់ប្រគល់ព្រះរាជបុត្រឲ្យពួកបរិវារប្រុស ៗ បីបមថ្នមរក្សា ពួកប្រុស ៗ នោះប្រញាប់យកទឹកដោះពីស្រី ៗ មកបញ្ចុកព្រះរាជកុមារខ្លះ, យកសំពត់គ្របបិទដោះឲ្យជិត ទុកបន្តិចតែចុងដោះបន្តិច ឲ្យព្រះរាជកុមារបៅខ្លះ, ចោះប្រហោងកំពែងហើយ ឲ្យស្រីនៅក្នុងកំពែង បន្តិចតែចុងដោះតាមប្រហោង ឲ្យព្រះរាជកុមារជញ្ជក់ខ្លះ ។ លុះព្រះរាជ

កុមារកាន់តែចំរើនវ័យធំឡើង ព្រះរាជបិតាឲ្យសង់ដំណាក់មួយនៅទីវាល ស្ងាត់ដាច់ពីផ្ទះអ្នកទាំងពួង ហើយទ្រង់ហាមប្រាមមិនឲ្យស្រី ៗ ចូលទៅក្នុងដំណាក់នោះសោះ ឲ្យសុទ្ធតែបរិវារប្រុស ៗ នៅជាមួយនាំក្រសាលទាំងថ្ងៃទាំងយប់ ៗ

លុះចំណេរចរកាលយូរមក ព្រះរាជកុមារចំរើនវ័យធំឡើង បានព្រះជន្ម ១៦ ឆ្នាំគ្រប់ការហើយ ព្រះវរបិតាទ្រង់នឹកព្រួយព្រះទ័យថា អញមានបុត្រតែមួយគត់គ្មានបុត្រឯណាទៀតសោះ ឥឡូវបុត្រតែ ១ នេះបានអាយុ ១៦ ឆ្នាំ ល្មមឲ្យសោយរាជ្យជួសខ្លួនអញហើយ ប៉ុន្តែធ្វើម្តេចកូននេះព្រមទទួលសោយរាជ្យ បើគ្រាន់តែឃើញស្រីមិនបានផង បើដូច្នេះ អញនឹងឲ្យពួកស្រីក្រមុំ ៗ ចូលទៅប្រលោមលួងលោមកូនអញល្បងមើលក្រែងប្រែចិត្តបេះស្រឡាញ់ស្រីវិញ លុះទ្រង់ព្រះចិន្តាថាដូច្នេះហើយ ត្រាស់បង្គាប់រាជអាមាត្យឲ្យស្រាវជ្រាវរើសរកស្រីក្រមុំរូបល្អ ៗ ចូលទៅលួងលោមព្រះរាជកុមារ ៗ អាមាត្យទាំងនោះទទួលព្រះរាជឱង្ការហើយ ក៏ស្រាវជ្រាវរកស្រីក្រមុំរូបល្អ ៗ អាយុ ១៥ ឬ ១៦ ឆ្នាំ ប្រាប់ឲ្យឪពុកម្តាយស្អិតស្អាងកូនហើយជូនមកឯដំណាក់ព្រះរាជបុត្រ ៗ ឯនាងក្រមុំទាំងនោះសុទ្ធតែល្អ ៗ ទ្រង់ទ្រាយសក្តិសមហាក់ដូចរូបគំនូរដែលជាងគូររាស នាងខ្លះរាងស្តើងខ្ពស់ ចង្កេះរៀវស្លួចមូលក្លំ សមនឹងទ្រគាករកសាយ ភ្លៅមូលសត្រសូលដូចបណ្តូលចេក ដោះក្បំដូចផ្លែទន្សាមផ្ទាប់នឹងទ្រូង មុខមូល

ក្រឡន់ដូចវង់ព្រះចន្ទ្រា ថ្ពាល់ពេញកំពុងសមនឹងប្រមុះ សក់ខ្មៅស្រិល បំពោមមូលខ្នង់ដូចដងផ្ចុ បបូរមាត់ក្រហមដូចដិតស្វា ប្រុសណាឃើញ ស្ងើរវង្វេងបាត់ស្មារតី នាងខ្ទះកង់ធាត់ទាបទ្រនាប់ សម្បុរសណ្ដែកបាយ មុខជ្រុងថ្ពាល់ពេញប្រមុះស្រួច ម្រាមដៃដូចបន្លាក្រូច កំភួនជើងតូចរៀវ ដូចត្រយូងចេក ចង្កេះអែនង់ស្ដួត ទ្រូងតើង ដោះធំខ្ដោល ប្រុសឃើញ គួរឲ្យស្រើបស្រាលចិត្ត ៗ នាងខត្តិយនារីទាំងអស់នោះប្រាថ្នាចង់បាន ព្រះរាជកុមារធ្វើជាស្វាមីគ្រប់ ៗ អង្គ ខំតាក់តែងស្អិតស្អាងរាងកាយ យ៉ាង ផិតផង់ ស្លៀកពាក់សំពត់អាវលើបលន់ស្ដើង ៗ មើលសាច់ឃើញ បើមើលពីចម្ងាយ ហាក់ដូចជាលែងខ្លួនទទេ ៗ

គ្រានោះ ពួករាជអាមាត្យនាំនាងកញ្ញាដែលល្អឆើតឆាយដាច់គេ ចូលទៅក្នុងប្រាសាទមុនកញ្ញាឯទៀត អង្គុយចាំព្រះរាជកុមារនៅល្វែងខាងមុខ មួយស្របក់ស្រាប់តែទ្វារបន្ទប់បើកចេញ លេចព្រះរាជកុមារឆ្ពោះមក អ្នកបំរើប្រុសកំឡោះ ៗ ទាំងអស់នាំគ្នាក្រោកឈរស្រេក ៗ ក្នុងចំណោមប្រុសនោះ មានតែស្រីក្រមុំម្នាក់ក្រោកឈរតាមគេដែរ នាងងើបមើលទៅចំព្រះភក្ត្រព្រះរាជកុមារហើយនាងញញឹមពព្រាយ ៗ ឯព្រះរាជកុមារទតឃើញច្បាស់ជាស្រីហើយ មិនត្រាស់ថាអ្វីសោះ យកព្រះហស្ដទាំងពីរខ្ទប់ព្រះភក្ត្រវិលចូលក្នុងបន្ទប់វិញភ្លាម ហើយប្រើបំរើម្នាក់ឲ្យមកនាំនាងកញ្ញានោះចេញទៅខាងក្រៅមួយរំពេច ៗ រាជអាមាត្យយករឿងនេះទៅ

ក្រាបទូលព្រះមហាក្សត្រិយ៍ ព្រះអង្គរឹតតែព្រួយព្រះទ័យខ្លាំង ។

ក្នុងនគរនោះ មានស្រីប៉ុម្នាក់នៅក្រមុំអាយុ ១៦ ឆ្នាំ ជាតិជារាស្ត្រធម្មតា រូបឆោមលោមពណ៌ល្អឆើតឆាយ ចេះរាំចេះច្រៀងយ៉ាងស្ទាត់ ចាំងសំឡេងក៏ពីរោះ នាងឮគេដំណាលពីព្រះរាជកុមារថាស្អប់ស្រីណាស់ក៏គិតថា អញនឹងផ្ចាញ់ផ្ចាលព្រះរាជកុមារយកធ្វើជាស្វាមីឲ្យបាន ទើបនាងចូលទៅរកពួកអាមាត្យ ឲ្យនាំនាងចូលទៅគាល់ព្រះមហាក្សត្រិយ៍ ក្រាបទូលថា សូមព្រះអង្គកុំព្រួយព្រះទ័យ ខ្ញុំម្ចាស់ធានាធ្វើឲ្យព្រះរាជកុមារស្រឡាញ់ស្រីបាន សូមព្រះអង្គអនុញ្ញាតឲ្យខ្ញុំម្ចាស់ចូលទៅធ្វើចុះ ។

នាងឯងគិតធ្វើដូចម្ដេច បើស្រីក្រមុំមុន ៗ រូបល្អជាងនាងឯងទៅទៀត ម៉េចក៏នៅតែរាជកុមារមិនស្រឡាញ់សោះ ឲ្យគេបណ្ដេញចេញអស់ ។

ក្រាបទូល ! មកពីនាងមុន ៗ នោះ មិនយល់ចិត្តប្រុស មិនចេះធ្វើកិច្ចកលមាយាឲ្យប្រុសស្រើបស្រាល ឲ្យស្គាល់នូវរសសេវនកិច្ច(១) បើស្គាល់ហើយមុខជាជាប់ជក់ព្រះទ័យស្រឡាញ់ស្រីលែងស្អប់សោះ ។

បើដូច្នោះ នាងឯងទៅធ្វើតាមដំរេះប្រាជ្ញាចុះ បើរាជបុត្រព្រមស្រឡាញ់នាងឯង យើងនឹងតាំងនាងឲ្យធ្វើជាអគ្គមហេសីអភិសេករាជបុត្រឲ្យសោយរាជសម្បត្តិស្នងខ្លួនយើង ។

នាងបានឮដូច្នោះត្រេកអរណាស់ ថ្វាយបង្គំលាថយចេញមកក្រៅ

---

១- ន ម អានថា សេ-វៈ-នៈ-កិច្ច ការរួមដំណេកគ្នា ។

គិតថា អញមុខជាបានធ្វើអគ្គមហេសីព្រះរាជកុមារមិនខាន ទើបនាងចូលទៅនិយាយផ្ដែផ្ដាំប្រុសកំឡោះ ៗ អ្នកបំរើព្រះរាជកុមារថា យប់នេះដល់វេលាជិតភ្លឺ ខ្ញុំនឹងមកប្រៀងនៅរបៀងក្រៅប្រាសាទក្បែរក្រឡាបន្ទំព្រះរាជបុត្រ បើព្រះរាជបុត្រត្រូវខ្ញុំប្រៀងហើយខ្ញាល់ប្រើគេឲ្យបណ្ដេញខ្ញុំ ៗ ក៏រត់គេចចេញទៅ បើព្រះអង្គសព្វព្រះទ័យទ្រង់ព្រះសណ្ដាប់ចម្រៀងខ្ញុំ សូមអ្នកពល់គ្នាប្រាប់ខ្ញុំឲ្យដឹងសេចក្ដីផង ផ្ដាំរួចហើយលាគេទៅផ្ទះខ្លួនវិញ ៗ នាងនាដជាស្រីក្រមុំអ្នករបាំមែន ប៉ុន្តែជាស្រីល្អបរិសុទ្ធណាស់ មិនដែលមានប្រុសណាប៉ះពាល់ដល់ខ្លួននាងទេ បានជានាងហ៊ានទទួលយកអាសាចូលទៅប្រលោមលួងលោមព្រះរាជកុមារនោះ ព្រោះនាងចេះស្ទាត់ខាងកិច្ចកលមាយាស្រីអាចធ្វើចិត្តប្រុសឲ្យស្រើបស្រាល ដោយសារសំឡេងប្តូកក្បាច់ក្បួនរបស់នាង ៗ ពេលយប់នោះ ជិតភ្លឺព្រឹកព្រាងស្វាងព្រះសុរិយា នាងនាដចូលទៅអង្គុយនៅរបៀងក្រៅប្រាសាទក្បែរក្រឡាបន្ទំព្រះរាជកុមារ ចាប់ដេញពិណតាំងស្រែកប្រៀងជាបទបំពេថា -

ស្រណោះយប់ស្ងាត់ មនុស្សសត្វដេកស្ងប់ បងអង្វែល
អូន ដោយចិត្តស្នេហា ៗ ខ្មើយមួយពីរនាក់ ពន្លាក់កាយា
បង្អើតអស្ចារ្យ ភ្ញៀងផ្គររងំ ៗ នាគរាជលេងទឹក បោកបាចផ្ទ្រាំ
ព្យុះស្ទើររលំ រលើងគ្រឹះស្ថាន ៗ កុំថាតែមនុស្ស ទោះសត្វ
តិរច្ឆាន គង់តែបង់បាន រូបរសនិងពៀ ៗ

ព្រះរាជកុមារឮចម្រៀងនាងនាដលន្លង់លន្លោច សំឡេងស្រួយស្រេះស្របនឹងសំឡេងពិណ ក៏កើតព្រះទ័យព្រឺព្រួចស្រងេះស្រងោច នឹកឆ្ងល់ថាប្រុសស្រីស្រឡាញ់គ្នាធ្វើអ្វី ក៏ខំផ្ទៀងស្ដាប់ទាល់តែក្លីច្បាស់ នាងនាដឈប់ច្រៀងទៅផ្ទះវិញ ៗ លុះព្រឹកឡើងព្រះរាជកុមារសាកសួរជ្រាបរឿងនោះហើយត្រាស់ផ្ដាំអ្នកបំរើថាយប់នេះឲ្យនាងនោះមកច្រៀងក្នុងប្រាសាទទៀត ៗ អ្នកបំរើទៅប្រាប់នាងនាដ ៗ ត្រេកអរណាស់នឹកថា បានការហើយអញ ៗ ឯព្រះមហាក្សត្រិយ៍បានជ្រាបដំណឹងនេះ ក៏រីករាយព្រះទ័យយ៉ាងខ្លាំង ៗ លុះដល់ពេលយប់ពាក់កណ្ដាលអធ្រាត្រ ព្រះរាជកុមារឈប់ត្រសាលចូលផ្ទំហើយ នាងនាដចូលទៅក្នុងប្រាសាទ អង្គុយនៅល្វែងក្រៅខាងមុខ តាំងដេញពិណស្រែកច្រៀងជាបទបន្ទោលកាកថា ៖

ខ្ញុំជាស្រី ស្វែងរកស្វាមីរួមប្រាណ ឲ្យកើតសុខសាន្ត
ទើបបានហៅពេញជាស្រី ។ ឯប្រុសទាំងឡាយ ត្រូវតែខ្វល់
ខ្វាយមេត្រី រួមរសបេតី ជាមួយនឹងស្រីទើបសុខ ។ កើតកាល
វិលគុម្ព ត្រជាក់ត្រជំស្រណោក គ្មានអ្វីឲ្យស្អក - ស្អុតលើសរូប
ស្រីទៀតទេ ។ សប្បាយភ្លេចស្លាប់ ហានដល់សម្លាប់ប្ដីគេ
ជាប់ចិត្តស្និតទេ្វ បេះតែរីកធំរាល់ថ្ងៃ ។ ចិត្តប្រុសគ្រប់គ្នា ឥត
គិតជាក្សេណក្ស័យ គិតតែអាល័យ រលឹកដល់ស្រីសម្លាញ់ ។

ស្អិតដួចតាំងម៉ែ ចាប់ចិត្តស្និទ្ធស្នេហ៍ត្របាញ់ នឹកដល់រសធ្លាញ់
រឹតតែស្រឡាញ់ខ្លាំងណាស់ ៗ រឹតក្នុងលោក មានច្រើនគ
គោកឥតខ្វះ ប៉ុន្តែមិនច្បាស់ ដូចរូបស្រីផងទាំងពួង ៗ

ព្រះរាជកុមារទ្រង់ព្រះសណ្ដាប់ចម្រៀងដល់ត្រឹមនេះត្រិះរិះថា ខ្ញុន អញសព្វថ្ងៃនេះសប្បាយលើសប្រុស ៗ ទាំងអស់ ព្រោះក្នុងប្រាសាទអញ ល្បែងរបាំគ្រឿងប្រគំតូរ្យតន្ត្រីគ្រប់មុខឥតខ្វះកន្ទះអ្វីទេ គ្រាន់តែគ្មានស្រី ចូលលាយឡំមានតែប្រុសៗប៉ុណ្ណោះ ទាំងម្ហូបចំណីក៏សុទ្ធតែជារបស់ធ្លាញ់ណាស់ ឥឡូវនាងនេះមកច្រៀងថា ប្រុសស្រឡាញ់ស្រីសប្បាយខ្លាំងណាស់ទាល់តែក្ស័យស្លាប់ តើសប្បាយយ៉ាងណាទៅទៀតអេះ អញចង់ដឹងណាស់ ទ្រង់ព្រះចិន្តាយ៉ាងនេះហើយ យាងមកឈរក្បែរទ្វារបន្ទប់ទតមើលរូបនាងនាដដែលកំពុងតែដេញពិណច្រៀងខាងក្រៅ ប៉ុន្តែគ្មានព្រះទ័យចាប់ប្រតិព័ទ្ធស្នេហាស្រឡាញ់នាងបន្តិចសោះ គ្រាន់តែនឹកថានាងនេះរូបល្អណាស់ ហើយយាងចូលទៅក្នុងវិញ ហៅអ្នកបម្រើមកប្រាប់ឲ្យនាងឈប់ច្រៀងវិលទៅផ្ទះវិញចុះ ព្រោះដល់ពេលដេកហើយ ចាំយប់ស្អែកសឹមឲ្យមកច្រៀងទៀត ចាប់តាំងពីព្រលប់ ហើយឲ្យនាងអង្គុយច្រៀងក្បែរទ្វារបន្ទប់ខ្ញុំនេះ ៗ នាងឮអ្នកបម្រើប្រាប់ដូច្នោះអរព្រួចព្រឺ ខ្ញុននឹកថាយប់ស្អែកមុខជាបានសម្រេចដូចបំណងអញមិនខាន ៗ ដំណឹងនេះជ្រាបដល់ព្រះមហាក្សត្រិយ៍ ទ្រង់សោមនស្សយ៉ាងក្រៃលែង ៗ

លុះដល់រាត្រីជាគំរប់បី នាងនាងតែងខ្លួនជាស្រីល្ហានស្លៀកពាក់ព្រៃស្បៃយ៉ាងស្ដើងរលោងរលើប មើលសាច់ឃើញច្បាស់ លាបម្សៅរមៀតឡើងស្រស់បំព្រង ពាក់មាសពេជ្រត្បូងប្រាលរន្ទាល ប្រុស ៗ ឃើញសំឡឹងមើលទាល់តែភ្លេចខ្លួនដើរចំពប់ជើងស្ទើរដួលស្លាប់ ៗ នាងនាងចូលទៅអង្គុយលើកម្រាលដែលគេក្រាលទុកឲ្យ ក្បែរទ្វារបន្ទប់ព្រះរាជកុមារតាំងពីពេលព្រលប់ធំ មានស្រីក្រមុំល្អ ៗ ពីរនាក់ទៀតជូននាងទៅផង លុះដល់អង្គុយស្ងប់ហើយ ចាប់រឹតខ្សែពិណឲ្យស្រួលបួលតាំងស្រែកច្រៀងរាយទំនុកជាបទពពកសោកថា ៖

( បទពាក្យ ៧ )

ស្រណោះដើមឆ្នាំភ្លៀងធ្លាក់ម្ដង ឈើស្មៅវល្លិ៍ផងលាស់
ស្រស់ខ្ចី ស្លឹកខៀវស្រងាត់គួរបេតី ផែនដីត្រជាក់ដោយ
ធារា ៗ ហ្វូងសត្វបក្សាផងទាំងឡាយ ហើរលេងសប្បាយលើ
វេហាស៍ យាសយំឆ្លើយឆ្លងរកគ្នីគ្នា នៅតាព្រឹក្សាសប្បាយ
ណាស់ ៗ ឯមនុស្សប្រុសស្រីក្នុងភូមិឋាន លេងសើចកំសាន្ត
ទាំងក្មេងចាស់ មានប្ដីប្រពន្ធឥតដែលខ្វះ ព្រោះសប្បាយ
ណាស់គ្មានអ្វីប្រៀប ៗ

ព្រះរាជកុមារទ្រង់ព្រះសណ្ដាប់ដល់ត្រឹមនេះ ទំព្រាំសម្ងំស្ដាប់តទៅ

ទៀតមិនបាន ព្រោះត្រូវត្រង់រឿងដែលធ្លាប់រួចមកហើយថា ប្រុសស្រឡាញ់ស្រីនោះតើរកសប្បាយយ៉ាងណាទៅអេះ ទើបយាងចេញមកអើតនៅមាត់ទ្វារស្រែកហៅថា : នៃនាងដែលច្រៀង ! នាងចូលមកឯនេះសិន ៗ នាងនាងត្បាស់ត្រេកអរណាស់ ហាក់ដូចជាបានមាសប៉ុនដួងទុំដាក់ពិណចេញពីដៃភ្លាម ក្រោកឡើងបណ្តើរចាក់ក្បាច់បណ្តើរ កំរំពេនលំនាំកិន្នរបេះផ្កា ហើយស្រែកច្រៀងសម្លេងគ្រលួចថា ៖

( បទពាក្យ ៧ )

ព្រះអង្គហៅខ្ញុំមានហេតុអ្វី ខ្លួនខ្ញុំជាស្រីមិនមែនប្រុស បើ
ទ្រង់រកាំងជ្រាបការត្រូវខុស ខ្ញុំម្ចាស់មិនតុះទាល់គំនិត ៗ ក្រាប·
ទូលឲ្យជ្រាបសព្វកលកិច្ច អំពីល្បងល្បិចនៃស្រីពិត ហេតុអ្វី
ទើបប្រុសបង់ជួបជិត ទោះក្ស័យជីវិតលែងគិតស្តាយ ៗ រឿង
នេះទូលបានតែពេលស្ងាត់ ទីកំបាំងបាត់ភ្នែកទាំងឡាយ គេ
មើលមិនឃើញទោះជិតឆ្ងាយ ទើបថ្វាយសេចក្តីឲ្យជ្រាបបាន ៗ

ព្រះរាជកុមារឈរទតនាងនាងកំកាំងស្មារតី លែងដាក់ព្រះនេត្រដោយដក់ព្រះទ័យនឹងក្បាច់របាំចម្លែកផង ដោយសារឮសម្លេងនាងស្រួយស្រិបដែលមិនធ្លាប់ឮផង ប៉ុន្តែគ្មានព្រះទ័យនឹកស្រឡាញ់នាងនាងបន្តិចសោះ ៗ នាងនាងរាំបណ្តើរច្រៀងបណ្តើរចូលសន្សឹម ៗ ទៅឧបព្រះរាជ·

កុមារ ។ គេចផុតមិនឲ្យនាងចាប់បានទ្រង់ចេះតែថយក្រោយរហូតទាល់តែដល់ទៅខាងក្នុងបន្ទប់សិប ។ នាងនាដឃើញបានឱកាសស្រួលហើយក៏ចាប់ឱបព្រះរាជកុមារកៀកយកទៅដាក់ឲ្យផ្ទំលើគ្រែ ហើយនាងអង្គុយជាមួយប្រថាប់ព្រះបាទ ។ ឯព្រះរាជកុមារចេះតែលើកព្រះបាទចេញមិនព្រមឲ្យនាងនាដចាប់ពាល់ប្រថាប់ព្រះបាទបានសោះ ត្រាស់សួរនាងនាដថា ចុះប្រុសស្រឡាញ់ស្រីនោះតើសប្បាយយ៉ាងណាទៅ? ចូរនាងប្រាប់ខ្ញុំផង ដ្បិតខ្ញុំមិនដែលដឹងសោះ ចេះតែនឹកឆ្ងល់ខ្លាំងណាស់ តាំងពីស្តាប់បម្រៀននាងមក ។

នាងនាដទូលថា បើព្រះអង្គចង់ជ្រាបរឿងនេះ លុះតែទ្រង់ផ្ទំឲ្យស្ងៀមកុំបម្រះ បណ្តាយឲ្យខ្ញុំម្ចាស់ធ្វើតាមអំពើចិត្ត ទើបខ្ញុំម្ចាស់ទូលពីរឿងប្រុសស្រឡាញ់ស្រីឲ្យទ្រង់ជ្រាបសព្វគ្រប់បាន ។

ព្រះរាជកុមារគ្មានព្រះទ័យប្រតិព័ទ្ធស្នេហា នឹងនាងនាដបន្តិចបន្តួចសោះទេ ប៉ុន្តែដោយហេតុចង់ជ្រាបពីរឿងប្រុសស្រឡាញ់ស្រីណាស់ បានជាខំអត់ទ្រាំសម្ងំផ្ទំស្ងៀម បណ្តាយឲ្យនាងនាដធ្វើតាមចិត្ត ទ្រង់ចេះតែខំចាំសង្កេតចំណាំ ។ នាងនាដដឹងថាបានកណ្តាប់ដៃខ្លួនសិបហើយក្នុងបន្ទប់ស្ងាត់ជិតឈឹងតែពីរនាក់ គ្មានគិតក្រែងរអែងអ្នកណាសោះ ក៏តាំងបញ្ចេញកលមាយាស្រីជាច្រើនប្រការ ។

(នៅមានត)

# រឿងព្រេងប្រទេសស៊ីរី

# រឿងដែលប្រព្រឹត្តទៅមិនបាន

ភិក្ខុ ម៉ែង-វៀម

និស្សិតពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែចាកភាសាអង់គ្លេស

---

ដំណឹងរំជើបរំជួលបានលេចឮរន្ទឺ ចូលមកក្នុងព្រះកាណ៌នៃព្រះបាទកាលិប (១) ថា នៅក្នុងទីក្រុងមានអ្នកនិយាយរឿងម្នាក់ ជាអ្នកប៉ិនប៉ាប់ជាទីបំផុត អាចនិយាយរឿងមិនចេះចប់ ហើយមិនចេះញញើតញញើមផង ។ ដំណឹងរំជើបរំជួលនេះបានឲ្យដឹងទៀតថា បុរសនេះអាចនិយាយរឿងផ្សងព្រេង តាំងពីពេលព្រះអាទិត្យលិច រហូតដល់ព្រហាមស្រាង ៗ រួចតាប់និយាយដោយឥតធុញទ្រាន់ ពីព្រះអាទិត្យរះ រហូតដល់យប់ទៀត ហើយមិនចេះនិយាយរឿងដដែល ១ ពីរដងឡើយ ។

ព្រះបាទកាលិប បានបញ្ជូនក្រុមតុលាការរបស់ព្រះអង្គ ទៅស៊ើបរកបុរសនោះ, ហើយកាលដែលគេនាំបុរសអ្នកនិយាយរឿងនោះ មកឈរចំពោះព្រះភក្ត្រព្រះអង្គ ទ្រង់ក៏ពោលថា : " ពមានការរំជើបរំជួលថា អ្នកឯងជាអ្នកចេះនិយាយរឿងយ៉ាងឆ្នើមបំផុតនៅលើដែនដីនេះ,

---

(១) ព្រះបាទកាលិបនេះ ជាមហាករនៃក្រុង បាក់ដាដ ( bagbab ) ពីជំនាន់ចាស់, ទ្រង់រក្សាទុកព្រះមស្សុវែងស្រអួម. ជាទីស្នេហានៃប្រជារាស្ត្ររបស់ព្រះអង្គ (ល) ។

ម៉េចក៏ខ្ញុំមិនដែលឮពីអ្នក? ” ។ បុរសទូលថា : “ ខ្ញុំព្រះអង្គ គ្មានសិទ្ធិទាមទារចំពោះភាពដ៏ផ្អែមបំផុតនោះទេ , ទូលព្រះបង្គំ គ្រាន់តែនិយាយរឿងពីរោះ ៗ នៅតៀមកាហ្វេ ដើម្បីរកកាក់រកសំឡាញ់ទូលព្រះបង្គំប៉ុណ្ណោះ ” ។ ទ្រង់ពោលថា : “ មក, ចូរមក ! ចូរយើងកុំនិយាយពីសេចក្ដីសុភាពរាបសាប្រាសចាកកិត្តិយស , គេនិយាយពីអ្នកថា អ្នកឯងអាចនិយាយរឿងគ្រប់បែបបាន ហើយអាចបន្លាយរឿងទាំងនោះដរាបទាល់តែអ្នកស្ដាប់ស្រែកឲ្យបញ្ឈប់ ; ឥឡូវកាលណាអ្នកឯងបរិភោគភោជនរួច, ខ្ញុំនឹងចាំស្ដាប់រឿងប្រឌិតមួយរបស់អ្នកឯង ” ។

ក្រុមតុលាការ បានជួបលៀងអ្នកនិយាយរឿង រួចគេនាំគាត់មកអង្គុយពីមុខ ព្រះបាទកាលិបម្ដងទៀត ។

ទ្រង់ពោលថា : “ អ្នកឯង អាចនិយាយរឿងណាមួយ បានតាមចិត្ត ឲ្យតែរឿងនោះចប់នៅពេលព្រលឹមស្រាង ៗ ; ហើយខ្ញុំជឿជាក់ថា អ្នកឯងអាចនិយាយរឿងដែលមានផ្ទៃសេចក្ដីពិត ៗ បាន បើប្រសិនណាជាខ្ញុំត្រូវការចំពោះរឿងបែបនេះ, តែរឿងដូច្នេះ មិនមែនជាការពិសោធន៍ជាក់ស្ដែងទេ ព្រោះអ្នកនិយាយរឿងដទៃ ៗ ទៀត ក៏អាចនិយាយបាន; រឿងដែលខ្ញុំត្រូវការឲ្យអ្នកនិយាយគឺរឿងខ្លី ប៉ុន្តែតួសេចក្ដីផ្ទៃរឿងត្រូវតែជាពាក្យកុហកទាំងស្រុង; បើប្រសិនណាជាខ្ញុំកត់សំគាល់នូវពាក្យសូម្បីមួយម៉ាត់ក្នុងរឿងអ្នកឯងនោះ ថាជាពាក្យពិតបាន ខ្ញុំនឹងយកអ្នក

ឯងធ្វើជាទាសៈរបស់ខ្ញុំ, ឥឡូវ ចូរនិយាយចុះ!" ។

កាលដែលអ្នកនិយាយរឿង បានឮព្រះរាជបញ្ជាដូច្នោះ គាត់ក៏រុញរា, ពីព្រោះថា ការនិយាយអស់ពេលវេលាដ៏វែង ដោយចៀសវាងកុំពោលពាក្យពិតឲ្យសោះដូច្នេះ ជាការមួយលំបាកណាស់, ប៉ុន្តែគាត់កាត់សាញ រួចចាប់និយាយរឿងដូចតទៅនេះ ៖

បពិត្រព្រះអង្គដ៏ទ្រទ្រង់នូវឥស្សរភាព! ខ្ញុំព្រះអង្គនេះត្រូវជាបងប្អូននៃឪពុកខ្ញុំ ។ កាលឪពុកខ្ញុំកើត ខ្ញុំមានអាយុ ៨ ឆ្នាំហើយ ។ ជីតារបស់ខ្ញុំបានយកឪពុកខ្ញុំនោះមកដាក់ក្នុងដៃខ្ញុំ ហើយបង្គាប់ខ្ញុំឲ្យមើលថែរក្សាលួងគាត់កុំឲ្យយំ ។ ប៉ុន្តែគ្មានអ្វី ដែលអាចធ្វើឲ្យឪពុកខ្ញុំគាត់សប្បាយចិត្តសោះ, ម្ល៉ោះហើយគាត់ប្រាប់ខ្ញុំឲ្យពគៈគាត់ទៅហាងផ្សារនៅក្នុងទីផ្សារ គាត់ដូចជាសប្បាយចិត្តដោយហេតុគាត់បានពិភាក្សា ជាមួយនឹងអ្នកដទៃទៀត នូវបំណាចដ៏ល្អ ៗ ខ្លះនៃគម្ពីរកូរ៉ាន(១) ។ មុនដែលយើងនឹងចាកចេញពីហាងផ្សារ, គាត់ទទូចឲ្យខ្ញុំទិញពងមាន់ឆៅមួយ ប៉ុន្តែ មិនយូរឆ្ងាយប៉ុន្មានពីពេលដែលទិញ ពងនោះក៏ស្រាប់តែញាស់ឡើង ។ ដោយហេតុតែកូនមាន់នោះធំសម្បើមពេក ហើយត្រូវនឹងយើងទាំងពីរនាក់កំពុងតែអស់កំឡាំងផងនោះ យើងបានដឹកកូនមាន់បត្រឡប់មកផ្ទះវិញ ។ នៅពេលមកដល់ផ្ទះ កូនមាន់កែទំហំធំ ប៉ុនអូដ្ឋ ។ ម្ល៉ោះហើយ ខ្ញុំ

(១) កូរ៉ាន ជាឈ្មោះគម្ពីរដ៏ស័ក្តិសិទ្ធិមួយ របស់មោហាម៉េដ ។

ត្រូវតែលើកឪពុកខ្ញុំដាក់ឲ្យទៅជីតាខ្ញុំ ដែលត្រូវជាឪពុកខ្ញុំដែរ ពីព្រោះឪពុកខ្ញុំត្រូវជាប្អូនបង្កើតរបស់ខ្ញុំ ! ។

មកដល់ត្រឹមនេះ ព្រះបាទកាលិបបានលាន់ព្រះឱស្ឋ នឹងការកុហកដ៏អស្ចារ្យនៃអ្នកនិយាយរឿង ។

គាត់ចាប់និយាយតទៅទៀតថា :

កូនមាន់នោះ ស៊ីច្រើនសម្បើមណាស់ដែលកន្លងយូរមកអាចធ្វើឲ្យយើងឋិតនៅក្បែរគែមនៃទុរភិក្សភាព ហើយយើងក៏បានសំរេចចិត្តប្រើឲ្យធ្វើការ ។ តាំងតែពីកូនមាន់បានមកជាកម្មសិទ្ធិនៃឪពុកខ្ញុំ គាត់តែងបរពេញទៅក្រៅពល់ព្រឹក ហើយផ្ទុកឱសលើខ្នងៈត្រឡប់មកវិញ, ធ្វើយ៉ាងនេះដរាបដល់យើងមានគំនរឱសយ៉ាងខ្ពស់នៅលើទីធ្លាផ្ទះ ។ ប៉ុន្តែការកកិតឱសនៅលើខ្នងមាន់ ធ្វើឲ្យរបួសដាច់ស្បែក, ដូច្នេះកូនមាន់ក៏ឈឺចាប់ ។ ជីតាខ្ញុំទៅជារវល់រវក់ ហើយគាត់ពិគ្រោះជាមួយឪពុកនឹងយាយទួតខ្ញុំថា តើត្រូវធ្វើដូចម្តេច ? ។ យាយទួតខ្ញុំប្រាប់គាត់ឲ្យយកគ្រាប់ស្វាយមកធ្វើថ្នាំបំពោក រួចយកទៅបិទលើខ្នងកូនមាន់ត្រង់កន្លែងរបួសនោះ ។ ជីតាខ្ញុំក៏បានធ្វើតាម ។ ព្រឹកឡើង ពេលដែលយើងភ្ញាក់កូនមាន់ក៏បានជាសះស្បើយឡើងវិញ, ប៉ុន្តែស្រាប់តែមានដើមស្វាដុះចេញពីខ្នងកូនមាន់មក ។ ចំនួនជា ៣ ថ្ងៃប៉ុណ្ណោះកូនស្វា ក្លាយទៅជាមេដើមស្វាមួយយ៉ាងធំអស្ចារ្យ ដែលចេះតែជាប់តាមកូនមាន់ ទៅគ្រប់ទីកន្លែងដែលកូន

មាន់ដើរទៅ ៗ មួយអាទិត្យក្រោយមក, ផ្លែស្វាក៏ផ្លែរយោនរយោន ពេញមែកទាំងអស់ ៗ ពេលនោះ មនុស្ស ១២ នាក់ បានត្រូវគេឲ្យ ឡើងបេះផ្លែស្វានោះ, បេះតាំងពីថ្ងៃសៅរ៍រហូតថ្ងៃអង្គារទើបអស់ ៗ ជាង ស្វាទាំងនោះ លូតឆ្ងាយ ៗ ពីគ្នាណាស់គឺថាបើអ្នកបេះស្វា ដើរស្ទួរពីចំណែកខាងកំដៅព្រះអាទិត្យ ទៅចំណែកខាងម្លប់នៃដើមឈើ អាចឃើញ ព្រះអាទិត្យលិចមុនពេលដែលទៅដល់ ៗ ដល់ត្រឹមនេះ, ព្រះបាទ កាលិបទ្រង់ត្រាស់ព្រះសិរសួចដកដង្ហើមធំយូ! យូ! ៗ

កាលគេបេះស្វារួចពល់អស់ហើយ (គាត់ចាប់និយាយត) ខ្ញុំបាទ ដើរក្រឡឹងជុំវិញដើមស្វា ដើម្បីពិនិត្យមើលឲ្យដឹងថា តើគេប្រមូលផ្លែ ស្វាអស់រលីងហើយឬនៅ ៗ គ្រាន់តែដើរព័ទ្ធដើមនេះអស់មួយថ្ងៃគត់ ៗ ហើយកាលដែលខ្ញុំរៀបនឹងត្រឡប់ទៅផ្ទះវិញ ស្រាប់តែក្រឡេកទៅឃើញ កូនមាន់ឳពុកខ្ញុំទំលើជាងស្វា, វាដេកលក់ក្នុងវេលាយប់ស្រេចទៅហើយ ៗ ខ្ញុំរើសយកដីមួយដុំ រួចគោលសំដៅទៅវា ៗ ដុំដីនោះ បានហើរទៅ លើដើមស្វា ប៉ុន្តែវាមិនធ្លាក់មកវិញសោះ វាទៅជារីកទំហំធំឡើងៗ ដកប ដល់គ្របដណ្តប់ពីលើដើមស្វា ហើយខ្ញុំហៅសែនសប្បាយចិត្តដោយ បានដី ៤០ អារ សុទ្ធតែជាដីចំការយ៉ាងថ្មីនៅលើអាកាស ៗ

យើងយកសត្វពាហនៈ ទៅដាក់ឲ្យស៊ីស្មៅនៅទីនោះ ហើយកាល ដែលរដូវក្តៅកសមកដល់ យើងបានយកដីថ្មីនោះ សំរាប់ដាំដំណាំ ៗ

ដីតាខ្ញុំហើយនឹងខ្ញុំ បានយកគ្រាប់ល្វទៅដាំ, មួយខែក្រោយមក យើងគ្មានឃើញអ្វីដុះចេញមកសោះ ។ ជីតាខ្ញុំ បានសួរអ្នកជិតខាងពីហេតុនេះ, គេបន្ទោសគាត់ថា គាត់ជាមនុស្សល្ងីល្ងើទៅដាំងដើមល្វវិញ ហើយគេថា នៅលើដីដែលមានស្មៅល្អិតទន់ល្មើយដូច្នេះ មានតែឆ្កឹកទេ ទើបដាំដុះ ។ ម្ល៉ោះហើយជីតាខ្ញុំគាត់ប្រើខ្ញុំ នឹងប្អូនប្រុសខ្ញុំដែលត្រូវជាប្អូននៃឪពុកខ្ញុំនោះ ទៅប្រមូលយកគ្រាប់ល្វទាំងអស់ ដែលយើងសាបពីមុននោះមកទុកវិញ ។

គ្រាន់តែប្រមូលនេះអស់មួយម៉ោង ពីព្រោះគ្រាប់ល្វទាំងអស់មានប្រហែល ៨ ប៊ុសស្ហែល(១) ប៉ុន្តែកាលដែលយើងដើរវិលទៅផ្ទះវិញ ខ្ញុំសំគាល់ដឹងថា បាត់គ្រាប់ល្វមួយគ្រាប់ ។ ពេលនោះខ្ញុំត្រឡប់ទៅត្រង់ទីដី ៤០ អារនោះវិញ ដើម្បីរកមើលគ្រាប់ល្វដែលបាត់នោះ ។ ខ្ញុំរៀបតែឈប់លែងរកវាទៅហើយ ស្រាប់តែក្រឡេកទៅឃើញស្រមោចតូចមួយកំពុងតែទាញគ្រាប់ល្វនោះឆ្ពោះទៅសំបុកវា ។ ឃើញដូច្នោះ ខ្ញុំស្ទុះទៅទាញយកគ្រាប់នោះពីស្រមោច តែវាមិនព្រមលែងសោះ ជាហេតុនាំឲ្យយើងមានការទាញព្រ័ត្រសង្គ្រាមមួយយ៉ាងឃោរឃៅជាមួយនឹងស្រមោច, ប៉ុន្តែគ្មានអ្នកណាឈ្នះអ្នកណាសោះ ។ ក្នុងកំដៅនៃការប្រយុទ្ធ, គ្រាប់ល្វ

(១) ប៊ុសស្ហែលនេះ ជារង្វាល់មួយ. មួយប៊ុសស្ហែល មានចំនួនប្រហែល ៣២,៥ លីត្រ. ។ ដូច្នេះ ៨ ប៊ុសស្ហែល ២៦០ លីត្រ ។

កំដាប់ជា ២ កំណាត់ ហើយស្រាប់តែហូរប្រេងចេញលាន់ព៉ពីគ្រាប់ល្ង មួយគ្រាប់នោះយ៉ាងអស្ចារ្យ កើតបានទៅជាទន្លេមួយ ជាហេតុនាំឲ្យអ្នកស្រុកអុំទូកដឹកនាំផលានុផលរបស់គេ ទៅលក់ឯទីក្រុងយ៉ាងស្រួល ៗ មកដល់ត្រង់នេះ ព្រះបាទកាលិបទ្រង់ដកដង្ហើមធំឃូ! ឃូ! ម្តងទៀត ៗ

ពេលនោះ ( គាត់ចាប់និយាយត ) កាលដែលឪពុក ជីតាខ្ញុំហើយនឹងខ្ញុំកំពុងតែដាំឪឡឹក លោតែមានមហាព្យុះកំណាចមួយបក់ខ្លួចមក ៗ ដោយហេតុតែគ្មានជម្រកបែបណាមួយលើដី ៤០ អារនោះ យើងក៏មិនដឹងជាទៅជ្រកឯណា ៗ ម្ល៉ោះហើយ ជីតាខ្ញុំនឹងខ្ញុំក៏លោតចូលទៅក្នុងប្រហោងធ្មេញរបស់ឪពុកខ្ញុំ ៗ ឯឪពុកខ្ញុំ ក្រោយដែលក្រឡេកនាយអាយជុំវិញខ្លួនគាត់ ជាទីបំផុត គាត់បានលោតចូលទៅក្នុងបៀមមួយ ដែលគាត់បើតាមក្រោយយើង ៗ ព្យុះសង្ឃរាបានបោកបក់អស់រយៈពេល៤៧ថ្ងៃ ហើយកុំតែបានបៀមដែលឪពុកខ្ញុំ យកមកតាមជាមួយគាត់នោះ ខ្ញុំប្រ-ហែលអត់បាយក្រហាយទឹកនៅក្នុងប្រហោងធ្មេញនោះរហូត ៗ

ទីបំផុត យើងខំសំឡឹងមើលមកក្រៅ ហើយបានឃើញព្រះអាទិត្យកំពុងតែចែងចាំងរស្មី ប៉ុន្តែនៅពេលដែលយើងខំវារចេញពីរន្ធធ្មេញរួចមក កំស្រាប់តែបាត់ដី ៤០ អារនោះអស់រលីង ដោយសារភ្លៀងរំលាយ, ម្ល៉ោះហើយ យើងក៏ជាប់នៅលើអាកាសនោះ តែលតោលៗ តែម្តង ៗ ដោយភ័ព្វសំណាងមាន, ឪពុកខ្ញុំ ដែលជាមនុស្សចេះគិតអនាគត បាន

នាំខ្សែមួយទៅជាប់នឹងខ្លួនគាត់ ។ យើងបង់ខ្សែនោះ ដោយឥតព្រួយបារម្ភ រួចហើយយើងនាំគ្នាសម្រូតចុះតាមខ្សែនោះម្នាក់ម្តង ៗ ដកបដល់រួចខ្លួនផុតពីទុក្ខវៀនមក ។

ព្រះបាទកាលិប ដោយទ្រង់ឃើញថា អ្នកនិយាយរឿងបានបញ្ចប់រឿងខ្លួនហើយ ក៏ទ្រង់ពោលថា: "នេះគឺជារឿងផ្សេងព្រេងមួយ គួរឲ្យចងចាំដែលអ្នកបានពណ៌នា ; ខ្ញុំបង់សួរអ្នកឯងតែមួយមាត់ថា តើរឿងហ្នឹងពិត ឬ កុហក ? " ។ អ្នកនិយាយរឿងឆ្លើយថា : " បពិត្រព្រះអង្គ ! រឿងនេះជារឿងពិត តាំងពីដើមរហូតចប់ ។ –បើប្រសិនណាជាពិតមែន (ព្រះបាទកាលិបពោល) អ្នកឯងឈ្មោះថា មិនធ្វើតាមពាក្យខ្ញុំ ព្រោះខ្ញុំបានបង្គាប់អ្នក ឲ្យនិយាយតែពីរឿងកុហកកុំឲ្យមានពាក្យសច្ចៈ ក្នុងផ្ទៃរឿងឲ្យសោះ " ។ –ទូលព្រះអង្គ, (គាត់និយាយដោយញញឹម) ទូលព្រះបង្គំធ្វើតាមព្រះរាជឱង្ការព្រះអង្គគ្រប់មាត់ ពីព្រោះដែលខ្ញុំព្រះអង្គទូលថា "រឿងនេះជារឿងពិត គឺគ្រាន់តែបន្ថែមពាក្យកុហកទៅលើផ្ទៃរឿងកុហកចាស់ដែលបាននិយាយរួចមកហើយប៉ុណ្ណោះឯង ក្រាបទូល! ។ ទ្រង់ពោលតបថា : " យ៉ាងហ្នឹងមែនហើយ ! ដំណើររំដើបរំជួលដែលខ្ញុំបានឮពីប្រាជ្ញារបស់អ្នក ឥឡូវឃើញច្បាស់ហើយ ! " ។

ពេលនោះ ទ្រង់ព្រះរាជទានដល់អ្នកនិយាយរឿងនូវដុំមាសមួយកំបង់ ហើយបញ្ជូនគាត់ឲ្យត្រឡប់ទៅផ្ទះគាត់វិញហោង ។

# រឿងមាណពមិនចេះដេកប្រជ្រៀត

លោក ញូង · សឿង នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

មានសេចក្តីដំណាលថា កាលពីសម័យបុរាណ មានមាណពម្នាក់ ជាមនុស្សគោតល្ងង់ហើយអៀនខ្មាសណាស់ បើមានញាតិមិត្រប្រុសស្រី ជួបជុំលេងសើចសប្បាយត្រង់កន្លែងណា មិនហ៊ានចូលទៅកាន់ទីនោះទេ ព្រោះគេចេះតែចំអែចំអន់លើកទុកលើកដាក់លើនាងនេះនាងនោះ ៗ ពេលប្រជុំធំ ៗ ដូចជាពេលបុណ្យទានទៅវត្តក៏ ឬមង្គលការជាដើម ក៏បុរសនេះមិនសូវអើពើទៅលេងកំសាន្តដូចអ្នកផងទាំងពួងឡើយ គឺជាមនុស្សមុខខ្វរ អឹមអៀមអៀនប្រៀនមិនចុះជំនុំចំណោមទីឯគេសោះ ៗ ឯឈ្មោះដើមដំបូងរបស់មាណពនេះ គេមិនបានចាំប្រាកដថាឈ្មោះអ្វីទេ, តែដោយហេតុគាត់មានការអៀនខ្មាសច្រើនដូច្នេះ ទើបនាំឲ្យអ្នកស្រុកភូមិគេនាំគ្នាហៅថា “អាខ្វរ ៗ” ជាប់ដរាបមក ៗ សូម្បីតែឪពុកម្តាយបង្កើតរបស់មាណពនេះ ក៏ហៅថា “អាខ្វរ ៗ” ស្រួលមាត់តាមគេដូច្នោះដែរ ៗ

ចំណែកកិច្ចការស្រែចំការជាដើម អ្នកកំឡោះយកចិត្តទុកដាក់ធ្វើហ៊ឹងម៉ឹងម៉ាត់ជាទីបំផុត ជាហេតុនាំឲ្យឪពុកម្តាយស្រឡាញ់ពេញចិត្តណាស់ ទោះទាំងញាតិមិត្រជិតឆ្ងាយក៏សរសើរខ្វរគ្រប់មាត់ដែរ ៗ មានគេចង់លើកកូនក្រមុំឲ្យមាណពនេះជាច្រើននាក់, តែបុរសឥតត្រូវការនឹកនាពីរឿងប្រពន្ធកូនសោះ ៗ រីឯឪពុកម្តាយ ចេះតែព្រួយបារម្ភ ព្រួយត្រង់

កូនមិនព្រមយកប្រពន្ធនេះឯង ណាមួយទៀតខ្លួនមានអាយុកាន់តែច្រើនផង គឺជិត ៣០ ឆ្នាំទៅហើយ ។ តមកក្រោយ, ឪពុកម្តាយនិងញាតិមិត្តនិយាយលួងលោមអង្វរសម្រុះសម្រួលខ្លះ បង្ខំខ្លះ ពន្យល់ហេតុផលផ្សេងៗខ្លះ អំពីរឿងប្រពន្ធនេះ, ខ្លួនក៏យល់ព្រមទាំងប្រថុយ ៗ គ្រានោះឪពុកម្តាយមានចិត្តត្រេកអរណាស់ បានទៅដណ្តឹងកូនក្រមុំគេម្នាក់ដែលខ្លួនពេញចិត្តហើយដែលនៅភូមិឆ្ងាយបន្តិច ។ ខាងស្រីក៏មានសេចក្តីអបអរសាទរណាស់ទៅទៀត ព្រោះគេចង់លើកឲ្យតាំងពីយូរណាស់មកហើយដែរ ។ បន្ទាប់ពីនោះមកមិនយូរប៉ុន្មាន, មាតាបិតាទាំងសងខាងបានរៀបចំមង្គលការយ៉ាងអឹកធឹកតាមគន្លងប្រពៃណី ។ ក្នុងថ្ងៃចូលរោងខ្លួនឥតញញឹមរីករាយអ្វីបន្តិចសោះ បេះតែក្រៀមក្រំជានិច្ច ព្រោះទើបនឹងបានជួបប្រទះនូវទីជុំទុំចំណោមគ្រានេះជាលើកដំបូងបង្អស់ ហើយជាការផ្ទាល់ខ្លួនឯងតែម្តង ៗ ទទួលពេលនោះ មានទាំងមិត្តភក្តិកំឡោះជាច្រើននាក់ គេមកចោមរោមបំអកចំអន់សើចលេងគឹល ៗ ផង ជាហេតុឲ្យខ្លួនរឹងរឹតតែអៀនខ្មាសណាស់ថែមឡើងទៀត ។ ពល់តែពេលធ្វើពិធីផ្សេង ៗ ដូចជាកាត់សក់, ក្រាបសំពះស្តាប់លោកសូត្រមន្តនឹងសែនបង្វិលដៃជាដើម, មាណពមានទឹកមុខស្ងួតស្រពោនជាដរាប ទោះបីគេសុំឲ្យញញឹមយ៉ាងណាក៏ដោយ ។ ថ្ងៃស្អែកឡើងព្រលឹមស្រាង ៗ ដល់កំណត់ពេលហើយ, អាចារ្យកាន់វេលាការ ក៏បាននាំសាមីខ្លួនឡើងទៅរង់ចាំ

ត្រង់កន្លែងសំពះផ្ទឹម ៗ គ្រានោះ ក្មេងបានប្រគំកំដរតាមទំនៀមយ៉ាងពីរោះ លន្លង់លន្លោចគួរឲ្យស្រងេះស្រងោចពេកក្រៃ នាំឲ្យពួកអ្នកមានគូស្រករ រួចហើយនឹកព្រឺព្រួចចង់រៀបមង្គលការខ្លួនម្ដងទៀត ៗ គ្រានោះ ខ្ញុំឡើង ទឹកមុខខ្មៅជាំ ភ័យបុកពោះផ្អក ៗ បែកញើសជោកទាំងព្រឹកព្រហាម ព្រោះពេលសំពះផ្ទឹមនេះជាមង្គលដំផ្ដាច់ព្រ័ត្រ ៗ លុះគេរៀបចំឲ្យអង្គុយ បត់ជើងស្រួលបួលហើយ, អាចារ្យបង្គាប់ឲ្យខ្ញុំប៉ោយហូតស្លាម្លូ ៣ ដែល គេដាក់លើខ្នើយសម្រាប់ក្រាបសំពះផ្ទឹម, ខ្ញុំភ័យញ័រទទ្រាក់ទទ្រើក ស្រាប់ តែដាក់ដៃទ្រប់សង្ក្រិបទៅលើខ្នើយនោះ ដូចឆ្មាលោតទ្រប់កណ្ដុរ ជ្រុះ ស្លាម្លូប៉ុនគេកយ ៗ គេនាំគ្នាសើចគិលឡើងលាន់ឮពេញទាំងផ្ទះ ៗ ពួកកំឡោះ ៗ ជើងរិលខ្ទះ កំរើលមាត់ក្អាត់ក្អួយពាក្យថា ថប់ណាស់អ៊ុយ! បើលេងតែប្រើស្នៀតលោតសង្គ្រុបយ៉ាងនេះ ដល់ពេលផ្សំដំណេកហើយ ក្នុងពេលយប់នេះ មើលទៅមុខជារង្គើគោករង្គើហ៊ឺងផ្អើលគេផ្អើលឯងមិន ខានទេអ៊ុយកនរយើង! ៗ គេនិយាយចំអន់លេងដូច្នេះមិនទាន់ទាំងផុតមាត់ ផង ស្រាប់តែឮស្នូរសំឡេងពីក្រោមគូថចៅខ្ញុំមកទៀត " ប៉េត ៗ - ប៉ា- រេត - ប៉េត ៗ!" ៗ សាមីខ្លួនធ្វើហាក់មិនដឹងខ្លួន ៗ ពួកអ្នកអង្គុយនៅ ឆ្ងាយមិនបានឮសំឡេងនេះទេ ព្រោះរាថ្ងង់តែនឹងស្នូរស័ព្ទក្មេង, តែបំណែក ពួកកំឡោះ ៗ ជាគូកនដែលអង្គុយកំដរជិត ៗ ខ្ញុំទាំងប៉ុន្មាន សឹងបានឮ ជាក់ប្រាកដណាស់ ទើបគេនាំគ្នាសើចគិលឡើងមួយសាទៀត ព្រមទាំង

អ្នកខ្លះបានបន្ថែមសំដីតិចៗ ថា អាខ្ចរ! ក្មេងគេមិនសូវពីរោះ ប៉ុយ៉ាងណា បានជាអាឯងចាំបន្ថែមស្រវៀប៉ុពកអី ៗ មកទៀត? អ្នកខ្លះឡើប ៗ ថា អាខ្ចរ! បើអាឯងលេងតែផ្គរទេទេ មិនជាការអ៊ីប៉ុន្មានទេ នៅមានផ្សគ្រាន់ទប់ទល់ខ្លះ តែបើមានតាំងក្មេងដោយមកជាមួយផងនុះ ពួកយើងមុខជាល្ងង់ចោលឥឡូវហ្នឹងហើយ ឥតបាននៅជួយកំដរគេទៅទៀតទេរុយ ៗ គ្រានោះ មាណពរីងរឹតតែអៀនខ្មាសទ្រុតឡើងយ៉ាងហួសប្រមាណៈស៊ីរបាត់ស្មារតី ទឹកមុខមៅក្ដៅក្រហាយ ឥតឧបមាពិចារណាតែក្នុងចិត្តថា "ពេលនេះឋុសការធំហើយអញ! គិតទៅរឿងការប្រពន្ធនេះហៅបំជាតិបាក់មែន! សោតឯអាដែងផងនេះទៀត បើឯងកំពុងតែខ្មាសគេជិតដាប់ខ្យល់ងាប់យ៉ាងនេះ ពបន្ថិបញ្ចេញសំឡេងយកមុខមាត់កក្រេតត្រេតកណ្ដាលបំណោម ធ្វើឲ្យឯងរឹតតែបាត់ព្រលឹងទៅទៀត, ម៉ែហើយនឹងឪគាត់ធ្វើឲ្យឯងរងកម្មអាម៉ាសមុខស្ទើរតែងាប់ខ្លួនតែម្ដងហើយជាន់នេះ ៗ បុរសគិតម្ដងថា ទីងក្រោកពោលទំលាយទីប្រជុំជនរត់ឲ្យបាត់ស្រឡះទៅ គិតម្ដងថា ណ្ហើយកុំ. . . ស៊ូទ្រាំបន្តិចទៅទៀតចុះ ៗ លុះអ្នកក្មេងម្នាក់បានបៀងកាំបើកកាំងនទរួចហើយ គេក៏នាំកូនស្រីចេញមកសំពះផ្ទឹមជាមួយ ៗ មួយសន្ទុះធំមកទៀត ការសំពះផ្ទឹម ក៏បានចប់សព្វគ្រប់ត្រឹមកិច្ចដែលអាចារ្យសូត្រធមិឲ្យពរស័ព្ទសាធុការតាមទំនៀម ៗ ចៅខ្ទរហាក់បានធូរចិត្តបន្តិចដូចគេដកបន្ទាពីដើមទ្រូង ទឹកស្មាខថាបានរួចខ្លួនហើយជាន់នេះ ៗ ពេល

ក្រោកពីសំពះផ្ទឹមគ្នា ចាស់ ៗ បង្គាប់ខ្វរឲ្យគោនជាយស្បែប្រពន្ធចូលទៅក្នុងបន្ទប់ ៗ ប៉ុន្តែគោនជាយស្បែបណ្ដើរងាកមើលក្រោយបណ្ដើរផតឃើញគេជូនជួយកំដរទៅជាមួយផងសោះ ក៏ទឹកព្រាយបារម្ភមួយលើកទៀត ព្រោះមិនដឹងជាមានរឿងអ្វីខ្លះទៅទៀតក្នុងបន្ទប់នោះ, ណាមួយក៏ស្រពន់ដើងខ្លាំងផង ឈានដើងដើរស្ទើរតែរួច, ដល់មាត់ទ្វារបន្ទប់ស្រាប់តែខ្វរមិនព្រមចូលតាមប្រពន្ធ នៅប្រទាញប្រទង់គ្នាយឺតចុះយឺតឡើង នាំឲ្យគេសើចលាន់ទ្រហឹងអឹងកងពេញទាំងផ្ទះ ទាល់តែចាស់ទុំខ្លះជួយរុញច្រានបង្ខំខ្លាំង ទើបខ្វរព្រមចូលទៅក្នុងបន្ទប់ទាំងខ្មែនមុខក្រហមផង ៗ រឿងអៀនខ្មាសនេះ មិនមែនមានចំពោះតែលើរូបសាមីខ្លួនខ្វរប៉ុណ្ណោះទេ, ទោះទាំងឪពុកម្ដាយបងប្អូនមាមីងទាំងប៉ុន្មានរបស់ខ្វរ ក៏ត្រូវទទួលការអាម៉ាស់មុខស្ទើរតែងើបមុខមិនរួចដែរ, តែមិនដឹងធ្វើដូចម្ដេច បើការនេះក៏ជ្រុលហួសអស់ទៅហើយ ៗ

លុះរួចកិច្ចមង្គលនេះហើយ, ឪពុកខ្វរក៏ដឹកបលាដន្ទងត្រឡប់ទៅផ្ទះវិញ ដោយមានឪរៈម្ដាយគាត់ចាស់ជកឈើជាទម្ងន់ គាត់ទុកតែប្រពន្ធគាត់ឲ្យនៅកំដរនៅទីនោះសិន ៗ មុននឹងលាទៅ ឪពុកខ្វរ បាននិយាយផ្ដាំផ្ញើប្រគល់កូនប្រុសគាត់ថា " អ្នកដន្ទងអើយ! សូមអ្នកអត់ទោសផងចុះកូនខ្ញុំនេះក៏អៀនខ្មាសធ្ងាំធ្ងន់ច្រើនណាស់ ដូចអ្នកបានឃើញស្រាប់ហើយតែចំណែកខាងរបៀបធ្វើកិច្ចការសព្វសារពើនោះ គឺក៏គ្រាន់បើដែរ, ឥឡូវនេះ ក៏បានមកជាកូនរបស់អ្នកហើយ ស្រេចតែអ្នកជាស្ដីប្រដៅប្រដៅក៏

ឲ្យបានស្រួលបួលផងចុះ " ។

ជនូងតប: " មិនអីទេអ្នក ! ការនាំធងបន្ទិចបន្តួចនេះ យើងអាច លៃលកកែសម្រួលទៅថ្ងៃក្រោយបានដែរ, សូមអ្នកអញ្ជើញចុះ, ឯរឿង យាយម្ដាយអ្នកដែលឈឺខ្លាំងនោះ បើយ៉ាងណា ៗ សូមអ្នកឲ្យដំណឹងខ្ញុំ វិញប្រញាប់ផងកុំខាន " ។ ឪពុកខ្វះដំកបលាជនូងរួច ក៏ចឹមរទេះបរ ចេញដំណើរយ៉ាងរួសរាន់ទៅទាំងព្រឹកនោះឯង ។

លុះដល់ពេលយប់ប្រហែលម៉ោង ៧ ជាពេលត្រូវផ្សំដំណេក, ជួន ចាស់ ២ នាក់ ( យាយអ៊ូនិងយាយច័ន្ទ ) ហៅគូស្រករថ្មីឲ្យមកអង្គុយទល់ មុខគ្នាក្នុងបន្ទប់នោះដែលមានចំអាប ១ ចាស នំងបន្ថែម ១ ចាស ព្រម ទាំងទឹកដូង នំងបេកចុំជាដើមតាមទំនៀម ។ ហៅខ្វះបែកញើសម្ដងទៀត អង្គុយនុនមុខជ្រប់គិតថា " ស្អីទៀតហើយអេះ ? ឯងស្មានថាចប់អស់ ហើយ, យីអើ ! គិតទៅរឿងការប្រពន្ធនេះនាំឲ្យបែកញើសច្រើនណា ណាស់តើ!" ។ បន្ទាប់ពីការធ្វើពិធីសែនព្រេនបន្តិចបន្តួចរួចហើយ, យាយ អ៊ូបង្គាប់នាងប្រពន្ធឲ្យជួសទឹកដូងបញ្ចុកប្ដី ៣ ស្លាបព្រា ហើយឲ្យប្ដីជួស បញ្ចុកប្រពន្ធវិញ ៣ ស្លាបព្រាដែរ ព្រមទាំងប្រាប់ទៀតថាត្រូវលេបឲ្យ- អស់កុំឲ្យធ្លាក់ចោល, អ្នកទាំងពីរក៏បានធ្វើតាម ។ រួចពីនេះទៅ យាយ ច័ន្ទបង្គាប់នាងប្រពន្ធឲ្យយកបេក ៣ ដុំ ( មួយដុំម្ដង ។ ) បញ្ចុកប្ដីដែល ក្រអឹមក្រអៀមស្ទើរតែមិនចង់ហារមាត់ទទួលផង ។ លុះបានបេកដល់

កូនមាត់ហើយ , ចៅខ្ញុំមិនព្រមលេបសោះ នៅបៀមត្រលរទ្ញមាត់ ដូចស្វាបៀមផ្លែឈើ ។ ដល់វេលាត្រូវខ្ញុំនបញ្ចុកប្រពន្ធវិញ , ខ្ញុំបញ្ចុកចូលមាត់គេបានតែបេក ២ ដុំ កាន់តែទឹកអៀនឡើង ១ ទុនមុខជ្រប់លែងហ៊ានមើលចំមុខប្រពន្ធ ដល់បញ្ចុក ១ ដុំទៀត លូកដៃស្ទាន ១ មិនប៉ះឯមាត់ ទៅពារលើឯច្រមុះគេវិញ , ពេលនោះប្រពន្ធមិនទាន់ទាំងទំពារលេបបេក ២ ដុំមុននោះអស់ផង ស្រាប់តែសើចយឹក-ប្ដីសើចយុះ ប៉ុនគេព្រួសព្រួសបេកដាក់មុខគ្នាទៅវិញៈទៅមក ប្រមូ្ចកមុខស្រមាមទាំងពីរនាក់ ។ យាយតាស់ ១ អ្នកផ្សំដំណេក សើចរឹងជំបាររពោះអស់ ។ យាយទាំងពីរបានយកទឹកឲ្យប្ដីប្រពន្ធលុបលាងមុខមាត់ឲ្យជ្រះស្អាតហើយក៏ឲ្យមកកអង្គុយកន្ទែងដដែលវិញ ទើបគាត់ប្រាប់អ្នកទាំងពីរថា ចៅប្រុសត្រូវដេកខាងស្ដាំ ឯចៅស្រីត្រូវដេកខាងឆ្វេង ហើយខ្សឹបខ្សៀវប្រាប់អំពីកិច្ចរមដំណេក . . . តាមប្រពៃណី ។ ដល់រៀបចេញពីបន្ទប់មកក្រៅ, យាយច័ន្ទខ្សឹបប្រាប់នាងប្រពន្ធថា ប្ដីនាងអៀនខ្មាសច្រើនណាស់ដូចនាងបានដឹងស្រាប់ហើយ , បើនាងសំកុកចាំតែមើលដំណើរទំនងប្ដីនោះ មើលទៅមុខជាមិនបានការអ្វីទេ , ដូច្នេះត្រូវនាងឯងដៃដល់បន្តិចទើបកើតការ . . . ។ លុះរួចកិច្ចសព្វគ្រប់ហើយ ជូនទាំងពីរក៏លើកថាសនិងអីវ៉ាន់កំប៉ុកកំប៉ុកចេញមកក្រៅរួចបង្គាប់នាងប្រពន្ធឲ្យបិទទ្វារ ហើយឲ្យខ្ទាស់ទុកឲ្យជាប់ ។ ចំណែកខ្ញុំ លុះគេចេញផុតមកក្រៅអស់ហើយ

នៅតែពីរនាក់ប្ដីប្រពន្ធ ក៏តាំងប្រះដេកយកដៃគងថ្ងាស គប់ប្រមល់ក្នុងចិត្តឥតឧបមា ពេះតែនឹកព្រួយបារម្ភភ័យផ្អុក ៗ : " ថប់អស់យ៉ាងហើយអញ! មើលទៅរបៀបការប្រពន្ធនេះមិនងាយចប់ឆាប់ទេ ពីរថ្ងៃកន្លងមកហើយនេះឃើញថាមានកិច្ចការរវាក់រវុបច្រើនណាស់ហើយសុទ្ធតែជាការនាំបណ្ដាលឲ្យកើតសេចក្ដីអៀនខ្មាសស្ទើរតែគ្រប់អន្ទើ , ពីម្សិលមិញបន្តិចថាកាត់សក់, បន្តិចថានេះ បន្តិចថានោះ មិនចេះអស់មិនចេះហើយសោះ, ព្រឹកមិញ គេឲ្យក្រាបសំពះផ្ទឹមគ្នា ឯងខំប្រឹងទប់ខ្លួនបែកញើសជោកទាល់តែលេចជោមកណ្ដាលជំនុំចំណោម . . . គេគិតតែនាំគ្នាសើចគឹលៗ..., ដល់មកល្ងាចនេះ គេឲ្យបញ្ចុកចេកព្រួសជាក់មុខគ្នា, យប់នេះទៀត មិនដឹងជាមានរឿងហេតុយ៉ាងណា យ៉ាងណាទៀតទេ បើយាយ ៗ ទាំងពីរនាក់នោះ បន្តិចមកខ្សិបខាងណេះបន្តិចទៅខ្សិបខាងណោះ . . . ឱអញអើយអញ! នៅសុខ ៗ មិនគួរបើមកខកខ្លួនដល់ម្ល៉េះសោះ " ៗ វេលានោះប្ដីប្រពន្ធទាំងពីរនាក់ ឥតមានពាក្យនិយាយគ្នាទៅវិញទៅមកថាដូច្នេះដូច្នោះទេ នៅតែស្ងៀមស្ងាត់រៀង ៗ ខ្លួន ៗ រំលងមកមួយស្របក់, នាងប្រពន្ធពន្លត់ចង្កៀងងងឹតឈឹងសូន្យ ៗ ប្ដីក្រោកឡើងស្ទាបរកឈើគូសចង់អុជចង្កៀងវិញ តែរកមិនឃើញក៏ប្រះដេកទៅវិញទៅ ៗ

វេលារាត្រីនោះ ប្រហែលម៉ោង ៩ ជិតភ្លឺ ស្រាប់តែនាយខ្បរទៅ

ដល់ផ្ទះ គោះទ្វារប៉ុក ៗ ហៅឪពុក មានទាំងហិបខ្មៅ(១) មួយស្ពាយ ប្រឆាំងទៅស្មាផង : " ឪអើយ ! អីឪ ! បើកទ្វារឲ្យខ្ញុំចូលផង " ។

–អាណាហ្នឹងគោះទ្វារទាំងយប់អធ្រាត្រ ?

– ខ្ញុំណាឪ ។

– អាណាខ្ញុំ ៗ ហ្នឹង អាខ្វ ឬ ?

– បាទ ខ្ញុំហ្នឹងហើយ ។ ឪពុកស្ទុះទៅបើកទ្វារឲ្យដោយភ័យផ្អក ៗ ផង " យីអើ ! ខ្មោចអាចោរអន្ធពាល ! ម៉េចក៏តែមកទាំងយប់អធ្រាត្រ ដូច្នេះ មានរឿងរ៉ាវយ៉ាងម៉េច ? ។ ខ្វចូលទៅក្នុងផ្ទះ ដាក់ហិបព្រុស ក្បែរកៀនជញ្ជាំង ហើយឈរសៀមបែបអេះអុញ មួយស្របក់ទើប និយាយ " រឿងស្រីនុ៎ងណា ..." ។

– ចុះនាងនុ៎ងវាយ៉ាងម៉េច វាមិនព្រមព្រៀង ឬ ក៏ឈ្លោះទាស់ ទែងគ្នាយ៉ាងណា ? អាឯងប្រាប់អញឲ្យអស់រឿងហូរហែមកមើល ។

– ខ្ញុំអៀនមាត់ណាស់ មិនចង់និយាយទេឪ ! ណ្ហើយ ! ឪឯង កុំដេញដោលសួរធ្វើអី ។

---

១– នៅស្រុកយើង ចាស់ពីដើម ច្រើនប្រើហិបខ្មៅដែលអ្នកខ្លះហៅថាហិបអាភៀន។ ហិបនោះ គេធ្វើពីឈើស្រល់យ៉ាងស្រាល, លាបថ្នាំខ្មៅរលោង ទំហំតូចល្មម មានត្រចៀកដែកទាំងសងខាងសម្រាប់ចាប់ លើកឬចងខ្សែស្ពាយឲ្យបានស្រួល; គំរបវាមានសណ្ឋានមូលល្អ ដូចគំរបក្តារមឈូសបិន, គេប្រើដាក់អាភៀននាំចូលមកលក់ក្នុងស្រុកយើង, កាលណាគេលក់អាភៀនអស់ទៅ បងប្អូនយើងជំនាន់នោះ ចូលចិត្តទិញហិបនេះយកប្រើសម្រាប់ដាក់ខោអាវ ។

-ទេ, បើអាឯងមិនប្រាប់រឿងអញៗ សំពងក្បាលអាឯងឥឡូវហ្នឹងៗ

-ចុះឲ្យខ្ញុំនៅដេកជាមួយឯណាផងបាន បើ . . . បើ . . . ។

-បើ . . . អី ? ។

-បើ... បើ... អត់អៀនអត់ខ្មាសអីសោះ លេងតែពន្ធត់បង្កៀង ហើយដេកប្រជ្រៀត, ខ្ញុំខិតទៅទើសជញ្ជាំងហើយ ក៏នៅតែតាមប្រជ្រៀតទៀត ហើយដៃនាងនោះនៅមិនស្ងៀមទេណាអើយ បេះតែលូកកាវឲ្យរើក បន្តិចស្ទាបត្រង់ណេះបន្តិចស្ទាបត្រង់ណោះ រកតែដេកមិនបាន, តាំងពីក្បាលល្ងាចមកខ្ញុំឥតបានផ្ទេចមួយប្រិមសោះ ។

ឪពុកក៏តែដើមទ្រូងគ្រឹត ៗ ទៅជាហួសចិត្ត ត្រឡប់ជាសើចផ្អើលគេផ្អើលឯងទាំងយប់ " អើ ! នេះបានបំផាកូនឪ ! អញខំរកប្រពន្ធការឲ្យអាឯង ពីព្រោះតែរឿងដេកប្រជ្រៀតហ្នឹងហើយ ឥឡូវ ត្រឡប់ទៅជាកំសាកញីពោលម្យ៉ៀតទៅវិញ ! ហ៊ុះ ! អញចង់តែណាក់អាឯងបំបាក់កឥឡូវហ្នឹង ធ្វើឲ្យអញខ្មាសគេពេញទាំងស្រុក ។

-ទេ ឪឯងទេតើដែលធ្វើឲ្យខ្ញុំខ្មាសគេ, តាមចិត្តដែលខ្ញុំទឹកមួយមៅក្តៅក្រហាយ ខ្ញុំចង់វត់ពោលតាំងពីកំពុងសំពះផ្ទឹមៈនោះម៉្លេះ តែនឹកសព្វ ៗ ទៅឃើញថាណ្ហើយ ! គួរទុកមុខមាត់ឲ្យឪឯងបន្តិចទៅចុះ ទើបខ្ញុំស៊ូទ្រាំបង្អង់ទៅវិញសិន, រឿងប្រពន្ធនេះ ខ្ញុំបានប្រកែកតាំងពីដំបូងថាទេ ៗ តែឪឯងហើយទទឹងម៉ែបេះតែបង្ខំខ្ញុំ ៗ ក៏ព្រមទាំងប្រចុយទៅ ។

- ឪពុកបែបតាល់ដើង ទើបត្រឡប់សួរសារដើម " ចុះកាលអាឯង ចុះចេញពីផ្ទះមកនោះ ប្រពន្ធអាឯងបានដឹងទេ ? " ។

- ឥតដឹងទេ គេកំពុងដេកលក់ ។

- ចុះម្តាយអាឯង ហើយនឹងឪពុកម្តាយក្មេកតើគេបានដឹងដែរឬទេ ?

- ឥតដឹងទាំងអស់ ព្រោះគេដេកលក់ស្ងាត់ស្ងៀមគ្មានសល់ម្នាក់ ។

- ណ្ហើយ ! ឥឡូវនេះ ត្រូវអាឯងត្រឡប់ទៅវិញជាមួយអញ ។

- ទេ ខ្មាសគេណាស់ ! ខ្ញុំបានគិតស្រេចហើយថា មកនេះគឺឥត ត្រឡប់ទៅវិញទេ ។

- ប្រាកដជាមិនទៅវិញមែនឬ អាខ្វៃ?

- បាទ ប្រាកដហើយ ។

ឪពុកស្ទុះចូលទៅក្នុងផ្ទះបាយ កន្ត្រាក់បានអង្រែបុកគ្រឿង ។ ខ្វៃ ឃើញដូច្នោះក៏អង្វរ " កុំអាលឪ... កុំអាលវៃខ្ញុំ... សុំឪអត់ទោស, ណ្ហើយចុះ រឿងត្រឡប់ទៅវិញនោះ មិនជាការធ្ងន់ស្រាលអីប៉ុន្មានទេ ខ្ញុំ ប្រថុយទៅវិញក៏បានដែរ, តែថាសុំឲ្យឪឯងទៅនិយាយសម្រុះសម្រួលនឹង នាងនោះសិនថា តទៅកុំឲ្យលេងតែដេកប្រជ្រៀតដូចយប់មិញនេះទៀត ទើបខ្ញុំព្រម ។

- ទេ! អញមិនឆ្កួតដូចអាឯងទេ ! ណ្ហើយ ! ខ្ជិលនិយាយដដែលៗ ឥឡូវបើអាឯងមិនចេះដេកប្រជ្រៀតជាមួយប្រពន្ធទេ យើងគិតប្រជ្រៀត

ជាមួយអង្រែបុកគ្រឿងនេះសាកល្បងមើលម្ដង ៗ ថាតែប៉ុណ្ណោះ ផុសស្ទុះភ្លែត, កូទគេបផ្លុបលោតព្រុសដល់ដី រត់រហូតក្រៅរបងផ្ទះ ៗ គ្រានោះឪពុកនាយខ្វរស្លៀកពាក់ខោអាវប្រញិកប្រញាប់ ហើយក៏ស្រូតរូតទៅផ្ទះដន្ទង ទាំងព្រឹកព្រហាម ដើម្បីឲ្យដំណឹងនឹងពិគ្រោះសម្រេចពីរឿងនេះ ៗ

យើងនឹងឆាកទៅមើលឯផ្ទះខាងស្រីឯណោះម្ដង តើមានហេតុការណ៍យ៉ាងណាខ្លះ ៗ ពេលព្រឹកនោះ នាងសាមីខ្លួនភ្ញាក់ឡើង ស្រាប់តែរកប្ដីមិនឃើញ ទាំងហិបនឹងខោអាវរបស់ប្ដីក៏បាត់អស់រលីង ៗ កាលបានដឹងដូច្នោះហើយ នាងក៏ភ័យបុកពោះផ្អក ៗ បានស្ទុះស្ទារទៅប្រាប់ឪពុកម្ដាយនឹងម្ដាយក្មេកតាមដំណើរ ៗ អ្នកទាំងអស់គ្នា ផ្អើលជ្រួលច្របល់ ខ្លះឡឹបខ្សៀវថាដូច្នេះ ខ្លះថាដូច្នោះ ខ្លះថាគេបានសង្កេតឃើញទឹកមុខកូនប្រុសតាំងពីល្ងាចម៉្លេះ គេស្មើរតែហ៊ានទាយទុកថា មុខជារត់ចោលប្រពន្ធពុំខានទេ ឥឡូវរត់បាត់មែន ៗ ម្ដាយបង្កើតរបស់នាយខ្វរ ឡើងទឹកមុខក្រៀមស្ពឹតស្ពៃស បាត់មាត់បាត់កនិយាយដូចម្ដេចក៏មិនកើត ៗ ពេលនោះគេបានហៅយាយចន្ទដែលជួយផ្សំដំណេកពីល្ងាចនោះ មកឲ្យជួយអង្កេតសាកសួរនាងប្រពន្ធយ៉ាងសម្ងាត់ ដើម្បីឲ្យបានដឹងជាក់ប្រាកដថា តើមានហេតុភេទដូចម្ដេចខ្លះក្នុងពេលយប់មិញ បានជានាយខ្វររត់បាត់ដូច្នេះ ៗ យាយក៏បានចូលទៅក្នុងបន្ទប់ស្ងាត់តែពីរនាក់នឹងសាមីខ្លួន ហើយផ្ដើមសួរ " នាង ! សុំនាងប្រាប់យាយឲ្យត្រង់មកមើល តើយប់មិញមានរឿង

ហេតុដូចម្ដេចខ្លះ  បានជាប្ដីនាងតែបាត់ទាំងយប់ដូច្នេះ ។

— ចាស ! គ្មានរឿងអីជាធំដុំទេ  ក្រោយពីពន្លត់ចង្កៀងមួយសន្ទុះធំ ខ្ញុំគ្រាន់តែធ្វើតាមបណ្ដាំយាយឯងប៉ុណ្ណោះ  ព្រោះយាយបានប្រាប់ថា គោងដៃដល់បន្តិច—ខ្ញុំនឹកឡើងចង់តែសើច—ដំបូង ខ្ញុំលូកដៃស្ទាប ១ ទៅ ស្រាប់តែប៉ះចំចង្កេះ  គេក្ដាក់ព្រើត  បែបរសើបខ្លាំង  រួចគេខិតរហូតដល់ កៀនជញ្ជាំង ។  យាយច័ន្ទសើចញញឹម : " ចប់ណាស់អញ ! ចប់តែ មិនមែនប៉ះចំចង្កេះ ក្រែងប៉ះចំត្រង់កន្លែងក្រោមចង្កេះទេដឹង ?

នាងសើចទើចបបូរមាត់: " អត់ទេ, ប៉ះចង្កេះមែន ខ្ញុំមិនកុហកទេ ។

— រួចយ៉ាងម៉េចទៅទៀត ?

— មួយស្របក់  ខ្ញុំប្រថុយខិតទៅតាម  ហើយលូកដៃរាវសាកល្បង មើលទៀត  ព្រោះខ្ញុំគិតឃើញថាបើទើសនឹងជញ្ជាំងទៅហើយ  តើគេស្ទុះ ទៅខាងណាទៀត,  លូកស្ទាបម្ដងណោះ  លេងពារចំត្រង់កន្លែងក្រោម ចង្កេះមែន,  ស្រាប់តែគេប្រឡេតខ្លួន  ដូចគោស្ទាវត្រូវមួយជន្ទញអីចឹង រួចទៅទង្គិចនឹងជញ្ជាំងព្រូសគ្រាំង ។

— យាយសើចក្អាក ១ : "អុញនុះ ! អញថាមែន ១ អីចា: ! អញ ថាមុខជាមានបើប៉ះពារចំកន្លែងអី ១ នុងមិនខានទេ, ឥឡូវមែន . . . គិត ទៅមង្គលការចៅឯងនេះ  មានរឿងចំឡែកនាំឲ្យបានសើចសប្បាយច្រើន ណាស់ ដូចកាលពីក្បាលព្រលប់ពេលផ្សំដំណេកម្សិលមិញដែលគេមពុក

បេកមកប៉ះបំប្រមុះទៅឯង ហើយព្រួសបេកដាក់មុខគ្នានោះ យាយសើច អើយសើច យាយទៅដល់ផ្ទះចូលដំណេកហើយក៏នៅតែសើចម្នាក់ឯង ទៀត ឥឡូវនេះទៅឯងលេងលូកដៃស្ទាបទាល់តែប៉ះចំអ៊ីកន់របស់គេវិញ, តែចំណែកគេ ៗ បានប៉ះតែគ្រឿងលើរបស់យើង ឯយើងលេងពារបំ គ្រឿងក្រោមសំខាន់របស់គេតែម្តង, គិតទៅទុកជាបានស៊ីសងរួចគ្នាដែរ... នៃទៅ! ហើយរួចពីនេះយ៉ាងម៉េចទៅទៀត ?

— ចាស ! តពីនេះទៅ គេស្ទុះក្រោកក្រេសទៅអង្ក្រុយចុងជើង ដក ដង្ហើមយូ ៗ បែបតឹងទ្រូងខ្លាំង, ចំណែកខ្ញុំ ៗ អស់កំឡាំងហើយនុយដេក ផង ខ្ញុំក៏ដេកលក់ទៅ, ភ្ញាក់ព្រលឹមឡើងស្រាប់តែបាត់គេតែម្តង មិនដឹង ជាគេទៅពីថ្មើរម៉ាន ហើយទៅឯណានោះ ខ្ញុំឥតបានដឹងសោះ, រឿង ក៏តែយប់មិញ មានតែប៉ុណ្ណោះ សូមយាយជ្រាប ៗ

— អូ! បើដូច្នោះ យប់មិញនេះគ្មានបានសម្រេចការអើម្យ៉ាង ៗ ជាធំ ដុំសោះទេ, រួបរួមសេចក្តីទៅឃើញថា គ្រាន់តែខាងគេឯណោះបាន ប៉ះប្រមុះយើង ហើយខាងយើងឯណោះបានស្ទាបប៉ះចំអ៊ីកន់គេតែប៉ុណ្ណោះ ឯង, ដូច្នេះ រឿងនេះគឺនៅបរិសុទ្ធស្អាតទាំងអស់គ្នា, ណ្ហើយ ! យាយ បានដឹងរឿងក៏តែប៉ុណ្ណឹងបានហើយ យាយសុំអរគុណទៅ! ៗ និយាយ ដូច្នេះហើយ យាយច័ន្ទក៏ចេញពីក្នុងបន្ទប់មកក្រៅ បានទៅជួបជុំខ្សែបខ្សៀវ រៀបរាប់ប្រាប់ឪពុកម្តាយនឹងម្តាយក្មេកនាងសាម៉ុន តាមដំណើររហូរហែ ដូចបានសាស័ព្ទខាងដើមមកហើយនេះឯង ៗ អ្នកទាំងអស់ ទៅជានាំ

គ្នាសើចក្អាកក្អាយពេញទាំងផ្ទះ ។

កន្លងពេលកំពុងជួបជុំសន្ទនាគ្នានោះ ស្រាប់តែលេចឪពុកខ្ញុំឡើង ក្តែតទៅដល់លើផ្ទះ ។ ឪពុកខាងស្រី ស្រែកភ្លាមដោយសេចក្តីត្រេកអរ "អូ! នំ! អ្នកជនូងអញ្ជើញមកដល់ហើយតើ, អញ្ជើញអង្គុយ! ខ្ញុំកំពុងគិតប្រើអ្នកណាម្នាក់ឲ្យទៅជំរាបសួរអ្នកឯណោះ កុំអីជ្រួសគ្នា, ឥឡូវបានអ្នកអញ្ជើញមកស្រួលហើយ ម៉េចទៅមានឃើញវាទៅឯផ្ទះឯណោះដែរឬទេ? ។ ឪពុកខ្ញុំ ដាក់គូថអង្គុយ មិនតបភ្លាមទេ ព្រោះគាត់កំពុងហត់ខ្លាំង, មួយស្របក់ទើបឆ្លើយ "បាទ, ឃើញ! ប្រហែលម៉ោង ៥ ជិតភ្លឺវាទៅដល់, រឿងនេះ ខ្ញុំក្តៅក្រហាយណាស់អ្នកអើយ, នឹកឡើងវាខ្មាសអ្នកជនូងហើយនឹងញាតិមិត្តទាំងអស់ ហួសពីខ្មាសទៅទៀតហើយក្នុងគ្រានេះ, តែមិនដឹងធ្វើដូចម្តេច បើរឿងនេះវាហួសជ្រុលអស់ទៅហើយ" ។ បន្ទាប់មក បុរសក៏រៀបរាប់អំពីពាក្យឆ្លើយឆ្លងរបស់ខ្លួននឹងកូនប្រុសហូរហែតាមដំណើរសព្វគ្រប់ រហូតដល់គាត់ដេញសំពងវា ។ លោតធ្លាក់ពីលើផ្ទះរត់បាត់ទៅទាំងព្រឹកនោះឯង ។ អ្នកទាំងអស់គ្នា បានស្តាប់ហើយ ក៏ទៅជានាំគ្នាសើចសប្បាយទៅវិញ ព្រោះបានផ្ទៀងផ្ទាត់មើលរឿងខាងណោះនឹងខាងណេះទៅ ឃើញថាវាត្រូវដំណើរទំនងស៊ីគ្នាឥតល្អៀងសោះ ។ ទីបំផុត ជនូងខាងប្រុសផ្តើមនិយាយ: "ខ្ញុំសុំជំរាបស្មើដល់អ្នកជនូង, តាមតែអ្នកអត់ទោសផងចុះ! ឥឡូវរឿងកូនយើងទាំងពីរនេះ ឃើញថាវាមិនបានជាប់គ្នាជាប្តីប្រពន្ធទេ ព្រោះ

ហេតុមកពីកូនប្រុសខ្ញុំវាអៀនខ្មាសគោតល្ងង់ណាស់ ដូចអ្នកបានដឹងរឿងហូរហែរចមកហើយ , កាលពីមុនខ្ញុំមិនស្មានថាវាជាមនុស្សពោលម្បៀតដល់ម្ល៉ឹងសោះ, ចំណែកខាងខ្ញុំ ការបង់ខាតរណ្ដាប់រណ្ដាជំនូនជូនដាក់ទាំងប៉ុន្មានក្នុងមង្គលការនេះ គឺវាជ្រុលហួសអស់ទៅហើយ, ឯខាងអ្នកឯណោះក៏មានបង់ខាតខ្លះដែរ គិតទៅទុកជាបង់អភ័ព្វទាំងអស់គ្នាទៅចុះ, រីឯកូនស្រីអ្នក ក៏ឃើញថានៅបរិសុទ្ធស្អាតដូចជានៅក្រមុំដដែលទេ, ឥឡូវយើងនឹងគិតលៃលកយ៉ាងណា ក៏គ្មានផ្លូវកែខៃដែរ ព្រោះអាពោលម្បៀតកូនប្រុសខ្ញុំនោះវាបានដាក់ ខសន្យាដូចខ្ញុំបាទជំរាបអ្នកអម្បាញ់មិញនេះរួចហើយថា ទាល់តែកុំឲ្យដេកប្រជ្រៀតគ្នា ទើបវាព្រមត្រឡប់មកជួបជុំគ្នាវិញ, សូមអ្នកជួយស្ដាប់ហើយពិចារណាមើលចុះ ពាក្យនេះគឺវានិយាយបំផុតដើងយើងតែម្ដង, ពេលនេះ ខ្ញុំសូមជូនពាក្យសំដីព្រមទាំងសូមជូនកូនស្រីដល់អ្នកវិញចុះ បើមានគេមកគិតគូរស្ដីដណ្ដឹងទៅថ្ងៃក្រោយ សូមអ្នកលៃលកយ៉ាងណា ក៏សម្រេចតាមអធ្យាស្រ័យអ្នកចុះ កុំឲ្យទាក់ទាមមកខាងខ្ញុំទៀត, តែចំណែកការរាប់អានគ្នា យើងត្រូវតែមានក្ដីស្មោះសរទៅវិញទៅមកទាក់ទងជាញាតិមិត្រតរៀងទៅ សូមអ្នកកុំអាក់អន់ស្រពន់ចិត្តអី . . ., ពាក្យដែលខ្ញុំជំរាបស្នើមកប៉ុណ្ណោះ តើអ្នកយល់ដូចម្ដេច ?

— ឪពុកកូនស្រីតប “ បាទ, ចំណែកប៉ែកខាងខ្ញុំឯណោះ ឥតមានយោបល់យល់ទាស់អ្វីទេអ្នក បើបានជួបជុំគ្នាវិញក៏អរ តែឥឡូវបើ

មិនបានជួបជុំគ្នាទេ ក៏មិនជាការអ្វីប៉ុន្មានដែរ, ឯសេចក្ដីស្នើរបស់អ្នកនេះ ល្មមគួរសមហើយ ដូច្នេះ យើងត្រូវតែបញ្ចប់រឿងហ្នឹងត្រឹមនេះទៅចុះកុំឲ្យវាវែងឆ្ងាយតទៅទៀត ធ្វើម្ដេចបើកូនប្រុសអ្នក គេមិនចេះដេកប្រជ្រៀត" ៗ

គ្រានោះ, ឪពុកម្ដាយនាយខ្វរ ក៏បានជំរាបលាជនូងវិលត្រឡប់ទៅផ្ទះវិញដោយសេចក្ដីក្រៀមក្រំ ។ ក្នុងរយៈពេលកំពុងធ្វើដំណើរទៅនោះ ប្ដីប្រពន្ធទាំងពីរនាក់ ចេះតែពិគ្រោះគ្នារអ៊ូតាមផ្លូវអំពីរឿងនេះ ៗ ដល់ទីបំផុត, ប្ដីនិយាយថា អាខ្វរវាបន្ទោសថាយើងធ្វើឲ្យវាខ្មាសគេ, ចំណែកយើង ៗ ក៏ថាវាធ្វើឲ្យយើងខ្មាសគេដែរ ចូរឯងគិតមើលចុះរឿងហ្នឹង, តែបើតាមអញដេញដោលរកឬសគល់ឲ្យជ្រៅឆ្ងាយទៅទៀត ឃើញថាៈទាស់ខុសមកពីយើងច្រើនដែរ ព្រោះរឿងប្រពន្ធនេះយើងចេះតែបង្ខំវាហើយ កំហុសធំម្យ៉ាងទៀតគឺតាំងពីវានៅតូចនៅឡើយនោះ យើងមិនបានពត់បង្ហាត់ទម្លាប់បណ្ដើរ ៗ ឲ្យវាចេះពុះពារ ឲ្យវាចេះក្លាហាន ឲ្យវាចេះប្រស្រ័យទាក់ទង ឲ្យវាចេះចូលជំនុំចំណោមនឹងគេសោះ យើងបានជំរុញវាឲ្យធ្វើតែត្រឹមកិច្ចការកាប់គាស់ដីធ្វើស្រែចំការតែប៉ុណ្ណោះ ម្ល៉ោះហើយវាទៅជាមនុស្សកុយមុយមុខខ្វរខូចអស់ ដល់វាមកជួបប្រទះផ្ទាល់ខ្លួនលើពេលជំនុំចំណោមធំ ៗ ដូចជាមង្គលការខ្លួនវានេះក៏ស្រាប់តែអន្តរធានទាំងវាទាំងឯងតែម្ដងទៅ, ណ្ហើយយើងជាន់នេះ ដាក់ចុះចិត្តថាទុកដូចជាចាក់អាប៉ោងខុសមួយចានទៅចុះ ។

## ផ្នែកកំណត់ដំណឹងប្រវត្តិការណ៍

# បុណ្យនមស្ការព្រះសក្យមុនីចេតិយ
# និងវិសាខបូជា

លោក ស្ដើង-ឆ្វូរ រៀបរៀង

ដូចអស់លោក-អ្នក បានជ្រាបស្រាប់មកហើយថា: បុណ្យនមស្ការព្រះសក្យមុនីចេតិយជាបុណ្យជាតិមួយ ផ្នែកខាងព្រះពុទ្ធសាសនា ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះនរោត្តមសុរាម្រឹត ព្រះចៅប្រទេសកម្ពុជា ជាទីគោរពនឹងជាទីស្នេហាស្មើដោយជីវិតនៃប្រជាជាតិខ្មែរ, កាលដែលព្រះអង្គទ្រង់គង់នៅ ក្នុងសិរីរាជសម្បត្តិនៅឡើយ ព្រះអង្គទ្រង់បានឲ្យព្រហស្ដលេខាលើព្រះរាជក្រិត្យលេខ ៧៣ ន.ស. ចុះថ្ងៃទី ២៤ មករា ១៩៥៨ កំណត់ឲ្យធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយនេះ នៅថ្ងៃ ១៥ កើតនឹង ថ្ងៃ ១ រោចខែពិសាខ ជាដរាបរៀងរាល់ឆ្នាំតទៅៗ តាំងពីពេលនោះមក, រាល់ថ្ងៃ ១៥ កើតនឹងថ្ងៃ ១ រោចខែពិសាខ នៅមុខព្រះសក្យមុនីចេតិយ ខាងកើតស្ថានីយរាជអយស្ម័យយាន ប្រទេសកម្ពុជា មានរៀបពិធីដ៏ឱឡារិកអធិកអធម ដើម្បីធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយ នឹងវិសាខបូជា ។ ឆ្នាំនេះ ជាឆ្នាំខួបទី ៤ នៃពិធីបុណ្យនេះ ព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ក៏បានរៀបធ្វើពិធីនេះដូចពីឆ្នាំមុនៗដែរ ។

ថ្ងៃ ១៤ កើតខែពិសាខ ( ២៩ មេសា ១៩៦១ )

ម៉ោង ១៧ និង ៣០ នាទី ជួបជុំព្រះសង្ឃ ៨០ អង្គ, ព្រះរាជវង្សានុវង្ស, សហជីវិនចៅសែនកុសល ហៅឈុំ ប្រធានរដ្ឋសភា ព្រមទាំងសមាជិក; អ្នកអង្គម្ចាស់នរោត្តម-កន្តុល ប្រធានក្រុមប្រឹក្សាព្រះរាជាណាចក្រ ព្រមទាំងសមាជិក, សមាជិករាជរដ្ឋាភិបាល, ប្រធាននៃពុទ្ធិកសមាគមទាំង ៣ មន្ត្រីគ្រប់ដំណែង ទាំងទាហាន-ទាំងស៊ីវិល លោកស្រី, ឧបាសក, ឧបាសិកា បាននិមន្ត - ស្តេចយាង - អញ្ជើញដល់ ។

ម៉ោង ១៨ គត់ សម្តេចក្រុមព្រះស៊ីសុវត្ថិ-មុនីរ៉េត ប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក ជាព្រះរាជតំណាង ដោយមានសមាជិកឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្ក និងព្រះរាជបរិពារតាមហែ បានស្តេចយាងដល់ព្រះពន្លា ដែលនៅពេលនោះទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរ-ភូមិន្ទ ក្រុមភ្លេងកងវរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យធ្វើគារវកិច្ចតាមទំនៀម ។

ក្រោយដែលសម្តេចព្រះរាជតំណាង បានទទួលនូវគារវកិច្ចអំពីកូនចៅព្រះអង្គហើយ ព្រះអង្គទ្រង់ប្រថាប់លើព្រះសុវណ្ណកោច្ឆៈនាព្រះពន្លា ។ ពេលនោះ, ពិធីបង្ហូតទង់ជាតិ បន្ទំដោយបទនគររាជ; បង្ហូតទង់សាសនា បន្ទំដោយបទសរភញ្ញ តាមសូរស័ព្ទនៃសំឡេងសិស្សប្រុស-ស្រីយ៉ាងគ្រលួច ក៏បានប្រារព្ធឡើងក្នុងបរិយាកាសដ៏ស្ងប់ស្ងាត់ និងអនុស្សាវរីយ៍

ដំជ្រាបផ្ញាយ ។ ព្រះសង្ឃ-គ្រហស្ថគ្រោកឈរ បែរព្រះភក្ត្រ-មុខគោរព ចំពោះព្រះសក្យមុនីចេតិយ ។

បន្ទាប់មក សហជីវិន ស៊ិន - ប៊ុប្ផកោ រដ្ឋលេខាធិការក្រសួងធម្មការ កងនាមនៃព្រះរាជរដ្ឋាភិបាល បានថ្លែងនូវសុន្ទរកថាមួយមានសេចក្ដីដើមដូចតទៅនេះ ៖

សូមព្រះតេជះគុណលើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល សម្ដេចក្រុមព្រះ ជាព្រះរាជតំណាងនៃសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

កងនាមនៃព្រះរាជរដ្ឋាភិបាល និងកងនាមនៃទូលព្រះបង្គំជាខ្ញុំ ជារដ្ឋលេខាធិការក្រសួងធម្មការ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាតសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាធិគុណនៃល្អងធូលីព្រះបាទ ដែលបានស្ដេចយាងជាព្រះរាជាធិបតី ក្នុងពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ នាថ្ងៃនេះ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះរាជឱកាសសម្ដេចជាអម្ចាស់ ដើម្បីថ្លែងនូវប្រវត្តិនៃព្រះបរមសារីរិកធាតុ និងសេចក្ដីគោរព ចំពោះព្រះសក្យមុនីចេតិយនេះ ។

សូមទ្រង់ព្រះមេត្តាប្រោស !

ព្រះបរមសារីរិកធាតុ ដែលដំកល់នៅលើកំពូលព្រះសក្យមុនីចេតិយនេះ គឺជាកស្តូតាន៍នៃស្នាព្រះហស្តសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់បានទទួលផ្ទាល់អំពីលោកអ្នកថែរក្សាព្រះបរមសារីរិកធាតុ នៅក្រុងកុណ្ឌី ប្រទេសសិរីលង្កា ដែលបានថ្វាយចំពោះព្រះអង្គ ។

នៅឱកាសដែលប្រទេសកម្ពុជា ធ្វើពិធីបុណ្យពុទ្ធសករាជ ២៥០០ ដែលពុទ្ធបរិស័ទនិយមហៅថា ជាបុណ្យពាក់កណ្តាលព្រះសាសនា ព្រះអង្គទ្រង់ព្រះតំរិះដោយព្រះវិចារណញ្ញាណឈ្វេងយល់ថា ការដែលព្រះអង្គបានទទួលព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធបរមគ្រូ ជាភ័ព្វព-សនាដ៏ឧត្តមនៃព្រះអង្គ ទើបព្រះអង្គទ្រង់សព្វព្រះរាជហ្ឫទ័យប្រកបដោយនូវសេចក្តីជ្រះថ្លាជាតិយោក្រភាព ទ្រង់ប្រោសព្រះរាជទានឲ្យមានធ្វើពិធីដង្ហែព្រះបរមសារីរិកធាតុមកដំកល់ទុក នៅលើកំពូលព្រះសក្យមុនីចេតិយ ដែលប្រកបដោយទស្សនីយភាពរុងរឿងក្នុងឱកាសដ៏ឧឡារិកនេះ ដើម្បីជាទីគោរពសក្ការៈបូជានៃប្រជាជាតិទូទៅ នាកាលថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ១៩៥៧ ។

បន្ទាប់មក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម - សុរាម្រឹត ដែលជាទីគោរពនៃប្រជាជាតិ កាលព្រះអង្គទ្រង់គង់នៅក្នុងសិរីរាជសម្បត្តិនៅឡើយ ព្រះអង្គទ្រង់បានឡាយព្រះហស្តលេខា

លើព្រះរាជក្រឹត្យលេខ ៧៣ នស. ចុះថ្ងៃទី ២៤ មករា គ.ស. ១៩៥៨ កំណត់ឲ្យធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយនេះ នៅថ្ងៃ ១៥ កើត ទីង ថ្ងៃ ១ រោចខែពិសាខ ជាដរាបរៀងរាល់ឆ្នាំតមក, ដោយទុកពិធីបុណ្យនេះជាបុណ្យជាតិផ្នែកខាងព្រះពុទ្ធសាសនា ។

ក្រសួងធម្មការ ដោយអនុវត្តន៍តាមព្រះរាជក្រឹត្យខាងលើនេះ បានប្រជុំជាមួយនឹងទីស្ដីការរដ្ឋមន្ត្រីនានា ព្រមទាំងសាលាក្រុង ចាត់ការធ្វើពិធីបុណ្យនេះចំនួន ៣ ឆ្នាំកន្លងមកហើយ ឃើញថាពិធីនេះ មានអាយុបាន ៤ ឆ្នាំ បើរាប់ទាំងឆ្នាំ ១៩៦១ នេះផង ។

សូមទ្រង់ព្រះមេត្តាប្រោស,

បន្ទាប់ពីនេះទៅ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះរាជឱកាសសម្ដេចជាអម្ចាស់ ថ្លែងនូវសេចក្ដីគោរពចំពោះព្រះបរមសារីរិកធាតុ ដែលទ្រង់ប្រតិស្ឋានទៅក្នុងព្រះសក្យមុនីចេតិយ តាមន័យដូចតទៅនេះ ៖

សូមនមស្ការព្រះសមណៈគោត្តមបរមសម្ពុទ្ធជាម្ចាស់ ថ្ងៃនេះជាថ្ងៃ-១៥ កើត ខែពិសាខ ដែលព្រះអង្គទ្រង់ប្រសូត ទ្រង់ត្រាស់ដឹងនូវព្រះអនុត្តរសម្មាសម្ពោធិញាណ ទីងទ្រង់ចូលព្រះបរមនិព្វានជាទក្ខត្តឫក្សប្រកបដោយសុភមង្គលយ៉ាងឧឡារិក ហើយដែលពុទ្ធបរិស័ទបានចងចាំទុកជានិច្ចក្នុងដួងចិត្តរៀងរាល់ខួប ពុំភ្លេចសោះឡើយ ។

បពិត្រព្រះបរមគ្រូជាម្ចាស់ ពិតមែនតែព្រះអង្គទ្រង់ចូលកាន់ព្រះបរម

និព្វានទៅ ២៥០៤ ឆ្នាំ ហើយ ក៏ប៉ុន្តែ ព្រះសាសនធម៌ដែលជាទុកទ្រ នៃព្រះអង្គ និងព្រះបរមសារីរិកធាតុដែលជាព្រះសរីរកាយរបស់ព្រះអង្គ ព្រមទាំងព្រះពុទ្ធបដិមាករដែលជាទុតេទ្ធសកចេតិយស្នងព្រះអង្គ បានឋិតថេរគង់វង់នៅទាំងអស់ ឥតមានរលុបរលាយសូន្យទៅឡើយ ។

ព្រះសាសនធម៌របស់ព្រះអង្គនេះ បានមកប្រតិស្ឋាននៅក្នុងប្រទេសកម្ពុជា តាំងពីសតវត្សរ៍ទី ១០ នៃពុទ្ធសករាជ គិតទៅ ១.០០០ ប្លាយឆ្នាំហើយ តែជំនឿនិងការគោរពពក់អានយ៉ាងមោះមុត របស់ប្រជាជាតិខ្មែរ ដែលមានព្រះមហាក្សត្ររបស់ខ្លួនជាទីគោរព បានរក្សាទុកនូវព្រះពុទ្ធោ-វាទរបស់ព្រះអង្គឲ្យមានថិរភាពនឹងវឌ្ឍនភាពរុងរឿងជានិច្ច ហាក់ដូចកាលព្រះអង្គទ្រង់គង់ព្រះជន្មាយុនៅឡើយ ។

បពិត្រព្រះគគវន្ទមុនី,

ថ្ងៃនេះជាអភិលក្ខិតកាលប្រកបដោយសិរីសួស្តី ជ័យមង្គលដ៏ប្រសើរ ប្រជាជាតិខ្មែរទាំងមូល មានសម្តេចក្រុមព្រះ ជាព្រះរាជាធិបតីបានស្តេចយាងមកជួបជុំក្នុងទីនេះ ដើម្បីធ្វើពិធីអស្ចារ្យជាទី ឡារិករំឭកចំពោះព្រះមហាករុណាទិគុណដ៏ថ្លៃថ្លានៃព្រះអង្គ ដែលមានព្រះបរមសារី-រិកធាតុរបស់ព្រះអង្គ ប្រតិស្ឋាននៅនាព្រះសក្យមុនីចេតិយនេះ ដោយគ្រឿងសក្ការៈបូជាមានទៀន-ធូប-ផ្កាភ្ញីជាដើម ។ កាលគង់ព្រះជន្មនៅឡើយ ព្រះអង្គធ្លាប់តែមានទឹកព្រះរាជហឫទ័យ ស្រោចស្រប់ទៅលើសត្វ-

លោកទាំងមូលជាអនន្តគុណ ដោយបានប្រតិស្ឋានព្រះពុទ្ធោវាទឲ្យសព្វសត្វទាំងអស់ បានក្រេបជញ្ជក់គោលគឺគោរពប្រតិបត្តិតាមមករហូតដល់សព្វថ្ងៃនេះ ។

នៅទីអវសាន ក្នុងនាមព្រះរាជរដ្ឋាភិបាល រដ្ឋសភា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ មន្ត្រីគ្រប់តំណែង ទាំងទាហានទាំងស៊ីវិល ព្រមទាំងប្រជាជាតិទាំងមូល ខ្ញុំព្រះករុណាទាំងឡាយ សូមបួងសួងចំពោះគុណព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយបីបាច់ថែរក្សាសម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គទ្រង់បានប្រកបដោយនូវសេចក្តីសុខ·ចំរើន និងសិរីសួស្តីជ័យមង្គល មានព្រះជន្មាយុយឺនយូរអស់រយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ដល់ប្រជានិករក្នុងព្រះរាជអាណាចក្រទាំងមូល ។

មួយវិញទៀត សូមប្រមូលកុសលរាសីទាំងអស់ដែលកើតមកពី ពិធីបុណ្យនេះ ក្រាបបង្គំទូលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃព្រះមហាកាញ្ចនកោដ្ឋ និងអតីតព្រះមហាក្សត្រទាំងអស់ ដែលបានគ្រប់គ្រងកម្ពុជរដ្ឋប្រកបដោយនូវទសពិធរាជធម៌ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ទទួលនូវឥដ្ឋមនុញ្ញផលវិបុលសុខ ដោយព្រះរាជហឫទ័យប្រកបដោយសោមនស្សប្រេតនា ៗ ចំពោះសមាជិកសភាទាំង ២ សមាជិកនៃរាជរដ្ឋាភិបាល និងនាម៉ឺនសព្វមុខមន្ត្រីទាំងទាហាន - ទាំងស៊ីវិល និងពុទ្ធបរិស័ទទាំងអស់

កំសូមឲ្យបានប្រកបដោយនូវសេចក្តីសុខចំរើនគ្រប់ប្រការ នឹងសូមឲ្យសាមគ្គីធម៌ពេញគ្នានឹងគ្នា បានគង់វង់នៅជាដរាបតទៅ ដើម្បីធ្វើការបំរើប្រទេសជាតិតាមសមត្ថកិច្ចរៀង ៗ ខ្លួន នឹងតាមតម្រាយព្រះមាគ៌ានយោបាយដែលអង្គសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គមគ្គុទ្ទេសក៍ទ្រង់បានត្រួសត្រាយឲ្យយើងៈដើរតាមក្រោយព្រះអង្គ ។

ទោៈទីបំផុត សូមព្រះរតនត្រ័យ ជួយប្រោះព្រំពិភពលោកទាំងមូលឲ្យបានបិតនៅក្នុងសន្តិភាពជានិរន្តរ៍តរៀងទៅ ។

ជយោ ព្រះពុទ្ធសាសនា

ជយោ ប្រទេសកម្ពុជា

ជៈយោ ព្រះរាជបល្លង្ក

លុះចប់សុន្ទរកថា នៃសហជីវិនរដ្ឋលេខាធិការក្រសួងធម្មការហើយ, មានធ្វើពិធីនមស្ការព្រះបរមសារីរិកធាតុ ដោយលោក ឈឹម - សុមន៍ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត នាំពុទ្ធបរិស័ទឲ្យថាតាមមានសេចក្តីដូចតទៅនេះ ៖

## ៣. គាថានមស្ការព្រះបរមសារីរិកធាតុ

ក្នុងឱកាសបុណ្យនមស្ការព្រះសក្យមុនីចេតិយ

អាយសេដ្ឋិ សម្ពុទ្ធោ ករុណា យោ តថាគតោ

សមសីត្យាយុកកាលេ បរិនិព្វាយិ សោ មុនិ

តស្ស សារីរិកា ធាតុ អម្ហាកំ បមុខេ ឋិតា

ឥធាគតោ ច សោ សត្ថា ធរមានោវ តិដ្ឋតិ

សក្ការេហាភិបូជេម តំ នមស្សាម សាទរំ

សាធុ នោ ភគវា នាថោ សព្វញ្ញូ សន្តិនាយកោ

ឥមេ ទលិទ្ទសក្ការេ អនុកម្បាយ គណ្ហាតុ

ទីឃរត្តំ ហិតាយេវ សុខាយម្ហាក សព្វទា ។

“ ព្រះតថាគត ភគវន្តមុនី អង្គណា ទ្រង់បានត្រាស់ហើយ (ឋិតនៅ ) អស់កាល ៤៥ ឆ្នាំ, ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនី ទ្រង់បរិនិព្វានហើយ ក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ ឆ្នាំគត់; (ឥឡូវ) ព្រះបរមសារីរិកធាតុនៃព្រះអង្គមកប្រតិស្ឋាន ក្នុងទីចំពោះមុខនៃយើងខ្ញុំព្រះអង្គ ហាក់ដូចជាព្រះបរមសាស្តាអង្គនោះទ្រង់គង់ព្រះធរមាននៅឡើយ ស្តេចយាងមកគង់ក្នុងទីនេះ យើងខ្ញុំ សូមបូជាចំពោះព្រះអង្គដោយគ្រឿងសក្ការៈទាំងឡាយ សូមនមស្ការព្រះអង្គ ដោយគោរព; សូមព្រះភគវន្តមុនី សព្វញ្ញូពុទ្ធ បរមលោកនាថ ដែលតែងតែប្រោសប្រទានសន្តិសុខដល់សត្វលោកទ្រង់ព្រះមេត្តាប្រោសទទួលនូវគ្រឿងសក្ការៈទាំងឡាយរបស់យើងខ្ញុំព្រះអង្គ ដែលជាសក្ការៈបូជារបស់អ្នកកំសត់ទុគ៌តនេះ ដើម្បីអនុគ្រោះយើងខ្ញុំព្រះអង្គឲ្យបានហិតប្រយោជន៍និងសេចក្តីសុខ

សព្វកាលវេលាយូរអង្វែងទៀតទៅហោង ” ។

( ក្រាបថ្វាយបង្គំ ៣ ដង )

លំដាប់មក សម្ដេចព្រះរាជតំណាង ព្រមទាំងវរជនឧបាសក-សិកាទាំងអស់ បានស្ដេចយាង និងអញ្ជើញទៅប្រទក្សិណព្រះសក្យមុនីចេតិយបីជុំ ហើយទ្រង់បូជាកម្រងមាលា ។ ចំណែកព្រះសង្ឃ-និងពុទ្ធបរិស័ទដែលពុំបានទៅ បានក្រោកឈរគោរពចំពោះព្រះសក្យមុនីចេតិយ ។ លុះចប់បូជនីយកិច្ចនេះហើយ, សម្ដេចព្រះរាជតំណាង ស្ដេចយាងគង់ប្រថាប់ក្នុងព្រះពន្លាវិញ ទ្រង់ព្រះសណ្ដាប់ព្រះសង្ឃ ៨០ អង្គដែលគង់កៅអីចំរើនពុទ្ធជយមង្គលគាថា រួចស្ដេចយាងត្រឡប់វិញដោយមានព្រះរាជបរិពារដែលតាមទៅ ។

បន្ទាប់ពីនោះ ពុទ្ធបរិស័ទគ្រប់ឋានៈ ចូលធ្វើសក្ការបូជាព្រះសក្យមុនីចេតិយ ដោយទៀន ធូប ភ្ញី ផ្កា និងបច្ច័យ រហូតដល់ម៉ោង ២០ ។ ចាប់ពីម៉ោង ២០ និង ៣០ នាទីទៅ មានធ្វើពិធីវិសាខបូជាដោយព្រះភិក្ខុសង្ឃនិងព្រះធម្មទេសនា ដោយសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ; វិសាខបូជា ដោយព្រះភិក្ខុសង្ឃ និងធម្មទេសនាដោយព្រះសមាធិធម្ម មាស-គន់ ជាតំណាងសម្ដេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិកនិកាយ បានប្រព្រឹត្តទៅក្រោមកិច្ចចាត់ចែងនៃពុទ្ធិកសមាគមទាំង ៣ ក្នុងការឧបត្ថម្ភនៃក្រសួងធម្មការ រហូតដល់

ម៉ោង ១ និង ៣០ នាទី ទើបបប់សព្ទគ្រប់ ។

ថ្ងៃ ១ កើតខែពិសាខ ( ៣០ មេសា ១៩៦១ ) វេលាម៉ោង ៨ និង ៣០ នាទី មានការជួបជុំដូចកាលពីល្ងាចថ្ងៃដំបូង ។ ដល់ម៉ោង ៨ និង ៤៥ នាទី សម្ដេចក្រុមព្រះ ជាព្រះរាជតំណាងដោយមានព្រះរាជបរិពារផ្គាល់ព្រះអង្គតាមហែ បានស្ដេចយាងមកដល់ ដែលមានទាហានក្រុមរក្សាព្រះអង្គ ក្រុមខេមរភូមិន្ទ ក្រុមកងរសេនាតូចរក្សាព្រះអង្គ ក្រុមតន្ត្រីព្រះរាជទ្រព្យធ្វើគារវកិច្ចតាមទំនៀមរួចហើយ ទ្រង់ប្រថាប់កុនព្រះពន្លាសមាទាននិច្ចសីល ។

បន្ទាប់មក ទ្រង់រាប់បាត្រព្រះសង្ឃ ៨០ អង្គ ហើយទ្រង់ប្រថាប់លើព្រះសុវណ្ណកោច្ឆៈដដែលវិញ ។ ឯព្រះសង្ឃ ក្រោយពេលដែលបានទទួលបង្ហាន់រួចហើយក៏និមន្តត្រឡប់មកគង់លើកៅអីវិញ ស្វាធ្យាយកត្តានុមោទនា បត្តិទានគាថា រួចមានពិធីដាក់ទង់ជាតិ-ទង់សាសនា ដោយបន្ទឹបទនគររាជ-បទសរគេញ តាមសំឡេងសិស្សប្រុស-ស្រី ។ ពេលនោះព្រះសង្ឃ-គ្រហស្ថក្រោកឈរគោរព បំពោះព្រះសក្យមុនីចេតិយ ។

ម៉ោង ១០ សម្ដេចក្រុមព្រះជាព្រះរាជតំណាង ស្ដេចយាងត្រឡប់វិញ ដោយមានព្រះរាជបរិពារដដែលតាមហែ ។ គមក ពុទ្ធបរិស័ទបានដាក់បាត្រព្រះសង្ឃយ៉ាងហូរហែ ។ ពិធីនេះ ក៏បានបប់សព្ទគ្រប់នៅពេលដាក់បាត្ររួច ។

---

៦

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៣ លេខ ៦ ខែមិថុនា

ព.ស. ២៥០៤ គ.ស. ១៩៦១

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ៦ ខែមិថុនា

ព.ស. ២៥០៤ គ.ស. ១៩៦១

ភ្នំពេញ

# ពិធីបុណ្យនៅវត្តឧណ្ណាលោម

# ប្រគេន-ថ្វាយ សម្តេចទាំងពីរព្រះអង្គ

---

ថ្ងៃទី ៥ មិថុនា ១៩៦១ ម៉ោង ៨ យប់ នាមហាកុដិវត្តឧណ្ណាលោម មានការជួបជុំពុទ្ធបរិស័ទជាច្រើន ក្រោមកិច្ចចាត់ចែងនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ រៀបធ្វើពិធីបុណ្យប្រគេនមហាកុសល ចំពោះសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយកគណៈមហានិកាយ ដែលកំពុងព្យាបាលព្រះនេត្រនៅប្រទេសបារាំង និងថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះប្រមុខរដ្ឋ ជាទីគោរព និងជាទីស្នេហាស្មើជីវិតនៃយើង ដែលព្រះអង្គកំពុងព្យាបាលព្រះរោគនៅប្រទេសបារាំង ព្រមទាំងទ្រង់កំពុងបំពេញព្រះរាជបេសកកម្មនៅក្រុងហ្សឺណែវ រកសន្តិភាពជូនប្រទេសលាវ និងសាកលលោក ។

ថ្ងៃទី ៦ ខែ ឆ្នាំដដែល ម៉ោង ៩ ព្រឹក មានពិធីដាក់បាត្រព្រះសង្ឃ ៥០០អង្គ, បប់កិច្ចដាក់បាត្រ ព្រះសង្ឃស្វាធ្យាយពុទ្ធជ័យមង្គលប្រសិទ្ធិពរ ប្រគេន ថ្វាយ ចំពោះសម្តេចទាំងពីរព្រះអង្គ សូមបាន, សូមទ្រង់បានសះស្បើយព្រះរោគ និងសូមទ្រង់បានជោគជ័យមហាប្រសើរក្នុងព្រះបេសកកម្មដ៏លំបាកក្រៃលែងនេះ ។

ពិធីនេះបានចប់សព្វគ្រប់នៅវេលាម៉ោង ៩, ៤៥ នាទីព្រឹក ។

ពុទ្ធសាសនបណ្ឌិត្យសូមចូលរួមក្នុងពិធីបុណ្យដោយកតញ្ញុតាភាព ។

ពុទ្ធសាសនបណ្ឌិត្យ

NATIONALE
DU CAMBODGE
P.K.1
1961-6

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* បញ្ជីរឿង *ទំព័រ*

- វិចារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា (ត) លោក ផល-ទិត្យ រៀបរៀង៥៩៧
- ពុទ្ធជីវប្បវត្តិ (តនឹងចប់) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៦០៨
- លោកុត្តរាភិសម័យ អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង . . ៦១៧
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក (ត) លោក ប៊ូ-ប៉ូ រៀបរៀង . . . ៦៣១
- មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះ ញ.ឈឹង ពិនិត្យ . . ៦៤៣
- មហោសថជាតក(ត)លោកអ៊ុម-ភនបម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-តួរពិនិត្យ. ៦៥២

*ផ្នែកអក្សរសាស្ត្រ*

- វប្បធម៌ខ្មែរ (ត) លោក លី-ធាមតេង រៀបរៀង . . . ៦៦១
- ពាក្យខ្មែរប្រែពីបរទេស ដោយគណៈកម្មការវប្បធម៌ (ត) . . . . . . ៦៦៦
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ៦៦៧
- ដើមកំណើតប្រាសាទអង្គរ លោកល្វីហ្វីណូត៍រៀបរៀង ក្រមការ ជុំ-មៅ ប្រែ· ៦៦៨
- រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែ . . . . ៦៨០
- រឿងមនុស្សចិត្តប្រែប្រួល (ត) លោក ប៊ូ-ប៉ូ រៀបរៀង . . ៦៩១
- ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសឥណ្ឌូចិនលោករ៉ូហ្សមបែរត៍រៀបរៀងលោកញ៉ែម-ទឹមប្រែ ៦៩៩
- លទ្ធផលនៃការប្រឡងប្រជែងអក្សរសាស្ត្រទូទៅ នៃសមាគមអ្នកនិពន្ធខ្មែរ . . ៧០៩

*ផ្នែកកំណត់ទិនប្បវត្តិការណ៍*

- ពិធីសម្ពោធធម្មមន្ទីរ វត្តព្រះវិហារហ្លួង ឧត្តុង . . . . . . . . . . ៧១៣

មួយឆ្នាំ មាន១២ សៀវភៅ ជំថ្លៃជារី ២៣០រ០០

33e Année — No 6 — juin 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire


### Partie religieuse — Pages

— Editorial " Les principes du Bouddhisme " ( suite ) par *M. PHAL-TITH* . . . . 597

— La Vie du Buddha ( suite et fin) par Vèn - *PANG-KHAT* . . 608

— Lok kuttara Bhisamaya par L'Okhna *TEA - SANN* . . . . . 617

— Prah Abhidhamma pitaka (Kampi Prah yamaka (suite) par *M. BOU - FO* . . . . . . 631

— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita *LOUIS - EM*, revu et corrigé par Vèn. *NHÉAN - CHHOEUN* . . . . 643

— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM - PHON*, revu et corrigé par Vèn. *KEM - TO* . . . . 652

### Partie littéraire

— La Culture Khmère (suite) par *M. LY - THEAM - TENG* . . 661

— Activités de la Commission Culturelle (suite) . . . . . . . . . . . 666

— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 667

— Origine d'Angkor par Louis Finôt traduite par *M. CHUM-MAU* 668

— Histoire de Sam-Kok (suite) traduite par Okhna *NOU - KAN* . . . . . . 680

— L'homme au coeur changeant (suite)par *M.BOU-FO* . . . . . . 961

— Géographie économique de l'Inde par *M ROSEMBERT*, professeur de la Faculté de Droit traduite par *M. NHEM - KHEM* 699

— Résultát du concours littéraire organisé par l'Association des Ecrivains khmèrs par *M. TRINH - HOANH* . . . . 709

### Notes et chroniques

— Fètê d'inauguration d'un sala à Vat Preah Vihean Lûong (Oudong) . . . 713


Prix d'abonnement annuel (comprenant 12 numéros): 23o|oo

ផ្នែកសាសនា

វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

(តមក)

លោក ដល-ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ព្រះមុនីកោសល ស្វរ-ហាយ ពិនិត្យ

---

- មនុស្សក្តី តិរច្ឆានក្តី ពួករុក្ខជាតិក្តី តើកើតមកអំពីអ្វី ?

— កើតមកពីធម្មជាតិដូចគ្នាទាំងអស់ ។

- បើកើតចេញពីធម្មជាតិដូចគ្នា ហេតុអ្វីក៏បានជាមានដំណើរចេះដឹងខុសគ្នា ដូចជាមនុស្ស មានការចេះដឹងជាងពួកតិរច្ឆាន និងពួករុក្ខជាតិ, តិរច្ឆាន មានការចេះដឹងជាងពួករុក្ខជាតិ ?

— ព្រោះវាមាន មនោធាតុ ចាស់-ខ្ចីខុសគ្នា គឺពួករុក្ខជាតិនោះ វាទើបតែនឹងកកើត មនោធាតុ ពីមូលធាតុ គឺធាតុដើមផ្ទាល់. ដូច្នេះ បានជានៅល្ងិតល្ងង់ណាស់ ស្ទើរតែមិនមានប្លែកអ្វីពីធាតុដើម គឺ ដី ទឹក ភ្លើង ខ្យល់ អាកាសនោះឡើយ ។ ឯពួកតិរច្ឆាន វាមាន មនោធាតុ ចាស់ជាងពួករុក្ខជាតិ ព្រោះវាកើតចំរើន មនោធាតុ ជាតំណបន្ទាប់ពីរុក្ខជាតិមក បានជាវាចេះដឹងជាងពួករុក្ខជាតិ, ចំណែកពួកមនុស្សវិញ បានជាចេះដឹងជាងគេ ព្រោះវាមាន មនោធាតុ កើតចំរើនបន្តពីពួកតិរច្ឆានមក ហើយមានលក្ខណៈជា មនោ ពេញលេញផង ។

— បើកើតពីធម្មជាតិយ៉ាងនេះ មានតែពេលស្លាប់-ង៉ាប់ទៅ ក៏នឹងរលាយសូន្យទៅជាធម្មជាតិដើមវិញ មែនឬទេ?

រឿងនេះ ជាសេចក្ដីល្អិតល្អន់ ខ្ញុំមិនអាចនិយាយឲ្យងាយស្ដាប់ដោយពាក្យខ្លីទេ, សូមចាំស្ដាប់អត្ថាធិប្បាយដូចតទៅនេះ ៖

រូបកាយនៃពួកមនុស្ស និងពួកតិរច្ឆានដែលមានជីវិតគឺការរស់នៅក្នុងលោកនេះ, តាមផ្លូវសាសនា លោកប្រាប់ថា មាន ធម៌ ២ យ៉ាង ដែលនៅជាប់ជាមួយគ្នាមិនអាចបំបែកចេញបាន គឺរូបធម៌ ១ នាមធម៌ ១ ៗ រូបធម៌ បានដល់រូបកាយដែលយើងមើលឃើញ, ឯ នាមធម៌ បានដល់ វិញ្ញាណ ( មនោ · ចិត្ត ) នេះឯង ៗ ប៉ុន្តែធម៌ទាំងពីរយ៉ាងនេះ ដែលអាចនឹងតាំងនៅបាន ក៏ត្រូវមានការទាក់ទងជាមួយនឹងធម្មជាតិឯ-ទៀត ៗ ដែរ ដូចមានសេចក្ដីបញ្ជាក់យ៉ាងច្បាស់ក្នុងមហានិទ្ទេសថា :

អស្សាសុបនិពទ្ធំ ជីវិតំ បស្សាសុបនិពទ្ធំ ជីវិតំ អស្សាសបស្សាសុបនិពទ្ធំ ជីវិតំ មហាភូតុបនិពទ្ធំ ជីវិតំ ឧស្មូបនិពទ្ធំ ជីវិតំ កពឡិង្ការាហារុបនិពទ្ធំ ជីវិតំ វិញ្ញាណុបនិពទ្ធំ ជីវិតំ = ជីវិត (របស់មនុស្សសត្វគ្រប់រូប) ជាធម្មជាតិជាប់ទាក់ទងដោយដង្ហើមចេញ ដោយដង្ហើមចូល ដោយដង្ហើមចេញនិងដង្ហើមចូល ដោយមហាភូតរូប ដោយឧស្ម័ន និងដោយវិញ្ញាណ ៗ

ដូច្នេះឃើញថា មនុស្សសត្វ ដែលមានជីវិតរស់នៅនោះ ព្រោះតែមានដង្ហើម មានរាងកាយមិនខូចខាត មានកំដៅឧស្ម័ន មានការបរិភោគអាហារភោជន និងមានវិញ្ញាណ (មនោ-ចិត្ត) ។ ប៉ុន្តែ ក្នុងកាលណាវិញ្ញាណ (មនោ-ចិត្ត) និងភ្លើងធាតុក្នុងរាងកាយនេះរលត់ហើយ, ក្នុងកាលនោះ រូបរាងកាយ ក៏បានឈ្មោះផ្សេងទៀតថា ងាប់ ឬ ស្លាប់វិញ រឿងនេះក្នុងមហាវគ្គបញ្ជាក់ថា :

អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ
អបវិទ្ធា តទា សេតិ និរត្ថំវ កលិង្គរំ

អាយុ គឺតំណជីវិតផង ឧស្មា គឺកំដៅភ្លើងធាតុក្នុងរូបកាយផង វិញ្ញាណ គឺមនោ-ចិត្តផង, (ធម្មជាតទាំង ៣ នេះ) លះបង់រូបរាងកាយចោលក្នុងកាលណា, ក្នុងកាលនោះ រូបរាងកាយក៏រមែងត្រូវគេយកទៅបោះចោលឲ្យដេកលើផែនដី (ស្លាប់-ងាប់) ដូចជាអង្កត់ឈើដែលគ្មានប្រយោជន៍ គឺយកមកប្រើជាសម្ភារៈពុំបាន ដូច្នោះ ។

សេចក្ដីនេះ ឲ្យយើងយល់ថា ក្នុងរូបរាងកាយនៃមនុស្សសត្វ មានអាយុនិងឧស្ម័នជារបស់សំខាន់មួយផ្នែកដែលសម្រាប់ធ្វើជីវិត គឺការរស់នៅឲ្យស្ថិតស្ថេរបាន ; តែអាយុនិងឧស្ម័ននេះ បើវិញ្ញាណ គឺមនោ-ចិត្ត ចេញផុតពីរូបរាងកាយហើយ វាក៏ត្រូវរលត់ទៅដែរ ព្រោះវាមិនអាចបែកចេញពីវិញ្ញាណ (មនោ-ចិត្ត) បានឡើយ ។ ឯរូបរាងកាយវិញ

បើធម្មជាតទាំងនេះរលត់អស់ហើយ ក៏បានឈ្មោះថា ដាច់ ឬ ស្លាប់, គេមិនអាចរស់នៅតទៅទៀតបានឡើយ ។ លុះស្លាប់ហើយ គេក៏ត្រូវរលាយបែកខ្ញែកទៅជាមហាភូតរូប ( មូលធាតុ ) គឺ ទឹក ដី ភ្លើង ខ្យល់ អាកាស ដើមវិញ ។ ឯ វិញ្ញាណ (មនោ - ចិត្ត) ក្នុងខណៈដែលរូបកាយស្លាប់, គេក៏ត្រូវរលត់ដែរ ព្រោះគ្មានអ្វីនៅអាស្រ័យ ប៉ុន្តែ វាអាចផុសបដិសន្ធិកើតឡើងក្នុងរូបថ្មីទៅទៀត ។ ដូចជាខ្ញុំបាននិយាយហើយថា ខ្សែនៃមនោ - ចិត្ត - វិញ្ញាណមានកំលាំងណាស់ អាចផ្លាយទៅចាប់ជាតិកំណើតក្នុងភពថ្មីទៀតបាន ហើយវាមិនចេះសូន្យបាត់ទៅឡើយៗ បើថា វិញ្ញាណ ( មនោ - ចិត្ត ) នេះ ដល់ពេលស្លាប់ហើយវានឹងសូន្យ, ពាក្យនេះពិតជាមិនសមទេ ព្រោះថា បើវាបានវិតចំរើនពីភាពទន់ខ្សោយរហូតមកដល់ភាពមាំមួនពេញលក្ខណៈយ៉ាងនេះហើយ ស្រាប់តែរលាយទៅឯង ៗ ឃើញថា មិនគួរទាល់តែសោះ ។ យ៉ាងនេះហើយ បានជាមនុស្សសត្វគ្រប់រូប ត្រូវតែមានដំណើរអន្ទោលទៅក្នុងសង្សារវដ្ត គឺការកើត - ស្លាប់ ស្លាប់ - កើត រកទីបំផុតគ្មាន ដូចជាព្រះពុទ្ធដីកាបញ្ជាក់ក្នុងមហានិទ្ទេសថា :

អនមតគ្គោយំ ភិក្ខវេ សំសារស្ស បុព្វាកោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសំយោជនានំ សន្ធាវតំ សំសរតំ = ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែល

មានអវិជ្ជាជាគ្រឿងរាំងរា, មានតណ្ហាជាគ្រឿងក្រងទុក, ដែលស្ទុះស្ទា អន្ទោលទៅ (កើត-ស្លាប់) រមែងមិនប្រាកដ ដើម និង ចុង នៃ សង្សារវដ្ដដែលឥតមានអ្នកណាមួយដឹងបាននេះឡើយ ។

តាមន័យព្រះពុទ្ធដីកានេះ យើងល្មមយល់បានថា ពួកមនុស្សសត្វ ធម្មតា គឺមិនមែនជាពួកព្រះអរិយបុគ្គល រមែងកើតហើយស្លាប់ទៅ ស្លាប់ ហើយកើតមកវិញ មិនអាចកំណត់បាននូវ ដើម និង ចុង ឡើយ ។ ត្រង់ពាក្យថា ដើម និង ចុង នេះ គឺការកផ្ដួច វិញ្ញាណ (មនោ-ចិត្ត) ឡើងជាដំបូង ហៅថា ដើម, ការរលត់ វិញ្ញាណ (មនោ-ចិត្ត) នោះទៅវិញ ហៅថា ចុង ។ ពាក្យថា មិនប្រាកដ បាន សេចក្ដីថា មនុស្សសត្វគ្រប់រូប គ្មានអ្នកណាមួយអាចមើលឃើញថា " យើងបានចាប់កផ្ដួចផ្ដើម វិញ្ញាណ (មនោ-ចិត្ត) ជាលំដាប់រហូតមក ដល់កើតជាមនុស្សនេះ ពីកាលណាឡើយ ហើយពេលដែលមនុស្សសត្វ ឈប់ស្លាប់ ឈប់កើតនោះទៀត ក៏មិនដឹងជាទៅចប់នៅពេលណាដែរ ។ រឿងកើត-ស្លាប់ឥតទីបំផុតនេះ គួរពុទ្ធជនយកចិត្តទុកដាក់ណាស់ ព្រោះ ក្នុងលោកនេះ បើគ្មានការកើត-ស្លាប់ឥតទីបំផុតនេះទេ ការកើតឡើងនៃ ព្រះពុទ្ធបរមគ្រូរបស់យើង ក៏គ្មានសារៈប្រយោជន៍ប៉ុន្មានដែរ, ព្រោះថា ក្នុងលោកនេះ ដែលកើតមានព្រះពុទ្ធ ក៏គឺព្រះអង្គមកដោះស្រាយសេចក្ដីទុក្ខ នៃពិភពលោកព្រោះការកើតស្លាប់ឥតទីបំផុតនេះឯង, ចុះបើមនុស្សសត្វ

ស្លាប់ហើយសូន្យប្រាកដមែន គេចាំបាច់មានព្រះពុទ្ធមកដោះស្រាយធ្វើអ្វី គឺថា បើទុកជាមនុស្សសត្វធ្វើអំពើអាក្រក់-ល្អ (បាប-បុណ្យ) យ៉ាងណាក៏ដោយ ដល់ពេលស្លាប់ហើយ វាមិនមែនមានផលអាក្រក់-ល្អដែលតម្រូវឲ្យអ្នកធ្វើរងទុក្ខ-សុខតទៅជាតិមុខទៀតដែរ ដូច្នេះ វាចប់ស្រេចឥតមានពិបាកដោះស្រាយអ្វីទៀតឡើយ ។ ឯសេចក្ដីពិតវិញ មនុស្សសត្វស្លាប់ហើយត្រូវតែកើតទៀតជាប្រាកដ គឺ វិញ្ញាណ (មនោ-ចិត្ត) ហ្នឹងឯង ដែលមិនរលត់សូន្យទៅដូចជារូបកាយទេ វានៅចងខ្សែបដិសន្ធិទៅកើតក្នុងរូបថ្មីទៀត ។

-ចុះបើ វិញ្ញាណ (មនោ-ចិត្ត) វារលត់ដូចរូបរាងកាយដែរ ម្ដេចក៏ថា វាទៅចាប់បដិសន្ធិកើតក្នុងភពថ្មីទៀតបាន ?

សូមលោកអ្នកអាន សង្កេតតាមពាក្យខ្ញុំតទៅមុខទៀត

ធម្មជាតិទាំងអស់ដែលកើតមកហើយ ត្រូវតែរលត់ទៅវិញជាការចាំបាច់ ដូចក្នុងមហាវគ្គបញ្ជាក់ថា :

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ

ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សង្ខារធម៌គឺធម្មជាតិទាំងឡាយ ពិតជាមិនទៀងទេ មានការកើតនិងស្លាប់ជាទំនៀម, វាតែងតែកើតឡើងហើយស្លាប់ទៅវិញៗ (យ៉ាងនេះឥតទីបំផុតចប់ឡើយ ) លុះតែរំលត់សង្ខារធម៌ គឺធម្មជាតិទាំងនោះបាន ទើប

បានសេចក្ដីសុខ គឺការឈប់កើត-ស្លាប់ ។

ដូច្នេះ ឃើញថា អ្វីក៏ដោយ ទោះជារូបកាយក្ដី វិញ្ញាណ (មនោ-ចិត្ត) នេះក្ដី ក៏ត្រូវតែស្លាប់-រលត់ដូចគ្នាទាំងអស់ ប៉ុន្តែ ការរលត់ទៅនៃវិញ្ញាណ (មនោ-ចិត្ត) នេះ មានដំណើរប្លែកពីរូបកាយ គឺវាមានវេទ្យប្រតិសន្ធិទៅផ្ដួចកើតក្នុងរូបថ្មីដែលយើងហៅថា បរលោក នោះទៀតបាន ។ គួរសង្ស័យដែរថា បើវារលត់ហើយ តើវាទៅផ្ដួចកំណើតជាថ្មីទៀតតាមទំនងដូចម្ដេច? រឿងនេះ គម្ពីរវិសុទ្ធិមគ្គបញ្ជាក់ថា :

លទ្ធប្បច្ចយមិតិ ធម្មមត្តមេតំ ភវត្តរមេតិ

នាស្ស តតោ សង្កន្តិ ន តតោ ហេតុំ វិនា ហោតិ ។

បើបានបច្ច័យស្រេចសព្វគ្រប់ ធម៌តែងតភពជាធម្មតា

តែមិនមែនចេញពីកាយា ទាំងវៀរហេតុវាក៏មិនមែន ។

ពាក្យថា ធម៌ គឺ រូបធម៌ និង នាមធម៌ ដូចបានអធិប្បាយពីខាងដើមរួចមកហើយ ។ ពាក្យថា "បានបច្ច័យសព្វគ្រប់" បានសេចក្ដីថា បើមានបច្ច័យ គឺរូបធម៌-នាមធម៌បច្ចុប្បន្ននេះហើយ រូបធម៌-នាមធម៌អនាគត ត្រូវតែកើតតភពទៅមុខទៀតជាធម្មតា ។ ពាក្យថា "វៀរហេតុវា" បានសេចក្ដីថា វៀរហេតុរបស់រូបធម៌-នាមធម៌បច្ចុប្បន្ន ។ រួមសេចក្ដីទៅថា កាលបើកើតមាន រូបធម៌ នាមធម៌ហើយ, រូបធម៌-នាមធម៌ នេះ ក៏ចេញទៅជាហេតុបច្ច័យឲ្យកើត រូបធម៌-នាមធម៌

ថ្មី ៗ តទៅទៀត ប៉ុន្តែ វាមិនមែនកើតពី រូបធម៌-នាមធម៌ ចាស់នោះទៅទេ ហើយបើថាវាមិនមែនចេញពី រូបធម៌-នាមធម៌ ចាស់ទេ គឺកើតមកពីហេតុបច្ច័យដទៃផ្សេងទៀត ដូច្នេះ ក៏មិនមែនដែរ, ប្រាកដជាវាកើតថ្មីព្រោះ រូបធម៌ - នាមធម៌ ចាស់នោះឯងជាបច្ច័យ ។ រឿងនេះក្នុងគម្ពីរដែលបានបញ្ជាក់ទៀតថា :

សិយុំ និទស្សនាចេត្ថ បដិឃោសាទិកា អថ
សន្តានពន្ធតោ នត្ថិ ឯកតា នាបិ នានតា

**ធម៌មួយហ្នឹង ឬធម៌ដទៃ ដែលមកចាប់ផ្ដើ គ្មានឡើយណា**
**ដូចជារូបថត, សូរ, ភ្លើង, ត្រា ក្នុងរឿងនេះជា ពាក្យនិទស្សន៍ ។**

ពាក្យថា "ធម៌មួយហ្នឹង" គឺ រូបធម៌-នាមធម៌ ចាស់ហ្នឹង ។ ពាក្យថា " ធម៌ដទៃ " គឺរូបធម៌-នាមធម៌ ដទៃក្រៅពី រូបធម៌ នាមធម៌ ចាស់នោះ ។ ពាក្យថា " មកចាប់ផ្ដើ " គឺមកកើតជាថ្មីទៀត ។ រួមសេចក្ដីទៅថា រូបធម៌-នាមធម៌ ចាស់នោះក្ដី ឬក៏ រូបធម៌-នាមធម៌ ផ្សេងដទៃទៀតក្ដី វាមិនមកចាប់ជាតិកំណើតកើតថ្មីទៀតទេ គឺវាគ្រាន់តែជាហេតុបច្ច័យឲ្យកើតប៉ុណ្ណោះ ប្រៀបដូចជារូបថត សូរ, ភ្លើង និងត្រាដូច្នោះ ។ សូមជ្រាបពាក្យនិទស្សន៍ខាងក្រោមនេះ :

គេយកបរិធានថត មកថតរូបយើង, លុះថតហើយគេយកទៅផ្ចិត ក៏លេចចេញរូបភាពយើងយ៉ាងច្បាស់នៅជាប់នឹងក្រដាស ។ តើយើងថា

រូបកាពជាប់នឹងក្រដាស ក៏ជាខ្លួនយើងចេញទៅឬ? ឬក៏ជារូបដទៃវិញ? តាមពិតក៏មិនមែនជាខ្លួនយើងចេញទៅទេ ព្រោះខ្លួនយើងនៅឯនេះដដែល ហើយរូបកាត ក៏នៅជាបនឹងក្រដាសឯនោះផ្សេង ប៉ុន្តែ បើនឹងថា ជារូបអ្នកណាមួយផ្សេងទៀត ក៏មិនមែនដែរ ព្រោះរូបកាពនោះ ក៏ចូលខ្សែស្រមោលពីរូបខ្លួនយើងទៅជាប់នឹងហ្វីលនោះ យ៉ាងណាមិញ, រូបធម៌-នាមធម៌ ថ្មី ក៏ចូលពី រូបធម៌-នាមធម៌ចាស់មក ប៉ុន្តែ នឹងហៅថា ក៏ជារូបធម៌-នាមធម៌ចាស់ចេញទៅក៏មិនមែន ឬថាជារូបធម៌-នាមធម៌ផ្សេងទៀតក៏មិនមែន យ៉ាងនោះដែរ ។

មួយទៀត ដូចជា ស្គរដែលគេដាក់នៅជិតទីមានទឹកច្រើន ឬទីមានគ្រឹះស្ថានធំ ៗ, កាលបើគេទូងក៏គងទីនោះ សូរក៏លាន់ឮឡើង ហើយបន្ទាប់គ្នា មានសូរមួយទៀតលាន់ឮឆ្លើយតបមកភ្លាម ដូចជាគេទូងក៏គងឡើង គេក៏នឹងឮសូរមួយទៀត លាន់ឆ្លើយពីកងទឹកឬផ្ទះ គងឡើងដែរ ។ ដូច្នេះ យើងនឹងនិយាយថា សូរលាន់ឆ្លើយមកនោះ ជាសូរដែលលាន់ឮនឹងស្គរនោះបានឬទេ ? មិនបានទេ ព្រោះសូរដែលលាន់តបមកជាសូរផ្សេង ឯសូរដែលលាន់ឮគងស្គរជាសូរផ្សេង ប៉ុន្តែ បើគ្មានសូរនឹងស្គរលាន់ឡើងទេ សូរឆ្លើយតបមកវិញក៏គ្មានដែរ ។ យ៉ាងនេះ បានជានឹងហៅថា ក៏ជាសូរដែលលាន់ឮគងសូរចេញទៅក៏មិនមែន ឬថាជាសូរលាន់ឡើងពីហេតុអ្វីមួយផ្សេងទៀតក៏មិនមែនដែរ យ៉ាងណាមិញ, រូប

ធម៌-នាមធម៌ចាស់ ជាបច្ច័យឲ្យកើតរូបធម៌-នាមធម៌ថ្មី ក៏យ៉ាងនោះដែរ ។

មួយទៀត ដូចគំនរសម្រាម ២ គំនរនៅខាងគ្នា , មនុស្សម្នាក់យកភ្លើងទៅដុតគំនរសម្រាម ១ , លុះភ្លើងឆេះគំនរសម្រាមនោះអស់ហើយ វាក៏ឆ្លងទៅឆេះគំនរសម្រាម ១ ទៀត ។ តើយើងគួរហៅថា ភ្លើងដែលឆេះគំនរសម្រាមថ្មីនេះ ជាភ្លើងដែលឆេះគំនរសម្រាមមុនបានឬទេ? តើភ្លើងនោះ វាមកពីណា? តាមពិត យើងនឹងហៅថា ជាភ្លើងឆេះសម្រាមមុនក៏មិនបាន ព្រោះភ្លើងដែលឆេះសម្រាមមុននោះ វារលត់បាត់ទៅហើយ ហើយយើងនឹងហៅថា វាជាភ្លើងផ្សេងមកពីទីឯទៀតក៏មិនមែន ព្រោះភ្លើងដែលឆេះសម្រាមថ្មីនេះ វាឆ្លងឆេះមកពីភ្លើងគំនរសម្រាមមុននោះដែរ យ៉ាងណាមិញ , រូបធម៌ - នាមធម៌ថ្មី ដែលឆ្លងមកពីរូបធម៌-នាមធម៌ចាស់ ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀត ដូចជា ស្នាមត្រាដែលគេបោះទៅនឹងក្រដាស, តើយើងអាចហៅស្នាមនោះថា វាជាតួត្រាបានឬទេ? មិនបានទេ ព្រោះស្នាមត្រាដែលដិតជាប់ទៅនោះវាជារបស់ផ្សេង ឯតួត្រាវិញក៏នៅផ្សេងដែរ ប៉ុន្តែ បើគ្មានតួត្រា ក៏ស្នាមត្រាមិនអាចមានទៅកើតដែរ យ៉ាងណាមិញ, រូបធម៌-នាមធម៌ចាស់ ជាបច្ច័យឲ្យកើត រូបធម៌ នាមធម៌ថ្មីនោះក៏យ៉ាងនោះដែរ ។

សេចក្តីឧបមាទាំងនេះ អាចឲ្យយើងយល់បានថា រូបកាយ នឹង

វិញ្ញាណ (មនោ-ចិត្ត) របស់មនុស្សសត្វដែលស្លាប់ហើយ វាអាចជាបច្ច័យជូនទៅធ្វើបដិសន្ធិ ជារូបកាយ នឹងវិញ្ញាណ (មនោ-ចិត្ត) ថ្មីទៀត យ៉ាងនេះឯង ។

-ចុះបើមនុស្សសត្វ ចេះតែទៅកើតទៀតយ៉ាងនេះ, តើមានពេលណានឹងចប់ការកើតស្លាប់ដែរឬទេ? ក្នុងជីវិតមនុស្សសត្វម្នាក់ ១ គួរឲ្យនឿយណាយដ៏ធ្ងន់ណាស់ ព្រោះត្រូវជួបនឹងសេចក្ដីទុក្ខលំបាកច្រើនហួសហែប ដូចជាការព្រាត់ប្រាស់ស្លាប់ចោលគ្នា ការឈឺចាប់ ការសោកសៅ ពេគាពាធ ការខំប្រឹងរកទ្រព្យសម្បត្តិនឹងអាហារភោជនដោយសេចក្ដីនឿយព្រួយលំបាកគ្រប់យ៉ាងជាដើម ចុះបើស្លាប់ហើយត្រូវទៅកើតទៀតយ៉ាងនេះ តើវាមិនត្រូវលំបាកទៀតហើយ ?

- ពិតជាទុក្ខលំបាកយ៉ាងហ្នឹងហើយ បានជាកើតបញ្ញាព្រះពុទ្ធឡើងក្នុងលោកនេះ ព្រោះព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងពិភពលោក ក៏ដោយសារសេចក្ដីទុក្ខឈឺចាប់លំបាក នៃពិភពលោក ឥតមានពេលចប់ពេលហើយនេះឯង ។

-តើមានផ្លូវទៅបញ្ចប់ការកើតស្លាប់នេះដែរឬទេ ?

-មាន, គឺត្រូវធ្វើខ្លួនឲ្យដូចជាព្រះពុទ្ធ ដែលយើងធ្លាប់ហៅថាព្រះអរិយបុគ្គល (ព្រះខីណាស្រព) នោះទើបយើងបញ្ចប់ការកើតទៀតបាន ។

(នៅមានត)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

(តនឹងលប់)

# យសបព្វជ្ជាកថា ទី ១២

១- យសបរិភោគកាម ២- យសកុលបុត្រជួបព្រះមានព្រះភាគ ៣- មាតាបិតាយស. កុលបុត្រស្វែងរក ៤- ទ្រង់ប្រោសបិតាយសកុលបុត្រ ៥- ទ្រង់ប្រោសមាតានៃយសកុលបុត្រ ៦- ទ្រង់ប្រោសសំឡាញ់ព្រះយស ៤ នាក់ ៧- ទ្រង់ប្រោសសំឡាញ់ ៥០ នាក់ ៨- ទ្រង់បញ្ជូនសាវ័កទៅប្រកាសពុទ្ធសាសនាក្នុងលោកមុនដំបូង ។

## ១- យសបរិភោគកាម

សម័យ[១]នោះឯង ក្នុងក្រុងពារាណសី មានកុលបុត្រម្នាក់ឈ្មោះ យស ជាកូនសេដ្ឋី ជាបុគ្គលចំរើនដោយសេចក្ដីសុខ ។ យសកុល-បុត្រមានប្រាសាទ ៣ ប្រាសាទមួយសម្រាប់នៅក្នុងរដូវរងា ប្រាសាទមួយសម្រាប់នៅក្នុងរដូវក្ដៅ ប្រាសាទមួយសម្រាប់នៅក្នុងរដូវភ្លៀង ។ យសកុលបុត្រនោះ មាតាបិតាឲ្យពួកអ្នកភ្លេងតូរ្យតន្ត្រីសុទ្ធសឹងតែស្រីឥតមានបុរសឡើយ ចាំបម្រើអស់កំណត់ ៤ ខែក្នុងរដូវភ្លៀង មិនដែលចុះមកកាន់ផ្ទៃខាងក្រោមនៃប្រាសាទទេ ។ យសកុលបុត្របរិភោគកាមឆ្អែតស្កប់ស្កល់ដោយកាមទាំង ៥ ប្រការ កាលពួកស្រីកំពុងបម្រើ ក៏ដេកលក់ទៅមុន ជនជាបរិស័ទដេកលក់ជាក្រោយ ។ ប្រទីបនេះភ្លឺព្រោងព្រាយពល់យប់ពល់ព្រឹក ។ គ្រានោះ យសកុលបុត្រភ្ញាក់ពីនិទ្រាមុនគេ បាន

១- មហាវគ្គ បឋមភាគ មហាខន្ធកៈ សៀ. ៦ ទំព័រ ៤៣ ។

ឃើញបរិស័ទកំពុងដេកលក់ ស្រីខ្លះមានពិណនៅត្រង់ក្លៀក ស្រីខ្លះមានសម្ភោរនៅត្រង់ក ស្រីខ្លះមានស្គរធំនៅក្បែរខ្លួន ស្រីខ្លះមានសក់រំសាយ ស្រីខ្លះមានទឹកមាត់ហូរហៀរ ស្រីខ្លះកំពុងមមើ មើលទៅហាក់ដូចជាព្រៃស្មសានឋានស្ងាត់ ។ យសកុលបុត្រឃើញដូច្នោះហើយកើតសេចក្ដីនឿយណាយ ទើបបន្លឺឧទានថា ឱ! ទីនេះរឹកររណាស់តើ ឱ! ទីនេះជំពាក់ពាក់វនណាស់តើ! ។

គ្រានោះ យសកុលបុត្រពាក់ទ្រនាប់ជើងមាស ដើរចេញទៅកាន់មាត់ទ្វារផ្ទះ ។ ទេពតាក៏បើកទ្វារឲ្យយសកុលបុត្រចេញទៅ ។ យសកុលបុត្រដើរតម្រង់ទៅកាន់ឥសិបតនមិគទាយវ័ន ។

## ២- យសកុលបុត្រជួបព្រះមានព្រះភាគ

គ្រានោះឯង(១) ព្រះមានព្រះភាគទ្រង់តើនពីព្រឹកបង្គ្រមក្នុងទីវាល ទ្រង់ទតព្រះនេត្រឃើញយសកុលបុត្រពីចម្ងាយ ឃើញហើយស្ដេចចៀសចេញពីចង្ក្រមប្រថាប់លើទីអាសនៈមួយកន្លែង ដែលក្រាលទុកស្រាប់ ។ ឯយសកុលបុត្របន្លឺឧទានថា ឱទីនេះរឹករណាស់តើ! ឱទីនេះជំពាក់ពាក់វនណាស់តើ! ក្នុងទីជិតនៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់តបវិញថា " ម្នាលយស! ទីនេះមិនរឹករទេ ទីនេះមិនជំពាក់ពាក់វនទេ, ម្នាលយស! មកណេះមកអង្គុយខាងនេះ តថាគតនឹងសំដែងធម៌ប្រាប់ ។

---
១ មហាវគ្គ មហាខន្ធកៈ សៀ. ៦ ទំព័រ ៤៩ ។

លុះយសកុលបុត្រចូលទៅអង្គុយក្នុងទីសមគួរហើយ ទ្រង់សំដែង អនុបុព្វីកថា គឺទានកថា សីលកថា សគ្គកថា កាមាទីនវកថា និង នេក្ខម្មានិសង្សកថា ៗ តទៅទ្រង់សំដែងអរិយសច្ច ៤ ប្រការគឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ៗ ធម្មតា សំពត់ស្អាតមិន ប្រឡាក់ដោយតែ្តមានពណ៌ទៅ គឺធ្យូង ប្លាក់ទៅជាដើម គួរទទួលទឹក ជ្រលក់ដោយល្អបាន មានឧបមាដូចម្តេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់យសកុលបុត្រ ក្នុងកន្លែងអង្គុយនោះថា ធម្មជាតណាមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅជាធម្មតា មានឧបមេយ្យដូច្នោះឯង ៗ

## ៣- មាតាបិតាយសកុលបុត្រស្វែងរក

កាលនោះ មាតាយសកុលបុត្រឡើងទៅលើប្រាសាទ មិនឃើញ កូនក៏ទៅប្រាប់ស្វាមីថា កូនយើងមិនឃើញទេ ៗ សេដ្ឋីជាបិតា ប្រើបម្រើ ឲ្យជិះសេះចេញទៅរកគ្រប់ទាំង ៤ ទិស ខ្លួនឯងដើរតម្រង់ទៅឥសិបតន- មិគទាយវ័ន ទៅដល់ហើយ ឃើញស្នាមទ្រនាប់ជើងមាសហើយដើរតាម ស្នាមជើងនោះទៅ ៗ ព្រះមានព្រះភាគទ្រង់ទតព្រះនេត្រឃើញសេដ្ឋីជា បិតានៃយសកុលបុត្រមកពីចម្ងាយទ្រង់បរិវិតក្កថា តថាគតគួរធ្វើឥទ្ធាភិ- សង្ខារបំបាំងកូនមិនឲ្យសេដ្ឋីឃើញកូនដែលអង្គុយនៅក្នុងទីនេះ ៗ សេដ្ឋី ចូលទៅគាល់ព្រះមានព្រះភាគ ចូលទៅដល់ហើយក្រាបទូលថា បពិត្រ

ព្រះអង្គដ៏ចំរើន! ទ្រង់បានឃើញយសកុលបុត្រដែរឬទេ? ព្រះមានព្រះភាគត្រាស់តបវិញថា ម្នាលគហបតី! ចូរអ្នកអង្គុយសិនចុះ បើអ្នកអង្គុយក្នុងទីនេះ អ្នកមុខជានឹងឃើញយសកុលបុត្រក្នុងទីនេះដែរ ។ ព្រះមានព្រះភាគទ្រង់ប្រទានអនុបុព្វីកថា លុះសំដែងចប់ហើយ សេដ្ឋីបានឃើញអរិយសច្ច ហើយធ្វើផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន! ព្រះពុទ្ធដីកានេះពីរោះណាស់ ប្រៀបដូចជាគេផ្ងារបស់ដែលគេផ្កាប់ឲ្យផ្ងារឡើង ឬដូចជាគេបើកនូវរបស់ដែលគេបិទបាំងទុក ពុំនោះដូចប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចទ្រោលបំភ្លឺនូវប្រទីបក្នុងទីងងឹត ឲ្យមនុស្សមានចក្ខុមើលឃើញរូបបាន ។ បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គសូមដល់នូវព្រះពុទ្ធនូវព្រះធម៌ផង ព្រះសង្ឃជាទីពឹង សូមទ្រង់ជ្រាបថា ខ្ញុំព្រះអង្គនេះជាឧបាសកអ្នកដល់នូវទីពឹងស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមត ៗ ។ សេដ្ឋីគហបតីនេះ បាននាមបញ្ញត្តិថា តេវាចិកឧបាសក ជាដំបូងក្នុងលោក ។

## ៤ - ទ្រង់ប្រោសបិតាយសកុលបុត្រ

កាលព្រះមានព្រះភាគកំពុងសំដែងធម៌ដល់បិតាខ្លួន យសកុលបុត្រក៏ពិចារណានូវភូមិធម៌ដែលខ្លួនបានឃើញ បានត្រាស់ដឹងហើយ ចិត្តក៏រួចស្រឡះចាកអាសវធម៌ទាំងឡាយ ឥតជាប់ជំពាក់ ដោយឧបាទាន

ឡើយ ។ ព្រះមានព្រះភាគជ្រាបច្បាស់ករៈចិត្តនៃយសកុលបុត្រថាបាន

ត្រាស់ដឹងធម៌ហើយ ទ្រង់ក៏រំសាយឥទ្ធាភិសង្ខារនោះចេញ ។

សេដ្ឋីជាបិតានិយាយថា នៃយស! មាតាអ្នក មានសេចក្តីសោក

ខ្សឹកខ្សួល ចូរអ្នកឲ្យជីវិតដល់មាតារបស់អ្នកផង ។ យសកុលបុត្រងើប

មើលព្រះមានព្រះភាគ ។ ព្រះមានព្រះភាគមានពុទ្ធដីកាថា យសកុល-

បុត្រនេះ បានឃើញធម៌ហើយដោយសេក្ខញាណនឹងសេក្ខទស្សនៈ ចិត្ត

ក៏រួចស្រឡះចាកអាសវធម៌ទាំងឡាយហើយ ឥតមានជាប់ជំពាក់ ដោយ

ឧបាទានឡើយ មិនគួរនឹងវិលត្រឡប់ទៅ ដើម្បីភាវៈជាគហបតីឡើយ

ហើយបរិភោគកាមទាំងឡាយដូចកាលនៅជាយកវសក្នុងកាលពីមុនទេ ។

សេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះមានព្រះភាគ

ទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃនេះ ព្រមទាំងយសកុលបុត្រជា

បច្ឆាស្រមណ៍ផង និមន្តរួចហើយ ក៏ដើរចេញទៅ ។ សេដ្ឋីចេញទៅមិន

យូរប៉ុន្មាន យសកុលបុត្រសូមបព្វជ្ជា នឹងឧបសម្បទាក្នុងសំណាក់ព្រះមាន

ព្រះភាគ ។ កាលនោះព្រះអរហន្តទាំងឡាយ ៧ អង្គ កើតមានក្នុងលោក

ក្នុងគ្រានោះឯង ។

## ៥– ទ្រង់ប្រោសមាតានៃព្រះយស

លំដាប់នោះ ព្រះមានព្រះភាគប្រដាប់ដោយបាត្រនឹងចីវរក្នុងបុព្វណ្ហ-

សម័យ មានព្រះយសជាបច្ឆាស្រមណ៍ យាងចូលទៅកាន់គេហដ្ឋាន

សេដ្ឋីគហបតី លុះចូលទៅហើយ ទ្រង់ប្រថាប់លើអាសនៈដែលសេដ្ឋីក្រាលបម្រុងទុកហើយ ។ គ្រានោះ មាតានឹងបុពណទុតិយិការបស់ព្រះយសនាំគ្នាចូលមកគាល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់សំដែងអនុបុព្វីកថា លុះចប់ធម្មីកថាហើយ មាតានឹងបុពណទុតិយិការបស់ព្រះយស សូមដល់នូវព្រះត្រៃសរណគមន៍ថា បពិត្រព្រះអង្គដ៏ចំរើន! យើងខ្ញុំទាំងនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមព្រះអង្គ ទ្រង់ជ្រាបនូវយើងខ្ញុំទាំងឡាយថាជាឧបាសិកាដល់នូវទីរលឹកស្មើដោយជីវិត កន្លងកាលមានថ្ងៃនេះជាដើមតទៅ ។

## ៦-ទ្រង់ប្រោសសំឡាញ់ព្រះយស ៤ នាក់

លំដាប់នោះសំឡាញ់៤ នាក់របស់ព្រះយសឈ្មោះវិមល ១សុពាហុ១ បុណ្ណជិ១ គវម្បតិ១ ជាបុត្រនៃត្រកូលសេដ្ឋីនឹងអនុសេដ្ឋីក្នុងក្រុងពារាណសីបានឮដំណឹងថា យសកុលបុត្រ កោរសក់នឹងពុកមាត់ ពុកចង្កា ស្លៀកពាក់សំពត់កាសាយៈចេញពីផ្ទះ ហើយបួសការន់យកភេទជាបុគ្គលមិនមានផ្ទះ ក៏នាំគ្នាចូលទៅរកព្រះយស ។ ព្រះយសក៏នាំសំឡាញ់គ្រហស្ថទាំង ៤ នាក់នេះ ចូលទៅគាល់ព្រះមានព្រះភាគ សូមព្រះមានព្រះភាគឲ្យទូន្មានប្រៀនប្រដៅសំឡាញ់ទាំងអម្បាលនោះ ។ ព្រះមាន ព្រះភាគទ្រង់សំដែងអនុបុព្វីកថាទៀត, ទីបំផុតធម្មទេសនា សំឡាញ់ទាំង ៤ នាក់ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន! យើងខ្ញុំព្រះអង្គគួរ

បានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា ឯថ ភិក្ខវោ ឲ្យអ្នកទាំងឡាយចូលមកជាភិក្ខុចុះ ព្រះអរហន្តទាំងឡាយ ១១ អង្គកើតមានក្នុងលោកក្នុងកាលនោះ ។

## ៧- ទ្រង់ប្រោសសំឡាញ់ព្រះយស ៥០ នាក់

មានសំឡាញ់របស់ព្រះយស ប្រមាណ ៥០ នាក់ទៀត បានឮដំណឹងថា ព្រះយសបួសហើយក្នុងសំណាក់នៃព្រះមានព្រះភាគ ក៏នាំគ្នាចូលទៅរកព្រះយស ។ គ្រានោះ ព្រះយសមានអាយុក៏នាំសំឡាញ់ ៥០ នាក់ចូលទៅគាល់ព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ទើបក្រាបទូលសូមទ្រង់ព្រះមេត្តាប្រោស ប្រទានទូន្មានប្រៀនប្រដៅសំឡាញ់ លុះចប់ធម្មកថាហើយ គ្រហស្ថជាសំឡាញ់សូមបព្វជ្ជា សូមឧបសម្បទា ។ ព្រះមានព្រះភាគទ្រង់ត្រាស់ទូន្មានភិក្ខុទាំងឡាយនោះដោយធម្មកថា ភិក្ខុទាំងឡាយចំនួន ៥០ អង្គនោះ បានរួចចាកអាសវធម៌ទាំងឡាយ ឥតមានជំពាក់ដោយឧបាទានឡើយ ។ ព្រះអរហន្តទាំងឡាយ ៦១ អង្គកើតឡើងក្នុងលោកក្នុងកាលនោះឯង ។

## ៨ ទ្រង់បញ្ជូនសាវ័កទៅប្រកាសពុទ្ធសាសនាក្នុងលោកមុនដំបូង

កាលស្តេចប្រោសវេនេយ្យសត្វមុនដំបូង ក្រោយពីកាលដែលទ្រង់ទើបនឹងបានត្រាស់ថ្មីៗ កាលនោះមានភិក្ខុចំនួន ៦១ អង្គរួមទាំងអង្គព្រះពុទ្ធជាម្ចាស់ផង ព្រះមានព្រះភាគទ្រង់ក៏ចាប់ផ្តើមធ្វើការផ្សាយពុទ្ធសាសនា

ដោយមានពុទ្ធបំណងឲ្យពុទ្ធសាសនាឈ្នះទុក ផ្សាយទូទៅពេញសាកលលោក ដូចមានព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយ ៦០ រូប ថា(១)

មុត្តាហំ ភិក្ខវេ សព្វបាសេហិ យេ ទិព្វា យេ ច មានុសា ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ មា ឯកេន ទ្វេ អគមិត្ថ ទេសេថ ភិក្ខវេ ធម្មំ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ សន្តិ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោ អហម្បិ ភិក្ខវេ យេន ឧរុវេលា សេនានិគមោ តេនុបសង្កមិស្សាមិ ធម្មទេសនាយាតិ ។

ម្នាលភិក្ខុទាំងឡាយ! តថាគតរួចហើយចាកអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី, ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយក៏បានរួចហើយចាកអន្ទាក់ទាំងអស់

---

១ មហាវគ្គ បឋមភាគ មហាខន្ធក សៀវ. ៦ ទំព័រ ៦៦ ។

ដែរ ទោះបីជារបស់ទេវតាក្តី ទោះបីជារបស់មនុស្សក្តី ។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក (ស្រុក និគម រាជធានី) ហើយសំដែងធម៌ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ចូរអ្នកទាំងឡាយ កុំទៅ ២ នាក់តាមផ្លូវមួយជាមួយគ្នាឡើយ, ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរសំដែងធម៌ឲ្យមានលំអ បទដើម បទកណ្តាលនិងបទចុង, អ្នកទាំងឡាយ ចូរប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធប្រកប ដោយអត្ថនិងព្យញ្ជនៈពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយ ដែលមានធូលីគឺរាគាទិក្លេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះ និងសាបសូន្យចាកមគ្គផល ព្រោះមិនបានស្តាប់ធម៌ សត្វទាំងឡាយច្រើននាក់ដែលបម្រុងត្រាស់ដឹងធម៌ ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ! ចំណែកតថាគត នឹងចូលទៅកាន់សេនានិគម ក្នុងឧរុវេលប្រទេស ដើម្បីប្រកាសធម៌ដែរ" ។

# លោកុត្តរភិស័យ

## ភាគទី ១

# សម្ភារនៃការត្រាស់ដឹងលោកុត្តរធម៌

អ្នកឧកញ៉ា ឆា-សាង អតីតរដ្ឋមន្ត្រី

រៀបរៀង

---

ការដុសខាត់ជំរះចិត្តឲ្យស្អាតបរិសុទ្ធផូរផង់ គោលគឺការលះកិលេស ដែលជាគ្រឿងសៅហ្មងចិត្តឲ្យជាប់ស្រឡះ ដោយសមុច្ឆេទប្បហាន ត្រូវបាត់ទុកជាសម្ភារ ដែលអាចញ៉ាំងការត្រាស់ដឹងលោកុត្តរធម៌ ឲ្យសម្រេចឡើងបាន, ពីព្រោះកិលេសមានរាគាទិក្កិលេសជាដើម, កាលបើមកកើតក្នុងខន្ធសន្តានហើយ, រមែងតែធ្វើចិត្តឲ្យសៅហ្មង គឺធ្វើចិត្តឲ្យប្រឡាក់ដោយមន្ទិល, ធ្វើចិត្តនេត់ញាប់ញ័រអន្ទះសា ស្រេកឃ្លានចង់ស្រើបស្រាលត្រេកត្រអាលចំពោះអារម្មណ៍ ៥ មានរូបជាដើម, ធ្វើសត្វឲ្យស្រវឹងវង្វេងភ្លេចខ្លួនជាប់ស្អិតទៅវិលវល់ក្នុងវដ្ដសង្សារ រងទុក្ខវេទនារកទីបំផុតគ្មានឡើយ ។

ដោយហេតុនេះ បានជាព្រះសម្ពុទ្ធទាំងឡាយ តែងរាស់ទៀនទូន្មានសត្វឲ្យខំព្យាយាមដុសខាត់ជំរះចិត្ត ឲ្យស្អាតបរិសុទ្ធផូរផង់រួចចាកគ្រឿងសៅហ្មង, ព្រោះព្រះអង្គមានព្រះហឫទ័យករុណាអាណិតសត្វ ចង់ឲ្យសត្វបានត្រាស់ដឹងនូវមគ្គ ៤ ផល ៤ និងនិព្វានដែលជាវិមោក្ខធម៌ អាចញ៉ាំង

សត្វឲ្យរួចផុតចាកកិលេស ដើម្បីបរមសុខ គឺសុខយ៉ាងឧត្តមក្រៃលែងនោះឯង ។

អាស្រ័យហេតុនេះ ទើបខ្ញុំយល់ឃើញថា មុននឹងធ្វើអត្ថាធិប្បាយអំពីលោកុត្តរកិសម័យ គឺការត្រាស់ដឹងលោកុត្តរធម៌នោះ គប្បីតែខ្ញុំលើកយកកិលេសនឹងចិត្តមកបរិយាយ បញ្ជាក់ឲ្យឃើញហេតុបច្ច័យនឹងផលជាមុនសិន ទើបជាហេតុអាចនឹងដឹកនាំអស់លោក-អ្នកអានឲ្យពិចារណាឃើញយល់បានដោយងាយស្រួល នូវអត្ថរសយ៉ាងល្អិតនៃមគ្គផលនិព្វាននឹងដំណើរប្រព្រឹត្តទៅនៃការត្រាស់ដឹងលោកុត្តរធម៌នោះបានផងទៀត ។

លំដាប់ពីនេះ ខ្ញុំនឹងបរិយាយរៀបរៀងសេចក្ដីតាមសមត្ថភាពដែលខ្ញុំបានចេះចាំដោយអានសៀវភៅធម៌ផ្សេង ៗ ផង និងតាមវិចារណប្បញ្ញាផង ដូចមានសេចក្ដីតទៅនេះ ៖

## ១ – កិលេស

មុននឹងធ្វើអត្ថាធិប្បាយអំពីកិលេសនេះ ខ្ញុំយល់ឃើញគប្បីបញ្ជាក់អត្ថន័យ នៃកិលេសស័ព្ទនេះឲ្យច្បាស់ជាមុនសិន ។

បើដូច្នេះ តើកិលេសស័ព្ទនេះមានន័យថាដូចម្ដេចទៅ ?

វចនានុក្រម ប្រែពាក្យកិលេសថា សេចក្ដីសៅហ្មងចិត្ត ។

មានអស់លោកជំនាញខាងភាសាបាលីខ្លះប្រែថា ៖ គ្រឿងសៅហ្មងចិត្ត ឬគ្រឿងសៅហ្មងនៃចិត្ត ។

រីឯសេចក្តីប្រែពាក្យកិលេសដូចខាងលើនេះ ឃើញថាមានន័យមិនខុសគ្នាប៉ុន្មានឡើយ ក៏ប៉ុន្តែអស់លោកអ្នកនិពន្ធសៀវភៅធម៌ ឃើញច្រើននិយមប្រើតែគ្រឿងសៅហ្មងចិត្តទុកជាន័យនៃកិលេសនោះ ។

រីឯគ្រឿងសៅហ្មងចិត្តនោះ គឺសំដៅអកុសលធម៌ មានអកុសលចេតសិកជាដើម ពីព្រោះអកុសលធម៌នោះ កាលមកកើតក្នុងខន្ធសន្តានរបស់បុគ្គលណាហើយ តែងតែធ្វើខន្ធសន្តាននោះឲ្យសៅហ្មង គឺឲ្យប្រឡាក់ដោយមន្ទិល ប្រែទៅជាចិត្តមិនស្អាតមិនបរិសុទ្ធវិញ ។

ឯកិលេសនោះមានជាពួក ៗ ប្លែកចេញពីគ្នាជាច្រើន តែទោះបីយ៉ាងនេះក៏ដោយ គេគង់អាចបំប្រួញឲ្យនៅត្រឹមតែ ២ ពួកគឺ ៖

ពួកលោកាទិក្កិលេស គឺពួកកិលេសដែលមានលោកៈជាអាទិ ។

និងពួកពគាទិក្កិលេស គឺពួកកិលេសដែលមានពគៈជាអាទិ ។

ឯអកុសលមូល ៣ និងកិលេស ១០ ហើយនិងឧបក្កិលេស ១៦ គួរសង្គ្រោះចូលក្នុងពួកលោកាទិក្កិលេស ។

ចំណែកឯកិលេសមូល ៣, នីវរណៈ ៥, កិលេសកាម ៦, អនុស័យ ៧ និងសំយោជនៈ ១០ គប្បីសង្គ្រោះចូលក្នុងពួកពគាទិក្កិលេស ។

ឯកិលេសទាំងឡាយនេះ ខ្ញុំមិនលើកយកមករៀបរាប់នៅទីនេះទាំងអស់ទេ, ដើម្បីកុំឲ្យវែងសេចក្តីបរិយាយពេក, ហើយម្យ៉ាងទៀត ពីព្រោះខ្ញុំជឿជាក់ថាអស់លោកអ្នកអានគង់បានជ្រាប អំពីកិលេសទាំងឡាយ

នោះសព្វគ្រប់ទៅហើយដែរ ។

ខ្ញុំសូមគ្រាន់តែលើកយកសំយោជនៈ ១០ មកអធិប្បាយបញ្ជាក់ ពីព្រោះសំយោជនៈ ១០ នោះជាប់ទាក់ទងជាពិសេស នឹងការត្រាស់ដឹងលោកុត្តរធម៌នោះ ។

ឯសំយោជនៈ ១០ នោះគឺ ៖

១- សក្កាយទិដ្ឋិ គឺសេចក្ដីយល់ឃើញខុសចំពោះកាយ មានការយល់ឃើញថាមានរូបក្នុងកាយជាដើម ។

២- វិចិកិច្ឆា គឺសេចក្ដីសង្ស័យចំពោះនាមរូប មានសេចក្ដីសង្ស័យថាអាត្មាអញធ្លាប់បានកើតដែរឬទេជាដើម ។

៣- សីលព្វតបរាមាស គឺសេចក្ដីចូលចិត្តកាន់អាន់វត្តប្រតិបត្តិខុសទំនង ។

៤- កាមរាគ គឺតម្រេកក្នុងកាមភព ។

៥- បដិឃៈ គឺសេចក្ដីបង្អៀតបង្អល់ចិត្ត ឬសេចក្ដីអាក់អន់ចិត្ត ។

៦- រូបរាគ គឺតម្រេកក្នុងរូបភព ។

៧- អរូបរាគ គឺតម្រេកក្នុងអរូបភព ។

៨- មានះ គឺសេចក្ដីប្រកាន់ខ្លួន ។

៩– ឧទ្ធច្ចៈ គឺ សេចក្ដីរាយមាយនៃចិត្ត ។

១០– អវិជ្ជា គឺ សេចក្ដីល្ងង់ ។

ឯសំយោជនៈ ១០ នេះ ជាកិលេសរឹងត្អឹងរឹតរួតចិត្តសត្វ ធ្វើឲ្យសត្វវង្វេងភ្លេចខ្លួនជាប់ស្អិតនៅវិលវល់ក្នុងវដ្ដសង្សារ, ដោយហេតុនេះ អរិយបុគ្គលគប្បីព្យាយាមលះសំយោជនៈ ១០ នោះ ឲ្យដាច់ស្រឡះអស់ពីខន្ធសន្ដានទើបអាចត្រាស់ដឹងលោកុត្តរធម៌ គឺមគ្គ ផល និព្វានបាន ។

លំដាប់តទៅនេះ ខ្ញុំនឹងអធិប្បាយវែកញែកបញ្ជាក់អំពីទោស នៃកិលេសដូចមានសេចក្ដីខាងក្រោមនេះ ។

កាលបើសត្វណាធ្វេសប្រហែស បណ្ដោយឲ្យពួកលោភាទិកិលេសចូលមកកើតក្នុងខន្ធសន្ដានហើយ កិលេសពួកនេះរមែងធ្វើសត្វនោះឲ្យវង្វេងភ្លេចភាំងស្មារតី លែងមានគំនិតគិតបំពេញនូវបុញ្ញកិរិយាវត្ថុមានទានសីលជាដើម, គិតឃើញតែពីលោកបង់មានបង់បានហួសហេតុ, គិតតែខឹងរករឿងហេតុដើម្បីប្រទូស្ដបៀតបៀនអ្នកដទៃ ហើយនឹងគិតឃើញតែខុសហើយប្រកាន់ឡើងថាជាត្រូវ ដែលជាហេតុនាំឲ្យកើតមនោទុច្ចរិត ៣ ប្រការគឺ អភិជ្ឈា, ព្យាបាទ និងមិច្ឆាទិដ្ឋិ ។ កាលបើសត្វលុះដោយអំណាចនៃមនោទុច្ចរិត ៣ ប្រការនេះហើយ, សត្វនោះលែងរអែង លែងញញើតនឹងប្រព្រឹត្តនូវកាយទុច្ចរិត ៣ និងវចីទុច្ចរិត ៤ ទៀត ដែលជាហេតុនាំឲ្យសត្វនោះ ធ្លាក់ខ្លួនទៅរងទុក្ខវេទនាក្នុងទុគ្គតិភពរកទីបំផុតគ្មានឡើយ ។

រីឯទោសនៃរាគាទិក្កិលេសនោះ មានសភាពនិងលក្ខណៈខុសពីទោសនៃលោភាទិក្កិលេសដូចបានអធិប្បាយខាងលើនេះ ។

ឯរាគាទិក្កិលេសនេះ បើមកកើតក្នុងខន្ធសន្តានការណាហើយ រមែងដុតកំដៅខន្ធសន្តានឲ្យក្តៅក្រហល់ក្រហាយ ឲ្យអន្ទះអន្ទែង និងឲ្យស្រេកឃ្លានត្រេកត្រអាលសប្បាយរីករាយចំពោះអារម្មណ៍ ៥ មានរូបជាដើម ដែលជាហេតុ នាំឲ្យសត្វស្រវឹងជ្រុលជ្រប់វង្វេងវិលវល់នៅក្នុងវដ្តសង្សារ រងទុក្ខវេទនារកទីបំផុតគ្មានឡើយ ។

អាស្រ័យហេតុដូចខាងលើនេះ ទើបលោកចាត់ទុករាគាទិក្កិលេស ជាកិលេសកាមគឺកិលេសជាអ្នកញុះញង់ និងលួងលោមចិត្តឲ្យប្រាថ្នា ឲ្យពេញចិត្តនូវអារម្មណ៍ ៥ មានរូបជាដើម, ហើយលោកចាត់ទុកអា-រម្មណ៍ ៥ នោះជាវត្ថុកាម គឺវត្ថុដែលជាទីគួរឲ្យប្រាថ្នាគួរឲ្យពេញចិត្ត, ព្រោះអារម្មណ៍ ៥ នោះ សុទ្ធតែមានសុភនិមិត្តគឺគ្រឿងសំគាល់ថា ល្អប្រចាំរៀងខ្លួនដូចជា:

រូបមានឆោមល្អប្រិមប្រិយជាដើម ជាសុភនិមិត្តលួងលោមចិត្តឲ្យស្រឡាញ់និងឲ្យប្រាថ្នា ។

សម្លេងពីរោះ ជាសុភនិមិត្តលួងលោមចិត្តឲ្យចង់ស្តាប់ ។ល។ គឺដំណើរចំរើននៃសេចក្តីប្រាថ្នានូវអារម្មណ៍ ៥ នេះ ឬ សេចក្តីជំពាក់ចិត្តនិងសេចក្តីប្រាថ្នានូវអារម្មណ៍ ៥ មានរូបជាដើមនេះហើយ ដែលហៅថា

កាមគុណនោះ ៗ ដោយហេតុនេះ ទើបសត្វដែលមានសន្តានចិត្តសៅហ្មងដោយកិលេសកាមនោះហើយ រមែងតែស្រវឹងជ្រុលជ្រប់វង្វេងភ្លេចខ្លួនជាប់ស្អិតនឹងវត្ថុកាមពោលគឺអារម្មណ៍ ៥ នោះ គម្រទឹងដកទាញចិត្តឲ្យរួចផុតពីវត្ថុកាមនោះបានដោយងាយស្រួលឡើយ ។

មិនតែប៉ុណ្ណោះ រាគានុសយកិលេសនេះ លោកចាត់ទុកជាសមុដ្ឋាននៃតណ្ហា ពីព្រោះតណ្ហាដែលនឹងមានដំណើរប្រព្រឹត្តទៅជាប្រក្រតីបាន ក៏ព្រោះតែរាគានុសយកិលេសនោះជាមូលហេតុ ។

តើតណ្ហានោះជាអ្វី ?

វចនានុក្រមឆ្លើយប្រាប់ថា ឯតណ្ហានោះគឺបំណង, សេចក្តីប្រាថ្នា, សេចក្តីស្រេកឃ្លាន ឬសេចក្តីអន្ទះអន្ទែង ។

រីឯលក្ខណៈនៃតណ្ហានោះ មានសៀវភៅសតិបដ្ឋានសូត្រ ទំព័រ ១០៣ ប្រាប់បញ្ជាក់ឲ្យដឹងថា : តណ្ហាឯណាដែលមានកិរិយាធ្វើនូវភពថ្មីជាប្រក្រតី កើតលើតព្រមដោយនន្ទិរាគៈ ត្រេកអរត្រេកអរក្នុងភពនោះៗ ឬក្នុងអារម្មណ៍នោះ ៗ តណ្ហានោះហៅថា ទុក្ខសមុទយអរិយសច្ចៈ ។

សេចក្តីបញ្ជាក់អំពីតណ្ហា ដែលខ្ញុំនាំយកមកពណ៌នាខាងលើនេះ ឃើញថាមានន័យគ្រោះក្រាយល្មមឲ្យយល់បានហើយ ។

រីឯតណ្ហានោះមាន ៣ ប្រការគឺ :

- កាមតណ្ហា គឺសេចក្ដីប្រាថ្នាចង់កើតក្នុងកាមភព ដោយមាន

កាមរាគ ជាសម្ផដ្ឋាន ។

- ភវតណ្ហា គឺសេចក្ដីប្រាថ្នាចង់កើតក្នុងរូបភព ដោយមាន

រូបរាគ ជាសម្ផដ្ឋាន ។

- វិភវតណ្ហា គឺសេចក្ដីប្រាថ្នាចង់កើតក្នុងអរូបភព ដោយមាន

អរូបរាគ ជាសម្ផដ្ឋាន ។

គឺតណ្ហានេះហើយ ដែលលោកចាត់ទុកជាមេជាង គឺជាអ្នកទទួលការកិច្ចខាងការស្ថាបនាកសាងខន្ធ ៥ គឺអត្តភាព ឬរូបកាយនៃសត្វឲ្យកើតមានក្នុងភពថ្មីទៀតនោះ ។

អាស្រ័យហេតុនេះ ទើបបណ្ឌិតទាំងឡាយ កាលបើបានដឹងជាក់ច្បាស់នូវទោសនៃពួកលោកាមិក្កិលេស និងពួកកាមិក្កិលេស ហើយនិងទោសនៃតណ្ហាដូច្នេះហើយ រមែងតែព្យាយាមបំពេញការវត្តធម៌ផ្សេង ៗ មានការចំរើនសមថកម្មដ្ឋាន និងវិបស្សនាការនាជាដើម ដើម្បីជាប្រយោជន៍ដល់ការត្រាស់ដឹងនូវមគ្គ ៤ ផល ៤ និងនិព្វាន ពីព្រោះមគ្គ ផល និព្វាន នេះ ៖

១- ជាវិមោក្ខធម៌ គឺធម៌អាចញុំាងសត្វឲ្យរួចចាកកិលេស និងតណ្ហានោះបាន ។

២– ជាមោក្ខធម៌ គឺធម៌អាចញុំាងសត្វឲ្យរួចចាកកងទុក្ខ មាន ជាតិទុក្ខជាដើមបាន ។

៣– និងជាលោកុត្តរធម៌ គឺធម៌អាចបម្លងសត្វឲ្យឆ្លងចេញរួចចាក លោក លែងត្រឡប់មកអន្ទោលវិលកើតវិលស្លាប់ក្នុងភពតូចភពធំទៀត ។

### សេចក្ដីឆ្លើយអំពីសំនួរ ៨១

ដើម្បីឲ្យអស់លោក-អ្នកអានសៀវភៅនេះ បានយល់អំពីកិលេស កាន់តែជ្រៅទៅទៀត ខ្ញុំនឹងធ្វើអត្ថាធិប្បាយឆ្លើយដោះស្រាយអំពីសំនួរ ដូចតទៅនេះ ៖

សំនួរទី ១ – តើហេតុដូចម្ដេចបានជាក្នុងពួកអកុសលមូលគឺ លោភៈ ទោសៈ មោហៈ និងក្នុងពួកកិលេសមូលគឺ រាគៈ ទោសៈ មោហៈ នោះគេឃើញមានទោសៈ និងមោហៈដូចគ្នា យ៉ាងដូច្នេះ ?

សេចក្ដីឆ្លើយ– បានជាដូច្នេះ ពីព្រោះទោសៈ និងមោហៈនោះ កាលបើនៅជាប់ជាមួយនឹងលោភៈ ត្រូវមានន័យប្លែកផ្សេងបន្តិចអំពី ទោសៈ និង មោហៈ ដែលនៅជាប់ជាមួយរាគៈ ។ អាស្រ័យហេតុនេះ កាលបើទោសៈ មោហៈ នៅជាប់ជាមួយលោភៈ ដែលជាអកុសល-មូលនោះទោសៈ មោហៈ នោះគួរមានន័យដូច្នេះគឺ ៖

ទោសៈ គឺសេចក្ដីប្រទូស្ត ប្ដូកំហឹងខឹងក្រៀងហេតុ និងបៀត បៀនអ្នកដទៃឲ្យដល់នូវសេចក្ដីវិនាសនឹងសេចក្ដីអន្តរាយផ្សេង ៗ ។

**មោហៈ** គឺសេចក្តីវង្វេង សេចក្តីល្ងង់យល់ខុសហើយប្រកាន់ឡើងថាជាត្រូវដែលជាហេតុនៃមិច្ឆាទិដ្ឋិ ។

កាលបើទោសៈនឹងមោហៈនៅជាប់ជាមួយនឹងរាគៈវិញ ទោសៈនឹងមោហៈនោះគប្បីមានន័យផ្សេងដូច្នេះគឺ ៖

**ទោសៈ** នេះគួរមានន័យត្រឹមតែបដិឃៈគឺសេចក្តីចង្អៀតចង្អល់ចិត្តឬថាំងថាក់ចិត្ត ពីព្រោះអនិដ្ឋារម្មណ៍គ្រាន់តែធ្វើចិត្តឲ្យចង្អៀតចង្អល់មិនឲ្យរីករាយ មិនឲ្យសប្បាយតែប៉ុណ្ណឹង កម្រនឹងបណ្តាយឲ្យកើតទៅជាសេចក្តីប្រទូស្ត ឬបៀតបៀនឡើយ ។

**មោហៈ** គឺសេចក្តីវង្វេងភាន់គំនិត ឲ្យយល់ខុសក្នុងដំណើរនៃសង្ខារធម៌ព្រមទាំងយល់ខុសក្នុងផ្លូវស្វែងរកសេចក្តីសុខ ដែលជាហេតុនៃសីលព្វតបរាមាសៈ គឺសេចក្តីកប់អារម្មណ៍ចូលចិត្តនឹងប្រតិបត្តិខុសទំនង ។ គឺមកតែពីទោសៈ មោហៈ មានន័យផ្សេងគ្នាយ៉ាងនេះហើយ ទើបកិលេសទាំង ២ ពួកនោះមានទោសៈនឹងមោហៈដូចគ្នា ។

**សំនួរទី ២.** អ្វីជាមូលហេតុដែលអាចញុំាងរាគៈ ទោសៈឲ្យចូលមកកើតក្នុងខន្ធសន្តានបាន ?

**សេចក្តីឆ្លើយ-** គឺអារម្មណ៍ ៥ មានរូបជាដើម ពីព្រោះបើអារម្មណ៍នោះជាឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីពេញចិត្តនោះ រមែងតែញុំាង

សោមនស្សឲ្យកើតឡើងដែលជាហេតុនាំឲ្យរាគៈ គឺសេចក្ដីត្រេកត្រអាលរីករាយ មកកើតក្នុងខន្ធសន្ដាន ។

មួយវិញទៀត បើអារម្មណ៍នោះជាអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីពេញចិត្តវិញ ក៏រមែងតែញុំាងទោមនស្សឲ្យកើតឡើង ដែលជាហេតុនាំឲ្យទោសៈ គឺសេចក្ដីអាក់អន់ចិត្ត ឬចង្អៀតចង្អល់ចិត្ត មកកើតក្នុងខន្ធសន្ដានជាដរាប ។

រីឯមូលហេតុនៃមោហៈនោះ មិនគឺអ្វីក្រៅពីអវិជ្ជាទេ ពីព្រោះកាលបើសត្វណាគ្មានវិជ្ជាអ្វីសោះ សត្វនោះត្រូវតែលង់ វង្វេងយល់ខុសពីការណ៍ពិតជាដរាប ។

សំនួរទី ៣_ កាលបើដឹងនូវមូលហេតុនៃរាគៈ ទោសៈ មោហៈដូច្នេះហើយ តើបុគ្គលជាបុថុជ្ជនអាចនឹងលះរាគៈ ទោសៈ មោហៈ ឲ្យដាច់ស្រឡះទៅបានឬទេ ?

សេចក្ដីឆ្លើយ_ ទោះបីបានដឹងនូវមូលហេតុនៃរាគៈ ទោសៈ មោហៈ ដូច្នេះក៏ដោយ បុគ្គលជាបុថុជ្ជនពុំអាចនឹងលះរាគៈ ទោសៈ មោហៈ ឲ្យដាច់ស្រឡះទៅបានទេ បើគ្រាន់តែធ្វើរាគៈ ទោសៈ មោហៈឲ្យស្ងប់រម្ងាប់ស្រាលស្បើយពីខន្ធសន្ដានតែប៉ុណ្ណោះ ទើបបុគ្គលជាបុថុជ្ជនអាចធ្វើឲ្យសម្រេចទៅបាន ដោយខំព្យាយាមសង្រួមឥន្ទ្រិយទាំង ៦ ប្រុងស្មារតីសម្បជញ្ញៈប្រយ័ត្នកុំឲ្យសោមនស្ស នឹងទោមនស្សកើតឡើងបាននូវពេល

ដែលអារម្មណ៍ខាងក្រៅមានរូបជាដើម មកប៉ះនឹងអាយតនៈខាងក្នុងមាន ភ្នែកជាដើម ហើយដំកល់ចិត្តឲ្យតាំងនៅក្នុងឧបេក្ខាធ្វើព្រងើយកន្តើយមិន អើពើចំពោះអារម្មណ៍នោះ ឲ្យបានយូរដកប៉ុណ្ណា ដកបនោះរាគៈ ទោសៈ មោហៈក៏ពុំអាចនឹងកើតឡើងបានឡើយ ។

ក៏ប៉ុន្តែឧបេក្ខានេះ ជាព្រហ្មវិហារុបេក្ខាអាចតាំងនៅយូរបានតែ ត្រឹម ១ ខណៈដែលបុគ្គលកំពុងប្រុងស្មារតីសង្រួមឥន្ទ្រិយតែប៉ុណ្ណោះ លុះ កាលណាលែងសង្រួមចិត្តគំនិតហើយ ឧបេក្ខានោះត្រូវផ្លាស់ទៅឲ្យ សោមនស្ស ឬឲ្យទោមនស្សចូលមកជំនួសខ្លួនវិញ ហើយនៅឱកាសនោះ រាគៈទោសៈ មោហៈ ក៏នឹងកើតឡើងវិញជាធម្មតា ។

សំនួរទី ៤– បើបុគ្គលនោះជាអរិយបុគ្គលវិញ តើលោកត្រូវធ្វើ ដូចម្តេចទើបលះរាគៈ ទោសៈ មោហៈ ឲ្យដាច់ស្រឡះទៅបាន ?

សេចក្តីឆ្លើយ – ប្រសិនជាអរិយបុគ្គលវិញ លោករមែងតែលះ រាគៈ ទោសៈ មោហៈ ឲ្យដាច់ស្រឡះអស់ពីខន្ធសន្តានដោយឈានុបេក្ខា គឺឧបេក្ខាដែលជាអង្គទី ២ នៃចតុត្ថជ្ឈាន ពីព្រោះឈានចិត្តទី ៤ នេះ ដែល សម្បយុត្តដោយអង្គឯកគ្គតា នឹងឧបេក្ខាតែងតាំងនៅជាកណ្តាលព្រងើយ កន្តើយជានិច្ចចំពោះអារម្មណ៍ ៤ មានរូបជាដើម ធ្វើហាក់ដូចជាបិទទ្វារ ទាំង ៦ មានចក្ខុទ្វារជាដើម ប្រឆាំងពាំងមិនឲ្យរាគៈ ទោសៈ មោហៈ ចូលមកកើតក្នុងខន្ធសន្តានបានជាដាច់ខាត ដែលអាចនឹងញ៉ាំងអរិយ-

បុគ្គលអង្គនោះឲ្យលះពាគាទិក្កិលេសដាច់ស្រឡះអស់ពីខន្ធសន្តាន ដោយប្រការដូច្នេះឯង ។

សំនួរទី ៥- ហេតុដូចម្តេចបានជាអរិយបុគ្គលកង់ដំណើរលះកិលេសនោះ ឃើញព្យាយាមលះតែសំយោជនៈ ១០ មិនឃើញខំព្យាយាមលះកិលេសឯទៀតមាន លោភៈ ទោសៈ មោហៈ ជាដើមផង ?

សេចក្តីឆ្លើយ- បានជាអរិយបុគ្គល លោកប្រព្រឹត្តដូច្នេះ ពីព្រោះសំយោជនៈ ១០ នោះ ជាកិលេសរឹងត្អឹងរឹតរួតចិត្តសត្វ ធ្វើឲ្យសត្វវង្វេងភ្លេចកាំងស្មារតី ភ្លេចខ្លួនជាប់ស្អិតនៅវិលវល់ក្នុងវដ្តសង្សារ ។

ម្យ៉ាងទៀត ពីព្រោះសំយោជនៈ ១០ ជាសមុដ្ឋាននៃតណ្ហា ៣ ប្រការដែលលោកចាត់ទុកថាជាមេជាងទទួលការកិច្ច ខាងការស្ថាបនាកសាងខន្ធ ៥ ឲ្យកើតមានក្នុងភពថ្មីទៀត ។ ដើម្បីឲ្យរួចចាកផុតពីកណ្តាប់ដៃនៃតណ្ហា ៣ ប្រការនោះ ទើបអរិយបុគ្គលលោកព្យាយាមខំលះសំយោជនៈ ១០ នោះឯង ។

ម្យ៉ាងវិញទៀត គប្បីយល់ថា ខន្ធសន្តានដែលរួចចាកសំយោជនៈ ១០ ហើយលែងអន្ទះអន្ទែង, លែងស្រេកឃ្លានទ្រព្យគកាមទៅហើយ ក៏រមែងតែនឿយណាយលែងស្រេកឃ្លាន ចង់បានទ្រព្យលោកិយសម្បត្តិជាលំដាប់ដែរ ។

សំនួរទី ៦- ឈានដែលលោកចាត់ទុកថាជាគ្រឿងសម្រាប់ដុត

កំដៅខន្ធសន្តានឲ្យរីងស្ងួតចាករាគាទិកិលេសនោះ តើឈាននោះអាចដុតកំដៅខន្ធសន្តានឲ្យរីងស្ងួតទៅបានដោយប្រការដូចម្តេចខ្លះ ?

សេចក្តីឆ្លើយ ឯពាក្យដែលពោលដូច្នេះ គឺជាពាក្យពោលដោយអត្ថប្បដិរូបគឺដោយបញ្ចិតបញ្ចៀង ព្រោះឈានចិត្តមានចតុត្ថជ្ឈានជាដើម មានអង្គឯកគ្គតានឹងឧបេក្ខាជាអ្នករង់ចាំតែបិទទ្វារទាំង ៦ មានចក្ខុទ្វារជាដើម មិនឲ្យរាគៈ ទោសៈ មោហៈ មកកើតក្នុងខន្ធសន្តានបាន ដែលជាហេតុនាំឲ្យខន្ធសន្តាននោះរីងស្ងួតចាករាគាទិកិលេសអស់ទៅ ។

អាស្រ័យហេតុនេះ បានជាលោកអ្នកប្រាជ្ញ លោកពោលដោយសន្មតថា ឈានជាគ្រឿងដុតពេលខន្ធសន្តាន ឲ្យរីងហួតស្ងួតចាករាគាទិកិលេសដោយប្រការដូច្នេះឯង ។

រីឯវិបស្សនាញាណក៏ដូចឈាននោះដែរ ព្រោះវិបស្សនាញាណ គឺញាណដែលដឹងច្បាស់នូវដំណើរនៃសង្ខារទៅតាមការណ៍ពិត, រមែងតែកំពង់មោហៈ នឹងមិច្ឆាទិដ្ឋិ មិនឲ្យមកកើតក្នុងខន្ធសន្តានបាន ដែលជាហេតុនាំឲ្យខន្ធសន្តានរួចចាកមោហៈនឹងមិច្ឆាទិដ្ឋិទៅបាន ។

សំនួរទី ៣_ ម្យ៉ាងទៀត ហេតុដូចម្តេចបានជាការរលត់នៃកិលេសទៅជាហេតុអាចនឹងញុាំងជាតិ គឺការកើតឡើងនៃបញ្ចក្ខន្ធឲ្យរលត់ទៅផងដែរ ?

(នៅមានត)

# ព្រះអភិធម្មបិដក

## គម្ពីរព្រះយមក

*លោក ប៊ូ-ប៊ូ ប្រែរៀបរៀង*

(តមក)

---

កុលុបកត្ថេរំ បុច្ឆិ បុរសជាបុត្រអមាត្យនឹកចង់ចំរើនមេត្តាព្រហ្មវិហារ ទើបទូលសួរព្រះមហាថេរថា “ភន្តេ បពិត្រលោកម្ចាស់ ការចំរើនមេត្តានោះ តើនឹងឲ្យចំរើនទៅក្នុងបុគ្គលណា ?” ។

ព្រះមហាថេរប្រាប់ថា “បិយបុគ្គលេ ភាវេតព្វា បុគ្គលគប្បីចំរើនមេត្តាទៅក្នុងបុគ្គលជាទីស្រឡាញ់” ។ បុត្រអមាត្យមានភរិយាជាទីស្រឡាញ់ពេញចិត្តណាស់ ទើបផ្សាយមេត្តាទៅក្នុងភរិយា ក៏រអិលចិត្តធ្លាក់ទៅខាងកាមៈ (តម្រេក) ចាប់ចិត្តប្រតិព័ទ្ធក្នុងភរិយារបស់ខ្លួន រឹតតែទ្រើឡើង មិនអាចញ៉ាំងមេត្តាឲ្យតាំងនៅបាន មានចិត្តពោរពេញទៅដោយកាមៈវិញ ។

មានព្រះបាលីទទួលកំបាំងជាសំអាង ដែលអាចារ្យពោលទុកថា “សព្វរត្តិំ ភិត្តិយុទ្ធំ អកាសិ បុត្រអមាត្យចំអត់សង្កត់រំលត់ចិត្តមិនបាន ព្រោះហេតុផ្សាយមេត្តាទៅក្នុងអារម្មណ៍ជាវិសភាគគឺស្ត្រីមិនអាចញ៉ាំងមេត្តាឲ្យកើតឡើងបាន ទើបលោកហាមមិនឲ្យផ្សាយក្នុងស្ត្រីជាមុន ។

ការដែលលោកហាមមិនឲ្យផ្សាយមេត្តាទៅក្នុងបុគ្គលស្លាប់នោះ ព្រោះមិនបានឧបចារជ្ឈាននិងអប្បនាឈានទេ ដូចភិក្ខុឈ្មោះមួយរូបចំរើនមេត្តា

កម្មដ្ឋានប្រារព្ធព្រះមហាថេរជាអាចារ្យ ដែលរលត់សង្ខារទៅហើយ ។ មេត្តាកម្មដ្ឋានក៏មិនបានប្រាកដ ភិក្ខុនោះកំណត់សំគាល់ថា “បក្ខុណភា ច មេត្តា អាត្មាអញនឹងចំរើនមេត្តាៗ នេះក៏ស្ទាត់ជំនាញចាំមាត់ប្រាកដក្នុងចិត្តអញ ហេតុអ្វីបានជាឧបចារជ្ឈាននឹងអប្បនាឈានមិនកើតឡើង” សំគាល់ដូច្នេះហើយ ទើបចូលទៅរកព្រះមហាថេរជាធំ ទូលសួរថា “បពិត្រព្រះករុណាម្ចាស់! ខ្ញុំព្រះករុណាចំរើនមេត្តាទាល់តែស្ទាត់ ចាំរត់មាត់ប្រាកដក្នុងចិត្ត ប៉ុន្តែមិនអាចធ្វើឲ្យកើតឧបចារជ្ឈាននឹងអប្បនា-ឈានបាន ហេតុអ្វីបានជាយ៉ាងនេះ ? ” ។

ព្រះមហាថេរប្រាប់ថា “គវេសាហិ អ្នកចូរស្វែងរកនិមិត្តចុះ” ។ ភិក្ខុនោះពិចារណាទៅក៏យល់ថា “អាត្មាផ្សាយមេត្តាទៅក្នុងលោកអាចារ្យដែលរលត់បញ្ចក្ខន្ធទៅហើយ” យល់ដូច្នោះ ទើបចំរើនមេត្តាប្រារព្ធបុគ្គលដទៃវិញ ក៏បាននូវមេត្តាសមាបត្តិ ។ ហេតុនោះ បានជាលោកហាមមិនឲ្យផ្សាយទៅក្នុងបុគ្គលស្លាប់ ។

ភិក្ខុចំរើននូវមេត្តាកម្មដ្ឋាន គប្បីចំរើន មេត្តាទៅក្នុងខ្លួនជាមុន ។ ចំរើនមេត្តាក្នុងខ្លួនឯងនោះថា “អហំ សុខិតោ ហោមិ ចូរឲ្យអាត្មាបានសុខ កុំឲ្យមានទុក្ខ ចូរកុំឲ្យមានពៀរព្យាបាទអន្តរាយ ចូររក្សាខ្លួនឲ្យបានសុខ” ។ ឲ្យចំរើននូវខ្លួនរឿយៗ យ៉ាងនេះជាមុនជាងបុគ្គលឯទៀត មេត្តាឈានក៏នឹងកើតមានឡើង ។

មានពាក្យបុច្ឆាថា: ឯវំ សន្តេ កាលបើផ្សាយមេត្តាក្នុងខ្លួនជាមុន មិនផ្សាយមេត្តាក្នុងបុគ្គលទាំងពួងជាមុនដូច្នេះ តើពាក្យដែលសម្តេចព្រះមានព្រះភាគត្រាស់ក្នុងគម្ពីរព្រះវិភង្គថា ឯកំ ទិសំ ផរិត្វា ភិក្ខុប្រាថ្នានឹងចំរើនមេត្តា គឺផ្សាយក្នុងទិសមួយនឹងទិសពីរជាអាទិដោយចិត្តមេត្តា ឯពាក្យក្នុងគម្ពីរបដិសម្ភិទាថា ឲ្យផ្សាយមេត្តាទៅក្នុងសព្វសត្វ នឹងពាក្យក្នុងមេត្តសូត្រថា សម្តេចព្រះមានព្រះភាគត្រាស់ទេសនាថា ឲ្យភិក្ខុទាំងឡាយផ្សាយមេត្តាចិត្តកុំឲ្យរើសមុខ ហើយគប្បីពោលថា ដោយកំណត់ទុកក្នុងចិត្តថា សុខិនោ វា ខេមិនោ ហោន្តុ សត្វទាំងឡាយទាំងពួងចូរប្រកបដោយសេចក្តីសុខ, អស់ទុក្ខ ; អស់ភ័យ, មានកាយនឹងចិត្តជាសុខ ។ ពាក្យទាំងឡាយដែលសម្តេចព្រះមានព្រះភាគត្រាស់ទេសនាក្នុងគម្ពីរវិភង្គ នឹងគម្ពីរបដិសម្ភិទា នឹងក្នុងមេត្តសូត្រ ដែលប្រាប់ឲ្យផ្សាយមេត្តាចិត្តទៅក្នុងសត្វទាំងពួង មិនខុសពីពាក្យដែលថា កុំឲ្យផ្សាយមេត្តាចិត្តទៅក្នុងមនុស្សទាំងឡាយជាមុនទៅហើយ ឬក៏មានន័យយ៉ាងណាទៅវិញ ? ។

មានពាក្យវិសជ្ជនាថា ពាក្យដែលថាឲ្យផ្សាយមេត្តាចិត្តក្នុងខ្លួនជាមុន នឹងពាក្យក្នុងគម្ពីរវិភង្គជាដើមនោះមិនខុសទេ ព្រោះហេតុថាឲ្យផ្សាយទៅក្នុងខ្លួនជាមុននោះ ដោយអំណាចបុគ្គលចំរើនមេត្តាក្នុងខាងដើម ឲ្យផ្សាយមេត្តាទៅឥតរើសមុខ ដោយអំណាចនៃបុគ្គលដល់នូវអប្បនាឈាន

នឹងឲ្យផ្សាយមេត្តាទៅក្នុងខ្លួនជាមុននោះ គឺនឹងបានធ្វើខ្លួនឲ្យជាបន្ទាល់ ហើយផ្សាយមេត្តាទៅក្នុងសត្វទាំងឡាយឥតលំបាកចិត្ត ។ ហេតុនោះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា "ពាក្យដែលថាមកទាំងអស់នេះ មិនខុសគ្នាទេ គប្បីចូលចិត្តតាមន័យនេះចុះ" ។

## វិធីចំរើនមេត្តា

អថានេន អរិយបុគ្គលេសុ យត្ថ កត្ថចិ បុនប្បុនំ មេត្តំ សមាបជ្ជិត្វា វុដ្ឋហិត្វា បុនប្បុនំ តំ បុគ្គលំ មេត្តាយន្តេន បដិឃំ វិនោទេតព្វន្តិ ។

លំដាប់នេះ នឹងពណ៌នានូវវិធីចំរើនមេត្តាតទៅ សេចក្តីថា: អ-ថានេន ក្នុងកាលព្រះយោគាវចរកុលបុត្រផ្សាយមេត្តាទៅក្នុងបុគ្គលមានពៀរនឹងគ្នាដែលនៅជាបុថុជ្ជន លុះរឭកនឹកទៅដល់អ្នកមានពៀរនឹងគ្នាហើយ បដិឃចិត្ត (ចិត្តគិតនឹងបៀតបៀន) ក៏កើតមានឡើង ហេតុតែនឹករឭកឃើញទោស ដែលបុគ្គលមានពៀរនឹងខ្លួននោះបានធ្វើដល់ខ្លួនកាលបដិឃចិត្តគិតបៀតបៀនបំផ្លិចបំផ្លាញគ្នាកើតហើយ ក៏ខំកំចាត់បង់ចេញបាន បើមិនព្យាយាមលះបង់ទេ ចិត្តបដិឃៈមិនរលត់ឡើយ គប្បីនឹករឭកដល់ព្រះបរមពុទ្ធោវាទទាំងឡាយ ដែលព្រះសាស្តាត្រាស់ដោយឧបមាក្នុងកកចូបមសូត្រជាដើម ហើយគប្បីឲ្យឱវាទប្រៀនប្រដៅខ្លួន

ដោយខ្លួនឯងថា "អវេ កុជ្ឈកាបុរិស ម្នាលអ្នកជាបុរសច្រើនដោយសេចក្ដីក្រោធ ជាមនុស្សអាក្រក់ សម្ដេចព្រះមានព្រះភាគមានព្រះពុទ្ធាធិប្បាយប្រោសប្រទាននូវព្រះបរមពុទ្ធោវាទថា សចេ បិ ភិក្ខវេ កកចេន ចោរា ម្នាលភិក្ខុទាំងឡាយ ចោរទាំងឡាយប្រព្រឹត្តនូវការដ៏ឃោរអាក្រក់ បើកាត់អវយវៈតូចធំរបស់អ្នក ហើយអ្នកខឹងនឹងចោរមានចិត្តប្រទូស្តរាយនឹងចោរវិញ អ្នកមិនឈ្មោះថាប្រតិបត្តិតាមឱវាទរបស់ព្រះតថាគតទេ យោ ច បដិកុជ្ឈតិ សូម្បីភិក្ខុណាក្រោធខឹងតបនឹងបុគ្គលអ្នកក្រោធ ភិក្ខុនោះឈ្មោះថាប្រកបដោយកម្មដ៏អាក្រក់លា-មកគឺនឹងកាត់បង់នូវប្រយោជន៍ នឹងធ្វើខ្លួនឲ្យធ្លាក់ទៅកាន់អបាយទាំងបួនមាននរកជាដើម កុទ្ធំ អប្បដិកុជ្ឈន្តោ បុគ្គលមិនក្រោធខឹងតបទៅបុគ្គលអ្នកក្រោធខឹងនឹងខ្លួននោះ ឈ្មោះថាឈ្នះនូវសង្គ្រាមដែលគេឈ្នះបានដោយក្រ ឧភិន្នំ អត្ថំ ចរតិ បុគ្គលមិនក្រោធខឹងតបនឹងអ្នកក្រោធខឹងនោះ ឈ្មោះថា ប្រព្រឹត្តធ្វើនូវប្រយោជន៍ ដល់បុគ្គលពីរនាក់ គឺខ្លួន ១ អ្នកដទៃ ១" ។

មនុស្សកើតមកក្នុងលោក គ្មានអ្នកណាម្នាក់មិនក្រោធខឹងទេ សុទ្ធតែក្រោធខឹងគ្រប់គ្នា ប៉ុន្តែ អ្នកណាមានស្មារតីត្រិះរិះថា "ចិត្តអញក្រោធខឹងហើយ ក៏ខំទាំមាត់អត់សង្កត់ដឹកគាស់រំលើងចេញដោយឧបាយ ១ ជា ឲ្យរឭកនឹកដល់ព្រះបរមពុទ្ធោវាទយ៉ាងនេះហើយ ទើបនឹងដំកល់ខ្លួនទុក

កុសលមូលនៃកុសលគឺ អទោសោ បាន អាស្រ័យមានខន្តី គឺសេចក្តីអត់ធន់" ។

ប្រការមួយទៀត ការដែលលះបង់នូវបដិឃចិត្តនោះ គប្បីកំណត់កុសិចិត្តតាមព្រះពុទ្ធោវាទដែលព្រះតថាគតទ្រង់ប្រទានព្រះសទ្ធម្មទេសនា ទុកថា "សត្តិមេ ភិក្ខវេ ធម្មា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៧ ប្រការ រមែងជាទីប្រាថ្នានៃបុគ្គលជាសត្រូវ ជាហេតុនៃបុគ្គលជាសត្រូវ រមែងមកដល់នូវស្ត្រីនិងបុរសដ៏ប្រកបដោយសេចក្តីក្រោធ" ត្រាស់ប៉ុណ្ណោះហើយ ទើបទ្រង់ត្រាស់បុច្ឆាថា "កតមេ សត្ត ធម៌ ៧ ប្រការ ជាទីប្រាថ្នានៃបុគ្គលជាសត្រូវនឹងគ្នានោះ តើគឺធម៌ណាខ្លះ ?"

ទើបត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា "ម្នាលភិក្ខុសង្ឃ បុគ្គលជាសត្រូវក្នុងលោកនេះ រមែងប្រាថ្នាដល់បុគ្គលជាសត្រូវនឹងខ្លួនថា អហោ វត ដូចអាត្មាអញប្រាថ្នា បុគ្គលនេះ គប្បីមានពណ៌សម្បុរអាក្រក់ជាទីស្អប់ខ្ពើមរបស់ជនទាំងឡាយ ហើយកុំឲ្យប្រកបដោយកិត្តិសព្ទ និងកិត្តិគុណឡើយ" ។ បុគ្គលជាសត្រូវប្រាថ្នាដល់បុគ្គលជាសត្រូវនឹងខ្លួនយ៉ាងនេះជាដើម ហេតុនោះ បុគ្គលជាសត្រូវនោះ មិនដែលប្រាថ្នាឲ្យបុគ្គលជាសត្រូវនឹងខ្លួន មានសេចក្តីសរសើរ ដេកជាសុខ និងមានភោគសម្បត្តិ, មានយសសក្តិ, អស់ជីវិតហើយទៅដេកនៅស្ថានសួគ៌ដូច្នេះសោះឡើយ ។ កោធនំ នាយំ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ

បុគ្គលក្រោធខឹងច្រើន សេចក្តីក្រោធគ្របសង្កត់ជាប់ជានិច្ច មានចិត្តក្រោធជាត្រីមុខ រមែងប្រព្រឹត្តធ្វើនូវអំពើទុច្ចរិតដោយកាយវាចានិងចិត្ត ។ កាយស្ស ភេទា លុះអស់ជីវិតព្រោះកាយបែកធ្លាយហើយ រមែងទៅកើតក្នុងទុគ្គតិចតុរាបាយ គឺអសុរកាយ, ប្រេត, នរក និងសត្វតិរច្ឆាន ។

អ្នកប្រាជ្ញគប្បីនឹករឭកដល់ក្រសែព្រះពុទ្ធបរិហារដែលប្រទានទេសនាទុកដូចពោលមកហើយ គប្បីព្យាយាមកំចាត់បង់នូវចិត្តក្រោធខឹងចេញ កុំឲ្យកើតមានឡើងក្នុងខន្ធសន្តានបាន បើព្យាយាមអត់សង្កត់ក្រោធបានហើយ បដិឃចិត្តក៏ស្ងប់រម្ងាប់ នេះជាកុសល ។ បើសុចរិតធម៌ណារបស់បុគ្គលនោះបរិសុទ្ធផូរផង់ គប្បីនឹករឭកដល់សុចរិតធម៌របស់បុគ្គលនោះឲ្យរឿយ ។ លុះបានរឭកឃើញរឿយ ។ ហើយ ក៏នឹងកំចាត់បង់នូវសេចក្តីអាឃាតគំនុំគុំគួនចងពៀរព្យាបាទឲ្យដាច់បាន ។

បុគ្គលពួកមួយក្នុងលោកនេះ មានកាយសមាចារ គឺអាការប្រព្រឹត្តដោយកាយស្ងប់រម្ងាប់ ក៏ជាទីស្រឡាញ់នៃជនទាំងពួង ។ បុគ្គលពួកមួយស្ងប់រម្ងាប់ល្អតែកាយម្យ៉ាង ឯវាចានិងចិត្តមិនស្ងប់ល្អ កុំគប្បីគិតនឹកដល់វាចាសមាចារ និងមនោសមាចារនៃបុគ្គលនោះឡើយ គប្បីនឹករឭករឿយ ។ តែកាយសមាចាររបស់អ្នកនោះម្យ៉ាង ១ បុគ្គលពួកមួយប្រព្រឹត្តល្អស្ងប់រម្ងាប់តែកាយនិងវាចា ឯចិត្តមិនស្ងប់ល្អ មិនស្ងប់រម្ងាប់ បុគ្គលនោះក៏ជាទីស្រឡាញ់របស់ជនទាំងពួង ព្រោះហេតុឈ្មោសវៃក្នុងសំដីនិយាយ

ពាក់ពាក់ទទួលបដិសណ្ឋារៈចំពោះគេទៀត ។ កុលបុត្រអ្នកចំរើនមេត្តាព្រហ្ម-
វិហារ កុំគប្បីគិតដល់កាយសមាចារ និងមនោសមាចារនៃបុគ្គលនោះ
ឡើយ គប្បីនឹករឭករឿយៗ តែវាចាសមាចាររបស់បុគ្គលនោះ ។ បុគ្គល
ពួកខ្លះប្រព្រឹត្តល្អផ្លូវចិត្ត តែកាយនឹងវាចាមិនស្ងប់ល្អ ។ កុលបុត្រអ្នកចំរើន
មេត្តាព្រហ្មវិហារផ្សាយទៅកន្លងបុគ្គលនោះ កុំគប្បីគិតនូវកាយសមាចារ
នឹងវាចាសមាចារនៃបុគ្គលនោះឡើយ គប្បីនឹករឭកតែមនោសមាចារ
របស់អ្នកនោះម្យ៉ាង ។ បុគ្គលប្រព្រឹត្តល្អផ្លូវចិត្តនោះ ប្រាកដក្នុងកាល
សំពះព្រះចេតិយ ព្រះស្រីមហាពោធិជាដើម អវូបសន្តចិត្តោ បុគ្គល
អ្នកមានចិត្តមិនស្ងប់ម្ងាប់នោះ នមស្ការព្រះមហាថេរ, ព្រះចេតិយ
នឹងព្រះស្រីមហាពោធិគ្មានសេចក្តីគោរពទេ ឆមូស្សរៈឆមណ្ឌលេ
កាលអង្គុយស្តាប់ព្រះសទ្ធម្មទេសនាក្នុងមណ្ឌលជាទីស្តាប់ធម៌ ក៏មិនតាំង
ចិត្តស្តាប់ដែរ បលាយន្តោ ប្រៀបដូចជារត់ចេញទៅ ។

វូបសន្តចិត្តោ បន ចំណែកបុគ្គលអ្នកមានចិត្តស្ងប់ម្ងាប់
កាលទៅសំពះព្រះថេរៈ, ព្រះចេតិយ ព្រះស្រីមហាពោធិ ក៏រមែង
សំពះដោយគោរព , កាលស្តាប់ព្រះសទ្ធម្មទេសនាក្នុងមណ្ឌលជាទី
ស្តាប់ធម៌ក៏ស្តាប់ដោយគោរព ។

បុគ្គលពួកមួយ មិនបានប្រព្រឹត្តស្ងប់ម្ងាប់ដោយកាយវាចាចិត្តទេ អ្នក
ផ្សាយមេត្តានោះ គប្បីតាំងទុកសេចក្តីករុណាក្នុងបុគ្គលនោះថា "ឯស

ចរតិ បុគ្គលនេះត្រាប់ទៅក្នុងមនុស្សលោកដោយប្រការនេះ រមែងប្រព្រឹត្តដូច្នេះក្នុងមនុស្ស លុះអស់ជីវិតហើយនឹងទៅកើតក្នុងទុស្សទនរក នឹងនរកធំ ៨ រណ្តៅទៀត មិនបានយូរទេ ប្រមាណពីរថ្ងៃបីថ្ងៃ អាស្រ័យសេចក្តីករុណានោះ ចិត្តអាឃាតព្យាបាទក៏ស្ងប់រម្ងាប់ ។

មានបុគ្គលពួកខ្លះស្ងប់រម្ងាប់ព្រមទាំងបីប្រការគឺ កាយ វាចា នឹងចិត្ត បុគ្គលផ្សាយមេត្តាទៅក្នុងអ្នកនោះនឹងធ្វើឲ្យច្រើនមិនបាន ។

កាលកុលបុត្រចំរើនមេត្តា ប៉ុន្តែ នៅតែមានចិត្តអាឃាតព្យាបាទ គប្បីឲ្យទូន្មានដល់ខ្លួនថា អត្តនោ វិសយេ ទុក្ខំ ទុក្ខរមែងកើតក្នុងវិស័យរបស់ខ្លួន បើអ្នកមិនបានធ្វើទុក្ខមកទេ បុគ្គលមានពៀរនោះធ្វើយ៉ាងណាមួយ ទុក្ខនេះមិនមែនវិស័យនៃបុគ្គលមានពៀរទេ គឺ បជហាសិ ហេតុអ្វីបានជាអ្នកមិនលះបង់ក្រោធខឹងចេញ ចិត្តក្រោធខឹងនេះធ្វើឲ្យខូចខាតប្រយោជន៍ច្រើនណាស់ ធ្វើឲ្យវិនាសយ៉ាងធំយា ទិ រក្ខិត-សីលាទិ សីលទាំងឡាយឯណាដែលបុគ្គលរក្សា ទោសោគឺសេចក្តីក្រោធនេះកំចាត់បង់នូវទីតាំងនៃសីលទាំងនោះដែលបុគ្គលរក្សា គប្បីឲ្យទូន្មានដល់ខ្លួនដូច្នេះហើយនៅតែមិនបាត់បង់ឃចិត្ត កម្មស្សកតា វេទិតព្វា គប្បីពិចារណាឲ្យឃើញជាក់ច្បាស់ក្នុងចិត្តដោយភាពនៃខ្លួននឹងសត្វឯទៀតមានកម្មជារបស់ខ្លួន គប្បីពិចារណាឲ្យឃើញក្នុងកម្មស្សកតាបញ្ញាថា តស្ស ការោ អ្នកក្រោធខឹងនឹងបុគ្គលនោះ នឹងធ្វើយ៉ាង

ណាដល់បុគ្គលនោះ  អាការដែលអ្នកបានទុក្ខទោសស្រ័យហេតុអ្នកបាន
ធ្វើអកុសលកម្មមិនមែនឬ ? ។

ប្រការមួយទៀត  សូមអ្នកបានសោយសេចក្តីសុខ  បុគ្គលដទៃ
ប្រាថ្នានឹងញុំាងអ្នកឲ្យប្រាសចាកសេចក្តីសុខ  ការនោះនឹងធ្វើយ៉ាងណា
អ្នកបានសេចក្តីសុខក៏អាស្រ័យអ្នកបានធ្វើកុសលកម្មទុកមក អ្នកដទៃដែល
បានទុក្ខ អ្នកនឹងគិតធ្វើយ៉ាងណា  អ្នកដទៃបានសុខនោះ  ក៏អាស្រ័យតែ
កុសលកម្មដែលគេបានធ្វើទុកមក កម្មស្សកោម្ហិ ខ្លួនអ្នកក្តី បុគ្គល
ដទៃក្តី  កើតមកក្នុងលោកនេះមានកម្មជារបស់ខ្លួន  មានកម្មជាទាយាទ
មានកម្មជាកំណើតនាំឲ្យកើតក្នុងសុគតិនិងទុគ្គតិ មានកម្មជាផៅពង្ស មាន
កម្មជាទីអាស្រ័យ  ធ្វើកម្មណាទុកមក  ក៏ត្រូវទទួលផលរបស់កម្មនោះ ។

សេចក្តីក្រោធនេះ  មិនអាចនាំឲ្យបាននូវសម្ពុទ្ធសម្បត្តិ,  បច្ចេក
ពុទ្ធសម្បត្តិ, សាវកសម្បត្តិ និងសម្បត្តិទេវតា, ព្រះឥន្ទ្រ, ព្រះព្រហ្ម,
ព្រះបរមចក្រ,  ស្តេចប្រទេសរាជឡើយ  ។ កាលបើអ្នកលុះទៅក្នុង
អំណាចនៃទោសោ ធ្វើចិត្តឲ្យប្រទូសរាយអ្នកដទៃហើយក៏ឈ្មោះថា បាច
គាបកោយកាយទោសដាក់លើខ្លួនឯង  ប្រៀបដូចបុគ្គលនៅក្នុងទីក្រោម
ខ្យល់ ប្រាថ្នានឹងបាចធូលីទៅលើអ្នកដែលនៅលើខ្យល់  ធូលីនោះត្រ-
ឡប់បកមកត្រូវខ្លួនឯងវិញមិនត្រូវខ្លួនអ្នកនៅលើខ្យល់នោះឡើយ ។ បើ
ពិចារណាដោយកម្មស្សកតាញាណយ៉ាងនេះហើយ នៅតែមិនបាត់បង់យ-

ចិត្តគប្បីនឹករឭកដល់ព្រះគុណនៃសម្តេចព្រះបរមសាស្តាចារ្យកាលព្រះអង្គ មិនទាន់បានត្រាស់ដឹង នៅជាព្រះបរមពោធិសត្វនៅឡើយ ដែលទ្រង់ប្រព្រឹត្តពីកាលមុនមកថា "សម្តេចព្រះបរមសាស្តាចារ្យកាលនៅជាព្រះពោធិសត្វ កំពុងតែស្វែងរកព្រះពោធិញ្ញាណនោះ មិនដែលមានចិត្តប្រទូសកាយដល់អ្នកសម្លាប់ព្រះអង្គ, សម្លាប់ភរិយារបស់ព្រះអង្គទេ, កាលព្រះអង្គសោយព្រះជាតិជាភូរិទត្តនាគរាជ ក៏គ្មានចិត្តប្រទូសកាយដល់អាលម្ពាយដែលធ្វើបាបព្រះអង្គ" ។ កាលនឹករឭកឃើញដោយន័យដូច្នេះជាដើមហើយ ក៏នឹងបាននូវមេត្តាឈាន នឹងផ្សាយមេត្តាចិត្តទៅកាន់ទិសទាំងដប់ គឺទិសធំបួន ទិសតូចបួន ទិសលើមួយ ទិសក្រោមមួយ គ្រប់ជាដប់ទិស ។ ព្រះយោគាវចរកុលបុត្រនោះ ក៏ប្រាសចាកពៀរ, ប្រាសចាកព្យាបាទ, ប្រាសចាកអាឃាត ប្រកបដោយសេចក្តីសុខគ្មានទុក្ខអ្វីឡើយ នឹងជាទីស្រឡាញ់ពេញចិត្តនៃមនុស្សទាំងឡាយ ដូចព្រះវិសាខត្ថេរ សេចក្តីថា ៖

សោ កិរ កុដុម្ពិកោ មានដំណាលថា ព្រះវិសាខត្ថេរ កាលលោកនៅជាគ្រហស្ថនៅឡើយ ប្រកបដោយសម្បត្តិ មានសទ្ធាជ្រះថ្លាបរិច្ចាគសម្បត្តិអស់ហើយបួសឧបសម្បទក្នុងព្រះពុទ្ធសាសនា ចំរើនមេត្តា ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ អ្នកទាំងនោះស្រឡាញ់ដោយសារតែលោកមានមេត្តា ។ ព្រះវិសាខត្ថេរបាននូវមេត្តានោះ, ព្រោះ

អាស្រ័យបាននូវខន្តី ។ កើតឡើងបានព្រោះអាស្រ័យនូវអទោសោ ។ ហេតុនោះ សម្តេចព្រះមានព្រះភាគទ្រង់រាប់អទោសោបញ្ចូលក្នុងមូលនៃកុសលប្រការមួយ ក្នុងបទគឺ សព្វេតេ កុសលមូលា ក្នុងគម្ពីរព្រះយមកដូច្នេះ ។

---

## អមោហោ

អមោហោតិ ឯត្ថ មុយ្ហតីតិ មោហោ, បមាទោ ឯវ មោហោ ន មោហោ អមោហោ, សោ យស្ស សន្តានេ បវត្តោ សោ អប្បមត្តោ សតិសម្បន្នោយេវ ហោតិ ។

លំដាប់នេះ នឹងពណ៌នាក្នុងមូលនៃកុសលដែលមានក្នុងមូលយមកៈ តទៅ ។ មានពាក្យព្រះអដ្ឋកថាចារ្យសំដែងដោយបទវិគ្រោះថា មុយ្ហតិ សភាវៈឯណា ញុំាងសត្វឲ្យវង្វេង សភាវៈនោះឯង ឈ្មោះថា មោហោ ។ នោះគឺសេចក្តីប្រមាទ, ការដែលមិនវង្វេង គឺមិនប្រមាទនោះ សូម្បីអ្នកប្រាជ្ញទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ត្រាស់ហៅថា អមោហោ ។ នោះសម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ចាត់ចូលក្នុងមូលនៃកុសលក្នុងមូលយមកនេះ ។

(នៅមានត)

# មធុរសាហិណី

## សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ.ឈឹន ពិនិត្យ

( តមក )

### ព្យគ្ឃវត្ថុកថា

សំដែងរឿងនិទានខ្លាធំជាលំដាប់តទៅទៀត ដោយបទបាលីថា:

ជម្ពុទីបេ បច្ចុន្តរដ្ឋា សន្ទេ ដូច្នេះជាដើម,

អធិប្បាយថា : ក្នុងជម្ពូទ្វីប ( ឥណ្ឌា ) មានផ្លូវធំមួយកាត់សំដៅទៅកាន់ក្រុងឈ្មោះបំសុបតិត្តជិតស្រុកឈ្មោះបុព្វរដ្ឋនាក្រុងពារាណសីនោះៗ

ក្នុងទីពាក់កណ្ដាលផ្លូវនោះ មានខ្លាធំមួយឥតមានមេ មានតែបាចាស់ជរាខ្លាក់ភ្នែក ខ្លានោះបានយកបារបស់ខ្លួនទៅទុកឲ្យនៅក្នុងគុហាក្បែរភ្នំ ហើយស្វែងរកអាហារឲ្យបរិភោគ តែងចិញ្ចឹមថែរក្សាអស់កាលជានិច្ចនៅទីនោះ ៗ ឯខាងព្រៃក្នុងនោះសោតមានដើមឈើមួយដើម មានសេកមួយឈ្មោះតុណ្ឌិលនៅអាស្រ័យលើដើមឈើនោះ, ឯសត្វទាំងពីរគឺខ្លានឹងសេក, ជាមិត្តសំឡាញ់ពេញចិត្តនឹងគ្នាទៅវិញទៅមកយ៉ាងមាំឥតមានបែកចិត្តគំនិតគ្នានឹងគ្នាឡើយ ៗ

សម័យមួយ មានមនុស្សអ្នកនៅក្នុងបច្ចន្តគ្រាមម្នាក់ កើតជម្លោះឈ្លោះប្រកែកគាស់ទែងគ្នានឹងភរិយារបស់ខ្លួន ហើយលែងលះភរិយា

ទៅហើយ ដើរចេញទៅកាន់ទីក្រុងពារាណសី ក៏បានទៅដល់ទ្វារព្រៃនោះឯង ។

កាលនោះ សត្វសេកបានឃើញបុរសនោះ មានអត្តភាពដ៏ថោកថយ ដល់នូវសេចក្តីទុក្ខលំបាកដើរមកដូច្នោះ ក៏មានចិត្តអាណិតញាប់ញ័រដោយសេចក្តីករុណាពន់ពេកហើយស្រែកហៅបុរសនោះ ឲ្យដើរចូលមកកាន់សំណាក់នៃខ្លួនហើយសួរថា ម្នាលអ្នកដ៏ចំរើន! អ្នកដើរត្រាច់ទៅទីណា? មកពីណា? នេះ ។

បុរសនោះ បានស្តាប់ហើយ ពោលតបថា យើងទៅកាន់ដងព្រៃខាងមុខនេះឯង ។ ឯតុណ្ឌិលសេកក៏និយាយប្រាប់ថា ម្នាលអ្នកដ៏ចំរើនក្នុងដងព្រៃឯនោះ មានខ្លាធំមួយរបឹងរឹងសេកាចអាក្រក់ណាស់ វាមែងចាប់មនុស្សនឹងសត្វទាំងឡាយទំពាស៊ីជាអាហារអស់កាលជានិច្ច ។ ដូច្នេះត្រូវអ្នកកុំដើរទៅកាន់ទីនោះឡើយ ។

ឯបុរសជាមនុស្សប្រេដៅក្រ មានសន្តានចិត្តជាអកតញ្ញូនោះ ពុំបានអើពើស្តាប់បង្គាប់ពាក្យសេក ដែលជាអ្នកប្រាថ្នាប្រយោជន៍ដល់ខ្លួននោះទេ ត្រឡប់ជាពោលពាក្យទ្រគោះតបវិញថា អញចេះតែទៅ អញមិនខ្លាចអ្វីឡើយ ។

តុណ្ឌិលសេកអ្នកមានសន្តានចិត្តល្អជាសប្បុរស លុះបានស្តាប់ពាក្យគំរោះគំរើយដូច្នោះហើយ ក៏ពុំលះបង់ធម៌សប្បុរសរបស់ខ្លួនឡើយ បាន

ពោលសាំតបទៅនឹងបុរសនោះទៀតថាៈ ម្នាលសំឡាញ់មានធុរៈស្មើ ! បើអ្នកពុំបានត្រឡប់វិញទេ បេះតែទៅដូច្នោះនោះ ខ្ញុំមានខ្លាធំមួយជាសំឡាញ់នៅអាស្រ័យក្នុងទីនោះ, រីឯខ្លាធំនោះបើប្រសិនបាន ស្តាប់ពត៌មាននៃខ្ញុំអំពីសំណាក់អ្នកហើយ មុខជាមិនអាចនឹងបៀតបៀនចាំពាំនាំអ្នកយកទៅធ្វើជាអាហារឡើយ ៗ

បុរសអកតញ្ញូនោះ ក៏ពុំបានអើពើកាន់យកពាក្យនោះទៀត ត្រឡប់បែរជាមានចិត្តប្រទុស្តតបដល់សេកនោះវិញ មិនត្រឹមតែប៉ុណ្ណោះ ក៏យកដំបងប្រហារវាយសម្លាប់គុណ្ឌលសេកនោះឲ្យក្សីណក្ស័យទៅ ហើយបង្កាត់ភ្លើងដុតឆ្អើរសេកនោះ លុះឆ្អិនហើយក៏ទំពាស៊ីអស់ទៅ ៗ

ការបំភ្លឺសេចក្តីថា កិរិយាដែលនៅប្រប៉ូកប្រប៉ល់ជាមួយបុគ្គលអសប្បុរសដូច្នេះនេះ ជាហេតុនាំមកនូវសេចក្តីទុក្ខលំបាកក្នុងលោកនេះ និងលោកខាងមុខដោយចំណែកមួយពិត ៗ ព្រោះហេតុដូច្នោះ បានជាព្រះគន្ថវេចនាចារ្យ លោកពោលជាបទព្រះគាថាទាំងឡាយដូចមានសេចក្តីថា :

នរជនជាអសប្បុរស ទោះបីសំឡាញ់របស់ខ្លួន ប្រកាសសំដែងប្រាប់ប្រយោជន៍ល្អ, ធ្វើឧបការគុណដល់ខ្លួនក្តី ទោះបីសំឡាញ់ពោលបំភ្លឺសេចក្តីពិសេសជាងនេះក្តី ក៏គង់ក្លែងបញ្ឆោតសំឡាប់ ហើយដុតនូវសរីរៈសំឡាញ់ខ្លួននោះ ចំអិនឲ្យឆ្អិនធ្វើជាអាហារបរិភោគជាមួយនឹង

វ៉ែកមានទឹកឃ្មុំ ទឹងទឹកដោះគោជាដើម ជាអំពើពុំប្រពៃវិញ ។

ឯនរជនជាអសប្បុរសនោះតែងទឹង ហើយប្រទុស្តដល់មិត្តវិញ បី ដូចជាសត្វអសិរពិសតែខឹងហើយ តែងចឹកទាំងសិរៈនៃបុគ្គលអ្នកចិញ្ចឹម នោះវិញដូច្នោះឯង ។ កិរិយាដែលសេពគប់សូម្បីតែមួយរំពេច ជាមួយ នរជនកាចអាក្រក់ជាអ្នកសាត់ព្រាត់ មានបាបលាមកថោកទាបជាមនុស្ស អកតញ្ញូយ៉ាងនេះ បុគ្គលមិនគប្បីសេពគប់យកជាមិត្តឡើយ ។ មួយវិញ ទៀត បុគ្គលជាអសប្បុរសតែងមានសេចក្តីក្រោធខឹងជាប់ជានិច្ច ព្រម ទាំងធ្វើនូវសេចក្តីវិនាសដល់មិត្តវិញដោយពិត ។

លុះជនជាអសប្បុរសបានទំពាស៊ីសាច់សេកនោះរួចហើយ ក៏ដើរ សំដៅទៅកាន់ដងព្រៃ កាលបានដល់កណ្តាលដងព្រៃនោះហើយ, ស្រាប់តែខ្លាធំបានឃើញមួយរំពេច ក៏ធ្វើនូវសំឡេងគ្រហឹមឲ្យលាន់ឮ ខ្ទាំង ស្ទុះលោតចូលមកប្រឈមទីងចាប់ខាំបុរសនោះក្នុងកាលនោះឯង ។ បុរសអកតញ្ញូនោះ បានឃើញខ្លាធំស្ទុះលោតចូលមកប្រឈមនឹងខាំខ្លួនហើយ ក៏ដល់នូវសេចក្តីភ័យតក់ស្លុតពន់ពេក ទើបនឹករលឹកដល់ពាក្យបណ្តាំរបស់ សេកឈ្មោះគុណ្ឌិលនោះ ហើយពោលពាក្យចំពោះខ្លាធំថា: បពិត្រអ្នក ម្ចាស់ដ៏ចំរើនអើយ ! ខ្ញុំនេះបាននាំពតិមានមកអំពីសំណាក់នៃគុណ្ឌិល សេកជាសំឡាញ់របស់អ្នកដែលនៅឯនាយនោះ ។

ឯសត្វខ្លាធំ លុះបានស្តាប់ពាក្យថាគុណ្ឌិលសេកផ្តាំមកដូច្នោះហើយ

ក៏មានចិត្តត្រេកអរពីកាយហៅបុរសនោះចូលមកថា ម្នាលសំឡាញ់មានធុរៈស្ទើបអ្នកមកចុះ ហើយនាំបុរសនោះចូលនៅកាន់ទីលំនៅរបស់ខ្លួនបានឲ្យអាហារចំណីដែលគួរបរិភោគដល់បុរសនោះ ឲ្យបរិភោគជាបដល់ឆ្អែតស្រេចហើយ ឲ្យអង្គុយនៅក្នុងសំណាក់នៃខ្លាចាស់ជាបារបស់ខ្លួនហើយចេញទៅកាន់ដងព្រៃទៀត ដើម្បីស្វែងរកអាហារដោយរហ័ស ។

កាលនោះ ខ្លាចាស់ជាបារបស់ខ្លាធំនោះ, កាលបើខ្លាធំជាកូនរបស់ខ្លួនបានចេញទៅស្វែងរកចំណីហើយ, ក៏និយាយបរាជាមួយនឹងបុរសនោះ ដោយសេចក្តីស្និទ្ធស្នាលស្មោះត្រង់ ហើយបានស្តាប់សម្តីសព្ទពាក្យបុរសនោះ ក៏បានដឹងច្បាស់ថា បុរសនេះសំឡាប់សេកឈ្មោះគុណ្ឌិលបំអិនធ្វើជាអាហារបរិភោគរួចហើយ ដោយរលឹកតាមពាក្យបុរសអកតញ្ញូនោះឯង ។

បន្ទាប់ពីនោះ ខ្លាធំត្រឡប់មកពីរកចំណីវិញ ខ្លាចាស់ជាបាបាននិយាយប្រាប់កូនថា ម្នាលកូនដ៏ពុកអើយ ! គុណ្ឌិលជាសំឡាញ់របស់អ្នកគឺបុរសនេះក៏សំឡាប់ទៅហើយ ។

ឯខ្លាធំជាកូនបានស្តាប់ពាក្យនៃបាប្រាប់ដូច្នោះហើយ ក៏មានចិត្តអាក់អន់ញាប់ញ័រខ្លួន នឹកអាណិតអាសូរដល់សំឡាញ់ខ្លួនពន់ពេក ក៏ស្ទុះចេញទៅកាន់ទីលំនៅនៃគុណ្ឌិលសេកជាសំឡាញ់ ដោយរហ័សរួស

កន់ហើយស្រែកហៅថា ម្នាលគុណ្ឌិលសំឡាញ់អើយ! សំឡាញ់ទៅណាទៅ? កាលបើស្រែកហៅពីរបីមាត់ពុំបានឮពាក្យឆ្លើយតបមកសោះ ក៏ដើរស្វែងរកគយគន់មើល បានឃើញស្លាបដែលបុរសនោះបោចចោលក្នុងទីនោះ ទើបចូលចិត្តដឹងច្បាស់ឥតមានសង្ស័យថា សំឡាញ់របស់អាត្មាអញត្រូវបុរសនេះសម្លាប់ដោយពិត, ហើយសោយសោកទ្រហោយំខ្សឹកខ្សួលបំរះនទៀល លុះក្រោកឡើងក៏រត់ត្រឡប់មកកាន់ទីលំនៅរបស់ខ្លួនវិញ ។

ចំណែកជនជាអសប្បុរស កាលបើខ្លាធំនោះបានចេញចាកពីទីនោះទៅហើយ ក៏លើកផែនថ្មយ៉ាងធំគប់ក្បាលខ្លាចាស់ប្រហារឲ្យក្បែណក្បែយទៅ ហើយគិតថា អញនឹងសម្លាប់ខ្លាធំនោះទៀតក្នុងពេលលំដាប់គ្នានេះឯង ។ ជនអសប្បុរសក៏នៅរង់ចាំមើលផ្លូវខ្លាធំនោះត្រឡប់មកវិញ, បានលាក់ខ្លួនពួននៅក្នុងទីកំបាំងមួយ ។

ខណៈនោះ ខ្លាធំក៏បានត្រឡប់មកដល់វិញក្នុងកាលនោះដែរ ។ ឯមនុស្សបាប លុះបានឃើញខ្លាធំមកដល់ហើយ ក៏ភិតភ័យតក់ស្លុតខ្លត់ដោយតេជៈអំណាចនៃខ្លា បែរជាស្ទុះរត់ទៅក្រាបសំពះលូនដោយទ្រូងទៀបបាទជើងនៃខ្លាធំហើយពោលថា: បពិត្រអ្នកជាម្ចាស់សូមអ្នកមេត្តាឲ្យជីវិតដល់ខ្ញុំផង ។

ចំណែកឯខ្លាធំក៏បានញុំាងសេចក្តីក្រោធខឹងឲ្យរម្ងាប់រលត់ទៅ ក្នុង

អំពើដែលបុរសបាបនោះបានធ្វើហើយ ពុំបានបងគំនុំគុំគួនឡើយ ដោយពិចារណាយល់ថា: អំពើដែលអាត្មាអញប្រុងនឹងប្រទុស្តដល់បុរសដែលបាននាំពាក្យបណ្ដាំរបស់សម្លាញ់មកឲ្យនេះពុំគួរសោះឡើយ, លុះខ្ញាជំគិតដូច្នេះហើយ ក៏សោយនូវសេចក្ដីក្រោធខឹងចេញមួយរំពេច ត្រឡប់ជាមានចិត្តករុណាលួងលោមបុរសបាបលាមកនោះ ពុំឲ្យមានសេចក្ដីភិតភ័យអ្វីឡើយ ហើយបញ្ជូនឲ្យទៅដោយស្រួលថា: ម្នាលសំឡាញ់មានធុរៈស្នើត្រូវអ្នកដើរចេញទៅដោយសុខសប្បាយចុះ ។

អំពើដែលបុគ្គលបានសេពគប់នឹងជនជាសប្បុរស រមែងនាំមកនូវសេចក្ដីសុខសប្បាយយ៉ាងនេះឯង ។

ព្រោះហេតុដូច្នោះ បានជាមានពុទ្ធភាសិតសំដែងដូច្នេះថា :

សព្ភិរេវ សមាសេថ   សព្ភិ កុព្វេថ សណ្ឋវំ
សព្វត្ត សណ្ឋាភេ សព្ភិ   សេយ្យោ ហោតិ ន បាបិយោ
សុចារយោ ទុក្ខានុគោ   សទា សព្ភិ សមាគមោ
តស្មា សប្បុរិសេហេវ   សង្គមោ ហោតុ ជន្តុនំ ។

អធិប្បាយថា: បុគ្គលត្រូវតែសេពគប់ជាមួយនឹងជនជាសប្បុរសទាំងឡាយដោយពិត, បុគ្គលត្រូវតែធ្វើនូវមិត្តសណ្ឋវៈរាប់អានរួបរួមជាមួយនឹងជនជាសប្បុរសទាំងឡាយ មិត្តសណ្ឋវៈដែលបុគ្គលប្រព្រឹត្តស្និទ្ធស្នាលយកជាមិត្តមួយអន្លើដោយជនជាសប្បុរសទាំងឡាយហើយ តែងបានល្អ

ប្រសើរដោយវិសេស ពុំបានលាមកអាក្រក់ក្នុងទីទាំងឡាយទាំងពួង, អំពើដែលបុគ្គលសេពគប់ជាមួយនឹងជនជាសប្បុរសសព្វ ៗ កាលនេះ អាចបន្ទោបង់នូវសេចក្ដីទុក្ខលំបាកបាន ហើយអាចប្រមូលនាំមកនូវសេចក្ដីសុខក្សេមក្សាន្តដោយបំណែកមួយ, ព្រោះហេតុដូច្នោះ នរជនទាំងឡាយត្រូវសេពគប់ជាមួយនឹងជនជាសប្បុរសដោយពិត ៗ លុះដល់មកក្នុងកាលជាខាងក្រោយ ខ្លាធំក៏បានធ្វើមរណកាលក្សិណក្ស័យជីវិតទៅ, ដោយអានុភាពផលានិសង្សនៃសេចក្ដីករុណាគុណនោះ ក៏បានឡើងទៅកើតក្នុងស្ថានសួគ៌ទេវលោកនាយ សោយទិព្វសម្បត្តិទាំង ១០ ប្រការ ជាសុខសួស្ដីនៅក្នុងប្រាសាទកែវទាំង ៧ ប្រការ សឹងបរិបូណ៌ទៅដោយស្រីទេពអប្សរជាច្រើនចោមរោមជាបរិវារក្នុងកាលនោះឯង ។

ព្រោះហេតុដូច្នោះ ព្រះអរហន្តទាំងឡាយ លោកពោលជាបទព្រះគាថាដូច្នេះថា :

ឯវំ វិជានិ ជន្តុសោ បរមំ សមាចរិ
ព្យគ្ឃោ ឧយាយុបគតោ សុគតឹ សុមេធោ
តស្មា ការេថ ការុណំ សុគតំ ជនានំ
តំ វេ ធនាតិ វិករញ្ញូ ករេសុ ភោគំ ។

អធិប្បាយថា: សូម្បីខ្លាធំកាចអាក្រក់មានប្រការយ៉ាងនេះ តែងខាំពាំនាំមកនូវសាច់នៃសត្វដទៃជាប្រក្រតី តែថាជាសត្វមានប្រាជ្ញាល្អអាច

ត្រឡប់ចិត្តទៅកាន់សេចក្តីករុណាធម៌វិញ, ហើយបានរួចចាកអបាយភូមិ
បានទៅកាន់សុគតិវិញ ព្រោះហេតុដូច្នោះ អ្នកទាំងឡាយត្រូវធ្វើនូវសេចក្តី
ករុណា តាមគន្លងនៃជនទាំងឡាយដែលជាសប្បុរសល្អចុះ, អំពើដែលប្រ
កបដោយករុណាធម៌នោះ នឹងមានអានិសង្សច្រើនអាចឲ្យនូវភោគសម្បត្តិ
ក្នុងកពជាន់ទាបជាន់ខ្ពស់ទាំងឡាយផង អាចឲ្យនូវសម្បត្តិព្រះនិព្វានឥត
មានកពដទៃប្រសើរជាងផង ដល់អ្នកទាំងឡាយដោយពិត ។

សំដែងរឿងនិទានសត្វខ្លាធំជាគំរប់ ៤ កង់វគ្គទីពីរក៏ចប់សេចក្តីជា
សង្ខេបតែប៉ុណ្ណោះឯង ។

(នៅមានត)

# លោក អ៊ុម-ភន បម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គិម-តូរ ពិនិត្យ

(តមក)

---

អសំវិហិតកម្មន្តំ ពាលំ ឧម្មន្តិ មន្តិនំ
សិរី ជហាតិ ទុម្មេធំ ជិណ្ណំវ ឧរគោ តចំ
ឯតម្បិ ទិស្វាន អហំ វទាមិ បញ្ញាវ
សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះមហារាជអើយ ! សូម្បីសិរីសម្បត្តិ ក៏សឹងតែលះបង់នូវអ្នកខ្លៅអប្បឥតប្រាជ្ញា ឥតជំរិះ បើរិះគិតធ្វើការ ឧបមាដូចពស់វែកលះបង់ចោលនូវសំណកចាស់នោះហោង; ហេតុនោះខ្ញុំយល់ថា អ្នកមានប្រាជ្ញានោះទើបប្រសើរ, ឯអ្នកកំឡៅគ្រាន់តែមានយសបរិវារនោះពុំប្រសើរឡើយ ។

លំដាប់នោះ; ស្តេចទ្រង់ព្រះសណ្តាប់ហើយ មានព្រះបន្ទូលទៅនឹងអាចារ្យសេនកៈថា ដូចម្តេចទៅ ? អាចារ្យសេនកៈគិតហើយទូលថា ធរ៎ បពិត្រមហារាជអើយ ! រីមហោសថនេះជាក្មេងតូចក្តាត់គាត់ដឹងអ្វី, ខ្ញុំនឹងធ្វើមិនឲ្យមហោសថឆ្លើយតបបានឡើយ , សូមទានអញ្ជើញស្តេចស្តាប់ខ្ញុំ , ទើបអាចារ្យសេនកៈសូត្រនូវគាថានេះថា :

បញ្ចុ បណ្ឌិតា មយំ ភទន្តេ
សព្វេ បញ្ជលិកា ឧបដ្ឋិតា តេ
ត្វំ នោ អភិភុយ្យ ឥស្សរោសិ
សក្កោវ ភូតប្បតិ ទេវរាជា
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោ និហីនោ សិរិមាវ សេយ្យោតិ ។

បពិត្រមហារាជមានសិរីសួស្តីប្រសើរអើយ ! រីយើងខ្ញុំផងទាំងឡាយជាអ្នកប្រាជ្ញទាំង ៥ នេះ សឹងបំរើធ្វើនមស្ការក្រាបថ្វាយបង្គំប្រណម្យព្រះអង្គជាអម្ចាស់នៃយើងខ្ញុំផងទាំងឡាយ ដូចព្រះឥន្ទ្រាធិរាជមានអំណាចអ្វីក៏មកនៅជាខ្ញុំបំរើអម្ចាស់នេះ តើដូច្នេះយល់ថាមហោសថមានប្រាជ្ញាប្រសើរ ឬអម្ចាស់មានសម្បត្តិជាឥស្សរនោះប្រសើរ, ខ្ញុំយល់ហេតុនោះហើយខ្ញុំថា អ្នកមានសម្បត្តិនោះប្រសើរ, ឯអ្នកមានតែប្រាជ្ញាថយលែងសម្បត្តិនោះពុំប្រសើរឡើយ ។

ហៃសប្បុរសផងទាំងឡាយអើយ! រីអាចារ្យសេនកៈនាំហេតុមកស្រដីដូច្នេះ បើវៀរលែងពោធិសត្វហើយ, ឯអ្នកដទៃទោះបីនឹងអាចឆ្លើយកាត់ទំលាយនូវពាក្យនោះបានឥតអង្គមានឡើយ; ស្តេចទ្រង់ព្រះសណ្តាប់ពាក្យអាចារ្យសេនកៈទូលនូវប្រការអម្បាលនោះហើយ ទ្រង់ព្រះចិន្តាថា អាចារ្យសេនកៈនាំនូវហេតុនេះ មកសំដែងដូច្នេះយល់ជាការគាប់ពិត ប៉ុន្តែគំនិត

មហោសថនឹងនាំនូវហេតុដទៃ មកស្រដីឲលាយកបនូវពាក្យនោះបាន ទើបស្តេចមានព្រះបន្ទូលទៅកាន់ពោធិសត្វថា បណ្ឌិត ហៃអ្នកប្រាជ្ញអើយ! បាននឹងឆ្លើយដូចម្ដេចវិញ? ពោធិសត្វស្ដាប់ហើយ ក៏ឆ្លើយរទៈលំលាយនូវពាក្យនោះបានដោយនូវអាថ៌កំបាំងដំណឹងការគ្នា ទូលព្រះមហាក្សត្រថា បពិត្រមហារាជអើយ! រីអាចារ្យសេនកៈនោះនឹងដឹងអ្វី គាត់រមិលមើលយល់តែយសឯង មិនទាន់ដឹងនូវប្រាជ្ញាវិសេសនៃខ្ញុំឡើយ, មហារាជអើយ! សូមទ្រង់ព្រះសណ្ដាប់ខ្ញុំនឹងឆ្លើយថ្វាយឲ្យប្រាកដ, ទើបពោធិសត្វសូត្រជាបទគាថា ដូច្នេះថា :

ទាសោវ បញ្ញស្ស យសស្សី ពាលោ
អត្ថេសុ ជាតេសុ តថាវិធេសុ
យំ បណ្ឌិតោ និបុណំ សំវិធេតិ
សម្មោហមាបជ្ជតិ តត្ថ ពាលោ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញោវ សេយ្យោ ន យសស្សី ពាលោតិ ។

បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ ! រីអាថ៌សេចក្ដីកើតមានដោយដំពូកដូច្នោះ ពោះអ្នកដ៏មានយសសម្បត្តិច្រើនប៉ុន្មានក្ដី បើខ្លៅហើយ សឹងទៅបំរើធ្វើដូចខ្ញុំនៃអ្នកដ៏មានប្រាជ្ញានោះហោង; រីអ្នកមានប្រាជ្ញា កាលណាបើត្រិះរិះរកណ្ដាប់នូវកិច្ចការសេចក្ដីឯណា សឹង

មានអាថ៌លាក់លៀមកំបាំងជ្រៅក្រៃ កម្រអ្នកដទៃនឹងអាចដឹងបានឡើយ ខ្ញុំយល់នូវហេតុនោះហើយ បានជាខ្ញុំសរសើរអ្នកមានប្រាជ្ញា, រីពាក្យអាចារ្យសេនកៈថា អ្នកមានសម្បត្តិប្រសើរ ហេតុអ្វីកាលអម្ចាស់ឲ្យគេអាថ៌ប្រស្នាផ្ទៃនឹងពពែនោះ ក៏គាត់មិនយកសម្បត្តិនោះទៅដោះសាប្រស្នា គាត់ធ្វើអាត្មានោះដូចជាខ្ញុំគេ ទៅសុំរៀនអាថ៌ប្រស្នាអំពីខ្ញុំ ហើយនាំអាថ៌ប្រស្នានោះមកឆ្លើយថ្វាយព្រះអង្គ ? ទើបគាត់បានគង់ខ្លួននៅទាំងម៉្លេះ ដូច្នេះយល់ថាអ្នកមានប្រាជ្ញាប្រសើរ ឬអ្នកកំឡៅមានសម្បត្តិប្រសើរ ? ។

ព្រះពោធិសត្វសំដែងហេតុនោះ ទូលព្រះមហាក្សត្រដោយនូវអានុភាពប្រាជ្ញា ឧបមាដូចអ្នកយកខ្សាច់មាសអំពីជើងភ្នំព្រះសុមេរុ លើកឡើងយល់ជាប្រាកដ ពុំនោះសោតដូចព្រះចន្ទពេញបូណ៌មី យល់ច្បាស់ឰដ៏កណ្ដាលពពកផ្កាយនោះហោង ។ ស្ដេចទ្រង់ព្រះសណ្ដាប់ពាក្យពោធិសត្វទូលដូច្នោះហើយ មានព្រះបន្ទូលទៅនឹងអាចារ្យសេនកៈថា ម្ដេចទៅអាចារ្យ ចូរសំដែងមកវិញទៀតហោង ។ អាចារ្យសេនកៈស្ដាប់ហើយពុំអាចនឹងឆ្លើយតបបានឡើយ ដូចគេមានស្រូវទុកក្នុងឃ្លាំងពេញហើយគេយកចេញខាតអស់ អង្គុយស្ងៀមទ្រមឹងឥតបើនឹងស្រដីតបទៅវិញទៀតបានឡើយ ។ បពិត្រអើយ ! អាចារ្យសេនកៈនោះ ទោះបីអាចនាំហេតុដទៃមកសំដែងនូវគាថាដល់មួយពាន់ក្ដី ក៏ពោធិសត្វកើតជាមហោសថនេះ ស្ដេចនឹងសម្រេចផ្ចាញ់គេដោយនូវព្រះប្រាជ្ញាវិសេសហោង ។

ព្រះពោធិសត្វសោតសរសើរនូវព្រះប្រាជ្ញាវិញទៀត ទើបសូត្រជាគាថាដូច្នេះថា :

អទ្ធាបិ បញ្ញាវ សតំ បសដ្ឋា
កន្តា សិរី ភោគរតា មនុស្សា
ញាណញ្ច ពុទ្ធានមតុល្យរូបំ
បញ្ញំ នាច្ចេតិ សិរិមា កទាចិ
ឯតម្បិ ទិស្វាន អហំ វទាមិ
បញ្ញាវ សេយ្យោ ន យសស្សីពាលោតិ ។

បពិត្រមហារាជអើយ ! អ្នកប្រាជ្ញានោះ គឺសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម សឹងសរសើរអ្នកនោះ, មនុស្សផងជាអ្នកកំឡៅ មានតែស័ក្តិយសរបស់ច្រើន ហើយរង្វើងស្រឡាញ់ភោគសម្បត្តិនោះ សឹងជាដំនៀលនៃអ្នកប្រាជ្ញផង ពុំដែលកន្ទង់អ្នកមានប្រាជ្ញានោះបានឡើយ; ខ្ញុំព្រះអង្គឃើញនូវហេតុនោះហើយ បានជាពោលថា អ្នកមានប្រាជ្ញានោះប្រសើរ, ឯអ្នកអន្ធពាល មានតែយសបរិវារនោះពុំប្រសើរឡើយ ។

ស្តេចទ្រង់ព្រះសណ្តាប់ពាក្យពោធិសត្វទូលនូវប្រការអម្បាលនោះ ហើយ មានព្រះទ័យនោះទ្រង់ព្រះអំណរអរនឹងបម្លើយប្រស្នា ស្តេចក៏បូជាព្រះមហាសត្វនូវទ្រព្យរតនាករ ដូចភ្លៀងបង្អុរចុះដ៏គ្រាស់ហើយ សូត្រជាគាថាដូច្នេះថា :

យន្តំ អបុច្ឆិម្ហា អកិត្តយីនោ
មហោសធំ កោវិលជម្ពុធស្សី
កវិសហស្សំ ឧសភញ្ច ជាតំ
អាជញ្ញយុត្តេ ច រថេ ទស ឥមេ
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ
ទទាមិ តេ គាមវរានិ សោឡសាតិ ។

មហោសធ ម្នាលបាមហោសធអើយ ! បាមានប្រាជ្ញាយល់អាថ៌ធម៌ទាំងពួងជាក់ច្បាស់ប្រាកដពេក, ឯយើងទាំងឡាយនេះ នឹងត្រិះរិះគិតនូវអាថ៌ប្រស្នាឯណាដូចចៅនោះពុំបានឡើយ, អញអរនឹងបាឆ្លើយដោះសារអាថ៌ប្រស្នា អញនឹងបូជាចៅនូវគោនោះមួយពាន់ សឹងឧសភពជប្រសើរ, នូវដំរី នូវរថទឹមដោយសេះអាជានេយ្យនោះដប់, នូវស្រុកប្រសើរនោះដប់ប្រាំមួយ, អញបូជាបាហោង ។ ស្ដេចមានព្រះបន្ទូលអម្បាលនោះហើយ ស្ដេចឲ្យអស់ទ្រព្យ នូវស្រុកទាំងនោះមកពោធិសត្វហោង ។

វីសតិនិបាតេ សិរិមេណ្ឌកបញ្ហោ និដ្ឋិតោ ។ រឿងស្រដីសិរិមេណ្ឌកបញ្ហា ប្រស្នាមានក្នុងវីសតិនិបាតមិញ ក៏ចប់នូវប្រការអម្បាលនេះឯងហោង ។

តតោ បដ្ឋាយ ពោធិសត្តស្ស យសោ មហា អហោសិ ។ តំ សព្វំ បញ្ញាបិ ឧទុម្ពរទេវី យេវ វិចារេសិ ។

រីនាងឧទុម្ពរទេវីពិចារណាគិតថា ចៅមហោសថ បានអាយុ ១៦ ឆ្នាំ ហើយ, រីយសសម្បត្តិចៅមហោសថប្អូនអញមានច្រើន គួរអញនឹងរកប្រពន្ធឲ្យចៅមហោសថ, នាងគិតនូវប្រការអម្បាលនោះហើយនាងទៅទូលព្រះបាទវិទេហរាជ ដោយនូវប្រស្នានោះ ហើយក៏ស្ដេចអនុញ្ញាតឲ្យថា ករេធ្ឋ ម្នាលនាងឧទុម្ពរទេវីជាអគ្គមហេសីសំឡាញ់អើយ! ចូរនាងរកចុះ, រីនាងឧទុម្ពរនាងដឹងជាស្ដេចអនុញ្ញាតឲ្យហើយ នាងទទួលយកព្រះបន្ទូលដោយនូវហេតុនោះ ហើយនាងលាព្រះមហាក្សត្រវិលមកហើយនាងថា ហៃចៅមហោសថអើយ! អញចង់រកក្មេងស្រីមួយមកឲ្យជាភរិយាបំរើបាហោង ៗ ពោធិសត្វឮហើយគិតថាបើព្រះនាងនឹងរកក្មេងស្រីនោះមកឲ្យជាភរិយាអញ មានកាលគាប់ចិត្តអញ មានកាលពុំគាប់ចិត្តអញ គួរអញទៅស្វែងរកដោយខ្លួនឯងវិញ គិតដូច្នោះហើយឆ្លើយថា បពិត្រព្រះនាងឧទុម្ពរបវរល័ក្ខណ៍អគ្គមហេសីទេពីក្សត្រថ្លៃជាអម្ចាស់ប្អូនអើយ! ប្អូននឹងទៅស្វែងរកដោយខ្លួនឯង, ប្អូននឹងលាអ្នកទៅបានពីរបីថ្ងៃ កុំអម្ចាស់មានព្រះបន្ទូលនឹងព្រះមហាក្សត្រឲ្យជ្រាបឡើយ, បើខ្ញុំទៅរកបានពេញចិត្តខ្ញុំហើយ ខ្ញុំនឹងនាំមកហោង កុំឲ្យព្រួយចិត្តអ្នកជាបងរកឲ្យខ្ញុំឡើយ ៗ រីនាងឧទុម្ពរទេវី នាងស្ដាប់ពាក្យចៅមហោសថដូច្នោះហើយ នាងមានព្រះបន្ទូលថា ហៃបាមហោសថអើយ! ចូរបាទៅរកចុះ ៗ ពោធិសត្វក៏ក្រាបលានាងឧទុម្ពរទៅផ្ទះអាត្មា

ប្រាប់អស់ពួកបរិវារទាំងឡាយឲ្យរៀបប្រដាប់ប្រដាអាត្មា ហើយគៀស ខ្លួនមិនឲ្យអ្នកដទៃស្គាល់បាន ហើយយកនីទៅនូវអស់ប្រការប៉ាក់ដុលនឹង បង្កើតឧបករណ៍នោះហោង, ចៅមហោសថ ក៏ដើរសើហនាទគតាតចេញ ទៅនាទ្វារឯជើងតែម្នាក់ឯងចូលទៅនាស្រុកឧត្តរយវមជ្ឈគ្រាមនោះហោងៗ

តទា បន តត្ថ ឯកំ បុរាណសេដ្ឋិកុលំ បរិជិណ្ណំ អហោសិ ។ បពិត្រអើយ! ក្នុងកាលនោះ មានត្រកូលសេដ្ឋីចាស់មួយនៅនាស្រុកឧត្តរយវមជ្ឈគ្រាមនោះ ក៏ថយសម្បត្តិជាអ្នកខ្សត់វិញហោង ។ ត្រកូលសេដ្ឋីនោះ មានកូនក្រមុំមួយឈ្មោះ អមរាទេវី ។ នាងនោះមានប្រាជ្ញាប្រកបនូវលក្ខណាទាំងពួង ឥតអ្នកឯណានឹងប្រាថ្នាយកជាភរិយាបានឡើយ ជាស្ត្រីមានបុណ្យច្រើន ។ មានកាលថ្ងៃមួយ, នាងក៏ភ្ញាក់ឡើងអំពីព្រឹក នាងចំអិនយាគូនឹងយកទៅជូនឪពុកនាហាលស្រែនាយនោះ នាងដើរចេញអំពីផ្ទះទៅដោយផ្លូវនោះហោង ។ ក្នុងកាលនោះ, ព្រះមហោសថអ្នកប្រាជ្ញ អាចពិតពិលរមិលមើលទៅយល់នូវនាងអមរាលីលាដើរមកអំពីចម្ងាយ ប្រកបនូវលក្ខណាទាំងក្នុងដូច្នោះហើយ ក៏ត្រិះរិះក្នុងព្រះហឫទ័យថា នេះស្រីមានលក្ខណា, ស្រីនេះ បើកុំទាន់មានប្តីគួរអញយកជាភរិយាឲ្យបំរើប្រចាំជើងដៃអញហោង ។ សាបិ តំ ទិស្វា ។ នាងអមរាទេវីលីលាដើរទៅដោយផ្លូវ ពិតពិលរមិលមើលទៅយល់ចៅមហោសថ

កំពុងដើរលើលាដោយទ្រូវផ្ទំចំពោះមុខដូច្នោះហើយ  នាងគិតជញ្ជឹងរំពឹងក្នុងចិត្តថា  បុរសនោះមានសុភាពបង្គួរដូច្នោះ  ទោះយោបីបើបានមកនៅក្នុងផ្ទះអញ ១ នឹងបំរើផ្គើចិត្ត ផ្គាប់ចិត្តអ្នកនោះបានហោង ។

លំដាប់នោះ,  ព្រះមហោសថគិតថា ស្រីនេះមានប្តីហើយក្តី ក៏គួរអញដណ្តឹងស្រីនេះលេងមើលហ៎ះ, ទោះបីបើនាងមានប្រាជ្ញាក្តី  ក៏អញអាចដឹងអាថ៌ប្រស្នាអំពីចម្ងាយឥឡូវនេះហោង,  ព្រះមហោសថគិតទូវប្រការអម្បាលនោះហើយ  ក៏ក្តាប់ដៃបង្ហាញទៅនាងអមរា,  នាងអមរាដឹងហើយថា អ្នកនេះដណ្តឹងអញហើយថា សុភាពមានប្តី ឬឥតប្តីនៅឡើយ? នាងគិតដូច្នោះហើយ  នាងឈរនៅហាននោះហើយនាងលាដៃបង្ហាញមកពោធិសត្វវិញហោង  ។  រីព្រះមហោសថអ្នកប្រាជ្ញអាចដឹងជានាងនេះចេះដោះសាអាថ៌ប្រស្នានោះហើយ  ក៏ដើរចូលទៅទៀបហើយដណ្តឹងថា  ភទ្ទេ  ម្នាលនាងស្រីក្រមុំព្រហ្មចារីអើយ ! នាងដើរមកនាងឈ្មោះអ្វីនាងចូរស្រដីប្រាប់បង  ដ្បិតបងចង់ដឹងស្គាល់នាងហ៎ះ ? ។  រីនាងអមរាក្តាហើយឆ្លើយថា  សាមិ  ម្នាលអ្នកអើយ ! រីឈ្មោះអញខ្ញុំឯណា  ក្នុងកាលជាអតីត  នឹងអនាគតក្តី  ក្នុងកាលបច្ចុប្បន្នឥឡូវនេះក្តី  ឥតអង្គមានឡើយ,  រីអំពើនោះគេយកមកជាឈ្មោះនៃអញខ្ញុំដូច្នេះណាអ្នកអើយ ! ។ ព្រះមហោសថស្តាប់ពាក្យនាងអមរាហើយថា  ភទ្ទេ  ម្នាលនាងអើយ !

(នៅមានត)

## វប្បធម៌ខ្មែរ

# តន្ត្រីជាផ្នែកជាងនៃវប្បធម៌

លោក លី - ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

---

យើងបានដឹងមកហើយថា តន្ត្រីក៏ជាផែកធាងមួយយ៉ាងសំខាន់នៃវប្បធម៌របស់ជាតិនីមួយ ៗ ព្រោះតាំងពីដើមរៀងមក តន្ត្រីមិនត្រឹមតែជាគ្រឿងកែកំសាន្តតែម្យ៉ាងទេ គឺជាមេគំនិតមួយក្នុងផ្នែកសិល្បៈ ហើយដែលអ្នកប្រាជ្ញរមែងទុកជាមធ្យោបាយយ៉ាងប្រសើរ ក្នុងការលាតត្រដាងគំនិត, កាយវិការនឹងល្បិចឧបាយរបស់លោក ៗ ហេតុនេះហើយបានជានៅសម័យបច្ចុប្បន្ននេះ គេតែងលើកយកតន្ត្រីធ្វើជាមុខជាមាត់នៃប្រទេសក្នុងសម័យបាតុកម្មអន្តរជាតិធំ ១ ឬក្នុងការប្តូរផ្លាស់វប្បធម៌រវាងប្រទេសមួយនឹងប្រទេសមួយ ៗ បានសេចក្តីថា បើគេបានពិនិត្យពីតន្ត្រីរបស់ប្រទេសណាមួយឲ្យបានជាក់លាក់ គេនឹងបានស្គាល់ប្រាកដពីអារ្យធម៌ គឺទំនៀមទំលាប់ ការរស់នៅ ប្រពៃណីសេចក្តីជឿនលឿននឹងមនោគតិរបស់ប្រទេសនោះ ៗ

បើយើងពោលមកដូច្នេះ  យើងត្រូវងាកបែរមកមើលតន្ត្រីនៃប្រទេសយើងម្តង ៗ យើងឃើញតន្ត្រីខ្មែរមានកំណើតមកជាអង្វែងហើយ តាំងពីគ្រាដែលខ្មែរស្គាល់នាអារ្យធម៌ របស់ខ្លួនមកម្ល៉េះ ៗ  ឯការលូតលាស់នៃតន្ត្រីនេះ  តែងតែមានដំណើរប្រព្រឹត្តទៅមុខជាដរាប  ព្រោះដូចយើងពោលខាងលើហើយថា  តន្ត្រីមិនតែលូតលាស់ទៅតាមចង្វាក់នៃវប្បធម៌របស់មនុស្ស ៗ  រហូតមកដល់សព្វថ្ងៃ  តន្ត្រីខ្មែររឹតតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បរិបូណ៌ឡើងទៀត  សំរាប់ជួយបំពេញសេចក្តីត្រូវការនៃជនជាតិសម័យថ្មីនេះ  មានការប្រផ្ទាស់ជាមួយបរទេសជាដើម ៗ ប្រសិនណាជា  យើងឃើញតន្ត្រីយើងមានគោលចារឹក  មានលក្ខណៈសម្បត្តិសមសួនដូចនេះហើយ  តើយើងត្រូវមានភារៈក្នុងការរក្សាទុករៀបចំតន្ត្រីជាតិយ៉ាងណាទៀតទេ? យើងឆ្លើយចំពោះសំនួរនេះភ្លាមថា  យើងត្រូវមានភារៈប្រាកដណាស់  ក្នុងការរៀបចំថែរក្សាទុកកសាងតន្ត្រីនេះឲ្យមានសភាពទាន់កាលទាន់សម័យដូចអារ្យប្រទេសនានាដែរ ដ្បិតយើងទុកដាក់ជាស្រេចថា  តន្ត្រីជាមែកធាងដ៏សំខាន់នៃវប្បធម៌ជាតិ ៗ  ហេតុនេះ តន្ត្រីយើងក៏ត្រូវតែមានលក្ខណៈជាខ្មែរពិតប្រាកដដែរ  ទោះតន្ត្រីបែបបុរាណក្តី  បែបទំនើបក្តី ។ ឧទាហរណ៍ជាក់ស្តែង  គឺនៅគ្រាបច្ចុប្បន្ននេះ ដែលប្រទេសជាតិយើងកំពុងតែមានការចំរើនលូតលាស់  ទៅមុខជារៀងរាល់ថ្ងៃ ៗ  ពលរដ្ឋខ្មែរកំពុងតែប្ដូរដៃគ្នាកសាងប្រទេសជាតិមានការបំ

ពេញពលកម្មស្ថាបនាទំនប់ទឹក, លើកផ្លូវថ្នល់, មន្ទីរពេទ្យ, សាលារៀនជាដើម ពោលគឺជាសម័យកសាងប្រកបដោយកាយវិការរហ័សរហួនញាប់ដៃញាប់ជើងប្រុងប្រៀបស្មារតីម៉ឺងម៉ាត់គ្រប់ៗគ្នា ។ រីឯតន្ត្រីទំនើបដែលជាគ្រឿងកំដរបរិយាកាសបច្ចុប្បន្នក៏គួរតែមានសភាពរហ័សរហួន និងម៉ឺង-ម៉ាត់ដូចគ្នាដែរ ដើម្បីជាជំនួយជួយរុញច្រានកំឡាំងសាមគ្គីនិងកំឡាំងពលកម្មស្ថាបនាជាតិរបស់យើង ឲ្យរឹតតែលឿនទៅកាន់សេចក្តីចំរើនថែមឡើងទៀត ។ បានសេចក្តីថា ប្រសិនជាយើងរៀបចំទំនុកច្រៀងឬក្រងជាបទណាមួយ យើងគួរធ្វើបទនោះឬទំនុកនោះឲ្យប្រកបដោយចលនារស់រវើក ពោរពេញទៅដោយភាពស្វាហាប់ មានវិស័យដូចជាគ្រឿងដឹកនាំចិត្តអ្នកស្តាប់ឲ្យស្ទុះ ទៅក្នុងការបញ្ចេញកំឡាំងពលំ ដើម្បីស្ថាបនាជាតិឲ្យបានទៅជាប្រទេសអារ្យៈមួយ ពេញលេញសមសួនដូចរដ្ឋនានាក្នុងចំណោមរដ្ឋដែលចំរើនលូតលាស់ជាងគេ ៗ ត្រង់ចំណុចនេះ យើងឃើញដូចជាការពោលនេះឯងហួសនិស្ស័យបន្តិច ព្រោះថាគ្រាន់តែស័ព្ទសំនៀងតូរ្យតន្ត្រីសោះ ហេតុអ្វីក៏អាចទៅជាគ្រឿងជួយបំប៉នកំឡាំងការកសាងជាតិបាន? ប៉ុន្តែបើយើងរស់ឲ្យសព្វគ្រប់ទូទៅទំហំនៃតន្ត្រីយើងឆ្លើយថា ពុំមែនជាការហួសនិស្ស័យទេ ដ្បិតមនុស្សត្រូវការបញ្ញាស្មារតីឬមនោសញ្ចេតនាសំរាប់រុញជំរុល ការប្រតិបត្តិរបស់បុគ្គលនោះ ៗ ឲ្យទិតទំ ឲ្យឈ្នះឈ្នាតស្រាក់ស្រទេញចាប់ប្រកបកិច្ចការអចិន្ត្រៃយ៍ ៗ

យើងមើលចុះ អ្នកពុំសូវប្រកបដោយបញ្ញា ធ្វើការក៏ពុំសូវចំរើនដែរ ពោះបីប្រឹងខិតខំយ៉ាងណាក៏មិនឈ្នះអ្នកដែលមានបញ្ញាដែរ ។ ត្រង់នេះស្របនឹងពាក្យចំនៀមបុរាណរបស់ខ្មែរមួយ ឃ្លាថា "ចេះដប់មិនស្មើនឹងប្រសប់មួយ" ។ បានន័យ សូម្បីអ្នកចេះប្រាកដប្រជាយ៉ាងណា ហើយខំប្រឹងប្រើកំឡាំងខ្លួនយ៉ាងណា បើការងារដែលខ្លួនធ្វើនោះ ពុំបានយកប្រាជ្ញាមកប្រើជាមួយផងទេ, កិច្ចការនោះឯងពិតជាពុំបានសំរេចផលឆាប់រហ័សដូចអ្នកដែលចេះតែល្មម ៗ ហើយប្រើប្រាជ្ញាផ្សំផងនោះឡើយ ។ រីឯតន្ត្រីដូចយើងពោលខាងលើហើយថា ៖ — ជាប្រភពបំប៉នបញ្ញាស្មារតី ឬជាគ្រឿងពត់ហាត់នៃមនោសញ្ចេតនារបស់មនុស្ស ។ មនុស្សណាមួយក៏រមែងមានការជាប់ជំពាក់ចិត្តក្នុងតន្ត្រីដែរ ។ ឧបមាថា មនុស្សម្នាក់អួតខ្លួនថាគេពុំចេះស្រឡាញ់តន្ត្រីទេ ពុំចេះស្ដាប់ភ្លេងទេ ប៉ុន្តែបើយើងទៅលេងភ្លេងក្បែរអ្នកនោះ ហើយលេងបទណាមួយដែលពីរោះរមើល បើមិនអ្នកនោះដក់ចិត្តស្ដាប់មួយសន្ទុះទៅដែរ ប្រសិនជាដេញយើងឲ្យចេញឆ្ងាយពីគាត់ ក៏គង់តែមិនទាន់ដេញភ្លាមៗទេ ទុកចាំតែចប់មួយបទសិនដែរ ទើបដេញជាក្រោយ ។

បើសង្កេតតាមនេះ ឃើញថាមនុស្សរមែងត្រូវការចាំបាច់នឹងសិល្បៈតន្ត្រីសំរាប់ជាគ្រឿងបំប៉នបញ្ញាស្មារតី ឬពត់ហាត់មនោសញ្ចេតនាសិល្បៈតន្ត្រីសំរាប់ជាគ្រឿងបំប៉នបញ្ញាស្មារតី ឬ ពត់ហាត់មនោសញ្ចេតនារៀងៗ

ខ្លួន ៗ បើយល់ពិតដូច្នេះហើយ គប្បីតែ យើងយកសិល្បៈតន្ត្រីនេះធ្វើជាមធ្យោបាយពត់ហាត់សន្តានចិត្តជនរួមជាតិឲ្យបានរឿនរឿនតែម្តង ៗ ព្រោះបុរាណាចារ្យយើងពុំមែនភ្លេចគិតដល់រឿងនេះទេ មើលចុះ ភ្លេងខ្មែរបុរាណ មានបទលួងលោមចិត្តក្នុងការនឿយណាយ (បទសត្វមហោរី , បទបំពេ · បទផាត់ជាយ . . មានបទបន្ទុកអនុស្សាវរីយ៍របស់មាតុភូមិ (បទនគរជ, សុរិន្ទខ្មែរ, ត្រពាំងពាយ ..) ទាំងបទបង្ហាញពីចលនានៃអ្នកស្រុកក្នុងពេលប្រកបការងារ ( បទខ្មែរច្រូតស្រូវ-បោលចាប , អុំទូក ៗ បទទាំងនេះបើយើងយកមកសង្កេតឲ្យល្អិតល្អន់ម៉ត់ចត់គ្រប់ឃ្លាគ្រប់ពាក្យ យើងច្បាស់ជាឃើញជាក់ស្តែងអំពីកំឡាំងទឹកចិត្តរបស់បុព្វបុរសយើងដែលបង្កប់នៅក្នុងនោះ ។

ដោយមានលក្ខណៈច្រើនយ៉ាងដូចជាយើងស្រង់ខ្លះ ៗ មកពោលជាឧទាហរណ៍ខាងលើនេះហើយ បានជាយើងសន្មតបានថា " តន្ត្រីជាមែកធាងនៃវប្បធម៌ " ហើយដែលយើងពុំគប្បីភ្លេចទុកឲ្យនៅមានដំណើរយឺតជាងគេបានឡើយ ។

(នៅមានត)

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Solanacée | *n. f.* | ឆត្តាកុល |
| Ombelle | *n. f.* | ឧច្ចត្តបុស្ប |
| Convolvulacées | *n. f.* | សំវេលកូល |
| Borraginacées | *n. f.* | សោណ្ណកូល |
| Kutacées | *n. f.* | ពេឡុក្កល |
| Composées | *n. f.* | និម្មកូល |
| Roche | *n. f.* | ថ្ម |
| Roche primitive | | សិលាបុព្វជាតិ |
| Roche cristalline | | សិលាក្រាម |
| Roche éruptive | | សិលាឧទ្គម |
| Roche sédimentaire | | សិលាអវសាទ |
| Sédiment | *n. m.* | អវសាទ, កណ្តង |
| Sédimentation | *n. f.* | អវសាទកម្ម |
| Granit | *n. m.* | កណសិលា |
| Mica | *n. m.* | មីកា |
| Quartz | *n. m.* | ក្វាត្ស |
| Feldspath | *n. m.* | ហ្វេលស្ប៉ាថ |
| Porphyre | *n. m.* | ប្រភិរ្យសីកា |
| Avaries | *n. f.* | ការខូចខាត |
| Dégâts | *n. m.* | អន្តរាយ |
| Détérioration | *n. f.* | ការរិត |
| Lave | *n. f.* | ភូភល |

(នៅមានត)

# វចនានុក្រមសំស្រ្កឹត.ខ្មែរ

ព្រះមហា ប៉ាង - ខាត់ រៀបរៀង

(តមក)

អតិភូមិ ស្រ្តី ភូមិក្រៃលែង, ភូមិប្រសើរ, គោលចុងបំផុត ។

អតិភូមិ គមិ, ទៅកាន់ភូមិក្រៃលែង ។

អតិភូរិ គុ. ដែលច្រើនក្រៃពេក ។

អតិភូបិ៍ ធាតុ. ស្អិតស្អាងក្រៃលែង ។

អតិភ្របិ គុ. ដែលនាំទៅនូវភារៈក្រៃលែង ។

អតិភ្របិត គុ. ដែលមានភារៈធ្ងន់, ដែលធ្ងន់; ដែលពេញ

អតិភៃរវិ គុ. ដែលគួរខ្លាចក្រៃលែង ។

អតិភោជន ន បុំ ភោជនក្រៃលែង, ភោជនប្រសើរ ។

អតិមញ្ញុល គុ. ដែលទន់ភ្លន់ក្រៃលែង, ។

អតិមតិ គុ. ដែលមានមតិក្រៃលែង ។ អតិមតិមន្ត, គុ. ដែល

មានមតិក្រៃលែង ។

អតិមទ បុំ. សេចក្ដីស្រវឹងក្រៃលែង ។

អតិមធ្យ៉ទិន ន បុំ ថ្ងៃត្រង់ក្រៃលែង, ថ្ងៃត្រង់ជាក់ ។

អតិមនិ ធាតុ. ប្រមាថ, មើលងាយ ។

(នៅមានត)

ដើមកំណើតប្រាសាទអង្គរ

លោក ល្វីហ្វីណូត៍ រៀបរៀង

ក្រមការ ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ

លោក ញ៉ែម-ទឹម ពិនិត្យ

និងកែសម្រួលជាថ្មី

( តមក )

---

គេបានឃើញរូបលោកេស្វរ ១ ទៀតដូចជារូបមុននោះដែរ ប៉ុន្តែដោយរូបនោះស្ថិតនៅទីខ្ពស់ជាងមុននោះ គេក៏បានកាត់ព្រះកេសចេញនៅវេលាដែលគេម៉ាស់មេដំបូលខាងលើ ៗ គេឃើញមានរូបមនុស្សបាក់បែកមួយទៀត ប្រហែលជាព្រះពុទ្ធរូបទ្រង់នាគ រូបឈរជាច្រើនបាក់កំបុតហើយធ្លាក់ទៅជាលំអឺវិញ និងរូបព្រះឥន្ទ្រជិះដំរី ៗ តមកទៀតមានរូបរឿងព្រាហ្មណ៍ដំទង់ម្នាក់ គ្រវែញស្តេចទសរថស្លាប់ ប្រហែលជាធ្វើតាមរឿងសាមជាតក ៗ

ក្នុងបណ្តាខ្លោងទ្វារទាំងអស់ មានខ្លោងទ្វារមួយឆ្លាក់រឿងព្រះឥស្វរនៅលើដណ្តើរមុខ ខាងជើង ៗ ខ្លោងទ្វារនោះធ្វើជារូបព្រះឥស្វរ មានព្រះព្រហ្ម និងព្រះនារាយណ៍ លុតជង្គង់ប្រណម្យធ្វេងស្តាំ ព្រះឥស្វរឈរក្នុងប្រឡោះទ្វារ ដែលមានរនាំង ពីរជាន់ទំលាក់មកខាងក្រោយ ដៃស្តាំកាន់ផ្កា ដៃឆ្វេងកាន់បែបជាពាន ១ ៗ នៅមេទ្វារខាងលើ

គេឃើញមានរូបដីនចក់ ឬរូបក្រពើ ប្រដុំរូបទាំងអស់ហាក់ដូចទំនង ជាធ្វើជារឿងព៌វ មិនមែនជាធ្វើសំរាប់គោរពទេឡើយ លើកលែងតែខ្លោងទ្វារ ១ នេះ ខ្លោងទ្វារទាំងអស់ឯទៀតក្នុងថៃវជាន់ទី ២ នោះ សុទ្ធតែ ឬទុកជាខ្លោងទ្វារខាងពុទ្ធសាសនាទាំងអស់ ។

នៅលើមេដំបូល គេបានឃើញបំណែកព្រះពុទ្ធអង្គ ដែលបាក់បែកពត់កយជាច្រើន គឺស្ពានរណ្ដៅដែលបន្ទុបព្រះពុទ្ធរូបធ្វើជាកំពូល ។ គេវាយកំទេចព្រះពុទ្ធរូបចោលទាំងអស់ លើកតែរូបខ្លះដែលធ្វើជាកេងឥសី ។ មាននៅត្រង់កន្លែងសន្និបាត ១ តូចខាងទិសឦសាន, នោះ រូបទាំងឡាយគេបំផ្លាញកំទេចចេញទាំងអស់ ឯប្រាសាទតូច ១ ដែលជាប់បន្ទប់ខាងត្បូងប្រាសាទធំក៏ដូចគ្នាដែរ ។ ស្ពានដែលនៅសល់លើខ្លោងទ្វារខាងត្បូងនោះ ធ្វើឲ្យយើងសំគាល់បានថា ជាព្រះពុទ្ធរូប ១ អង្គទ្រង់ក្មេន នឹងរូបលោកេស្វរ ១ អង្គ ឈរនៅលើសសរទីងជញ្ជាំង ។ តពីកន្លែងមហាសន្និបាតទៅ រូបព្រះពុទ្ធទាំងឡាយដែលបានធ្លាក់ជាប់នៅនោះ គេបានដុសចេញ ប៉ុន្តែ នៅមើលឃើញច្បាស់ប្រាកដ ហើយនៅលើជញ្ជាំងកំពូលទៀត ក៏ឃើញមានព្រះពុទ្ធរូបជាច្រើន ដែលគេវាយបំបាក់ចេញ ឬធ្លាក់ទៅជាលិង្គវិញ ។

សួរថាចុះអ្វីខ្លះ ដែលជារបស់សម្រាប់សាសនាព្រះឥស្វរដ៏ពិតប្រាកដនៅក្នុងបន្ទាយបាយ័ននោះ? ឆ្លើយថា ខ្ញុំយល់ថាមានតែរបស់តែ

ប៉ុន្មានដូចមានខាងក្រោមនេះទេ គឺ ១ ជញ្ជាំងថែវខាងក្នុង ឯជញ្ជាំងថែវខាងក្រៅនោះគ្មានផ្ទាក់រូបអ្វីទេ, ២ អាស្រម ៣ ឬ ៤, មួយសម្រាប់វិស្ណុ ឬព្រះនារាយណ៍ ក្រៅពីនោះសម្រាប់សិវ ឬ ព្រះឥសូរទាំងអស់ ។ វត្តទាំងប៉ុន្មាននេះ ទំនងជាទើបនឹងសាងជាក្រោយប្រាសាទនោះគឺថាបាន ហើយសេចក្ដីដែលថាទើបសាងជាក្រោយនោះ ជាការពិតប្រាកដណាស់ ចំពោះអាស្រម ១ បណ្ដាអាស្រមទាំងប៉ុន្មាន ដែលខ្ញុំទើបនឹងដំរាបខាងលើនេះ ។ អាស្រមនេះស្ថិតនៅខាងក្នុងនឹងក្លៀសានវែនថ្នាក់ទី ២ ។ បើគេទៅឈរពីខាងមុខអាស្រមនេះ ដែលមានជើងក្អកណ្ដាលនៅពីខាងត្បូង ទឹងថែវដែលព័ទ្ធជុំវិញពីខាងស្ដាំ នោះគេនឹងឃើញខ្លោងទ្វារ ១ នៅពីខាងមុខចំកណ្ដាលជញ្ជាំង ២ ផ្ទាំង ។ ខ្លោងទ្វារនោះមានរូបសិវ គឺព្រះឥសូរ ឯជញ្ជាំងនៅទិសខាងកើតមានរូបលិង្គ ឯជញ្ជាំងនៅជ្រុងខាងលិចវិញនោះ គ្មានផ្ទាក់អ្វីសោះ ។ សួរថាតើដោយហេតុអ្វីបានជាយ៉ាងដូច្នេះ? ឆ្លើយថា ដោយហេតុជញ្ជាំងនេះបៀបនឹងប៉ះជល់ជើងក្អកណ្ដាល ហើយជាងផ្ទាក់គ្មានកន្លែងវាល នឹងលូកដៃដកផ្ទាក់ទៅផ្ទាក់បាន ជាភ័ស្ដុតាងបញ្ជាក់ឲ្យដឹងថា អាស្រមសម្រាប់សិវនេះទើបនឹងសាងជាក្រោយប្រាសាទនោះ នៅលើកន្លែងដែលមិនបានបម្រុងទុកនឹងសាងឡើយ ។

សេចក្ដីត្រង់នេះអាចកើតជាសំនួរថា បុះប្រាសាទសម្រាប់ព្រះឥសូរ

ស្តេចក៏ឲ្យមានលាយឡំរូបផ្សេង ៗ ខាងពុទ្ធសាសនា ដែលគេឃើញមាន នៅជុំវិញកន្លែងសន្និបាត ហើយនឹងរឿងក៏ដែរច្រើននៅជាប់នឹងជញ្ជាំង បន្ទប់សន្និបាតនោះផង? ឆ្លើយថា តាមគំនិតខ្ញុំ ការទាំងនេះនឹងយក ជាប្រមាណមិនបាន ខ្ញុំមិនមែនមិនដឹងទេថា នៅក្នុងស្រុកខ្មែរនេះ មាន សាសនាលាយឡំចូលគ្នា ដោយមានគុណៈដូចគ្នា ហើយដោយសេចក្តី អនុញ្ញាតអំពីម្ចាស់ផែនដីនឹងសេនាបតី ស្តេចយសោវរ្ម័ន បានសាង ប្រាសាទ ២ ប្រាសាទ ១ សម្រាប់សាសនាព្រាហ្មណ៍ ១ ទៀតសម្រាប់ ព្រះពុទ្ធសាសនា ។

ស្តេចកជេន្ទ្រវរ្ម័ន គ្រងរាជពីសកកាជ ៨៦៦ ទៅដល់ ៨៩០ ត្រូវ នឹងគ្រិស្តសកកាជ ៩៤៤ ដល់ ៩៦៨ ជាក្សត្រកាន់សាសនាព្រះឥសូរ ។ មានសេនាបតីម្នាក់ដែលកាន់ខាងព្រះពុទ្ធសាសនា បានសាងប្រាសាទ សម្រាប់សាសនាព្រាហ្មណ៍ ថ្វាយស្តេច នឹងសាងប្រាសាទសម្រាប់ ព្រះពុទ្ធសាសនាសម្រាប់ខ្លួនឯង ។ ចារឹកនៅប្រាសាទព្រះខ័ន បាន បញ្ចូលធម៌ព្រះឥសូរនឹងធម៌ព្រះពុទ្ធជាមួយគ្នា ។ ប៉ុន្តែយើងសំគាល់បាន ថា ការចូលគ្នានេះ គឺចូលគ្នាតែដោយសំដីមិនបានជាចូលដល់ទៅមេ វិហារជាមួយគ្នានោះទេ ។ ព្រះមហាក្សត្រិយ៍បានសាងទីសន្និបាតទាំង ឡាយ សម្រាប់ព្រះផ្សេង ១ មានសម្រាប់ព្រះពុទ្ធផង ឯសាសនាដែល នៅជិតគ្នា តែមិនមែនសត្រូវនឹងគ្នា មានការស្រមជាច្រើនផ្សេងពីគ្នា

នៅក្នុងវិហារជាមួយបាន ៗ ប៉ុន្តែ បើស្តេចកាន់សាសនាព្រះឥសូរ បានសាងប្រាសាទ ១ សម្រាប់លិង្គ ជាអ្នកទ្រទ្រង់នៅនគរ ហើយរៀប គុប់តែងទ្វាររូបព្រះពុទ្ធ និងរូបពោធិសត្វជុំវិញជាច្រើនទុកជារបស់គោរព ផងទៀត នោះឃើញថាជាការពិបាកនឹងគិតនឹងនាំឲ្យមានការសង្ស័យ ជាច្រើន ៗ

យើងសូមទុកសេចក្តីសង្ស័យនេះ មួយអន្លើសិន ហើយយើងបែរ មកពិចារណាសួរថា តើប្រាសាទបាយ័នមិនមែនសាងសម្រាប់ពុទ្ធសា-សនាជាមុន ៗ ទើបបានមកជាកន្លែង សម្រាប់សាសនាព្រះឥសូរ ទេ ឬអ្វី? ការត្រង់នេះយើងពិបាកនឹងឆ្លើយណាស់ ព្រោះហាក់ដូចជាឃ្លាតពី សេចក្តីដែលគេធ្លាប់ជឿ ៗ មក ៗ

ដូច្នេះ, យើងសូមបញ្ជាក់ ហើយពិចារណាយ៉ាងនេះថា ប្រសិន បើប្រាសាទកណ្តាលនៃទីក្រុងនោះ ជាប្រាសាទសម្រាប់ព្រះពុទ្ធសាសនា ហើយ តើទីក្រុងទាំងមូលនោះ កាន់ព្រះពុទ្ធសាសនាដែរឬទេ ៗ

បើឆ្លើយឲ្យត្រូវនឹងសំនួរនេះ គួរគប្បីពិចារណាដល់ទីឋានដែលមាន ជាប្រធាន នៅក្នុងក្រុងនោះ គឺទ្វារទាំងកំផែងជុំវិញ ១ សួរថាចុះតើទ្វារនោះ នឹងឲ្យយើងបានដឹងការយ៉ាងណាខ្លះ? ឆ្លើយថាខ្លោងទ្វារទាំងឡាយនោះ បាក់បែកអស់ទៅហើយ នៅសល់តែបំណែកមួយគង់នៅ ១ ត្រង់ទ្វារ ជ័យ ៗ បំណែកនោះឃើញជាកងចង្កេះឆ្លងនឹងក្បាលរូបមនុស្ស ៤ ឈរ

នៅកណ្ដាលរូបហោះឯទៀតជាច្រើន ៗ លុះធៀបរូបនេះទៅនឹងរូបឯទៀត ដែលមានភាពដូចគ្នា នាំឲ្យសំគាល់បានថា រូបនេះជារូបលោកេស្វរ ៗ

បន្ទប់ខាងលើនៃទីដែលហៅថា គោបុរនោះ មានខ្លោងទ្វារបន្តបន្ទាប់ រូបទាំងអស់ ឃើញមានសល់រូបខ្លះដែលគង់នៅ គឺសុទ្ធតែជាព្រះពុទ្ធរូបទ្រង់ក្អែន ៗ

ឥឡូវនេះបើយើងឡើងទៅលើបន្ទាយក្រៅ ហើយដើរជុំវិញមើល ទៅប្រាសាទជ្រុងទាំងបួន នោះយើងគ្មានសង្ស័យអ្វីសោះរូបលោកេស្វរ ធំ ៗ នឹងលេចឡើងដេរដាស នាំឲ្យយើងស្គាល់បានដោយងាយ ៗ

ឯសេចក្ដីយល់ឃើញនោះយ៉ាងដូច្នេះ គឺថាលោកេស្វរនោះជារូបទេវតា ដែលមានដៃជើងច្រើននៅអង្គរធំ ហើយអង្គរធំនេះ ដែលគេស្មានថាសាងសម្រាប់សាសនាសិវៈជាដំបូងមកនោះ កាលវេលាសាងនោះ គេសាងសម្រាប់ពុទ្ធសាសនាទេ ៗ

សេចក្ដីយល់ឃើញនេះ ខុសគ្នាយ៉ាងធំ នឹងគំនិតដែលធ្លាប់ជឿមក ហើយដែលយើងត្រូវតែរកសំអាងអំពីសេចក្ដីយល់ឃើញនេះ ដោយរករឿងប្រហែលគ្នាមកអធិប្បាយ គឺយើងបានដឹងថាមានប្រាសាទ ១ ផ្សេងទៀត មានបែបផែនប្រហែលនឹងអង្គរធំដែរ ដែលហៅថាប្រាសាទបន្ទាយឆ្មា ៗ

ប្រាសាទបន្ទាយឆ្មាស្ថិតនៅខាងជើងបំផុត នៃទីរួមខេត្តបាត់ដំបង

នៅលើដើមភ្នំដងរែក គឺជាប្រាសាទមួយ ដែលបាក់បែកខ្ទេចខ្ទាំជាងគេ ហើយទីក្រុងស្តេចប្រហែលជាផុតត្រឹមប្រាសាទនេះ ។ លោកគ្រោលីយេ បានពិនិត្យសព្វគ្រប់ទៅឃើញថា ប្រាសាទនេះប្រហែលពិតជារបស់ស្តេចជ័យវរ្ម័នទី ២ គឺប្រាសាទអមរេន្ទ្របុរៈដែលសាងក្នុងសករាជ ៨០០ ក្នុងពាក់កណ្តាលឆ្នាំ ៩០០ នៃគ្រិស្តសករាជ ។

បើយើងពិនិត្យបន្ទាយឆ្មារតាមទស្សនៈខាងសាសនា នោះយើងនឹងស្គាល់មួយរំពេចនៅពេលដែលគេឡើកទៅចំប្រាសាទ គឺដំបូលទាំងអស់មានបន្ទុបកំពូលថ្មហើយមានរចនារូបអមព្រះពុទ្ធពីសង្ខាង គឺរូបព្រះពុទ្ធទ្រង់ភ្នែកក្នុងក្បាំងដែលគេលកខ្ចង ។ នៅគ្រប់តែសសរទាំងអស់នោះមានរចនាជារូបស្រីទេពអប្សរ និងព្រះពុទ្ធរូបគ្រប់កន្លែង ។ គេបានឃើញនៅមេទ្វារខាងលើ រឿងរ៉ាវទាំងឡាយរបស់ព្រះពុទ្ធ មានរឿងត្រង់ព្រះអង្គចេញពីនគរទៅទ្រង់ផ្នួស ឬត្រង់គេគោរពព្រះពុទ្ធជាដើម ។ នៅជញ្ជាំងខាងលិច បែកខាងត្បូង នៅជញ្ជាំងថែវនោះ មានឆ្លាក់រូបលោកេស្វរ ៨ យ៉ាង, មានកំពស់ប្រហែល ២ ម៉ែត្រ ។

ក្រៅពីគេបានរកឃើញក្នុងប្រាសាទនោះ រូបពោធិសត្វមួយអង្គ នឹងព្រះពុទ្ធរូប ២ អង្គ ។

បញ្ចប់សេចក្តីទៅឃើញថា រូបទាំងប៉ុន្មានដែលមាននៅប្រាសាទនោះ ជារូបក្នុងព្រះពុទ្ធសាសនាទាំងអស់ លើកតែកន្លែងមួយចេញ គឺ

បន្ទប់ដែលមានក្រឡាខ្វែង ៤ ជ្រុង នៅខាងមាត់ទ្វារចូលទៅកំផែងខាងក្នុង ៗ ខ្លោងទ្វារមួយនៃបន្ទប់នោះមានឆ្លាក់ជារឿងព្រះឥសូរ គឺរូបព្រះឥសូរ ដែលមានពួកព្រាហ្មណ៍ជាអ្នកគោរព នឹងព្រះវិស្ណុ ៗ ឯខ្លោងទ្វារឯទៀតនោះមានរូបមិនប្រាកដ ៗ ប៉ុន្តែ វិមាននេះដែលគេឃើញមានក្នុងបំណោមប្រាសាទធំ ៗ ឯទៀតនោះ ហាក់ដូចជាមានភាពជាគេមិនរាប់អាន ហើយហាក់ដូចជាខុសពីប្រាសាទឯទៀត ដែលជាប្រាសាទកសាងឡើងសម្រាប់សាសនាដែរ ៗ

ម្យ៉ាងវិញទៀត ក្រៅពីរូបលោកេស្វរតាំង ៨ រូបចម្លាក់នៅលើថែវតាំងឡាយគ្មានឡើយ គឺមានតែរឿងចម្បាំងជាក្បួនហែ នឹងរឿងរាំរបស់ស្តេច ៗ គេឃើញមានរឿងព្រាហ្មណ៍អង្គុយគោរពលិង្គ ១ ដែរ ប៉ុន្តែ រឿងនេះគ្រាន់តែតុបតែងទៅជាគំនូរប៉ុណ្ណោះទេ នឹងយកជាការឲ្យដឹងថា អ្នកកសាងគោរពរូបនេះក៏ទេដែរ ៗ

ដូច្នេះក្នុងទីនេះ យើងឃើញរូបព្រះពុទ្ធតាំងអស់ ដែលមានសល់នៅឯអង្គរធំ នឹងរូបតាំងឡាយ ដែលពួកអ្នកគោរពរូបនៅអង្គរបានដំនឹងញញួរ គោះបោល នឹងធ្វើឲ្យខុសរូបរាងដើម ៗ ក្នុងក្រុងតាំងពីនេះ គេឃើញតែរូបលោកេស្វរទេ ដែលតាំងនៅក្នុងកន្លែងកិត្តិយស គឺរូបលោកេស្វរនេះលេចឡើងជាចៅហ្វាយនៃទីក្រុងនោះ ៗ អម្រេន្ទ្របុរៈនឹងយសោធរបុរៈជាទីក្រុងពីរមានភាពដូចគ្នា ហើយទីក្រុង ១ នៅមានទំនង

ជាទីក្រុងសម្រាប់ពុទ្ធសាសនា ឯទីក្រុង ១ ទៀតនោះបាត់ក័ស្តុតាងអស់ខ្លះទៅហើយ ។ សេចក្តីដែលថាដូចគ្នានេះមានយ៉ាងពិតប្រាកដ ដូចជាក្បាច់ចម្លាក់កំពូលមុខបួន ខឿនទេវរូបនាគ និងនៅខាងកើតទីក្រុងមានស្រះធំ ១ រាងបួនជ្រុង ឯផែនទីក៏គ្មានការប្លែកអ្វីឲ្យជាសំខាន់ដែរ គឺគ្រាន់តែប្លែកថា ក្រុងអង្គរធំនោះមានទំហំធំជាងបន្ទាយឆ្មា ២ ដង ហើយ ១ ទៀត ឯសីមានៃអង្គរធំនៅក្នុងកំផែងជុំវិញ ឯសីមានៃបន្ទាយឆ្មាវិញនោះ ស្ថិតនៅចន្លោះកំផែង និងដីទួលដែលលើកសម្រាប់ការពារក្រុងពីខាងក្រៅ ។ ក្រៅអំពីនេះ អង្គរធំជាប្រាសាទមានភាព ដូចគ្នាស្ទើនឹងបន្ទាយឆ្មា ជាក្រុងមួយយ៉ាងធំ យ៉ាងត្រឹមត្រូវតាមក្បួនខ្នាត ដែលបញ្ជាក់យ៉ាងពិតអំពីអាណាចក្រដ៏ធំទូលាយរបស់ម្ចាស់ផែនដី ទាំងអំពីរបៀបតាក់តែងនឹងរចនាក្រុង ប៉ុន្តែ របៀបកសាង របៀបតុបតែងទីក្រុងមានភាពមិនខុសគ្នាប៉ុន្មានអំពីបែបភាពទីក្រុងជាន់មុន ៗ ឡើយ ។ ប៉ុន្តែយើងត្រូវកត់សំគាល់មួយចំណែកទៀតថា មានការប្លែកបន្ទាប់បន្សំ ១ ទៀត តែការប្លែកនេះមិននាំឲ្យមានការប្រែប្រួលអ្វីទេ គឺថាបន្ទាយឆ្មាមានប្រាសាទតូច ១ ប្លែកណាស់ដែរ ឯអង្គរធំវិញ គ្មានប្រាសាទតូចនេះឡើយ ប៉ុន្តែប្រាសាទតូចនេះឃើញមាននៅក្នុងប្រាសាទធំៗ ជិតទីនោះ ដែលសាងក្នុងគ្រាជាមួយគ្នាៗ បានជាខ្ញុំនិយាយត្រង់កន្លែងនេះដោយពិស្តារបន្តិច ព្រោះសំណង់របៀបនេះជាសញ្ញាសំគាល់មួយដ៏សំខាន់ក្នុងពង្សាវតារ ហើយម្យ៉ាងទៀតព្រោះ

ខ្ញុំបន់ស្នើសេចក្ដីយល់ឃើញថ្មីមួយចំពោះរឿងប្រាសាទនេះ ។

ប្រាសាទតូច ៗ ទាំងនេះមានបណ្ដោយពី ១៤ ទៅ ១៥ ម៉ែត្រ សាងពីថ្មភក់និងថ្មបាយក្រៀមមានសភាពក្រាស់ធ្ងន់ៗ ។ ប្រាសាទនេះចែកជា ៣ ចំណែក ខាងកើត មានយ៉ នៅកណ្ដាលមានបន្ទប់វែង ១ និងខាងលិចមានប៉មមួយ សាងឲ្យខ្ពស់ដល់លោកស្មរដូចមានខ្លោងទ្វារជាសំអាងស្រាប់ ។ បន្ទប់វែងនោះមានពិតាន ១ សំគាល់ឃើញពីខាងក្រៅទូរដំបូលកណ្ដាល ១ និងថែវសង្ខាង ២ ឯពីខាងក្នុង គេសំគាល់ឃើញមានស្នាមខ្ពស់ទាបហាក់ដូចជាគេបានបំបាត់សសរ ២ ជួរចោល ហើយរំលប់ជ្រុងចេញ ។ គួរកត់សំគាល់ថា លើកតែត្រង់កន្លែងព្រះបាទពិធូចេញ-បន្ទប់នេះទទួលពន្លឺតែពីទិសខាងត្បូង ឯជញ្ជាំងខាងជើងនឹងសូន្យឈឹង ហើយគ្រាន់តែមានធ្វើបែបជាបង្អួចបញ្ឆោតប៉ុណ្ណោះ ។

សព្វថ្ងៃនេះ គេបានរកឃើញប្រាសាទដូច្នេះ ១៥ គឺប្រាសាទព្រះខ័នទាំងពីរ តាព្រហ្ម បឹងមាលានិងបន្ទាយឆ្មា ឯប្រាសាទឯទៀតនោះ ស្ថិតនៅតាមបណ្ដោយផ្លូវធំ ២ នៃស្រុកខ្មែរចាស់ គឺជាផ្លូវដែលចេញពីអង្គរធំទាំង ២ ហើយ ១ ឆ្ពោះទៅខាងកើតគឺទៅព្រះខ័ន ១ ទៀតឆ្ពោះទៅទិសពាយ័ព្យតម្រង់ទៅភិមៃ ។

តាមធម្មតា ប្រាសាទទាំងនេះសង់នៅឆ្ងាយពីគ្នាចំនួនពី ១៥ ទៅ ២០ គីឡូម៉ែត្រ ហើយស្ថិតនៅពីខាងជើងផ្លូវជាដរាប ជាការបញ្ជាក់ឲ្យដឹងថា

ប្រាសាទទាំងនេះទទួលពន្លឺតែពីទិសខាងត្បូង ។ គេសាងប្រាសាទទាំងនេះតាមការប្រែប្រួលនៃផ្លូវ ទុកសម្រាប់អ្នកដំណើរ ។ គេមិនអាចពោលថា ប្រាសាទនេះមិនមែនកសាងសម្រាប់អ្នកដំណើរទេ ហើយបើសិនជាគេគិតថា ប្រាសាទទាំងនេះសាងសម្រាប់លោកេស្វរ ហើយពោធិ-សត្វនេះជួនកាលមាននាមថា លោកេស្វរនៃមន្ទីរពេទ្យ (អារោគ្យសាលី) នោះគេនឹងយល់ថាប្រាសាទដែលសាងកាយតាមផ្លូវធំ ។ នោះជា មន្ទីរព្យាបាលរោគ គឺអារោគ្យសាលា សម្រាប់បូជនីយស្ថានដែលធ្វើដំណើរទៅកាន់ប្រាសាទដ៏ល្បី ៗ ឈ្មោះ ប្រហែលជាទៅកាន់ប្រាសាទនៃលោកដ៏មានឥទ្ធិឫទ្ធិអាចកំចាត់បង់នូវទុក្ខបាន ។ បើប្រសិនជាប្រាសាទទាំងនោះសាងសម្រាប់ឧបត្ថម្ភមនុស្សជម្ងឺមែន ។ នោះគេគ្មានសង្ស័យអ្វីឡើយដែលឃើញប្រាសាទទាំងនេះនៅក្នុងកំពង់ក្រៅឆ្ងាយអំពីទីប្រជុំ ព្រោះកុំឲ្យសៅហ្មងដល់សេចក្ដីបរិសុទ្ធ ។

ទោះជាយ៉ាងណាក៏ដោយ ដោយយើងមានការលំបាក នឹងរកពាក្យហៅប្រាសាទទាំងនោះឲ្យរំប្រាកដ ហើយដោយប្រាសាទនោះមានឈ្មោះផ្សេង ៗ ឯពាក្យដែលគេធ្លាប់ហៅថាប្រាសាទគុរុទំពជ័យ ៗ នោះហាក់ដូចជាមិនមែនជាឈ្មោះពិតប្រាកដរបស់ប្រាសាទនោះឡើយ ដូច្នេះយើងសូមសន្មតកំណត់ហៅប្រាសាទនេះថា អារោគ្យសាលាវិញ, ប៉ុន្តែ បើថ្ងៃក្រោយគេរកស្ដាំងឃើញពិតប្រាកដ អំពីឈ្មោះនៃប្រាសាទទាំងនោះយើង

នឹងយកឈ្មោះជាក្រោយមកជំនួសវិញដូច្នេះ បន្ទាយឆ្មាមាន អរោគ្យ-សាលា ១ ឯអន្តរធំគ្មានទេ ព្រោះប្រាសាទដ៏តូចដូច្នេះ មិនសមនឹងសេចក្តីត្រូវការនៃទីក្រុងដ៏ធំឡើយ ។ ប៉ុន្តែ គេឃើញមានអរោគ្យសាលានេះក្នុងប្រាសាទផ្សេង ៗ ជិតទីនោះ គឺនៅប្រាសាទតាព្រហ្ម ប្រាសាទព្រះខ័ននឹងក្នុងប្រាសាទមួយទៀតនៅជាប់ពីគេទៅក្នុងព្រៃខាងជើងក្រុង គឺប្រាសាទផ្ទូ ៗ តាមការសង្កេតទូទៅគេអាចសំគាល់បានថា ប្រាសាទបន្ទាប់បន្សំនេះជាលក្ខណៈពិសេសមួយនៃប្រាសាទទាំងឡាយ ដែលកសាងក្នុងជំនាន់ដែលយើងអាចហៅថា ជំនាន់សិល្បៈបាយ័ន ហើយប្រាសាទនេះនឹងត្រូវគេរើពិនិត្យជាខាងក្រោយទៀត នៅវេលាដែលគេនឹងពិនិត្យរឿងក៏ដែលទាក់ទងនឹងប្រាសាទដែលសាងក្រោយ ១ ដូចប្រាសាទព្រះខ័នខាងកើតនឹងបឹងមាលា ។

(នៅមានត)

# កណ្ឌទី ៤៥

ឧកញ៉ាវិបុលរាជសេនា គូ-កឹង ប្រែរៀបរៀង

( តមក )

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ |
| អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងបេះឧបាយកលចំណាន |
| ទាំងមានសន្តានស្នេហាជាតិ ។ |

## សាមកុកខ្សែ ៤៥

តាំងពីទៀវឡុងចាប់ទៀវហួនបាន ឡៅកីរប្រើទៀវហ៊ុយទៅវាយស្រុកប៉ីឡេងបានហើយ ក្លួនអ៊ូទទួលយកអាសាទៅវាយស្រុកទៀងសាបែកបានហាងតុង ដឹងអ៊ុយគៀនស៊ុនក្លួនប្បាំង នឹងទៀវលៀវឡៀវគឺស្លាប់ ឡេហ៊ួសុកទៅវាយយកស្រុកកេងជីវពីឡៀវពី ខុងបេង ។

ខុងបេងសួរថា ហេតុម្តេចបានចងទៀវហាមទុកដូច្នេះ ទៀវហាមក៏អធិប្បាយសេចក្តីឲ្យខុងបេងស្តាប់គ្រប់ប្រការ ខុងបេងឮដូច្នោះក៏ឲ្យស្រាយចំណងទៀវហាមចេញ ហើយនិយាយនឹងជូឡុងថា ទៀវហាមរាប់អានអ្នកដោយស្មោះត្រង់ បានជាលើកបងថ្លៃឲ្យជាភរិយាអ្នក នោះក៏ឃើញថា ជាការគាប់ប្រសើរ ហេតុអ្វីអ្នកត្រឡប់ទៅខឹងសម្បារនឹងគេវិញ ជូឡុងថា ទៀវហាមនឹងខ្ញុំបានរាប់អានគ្នាដោយបាននាំរឿងការឃើញថា

សែស្រឡាយជាមួយគ្នា គួរប្ដូរទៀវហាមមកលើកបង់ថ្លៃឲ្យខ្ញុំបាទនោះ មិនគួរសោះ ព្រោះនាងនោះជាស្រីមេម៉ាយ នឹងបង្ខំឲ្យគេមានប្ដីក៏ខុសទៅ ប្រការមួយខ្ញុំបាទ ក៏នៅមិនទាន់ទុកចិត្ត ព្រោះទៀវហាមនឹងខ្ញុំបាទទើបតែនឹងស្គាល់គ្នា ខ្លាចនឹងប្រើជាកលឧបាយយ៉ាងណាក៏មិនដឹង ឯការដែលលោកប្រើមកជាមុខក៏នឹងខូចទៅ ប្រការមួយ ឡៅតីជាចៅហ្វាយនាយកំពុងព្រួយចិត្តនឹងរិះគិតធ្វើការអ្វី ៗ ពុំទាន់ឃើញមុខបាទយ៉ាងណា ប្រាថ្នានឹងទំនុកបំរុងដែនដីក៏ពុំទាន់សម្រេច ឡៅតីទៅដេកធ្មេចភ្នែកមិនជិតជាប្រក្រតី ដែលខ្ញុំបាទនឹងមកយកស្រីជាភរិយានោះ ឃើញថាមិនគួរសោះប្រៀបដូចជាឆ្អិនមុនដណ្ដាំ មនុស្សទាំងពួងក៏ចាំគរហានិន្ទា ៗ

ឡៅតីឮដូច្នោះក៏និយាយនឹងដូឡុងថា ការក្នុងស្រុកហ៊ុយអៀងក៏សម្រេចហើយ យើងនឹងរៀបចំឲ្យបានគ្នាជាភរិយាស្វាមីតាមពាក្យទៀវហាមទៅចុះ ដូឡុងថា ដែលលោកនឹងឲ្យខ្ញុំបាទយកស្រីមេម៉ាយនោះមិនគួរ ព្រោះគ្រីស្រីក្រមុំពេញផែនដី ប្រការមួយ ខ្លួនលោកក៏តាំងទីមិនទាន់ប្រាកដនៅឡើយ នឹងប្រញាប់ទៅយកភរិយានោះ ខ្ញុំបាទមិនព្រមទេ ឡៅតីឮដូច្នោះ ក៏សរសើរដូឡុងថា ជាមនុស្សមានសេចក្ដីសត្យកតញ្ញូណាស់ ទើបយកមាសប្រាក់ឲ្យជាបំណាច់រង្វាន់ដូឡុងជាច្រើន ទើបយកត្រាសម្រាប់ការនោះប្រគល់ឲ្យទៀវហាមធ្វើជាចៅហ្វាយស្រុកដូចដែល ៗ

ទៀវហ៊ុយឃើញដូច្នោះ ក៏និយាយនឹងខុងបេងថា ដូឡុងបានយក

អាសាមានសេចក្ដីគាប់ប្រសើរហើយ ឥឡូវខ្ញុំបាទនឹងសុំទាហាន ៣ ពាន់ លើកទៅវាយយកស្រុកប៉ីឡេង ចាប់យកខ្លួនកិមសួនមកជូនលោក នឹងបានជាសេចក្ដីគាប់ប្រសើរខ្លះផង ខុងបេងក៏និយាយនឹងទៀវហ៊ុយថា កាលដូឡេង ទទួលយកអាសាមកធ្វើការនេះ បានសរសេរសំបុត្រសញ្ញាទុកឲ្យយើង ចុះខ្លួនទៅវាយស្រុកប៉ីឡេងគ្រានេះ មានតែត្រូវសរសេរសំ-បុត្រសញ្ញាទុកឲ្យយើងសិន ទើបបានទៀវហ៊ុយក៏តាំងសរសេរសំបុត្រសញ្ញាទុកឲ្យខុងបេងថា ខ្ញុំបាទនឹងសុំយកអាសាទៅវាយស្រុកប៉ីឡេងចាប់ខ្លួនកិមសួនឲ្យបាន បើមិនបានដូចសញ្ញានេះទេ ក៏ឲ្យកាត់ក្បាលខ្ញុំបាទវិញចុះ ហើយទៀវហ៊ុយក៏លាខុងបេងនាំទាហាន ៣ ពាន់ ស្រូតលើកទៅដល់ស្រុកប៉ីឡេង ទើបឲ្យតាំងបន្ទាយមាំមួនខាងក្រៅស្រុក ។

ឯកិមសួនចៅហ្វាយស្រុកដឹងថា ទៀវហ៊ុយលើកទ័ពមក ក៏រៀបបំរុងសេនាទាហានទុកព្រម ដើម្បីនឹងលើកចេញមកច្បាំង ខុងជីទប្រឹក្សាក៏និយាយនឹងកិមសួនថា ដែលលោកនឹងលើកចេញទៅតស៊ូនឹងទៀវហ៊ុយនោះមិនគួរ ព្រោះឡៅពីជាពូជព្រះកដវង្សព្រះចៅហៀនតេ ហើយមានជម្រះប្រាជ្ញាតាំងចិត្តក៏ល្អសុភាពនឹងអាណាប្រជានុរាស្ត្រទាំងពួង ឯទៀវហ៊ុយដែលជាប្អូនឡៅពីលើកទ័ពមកគ្រានេះ ក៏ជាមនុស្សមានកំឡាំងខ្លាំងពូកែណាស់ មុខជាយើងតស៊ូមិនបាន សូមឲ្យលោកចេញទៅចំណុះចុះចូលនឹងទៀវហ៊ុយតែម្ដងទៅចុះ ទើបបានសេចក្ដីសុខតទៅ ។

កិមសួនពុដូហ្វោះក៏ខឹងណាស់ ឆ្លើយតបទៅខុងជីថា ខ្លួននេះគិតជាគលសឹកឬ? បានជានិយាយពូលទៅទាន់ទៀវហ៊ុយ ជាផ្លូវគោតញញើតដូច្នេះ ហើយក៏បង្គាប់ទាហានឲ្យយកខ្លួនខុងជីទៅសម្លាប់ ទីប្រឹក្សានិងទាហានទាំងពួងក៏និយាយយល់ទាស់ថា ការដែលនឹងធ្វើសឹកសង្គ្រាមជាធំលោកមិនរំពឹងគិត មកទាស់ចិត្តដោយពាក្យទីប្រឹក្សាជំពប់បណ្ដោយមិនគួរទេ សុំឲ្យលោកលើកទោសម្ដងទៅចុះ កិមសួនពុដូហ្វោះក៏រសាយកំហឹង ឲ្យលើកខុងជី ហើយកិមសួនក៏រៀបចាត់ចែងសេនាទាហានលើកចេញទៅចម្ងាយផ្លូវពីស្រុកប្រហែល ២០០ សិន (៨ គ.ម.) ប្រទាំងនឹងកងទ័ពទៀវហ៊ុយ ទៀវហ៊ុយលើកមកក៏បញ្ឈប់ទាហាន ទៀវហ៊ុយជិះសេះកាន់លំពែងចេញមកឈរនៅមុខទ័ព ហើយស្រែកសួរថា នរណាចេញមកតស៊ូនឹងយើង កិមសួនពុដូហ្វោះក៏ងាកទៅសួរទាហានទាំងអស់ថា នរណាទទួលយកអាសាចេញទៅតស៊ូនឹងទៀវហ៊ុយគ្រានេះបាន ទាហានទាំងអស់ក៏ស្ញើបខ្លាចថ្វីដៃទៀវហ៊ុយ នៅស្ងៀមទាំងអស់គ្នា កិមសួនឃើញទាហានទាំងអស់ស្ងៀមដូច្នោះ ក៏បរសេះចេញទៅតយុទ្ធនឹងទៀវហ៊ុយ ទៀវហ៊ុយឃើញកិមសួនចេញមក ក៏ស្រែកគំហកដោយសំឡេងខ្លាំង កិមសួនស្ញាំងកាំងភ័យតក់ស្លុត ក៏បំបោលសេះរេរត់ថយមកក្រោយចូលទៅក្នុងស្រុកវិញ ទៀវហ៊ុយក៏លើកទាហានដេញជិតជាប់ទៅដល់កំផែង ខុងជីនិងទាហានដែលនៅក្នុងស្រុកនោះ ក្រឡេកឃើញកិមសួនបែកទ័ពត្រឡប់រត់ពីទៀវហ៊ុយមក

ជិតដល់ទ្វារក៏ម្នីម្នាយកធ្នូមកបាញ់ចម្រុះចេញទៅ គិមសួនភ័យណាស់ ក្រឡេកទៅឃើញខុនជីឈរពីលើសេះ ស្រែកថា យើងបាននិយាយហាមឃាត់អ្នកឯងៗ មិនព្រមស្តាប់យើងតាំងពីដំបូង ត្រឡប់គេរៀងគិតសម្លាប់យើងវិញ ឥឡូវពួកអ្នកស្រុក ក៏ស្ម័គ្រចិត្តទៅនៅនឹងឡៅពីទាំងអស់គ្នា ហើយ ខុនជីក៏យកធ្នូបាញ់ទៅត្រូវមុខគិមសួនធ្លាក់ពីលើសេះ ទាហានទាំងអស់ឃើញដូច្នោះ ក៏បង់បានសេចក្តីគាប់ប្រសើរនាំគ្នាស្ទុះទៅប្រហារជីវិតកាត់ក្បាលគិមសួនយកទៅជូនទៀវហ៊ុយ ។

ខណៈនោះខុនជីក៏ឲ្យបើកទ្វារស្រុក នាំទាហានទៅគំនាប់ទៀវហ៊ុយៗ មានអំណរណាស់ នាំខ្លួនខុនជីទៅជួបឡៅពីខុនបេងឯស្រុកហ៊ុយអៀង ហើយស្ងើរសេចក្តីគាប់ប្រសើរខុនជីជាច្រើន ឡៅពី, ខុនបេងក៏សោមនស្សណាស់នាំគ្នាលើកកងទ័ពត្រឡប់ទៅស្រុកប៊ុឡេង ហើយឡៅពីក៏ប្រគល់ត្រាសម្រាប់ការឲ្យខុនជីធ្វើចៅហ្វាយស្រុក ឡៅពីខុនបេងក៏ប្រើទាហានកាន់សំបុត្រទៅឲ្យគួនអ៊ូឯស្រុកកេងជីវ ក្នុងសំបុត្រនោះសេចក្តីថា យើងលើកទ័ពទៅវាយបានស្រុកឡេងឡេង, ដូឡេងលើកទៅវាយយកស្រុកហ៊ុយអៀងបាន, ទៀវហ៊ុយ លើកទៅវាយយកស្រុកប៊ុឡេងបានទៀត ខ្លួនយើងនឹងសេនាទាហានទាំងអស់គ្នា ក៏សុខសប្បាយគ្មានអន្តរាយដោយហេតុអ្វីទេ ។

គួនអ៊ូដឹងក្នុងសំបុត្រដូច្នោះ ក៏ធ្វើសំបុត្រតបទៅឡៅពីវិញ សេចក្តី

ថាខ្ញុំបាទគួនអ៊ី សូមគំនាប់មកដល់អ្នកជាបងបានជ្រាប ព្រោះខ្ញុំបាទដឹងថាអ្នកជាបងបានសេចក្ដីសុខសប្បាយនោះ ខ្ញុំបាទត្រេកអរណាស់, ឯស្រុកហ៊ុយអៀង ស្រុកប៊ុឡេងនោះ ដូឡេងនឹងទៀវហ៊ុយ ទៅវាយបានអស់ហើយ នៅសល់តែស្រុកទៀងសា ១ មិនទាន់បំណុះចុះចូលនៅឡើយ ខ្ញុំបាទជាអ្នកមានសតិបញ្ញានឹងកំឡាំងតិច សុំទទួលយកអាសា ទៅវាយយកស្រុកនោះឲ្យបាន ទាហានក៏នាំសំបុត្រទៅដល់ឡៅតឺៗ ទទួលមើលដឹងសេចក្ដីមានអំណរណាស់ ទើបប្រើទៀវហ៊ុយៈទៅនៅឈររក្សាស្រុកគេងដីវ ហើយឲ្យប្រាប់គួនអ៊ីស្រួតទៅជួបនឹងឡៅតឺឯស្រុកប៊ុឡេង ។

លុះគួនអ៊ីទៅដល់ ខុងបេងក៏កែងនិយាយថា កាលដូឡេងនឹងទៀវ-ហ៊ុយលើកទ័ពទៅវាយបានស្រុកហ៊ុយអៀងនឹងស្រុកឡេងនោះ ក៏យកទាហានទៅតែម្នាក់ ៣ ពាន់ ឯស្រុកទៀងសានោះ ពីដើមជាស្រុកបំណុះស្រុកគេងដីវ ឡៅពៀវឲ្យឡៅកួនជាក្មួយទៅធ្វើចៅហ្វាយស្រុក ដល់ឡៅពៀវស្លាប់ទៅ ស្រុកទៀងសាក៏ទៅឡើងស្រុកហ៊ូតោវិញ ចូធូតាំងឲ្យហ័នហៀនជាធំឈររក្សាស្រុកនោះ ហ័នហៀននោះ ជាមនុស្សល្ងង់អប្បឥតប្រាជ្ញា នឹងធ្វើការអ្វីមិនពិគ្រោះពិចារណា មានតែគំរាមគំហែងបណ្ដារាស្ត្រឲ្យបានសេចក្ដីក្ដៅក្រហាយ រាស្ត្រទាំងឡាយប្រែចិត្តឥតគោរពខ្លាចស្រឡាញ់ តែវេលានេះ នៅបារម្ភតែទាហានឯកម្នាក់ឈ្មោះហាងតុង ពួកស្រុកឡាំអៀងអាយុប្រហែល ៦០ ឆ្នាំហើយ មានកំឡាំងខ្លាំងពូ

កែណាស់តែដើមជាទាហានឡៅកួន ។ ចេញពីភដការទៅ ហង់តុងក៏ស្នើគ្នាទៅនៅធ្វើការនឹងហ័នហៀន ដែលអ្នកនឹងលើកទ័ពទៅយកស្រុកទៀនសាគ្រានេះ ត្រូវតែយកទាហានទៅឲ្យច្រើនទើបបាន ព្រោះហង់តុងខ្លាំងពូកែណាស់ ។

គួនអ៊ូឮដូច្នោះ ក៏គិតមានះក្នុងចិត្តថា ខ្ញុំបាទនឹងខាចអ៊ីជីដៃហង់តុងនោះព្រោះជាមនុស្សចាស់ទៅហើយ ខ្ញុំបាទសុំយកតែទាហានស្ម័គ្របក្ខពួកខ្ញុំបាទ ៥០០ លើកទៅជ័យយកស្រុកទៀនសា កាត់យកក្បាលហ័នហៀននឹងហង់តុងមកជូនលោកឲ្យបាន ឡៅពីក៏និយាយនឹងគួនអ៊ូថា ប្អូនឯងកុំអាលមើលងាយប្រមាថហង់តុងដូច្នោះ ទោះបីគេចាស់ក៏មែន តែមានកំឡាំងខ្លាំងពូកែណាស់ ដែលប្អូននឹងយកទាហានទៅតែ ៥០០ នោះបងនៅមិនទាន់ទុកចិត្តសោះ ក្រែងចួសការនឹងគេទេដឹង ។

គួនអ៊ូឮដូច្នោះ ក៏មិនសុំយកទាហានថែមទៀត កុំឲ្យខុសនឹងពាក្យដែលថារួចហើយ គួនអ៊ូក៏លាខុងបេងនឹងឡៅពីលើកទាហាន ៥០០ ចេញទៅ លុះគួនអ៊ូទៅខុងបេងក៏និយាយនឹងឡៅពីថា គួនអ៊ូលើកពលទៅគ្រានេះ ឃើញថាមើលងាយប្រមាថហង់តុងណាស់ ខ្លាចក្រែងចួសការត្រូវយើងលើកទាហានជាជំនួយជូនទៅទៀត ឡៅពីយល់ព្រមផងក៏រៀបចាត់ចែងទាហានលើកចេញទៅតាមគួនអ៊ូជាមួយនឹងខុងបេង ។

ឯហ័នហៀនចៅហ្វាយស្រុកទៀងសា លុះដឹងថាគួនអ៊ូលើកទ័ពមក ក៏ប្រឹក្សានឹងហាងតុងថា អ្នកនឹងជួយរិះគិតការពារប្រការម្តេច ហាងតុងឆ្លើយថា លោកកុំព្រួយអ្វីឡើយ នឹងខ្លាចអ្វីដៃគួនអ៊ូប៉ុណ្ណោះ ទោះបីគួនអ៊ូលើកទាហានមកប៉ុន្មានពាន់ ក៏នឹងស្លាប់ដោយគ្រឿងកៅទ័ណ្ឌនឹងដាវដងខ្ញុំមិនខាន អៀវឡេងនាយទាហាន ក៏និយាយនឹងហ័នហៀនថា ដែលនឹងចេញតស៊ូនឹងគួនអ៊ូនោះ មិនត្រូវឲ្យក្តៅរំជួលទៅដល់ហាងតុងជាធំឡើយ សូម្បីតែត្រឹមខ្លួនខ្ញុំបាទក៏នឹងអាចចេញទៅចាប់ខ្លួនគួនអ៊ូឲ្យបាន ហ័នហៀនឮដូច្នោះក៏អរណាស់ប្រគល់ទាហាន ១ ពាន់ឲ្យអៀវឡេង ៗ ក៏លើកទាហានចេញពីស្រុកទៅ ចម្ងាយផ្លូវប្រហែល ៥០០ សិន (២០គ ម) ទទួលគួនអ៊ូលើកទ័ពមកប្រទះគ្នា អៀវឡេងក៏ញាក់សេះស្ទុះទៅមុខទាហាន គួនអ៊ូឃើញដូច្នោះ ក៏បំផាយសេះដេញចូលទៅប្រយុទ្ធគ្នានឹងអៀវឡេងបាន ៣ ក្លេង គួនអ៊ូក៏យកដាវកាប់ត្រូវអៀវឡេងធ្លាក់ពីលើសេះស្លាប់ ហើយក៏ដេញកាប់សម្លាប់ទាហានអៀវឡេងទៅទល់នឹងជើងកំផែង ហ័នហៀនឃើញដូច្នោះ ក៏តក់ស្លុតរន្ធត់ចិត្តទើបឲ្យហាងតុងលើកទាហាន ៥០០ ចេញទៅប្រយុទ្ធគ្នានឹងគួនអ៊ូ ៗ ឃើញហាងតុងជិះសេះលើកទាហានចេញមកក៏ស្រែកសួរថា អ្នកនេះឬឈ្មោះហាងតុង ៗ ឆ្លើយថា អ្នកស្គាល់ឈ្មោះយើងហើយ ហេតុម្តេចមកសួរធ្វើអ្វីទៀត អ្នកមិនខ្លាចសេចក្តីស្លាប់ឬទេ ? គួនអ៊ូតបថា យើងលើកទ័ពមកប្រាថ្នានឹងយកក្បាលអ្នកឯង

ហង់តុងចិនណាស់ញាក់សេះប្លូលប្រយុទ្ធនឹងគួនអ៊ូបាន ១០០ ក្បួន នៅមិនទាន់ចាញ់ឈ្នះ ហ័នហៀនក៏ឈរមើលលើសេនបន្ទាយ ហើយឃើញហង់តុងច្បាំងនឹងគួនអ៊ូយូរណាស់ គិតខ្លាចថា ហង់តុងដកកំឡាំងតបក្រែងចុះការនឹងគួនអ៊ូ ក៏ឲ្យវាយឃ្មោះហៅហង់តុងឲ្យនាំទាហានត្រឡប់ចូលក្នុងផ្ទះវិញ ។

ឯគួនអ៊ូលើកទាហានត្រឡប់ចូលបន្ទាយ ហើយគិតថា វេលាថ្ងៃនេះយើងច្បាំងនឹងហង់តុងដល់ ១០០ ក្បួនហើយ ក៏នៅមិនទាន់ចាញ់ឈ្នះគ្នា វេលាព្រឹកស្អែកយើងនឹងប្រើកលឧបាយបញ្ឆោតហង់តុងយកជ័យជំនះឲ្យខាងតែបាន លុះវេលាព្រឹកឡើង គួនអ៊ូក៏លើកទាហានចូលទៅជើងកំផែងហើយស្រែកហៅហង់តុង ហ័នហៀនឮដូច្នោះក៏ឲ្យហង់-តុង លើកទាហានចូលទៅដល់ជើងកំផែង ហើយស្រែកហៅហង់តុង ហ័នហៀន ៗ ឮដូច្នោះក៏ឲ្យហង់តុង លើកទាហានចេញទៅច្បាំងនឹងគួនអ៊ូបាន៥០ក្បួនគួនអ៊ូក្បួនធ្វើជាចាញ់ទាញសេះរត់ទៅក្រោយ ហង់តុងក៏ដេញបណ្ដោយតាមទៅសេះនោះក៏ភ្លាត់ជើង ហង់តុងក៏ធ្លាក់ពីលើខ្នងសេះដួលសន្ធប់អាវុធក៏ ប្អូតផុតពីដៃ គួនអ៊ូក្រឡេកមក ឃើញលើកដាវឡើងនឹងកាប់ក៏ត្រឡប់ចិត្តគិតឃើញថា យើងបានចេញពាក្យថាទុក បើនរណាគ្មានអាវុធនៅដៃ មិនត្រូវធ្វើឲ្យអន្តរាយ ឥឡូវហង់តុងដួលសន្ធប់ចុះជ្រុះអាវុធអស់ពីដៃ បើនឹងសម្លាប់ឲ្យខ្ញុំយកក៏មិនគួរ គួនអ៊ូក៏និយាយនឹងហង់តុងថា

គ្រានេះយើងទុកអាយុឲ្យអ្នក ៗ ចូរត្រឡប់វិលទៅស្រុកវិញចុះ យកសេះឯទៀតចេញមកតស៊ូនឹងយើងទៀត ។

ហង្សតុងត្រូវដូច្នោះក៏ក្រោកឡើងជិះសេះ នាំទាហានចូលទៅក្នុងស្រុកវិញ ហ័នហៀនក៏សួរហង្សតុងថា ហេតុម្ដេចបានជាអ្នកធ្លាក់ពីលើសេះ!? ហង្សតុងថាសេះនេះមិនធ្លាប់ជិះចេញច្បាំងមកយូរហើយ បានជាភ្លាត់ជើងឲ្យធ្លាក់ដូច្នេះ ហ័នហៀនក៏ថា អ្នកធ្លាប់មានថ្វីដៃខ្លាំងពូកែ បើជាបាញ់នឹងធ្នូវិញក៏គ្មាននរណាស្មើបាន ហេតុម្ដេចអ្នកមិនយកធ្នូបាញ់គួនអ៊ូ ហង្សតុងថា ក្នុងថ្ងៃនេះច្បាំងជាប់ដៃគ្នាផាំងពបមក បើនឹងវិលមកយកធ្នូក៏មិនទាន់ការ ពេលព្រឹកស្អែកខ្ញុំនឹងធ្វើជាចាញ់ ឲ្យគួនអ៊ូដេញមកដល់ជើងកំផែងស្រុក ហើយនឹងយកធ្នូបាញ់គួនអ៊ូឲ្យបាន ។

ហ័នហៀនក៏យកសេះដែលជិះនោះឲ្យហង្សតុង ៗ ក៏ត្រឡប់ទៅកាន់ទីគេហស្ថាន ទើបរិះគិតថា ក្ដីល្បីគេនិយាយថា គួនអ៊ូនេះមានសេចក្ដីស័ត្យពិតត្រង់ ឃើញច្បាស់ប្រាកដមែន គឺគួនអ៊ូទុកអាយុជីវិតយើង មានគុណដល់យើងខ្លាំងណាស់ ពេលព្រឹកស្អែកបើយើងនឹងយកធ្នូបាញ់សម្លាប់គួនអ៊ូវិញក៏ពុំគួរ តែបើយើងមិនបាញ់ ហ័នហៀនក៏នឹងយកទោសយើង ហង្សតុងគិតវិតក្កដូច្នេះទើសក្ដីដេកមិនលក់ លុះព្រឹកឡើងមានទាហានចូលមកប្រាប់ថា គួនអ៊ូជិះសេះមកបញ្ជូរចាំច្បាំងនឹងលោកនៅជិតជើងកំផែង ហង្សតុងត្រូវដូច្នោះក៏ឡើងសេះនាំទាហានចេញពីក្នុងស្រុកទៅ ។

ឯគួនអ៊ូក៏គិតមើលងាយប្រមាថ ប៉ងនឹងយកជ័យជំនះឲ្យបាន លុះឃើញហាង់តុងលើកទាហានចេញមក ក៏បរសេះចូលទៅច្បាំងនឹងហាង់តុងបាន ៣០ ក្លែងហាង់តុងធ្វើជាចាញ់ទាញសេះរត់ទៅក្រោយ គួនអ៊ូក៏បំផាយសេះបណ្ដោយតាមហាង់តុងទៅ ហាង់តុងក្រឡេកមើលមកក្រោយក៏យកដងធ្នូដំឡើងខ្សែ តែមិនបានយកព្រួញបាញ់ ១ តែទទេដល់ ២ ដង គួនអ៊ូចាំរង់ក៏មិនឃើញព្រួញទៅដល់តែតែមានចិត្តកំរើបខ្លាំងឡើងទៀត ទើបបំផាយសេះទៅដល់ទឹមស្មាគ្នា ហាង់តុងរត់ទៅដល់ជើងកំផែងឃើញគួនអ៊ូជិតចូលមក ក៏យកខ្សែដំឡើងធ្នូដាក់ព្រួញបាញ់ជម្រង់តែរំកាយមួកគួនអ៊ូ ១ ក៏ភ័យស្លុតក៏ត្រឡប់សេះវិលមកបន្ទាយវិញ ហាង់តុងក៏ចូលទៅក្នុងស្រុក គួនអ៊ូក៏គិតថា ឮល្បីគេនិយាយថា ហាង់តុងប៉ិនប្រសប់បាញ់ធ្នូណាស់ ក៏ឃើញមែនប្រាកដ វេលាថ្ងៃនេះប្រហែលហាង់តុងគិតដល់គុណយើង ដែលយើងទុកអាយុជីវិតមិនសម្លាប់ បានជាបាញ់ធ្នូឲ្យត្រូវតែរំកាយ កយើង ។

(នៅមានត)

# រឿងមនុស្សពិតប្រែប្រួល

## ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ រៀបរៀង

(តមក)

---

ពេលនោះ ជារដូវប្រាំងកំពុងសហោះ មិនដែលមានភ្លៀងរលឹមទេ ប៉ុន្តែ ដោយសារកំណាចព្រះរាជកុមារព្រះជន្ម ១៦ ឆ្នាំ បានជួបនឹងស្រីក្រមុំអាយុ ១៦ ឆ្នាំ ស្អុះតែជោគជ័យមិនធ្លាប់ស្គាល់កាមរសជួបគ្នា ក៏បណ្តាលហេតុជាអស្ចារ្យយ៉ាងក្រៃលែង ក្តៅក្រហាយដល់វេលាហកទៅ-គា(១) បង្អុរភ្លៀងរលាយយ៉ាងធំ កើតជាមេឃមីរងងឹតអ័ព្ទផ្សែងចាក់ក្នុកមិនយល់ ផ្គររន្ទះលាន់ឮគ្រាំគ្រេងសម្លេងខ្ទរខ្ទារបណ្តើររណ្តំញាប់រន្ទាន់ ខ្យល់ព្យុះសង្ឃរាបោកបក់បាក់មែកព្រឹក្សាជ្រុះស្លឹកផ្លែផ្កាផាសពាសពេញផ្ទៃពេញស្រុកភូមិ សត្វបក្សាផងទាំងពួងកំពុងតែដេកលក់ក្នុងទ្រនំ ស្រាប់តែភ្ញាក់ផ្អើលភិតភ័យស្រែក កកកាកព្រួយាំងអឺងកងលើមែករុក្ខា ហើយធ្វើខ្សែទៅមករកគ្នីគ្នា ។ ឯពួកមនុស្សម្នាក្នុងដំណើរដើរផ្លូវនាំគ្នាតេជ្រកពួនអស់ព្រោះខ្លាចទទឹកភ្លៀង ៈ ចំណែកពួកភក្តី ១ អ្នកនៅចាំការពារព្រះរាជកុមារគង់ព្រាហ្មទេះនោះ ភិតភ័យស្រឡាំងកាំង ធ្វើក្អកស្ទើរគប់គ្នាតែបួលដេកក្នុងដំណោកភ្លៀងខ្លួន ។ ស្រីក្រមុំនាក់ដែលជួនគាំនាងទៅនោះក៏ស្មុះឃើញអាត្មដឹងព្រះរាជកុមារចូលទៅក្នុងបន្ទប់តែពីរនាក់ផ្ទាត់ បិទទ្វារ

---

(១) [illegible] រលាយហុកទេវតា។

ជិតឃើញមិនចេញមកវិញដូច្នោះ ក៏នាំគ្នាចុះពីប្រាសាទដើរយ៉ាងលឿនទៅផ្ទះពល់ខ្លួន ៗ ភ្លៀងចាប់ផ្ដាក់តាំងពីពេលជិតពាក់កណ្ដាលអធ្រាត្ររហូតដល់ភ្លឺច្បាស់ព្រះអាទិត្យរះទើបរាំងជ្រះស្រឡះ ៗ

លុះព្រឹកព្រាងស្វាងព្រះសុរិយា ព្រះអធិត្តកន្ទកុមារ បានស្គាល់តាមរសជាក់លាក់លែងសន្ទិះសង្ស័យ ទ្រង់បើកទ្វារបន្ទប់យាងចេញមកខាងក្រៅ ត្រាស់បណ្ដេញប្រុស ៗ អ្នកគាល់បំរើឲ្យចុះចេញពីប្រាសាទអស់ លែងឲ្យមានប្រុសនៅជាមួយដល់ម្នាក់ ឲ្យសុទ្ធតែពួកស្រី ៗ ទៅនៅគាល់បំរើវិញ កើតព្រះទ័យប្រែប្រចណ្ឌនាងនាងយ៉ាងខ្លាំង មិនឲ្យនាងចេញក្រៅប្រាសាទសោះ ហាមប្រាមពួកប្រុស ៗ មិនឲ្យអ្នកណាចូលទៅជិតនាងនាងឡើយ ដោយព្រះទ័យប្រតិព័ទ្ធស្នេហាស្រឡាញ់នាងនាងជ្រុលពេក ទាល់តែកាន់ដាវជាប់នឹងព្រះហស្ដចេញទៅឈរកណ្ដាលថ្នល់មុខប្រាសាទ ចាំដេញកាប់ប្រុស ៗ ដែលដើរមកតាមផ្លូវនោះដោយមិនបានដឹងរឿងរ៉ាវនោះសោះ ៗ ពួកប្រុស ៗ ខ្លាចរអាគ្រប់គ្នា ខ្សឹបខ្សៀវប្រាប់គ្នីគ្នាត ៗ ទៅមិនឲ្យដើរតាមផ្លូវកាត់មុខប្រាសាទព្រះរាជកុមារឡើយ ៗ

ដំណឹងនេះលេចឮខ្ទរសាយភាយទូទៅពេញទាំងព្រះនគរ ជ្រួតជ្រាបរហូតដល់ព្រះបាទព្រហ្មទត្តជាព្រះវររាជបិតា ៗ ព្រះមហាក្សត្រិយ៍ទ្រង់ស្ដុតព្រះរាជហទ័យ គ្រវីព្រះសិរលាន់ព្រះឧស្ឋថា យីអើ ! បុត្តកុមារនេះចំឡែកណាស់តើ កាលនៅក្មេងតាំងពីកើតមកភ្លាមស្អប់ស្រីណាស់ មិន

ព្រមឲ្យស្រីបីតពាល់ត្រូវសាច់ខ្លួនទេ គ្រាន់តែឃើញរូបស្រីឬ ឮសំឡេងស្រីក៏មិនបានដែរ ចេះតែស្រែកយំលួងមិនស្ងៀមសោះ ដោយហោចទៅសូម្បីមាយបង្កើតរបស់ខ្លួនក៏កាន់បីមិនបានផង ឥឡូវនេះបែរជាប្រែផ្លាស់ចិត្តលែងស្អប់ស្រីហើយ ស្រឡាញ់ស្រីយ៉ាងខ្លាំងទៅវិញ ទាល់តែបណ្ដេញប្រុសៗ ចេញអស់លែងឲ្យមានប្រុសម្នាក់នៅជាមួយ សូម្បីគ្រាន់តែប្រុសណាដើរកាត់មុខប្រាសាទក៏មិនបាន កាន់ដាវឈរនៅកណ្ដាលផ្លូវចាំដេញកាប់ប្រុស ៗ ដែលគេដើរទៅតាមផ្លូវនោះ បើកូននេះវិបលាសចិត្តវង្វេងឈ្លក់នឹងស្រីដល់ម្លឹងហើយ តើអញនឹងឲ្យសោយរាជ្យដូចម្ដេចកើត ត្រូវតែបណ្ដេញវាឲ្យចេញផុតពីនគរទៅ កុំឲ្យវាធ្វើបាបប្រុសៗផងកុំឲ្យខ្មាសគេផង ទ្រង់ព្រះចិន្ដាដូច្នេះហើយក៏ត្រាស់ប្រើរាជបុរសឲ្យទៅបណ្ដេញព្រះរាជកុមារចេញ ។

ឯព្រះរាជកុមារមិនហ៊ានរឹងទទឹងព្រះរាជឱង្ការ នាំនាងនាដចុះចេញពីប្រាសាទយាងសំដៅឆ្ពោះទៅឯព្រៃហិមពាន្ត សង់អាស្រមនៅក្បែរឆ្នេរស្ទឹងគង្គាជិតមាត់សមុទ្រ នៅជាគេហយកសទាំងពីរនាក់ មិនបានបួសជាតេងតាបសឬសីទេ ។ ព្រះរាជកុមារមិនឲ្យនាងនាដចេញដើរទៅទីឯណាឆ្ងាយពីអាស្រមសោះ ឲ្យនៅស្ងួតណ្ដាំតែក្នុងអាស្រមប៉ុណ្ណោះ ឯព្រះអង្គឯងតែងចេញទៅស្វះស្វែងរក ផ្លែឈើមើមឈើយកមកចិញ្ចឹមប្រពន្ធមិនឲ្យអត់ឃ្លាន ។

លុះនៅក្នុងព្រៃយូរមក ថ្ងៃមួយ ព្រះរាជកុមារចេញទៅរកផ្លែឈើក្នុងព្រៃឆ្ងាយបាត់ទៅតាំងពីព្រលឹម គ្រានោះ មានតាបសមួយអង្គអាស្រ័យនៅកោះមួយនាកណ្ដាលសមុទ្រ បានឈានហោះហើរតាមផ្លូវអាកាសចូលទឹកមកបេះផ្លែឈើឯត្រើយសមុទ្រ លុះហោះមកជិតអាស្រមនាងនាងបានឃើញផ្សែងភ្លើងហុយឡើងទៅលើអាកាស ក៏ចុះមកឈរនៅនាមុខអាស្រម ៗ ឯនាងនាងកំពុងតែអង្គុយស្ងួតណ្ដាំ ក្រឡេកឃើញតាបសនិមន្តឲ្យឡើងទៅគង់ក្នុងអាស្រម និយាយសំណេះសំណាលសាកសួរសុខទុក្ខផ្សេង ៗ ហើយក៏កើតចិត្តជំរេកត្រេកត្រអាលនឹងតាបសដោយកាមរសទើបនាងនាងធ្វើឫកពាបញ្ចេញកលមាយាស្រីឲ្យតាបសឃើញ ៗ តាបសទ្រាំអត់មិនបានដាច់ឈានក្នុងពេលនោះ ហើយសម្ងំនៅក្នុងអាស្រមជាមួយនាងនាងតាំងពីព្រឹករហូតដល់ថ្ងៃរសៀលជាប់ចិត្តប្រតិព័ទ្ធនឹងនាងនាងដើរចេញមិនរួចដោយសារខានជួបជិតស្រីជាយូរឆ្នាំហើយ ៗ

លុះដល់ថ្ងៃរសៀល តាបសក្រឡេកមើលទៅមុខសាលា ឃើញព្រះរាជកុមារយាងមកពីចម្ងាយលឹម ៗ ក៏ភិតភ័យចុះពីលើសាលាក្ដាមរត់សំដៅឆ្ពោះទៅរកមាត់សមុទ្រយ៉ាងលឿន ៗ ព្រះរាជកុមារទតឃើញតាបសរត់លឿនដូច្នោះនឹកថា តាបសនេះប្រហែលជាមកស្រឡាញ់ដេកជាមួយប្រពន្ធអញហើយ បានជាគ្រាន់តែឃើញអញគេចរត់យ៉ាងប្រញាប់ដូច្នេះ ទើបស្ទុះទៅយកដាវពីអាស្រមដេញតាមតាបសស្ទើតទៅ ៗ

ឯតាបសរត់ទៅដល់មាត់សមុទ្រលោតឡើង ប្រុងនឹងហោះឆ្លងទៅឯកោះរបស់ខ្លួន ប៉ុន្តែ ហោះមិនរួចក៏ធ្លាក់ធ្លុងទៅក្នុងទឹកសមុទ្រព្រោះដាច់ឈានទៅហើយ ព្រះកុមារតាមទៅទាន់ឃើញតាបសឈរក្នុងទឹកដូច្នោះគិតថា ឲ្យតាបសនេះកាលមកពីកោះកណ្តាលសមុទ្រនោះ ប្រហែលជាហោះមកដោយកំឡាំងបុទ្ធិរបស់ឈាន លុះមកជួបជិតប្រឡូកប្រឡំនឹងស្រីក៏ដាច់ឈានហោះទៅវិញលែងរួច បានជាធ្លាក់ទឹកយ៉ាងនេះ ណ្ហើយចុះគួរតែអញអាណិតតាបសនេះកុំធ្វើបាប ព្រោះចិត្តអញក៏ស្រឡាញ់ស្រីដូចចិត្តតាបសដែរ គួរតែអញរំលឹកទូន្មានតាបសនេះវិញចុះ លុះទ្រង់ព្រះចិន្តាដូច្នោះហើយ ក៏ត្រាស់ទៅរកតាបសថា បពិត្រលោកដ៏ចំរើន លោកកុំគិតភ័យខ្លាចខ្ញុំថ្វីឡើយ ធម្មតាស្រីតែងធ្វើឲ្យប្រុសវិលវល់ខ្វល់ខ្វក់ដោយកាមគុណជាប់ជានិច្ច ដ្បិតស្រីមានកលមាយាច្រើនណាស់គ្មានទីបំផុតទេ ដូចពាក្យចាស់ទុំបុរមបុរាណលោកសំដែងទុកមកថា ធម្មតាស្រីមានមាយាដូចថ្ងៃបណ្តើរកូន ប្រុសមានទុក្ខសោកពេកភ័យចង្រៃអន្តរាយមកពីសេពគប់ស្និទ្ធស្នាលនឹងស្រី, ស្រីជាចំណងចងប្រុសទុកក្នុងផ្ទះ, ស្រីជាអន្ទាក់របស់សេចក្តីស្លាប់, ស្រីមានរូបរាងកាយដូចគោហាជាទីសំណាក់អាស្រ័យប្រុសណាសេពគប់ស្និទ្ធស្នាលវង្វេងស្មារតីទៅតាមស្រី ប្រុសនោះឈ្មោះថាជាអ្នកឥតធម៌ : មួយទៀត ស្រីតែងធ្វើប្រុសអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរឲ្យខូចធម៌ តែងធ្វើប្រុសឲ្យលិចលង់នៅក្នុងវាលវដ្តសង្សារ អ្នកប្រាជ្ញកាល

បើបានដឹងយ៉ាងនេះហើយ គួរតែខំចៀសវាងឲ្យឆ្ងាយអំពីស្រី មិនគួរសេពគប់ផ្ដេកផ្ដិតស្និទ្ធស្នាល វង្វេងឈ្លប់ចិត្តនឹងស្រីទេ ដ្បិតស្រីបើសេពគប់នឹងប្រុសណាដោយចិត្តស្រឡាញ់រូបកាយប្រុសនោះក្ដី ដោយចិត្តចង់បានមាសប្រាក់ទ្រព្យសម្បត្តិពីប្រុសនោះក្ដី តែងបំផ្លិចបំផ្លាញប្រុសនោះឲ្យវិនាសយ៉ាងឆាប់រហ័ស ប្រៀបដូចភ្លើងដុតកំទេចសម្រាម ឲ្យឆេះខ្លោចអស់រលីងទៅក្ដាម ៗ ដែរ នេះសំដៅយកស្រីអាក្រក់ស្រីខាតលក្ខណ៍តែម្យ៉ាង ឯស្រីល្អគ្រប់លក្ខណ៍វិញ មិនមែនបំផ្លាញប្រុសដូច្នោះទេ មានតែជួយទំនុកបម្រុងយ៉ាងប្រុសស្មោះត្រង់នឹងប្ដីណាស់ ទុកជាដល់ស្លាប់ខ្លួនក៏មិនក្បត់ប្ដីដែរ សមដូចសុភាសិតមួយបទថា "...ដុះពិស្រណោក ដ្បិតលក្ខណ៍ស្រីជា" នឹងមួយបទទៀតថា "សំណាបយោងដី ស្រីយោងប្រុស" ៗ

តាបសឈរកង់ទឹកស្ដាប់ឱវាទព្រះរាជកុមារចប់ហើយ កើតសេចក្ដីសង្វេគស្លុតចិត្តចំរើនឈានឲ្យកើតឡើងវិញ ហើយហោះទៅឯកោះជាលំនៅរបស់ខ្លួនក្នុងគ្រានោះឯង ៗ

បំណែកព្រះរាជកុមារកាលបើឃើញតាបស ហោះឡើងពីទឹករួចអណ្ដែតត្រសែតទៅតាមអាកាសដូច្នោះ ក៏នឹកពិចារណាថា តាបសនេះចេះចំរើនឈានហោះទៅរួច ឯខ្លួនអញត្រូវតែលះបង់ស្រីចេញ ហើយខំចំរើនឈានឲ្យបានកើតដូចជាតាបសដែរ ទ្រង់ព្រះចិន្តាយ៉ាងនេះ រួច

ត្រឡប់ទៅអាស្រមវិញហៅនាងនាដមកប្រាប់ថា បងគ្មានចិត្តអាក់អន់អ្វីនឹងប្អូនទេការដែលប្អូនធ្វើខុសនឹងបងដូចម្តេច ក៏បងគ្មានចិត្តប្រកួតប្រកាន់ដែរ ប៉ុន្តែពេលនេះបងសូមលាកម្លាពៀនឹងប្អូនហើយ ដ្បិតចិត្តបងចង់បួសជាតាបសឫសីនៅក្នុងព្រៃនេះរហូតដល់ស្លាប់ បងលែងទៅនៅក្នុងស្រុកទេសវិញហើយ ចូរនាងវិលទៅនៅស្រុកមានប្តីទៀតចុះ ៗ នាងនាដត្បូងថ្នោះ មានចិត្តអាឡោះអាល័យព្រះរាជកុមារណាស់អង្វរសុំនៅជាមួយគេទៅទៀតរហូតអស់ជីវិត ៗ ព្រះរាជកុមារមិនព្រមឲ្យនាងនៅ ប្រាប់ថាប្អូននៅជាមួយបងមិនបានទេ ព្រោះនាំឲ្យបងខ្វល់ចិត្តណាស់ ចំរើនឈានមិនកើត ប្រាប់រួចជូននាងនាដឲ្យទៅនៅស្រុកកំណើតរបស់ខ្លួនវិញ ហើយត្រឡប់មកអាស្រមបួសជាតាបសឫសីចំរើនឈាន មិនយូរប៉ុន្មានក៏បានសម្រេចដូចប្រាថ្នា លុះធ្វើកាលកិរិយាក្ស័យជីវិតហើយបានទៅកើតនៅឋានព្រហ្មលោកដោយអំណាចឈាន ៗ

ព្រះរាជកុមារតាបសនោះ គឺជាព្រះសម្មាសម្ពុទ្ធម្ចាស់យើង កាលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ ៗ

អ្នកតាកើត—និយាយរឿងប្រុសស្អប់ស្រីចប់ហើយ ប្រាប់កូនថា ឯងស្តាប់រឿងនេះឲ្យច្បាស់ចុះ អម្បាលព្រះរាជកុមារ ជាអម្បូរព្រះបរមពោធិសត្វផង ម៉េចក៏នៅតែមានចិត្តប្រែប្រួលមិនទៀងទាត់ដែរ ម្តងថាស្អប់ណាស់ ម្តងថាស្រឡាញ់ណាស់ ឯតាបសៈសាតទៀតជាអ្នកបួសត្រឡាំង

ចំរើនឈានហោះហើរដើរលើអាកាសបាន គ្មានចិត្តសប្បាយរីករាយក្នុងលោកិយសោះ ម៉េចក៏គង់តែដាច់ឈានដោយសារជួបប្រទះនឹងស្រីដែរ ហើយលោកនៅព្រៃហិមពាន្តឆ្ងាយដាច់ស្រយាលពីស្រី ៗ ផង ចំណង់បើឯងនៅក្នុងស្រុកភូមិជាមួយមនុស្សប្រុសប្រឡូកប្រឡំនឹងស្រី ៗ គរគោកយ៉ាងនេះ ក្រែងឯងស្ទុះមិនរួច ធ្លង់មិនផុតពីក្បិនស្រី ត្រូវឯងទៅដេកគិតស្ដួរដេញដោលចិត្តខ្លួនឲ្យជាក់លាក់សិន បើថាមុខជាគេចមិនរួចពីយកប្រពន្ធទេ គប្បីយកពីក្មេងឲ្យហើយទៅកុំចាំចាស់ ដូចភាសិតមួយបទថា " ចូលព្រៃទាន់ព្រឹក សឹកទាន់នៅក្មេង " ។

ដីប្រែ — ទេផ ! ចិត្តខ្ញុំដាច់ស្រេចហើយ ឲកុំបង្ខំខ្ញុំពីរឿងប្រពន្ធកូននោះ ម៉ែថាចាំរើសរកកូនគេអ្នកមានពូជល្អឲ្យខ្ញុំ ៗ ក៏នៅតែមិនព្រមយកដែរ ព្រោះខ្ញុំសំគាល់ថាស្រីទាំងអស់សុទ្ធតែចិត្តវៀច មានកលល្បិចមាយាច្រើនណាស់ ដេញពុតមិនទាល់សោះ គ្មានត្រង់ម្នាក់ទេ ។

អ្នកតាកោត - ចុះម៉េចក៏ឯងដឹង ? បើឯងមិនដែលសេពគប់នឹងស្រីណាសោះ ។

ដីប្រែ — បាទ ! ខ្ញុំមិនដែលស្និទ្ធស្នាលនឹងស្រី ៗ មែន ប៉ុន្តែ កាលខ្ញុំកំពុងរៀន ខ្ញុំបានមើលសៀវភៅមួយដែលគូកនម្នាក់ឲ្យខ្ញុំ ក្នុងសៀវភៅនោះនិយាយអំពី ៖

(នៅមានត)

# ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសឥណ្ឌា

លោក រ៉ូហ្សេមបែរត៍ អតីតសាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ រៀបរៀង
ក្នុងឆ្នាំ ១៩៥៩ លោក ញ៉ែម-ទឹម នៅក្រសួងធម្មការប្រែជាភាសាខ្មែរ

---

ប្រទេសឥណ្ឌាមានផ្ទៃដីជាង ៤ លានម៉ែត្រក្រឡា ។ កាលពីឆ្នាំ ១៩៤៧, ប្រទេសនេះបានត្រូវបែងចែកជារដ្ឋពីរៈ មួយហៅថាប៉ាគីស្ថង់, មួយទៀតគឺសហភាពឥណ្ឌា ។ ការបែងចែកនេះបណ្ដាលមកពីសាសនា ។

## លក្ខណៈនៃប្រទេស

ប្រទេសឥណ្ឌាទាំងមូលចែកជាបីចំណែកៈ

ក)– ខាងជើងៈ មានជួរភ្នំធំមួយហៅថា ហិមាល័យ (ហិមពាន្ត) ។ ជួរភ្នំនេះមានបណ្ដោយ ១.៥០០ គ.ម., ទទឹង៤០០ គ.ម., ហើយមានកំពូលខ្ពស់ក្រៃលែង ។ កំពូលដែលខ្ពស់ជាងគេហៅថា ម៉ុងអេវ៉េរេស្ត៍ (Mont Everest) ៨.៨៤០ ម. ។

ខ) ខាងត្បូងៈ មានឧបទ្វីបមួយ (Péninsule) យ៉ាងធំ ហៅថា ដេកង់ (Deccan) ។ គឺជាតំបន់ដីដ៏ចាស់យូរលង់មកហើយ ។ ត្រូវទឹកបក់បោកបាក់បែកកាលពីបឋមសម័យ ។ ឧបទ្វីបនេះបានរៀនចូលមកប៉ះនឹងទ្វីបអាស៊ី ។ ផ្ទាំងថ្មនៅទីនោះ គឺជាផ្ទាំងថ្មមានឫសកែវដូចគ្នានឹងផ្ទាំងថ្មឯណា ។ ប៉ុន្តែ ឧបទ្វីបដែលហៅថាដេកង់នោះបានដុះឡើងវិញនៅក្នុងយុគទីបី តែមិនរាបស្មើទេ គឺខ្ពស់ខាងលិចហើយទាបកណ្ដាល ។

ជ្រុងខាងលិចខ្ពស់ជាងជ្រុងខាងកើតជាច្រើន ។ ជ្រុងទាំងសងខាងនេះហៅថាហ្គាត (ghâtes: គឺភ្នំនៃឧបទ្វីបដេក្កង់) ។ នៅខាងទិសពាយ័ព្យនៃដេក្កង់មានបាតុភូតគំហើញមួយ ដែលញុំាងទីដីនៅជិតនោះឲ្យមានដីជាតិយ៉ាងសំខាន់ ។

គ)– នៅចំកណ្ដាលប្រទេសឥណ្ឌា : គឺជាវាលល្បប់មួយយ៉ាងធំ ដែលមានទន្លេធំពីរគឺ អាំងឌុស និងគង្គា បានហូរកាត់បំពេញ ។ ដីវាលនោះរាបស្មើ, គ្មានអ្វី ៗ លូតខ្ពស់ឡើយ ហើយប្រកបដោយដីជាតិផង ។

ប្រទេសឥណ្ឌាមានធាតុអាកាសអាស្រ័យដោយខ្យល់រដូវ ។ ខ្យល់រដូវនេះជាបាតុភូតមួយយ៉ាងសំញ៉ាំ បណ្ដាលមកពីធាតុអាកាសខុសគ្នានៅលើទ្វីបអាស៊ី និងនៅលើមហាសាគរឥណ្ឌា ។ នៅវស្សានរដូវដែនដីគោកមានកំដៅខ្លាំងពេក ឯមហាសាគរមានធាតុអាកាសក្ដៅបន្តិច ៗ ខ្យល់បក់ពីសមុទ្រទៅកាន់ដីគោក គឺពីទិសនិរតីទៅទិសឦសាន ។ ខ្យល់នេះត្រជាក់ហើយសើម ។ រដូវភ្លៀងគឺចាប់ពីខែឧសភាទៅខែវិច្ឆិកា ។ ផ្ទុយទៅវិញ, បើនៅសិសិររដូវ (រដូវត្រជាក់ខ្លាំង) ដែនដីគោកមានធាតុអាកាសត្រជាក់, ឯមហាសាគរនៅក្ដៅបន្តិច ៗ ដដែល ខ្យល់បក់ពីដែនដីគោកទៅកាន់សមុទ្រ គឺពីទិសឦសានទៅទិសនិរតី ខ្យល់ត្រជាក់ហើយស្ងួត ។

រដូវក្តៅគឺចាប់ពីខែវិច្ឆិកាទៅខែឧសភា ។ ប៉ុន្តែ សូមជ្រាបថា ធាតុអាកាសក្នុងប្រទេសឥណ្ឌៀមិនដូចគ្នាទេ ដូចជានៅវស្សានរដូវ, ដំបន់ឯទៀតមានធាតុអាកាសក្តៅទាំងអស់ (កាល់គុត្តា : ខែកក្កដា ២៩ អង្សា ម៉ាដ្រាស : ខែកក្កដា ២៧ អង្សា) ។ ផ្ទុយទៅវិញ, នៅសិសិររដូវ, នៅដំបន់ខាងជើងនៃប្រទេស, ធាតុអាកាសត្រជាក់ណាស់ (ម្បាហ៊ារ : ខែមករា ១៣ អង្សា ; ម៉ាដ្រាស ខែមករា ២៤ អង្សា) ។

ទឹកភ្លៀងធ្លាក់មិនស្មើគ្នានៅក្នុងប្រទេសទេ ។ អាស្រ័យហេតុនេះហើយ, បានជានៅដំបន់ខ្ពស់ៗ មានភ្លៀងយ៉ាងបរិបូណ៌, ឯដំបន់ទាបៗវិញមានភ្លៀងតែបន្តិចបន្តួច ។ ហេតុនេះ បានជានៅជ្រុងខាងលិចនៃឧបទ្វីបដេកង់មានភ្លៀង ពី ២ ទៅ ៤ ម៉ែត្រ ក្នុងមួយឆ្នាំ ។ ផ្ទុយទៅវិញនៅត្រង់តំបន់កណ្តាលនៃដេកង់មានភ្លៀងតិចជាង ៧០០ ម.ម. ។ ក្រៅពីនេះ, ខ្យល់ត្រជាក់បាននាំមកនូវទឹកភ្លៀងយ៉ាងសម្បូរត្រង់ទីទៀបជើងភ្នំហិមាលយា ។ នៅបេនហ្គាល់មានទឹកភ្លៀងពី ២ ទៅ ៤ ម៉ែត្រ ប៉ុន្តែខ្យល់រដូវបានទៅប៉ះនឹងភ្នំហិមាលយា ពុំអាចឆ្លងកាត់ភ្នំបានឡើយ ហើយក៏ត្រូវប្តូរទិសបែកពីទិសពាយ័ព្យទៅទិសអគ្នេយ៍វិញ ។ ខ្យល់នេះ ថយត្រជាក់បន្តិចម្តងៗ ហើយវាលឥណ្ឌូគង្គាមានភ្លៀងតែ ១ ម. នៅតំបន់កណ្តាល និង ៥០ ស.ម. នៅតំបន់ខាងជើង ក្នុងមួយឆ្នាំ ។

ការដែលទឹកភ្លៀងធ្លាក់មិនស្មើនៅក្នុងប្រទេស បណ្តាលឲ្យប្រជា

ជនទៅបែកខ្ញែកគ្នាដែរ, ហើយសកម្មភាពសេដ្ឋកិច្ចសោត ក៏ប្លែកគ្នាពីកន្លែងមួយទៅកន្លែងមួយ ។

ប្រទេសឥណ្ឌាមានរុក្ខជាតិសម្បូរតែនៅតំបន់ព្រៃភ្នំ ឯក្នុងវាលឥណ្ឌូគង្គាវិញ, គេឃើញមានតែវប្បកម្ម (ការសាបព្រោះ) ។ ប្រទេសឥណ្ឌាមានទន្លេធំពីរគឺ : សាំងឌុស និងគង្គា ។

ក)- ឆន្ទេអាំងឌុស : ទន្លេអាំងឌុសនេះមានប្រភពចេញមកពីភ្នំហិមាលយា ហើយហូរព័ទ្ធពេនតាមភ្នំនោះអស់ប្រវែង ១៥០០ គ.ម. ។ ទន្លេនេះមានបណ្ដោយទាំងអស់ចំនួន ៣.០០០ គ.ម. ហូរសំដៅទៅដែនដីសណ្ដរ ហើយកាត់តាមដំបន់ស្ងួតហែង ។ គឺជាទន្លេដែលគេពុំសូវប្រើការ ប៉ុន្តែ នៅត្រង់ដំបន់ដែលមានខ្សែទឹកហូរធម្មតា គឺត្រង់ប្រាំងខាងជើងដែលមានដៃទន្លេប្រាំហូរធ្លាក់មក, គេអាចទប់យកទឹកបញ្ចូលទៅក្នុងដំបន់ជិតខាងបាន ។ នៅជិតដែនដីសណ្ដរនៃទន្លេនេះក៏មានកន្លែងសម្រាប់បញ្ចូលទឹកទៅក្នុងស្រែដែរ ។ សព្វថ្ងៃគេមានសង់ទំនប់ទឹកដ៏ធំពីរនៅទីនោះ ។

ខ) ឆន្ទេគង្គា : ទន្លេគង្គាប្លែកពីទន្លេអាំងឌុស ។ គឺទន្លេនេះហូរបែកចេញភ្លាមពីភ្នំហិមាលយា គឺឥតព័ទ្ធពេនតាមភ្នំទេ ។ គឺជាទន្លេរាបស្មើ មានព្រិលនិងទឹកភ្លៀងហូរធ្លាក់បំពេញ មានបណ្ដោយចំនួន ៣០០០ គ.ម ហើយទន្លេនេះក៏សម្រាប់ទប់យកទឹកបញ្ចូលស្រែបានដែរ ។

នាវាអាចបើកចេញចូលបានដោយស្រួល ។ ទន្លេគង្គានេះបានហូរប្រទាក់ទៅនឹងទន្លេប្រាម៉ាពូត្រ ហើយកើតទៅជាកងដីសណ្ដរមួយយ៉ាងធំតែរដ្ឋបេងហ្កាល់ ។

# អំពីប្រទេសប៉ាគីស្ថង់

គឺពួកមូលស៊ីយម៉ង់ដែលជាអ្នកបង្កើតរដ្ឋនេះ ពីឆ្នាំ ១៩៤៧ ហើយរដ្ឋនេះមានចែកជាពីរផ្នែកគឺ ប៉ាគីស្ថង់ខាងលិច និងប៉ាគីស្ថង់ខាងកើត, ឃ្លាតពីគ្នាចម្ងាយ ២.០០០ គ ម. ។ ប៉ាគីស្ថង់ខាងលិចស្ថិតនៅខាងទិសនិរតីមាន ទំហំ ៨០០ ០០០ គីឡូម៉ែត្រក្រឡា, ឯប៉ាគីស្ថង់ខាងកើតមានទំហំ ១៤០ ០១០ គីឡូម៉ែត្រក្រឡា ។

ក)- ប៉ាគីស្ថង់ខាងលិច : មានផ្ទៃធំជាងខាងកើត ប៉ុន្តែមានប្រជាជនតិច (៤៥ មនុស្ស ក្នុង ១ គ ម$^{2}$ ) គឺជាតំបន់ស្ងួតហែងមានភ្លៀងធ្លាក់តិចជាង ៥០០ មីល្លីម៉ែត្រ, ហើយផលដំណាំអាចធ្វើបានតែដោយសារការបាចទឹកបញ្ចូលស្រែ ។ នៅខាងជើងនៃដំបន់នេះ គឺត្រង់ដំបន់បញ្ចាប់ ( Pendjab ប្រទេសស៊ីងប៉ាំ) រាជការអង់គ្លេសបានធ្វើកន្លែងសម្រាប់បាចទឹកបញ្ចូលស្រែមួយយ៉ាងពិសេស, ហើយបានទាំងដាំផលិតផលពីរមុខយ៉ាងសំខាន់គឺ: ស្រូវសាលី, និងកប្បាស ។ ផុយទៅវិញប៉ែកខាងត្បូងនៃប្រទេសប៉ាគីស្ថង់ខាងលិច ជាតំបន់គ្រគ្រានដីជាតិសោះ ។ គេបានសង់ទំនប់ទឹកដើម្បីយកទឹកធ្វើដំណាំ ។ រាជការអង់

គេស បានសង់ទំនប់ទឹកមួយត្រង់សាក្ការ ហើយតាំងពីប្រទេសឥណ្ឌា បានឯករាជ្យបរិបូណ៌មក, គេក៏បានសង់ទំនប់ទឹកមួយទៀតនៅឯតំបន់កូ-ទ្រី ។ អាស្រ័យដោយមធ្យោបាយនេះ, គេក៏បានបង្កើតផលដំណាំស្រូវ និងកប្បាស ។ នៅក្នុងតំបន់នោះ គេឃើញមានទីក្រុងមួយយ៉ាងធំគឺ ការាជី ដែលជារដ្ឋធានីនៃប្រទេសប៉ាគីស្ថាន ។ តាំងពីពេលបានឯករាជ្យមក, ប្រជាជនក្នុងទីក្រុងនោះបានកើនឡើងជាលំដាប់ ដែលសព្វថ្ងៃមានប្រជាជនចំនួន ១.៣០០.០០០ នាក់ ។ ទីក្រុងនេះជាកំពង់ផែមួយយ៉ាងធំ និងជាមូលដ្ឋានអាកាសចរមួយយ៉ាងសម្បើម ។

ខ)– ប្រទេសប៉ាគីស្ថានខាងកើត : តំបន់នេះស្ថិតនៅតាមបណ្តោយបេនហ្គាល់ខាងកើត ជាតំបន់មានប្រជាជនច្រើនក្រៃលែង ( ៣៣០ មនុស្សក្នុង ១ គ.ម² ) ជាតំបន់សើមហើយមានដីជាតិណាស់ ។ គេច្រើនធ្វើផលដំណាំពីរដងក្នុងមួយឆ្នាំ ។ ផលដំណាំទីមួយគឺស្រូវ បន្ទាប់មកគឺធ្មៃ សម្រាប់ធ្វើបាវ ។

ទីក្រុងមិនសូវជាធំប៉ុន្មានទេ, មានទីក្រុងពីរដែលយើងត្រូវស្គាល់ គឺដាក្កា (Dacca) ដែលជាទីក្រុងរដ្ឋបាល មានប្រជាជនចំនួន ៤០០.០០០ នាក់ និងកំពង់ផែមួយហៅថាស៊ីត្តាហ្គង (Chittagong) ។

គ)– អំពីបញ្ហាប្រទេសប៉ាគីស្ថាន : ប្រទេសប៉ាគីស្ថានជារដ្ឋប្រកបរបរកសិកម្ម ។ ក្នុងមួយឆ្នាំ ១ ប្រទេសប៉ាគីស្ថានធ្វើស្រូវបាន

ចំនួន ៨.០០០.០០០ តោន, ស្រូវសាលី ៣.០០០.០០០ តោន និង ក្រចៅ ៣/៤ នៃផលិតកម្មក្នុងសាកលលោក ។ មួយចំណែកទៀត, ប្រទេសប៉ាគីស្ថានបានធ្វើកប្បាសប្រកបដោយគុណភាពល្អក្រៃលែង និង មានដាំរុក្ខជាតិផ្សេង ៗ ដែលឲ្យប្រេង ។

ឧស្សាហកម្មពុំសូវចំរើនទេ ដោយប្រទេសនេះខ្វះធនធានខាង អណ្តូងរ៉ែ ហើយបានចំបង្កើតតែឧស្សាហកម្មសម្រាប់ធ្វើកប្បាស, ធ្វើប្រចៅ, រោងចក្រធ្វើកប្បាស-ធ្វើក្រចៅ ៗ ក្រៅពីនេះ ប្រទេសនេះក៏បាន ខិតខំបង្កើតរោងចក្រធ្វើជី, ធ្វើស៊ីម៉ងត៍ដែរ ដោយបានបង្កើតផែនការ ៦ ឆ្នាំ ដែលទើបតែនឹងចប់ ។ ប៉ុន្តែ ប្រទេសនេះមានឧបសគ្គមួយដ៏ធំ គឺថវិកា ជាតិពាក់កណ្តាលទុកសម្រាប់តែចិញ្ចឹមកងទ័ព ។ ដូច្នេះ ប្រទេសនេះ ត្រូវខ្វះមូលធនដើម្បីយកទៅបង្កើតរោងឧស្សាហកម្ម ពិតមែនតែសហរដ្ឋ អាមេរិកបានជួយជំនួយជាច្រើនក៏ដោយ ។ មានបញ្ហាដ៏លំបាកមួយទៀត ដែលត្រូវដោះស្រាយ គឺការប្រកួតប្រជែងគ្នារវាងប៉ាគីស្ថានខាងកើតនិង ប៉ាគីស្ថានខាងលិច ។ ពួកប៉ាគីស្ថានខាងលិចបានដណ្តើមយកប៉ុស្តិ៍បញ្ជាការខ្ពស់ពីប៉ាគីស្ថានខាងកើត ហើយប្រជារាស្ត្រប៉ាគីស្ថានខាងកើតបាន តក់ជាច្រើន ។

## អំពីសាធារណរដ្ឋឥណ្ឌា

សាធារណរដ្ឋឥណ្ឌាមានទំហំ ៣.០០០ ០០០ គ.ម², ហើយមាន

ប្រជាជន ៣៦០.០០០.០០០ នាក់គឺមាន ១២៦ មនុស្សក្នុង ១ គ.ម២ៗ ចំនួនមនុស្សក្នុង ១ គ.ម២ នេះ ឃើញជាច្រើនសមល្មម ចំពោះប្រទេសដែលប្រកបរបរកសិកម្ម ៗ ឯកភាពជាតិពិបាកនឹងធ្វើណាស់ ៗ សាធារណៈរដ្ឋឥណ្ឌាមានចែកជា ១៧ ខេត្ត ហើយខេត្តនីមួយ ៗ មានស្វយភាពយ៉ាងធំទូលាយ ៗ គឺជាសាធារណរដ្ឋ សហព័ន្ធ (République fédérale) ៗ កន្លែងដែលសំខាន់ជាងគេនៃសហភាពឥណ្ឌា គឺវាលឥណ្ឌូគង្គា ៗ វាលនេះប្រកបដោយដីមានជីជាតិ ៗ ដំណាំដាំងឡាយមានធ្វើជាបន្ត ៗ គ្នាតាមលំដាប់នៃទឹកភ្លៀងធ្លាក់ ៗ នៅបេនហ្គាល់ ពេលដីនៅសើមខ្លាំង, គេធ្វើរបរពីរដងក្នុងមួយឆ្នាំ, ដំបូងគេធ្វើស្រូវ, បន្ទាប់មកគេដាំអំពៅ លុះទឹករីងស្ងួតទៅវិញ ដំបូងគេធ្វើស្រូវម្យ៉ាងហៅថាមីយេ (Millet) រួចក្រោយមកគេធ្វើស្រូវសាលី ៗ

ដីវាលទាំងឡាយនៃឧបទ្វីបដេកាន់ ដែលស្ថិតនៅតាមឆ្នេរសមុទ្រជាដីសើម ៗ អាចឲ្យគេធ្វើស្រូវ, ធ្វើសណ្ដែកដី, ដាំកប្បាសបាន ហើយនៅត្រង់ទិសនិរតី គេមានដាំម្រេចផង ៗ

សារៈសំខាន់នៃសហភាពឥណ្ឌា ស្ថិតនៅត្រង់ប្រទេសនេះសម្បូណ៌ដោយសម្បត្តិអណ្ដូងរ៉ែ ៗ នៅត្រង់ខ្ពង់រាប (plateau) នៃឧបទ្វីបដេកាន់, ឃើញមានម៉ង់ហ្គាណែសជាច្រើនក្រៃលែង (Manganèse) ដែលប្រទេសឥណ្ឌាជាប្រទេសលេខមួយក្នុងសាកលលោកក្នុងការនាំលោហៈ

ជាតិនេះទៅលក់ឯបរទេសៗ នៅខាងជើងនៃដេក្កន់, គេឃើញមានអណ្តូងរ៉ែធ្យូងថ្ម នឹងអណ្តូងរ៉ែដែកជាច្រើនស្ថិតនៅជិត ៗ គ្នា (៣៥.០០០.០០០ តោនធ្យូងថ្ម) ។ អាស្រ័យដោយសម្បត្តិអណ្តូងរ៉ែនេះហើយ រោងឧស្សាហកម្មទាំងឡាយ ក៏អាចកើតឡើង គឺឧស្សាហកម្មនៃលោហកម្ម, នឹងឧស្សាហកម្មនៃគីមី ។ ក្រៅពីនេះ, ប្រទេសឥណ្ឌាមានរោងចក្រខាងការត្បាញសំពត់មួយយ៉ាងធំក្នុងសាកលលោក , ប៉ុន្តែ រោងចក្រនេះធ្វើតែកប្បាសទេ, នឹងរោងចក្រធ្វើអម្បោះដ៏សំខាន់មួយទៀតនៅបុមបៃ ។ ទីក្រុងបុមបៃនេះមានប្រជាជន ៣ ០០០.០០០ នាក់, ហើយជាកំពង់ផែនៃប្រទេសផង ។

ផ្ទុយទៅវិញ កាល់គុត្តាជាទីក្រុងពិសេសខាងធ្វើដើមក្រចៅឲ្យទៅជាបាវ ។ ទីក្រុងនេះស្ថិតនៅជិតកន្លែងរ៉ែ ហើយជាកន្លែងធ្វើលោហធាតុផង ។ កាល់គុត្តាមានប្រជាជន ៦.០០០.០០០ នាក់ស្ថិតនៅចម្ងាយ ៨០ គ.ម ពីសមុទ្រ, ជាប់នឹងដៃទន្លេគង្គា, ជាកំពង់ផែទីពីរនៃប្រទេស ។

## ការទាក់ទងគ្នារវាងប្រទេសទាំងពីរ
## (ប៉ាគីស្ថាននិងសហភាពឥណ្ឌា)

ពីដំបូង ការទាក់ទងគ្នារវាងប្រទេសទាំងពីរមានសភាពពុំសូវល្អទេ ។ ប្រទេសប៉ាគីស្ថាន ពុំព្រមលក់ក្រចៅទៅឲ្យរោងចក្រធ្វើអំបោះនៅឯកាល់គុត្តា ។ ជាពិសេសជម្លោះកើតមានកាន់តែធំឡើងចំពោះរឿងកាស្មៀរ

(Caehemire) ហើយសង្គ្រាមហៀបតែនឹងផ្ទុះឡើងជាច្រើនដង រវាងរដ្ឋទាំងពីរនេះ ។

ជាពិសេសទៅទៀត, គឺរដ្ឋទាំងពីរនេះរើសយកមាគ៌ានយោបាយក្រៅប្រទេសខុសពីគ្នាស្រឡះ ។ ប្រទេសប៉ាគីស្ថានដើរតាមក្រោយសហរដ្ឋអាមេរិក, ប្រទេសឥណ្ឌារើសយកនយោបាយអព្យាក្រឹត្យ មិនចូលនឹងបក្សខាងណាទាំងអស់ ។

ឥឡូវនេះ រដ្ឋទាំងពីរនេះមានការទាក់ទងគ្នាយ៉ាងប្រសើរ ។ ការយល់ព្រមបែកព្រំដែនទឹក គឺស្ទឹងទាំងឡាយក៏បានធ្វើឡើង ។ ស្ទឹងនេះមានប្រភពចេញមកពីសហភាពឥណ្ឌា ហើយអាចបញ្ចូលទឹកទៅក្នុងរដ្ឋប៉ាគីស្ថានបានត្រង់តំបន់បញ្ចប់ ។

សេដ្ឋកិច្ចនៃប្រទេសទាំងពីរនេះគឺពឹងពាក់គ្នាទៅវិញទៅមក ។ ប្រទេសប៉ាគីស្ថានក្រខាងវត្ថុធាតុដើម អាចទិញធ្យូងថ្មនឹងដែកពីប្រទេសឥណ្ឌាបាន ចំណែកឯប្រទេសឥណ្ឌាទិញពីប្រទេសប៉ាគីស្ថានវិញ នូវផលិតផលខាងកសិកម្ម មានស្រូវនឹងស្រូវសាលីជាដើម ។

( ចប់ )

# លទ្ធផលនៃការប្រឡងប្រជែងអក្សរសាស្ត្រ នៃសមាគមអ្នកនិពន្ធខ្មែរ រង្វាន់ "ឥន្ទ្រទេវី" ឆ្នាំ ១៩៦០-១៩៦១

ដោយសមាជិក ទ្រឹញ-ង៉ាញ ប្រធានគណៈមេប្រយោគ

នៃសមាគមអ្នកនិពន្ធខ្មែរ

---

ការប្រឡងប្រជែងអក្សរសាស្ត្រទូទៅ រង្វាន់ "ឥន្ទ្រទេវី" សម្រាប់ឆ្នាំ ១៩៦០ និង ១៩៦១ ដែលសមាគមអ្នកនិពន្ធខ្មែរ បានចាត់ចែងធ្វើនោះ បានលទ្ធផលដូចតទៅ ៖

## ក) ផ្នែកប្រលោមលោក – ( មានបេក្ខជន ៨៨ នាក់ )

រង្វាន់ទី ១– បានទៅលោក សួន-សុរិន ធ្វើការនៅព្រះរាជប្រតិភូស្ថានក្រុងភ្នំពេញ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ។

រង្វាន់ទី ២– បានទៅលោក អ៊ុម-ជុំ អ្នកតំណាងរាស្ត្រ នៅរដ្ឋសភា ក្រុងភ្នំពេញ រឿងវ៉ែនណែត ។

រង្វាន់ទី ៣ បានទៅលោក ឈុប-សាវ៉ាង លេខាធិការ នៅក្រុមអាជីវកម្មរាជកាយស្វ័យយាន ក្រុងភ្នំពេញ រឿងជីវិតខ្ញុំ ។

## រង្វាន់លើកទឹកចិត្តមាន ៣ គឺ៖

១ បានទៅលោក ឃៀប-កាន់ឌី ធ្វើការនៅទីចាត់ការអប់រំមូលដ្ឋានជាតិ ភ្នំពេញ រឿងភពរដ្ឋគិរ ។

២- បាននៅលោក កុយ-ឡុត លេខាធិការ នៅមន្ទីរពេទ្យកាល់ម៉ែត ភ្នំពេញ រឿងសែងគំសត់ ។

៣- បាននៅលោក សរ-ឡុច គ្រូបង្រៀននៅសាលាបឋមសិក្សាមាស ឃុំពោងម៉ាង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង រឿងភាសណាយុវជន ។

## ១) ផ្នែកកវីនិពន្ធ– (មានបេក្ខជន ៨៧ នាក់)

រង្វាន់ទី ១– បាននៅលោក ចាប-ពិន អធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ កំណាព្យមានចំណងជើងថា : អធិប្បាយច្បាំសុភាសិត ។

រង្វាន់ទី ២- បាននៅលោក ជល-និត្យ ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ កំណាព្យរឿងជូងជា ។

រង្វាន់ទី ៣– បាននៅលោក ក៉ង់-សរ និស្សិតមន្ត្រីជាន់ខ្ពស់នៅសាលាភូមិន្ទរដ្ឋបាល ភ្នំពេញ កំណាព្យរឿង ព្រះជីវប្រវត្តិសម្តេចព្រះនរោត្តម-សីហនុ ព្រះបិតាឯករាជ្យជាតិ ។

## រង្វាន់លើកទឹកចិត្តមាន ៣ គឺ:

១– បាននៅលោក ឱម-ណាត្រី ធ្វើការនៅវិទ្យាស្ថានជាតិគរុកោសល្យ ភ្នំពេញ កំណាព្យ អក្សរសាស្ត្រនិងកវីខ្មែរ ។

២- បានទៅលោក យូ-អ៊ុង ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ កំណាព្យរឿង ជារធកស្ព្រប ។

៣- បានទៅលោក ញូង-សៀង លេខាធិការនៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ កំណាព្យ ការរណភ យកតដែជដី ជីង កើតសារជាថ្មីឡើងវិញ ។

គ) ផ្នែករឿងល្ខោន- (មានបេក្ខជន ២០ នាក់)

រង្វាន់ទី១ (គ្មាន)

រង្វាន់ទី២- បានពីរគឺ :

១- បានទៅលោក ជេង-ផុង ធ្វើគ្រូបង្រៀន ហើយជាអ្នកកំកន៍វង់ល្ខោនព្រះរាជទ្រព្យ រឿងស្វិការឈើខ្វះ ថ្នាក់ថ្នាយពីកល់ ។

២- បានទៅលោក ង៉ួង-កាង ធ្វើគ្រូបង្រៀន នៅមន្ទីរហាត់ការគរុកោសល្យ ភ្នំពេញ រឿងពិតដងដំពោះដង ។

រង្វាន់ទី ៣ មានពីរគឺ :

១- បានទៅលោក លី-គីមអួង ធ្វើគ្រូបង្រៀន នៅមន្ទីរហាត់ការគរុកោសល្យ ភ្នំពេញ រឿងសោកណាភក្រី ។

២- បានទៅលោក តាំង-សេងគី អតីតសិស្សគរុវិជ្ជា រឿងវីរជនខ្មែរ ។

ឯពិធីប្រគល់រង្វាន់ផប៉ៃអស់លោកជ័យលាភី នឹងរៀបចំឡើងក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋ ដែលទ្រង់ជាប្រធានកិត្តិយស នៃសមាគមអ្នកនិពន្ធខ្មែរនៅព្រះទីនាំងកោជនីយក្នុងព្រះបរមរាជវាំងចតុមុខ ភ្នំពេញ ។

កាលបរិច្ឆេទ នៃមហាបាតុកម្មផែកវប្បធម៌នេះ នឹងមានជូនឲ្យបានជ្រាបនៅពេលខាងមុខ ។

ផ្នែកកំណត់ជីវប្រវត្តិការណ៍

# ពិធីសម្ពោធធម្មមន្ទីរ វត្តព្រះវិហារហ្លួង ឧត្តុង្គ

---

កាលពីថ្ងៃទី ១១ ខែមិថុនា គ. ស. ១៩៦១ សម្តេចព្រះរាជកនិដ្ឋា-រស្មីសោភ័ណ បានទ្រង់ស្តេចយាងជាព្រះអធិបតី នៃពិធីបុណ្យសម្ពោធធម្មមន្ទីរ វត្តព្រះវិហារហ្លួង ឃុំឧត្តុង្គ ស្រុកពញាឮ ខេត្តកណ្តាល ។ ធម្មមន្ទីរនេះ បានសាងឡើងពីឆ្នាំ ១៩៥៩ ដម្លៃ ៤៨៤.០០០៛០០ ជាស្នាព្រះហស្តនៃព្រះគ្រូមុនី (ទៀង · អ៊ុជ) ចៅអធិការវត្តនេះ ។ ក្នុងព្រះដំណើរនេះ ព្រះរាជវង្សានុវង្ស ជំទាវ និងឯកឧត្តម ឯកអគ្គរាជទូតនៃប្រទេសលាវ ព្រមទាំងឥស្សរជនដទៃទៀតជាច្រើន បានស្តេចយាងបានអញ្ជើញទៅរួមក្នុងពិធីនេះផង ។

នៅវេលាស្តេចយាងដល់ ទ្រង់បានទទួលនូវគារវកិច្ចអំពីសំណាក់ពុទ្ធបរិស័ទទាំងឡាយ ដែលមានលោក ប្រាក់ · ម៉ៃ ជាតំណាងក្នុងបរិយាកាសដ៏សែនរីករាយ ។

លុះទ្រង់គង់ក្នុងទីដ៏សមគួរហើយ, លោក ប្រាក់ - ម៉ៃ តំណាងគណៈកម្មការបុណ្យនិងពុទ្ធបរិស័ទ បានថ្វាយសុន្ទរកថាមួយ សំដែងសេចក្តីត្រេកអរជាខ្លាំង ចំពោះសម្តេចព្រះរាជកនិដ្ឋារស្មីសោភ័ណដែលទ្រង់បានស្តេច

យាងមកជាព្រះអធិបតី នៃពិធីបុណ្យនេះ ព្រមទាំងបានរៀបរាប់អំពីជីវប្រវត្តិនៃវត្តនេះ ដែលសាងឡើងតាំងពីក្នុងរជ្ជកាលនៃព្រះករុណាព្រះអង្គឯង ហើយតែងបានទទួលនូវការឧបត្ថម្ភពីព្រះមហាក្សត្រទាំងឡាយព្រមទាំងព្រះរាជវង្សានុវង្ស រហូតដល់រជ្ជកាលនៃព្រះករុណាព្រះមហាការុញនរោត្តម និងសម្តេចព្រះមហាក្សត្រិយានី ជាព្រះមាតាជាតិនាបច្ចុប្បន្ននេះ ពុំដែលអាក់ខានឡើយ ។

នៅទីអវសាន សម្តេចព្រះរាជកនិដ្ឋាសេនាសេកីណា ទ្រង់បានដាំដើមពោធិព្រឹក្សពីរដើម នៅមុខ ធម្មសាលា នោះ ជាកិច្ចបញ្ចប់ពិធីបុណ្យ ។

សូមបញ្ជាក់ថា វត្តព្រះវិហារហ្លួងនេះ ជាវត្តចាស់មួយ មានអាយុកាលដ៏វែង ហើយបានរក្សាទុកនូវប្រវត្តិនៃធម្មយុត្តិកនិកាយ តាំងពីកាលដែលកើតមាននៅក្នុងប្រទេសកម្ពុជា ហើយនឹងរក្សាទុកនូវគម្ពីរបាលី ក្បួនច្បាប់ផ្សេង ៗ តាំងពីសម័យនោះ រហូតមកដល់សម័យនេះ ជាប់មិនដាច់ ។

ពុទ្ធសាសនបណ្ឌិត្យ សូមចូលរួមសំដែងសេចក្តីសោមនស្សជាអនេកប្បការ ចំពោះពិធីបុណ្យនេះ ហើយសូមប្រសិទ្ធិឲ្យវត្តនេះ មានអានុភាពទ្រទ្រង់ព្រះពុទ្ធសាសនាឲ្យបានស្ថិតស្ថេរបើរកាលតទៅ ។

ពុទ្ធសាសនបណ្ឌិត្យ

---

ពជបុណ្យនៅវត្តលង្កា

# ប្រគេន - ថ្វាយ សម្ដេចទាំងពីរព្រះអង្គ

ថ្ងៃទី ១០ មិថុនា ១៩៦១ នៅព្រះវិហារវត្តលង្កា ក្រុងភ្នំពេញ មានការជួបជុំពុទ្ធបរិស័ទជាច្រើន ក្រោមកិច្ចចាត់ចែងនៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ ធ្វើពិធីបុណ្យប្រគេនមហាកុសលចំពោះសម្ដេចព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយកគណៈមហានិកាយ ដែលកំពុងព្យាបាលព្រះនេត្រ នៅប្រទេសបារាំង និងថ្វាយព្រះមហាកុសលចំពោះសម្ដេចព្រះប្រមុខរដ្ឋ ជាទីគោរព ជាទីស្នេហាស្មើជីវិតនៃយើង ដែលព្រះអង្គកំពុងព្យាបាលព្រះរោគ នៅប្រទេសបារាំង ព្រមទាំងទ្រង់កំពុងបំពេញព្រះរាជបេសកកម្ម នៅក្រុងហ្សឺណែវ រកសន្តិភាពជូនប្រទេសលាវ និងសាកលលោក ។

ថ្ងៃទី ១១ ខែឆ្នាំដដែល ម៉ោង ៩ ព្រឹក មានពិធីដាក់បាត្រព្រះសង្ឃ ១០០ អង្គ ចប់កិច្ចដាក់បាត្រ ព្រះសង្ឃសូត្រធ្យាយពុទ្ធជ័យមង្គលប្រសិទ្ធពរ ប្រគេន-ថ្វាយ ចំពោះសម្ដេចទាំងពីរព្រះអង្គ សូមបាន, សូមទ្រង់បានសះស្បើយព្រះរោគ និងសូមទ្រង់បានជោគជ័យមហាប្រសើរក្នុងព្រះរាជបេសកកម្មដ៏សែនលំបាកនេះ ។

ពិធីនេះបានចប់សព្វគ្រប់នៅវេលាម៉ោង ១០, ៣០ នាទីព្រឹក ។

ពុទ្ធសាសនបណ្ឌិត្យសូមចូលរួមក្នុងពិធីបុណ្យនេះ ដោយកតញ្ញុតាគុណ ។

ពុទ្ធសាសនបណ្ឌិត្យ

៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ៧ ខែកក្កដា

ព.ស. ២៥០៤ គ.ស. ១៩៦១

— ភ្នំពេញ —

P. K_1
1961_7

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា　　　　បញ្ជីរឿង　　　　ទំព័រ


- វិបាកណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា (ត) លោក ផល-ទិត្យ រៀបរៀង ៧១៣
- ពុទ្ធចរិត ថ្លែងអំពីព្រះជីវប្រវត្តិ នៃព្រះគោតម លោក គួច-គីឡេង ប្រែ . . . ៧២៥
- លោកុត្តរាភិសម័យ (ត) អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង . . ៧៣២
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក (ត) លោក ប៊ូ-ប៊ូ រៀបរៀង . . . ៧៤៥
- ខុទ្ទសាភិហារិណី (ត) សម្ដេចព្រះធម្មលិខិតស៊ូ-ឯម ប្រែ ព្រះ ញ.ឈឿង ពិនិត្យ . . ៧៥៨
- មហោសថជាតក (ត) លោកអ៊ុម-ភានចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-តួរពិនិត្យ. ៧៦៦


ផ្នែកអក្សរសាស្ត្រ


- វប្បធម៌ខ្មែរ (ត) លោក លី-ធាមតេង រៀបរៀង . . . ៧៧៧
- ពាក្យខ្មែរប្រែពីបរទេស (ត) ដោយគណៈកម្មការវប្បធម៌ . . . . . ៧៨២
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ជាំង-ខាត់ រៀបរៀង . . . ៧៨៣
- ហេតុកំណើតប្រាសាទអង្គរ (ត) លោក ហ្សេីក្វីលភូត់ រៀបរៀង ក្រមការ ជុំ-មៅ ប្រែ ៧៨៤
- រឿងសាមកុក (ត) ឧកញ៉ា នូ-ករ ប្រែ . . . . ៧៩៨
- រឿងមនុស្សចិត្តប្រែប្រួល (ត) លោក ប៊ូ-ប៊ូ រៀបរៀង . . ៨០៨
- ភូមិសាស្ត្រ សេដ្ឋកិច្ចប្រទេសជប៉ុន លោកហ្វ្រែម៉ុន រៀបរៀង លោកញ៉ែម-ទឹម ប្រែ ៨១៣
- រឿងព្រេងខ្មែរជាពណ៌ នៅវត្តជាត់ដំបង តាមឯកសារទំនៀមទម្លាប់ . . ៨២៤


ផ្នែកកំណាព្យនិងប្រវត្តិការណ៍


- ជាតិ សាសនា ព្រះមហាក្សត្រ . . . . . . . . . . . ៨២៩


ម្ភៃបន្ទាត់ មាន១២ សៀវភៅ ជំឡៀការ ២៣:៤០០

# សេចក្ដីជូនដំណឹង

កាលពីថ្ងៃទី ២២ កក្កដា ១៩៦១ សហជីវិន ស៊ុន-បុប្ផកោ រដ្ឋលេខាធិការ ក្រសួងធម្មការ, សហជីវិន ក៉យ-លុត ប្រធានពុទ្ធិកសមាគមពិភពលោក មជ្ឈមណ្ឌលក្សិភាគកម្ពុជរដ្ឋ នឹងសហជីវិន គួច-គីឡេង សាស្ត្រាចារ្យពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ជាគណៈប្រតិភូពុទ្ធសាសនានៃកម្ពុជរដ្ឋ បានធ្វើដំណើរតាមអាកាសយាន អែរប្រាង់ ឆ្ពោះទៅកាន់ប្រទេសជប៉ុន ដើម្បីនឹងចូលរួមធ្វើសន្និសីទសា-សនាពិភពលោក ដើម្បីសន្តិភាព ។

យើងសូមបញ្ជាក់ថា: សន្និសីទនេះ ចាប់ធ្វើតាំងពីថ្ងៃទី ២៣ កក្កដា រហូតដល់ថ្ងៃទី ៦ សីហា ទើបចប់ ។

ឯលទ្ធផលនៃសន្និសីទនេះ យើងនឹងចុះផ្សាយទៅលេខក្រោយ ។

ពុទ្ធសាសនបណ្ឌិត្យ

P. K - 1
1961 - 7

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |
| - វិហារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា (ត) លោក ឆល-រិត្យ រៀបរៀង | | ៧១៧ |
| - ពុទ្ធចរិត ថ្លែងអំពីព្រះជីវប្រវត្តិ នៃព្រះគោតម លោក គួច-គីឡុង ប្រែ | | ៧២៥ |
| - លោកុត្តរភិសម័យ (ត) អ្នកឧកញ៉ា ទា-សាន អតីតៈមន្ត្រី រៀបរៀង | | ៧៣២ |
| - ព្រះអភិធម្មបិដក គម្ពីរព្រះយមក (ត) លោក ប៊ូ-ប៉ូ រៀបរៀង | | ៧៤៥ |
| - ខុទ្ទសភិហារី (ត) សម្ដេចព្រះធម្មលិខិតស៊ូ-ឯម ប្រែ ព្រះ ញ.ឈឹង ពិនិត្យ | | ៧៥៨ |
| - មហោសថជាតក (ត) លោកអ៊ុម-ភានបម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-ទូរពិនិត្យ | | ៧៦៦ |

ផ្នែកអក្សរសាស្ត្រ

| | | |
| --- | --- | --- |
| - វប្បធម៌ខ្មែរ (ត) លោក លី-ធាមតេង រៀបរៀង | | ៧៧៧ |
| - ពាក្យខ្មែរប្រែពីបរទេស (ត) ដោយគណៈកម្មការវប្បធម៌ | | ៧៨២ |
| - វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង | | ៧៨៣ |
| - [illegible] (ត) [illegible] ប្រែ | | ៧៨៤ |
| - រឿងសាមកុក (ត) ឧកញ៉ា នូ-កា ប្រែ | | ៧៩៨ |
| - រឿងមហាសូបិ ប្រែប្រួល (ត) លោក ប៊ូ ប៉ូ រៀបរៀង | | ៨០៨ |
| - [illegible] រៀបរៀង ... ញ៉េម-ទឹម ... | | ៨១៣ |
| - រឿងព្រេងខ្មែរ ... តាមឯកសារទំនៀមទម្លាប់ | | ៨២៤ |

ផ្នែកសំភាសន៍និងប្រវត្តិការណ៍

| | | |
| --- | --- | --- |
| - ការិ សារបរ ព្រះបរកម្ម | | ៨២៩ |


មួយឆ្នាំ មាន ១២ សៀវភៅ [illegible]

33e Année — No 7 — Juillet 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Page

— Editorial " Les principes du Bouddhisme " ( suite ) par *M. PHAL-TITH* . . . 717
— Buddha carita traduite par *M. KUOCH-KY LENG* . . 725
— Lokkuttara Bhisamaya par L'Oknha *TEA-SANN* . . . . . 732
— Prah Abhidhamma pitaka (Kampi Prah Yamaka (suite) par *M. BOU-PO* . . . . . 745
— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita *LOUIS-EM*, revu et corrigé par Vèn. *NHÉAN-CHHOEUN* . . . . 758
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM-PHON*, revu et corrigé par Vèn. *KEM-TO* . . . . 766

### Partie littéraire

— La Culture Khmère (suite) par *M. LY-THEAM-TENG* . . 777
— Activités de la Commission Culturelle (suite) . . . . . . . . . . 782
— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 783
— Origine d'Angkor par Louis Finot traduite par *M. CHUM-MAU* 784
— Histoire de Sam-Kok (suite) traduite par Oknha *NOU-KAN* . . . . . . 798
— L'homme au coeur changeant (suite) par *M. BOU-PO* . . . . . . 808
— Géographie économique du Japon par *M. ROSEMBERT* professeur de la Faculté de droit traduite par *M. NHEM-KHEM* . 817
— Histoirè de Phnom Banan à Battambang . . . . . . . 824

### Notes et chroniques

— La Nation - la Religion et la Royauté . . . . . . 829

Prix d'abonnement annuel (comprenant 12 numéros): 23o|oo

ផ្នែកសាសនា

វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

(តមក)

លោក ជល ធិត្យ នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ព្រះមុនីកោសល ស្វូរ ហាយ ពិនិត្យ

---

–ចុះព្រះអរិយបុគ្គល លោកមានរូបកាយ មាន មនោ-ចិត្ត-វិញ្ញាណ ដូចយើងគ្រប់គ្នាដែរឬទេ ?

– មានដូចគ្នាទាំងអស់ ឥតមានខុសគ្នាអ្វីបន្តិចបន្តួចឡើយ ។

– បើមានដូចគ្នា ហេតុអ្វីក៏បានជានិយាយថា ព្រះអរិយបុគ្គលស្លាប់ហើយលែងកើតទៀត ? ប្រសិនជាលែងកើតដូច្នោះមែន យើងរាល់គ្នាក៏លែងកើតទៀតដែរ ព្រោះវាជាតែគប ?

– មានដូចគ្នាមែន ប៉ុន្តែ វាមានសេចក្តីពិសេសខ្លះ ដែលអនុញ្ញាតលោកមិនឲ្យកើតទៀត ដូចខ្ញុំអធិប្បាយតទៅនេះ –

មែនពិត ក្នុងសាសនានេះ លោកបានសំដែងទុកថា មនុស្សសត្វដែលកើតហើយស្លាប់ទៅវិញ ស្លាប់ហើយកើតមកវិញ មិនឈប់ឈរ ព្រោះមានធម៌ ៤ យ៉ាង នៅព័ទ្ធកំបាំងទុក ។ ធម៌ ៤ យ៉ាងនោះ គឺ កម្ម ១ វិញ្ញាណ ១ តណ្ហា ១ អវិជ្ជា ១ ។ លោកបាន

ប្រៀបទុកថា កម្មំ ខេត្តំ, វិញ្ញាណំ ពីជំ, តណ្ហា សិនេហំ,
អវិជ្ជា មរិយាទំ; កម្ម ទុកដូចជាស្រែ, វិញ្ញាណ ទុកដូចជា
ពូជ, តណ្ហា ទុកដូចជាទឹក, អវិជ្ជា ទុកដូចជាភ្លឺស្រែ ។ ធម្មតាស្រែ
សន្ទូន, ពួកកសិករតែងធ្វើភ្លឺស្រែព័ទ្ធជុំវិញ សម្រាប់ទប់ទឹកកុំឲ្យហូរចេញ
គេក្រដីឲ្យល្អ ហើយយកស្រូវពូជទៅសាបព្រោះ ។ កាលធ្វើយ៉ាងនេះហើយ
ស្រូវពូជនោះ ក៏ចាប់ផ្ដើមចេញពន្លកដុះឡើង យ៉ាងណាមិញ, មនុស្ស
សត្វទាំងអស់ មានអវិជ្ជានៅព័ទ្ធជុំវិញពាំងមិនឲ្យតណ្ហាហូរចេញក្រៅ
រូបវិញ្ញាណ (មនោ-ចិត្ត) ក៏ចាប់ផ្ដុចដុះឡើងនៅលើកម្មដែលជាទីកន្លែង
ឲ្យកើត ក៏យ៉ាងនោះដែរ ។ ស្រែសន្ទូន ដែលអាចនឹងបណ្ដុះស្រូវពូជ
ឲ្យដុះឡើងបាននោះ លុះតែមានទឹកដក់នៅសើមគ្រប់គ្រាន់, ឯទឹក ដែល
នឹងអាចស្ដុកដក់នៅបានក្នុងស្រែនោះ ក៏ដោយសារមានភ្លឺស្រែនៅឃាំង
ទប់ដែរ យ៉ាងណាមិញ, កម្ម ដែលអាចនឹងបណ្ដុះវិញ្ញាណ (មនោ-ចិត្ត)
ឲ្យកើតឡើងបានទៀតនោះ លុះណាតែមានតណ្ហាជាគ្រឿងស្រោចគ្រប់គ្រាន់,
ឯតណ្ហា ដែលនឹងអាចនៅជាប់នឹងកម្មនោះ ក៏ដោយសារមានអវិជ្ជាជាទំ-
នប់ព័ទ្ធពាំងទុកមិនឲ្យហូរចេញពីកម្មបាន ក៏យ៉ាងនោះដែរ ។ ចំណែកព្រះអរិ-
យបុគ្គល លោកបានកាប់ទំលាយអវិជ្ជាឲ្យធ្លាយ ហើយបង្ហូរទឹកគឺតណ្ហា
ឲ្យចេញអស់ពីស្រែគឺ កម្ម ។ ដូច្នេះ កម្មក៏រីងស្ងួតហួតហែង លែងឲ្យ
ស្រូវពូជគឺ វិញ្ញាណ (មនោ-ចិត្ត) នោះ អាចដុះដាលកើតឡើងបាន

ទៀយ ៗ ហេតុនេះហើយ បានជាលោកលែងទៅកើតក្នុងភពថ្មីទៀត ៗ ពាក្យប្រៀបធៀបដែលនាំមកនេះ ជាសេចក្ដីល្មមស្ដាប់បានខ្លះហើយ, ដូច្នេះ ខ្ញុំនឹងអធិប្បាយធម៌ទាំង ៤ យ៉ាងនេះតទៅទៀត ដើម្បីបញ្ជាក់ឲ្យឃើញថា តើន័យរបស់ពាក្យថា កម្ម, វិញ្ញាណ, តណ្ហា, អវិជ្ជា, នេះ យ៉ាងណា បានជាមានអានុភាពឲ្យមនុស្សសត្វ ស្លាប់កើត ៗ គ្មានទីបំផុតនោះ?

កម្ម នេះ បើនឹងប្លាប់ប្រែថា " អំពើ " ខ្លះប្រែថា " ការងារ " ខ្លះ ៗ ប៉ុន្តែពាក្យថា " អំពើ " ខ្មែរច្រើនប្រើដោយន័យថា " ការ-ប្រើមន្តអាគម " ៗ ឯពាក្យថា " ការងារ " វិញ ក៏យើងច្រើននិយាយចំពោះកិច្ចការដែលមានមុខ ដូចជាការងារស្រែ ការងារចំការ ការងារជំនួញ ការងារលើសែងជាដើម ៗ បើពិនិត្យទៅឃើញថា ពាក្យប្រែទាំងពីរបែបនេះ មានន័យមិនទាន់ស្មើនឹងពាក្យថា កម្ម ពេញលេញទេ ព្រោះពាក្យថា កម្ម នេះ វាជាដំណើរកើតចេញមកអំពី វិញ្ញត្តិ ដែលប្រែថាការកំរើក ៗ វិញ្ញត្តិ គឺការកំរើក ដែលជាដំណើរបង្ករបង្កើតឲ្យទៅជាកម្មនេះ ក្នុងមហាដីកា លោកចែកជា ៣ យ៉ាង គឺកាយវិញ្ញត្តិ ១ វចីវិញ្ញត្តិ ១ មនោវិញ្ញត្តិ ១ ៗ កាយវិញ្ញត្តិ បានខាងការកំរើកកាយ ដូចជាលើកដៃ - ជើង ដើរ អង្គុយ ឈរ ឈ្ងោក ងើប ផ្ងាកជាដើម ដែលជាដំណើរឲ្យកើតទៅជាកាយកម្ម ៗ វចីវិញ្ញត្តិ បានខាងការកំរើក

វាចា គឺការបញ្ចេញពាក្យ សំដី និយាយ ស្រែក ហៅជាដើម ដែលជាដំណើរឲ្យកើតទៅជាវចីកម្ម ៗ ឯមនោវិញ្ញត្តិ បានខាងការកំរើកចិត្ត គឺសំដៅយកការនឹកគិតតាមផ្លូវចិត្ត ដែលជាដំណើរឲ្យកើតទៅជាមនោកម្ម។ ការកំរើកទាំងនេះ ដែលរាប់ថាជាដំណើរឲ្យកើតទៅជាកម្មនោះ ព្រោះថាការងារអ្វីមួយ ទោះល្អក្តី អាក្រក់ក្តី ដែលគេត្រូវធ្វើ ក៏គេតែងអាស្រ័យការកំរើកខ្លួន កំរើកពាក្យសំដីនឹងកំរើកចិត្តជាមុនដែរ ទើបសម្រេចទៅជាការងារនោះ ៗ ឧទាហរណ៍ដូចជា ការលួចប្លន់គេដែលរាប់ថា ជាកម្មអាក្រក់ ( បាបកម្ម ឬ អកុសលកម្ម ) ប្រសិនបើយើងនៅស្ងៀម ឥតមានកំរើកខ្លួន ឬប្រើពាក្យសំដី ឬក៏នឹកគិតអ្វីសោះ តើនឹងហៅថា យើងបានទៅលួចប្លន់គេឬទេ ? បើតាមពិត លុះណាតែយើងបានកំរើក គឺឈានជើង លូកដៃ លួចឆក់ប្រទាញប្រទង់ ឬចេញពាក្យសំដីនិយាយសំឡុតបង្ខំ ដោយមានបំណងគំនិតអាក្រក់ដូច្នោះផង ទើបហៅថា យើងបានលួចប្លន់គេមែន ៗ រួមសេចក្តីមកថា ដែលហៅថា កម្ម មិនមែនសំដៅយកត្រឹមតែប្រើមន្តអាគម ឬត្រឹមតែកិច្ចការមានមុខប៉ុណ្ណោះឡើយ គឺសំដៅយកការធ្វើគ្រប់ចលនាទូទៅទាំងអស់ ៗ ចុះបើកម្មៈកើតចេញមកពីវិញ្ញត្តិ គឺចលនាយ៉ាងនេះ តើពួកអវិញ្ញាណកសង្ខារ ដូចជាពួករុក្ខជាតិជាដើម មាន កម្ម ដែរឬទេ ព្រោះមានការកំរើកដែរ?

រឿងនេះ យើងអាចវែកញែកបានថា ពួករុក្ខជាតិមិនមាន កម្ម

ទេ ព្រោះថា ពិតមែនតែវាចេះកំរើក ប៉ុន្តែ ការកំរើករបស់វា កើតឡើងដោយសារតែហេតុខាងក្រៅមកធ្វើវា ដូចជាខ្យល់បោក ឬមនុស្សអង្រួនជាដើម វាមិនចេះកំរើកដោយខ្លួនវាឡើយ ។ ឯមនុស្សសត្វវិញមិនដូចរុក្ខជាតិទេ គឺវាចេះកំរើកដៃ ជើង ឈរ អង្គុយ ដើរ ដេក ជាដើមគ្រប់បែប តាមទំនើងខ្លួនឯង ។ ដូច្នេះ បានសេចក្តីថា ការកំរើកនោះ ពិតមែនតែក៏ជាដំណើរឲ្យកើតទៅជាកម្ម ប៉ុន្តែ លុះត្រាណា វាមានចិត្ត ( មនោ - វិញ្ញាណ ) នៅបង្គាប់បញ្ជាផង, ប្រសិនបើគ្មានចិត្តនៅបង្គាប់ទេ ការកំរើកនោះ ក៏វាមិនមែនជាដំណើរឲ្យកើតទៅជាកម្មបានដែរ ។ កាលបើយ៉ាងនេះ យើងអាចចែកការកំរើកជា ២ យ៉ាងគឺ ១- ការកំរើករបស់អវិញ្ញាណកសង្ខារ, ២- ការកំរើករបស់សវិញ្ញាណកសង្ខារ ។

ការកំរើករបស់អវិញ្ញាណកសង្ខារ មិនអាចឲ្យកើតទៅកម្មបានទេ ព្រោះវាមិនមែនកំរើកតាមទំនើងខ្លួនឯង គឺវាគ្មានមនោ - ចិត្ត - វិញ្ញាណ នៅបង្គាប់បញ្ជាឲ្យកំរើក, ឯការកំរើករបស់សវិញ្ញាណកសង្ខារវិញ ទើបអាចបង្កើតទៅជាកម្មបាន ព្រោះវាអាចកំរើកបានតាមទំនើងខ្លួនឯង គឺវាមានមនោ-ចិត្ត-វិញ្ញាណ នៅបង្គាប់បញ្ជាឲ្យកំរើក ។ ប៉ុន្តែ ការកំរើករបស់សវិញ្ញាណកសង្ខារ គឺមនុស្សសត្វនេះ យើងអាចចែកជា ២ យ៉ាងទៀត គឺកំរើកដោយមានចិត្ត ( មនោ-វិញ្ញាណ ) បង្គាប់បញ្ជា ( ដឹងខ្លួន ) និងកំរើកដោយមិនមានចិត្ត (មនោ-វិញ្ញាណ) បង្គាប់បញ្ជា (មិនដឹងខ្លួន) ។

ក- ការកំរើកណា ដែលមានចិត្តគិតអាក្រក់ ទីងចិត្តគិតល្អនៅបន្ទាប់បញ្ហាផង, ការកំរើកនោះ ទើបអាចបង្កើតទៅជា កម្ម បាន ។ ផ្នែកខាងចិត្តគិតអាក្រក់, ដូចជាចោរ ដែលមានចិត្តប្រឹងនឹងលួចទ្រព្យរបស់គេ, កាលដែលវាឃើញសម្បត្តិទ្រព្យគេហើយ វាក៏ងាកខ្លួន ឈានជើង លើកដៃ ដោយបំណងនឹងឆក់ទាញលួចទ្រព្យសម្បត្តិគេនោះ ។ លោកបញ្ជាក់ប្រាប់ថា ការកំរើករបស់វាគ្រប់បែបនេះ ហៅថា កម្មអាក្រក់ (អកុសលកម្ម) ទាំងអស់ គឺត្រង់ការលើកដៃ ក៏ជាកម្មអាក្រក់, ត្រង់ការឈានជើង ក៏ជាកម្មអាក្រក់, ត្រង់ការងាកខ្លួន ក៏ជាកម្មអាក្រក់, អាក្រក់ទាំងអស់ ។ ផ្នែកខាងល្អវិញ ដូចជា យើងចង់ទៅវត្តដើម្បីស្មាទានសីល, កាលយើងដើរទៅ ហើយថ្វាយបង្គំព្រះសង្ឃ សូត្រធម៌ស្មាទានសីល លោកបញ្ជាក់ប្រាប់ថា ការកំរើករបស់យើងទាំងអស់ សុទ្ធតែជា កម្មល្អ (កុសលកម្ម) គឺឈានជើងដើរទៅ ក៏ជាកម្មល្អ, លើកដៃថ្វាយបង្គំក៏ជាកម្មល្អ ហាមាត់បញ្ចេញសូត្រធម៌ក៏ជាកម្មល្អ, ល្អទាំងអស់ ។

ខ- ការកំរើកណា ដែលគ្មានចិត្តគិតល្អ, ឬចិត្តគិតអាក្រក់នៅបន្ទាប់បញ្ហាទេ ដូចជាមនុស្សដេកលក់ បម្រះខ្លួន ប្រែខ្លួន លើកដៃ ឬលើកជើងដាក់ទៅលើនេះទៅលើនោះជាដើម, ការកំរើកនោះ មិនឲ្យកើតទៅជា កម្ម បានទេ ។

-តើព្រះអរិយបុគ្គល លោកមាន កម្ម ដែរឬទេ ?

- លោកមិនមានកម្មទេ ។

- តើលោកនេះកំកើតដែរឬ ឬក៏ដូចជាដុំថ្ម ?

- មិនមែនដូចជាដុំថ្មទេ គឺលោកនេះកំកើតដែរ ។

- លោកកំកើតដោយមានចិត្ត (មនោ-វិញ្ញាណ) នៅបង្គាប់បញ្ជាដែរឬ ? ឬក៏កំកើតដោយឥតមានចិត្តនៅបង្គាប់បញ្ជាទេ ?

- លោកកំកើតដោយមានចិត្ត (មនោ-វិញ្ញាណ) នៅបង្គាប់បញ្ជាដូចជាយើងគ្រប់គ្នាដែរ ។

- បើដូច្នោះ ហេតុអ្វីក៏និយាយថា ព្រះអាទិទេពគ្មានកាម្ម បើលោកនេះកំកើតដោយមានចិត្តបង្គាប់បញ្ជាដូចយើងដែរ ?

- រឿងនេះហើយ ដែលជាបញ្ហាផ្ទាល់ខ្លួនសម្រាប់មនុស្សគ្រប់ប្រភេទ ដោះស្រាយក្រោមទង់សាសនានៃព្រះពុទ្ធជាម្ចាស់ ។ ព្រោះថា ពិភពលោកដែលនេះតែវិនាសទៅដោយការចាស់ ឈឺ ស្លាប់ ដែលមានការកើត (ជាតិ) ជាប្រភពនេះ, មនុស្សទាំងឡាយ នាំគ្នាភ័យព្រួយរកប្រកែកខ្លួនឲ្យផុតពីការវិនាសទាំងនោះគ្រប់ ៗ គ្នា ម៉្លោះហើយ ក៏ខំប្រឹងស្រាវជ្រាវរកទ្រឹស្តីពិតប្រាកដមកអនុវត្ត ដើម្បីរំលត់សេចក្តីទុក្ខទាំងនោះ ។ បំណែកខាងព្រះពុទ្ធបរមគ្រូ ក៏ទ្រង់ប្រកាសសាសនាឡើងក្នុងពិភពលោកដែរ, សាសនានោះ គឺព្រះអង្គទ្រង់លើកយក កាម្ម ជាគួសំខាន់បំផុត ព្រោះព្រះអង្គទ្រង់បញ្ជាក់ដោយអះអាងថា " ពិភពលោកនេះ មានកម្ម

ជារបស់ខ្លួន ( កម្មស្សកោ ) មានកម្មជាមរតក ( កម្មទាយាទោ ) មាន កម្មជាអ្នកបង្កើត ( កម្មយោនិ ) មានកម្មជាផៅពង្ស (កម្មពន្ធុ) មានកម្មជា ពំនឹង ( កម្មប្បដិសរណា ) " រួចទ្រង់បញ្ជាក់បន្ថែមទៀតថា " យើង ត្រូវតែទទួលផលនៃកម្មដែលយើងធ្វើហើយ ជាការចៀសមិនរួច " ។ ដូច្នេះ យើងអាចនិយាយថា ពុទ្ធសាសនា ជាកម្មនិយមក៏បាន ព្រោះ នៅគ្រប់ទំព័រព្រះត្រៃបិដក យើងពិនិត្យឃើញថា សុទ្ធតែជាព្រះពុទ្ធដីកា ប្រដៅឲ្យជឿ កម្ម នឹង ផលនៃកម្ម ទាំងអស់ ។ បើពិតដូច្នេះ ហើយបានជាព្រះពុទ្ធសាសនា ទូន្មានមនុស្សឲ្យខ្លាចកម្ម នឹងឲ្យប្រយ័ត្ន កម្មនេះជាទីបំផុត ទោះបីកម្មនោះតិចតួចយ៉ាងណាក៏ដោយ ។ ការពិនិត្យ កម្មនេះជាជំហានទីមួយដែលអាចធ្វើឲ្យមនុស្សលែងកើត - ស្លាប់ទៀតបាន ព្រោះថា កាលបើអ្នកណាមួយបានពិនិត្យមើលកម្មនេះម៉ត់ចត់ហើយអ្នក នោះ ក៏ប្រឹងសម្រិតសម្រាំងធ្វើតែកម្មណាដែលល្អ ដែលត្រឹមត្រូវ ។ លុះហាត់ធ្វើតែកម្មល្អនេះយូរ ៗ ទៅ និស្ស័យល្អយ៉ាងរឹងប៉ឹងក៏កើតឡើង គឺពេញចិត្តតែកម្មល្អ ស្អប់ខ្ពើម ខ្លាចរអែង ចំពោះកម្មអាក្រក់គ្រប់បែប ។ កាលបើវៀរចាកកម្មអាក្រក់នេះ បានដាច់ស្រឡះហើយ អ្នកនោះ ក៏មានតែការធ្វើកម្មល្អម្យ៉ាង រួចក្រោយមក ក៏ខំប្រឹងលះកម្មល្អនោះ

(នៅមានត)

# ពុទ្ធចរិតៈ

## រឿងពីព្រះជីវប្រវត្តិនៃព្រះគោតម

លោកគួច-គីឡេង

ប្រែរៀបរៀង

---

ពុទ្ធចរិតៈនេះ ជាគម្ពីរមួយដ៏បរមបុរាណណាស់ក្នុងភាសាសំស្ក្រឹត ដែលថែងអំពីជីវប្រវត្តិនៃព្រះសមណគោតមបរមសម្ពុទ្ធ ។ គេបានរៀបរៀងបង្ក្រងឡើងនៅពេលខាងដើមនៃគ្រិស្តសករាជ ។ អ្នកដែលបានរៀបរៀងឡើងនោះគឺអស្វឃោសៈ ដែលគេអាចសន្និដ្ឋានបានថា ជាអ្នកប្រាជ្ញមួយរូបដ៏ជំនាញ ខាងផ្នែកអក្សរសាស្ត្រនិងជាទស្សនវិទូដ៏ឆើត ។ អ្នកប្រាជ្ញរូបនេះ ខ្មែរស្ទើរតែគ្រប់រូបទាំងបព្វជិតទាំងគ្រហស្ថ ដែលបានក្រេបជញ្ជាក់ហើយនូវព្រះសទ្ធម្មបានស្គាល់នាមដោយច្បាស់លាស់ ។ តាមដំណឹងតៗគ្នាមកថា អស្វឃោសៈបានកើតក្នុងត្រកូលព្រាហ្មណ៍ ហើយក៏កាន់សាសនាព្រាហ្មណ៍រហូតមក, តែដល់ក្រោយមក ក៏ត្រឡប់ទៅជាពុទ្ធ-សាសនិកទៅវិញ ។ មិនគ្រាន់តែជឿព្រះពុទ្ធសាសនាប៉ុណ្ណោះ ថែមទាំងខ្នៃខ្នងឲ្យបានទៅជាអ្នកប្រាជ្ញមួយរូបដ៏ឆ្នើម ក្នុងចំណោមពុទ្ធសាស-និកជនក្នុងសម័យនោះ ។ បណ្ឌិតរូបនេះ បានទទួលឋានៈជាអ្នកនិពន្ធ (author) ផ្នែកខាងនាដកសាស្ត្រ (Drama) ជាពាក្យកាព្យឃ្លោងជាភា-សាសំស្ក្រឹត ដែលបើយើងរើសយក សុត្តន្តប្រើជាឧន្ទ នៃប្រទេស

កម្ពុជា, ស្ហេកស្ពៀរ (Shakespeare) នៃប្រទេសអង់គ្លេស, ករណីយ៍ (Corneille) ឬ រ៉ាស៊ីន (Racine) នៃប្រទេសបារាំង, របិន្ទ្រនាថតាគរ (Rabindranath Tagore) ឬ វ៉ាល្មិគី (Valmiki) នៃប្រទេសឥណ្ឌា មកប្រៀបក៏នៅតែមិនទាន់ស្មើ ។

តាមច្បាប់ដើមនៅប្រទេសឥណ្ឌា ពុទ្ធចរិតៈមាន ២៨ គាថា ប៉ុន្តែឥឡូវនេះនៅសល់តែ ១៧ គាថាទេ ។ ក្នុងបណ្តាគាថាទាំង ១៧ នេះ អ្នកប្រាជ្ញខ្លះមានយោបល់ថា គាថាពីទី ១ ដល់ទី ១៣ ជាគាថារៀបរៀងឡើងដោយស្នាដៃអស្វឃោសៈ ។ រីឯគាថាដទៃពីនេះ កវីនិពន្ធជាតិនេប៉ាល់ឈ្មោះ អម្ឫតានន្ទ បានបន្ថែមកាលពីឆ្នាំ ១៨៣០ នៃគ្រិស្តសករាជ ។ អម្ឫតានន្ទ ដែលបានធ្វើបំពេញឡើងនេះ ដោយលោករកទៅពុំឃើញនូវចំនួនគាថាដែលអស្វឃោសៈបានតែងទុកនោះ ។

តទៅនេះតាំងពីគាថា (Canto) ទី ១ ដល់ទី ១៣ និងខាងដើមគាថាទី ១៤ ដែលមានចំនួនទាំងអស់ ១០៣៣ ព្យាង្គ (Verses) ជាការងារដែលធ្វើដោយអស្វឃោសៈ ។ ព្យាង្គទាំងនេះចប់ត្រង់ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់បានទទួលសព្វញ្ញុតញ្ញាណក្រោមដើមពោធិព្រឹក្ស ។ របៀបតែង (style) នៃពាក្យកាព្យនេះមានរលកល្អណាស់ ។ ពាក្យកាព្យដែលជាសេចក្តីបន្ថែមរបស់អម្ឫតានន្ទនោះ មានអត្ថាធិប្បាយតាំងពីពេលដែលព្រះអង្គទ្រង់សំដែងព្រះធម្មចក្កប្បវត្តនសូត្រ នៅឥសិបតនមិគទា-

យវ៉ែន នាក្រុងពាកណាសី ។

អត្ថបទ (text) ទាំងនេះ គេបានប្រែទៅជាភាសាចិន ក្នុងសតវត្សរ៍ទី ៥ និងទៅជាភាសាទីបេត៍ ក្នុងសតវត្សរ៍ទី ៧ និង ៨ នៃគ្រិស្តសករាជ ។ ការរៀបរៀង (Composition) របស់អស្វឃោសៈបានបង្ហាញឲ្យឃើញថា លោកបានដឹងដោយហ្មត់ចត់នូវរឿងរាមាយនៈ (រាមកេរ្តិ៍) និងមហាភារតៈ ។ រីឯកាលិទាសៈ ដែលជាអ្នករៀបរៀងរាមាយនៈក្នុងសតវត្សរ៍ទី ៥ វិញ ក៏បានចម្លងបែបផែន របស់អស្វឃោសៈជាច្រើនដែរ ។

គាថាទី ១– ព្រះវរមាតានៃព្រះសិទ្ធត្ថកុមារនាមមហាមាយាទេវី បានប្រសូតបុត្រនូវឧទ្យានលុម្ពិនីខាងក្រៅទីក្រុងកបិលវត្ថុ ជាទីដែលព្រះបាទសិរីសុទ្ធោទនៈទ្រង់សោយរាជ្យ ។ ព្រះរាជបុត្រទ្រង់ប្រសូតចេញអំពីគភ៌នៃព្រះមាតាតាមជ្រុងខាងស្តាំនៃផ្ទៃ ហើយទ្រង់យាងបាន ៧ ជំហាន ព្រះរាជបុត្រមានព្រះទ័យរីករាយងាកទតទិសទាំង ៤ ហើយទ្រង់បន្លឺនូវវាចាថា: អញកើតមកនេះ គឺដើម្បីស្វែងរកសម្ពោធិញ្ញាណ ដើម្បីជាប្រយោជន៍ដល់សត្វលោក, ការកើតម្តងនេះជាទីបំផុតហើយ ។ ផែនដីក៏ញាប់ញ័រមួយរំពេច ហើយផ្កាធ្លាក់ដូចជាទឹកភ្លៀងមកពីកន្លែងដែលទេវតាគ្រប់ឋានៈទ្រង់ប្រជុំគ្នា ។

មានឥសីចាស់ម្នាក់ឈ្មោះអសិតៈ និមន្តមកព្រះបរមរាជវាំង ដោយ

មានបំណងចង់ឃើញព្រះរាជបុត្រដែលទើបនឹងប្រសូត ៗ លុះឃើញហើយក៏យំ ដោយហេតុថាខ្លួននឹងពុំអាចមានជីវិតរស់នៅដរាបដល់ពេលដែលព្រះរាជបុត្របានទទួលសម្មោធិញ្ញាណជាធម៌ អាចញ៉ាំងសត្វលោកឲ្យផុតចាកទុក្ខទាំងពួងបាន ។ គង់កាលនោះ តាបសក៏បាត់ពីនោះទៅ ៗ

គាថាទី ២:– ដោយព្រះនាងមានសេចក្ដីត្រេកអរសប្បាយពេកនឹងកំណើតនៃបុត្ររបស់ព្រះនាង ដែលនឹងត្រូវបានទៅជាឥត្ដបុរសដល់ម្ល៉ោះ ព្រះវរមាតាក៏ទិវង្គតទៅ ៗ រីឯទារកក៏ត្រូវធ្លាក់ទៅលើដៃព្រះនាងបជាបតិគោតមីដែលជាប្អូនបង្កើតនៃព្រះមហាមាយាទេវី ហើយដែលជាអគ្គមហេសីទី ២ នៃព្រះមហាក្សត្រផង ឲ្យចិញ្ចឹមបីបាច់ថែរក្សា ៗ

លុះដល់ធំតាមលំដាប់ឡើង សិទ្ធត្ថកុមារក៏បានរេះដឹងវិជ្ជាគ្រប់បែបគ្រប់យ៉ាងដោយរួសរាន់ ដែលជាវិជ្ជាពុំអាចនឹងមានបុគ្គលណាមួយសិក្សាបានដោយងាយ ៗ ដោយសេចក្ដីខ្លាចព្រោះហោរាទាយថា ព្រះរាជបុត្រនឹងចេញចាកលោកទៅសាងព្រះផ្នួស ព្រះវរបិតាទ្រង់រៀបអាពាហ៍ពិពាហ៍ឲ្យទ្រង់គង់ជន្មាយុ ១៦ ឆ្នាំ ជាមួយនឹងបវរកញ្ញាម្នាក់នាមយសោធរា ដែលជានារីប្រកបដោយសោភណភាព នឹងឧត្ដមគតិដំណើតគង់កាលៈទេសៈនោះ ៗ ព្រះពៅផែនដីទ្រង់សព្វព្រះរាជហឫទ័យ ឲ្យចាត់ចែងរៀបចំផែនការ ឲ្យមានកញ្ញាជាច្រើនដែលប៉ុនប្រសប់ខាងឆ្លក់ចិត្តប្រុស ឲ្យនៅចោមរោមព្រះរាជបុត្រជាអចិន្ត្រៃយ៍ ហើយឲ្យកែខៃធ្វើដូចម្ដេចឲ្យខាងតែ

ព្រះរាជបុត្រសព្វព្រះរាជហឫទ័យនឹងកាមគុណ ។ ព្រះនរបតីទ្រង់បញ្ជាឲ្យគេរៀបចំព្រះរាជនិវេសន៍នៅតែក្នុងទីស្អាតបាតប្រសើរវិសេស កុំឲ្យមានគ្រឿងអ្វីដែលនាំឲ្យសៅហ្មងចិត្តព្រះរាជបុត្រ ។ បំណោរបីកាលតមក ព្រះសិទ្ធត្ថកុមារទ្រង់មានព្រះរាជបុត្រមួយនាមរាហុល ។

គាថាទី ៣: កាលដែលព្រះសិទ្ធត្ថគោតម ស្តេចយាងចេញតាមព្រះរាជវាំងទៅប្រពាតព្រះបរមឧទ្យានខាងក្រៅទីក្រុង ទេវតាបាននិម្មិតខ្លួនធ្វើជាមនុស្សចាស់ (ជរា) មនុស្សឈឺ (ព្យាធិ) នឹងមនុស្សស្លាប់ (មរណ:) នៅទីចំពោះព្រះភក្ត្រព្រះអង្គ ។ ដោយពុំធ្លាប់ឃើញអាការ:ដ៏ចំឡែកដូច្នេះ ព្រះសិទ្ធត្ថក៏សួរនាយសារថីក្លាម ។ លុះបានជ្រាបថាបុគ្គលគ្រប់រូបក្នុងលោក ត្រូវតែទទួលជរា, ព្យាធិ, នឹងមរណ:តាមលំដាប់វេនគ្នាដូច្នេះហើយ ព្រះសិទ្ធត្ថទ្រង់ព្រួយព្រះទ័យជាខ្លាំងឥតឧបមា ។ ព្រះភក្ត្រព្រះអង្គស្រពោនជានិច្ច ហើយទ្រង់ត្រិះរិះតែក្នុងព្រះទ័យថា: ម៉េចក៏គេចេះតែនៅសុខស្រួលជាមួយនឹងសេចក្តីស្លាប់ឯចឹង ម៉េចក៏មិនរកផ្លូវចេញឲ្យរួច ។

គាថាទី ៤:- ពេលដែលព្រះអង្គទ្រង់ស្រពោនព្រះទ័យណាស់ពេកនោះ ពួកបវរកញ្ញាបានទំប្រឹងប្រែងឧបាយកលមាយាជាច្រើនបែប ដើម្បីនឹងស្ងប់ព្រះទ័យព្រះអង្គឲ្យជាប់នឹងសន្ទុះពោលគឺសោភណភាពរបស់នាង ប៉ុន្តែព្រះអង្គត្រឡប់ទៅជាបុគ្គលរឹងរឹតតែស្ងឹងស្ងាត់ទៅវិញ ។ ការល្បួង

លួងលោមទាំងប៉ុន្មានហើយហោនោះ ត្រឡប់ទៅជាមោឃៈទាំងអស់ ។ ចំណែកខាងមិត្តភក្តិដែលនៅអមព្រះអង្គ ក៏បានជួយរំលឹកព្រះអង្គដែរ ប៉ុន្តែទ្រង់មិនយល់ស្របតាម ត្រឡប់ជាប្រកាសប្រាប់ដូច្នេះទៅវិញថាៈ

ចិត្តរបស់ខ្ញុំផុតជាប់ពីសុខកាមារម្មណ៍ប្រកប ដោយរស្សខណលក្ខណៈ (លក្ខណៈមានខណៈខ្លី ។) តាំងនេះហើយ ។

គាថាទី ៥ ក្នុងសម័យថ្ងៃមួយព្រះគោតមស្ដេចទ្រង់យាងចេញជាមួយនឹងសហជីវិនរបស់ព្រះអង្គទៅខាងក្រៅ ដើម្បីកំសាន្តក្នុងព្រៃព្រឹក្សា ស្រាប់តែព្រះអង្គយាងគេចចេញពីគេ ហើយយាងទៅរកកន្លែងស្ងាត់មួយដើម្បីធ្វើសមាធិ ។ ព្រះអង្គទ្រង់គង់ក្រោមដើមព្រីងហើយទ្រង់ពិសោធចិត្តរបស់ខ្លួនឯងមើល ។ ចក្ខុសម្ផស្ស (vision) ជាភេទអ្នកបួសបានកើតប្រាកដឡើងចំពោះព្រះភក្ត្រព្រះអង្គ ហើយក៏វិនាសបាត់ទៅវិញទៅ ។ ព្រះអង្គក៏សួរខ្លួនឯងថាៈ អ្នកបួសមានសភាពបែបនេះហើយមើលទៅ ដែលអាចញ៉ាំងខ្លួនឲ្យរួចចាកទុក្ខពីវដ្ដសង្សារបាន ។ ការឃើញរូបអ្នកបួសនេះបានតែបំណាក់ព្រះទ័យព្រះអង្គឲ្យតែតែនឿយណាយឡើង ៗ ពីសម្ភារនិយម (matérialisme) ។ លុះដល់វេលាត្រឡប់មកព្រះរាជវាំងវិញហើយ ទ្រង់សុំព្រះបរមរាជានុញ្ញាតអំពីព្រះវរបិតាដើម្បីសាងព្រះផ្នួស ។ ព្រះចៅសុទ្ធោទនៈព្រះអង្គពុំបានយល់ស្របតាមទេ តែថាពុំអាចនឹងញ៉ាំង

ព្រះទ័យព្រះរាជបុត្រឲ្យយល់តាមខ្លួនបានដែរ ។ ចំណែកខាងពិធីរៀបចំបរិកេញ្ញាក៏កាន់តែកើនឡើង ៗ ជាលំដាប់ ។ សម័យយប់មួយ ពពួកទេព្តាក៏និម្មិតធ្វើឲ្យបរិកេញ្ញាទាំងនោះពុលដោយថ្នាំងងុយ ដេកតាំងពីពេលព្រលប់ ។ ដេកហើយនាងខ្លះអាក្រាត, ខ្លះបួរ, ខ្លះស្រគៀតធ្មេញ, ខ្លះហៀរទឹកមាត់ ។ ព្រះអង្គឃើញហើយទ្រង់នឿយណាយឥតឧបមា ទាល់តែតាំងអធិដ្ឋានចិត្តថា នឹងយាងទៅសាងអភិនិស្រ្កមណ៍ជាប្រាកដក្នុងរាត្រីនោះ ។ ព្រះអង្គដាស់ឆន្នអមាត្យឲ្យរៀបចំសេះដែលជាទីពេញព្រះទ័យព្រះអង្គ ។ សេះកណ្ឋកៈឥតទ្រួលទានដំណេកទេក្នុងយប់នោះ ។ ពួកទេព្តាបានបើកទ្វារប្រាសាទជាស្រេចថ្វាយព្រះអង្គ ។ ក៏បរសេះចេញទៅទាំងអាល័យដោយមានឆន្នអមាត្យជាសហជីវិន ។ ពួកទេព្តាបានទ្រជើងសេះទាំង ៤ ដោយមធ្យ័តដើម្បីកុំឲ្យឮសូរក្រែងភ្ញាក់អស់ពួកព្រះរាជបរិពារ ។ ពេលកំពុងយាងចេញទៅព្រះសិទ្ធត្ថទ្រង់ប្រកាសថាៈ—

ដរាបណាអញពុំបានទទួលជ័យជំនះក្នុងការរំលត់ជាតិ (ការកើត) និងមរណៈ (ការស្លាប់) ទេ ដរាបណោះ អញនឹងមិនបានវិលត្រឡប់មកកាន់រាជធានីវិញឡើយ ។

(នៅមានត)

## ភាគទី ១

# សមុដ្ឋាននៃការត្រាស់ដឹងលោកុត្តរធម៌

អ្នកឧកញ៉ា ធា·សាឆ អតីតរដ្ឋមន្ត្រី រៀបរៀង

(តមក)

---

សេចក្តីឆ្លើយ– ចំពោះពាក្យបុច្ឆានេះគប្បីយល់ថា កិលេសជាបច្ច័យតាក់តែងតណ្ហាឲ្យមានដំណើរប្រព្រឹត្តទៅបានជាធម្មតា ។

ម្យ៉ាងទៀត កាលបើតណ្ហាកើតមានឡើងហើយ, តណ្ហានោះក៏តាក់តែងឧបាទាន ៤ នឹងកម្ម ២ គឺកុសលកម្ម នឹងអកុសលកម្ម ឲ្យមានដំណើរប្រព្រឹត្តទៅបានជាលំដាប់ ។

កាលបើឧបាទាន នឹងកម្មកើតមានឡើងហើយ, ឧបាទាននឹងកម្មនោះ ក៏តាក់តែងកសាងជាតិ គឺការកើតឡើងនៃខន្ធ ៥ ឲ្យកើតមានក្នុងភពថ្មីទៀតជាដរាប ។

ត្រង់នេះគប្បីយល់ថា បើកិលេសជាមូលហេតុរលត់ហើយ, ឧបាទានកម្ម នឹងជាតិដែលជាផលត្រូវតែរលត់ជាលំដាប់ដែរ ។

ដោយហេតុនេះ ទើបកិរិយារលត់នៃកិលេសគប្បីចាត់ទុកជាហេតុអាចញ៉ាំងជាតិគឺការកើតឡើងនៃខន្ធ ៥ ឲ្យរលត់ដោយប្រការដូច្នេះឯង ។

ម្យ៉ាងវិញទៀត ដោយសំអាងទៅលើទ្រឹស្តីដូចមានអធិប្បាយខាង

លើនេះ ខ្ញុំសូមថ្លែងបញ្ជាក់ថែមទៀតថា កិរិយារលត់នៃកិលេសអាចនឹងញុំាងត្រៃវដ្ត គឺកិលេសវដ្ត កម្មវដ្ត និងវិបាកវដ្ត ឲ្យផុតរលត់អស់លែងមានអានុភាពអាចវិលបញ្ជូនហេតុផលទៅមកបានទៀតឡើយ ។

រីឯត្រៃវដ្តនេះជាមេកម្លាំង ឬជាអ្នកគាក់តែងធ្វើឲ្យបដិច្ចសមុប្បាទធម៌ គឺ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ភព ជាតិ ជរា ព្យាធិ មរណៈ អាចមានដំណើរវិលទៅមក បញ្ជូនហេតុផលពីអតីតមកបច្ចុប្បន្ន ហើយពីបច្ចុប្បន្នទៅអនាគតបានជាលំដាប់ ។

កាលបើត្រៃវដ្តរលត់ហើយ បដិច្ចសមុប្បាទធម៌នោះក៏ត្រូវរលត់ទៅជាមួយគ្នាដែរ ។

មិនតែប៉ុណ្ណោះវដ្តសង្សារ គឺដំណើរនៃការអន្ទោលវិលកើតវិលស្លាប់ក្នុងភពថ្មីទៀត ដែលជាផលនៃបដិច្ចសមុប្បាទធម៌នោះ ក៏ត្រូវរលត់អស់ត្រឹមនេះ ដែលជាហេតុធ្វើឲ្យសេចក្ដីសុខឲ្យឈឹង កើតមានឡើងជាលំដាប់ដោយប្រការដូច្នេះឯង ។

សំនួរទី ៨_ បើដូច្នេះ តើកិរិយារលត់នៃកិលេសគួរចាត់ទុកជាហេតុនៃនិព្វានបានដែរឬដូចម្ដេច ?

សេចក្ដីឆ្លើយ – ឯកិរិយារលត់នៃកិលេស ពិតជាហេតុនៃនិព្វានមែន ពោលគឺជាហេតុអាចនឹងញុំាងនិព្វានឲ្យសម្រេចកើតឡើងបាន ក៏ប៉ុន្តែ

ដោយនិព្វានមាន ២ ប្រការ គប្បីចាត់ទុកកិរិយារលត់នៃកិលេសជាហេតុនៃឧបាទិសេសនិព្វាន គឺនិព្វានក្នុងបច្ចុប្បន្ន ហើយកិរិយារលត់នៃជាតិគប្បីចាត់ទុកជាហេតុនៃអនុបាទិសេសនិព្វាន គឺនិព្វានទៅអនាគត ពីព្រោះលុះណាតែធ្វើឲ្យកិលេសរលត់អស់ពីខន្ធសន្តានជាមុន ទើបជាហេតុអាចញុំាងជាតិ ជរា ព្យាធិ មរណៈ ឲ្យរលត់នៅពេលជាអនាគតទៅបាន ។

## ២-ចិត្ត

ចិត្តនេះជានាមធម៌គ្មានរូប គ្មានសណ្ឋានអ្វីល្មមឲ្យស្ទាបប៉ះពាល់ត្រូវ ឬក្រឡេកមើលឃើញបានសោះឡើយ តែចិត្តនោះមានទីកន្លែងសំរាប់ជ្រកអាស្រ័យជាធម្មតាក្នុងរូបកាយរបស់យើង ។

ចិត្តនោះពិតមែនតែគ្មានរូប គ្មានសណ្ឋានអ្វីសោះ តែអាចនឹងដឹងច្បាស់នូវអារម្មណ៍ផ្សេង ៗ ហើយរមែងញាប់ញ័រអន្ទះសាស្ទុះចេញទៅស្វែងរកសន្សំអារម្មណ៍ នៅគ្រប់ទិសទីបានទាំងអស់ ។

មិនតែប៉ុណ្ណោះចិត្តនេះអាចនឹងគិតត្រិះរិះពិចារណាដឹងខុសត្រូវ ដឹងល្អ អាក្រក់ ទៅតាមយថាហេតុបាន ។

អាស្រ័យហេតុនេះ ទើបចិត្តនេះជាប្រធានលើអវយវៈទាំងអស់ ហើយជាអ្នកបង្គាប់ទៅលើអវយវៈទាំងនោះឲ្យគិតឲ្យធ្វើ ឬឲ្យនិយាយទៅតាមបញ្ជានៃខ្លួនបានទៀត ។

កាលបើចិត្តនោះល្អ ក៏រមែងបង្គាប់ឲ្យធ្វើនូវអំពើល្អ ឲ្យនិយាយពាក្យ

ពីព្រោះ នឹងឲ្យគិតឃើញនូវគំនិតល្អជាលំដាប់ ។

កាលបើចិត្តនោះអាក្រក់វិញ ក៏រមែងបង្គាប់ឲ្យធ្វើនូវអំពើអាក្រក់ ឲ្យពោលនូវពាក្យកួតកុហកនឹងឲ្យត្រិះរិះគិតឃើញនូវគំនិតអាក្រក់ជាលំដាប់ៗ

ឯចិត្តល្អនោះ គឺសំដៅកុសលចិត្ត ដែលប្រកបដោយញាណ ហើយប្រាសចាកលោភៈ ទោសៈ មោហៈ ។

រីឯចិត្តអាក្រក់នោះ គឺសំដៅអកុសលចិត្តដែលប្រាសចាកញាណ ហើយប្រកបដោយលោភៈ ទោសៈ មោហៈ នោះ ។

រីឯចិត្តដែលកើតចេញប្រាកដឡើងមានចំនួន ៨៩ ដួង ចែកចេញជា ៤ ថ្នាក់ហៅថាភូមិដូចតទៅនេះ ៖

១– កាមាវចរភូមិ មាន ៥៤ ដួង

២– រូបាវចរភូមិ មាន ៥ ដួង

៣– អរូបាវចរភូមិ មាន ១២ ដួង

៤– លោកុត្តរភូមិ មាន ៨ ដួង

លំដាប់តទៅនេះ ខ្ញុំនឹងលើកយកចិត្តដែលប្រព្រឹត្តទៅក្នុងភូមិនីមួយៗ ដូចមានខាងលើនេះ មកធ្វើអត្ថាធិប្បាយរៀករៀងតបញ្ជាក់ឲ្យពិស្តារដូចមានសេចក្តីតទៅនេះ ៖

## ១– កាមាវចរភូមិ

ចិត្តដែលប្រព្រឹត្តទៅក្នុងកាមាវចរភូមិ ហៅថាកាមាវចរចិត្ត គឺសំដៅ

ចិត្តរបស់មនុស្សនឹងចិត្តរបស់ពពួកទេវតា ដែលជាចិត្តប្រកបដោយសំយោ-
ជនៈ ១០ នៅឡើយ ។

ឯកាមាវចរចិត្ត ៥៤ដួងនោះចែកចេញជា ៖

សោភណចិត្ត ២៤

អកុសលចិត្ត ១២

អហេតុកចិត្ត ១៨

## ក- អំពីសោភណចិត្ត ២៤

ឯសោភណចិត្ត ឬហៅកុសលចិត្ត ២៤ នោះចែកចេញជា ៖

កុសលចិត្ត ៨

វិបាកចិត្ត ៨

កិរិយាចិត្ត ៨

ឯកុសលចិត្ត ៨ នោះមានលក្ខណៈដូចតទៅនេះគឺ៖

កុសលចិត្ត ដែលរួមជាមួយនឹងសោមនស្សប្រកបដោយញាណជា
អសង្ខារិក គ្មានអ្នកដឹកនាំមួយ ។

កុសលចិត្ត ដែលរួមជាមួយនឹងសោមនស្ស ប្រកដោយញាណ
ជាសសង្ខារិក មានគេដឹកនាំមួយ ។

កុសលចិត្ត ដែលរួមជាមួយនឹងសោមនស្ស ប្រាសចាកញាណជា
អសង្ខារិក គ្មានអ្នកដឹកនាំមួយ ។

កុសលចិត្ត ដែលរួមជាមួយនឹងសោមនស្ស ប្រាសចាកញាណជាសសង្ខារិក មានគេដឹកនាំមួយ ។

កុសលចិត្ត ដែលរួមជាមួយនឹងឧបេក្ខា ប្រកបដោយញាណជាអសង្ខារិក គ្មានអ្នកដឹកនាំមួយ និងជាសសង្ខារិក មានគេដឹកនាំមួយ ។

កុសលចិត្ត ដែលរួមជាមួយនឹងឧបេក្ខា ប្រាសចាកញាណជាអសង្ខារិក គ្មានអ្នកដឹកនាំមួយ និងជាសសង្ខារិក មានគេដឹកនាំមួយ ។

ឯវិបាកចិត្ត ៨ និងកិរិយាចិត្ត ៨ នោះ ខ្ញុំពុំដែលប្រទះឃើញមានចុះផ្សាយក្នុងសៀវភៅធម៌ណាសោះ តែដោយហេតុថា វិបាកចិត្តនឹងកិរិយា-ចិត្តសុទ្ធតែជាស្នាមគំនូសនៃកុសលនិងជាផលនៃបុញ្ញកម្ម ដែលបានកសាងសន្សំទុកអំពីអតីតកាលមក ប្រហែលមានលក្ខណៈដូចកុសលចិត្ត ៨ ដែលបានរៀបរាប់ខាងលើនេះដែរ ពីព្រោះចិត្តទាំង ៣ ប្រភេទនេះមានចំនួន ៨ ដូច ៗ គ្នាទាំងអស់ ។

## ១- អំពីអកុសលចិត្ត ១២

ឯអកុសលចិត្ត ១២ នេះចែកចេញជា ៖

លោភមូល ៨

ទោសមូល ២

និងមោហមូល ២

ឯលោភមូលចិត្ត ៨ នោះមានលក្ខណៈដូចតទៅនេះ គឺ៖

- លោភមូលចិត្ត ដែលរួមជាមួយនឹងសោមនស្សប្រកបដោយទិដ្ឋិ ជាអសង្ខារិកគ្មានអ្នកដឹកនាំមួយ នឹងជាសសង្ខារិកមានគេដឹកនាំមួយ ៗ

- លោភមូលចិត្ត ដែលរួមជាមួយសោមនស្សប្រាសចាកទិដ្ឋិជា អសង្ខារិក គ្មានអ្នកដឹកនាំមួយ នឹងជាសសង្ខារិកមានគេដឹកនាំមួយ ៗ

- លោភមូលចិត្ត ដែលរួមជាមួយឧបេក្ខាប្រកបដោយទិដ្ឋិជា អសង្ខារិក គ្មានអ្នកដឹកនាំមួយ នឹងជាសសង្ខារិកមានគេដឹកនាំមួយ ៗ

- លោភមូលចិត្ត ដែលរួមជាមួយឧបេក្ខាប្រាសចាកទិដ្ឋិ ជា អសង្ខារិក គ្មានអ្នកដឹកនាំមួយ នឹងជាសសង្ខារិកមានគេដឹកនាំមួយ ៗ

រីឯទោសមូលចិត្ត ២ នេះមានលក្ខណៈដូចតទៅនេះ គឺ៖

ទោសមូលចិត្ត ដែលរួមជាមួយទោមនស្សប្រកបដោយបដិឃៈ ជា អសង្ខារិក គ្មានអ្នកដឹកនាំមួយ នឹងជាសសង្ខារិកមានគេដឹកនាំមួយ ៗ

ចំណែកឯមោហមូលចិត្ត ២ នេះមានលក្ខណៈដូចតទៅនេះគឺ៖

មោហមូលចិត្ត ដែលរួមជាមួយនឹងឧបេក្ខាប្រកបដោយ៖

វិចិកិច្ឆា ១

នឹង ឧទ្ធច្ចៈ ១

## គ- អំពីអហេតុកចិត្ត ១៨

ឯអហេតុកចិត្ត ១៨ នោះចែកចេញជា៖

កុសលវិបាកាហេតុកចិត្ត ៨

អកុសលវិបាកាហេតុកចិត្ត ៧

អហេតុកកិរិយាចិត្ត ៣

អហេតុកកិរិយា ១៨ ដូចមានរៀករៀងខាងលើនេះ គឺសុទ្ធតែជាចិត្តមិនប្រកបដោយហេតុ តែអហេតុកចិត្តនេះអាចប្រែទៅជាកុសលចិត្ត ឬ ជាអកុសលចិត្តវិញបានតាមយថាហេតុ ។

ដោយហេតុនេះ ទើបកុសលវិបាកាហេតុកចិត្ត គឺអហេតុកចិត្តដែលជាស្នាមគំនូសនៃកុសលនោះ អាចប្រែទៅជាកុសលចិត្តបាន ហើយអកុសលវិបាកាហេតុកចិត្ត គឺអហេតុកចិត្តដែលជាស្នាមគំនូសនៃអកុសលក៏អាចប្រែទៅជាអកុសលចិត្តវិញបានដូចគ្នា ។ មានតែអហេតុកកិរិយាចិត្ត ៣ នោះទេ ដែលត្រូវនៅជាអហេតុកចិត្តដដែល ។

សរុបសេចក្តីទៅឃើញថា ចិត្តទាំង៣ប្រភេទ គឺកុសលចិត្ត អកុសលចិត្ត និងអហេតុកចិត្ត ដែលប្រព្រឹត្តទៅក្នុងកាមាវចរភូមិនោះជាសម្ផាន អាចនឹងនាំចេតសិកធម៌ ២៥ ឲ្យកើតឡើងជាលំដាប់ ពីព្រោះកាលបើកុសលចិត្តឬអកុសលចិត្ត ឬអហេតុកចិត្តក៏ សញ្ចេតនា (គិត) វិតក្ក (ត្រិះរិះ) និងវិចារៈ (ពិចារណា) អំពីការជាកុសល ឬ ជាអកុសលរមែងកើតជាគំនិតផ្សេងៗ ហៅថា ចេតសិក មាន ៥២ ចែកចេញជា ៖

កុសលចេតសិក ២៥

អកុសលចេតសិក ១៤

អញ្ញសមានាចេតសិក ១៣

រីឯអញ្ញសមានាចេតសិក ១៣ នេះ អាចប្រែទៅជាកុសលចេតសិក ឬជាអកុសលចេតសិកវិញ តាមយថាហេតុ ។

រីឯចេតសិក៥២ដូចមានចែកញែកខាងលើនេះ ខ្ញុំសូមអភ័យទោស ដោយពុំបានលើកយកមកពណ៌នានៅទីនេះ ពីព្រោះច្រើនពេក ។

## ២. រូបាវចរភូមិ

ចិត្តដែលប្រព្រឹត្តទៅក្នុងរូបាវចរភូមិ ហៅថា រូបាវចរចិត្ត គឺសំដៅ ចិត្តរបស់ព្រហ្ម ក្នុងឋានព្រហ្មដែលមានរូប ១៦ ជាន់នោះ ។

ឯរូបាវចរចិត្ត ១៥ នោះចែកចេញជា ៖

រូបាវចរកុសលចិត្ត ៥

រូបាវចរវិបាកចិត្ត ៥

រូបាវចរកិរិយាចិត្ត ៥

## ៣. អរូបាវចរភូមិ

ចិត្តដែលប្រព្រឹត្តទៅក្នុងអរូបាវចរភូមិ ហៅថា អរូបាវចរចិត្ត គឺសំ-ដៅចិត្តរបស់ព្រហ្ម ក្នុងឋានព្រហ្មដែលគ្មានរូប ៤ ជាន់ ។

ឯអរូបាវចរចិត្ត ១២ ដួងនោះចែកចេញជា ៖

អរូបាវចរកុសលចិត្ត ៤

អរូបាវចរវិបាកចិត្ត ៤

អរូបាវចរកិរិយាចិត្ត ៤

ឯរូបាវចរចិត្ត ១៥ ដួងនឹងអរូបាវចរចិត្ត ១២ ដួង ដូចបានរៀបរាប់ខាងលើនេះ ទោះជាវិបាកចិត្ត ឬកិរិយាចិត្តក្តី សុទ្ធតែជាកុសលចិត្តទាំងអស់ តែកុសលចិត្តទាំងនោះមិនមែនជាចិត្តស្អាតបរិសុទ្ធទេ, ដោយហេតុកុសលចិត្តនោះនៅសៅហ្មងដោយឧទ្ធម្ភាគិយសំយោជនៈ៥គឺរូបរាគ អរូបរាគ ឧទ្ធច្ចៈ មានះ នឹងអវិជ្ជា នៅឡើយ ។

## ៤. លោកុត្តរភូមិ

ឯចិត្តដែលប្រព្រឹត្តទៅក្នុងលោកុត្តរភូមិនោះ ហៅថា លោកុត្តរចិត្ត គឺសំដៅចិត្តដែលលះសំយោជនៈ ១០ ដាច់ស្រឡះដោយសមុច្ឆេទប្បហាន ។

ឯលោកុត្តរចិត្តនោះមាន ៨ ចែកចេញជាមគ្គចិត្តមាន ៤ នឹងផលចិត្តមាន ៤ ឯមគ្គចិត្ត ៤ នោះ បើតាមយោបល់ខ្ញុំគប្បីមានលក្ខណៈដូចតទៅនេះគឺ ៖

— មគ្គចិត្តទី ១ គឺលោកុត្តរចិត្ត ដែលលះសំយោជនៈ ៣ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ នឹងសីលព្វតបរាមាស ១ ដោយសមុច្ឆេទប្បហាន គឺលះដាច់ស្រឡះដោយដាច់ខាត ហៅថា សោតាបត្តិមគ្គ ។

— មគ្គចិត្តទី ២ គឺលោកុត្តរចិត្ត ដែលលះសំយោជនៈ ៣ ដូចមានឈ្មោះខាងលើនេះ ហើយនឿយណាយចំពោះកាមរាគនឹងបដិឃៈទៀត

ហៅថា សកទាគាមិមគ្គ ។

— មគ្គចិត្តទី ៣ គឺលោកុត្តរចិត្ត ដែលលះសំយោជនៈ៥ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ កាមរាគ ១ និងបដិឃៈ ដោយសមុច្ឆេទប្បហាន ហៅថា អនាគាមិមគ្គ ។

—មគ្គចិត្តទី ៤ គឺលោកុត្តរចិត្តដែលលះសំយោជនៈ ១០ គឺសំយោជនៈ៥ ដូចមានឈ្មោះខាងលើនេះ និងសំយោជនៈ៥ទៀត គឺរូបរាគ១ អរូបរាគ១ មានះ១ ឧទ្ធច្ចៈ១ អវិជ្ជា១ ដោយសមុច្ឆេទប្បហាន ហៅថាអរហត្តមគ្គ ។

ឯមគ្គចិត្ត ៤ នេះកាលបើសម្រេចកើតឡើងបរិបូណ៌ហើយ រមែងជាហេតុនឹងញុំាងផលចិត្ត ៤ ឲ្យសម្រេចកើតឡើងជាលំដាប់ទៀត ។

ឯផលចិត្ត ៤ នេះគឺ ៖

—ផលចិត្តទី ១ គឺលោកុត្តរចិត្តដែលរួចចាកសំយោជនៈ៣គឺសក្កាយទិដ្ឋិ១ វិចិកិច្ឆា១ និងសីលព្វតបរាមាស ១ ដោយសមុច្ឆេទវិមុត្តិ គឺរួចចាកស្រឡះដោយដាច់ខាត ហៅថាសោតាបត្តិផល ។

— ផលចិត្តទី ២ គឺលោកុត្តរចិត្ត ដែលរួចចាកសំយោជនៈ ៣ ដូចមានឈ្មោះខាងលើនេះ ហើយនៀយណាយចំពោះកាមរាគ និងបដិឃៈទៀតហៅថាសកទាគាមិផល ។

— ផលចិត្តទី ៣ គឺលោកុត្តរចិត្តដែលរួចចាកសំយោជនៈ៥ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ កាមរាគ១ និងបដិឃៈ ១

ដោយបង់បស្សទ្ធិវិមុត្តិ គឺរួចចាកដោយចិត្តស្ងប់ ហៅថាអនាគាមិផល ។

- ផលចិត្តទី ៤ គឺលោកុត្តរចិត្តដែលរួចចាកសំយោជនៈ ១០ គឺសំយោជនៈ ៥ ដូចខាងលើនេះ និងសំយោជនៈ ៥ ទៀតគឺ រូបរាគ អរូបរាគ មានះ ឧទ្ធច្ចៈ និងអវិជ្ជា ដោយនិស្សរណវិមុត្តិ គឺរួចចាកដោយរលាស់ចោលចេញអស់ ហៅថាអរហត្តផល ។

ក្នុងបណ្ដាចិត្ត ៨៩ ដួង ដូចបានពណ៌នាខាងលើនេះ គេអាចសំគាល់ឃើញថា ៖

១- កាមាវចរចិត្ត ៥៤ ដួងជាចិត្តប្រកបដោយសំយោជនៈ ១០ ដែលជាសមុដ្ឋាននៃតណ្ហា ៣ ប្រការ គឺ កាមតណ្ហា សេចក្ដីប្រាថ្នាចង់កើតក្នុងកាមភព ១ ភវតណ្ហា គឺសេចក្ដីប្រាថ្នាចង់កើតក្នុងរូបភព ១ និង វិភវតណ្ហា គឺសេចក្ដីប្រាថ្នាចង់កើតក្នុងអរូបភព ១ ។

២- រូបាវចរចិត្ត ១៥ ដួង ពិតមែនជាកុសលចិត្ត តែជាកុសលចិត្ត នៅប្រកបដោយឧទ្ធម្ភាគិយសំយោជនៈ ៥ គឺ រូបរាគ អរូបរាគ មានះ ឧទ្ធច្ចៈ និងអវិជ្ជាដែលជាសមុដ្ឋាននៃភវតណ្ហា គឺសេចក្ដីប្រាថ្នាចង់កើតក្នុងរូបភពនិងវិភវតណ្ហា គឺសេចក្ដីប្រាថ្នាចង់កើតក្នុងអរូបភពនៅឡើយ ។

៣- អរូបាវចរចិត្ត ១២ ដួង ក៏ជាកុសលចិត្តនៅសៅហ្មងដោយឧទ្ធម្ភាគិយសំយោជនៈ ៤ គឺ អរូបរាគ មានះ ឧទ្ធច្ចៈ និងអវិជ្ជា ដែលជាសមុដ្ឋាននៃវិភវតណ្ហា គឺសេចក្ដីប្រាថ្នាចង់កើតក្នុងអរូបភពនៅឡើយ ។

៤-លោកុត្តរចិត្ត ៨ ដួង គឺមគ្គចិត្ត ៤ និងផលចិត្ត ៤ ទើបជាចិត្តស្អាតបរិសុទ្ធផូរផង់រួចផុតស្រឡះចាកសំយោជនៈ១០ ដែលជាសមុដ្ឋាននៃតណ្ហា ៣ ប្រការនោះ ។

ដោយហេតុនេះ ទើបផលចិត្តទី ៤ ដែលហៅថា អរហត្តផល ជាលោកុត្តរចិត្តរួចផុតចាកកំដៅភ្លើងកិលេស តាំងនៅក្នុងសុខមាលសុខយ៉ាងឧត្តម, លែងស្គាល់សេចក្តីក្តៅក្រហាយ, សេចក្តីអន្ទះអន្ទែង, សេចក្តីស្រេកឃ្លាននឹងសេចក្តីប្រាថ្នាចង់ត្រេកត្រអាលក្នុងវត្ថុសង្ខារទៀតហើយ ។

---

(នៅមានត)

សោ យស្ស សន្តានេ បវត្តោ អមោហោនោះប្រព្រឹត្តទៅក្នុងសន្តាននៃបុគ្គលណា បុគ្គលនោះក៏មិនបានប្រមាទ គឺប្រកបដោយសតិ, អធិប្បាយថា អមោហោនោះ គឺមិនបានទៅប្រាសចាកសតិ ។

សតិនោះ បានដល់ការរឭក ។ ការរឭកនោះ ពោលដោយសរុបមាន ២ ប្រការគឺ មិច្ឆាសតិ រឭកខុស ១ សម្មាសតិ រឭកត្រូវ ១ ។ ក្នុងអមោហោ គឺមិនវង្វេង ប្រាថ្នាយកសម្មាសតិ គឺរឭកត្រូវ, រឭកមិនខុស, រឭកតាមព្រះពុទ្ធដីកាដែលសម្តេចព្រះភគវន្តបពិត្រប្រទានទេសនាទុកមក ៗ

រឭកត្រូវតាមព្រះពុទ្ធដីកានោះ គឺសតិបដ្ឋានបួន និងអនុស្សតិដប់ប្រការ ។ សតិបដ្ឋានបួននោះគឺ កាយានុបស្សនាសតិបដ្ឋាន ១ វេទនានុបស្សនាសតិបដ្ឋាន ១ ចិត្តានុបស្សនាសតិបដ្ឋាន ១ ធម្មានុបស្សនាសតិបដ្ឋាន ១ ។ អនុស្សតិដប់ប្រការនោះគឺ ពុទ្ធានុស្សតិ រឭករឿយ ៗ នូវគុណនៃព្រះពុទ្ធ ១ ធម្មានុស្សតិ រឭករឿយ ៗ នូវគុណនៃព្រះធម៌ ១ សង្ឃានុស្សតិ រឭករឿយ ៗ នូវគុណនៃព្រះសង្ឃ ១ សីលានុស្សតិ រឭករឿយ ៗ នូវគុណនៃសីលដែលខ្លួនរក្សា ១ ចាគានុស្សតិ រឭករឿយ ៗ នូវ

គុណនៃទានដែលខ្លួនបានបរិច្ចាគហើយ ១ ទេវតានុស្សតិ រឭករឿយ ៗ នូវទេវតា ឬនូវធម៌របស់ទេវតា ១ ឧបសមានុស្សតិ រឭករឿយ ៗ នូវព្រះនិព្វានដ៏រម្ងាប់កិលេស ១ មរណានុស្សតិ រឭករឿយ ៗ នូវមរណៈ ១ កាយគតាសតិ រឭកក្នុងអាការ ៣២ មានកេសាជាដើមដ៏តាំងនៅក្នុងកាយ ១ អានាបានស្សតិ រឭកដល់ខ្យល់ដង្ហើម ១ គ្រប់ជាអនុស្សតិដប់ប្រការ ៗ

ក្នុងអនុស្សតិដប់ប្រការនោះ នឹងវិសជ្ជនាក្នុងអានាបានស្សតិ ល្មមជាគ្រឿងប្រដាប់សតិបញ្ញា មានសេចក្តីថា ឥទំ[១] អានាបានស្សតិ. កម្មដ្ឋានំ ព្រះយោគាវចរកុលបុត្រដែលចំរើននូវព្រះអានាបានស្សតិ គប្បីកំណត់ទុកក្នុងចិត្តនូវខ្យល់ដង្ហើមចេញនិងចូល ៗ វិធីកំណត់នោះ គឺឲ្យកំណត់រាប់នូវខ្យល់ដង្ហើមចេញជាដើម ៗ កាលនឹងរាប់ខ្យល់អស្សាស-បស្សាសៈនោះ គប្បីរាប់យឺត ៗ ជាមុន ៗ រាប់ខ្យល់អស្សាសបស្សាសៈឲ្យយឺត ៗ នោះ ដូចជាបុរសវាល់នូវស្រូវ ធញ្ញបត្ថា ហិ មែនពិត បុរសអ្នកវាល់នូវស្រូវនោះ រមែងញាំងរង្វាល់ឲ្យពេញដោយស្រូវជាមុន ហើយ ទើបពោលថាមួយទៅ ឬ មួយហាបហើយទើបដាក់ចុះឲ្យហើសគ្រឡប់ដោយឆាប់រហ័ស ៗ ចិត្តព្រះយោគាវចរនោះ ក៏នឹងដល់នូវគាវៈមានអារម្មណ៍តែមួយដោយកំឡាំងនៃការរាប់ ដូចជានាវាដែលឈប់ក្នុង

---

(១) ក្នុងគម្ពីរព្រះសូត្រ សរសេរថា អានាបាណស្សតិ ហើយរៀងលំដាប់ជាទី ៩, ឧបសមានុស្សតិជាទី ១០ ។

ស៊ឹង  មានក្រសែក៏ដំហូរដោយកំឡាំងនៃខ្យល់ចំណងចងទប់ឲ្យឈប់នៅនឹងបាន ៗ  តស្ស ឥណភា ឆតោ  កាលព្រះយោគាវចរកុលបុត្រពប់នូវខ្យល់អស្សាសបស្សាសៈឲ្យញាប់ ៗ  មិនបានក្តាំងក្តាក់ដូច្នោះ  ព្រះអានាបានស្សតិកម្មដ្ឋានក៏ប្រាកដដូចជាប្រព្រឹត្តទៅមិនដាច់  ក្នុងលំដាប់នោះព្រះយោគាវចរកុលបុត្រមិនត្រូវប្រកាន់យកនូវខ្យល់ខាងក្នុងទេ  មិនត្រូវប្រកាន់យកនូវខ្យល់បក់ចេញមកខាងក្រៅទេ  ត្រូវតែកំណត់យកនូវការដល់ទ្វារតែម្យ៉ាងប៉ុណ្ណោះ  ព្រោះថាកាលបើព្រះយោគាវចរកុលបុត្រញុំាងចិត្តឲ្យចូលទៅជាមួយនឹងខ្យល់ខាងក្នុង ខ្យល់ដែលបក់នោះ  ក៏នឹងប្រាកដដូចជាពេញទៅដោយសតិដ៏តាំងមាំក្នុងកាយខ្លួន  កាលញុំាងចិត្តឲ្យចេញទៅជាមួយនឹងខ្យល់ដែលចេញទៅខាងក្រៅ  ចិត្តក៏នឹងអណ្តែតអណ្តូងទៅផ្សេង ៗ សតិ ឋបេត្វា  នឹងដំកល់សតិទុកក្នុងទីដែលខ្យល់ត្រូវត្រង់ការនាក៏ដល់នូវសេចក្តីវិនាស  ហេតុដូច្នោះ ទើបលោកហាមមិនឲ្យប្រកាន់យកនូវខ្យល់ដែលបក់ចេញទៅខាងក្រៅ  នឹងឲ្យកំណត់កប់តែខ្យល់ដែលដល់នូវទ្វារតែម្យ៉ាងប៉ុណ្ណោះ ៗ

ប្រការមួយទៀត  ព្រះយោគាវចរអ្នកព្យាយាមនឹងរៀនចំរើននូវព្រះអានាបានស្សតិកម្មដ្ឋាននោះ  គប្បីកំណត់ទុកក្នុងចិត្តដោយការប្រព្រឹត្តទៅតាមខ្យល់ដង្ហើមចូលចេញដោយខាងដើមនឹងកណ្តាលនឹងទីបំផុត ៗ  ឯខ្យល់ដង្ហើមចេញនឹងខ្យល់ដង្ហើមចូល  ត្រង់ខាងដើមនៃខ្យល់ដង្ហើមចេញ

នោះគឺនាភី (ផ្ចិត) ត្រង់កណ្តាលនៃខ្យល់ដង្ហើមចេញនោះគឺបេះដូង (ទ្រូង) ទីបំផុតនៃខ្យល់ដង្ហើមចេញនោះបានដល់នាសិក ។ ចំណែកខ្យល់ដង្ហើមចូលខាងចុងនាសិកជាទីខាងដើម, បេះដូង (ទ្រូង) ជាទីកណ្តាល, នាភីជាទីបំផុត ។

ប្រការមួយទៀត ព្រះយោគាវចរកុលបុត្រអ្នកចំរើនព្រះអានាបានស្សតិកម្មដ្ឋាន គប្បីកំណត់ទុកក្នុងចិត្តនូវខ្យល់អស្សាសបស្សាសៈដោយកំណាចនៃសរីរប្រទេសដែលខ្យល់ប៉ះពាល់ត្រូវ នឹងដែលខ្យល់ឈប់នៅឲ្យស្គាល់ដំនាញក្នុងចិត្ត ។

មានពាក្យព្រះអដ្ឋកថាចារ្យពោលឧបមាដោយមនុស្សអាគ្រាត នឹងប្រៀបដោយនាយទ្វារ មាននៅក្នុងអដ្ឋកថាទាំងឡាយ ។ ឯពាក្យអត្ថាធិប្បាយក្នុងគម្ពីរបដិសម្ភិទាថា ឧបមាដោយសត្វលួន ។ បង្គុឡូបមាដែលប្រៀបធៀបដោយមនុស្សអាគ្រាតនោះថា បង្គុលេខឡា ឲ្យបិត្តា បុរសអាគ្រាតនោះ រមែងបោះទៅនូវបន្ទះក្តារពោងអង្រួយនៅក្នុងទីជិតនៃសសរដែលចងបន្ទះក្តារពោង កាលក្តារយោលទៅមកក៏ឃើញនូវទីបំផុតទាំងពីរខាង នឹងឃើញនូវពាក់កណ្តាលនៃក្តារនោះដោយងាយ លុះឃើញហើយក៏ប្រាសចាកសេចក្តីខ្វល់ខ្វាយ ដើម្បីនឹងឲ្យឃើញនូវទីបំផុតនៃបន្ទះក្តារទាំងពីរខាង នឹងពាក់កណ្តាលនៃបន្ទះក្តារពោង សេចក្តីនេះមានឧបមាដូចម្តេច ព្រះយោគាវចរកុលបុត្រនោះ លុះបានកំណត់ក្នុងចិត្ត

នូវទីកន្លែងដែលខ្យល់ដង្ហើមប៉ះពាល់ត្រូវ នឹងទីដែលខ្យល់ដង្ហើមពបប៉ះ នឹងទីជាខាងដើម, ខាងកណ្ដាល, ខាងចុងបំផុតនៃខ្យល់អស្សាសបស្សាសៈដោយសតិ តាំងចិត្តទុកក្នុងខ្យល់អស្សាសបស្សាសៈដោយសតិ តាំងចិត្តទុកក្នុងខ្យល់អស្សាសបស្សាសៈទាំងឡាយ គឺឃើញដោយងាយគ្មានសេចក្ដីខ្វល់ខ្វាយ ដើម្បីនឹងឲ្យឃើញនូវខ្យល់អស្សាសបស្សាសៈទាំងឡាយនោះ មានឧបមេយ្យដូចបុរសអាក្រាតដូច្នោះ ។

ក្នុងពាក្យឧបមាដោយនាយទ្វារបាលនោះ មានសេចក្ដីថា ទោវារិកោ ច វិមំសតិ នាយទ្វារបាលនោះ នឹងបានពិចារណានូវបុគ្គលអ្នកចូលទៅខាងក្នុងនគរនឹងអ្នកនៅក្រៅនគរថា អ្នកណាមកអំពីទីណា នឹងទៅឯណា មានរបស់អ្វីនៅក្នុងនគរ នឹងបានគិតពិចារណាយ៉ាងនេះ ក៏ឥតអង្គមានសោះឡើយ គឺថាឥតគិតសោះ ទ្វារប្បត្តំ ឯវ មានកិច្ចពិចារណាត្រួតត្រាតែបុគ្គលដែលមកដល់ត្រង់ទ្វារតែម្យ៉ាងប៉ុណ្ណោះ សេចក្ដីនេះមានឧបមាដូចម្ដេច ខ្យល់ទាំងឡាយនឹងចេញទៅខាងក្រៅ ឬនឹងចូលទៅខាងក្នុង មិនបានជាការធុរៈដល់ភិក្ខុអ្នកចំរើនអានាបានសតិក៏ឥតអង្គមាន ទ្វារប្បត្តា ឯវ ខ្យល់ចំពូកណាមកដល់ទ្វារ ភិក្ខុអ្នកចំរើនអានាបានស្សតិកម្មដ្ឋាន គប្បីកំណត់នូវខ្យល់ចំពូកនោះ ដូចនាយទ្វារបាលត្រួតត្រាមនុស្សដែលចូលមកដល់ទ្វារនោះតែប៉ុណ្ណោះ ។

វុត្តំ ហេតំ ពាក្យនេះ សមនឹងពាក្យព្រះសារីបុត្តត្ថេរពោលថា

និមិត្តំ អស្សាសបស្សាសា ធម៌តាំងបីប្រការគឺ និមិត្ត ១ ខ្យល់ដង្ហើមចេញ ១ ខ្យល់ដង្ហើមចូល ១ មិនបានជាអារម្មណ៍នៃចិត្តតែមួយ ឥតោ អជានតោ កាលព្រះយោគាវចរកុលបុត្រអ្នកចំរើនអានា-បានស្សតិកម្មដ្ឋាននោះ មិនបានដឹងនូវធម៌បីប្រការគឺ និមិត្ត ១ ខ្យល់ដង្ហើមចេញ ១ ខ្យល់ដង្ហើមចូល ១ នឹងបាននូវអានាបានស្សតិភាវនាក៏ឥតអង្គឹមាន គឺថាមិនបានទេ ៗ

មានពាក្យបុច្ឆាថា ចុះហេតុដូចម្តេច បានជាព្រះយោគាវចរកុលបុត្រកាលមិនដឹងនូវនិមិត្ត នឹងខ្យល់ដង្ហើមចេញចូល ទើបមិនបាននូវការញ៉ាំងព្រះអានាបានស្សតិកម្មដ្ឋានឲ្យចំរើនបាន លុះត្រាតែកាលណាដឹងនូវនិមិត្ត នឹងដឹងនូវខ្យល់ដង្ហើមចេញចូល ទើបនឹងញ៉ាំងអានាបានស្សតិកម្មដ្ឋានឲ្យចំរើនបាន ? ៗ

មានពាក្យវិសជ្ជនាថា ន មេ តយោ ធម្មា ធម៌តាំងបីប្រការនេះ មិនមែនជាអារម្មណ៍នៃចិត្តតែមួយ ភិក្ខុអ្នកចំរើនព្រះអានាបានស្សតិកម្មដ្ឋាននោះ បើមិនដឹងធម៌បីប្រការនេះទេ ដឹងតែធម៌មួយឬពីរហើយចិត្តក៏នឹងអណ្តែតអណ្តូងរាយមាយទៅផ្សេង ៗ សេចក្តីព្យាយាមដែលខ្លួនតាំងទុកក៏មិនបានផលប្រាកដ ៗ ព្រះយោគាវចរកុលបុត្រនោះ ក៏មិនបាននូវឈាននឹងមគ្គផលធម៌វិសេស បើដឹងនូវធម៌តាំងបីប្រការហើយ ទើបចិត្តមិនអណ្តែតអណ្តូង សេចក្តីព្យាយាមនឹងសម្រេចប្រយោជន៍ជាប្រាកដ ៗ

ព្រះយោគាវចរកុលបុត្ររមែងបាននូវឈានទាំងមគ្គផលធម៌វិសេស ៗ ការ
ដែលលោកប្រាប់ឲ្យតាំងសតិទុក ប្រៀបដូចជាបុរសអ្នកអារកាត់ដើមឈើ
ធិក្កុត្តោ រុក្ខោ ដើមឈើដែលបុគ្គលតាំងទុកលើផ្ទៃរាបស្មើគ្នា បុរស
ទាំងអារកាត់ដើមឈើនោះ គប្បីអារដោយរណារដ៏មុត សតិ ឧបដ្ឋិតា
សតិនៃបុរសនោះ រមែងប្រាកដដោយអំណាចកំណត់នូវធ្មេញរណារដែល
រេះបុរាណ៍ ទាំងកំណត់ទុកក្នុងចិត្តនូវធ្មេញរណារដែលរេញទៅមកនោះក៏ទេ
ធ្មេញរណារដែលលឿនទៅមកនោះ បុរសអ្នកអារឈើមិនមែនមិនដឹងទេ
គឺបេះតែដឹង ប៉ុន្តែសេចក្ដីព្យាយាមនោះរមែងប្រាកដ បុរសនោះបង់បាន
ឈើក្រាស់ ឬ ស្តើងប៉ុណ្ណា ក៏បានសម្រេចដូចចិត្តប្រាថ្នា បុរសតាំងដើម
ឈើទុកក្នុងផ្ទៃដីរាបស្មើនោះ មានឧបមាដូចនិមិត្តដែលភិក្ខុអ្នកតាំងទុកនូវ
ខ្យល់អស្សាសបស្សាសៈ ៗ ខ្យល់អស្សាសបស្សាសៈនោះ ប្រៀបដូច
ធ្មេញនៃរណារដែលលឿនទៅមកត្រង់ដើមឈើ ធ្មេញរណារដែលបុរស
តាំងសតិទុកក្នុងទីនោះ ឧបមាដូចភិក្ខុអ្នកតាំងសតិទុកក្នុងទីខាងចុងនាសិក
ដែលខ្យល់ប៉ះពាល់ត្រូវ ៗ បើភិក្ខុអ្នកចំរើនអានាបានស្សតិកម្មដ្ឋានបានកំ-
ណត់ដឹងធម៌បីប្រការដូច្នេះហើយ ចិត្តក៏មានអារម្មណ៍តែមួយមិនបានពាយ-
មាយ ទាំងបាននូវឧបចារជ្ឈានទាំងអប្បនាឈាន សម្រេចដូចចិត្តប្រាថ្នា ៗ
ហេតុដូច្នោះ បានជាលោកពោលថា ព្រះយោគាវចរកុលបុត្រដឹងនូវ
ធម៌បីប្រការដូច្នេះហើយ អាចញុំាងព្រះអានាបានស្សតិកម្មដ្ឋានឲ្យចំរើន

ទៀតបាន បណ្ឌិតជាតិគប្បីសន្និដ្ឋានចូលចិត្តដោយន័យដូចវិសជ្ជនាមក នេះចុះ ។

អាណាបានសតិកម្មដ្ឋាន

អបរំ បដិសញ្ចិក្ខតោ ឥមេ អន្តោ កុច្ឆិយំ ឋត្វា ឧទកេ និមុគ្គានំ ឋត្វា តថា អសញ្ញីភូតានំ មតានំ ចតុត្ថជ្ឈានសមាបន្នានំ រូបារូបភវសមង្គីនំ និរោធសមាបន្នានន្តិ ញត្វា ឃរំ អត្តនោ អត្តា បដិបាទេតព្វោតិ ។

លំដាប់នេះ នឹងបានពណ៌នាក្នុងអាណាបានស្សតិកម្មដ្ឋានតទៅ សេចក្ដីថា អបរំ បដិសញ្ចិក្ខតោ កាលព្រះយោគាវចរកុលបុត្រអ្នកប្រព្រឹត្តនូវសេចក្ដីព្យាយាមចំរើនព្រះអាណាបានស្សតិកម្មដ្ឋាន គប្បីពិចារណាកំណត់ធម៌បីប្រការ គឺ និមិត្ត ១ ខ្យល់ដង្ហើមចេញ ១ ខ្យល់ដង្ហើមចូល ១ ដោយប្រការដូច្នេះហើយ គប្បីដឹងថាខ្យល់អស្សាសបស្សាសៈទាំងឡាយ នៃសត្វនៅក្នុងផ្ទៃមាតានោះគ្មានទេ, ឯសត្វដែលធ្លាក់លិចទៅក្នុងទឹកក៏គ្មានខ្យល់អស្សាសបស្សាសៈដែរ, សត្វកើតក្នុងអសញ្ញីភព នឹងសត្វកើតក្នុងរូបភព, អរូបភព, ព្រះអនាគាមិបុគ្គល នឹងព្រះខីណាស្រពដែលចូលនិរោធសមាបត្តិនឹងចតុត្ថជ្ឈាន ទាំងអម្បាលនេះគ្មានខ្យល់អស្សាសបស្សាសៈទេ ។ កាលបើបានដឹងដូច្នេះហើយ គប្បីដាស់

តឿនរំឭកខ្លួនថា បណ្ឌិតោ មាតុកុច្ឆិកោ ម្នាលអ្នកដ៏ប្រកបដោយបញ្ញា លោកអ្នកនៅក្នុងផ្ទៃរបស់មាតា នឹងចុះទៅក្នុងទឹកនឹងជាអសញ្ញីសត្វ នឹងអ្នកចូលបត្តជ្ឈាន, ចូលនិរោធសមាបត្តិជាសត្វព្រមព្រៀងដោយរូបកពនឹងអរូបកព មិនមែនគ្មានខ្យល់អស្សាសបស្សាសៈមែនឬទេ? អត្ថិ យេវ លោកប្រាកដជាមានខ្យល់អស្សាសបស្សាសៈតាមធម្មតា មន្ទបញ្ញាតាយ បន ប៉ុន្តែព្រោះហេតុថាលោកមានបញ្ញាទន់ខ្សោយមិនអាចពិចារណានូវខ្យល់អស្សាសបស្សាសៈដង្ហើមចេញចូលឲ្យឃើញប្រាកដបាន ។ ក្នុងលំដាប់នោះ ព្រះយោគាវចរគប្បីតាំងចិត្តទុកក្នុងខ្យល់ដែលប៉ះត្រូវហើយកំណត់សំគាល់ក្នុងចិត្តថា ឥមេហិ ឃដេន្តោ ព្រោះជាបុគ្គលមាននាសិក (ច្រមុះ) វែងធំ ខ្យល់អស្សាសបស្សាសៈទាំងឡាយប៉ះត្រូវនូវច្រមុះហើយទើបប្រព្រឹត្តទៅ បុគ្គលមានច្រមុះខ្លី ខ្យល់អស្សាសបស្សាសៈប៉ះត្រូវបបូរមាត់ហើយទើបប្រព្រឹត្តទៅៗ

ហេតុដូច្នោះ ព្រះយោគាវចរគប្បីកំណត់ថា ខ្យល់អស្សាសបស្សាសៈប៉ះត្រូវនូវទីនេះ ទើបតាំងទុកនូវនិមិត្តមែនពិត ។

កាលបើភិក្ខុតាំងចិត្តដូច្នេះហើយ ឈ្មោះថាធ្វើត្រឹមត្រូវតាមព្រះពុទ្ធដីកា ដ្បិតសម្តេចព្រះបរមសាស្តាត្រាស់ប្រាប់ភិក្ខុទាំងឡាយថា មុដ្ឋស្សតិស្ស ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ការចំរើននូវអានាបានស្សតិភាវនាកាលបើវង្វេងស្មារតីគ្មានបញ្ញាពិចារណាឲ្យដឹងសព្វគ្រប់ទេ គប្បីកំណត់

សំគាល់នូវខ្យល់ដង្ហើមចេញនឹងចូលហើយគប្បីតាំងទុកនូវនិមិត្ត ។ ហេតុនេះភិក្ខុអ្នកចំរើននូវអានាបានស្សតិកម្មដ្ឋាន កំណត់សំគាល់ខ្យល់អស្សាសបស្សាសៈដែលប៉ះត្រូវទីនេះៗ ហើយតាំងទុកនូវនិមិត្តនោះទើបបានឈ្មោះថាធ្វើត្រឹមត្រូវតាមក្រសែព្រះពុទ្ធដីកា ។

មែនពិត កម្មដ្ឋានណាមួយនឹងសម្រេចដល់ភិក្ខុអ្នកចំរើនព្រះកម្មដ្ឋាន រមែងសម្រេចដល់ភិក្ខុមានស្មារតីមានបញ្ញាពិចារណាដោយសព្វគ្រប់ មិនមែនសម្រេចដល់ភិក្ខុអ្នកប្រាសចាកស្មារតីគ្មានសតិបញ្ញា ន.គោ បឋ អញ្ញំ សូម្បីកម្មដ្ឋានឯទៀតក្រៅពីអានាបានស្សតិកម្មដ្ឋាននេះ(១) កាលភិក្ខុកំណត់សំគាល់ក្នុងមនោគារហើយក៏ដឹងប្រាកដដូចគ្នា ន.ធិ បឋ ប៉ុន្តែថា អានាបានស្សតិកម្មដ្ឋាននេះធ្ងន់ក្រជាងព្រះកម្មដ្ឋានទាំងឡាយដទៃ លំបាកចំរើនជាងព្រះកម្មដ្ឋានទាំងឡាយដទៃ ព្រោះហេតុជាមនសិការនៃព្រះសម្មាសម្ពុទ្ធ នឹងព្រះបច្ចេកពុទ្ធ, ព្រះពុទ្ធសាវ័ក នឹងព្រះពុទ្ធជិនោរសទាំងឡាយ ៗ អានាបានស្សតិកម្មដ្ឋាននេះ ព្រះអរិយបុគ្គលទាំងពួងមានសម្តេចព្រះសម្មាពុទ្ធជាម្ចាស់ជាដើម នឹងព្រះមហាបុរសទាំងឡាយដ៏ជាសែស្រឡាយផៅពង្សនៃសម្តេចព្រះសម្មាសម្ពុទ្ធទាំងឡាយ ធ្វើមនសិការកំណត់យ៉ាងណាៗ ក៏ល្អិតសុខុមយ៉ាងនោះៗ ព្រោះហេតុនោះ ព្រះយោគាវចរអ្នកចំរើនអានាបានស្សតិកម្មដ្ឋាន គប្បីប្រាថ្នានូវសតិដ៏ល្អិតនឹង

---

១) សូមត្រាប់ពាក្យថា កម្មដ្ឋាននឹងភាវនា ប្រើប្តូរគ្នាបាន គឺថា អានាបានស្សតិកម្មដ្ឋានក៏បាន ថាអានាបានស្សតិភាវនាក៏បាន ។

បញ្ញាដ៏ល្អ ៗ សតិនិងបញ្ញាមានកម្លាំងច្រើន សតិនិងបញ្ញាដ៏ល្អិត ប្រៀបដូចបុគ្គលដេរសំពត់សាច់ដ៏ល្អិតម៉ត់ រមែងប្រាថ្នាឲ្យឃើញម្ជុលដែល អាចដេរបានសម្រេចសេចក្ដីប្រាថ្នា បើសតិនិងបញ្ញាគ្រោតគ្រាតហើយ មិនអាចចំរើននូវអានាបានស្សតិឲ្យសម្រេចបានឡើយ ៗ ព្រះយោវចរអ្នកចំរើននូវព្រះអានាបានស្សតិកម្មដ្ឋាននោះ ប្រកបដោយសតិនិងបញ្ញាដ៏-ល្អិតសុខុម គឺសំដែងនូវឱកាសដែលខ្យល់អស្សាសបស្សាសៈប៉ះពាល់ត្រូវនឹងនិមិត្តហើយ គប្បីពិចារណាហាមឃាត់បាន គប្បីកំណត់ក្នុងខាងចុងនាសិក កំណត់នូវនិមិត្តក្នុងទីដែលខ្យល់ប៉ះត្រូវតែប៉ុណ្ណោះ ដូចជាបុរសភ្ជួរស្រែ កសិ កសិត្វា ធម្មតាបុរសភ្ជួរស្រែនោះ លុះភ្ជួររួចហើយ ក៏ដោះលែងគោឲ្យទៅរកស៊ីស្មៅ ចំណែកខ្លួនអង្គុយនៅក្រោមដើមឈើឲ្យបាត់ក្ដៅក្រហាយ គោទាំងនោះ ក៏ចូលទៅក្នុងដងព្រៃយ៉ាងលឿនរហ័ស យោ ហោតិ ឆេកោ អ្នកស្រែណាជាមនុស្សឈ្លាសវៃ អ្នកស្រែនោះប្រាថ្នានឹងចាប់គោទាំងឡាយយកមកទឹមក្នុងនឹម ក៏ដើរទៅតាមស្នាមជើងគោទាំងនោះ គ្រាប់ចូលទៅក្នុងដងព្រៃកាន់ខ្សែនឹងដន្ទញ ចូលទៅអង្គុយប្រដេកចាំឃ្លាំមើលគោនៅកំពង់ទឹកដែលគោទាំងឡាយនឹងមកប្រជុំគ្នាផឹកទឹក វិសជ្ជាតិ វិវរិត្វា ចំណែកគោទាំងនោះគ្រាប់ស្វែងរកស្មៅនឹងទឹកជាអាហារ លុះដល់វេលាល្ងាចក៏ត្រឡប់

មកឯកំពង់ទឹកជាទីប្រជុំគ្នា ចុះទៅងូតផឹកទឹករួចឡើងមកឈរនៅមាត់ច្រាំង រស្មិយា ពន្ធិត្វា អ្នកស្រែក៏ចាប់គោចងនឹងខ្សែ ហើយកាន់ទឹងជន្លួញ វាត់នឹងរំពាត់ដេញគោយកទៅ យោជេត្វា ទឹមចូលក្នុងនឹមហើយ ភ្ជួរស្រែរបស់ខ្លួនតទៅទៀតបានដូចចិត្តប្រាថ្នា សេចក្តីនេះ មានឧបមាយ៉ាងណា? ព្រះយោគាវចរអ្នកចំរើននូវអានាបានស្សតិកម្មដ្ឋាននោះ ក៏មិនត្រូវស្វែងរកទីមកនឹងទីទៅនឹងខ្យល់អស្សាសបស្សាសៈឡើយ ត្រូវប្រកាន់យកតែខ្សែគឺសតិ នឹងជន្លួញគឺបញ្ញា គប្បីកំណត់ចំណាំតែឱកាសដែលអស្សាសបស្សាសៈប៉ះពាល់ត្រូវជាប្រក្រតី គឺត្រង់ខាងចុងនៃនាសិកតែម្យ៉ាងប៉ុណ្ណោះ ដូចជាអ្នកស្រែនោះឯង ។

លុះបានកំណត់ចាំជាក់យ៉ាងនេះហើយ មិនយូរប៉ុន្មាន ខ្យល់អស្សាសបស្សាសៈនឹងកើតប្រាកដក្នុងចិត្ត ប្រៀបដូចជាគោទាំងឡាយដែលមករកកំពង់ជាទីប្រជុំគ្នា ទើបចាប់ចងនឹងខ្សែគឺសតិឲ្យជាប់មាំ មិនឲ្យគោគឺខ្យល់អស្សាសបស្សាសៈឃ្លាតទៅឆ្ងាយបាន ហើយទឹមចូលក្នុងនឹមគឺអានាបានស្សតិកម្មដ្ឋាន ហើយប្រហារចាក់នឹងជន្លួញគឺបញ្ញាត្រិះរិះពិរណាដោយសព្វគ្រប់ល្អិតល្អន់ ប្រកបរឿយ ៗ ក្នុងព្រះកម្មដ្ឋាន និមិត្តក៏នឹងកើតឡើង តំ បនេតំ និមិត្តដែលកើតដល់ព្រះយោគាវចរកុលបុត្រទាំងឡាយនោះ នឹងបានកើតឡើងប្រាកដតែម្យ៉ាងក៏ឥតអង្គីមាន អាចារ្យពួកខ្លះពោលថា កស្សចិ សុខំ សម្ផស្សំ ការដែលពាល់ត្រូវ

នូវសេចក្តីសុខនៃព្រះយោគាវចរអង្គខ្លះ កាលកើតឡើងរមែងប្រាកដដូចជាប៉ុយគប្ភសំឡី ៗ

អដ្ឋកថាសុ បន ក្នុងព្រះអដ្ឋកថាទាំងឡាយមានពាក្យពោលថា ឥទំ ហិ និមិត្តំ ពាក្យដែលថានេះ ត្រូវពិតហើយ និមិត្តនេះមានប្រាកដដល់ព្រះយោគាវចរដូចជារូបផ្កាយ ពួកខ្លះប្រាកដដូចជាដុំកែវមណី ពួកខ្លះដូចដុំកែវមុក្តា ពួកខ្លះប្រាកដមានសុខុមសម្ផស្ស ឧបមាដូចគ្រាប់នៃកប្បាស ពួកខ្លះប្រាកដដូចជាអង្រ្កែដែលបុគ្គលធ្វើដោយឈើខ្លឹម ពួកខ្លះប្រាកដដូចជាសង្វារដែលធ្វើដោយផ្កា ពួកខ្លះប្រាកដដូចអណ្តាតភ្លើង ពួកខ្លះនិមិត្តមានសុខសម្ផស្សស្មើដូចខ្យល់បក់ត្រូវកាយា ៗ និមិត្តនេះពួកខ្លះប្រាកដដូចជាសរសៃពីងពាង ពួកខ្លះប្រាកដដូចជាផ្ទៃមេឃនឹងពពក ពួកខ្លះប្រាកដដូចជាផ្កាបទុមជាតិ ពួកខ្លះប្រាកដដូចជាមណ្ឌលនៃសរីរៈ នឹងប្រាកដដូចជាមណ្ឌលនៃទិវាករទេវបុត្រក៏មាន ៗ និមិត្តនេះប្រាកដផ្សេង ៗ គ្នា មិនដូចគ្នាទេ ប្រៀបដូចនិមិត្តដែលបង្កើតដល់ភិក្ខុទាំងឡាយដែលស្វាធ្យាយទន្ទេញនូវព្រះសូត្រមានសេចក្តីដំណាលថា៖

(នៅមានត)

មធុរសវាហិណី

# សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ.ឈឹន ពិនិត្យ

( តមក )

---

## ផលកាខណ្ឌទិន្នវត្ថុកថា

សំដែងរឿងនិទានបុរសអ្នកឲ្យបន្ទះក្តារហែលឆ្លងសមុទ្រ ដោយពាក្យបាលីថា សាវត្ថិយំ កិរេកោ មនុស្សោ ដូច្នេះជាដើម ។

អធិប្បាយថា: កិរ ដូចបានឮរឿង ១ មកថា មានមនុស្សម្នាក់នៅក្នុងក្រុងសាវត្ថីបានគិតថា អាត្មានឹងធ្វើដំណើរចេញទៅកាន់ឧត្តរបថជនបទ លុះគិតហើយក៏ដើរចេញទៅកាន់ផ្លូវឆ្ងាយក្នុងគិម្ហរដូវ ( រដូវក្តៅ ) បានសេចក្តីលំបាកដោយកំដៅថ្ងៃខ្លាំងក្នុងទីពាក់កណ្តាលផ្លូវ ទើបចូលទៅឈប់សម្រាកក្រោមម្លប់ឈើមួយដើម, តែថាដើមឈើនោះមានបុរសម្នាក់ចូលទៅជ្រកមុន ឯបុរសអ្នកទៅមុននោះសោត បានឃើញមនុស្សអ្នកចូលមកដល់ក្រោយហើយក៏និយាយសុំស្ករនឹងមនុស្សនោះថា: ម្នាលសំឡាញ់ សូមអ្នកចែកស្ករមួយមាត់មកខ្ញុំឲ្យទាន ដ្បិតខ្ញុំស្រេកទឹកខ្លាំងណាស់ ខ្ញុំនឹងទំពារស្ករទទួលទានគ្រាន់មានទឹកមាត់សោះស្រេកទឹក ! ឯមនុស្សអ្នកមកដល់ក្រោយ មានចិត្តអាណិតបានឲ្យស្ករមួយមាត់ទៅបុរសនោះបរិភោគក្នុងកាលនោះឯង ។ លុះបុរសអ្នកសុំនោះបានទទួល

យកស្វាម្បបរិភោគហើយ  ក៏បានឲ្យកហាបណៈជាដំឡៃស្វាម្បដល់មនុស្ស អ្នកឲ្យនោះវិញ ។

លុះចំណេរកាលមកជាខាងក្រោយៈទៀត  បុរសទាំងពីរនាក់ក៏បាន ឡើងសំពៅទៅដើម្បីជួញជាមួយនឹងឈ្មួញឯទៀត លុះកន្លងទៅបាន៧ថ្ងៃ សំពៅក៏ត្រូវខ្យល់ព្យុះបោកបែកខ្ចាយលិចចុះក្នុងកណ្ដាលសមុទ្រនោះ ។

ឯមនុស្សទាំងឡាយក៏លិចលង់នៅក្នុងសមុទ្រ  ជាចំណីត្រីនិងអណ្ដើក ទាំងអស់ទៅ  នៅសល់តែបុរសពីរនាក់  គឺបុរសអ្នកសុំស្វាម្នាក់ ដោយ បានបន្ទះក្ដារមួយបន្ទះពឹងផ្អែកញដំទ្រូងហើយហែលទៅ  នឹងតម្តុលបុរស អ្នកឲ្យស្វាម្បម្នាក់  ក៏បានហែលទឹកសមុទ្រនោះទៅដែរ ។  លុះជនទាំង ពីរនាក់ហែលឆ្លងទឹកសមុទ្រកន្លងទៅបាន ៧ ថ្ងៃ  ក៏បានជួបប្រទះស្គាល់ គ្នាទៅវិញទៅមកជាក់ច្បាស់  ក្នុងវេលានោះឯង ។

បណ្ដាបុរសទាំងពីរនាក់នោះ  បុរសអ្នកសុំស្វាដែលបានឲ្យកហា- បណៈហើយទទួលយកស្វាម្បមកទំពារស៊ីនោះ គេបានបន្ទះក្ដារ មួយបន្ទះ មកក្រាប់នឹងទ្រូងហើយហែលឆ្លងទៅដូចបានពណ៌នាហើយ ។

ឯបុរសដែលបានឲ្យស្វាម្បពុំបានវត្ថុទ្រាប់ហែលទេ  ត្រូវហែលឆ្លង សមុទ្រតែដៃទទេ  ក៏ដល់នូវសេចក្ដីទុក្ខលំបាកអស់កម្លាំងពន់ពេក ។

ចំណែកឯបុរសដែលបានបន្ទះក្ដារតោងហែលឆ្លងទៅ  មានកំឡាំង

គ្រាន់បើ កំមានសទ្ធានចិត្តសប្បុរសប្រកបដោយកតញ្ញូកតវេទិតាធម៌បាន នឹកដល់ឧបការគុណដែលគេបានឲ្យស្លាម្លូដល់ខ្លួនហើយនោះ ទើបលះបន្ទះក្តាររបស់ខ្លួនឲ្យទៅបុរស ដែលមានគុណនោះគ្រាន់ហែលឆ្លងទឹកសមុទ្រ ឯខ្លួនឯងទំអត់ជន់ហែលឆ្លងទៅតែខ្លួនទទេ ៗ តម្ពុលទាយកបុរសដែលបានក្តារគោងក៏ទំហែលឆ្លងលះបង់ចោលសំឡាញ់របស់ខ្លួន ដោយមានក្តារជាកំឡាំងនោះឯង ៗ រីបុរសជាសំឡាញ់អ្នកមានសទ្ធានកតញ្ញូកំខំប្រឹងហែលឆ្លងទឹកសមុទ្រដោយដៃទទេក៏អស់កម្លាំងពន់ពេក នឹងខំព្យាយាម ប្រឹងហែលទៅទៀតពុំកើតបំរុងតែនឹងលិចលង់ក្នុងទឹកសមុទ្រនាកាលនោះ ៗ ដោយតេជៈផលកតញ្ញូកតវេទិតាធម៌នៃបុរសនោះទើបនាងទេវធីតាឈ្មោះមណីមេខលា ដែលនៅអាស្រ័យពង្សសមុទ្របានឃើញបុរសនោះបំរុងនឹងលិចលង់ដូច្នោះហើយ ក៏រំពឹងគិតពិចារណាថាបុគ្គលជាសប្បុរសយ៉ាងនេះ មិនគួរនឹងឲ្យវិនាសឡើយ លុះគិតដូច្នេះហើយក៏ស្ទុះចុះមកដោយឆាប់ហ័សរួសរាន់ ដោយកម្លាំងនៃសេចក្តីរលឹកគុណរបស់បុរសនោះឯង ៗ ទេវធីតាក៏បានដល់នូវសមុទ្រមួយរំពេចដោយអានុភាពឫទ្ធិរបស់ខ្លួន ទើបពារចម្លងបុរសនោះឲ្យបានដល់នូវត្រើយសមុទ្រដោយគុណានុភាពនៃសប្បុរសនោះឯង ៗ

កាលនោះ បុរសដែលបានឲ្យទានស្លាម្លូក៏បានដល់ត្រើយស្ថិតនៅ

លើទីគោក ហើយបានឃើញបុរសអ្នកទទួលយកស្លាម្មមានសន្តានកត·ញ្ញូនោះ បានជូនដល់គោកមុនខ្លួន ក៏ស្ញើចស្ញែងជាអស្ចារ្យក្នុងចិត្តពន់·ពេកទើបសួរថា! ម្នាលសំឡាញ់អ្នកមានធុរៈស្មើ! សំឡាញ់អ្នកបានជូនមកដល់ត្រើយមុនខ្ញុំ តើអ្នកបានជូនដោយអ្វី ? ។

ឯបុរសអ្នកទទួលស្លាម្មនោះ បានពោលតបវិញថា: ម្នាលសំឡាញ់ដ៏ចំរើន! ចំណែកខ្លួនខ្ញុំពុំបានជិះខ្លួនសោះឡើយ ស្រាប់តែបានដល់ត្រើយស្ថិតនៅលើទីគោកតែម្តង ដោយសុខសប្បាយឥតមានភ័យអន្តរាយអ្វីឡើយ ។

គ្រានោះ នាងទេវធីតាក៏សំដែងសរីរៈខ្លួនបង្ហាញឲ្យប្រាកដជាក់ស្តែង ហើយនិយាយប្រាប់ហេតុដែលខ្លួនបានចម្លងស្មូត្រជាបទព្រះគាថាទាំងឡាយដូច្នេះថា :

យោ មាតរំ បិតរំ វា ធម្មេន ឥធ បោសតិ
រត្តិន្ទិវំ សទា ទេវា សមុទ្ទេ វា ថលេបិ វា ។

អធិប្បាយជាសេចក្តីថា : បុគ្គលណាមួយមានចិត្តជាសប្បុរសបានចិញ្ចឹមរក្សាមាតាក្តីបិតាក្តី ដោយឧបដ្ឋានធម៌ក្នុងលោកនេះ ទេវតាទាំង·ឡាយតែងរក្សាបុគ្គលនោះ ទោះត្រាច់ទៅក្នុងសមុទ្រក្តីក្នុងទីគោកឬព្រៃភ្នំជាដើមក្តី សព្វកាលទាំងពួងពិត ។

យោ វេ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ

រក្ខន្តិ តំ សទា ទេវា សមុទ្ទេ ច ថលេបិ ច ។

បុគ្គលណាមួយបានដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹកដោយសុទ្ធចិត្តហើយ ទេវតាទាំងឡាយតែងតាមរក្សាបុគ្គលនោះ ទោះត្រាច់ទៅក្នុងសមុទ្រក្តី ក្នុងទីគោកឬព្រៃក្តីជាដើមក្តី សព្វកាលទាំងពួង ។

បញ្ចដ្ឋទសសីលានិ បាដិមោក្ខញ្ច សំវរំ

បាលេតិ យោ តំ បាលេន្តិ ទេវា សព្វត្ថ សព្វទា

បុគ្គលណាមួយទោះគ្រហស្ថក្តី អ្នកបួសក្តីបានរក្សាសីលប្រាំ សីលប្រាំបី សីលដប់ក្តី បានសង្រួមតាមព្រះបាដិមោក្ខក្តី ទេវតាទាំងឡាយតែងតាមរក្សាបុគ្គលទាំងអស់នោះក្នុងទីទាំងឡាយសព្វកាលទាំងពួង ។

បូរេតិ តីហិ ទ្វារេហិ តិវិធំ សុចរិតន្តុ យោ

បាលេន្តិ តំ សទា ទេវា សមុទ្ទេ ច ថលេបិ ច ។

ម្យ៉ាងទៀតបុគ្គលណាមួយបានញ៉ាំងសេចក្តីសុចរិតទាំង ៣ ប្រការ ឲ្យពេញបរិបូណ៌ដោយទ្វារទាំងបីគឺ កាយទ្វារ វចីទ្វារ មនោទ្វារ ឲ្យស្អាតបរិសុទ្ធល្អហើយ ទេវតាទាំងឡាយតែងតាមរក្សាបុគ្គលនោះ ទោះត្រាច់ទៅក្នុងសមុទ្រក្តី ក្នុងទីគោកឬព្រៃក្តីជាដើមក្តី សព្វកាលទាំងពួង ។

យោ សប្បុរិសធម្មេសុ ឋិតោវ ភាគតេជិនកា

បាលេន្តិ តំ សទា ទេវា សមុទ្ទេ ច ថលេបិ ច ។

បុគ្គលណាមួយបានស្ថិតនៅក្នុងសប្បុរិសធម៌ទាំងឡាយ មានមិនប្រព្រឹត្តសំឡាប់សត្វជាដើម ជាអ្នកដឹងនូវឧបការគុណដែលអ្នកដទៃបានធ្វើដល់ខ្លួនហើយ ធ្វើតបគុណគេវិញដោយពិត, ទេវតាទាំងឡាយតែងតាមរក្សាបុគ្គលនោះទោះទៅក្នុងសមុទ្រក្តី ក្នុងទីគោកឬព្រៃភ្នំជាដើមក្តី សព្វកាលទាំងពួង ។

លំដាប់នោះ បុគ្គលជាសប្បុរស លុះបានស្តាប់គាថានោះហើយ កំពោលពាក្យសួរគេវិញថា:

នេវ ទានំ អទាសាហំ ន សីលំ បរិបាលយិំ
កេន មេ បុញ្ញកម្មេន មមំ រក្ខសិ ទេវតា
បុច្ឆាមិ សំសយំ តុយ្ហំ តំ មេ អក្ខាហិ ទេវតេ ។

អធិប្បាយថា: បពិត្រទេវតា ខ្ញុំពុំបានឲ្យទាន ពុំបានរក្សាសីលទេ ចុះទេវតារក្សាខ្ញុំដោយបុញ្ញកម្មដូចម្តេចទៅ, ខ្ញុំសូមសួរសេចក្តីសង្ស័យចំពោះអ្នក សូមអ្នកសំដែងប្រាប់នូវសេចក្តីសង្ស័យនោះដល់ខ្ញុំឥឡូវនេះឯង ។

លុះទេវតាបានស្តាប់ហើយក៏ពោលពាក្យជាបទព្រះគាថាដូច្នេះថា:

"ម្នាលមាណព! អ្នកកាលបើសំពៅបែកធ្លាយហើយបានបន្ទះក្តារផ្ចាប់អែបទ្រូងហែលឆ្លងសមុទ្រសាគរដែលបុគ្គលឆ្លងបានដោយក្រ ព្រោះឥតមានកំពង់ឥតមានកោះត្រើយជាឱកាសវាលល្វឹងល្វើយ គួរខ្លាចស្ញប់ស្ញែងក្រពេក ប៉ុន្តែអ្នកបានស្ថិតនៅក្នុងសប្បុរិសធម៌មិនអាឡោះអាល័យ

ខ្លួនហើយបានឲ្យបន្ទះក្តាររបស់ខ្លួន ដល់បុរសជាមិត្តស្និទ្ធស្នាល ដោយអំណាចនៃទានគ្រាន់តែបានឲ្យស្លាម្លូដល់ខ្លួនមួយដងប៉ុណ្ណោះ, សប្បុរសធម៌របស់អ្នកទីងទានក្តាររបស់អ្នកនោះឯង បានជាទីពឹងមាំរបស់អ្នកក្នុងសមុទ្រសាគរនេះពិត អ្នកត្រូវដឹងដោយប្រការដូច្នេះចុះ" ។

ទេវតានោះ បានពោលយ៉ាងនេះហើយក៏ចាត់ឲ្យបុរសទាំងពីរនាក់បរិភោគអាហារទិព្វដ៏ផ្អែតបរិបូណ៌ស្រេចហើយ ឲ្យប្រដាប់ស្លៀកពាក់តាក់តែងខ្លួនដោយសំពត់ទីងគ្រឿងអលង្ការដ៏ជាទិព្វវិសេសរួចហើយ ក៏នាំទៅនគរសាវត្ថីវិញមួយរំពេចដោយអានុភាពរបស់ខ្លួន ហើយលាត្រឡប់មកកាន់សមុទ្រវិញ ។

ចាប់ដើមអំពីកាលនោះមក បុរសទាំងពីរនាក់បានធ្វើកុសលកម្មនោះឲ្យជាអារម្មណ៍ហើយបរិច្ចាគទ្រព្យឲ្យទានរក្សាសីលប្រាំសីលប្រាំបីជាប់ជានិច្ច លុះអស់អាយុសង្ខារហើយបានឡើងទៅកើតក្នុងស្ថានសួគ៌ទេវលោកសោយទិព្វសម្បត្តិជាសុខក្សេមក្សាន្តដរាបដល់កាលឥឡូវនេះឯង ។

ព្រោះហេតុដូច្នោះ ទើបព្រះអរហន្តទាំងឡាយលោកពោលជាបទព្រះគាថាដូច្នេះថា:

ឯវំ បរិត្តកុសលេន បិ សាគរស្មឹ

សត្តា លភន្តិ សរណំ ខលុ ធេវ

តាហិ តុម្ហេ សប្បុរិសតំ ច វិនាសយត្ថ
មា ភោ បមជ្ជថ សទា កុសលប្បយោគំ ។

អធិប្បាយថា: សត្វទាំងឡាយបាននូវទីពឹងអំពីសំណាក់នៃទេវតា ដោយចំណែកមួយក្នុងសមុទ្រសាគរ ដោយកុសលមានប្រមាណតិចយ៉ាងនេះឯង, ម្នាលអ្នកទាំងឡាយដ៏ចំរើន ! អ្នកទាំងឡាយមិនត្រូវញុំាងភាពខ្លួនជាសប្បុរសឲ្យវិនាសទៅទេ មិនត្រូវប្រមាទប្រហែសធ្វេសនូវកិរិយាប្រកបព្យាយាមសន្សំកុសលធម៌ក្នុងកាលទាំងពួងឡើយ ត្រូវតែខំឧស្សាហ៍ព្យាយាមសន្សំនូវការជាកុសលសព្វៗកាលតទៅខាងមុខដោយពិត ។

សំដែងរឿងនិទានបុរសអ្នកឲ្យបន្ទះក្តារហែលឆ្លងទឹកសមុទ្រ នឹងឲ្យទានស្វាម្ចូ ជានិទានគំរប់ប្រាំមួយ ក្នុងវគ្គទីពីរក៏ចប់សេចក្តីដោយសង្ខេបតែប៉ុណ្ណោះឯង ។

(នៅមានត)

# លោក អ៊ុម-ភន បម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-តូរ ពិនិត្យ

(តមក)

---

រីលោកផងទាំងឡាយ នាបីហៅថាមិនស្លាប់នោះឥតមានឡើយ, ចៅមហោសថគិតដូច្នោះហើយថា តុំ រីនាង អមរា ឆាម ឈ្មោះអមរាឬអ្វី ? ។ នាងអមរាស្តាប់ហើយ ឆ្លើយថា អើអញខ្ញុំឈ្មោះដូចអ្នកថានោះហោង ។ ព្រះមហោសថថា ភទ្ទេ ម្នាលនាងអើយ ! នាងយកយាគូទៅជូននរណា ? ។ រីនាងអមរាទេវី នាងស្រដីប្រាប់ទៅចៅមហោសថអ្នកប្រាជ្ញ ដែលអាចដណ្តឹងសួរមកនាងនោះថា សាមិ ម្នាលអ្នកអើយ ! អញខ្ញុំយកទៅជូនទេពតារក្សពីមុន, ពោធិសត្វថា នាបីហៅថាជាទេពតាពីមុននោះ គឺម្តាយអាពុកឯង មិនអ្នកឯទៀតឡើយ គិតដូច្នោះហើយថា នាងយកយាគូទៅជូនម្តាយអាពុកហ៎ះ ? ។ នាងអមរាទេវី នាងស្រដីប្រាប់ទៅពោធិសត្វថា អើដូចអ្នកថានោះហោង ។ ពោធិសត្វថា អាពុកនាងធ្វើការអ្វី ? ។ នាងអមរាថា អាពុកអញខ្ញុំធ្វើការមួយជាពីរ ។ ពោធិសត្វគិតថា នាបីហៅធ្វើការមួយជាពីរនោះ គឺធ្វើស្រែមិនទេឡើយ, ពោធិសត្វរំពឹងគិតថា ភទ្ទេ ម្នាលនាងអើយ ! អាពុកនាងទៅភ្ជួរស្រែហ៎ះ ? ។ នាងអមរាថា អើ ដូចអ្នកថានោះហោង ។

ពោធិសត្វថា អាពុកនាងទៅធ្វើស្រែត្រង់ឋានឯណាហ៎ះ ? ។ នាងអមរាទេវីនាងស្រដីប្រាប់ថា ឋានត្រង់ណាគេទៅតែម្ដងមិនមកវិញឡើយ ។ ពោធិសត្វគិតថា នាឋានគេទៅតែម្ដងមិនមកវិញនោះ គឺព្រៃស្មសានឋានដែលគេដុតខ្មោចមនុស្សសត្វផងទាំងឡាយឯងមិនទេឡើយ ហើយពោធិសត្វពោលថា រីអាពុកនាងទៅធ្វើស្រែខាងព្រៃស្មសាន ឋានដែលគេដុតខ្មោចនោះហោង ។ នាងថា កើដូចអ្នកថានោះហោង ។ ពោធិ-សត្វថា ម្នាលនាងអើយ ! នាងនឹងមកឥឡូវនេះវិញ ឬ នាងពុំទាន់មក ? ។ នាងអមរាឆ្លើយថា សាមិ ម្នាលអ្នកអើយ ! ទោះយោបីគេនោះមក អញខ្ញុំមិនមកឡើយ, ទោះយោបីគេមិនបានមកទេអញខ្ញុំមកវិញហោង ។ ពោធិសត្វរំពឹងគិតថា កទ្នេ ម្នាលនាងអើយ ! រីអាពុកនាងទៅធ្វើស្រែត្រើយនាយស្ទឹងនោះហ៎ះ ? រីទឹកជន់មកនាងមិនបានមកឡើយ, បើទឹកពុំជន់មក នាងមកហោង ។ នាងអមរាថា កើដូចអ្នកថានោះហោង ។

ឃត្តកំ អល្លាបសល្លាបំ តត្វា អជ ធំ អមរា-ទេវី ត្វំ យាតុំ បរិស្សសិ សាមិកំ ឆមេត្តសិ ។

ហៃសាធុសប្បុរសផងទាំងឡាយអើយ ! រីអ្នកទាំងពីរស្រដីនឹងគ្នាទៅវិញទៅមកអម្បាលនោះហើយ រីនាងអមរាទេវី នាងធ្វើសាធុការអញ្ជើញពោ-ធិសត្វថា ម្នាលអ្នកកំឡោះមានរូបល្អមេត្រីសំដីពិរោះអម្ចាស់ប្អូនអើយ !

ចូរអ្នកពិសាបបរយាគូ អំពីប្អូនចំអែតអាត្មា បំបាត់សម្រេកគំលានអ្នក ហោង ។ រីព្រះមហាសត្វអ្នកប្រាជ្ញអាចរំពឹងគិតថា គន្ធេ ម្នាល នាងស្រីក្រមុំព្រហ្មចារីស្រីមានរូបល្អសំឡាញ់បងអើយ ! បងស្តាប់ពាក្យ នាងស្រដីមកនោះ ពីរោះ ៗ ពេក បងនឹងយកធំហោង ។ នាងអមរា នាងដាក់ថ្នាំងយាគូអំពីសិរសាអាត្មាចុះ ហើយអង្គុយញ្ញជំហានមួយនឹងព្រះ ពោធិសត្វនោះហោង ។ រីព្រះមហាសត្វគិតថា នាងអមរានេះបើ សិនជាមិនលាងពាន មិនឲ្យទឹកអញលាងដៃ ហើយអញនឹងលះបង់ លែងនាងនាហានេះ ហើយអញទៅហោង ។ រីនាងអមរាសោត នាង យកទឹកលាងដៃ លាងជើង លាងពានជាស្អូរបហើយ នាងក៏គូរយាគូ ហើយជូនដាក់ទៅក្នុងពាន ។ ពោធិសត្វយល់យាគូនោះល្អល្អិតហើយ, លំដាប់នោះ, ព្រះមហាសត្វស្រដីនឹងនាងអមរាថា ម្នាលនាងអើយ ! រីយាគូនេះ ដ្បិតម្ដីក៏ទាប់អម្បាយម៉្លេះ? ។ នាងថា ម្នាលអ្នកអើយ ! យើងឥតទឹក ។ ពោធិសត្វថា ពុំបានទឹកនាងក្មេងហ៎ះ? ។ នាងអមរាថា អើដូចអ្នកថានោះហោង ។ រីនាងអមរាទេវី នាងជូសយាគូនោះទុកឲ្យ អ្នកអាពុក សំណល់ដែលអំពីនោះ នាងជូសឲ្យពោធិសត្វ, រីពោធិសត្វ អ្នកធីយាគូនោះស្រេចហើយខ្ពុរមាត់បិតនៅហោង ។ ក្នុងកាលនោះ មានដើមពុទ្រាមួយខាងនាហាននោះ ទ្រង់នូវផ្លែទុំប្រពៃពេកហោង ។

( សោ តំ អភិចិហត្វា ជលាធិ ខិបធិ អជ ធិ

មហាសត្តោ ជានេមហាំបិ ផលំ ទេន្តីតិ អាហា ) ។ រីនាងអមរា នាងប្រងាប់ស្វាមីឲ្យពោធិសត្វបរិភោគស្រេចហើយ នាងលាពោធិសត្វ ហើយនាងឡើងបេះផ្លែពុទ្រាដាក់ក្នុងថង់នាងជាស្រេចហើយ ។ លំដាប់នោះ ព្រះមហាសត្វស្រដីទៅនឹងនាងអមរាថា ភទ្ទេ ម្នាលនាងអើយ ! ចូរនាងឲ្យផ្លែពុទ្រាដក់នោះមកយើងខ្ញុំវ៉ា ។ នាងអមរាពិនិត្យគិតថា អ្នកនេះជាអ្នកប្រាជ្ញក្តី ពុំជាអ្នកប្រាជ្ញក្តី អញមិនដឹងឡើយ អញនឹងលងអ្នកនេះបន្តិចហ៎ : នាងអមរាគិតនូវប្រការអម្បាលនោះហើយ នាងស្រដីថា សាមិ ម្នាលអ្នកមានរូបល្អមេត្រីសំដីពីរោះអើយ ! អ្នកចង់ពិសាផ្លែពុទ្រាក្តៅ ឬ អម្ចាស់បួន ឬ អ្នកចង់ពិសាផ្លែពុទ្រាត្រជាក់ ? ។ រីពោធិសត្វមហោសថអ្នកប្រាជ្ញ អាចដឹងឈ្វេងយល់ប្រាជ្ញានាង លងកលឲ្យយល់ប្រាជ្ញានូវប្រការអម្បាលនោះហើយ ពោធិសត្វធ្វើដូចជាមិនដឹងនឹងចង់លងនាងស្រដីថា ហៃនាងអមរាអើយ ! អញចង់ធីផ្លែពុទ្រាក្តៅ ។ លំដាប់នោះនាងអមរាបេះផ្លែពុទ្រានោះបោះពាលនាឋានដីធូលីខ្សាច់ ហើយនាងថា សាមិ ម្នាលអ្នកអើយ ! អញ្ជើញអ្នកយកពិសាហោង ។ ពោធិសត្តោ តំ គហេត្វា ធមេន្តោ ខាទិ ។ រីពោធិសត្វ គឺព្រះមហោសថអ្នកប្រាជ្ញអាចរើសយកផ្លែពុទ្រានោះ ផ្លុំធូលីដីខ្សាច់ចេញហើយទើបធីហោង, ហើយនាងអមរានឹងចង់លងពោធិសត្វ ក៏ស្រដីនូវពាក្យវិញទៀតថា អម្ចាស់ចង់ពិសាផ្លែពុទ្រាត្រជាក់ឬ

ពោធិសត្វថា ភទ្ទេ ម្នាលនាងស្រីក្រមុំព្រហ្មចារីសំឡាញ់បងអើយ! ចូរនាងឲ្យផ្លែពុទ្រាត្រជាក់អញទឹងផងហោង ៗ លំដាប់នោះ, នាងអមរាបេះផ្លែពុទ្រាបោះចុះទៅនាភូមិបាទមានស្មៅនោះហោង ៗ ពោធិសត្តោ តំ កហេត្វា ជមេន្តោ ខាទិត្វា អយំ ធារកោ អតិវិយ បណ្ឌិតោតិ បុចិឆតិត្វា បុចិតុសិ ៗ រីពោធិសត្វ គឺចៅមហោ-សថអាចរើសយកផ្លែពុទ្រានោះមិនបានផុំដីឡើយ រើសតែហោង, ហើយពោធិសត្វគិតថា រីក្មេងស្រីក្រមុំព្រហ្មចារីមានប្រាជ្ញាច្រើនក្រពេកហ្ន៎! ម្ល៉ោះហើយពោធិសត្វ មានព្រះរាជហឫទ័យត្រេកអរសោទរនឹងនាងពេកហោង ៗ រីនាងអមរា ចុះមកអំពីដើមពុទ្រានោះមកឈ្ងឹបាទនោះហោង ៗ រីពោធិសត្វសោត ស្រដីនឹងនាងអមរានូវពាក្យដូច្នេះថា ភទ្ទេ ម្នាលនាងក្រមុំសំឡាញ់បងអើយ! នាងអាយេ! នាបាទផ្ទះនាងជាប្អូននៅភូមិបាទឯណា បងនឹងទៅចង់ស្គាល់ហ្ន៎? ចូរនាងបង្ហាញផ្លូវបង ៗ នាងអមរានាងសំដែងបង្ហាញផ្លូវពោធិសត្វថា សាមិ ម្នាលអ្នកអើយ! ចូរអ្នកមើលដៃខ្ញុំឲ្យយាគូអ្នក ខ្ញុំបង្ហាញផ្លូវ, ឯដៃខ្ញុំមិនឲ្យយាគូអ្នកខ្ញុំមិនសំដែងបង្ហាញផ្លូវអ្នកឡើយ, ទេះអំពីនេះផ្លូវខាងឯស្តាំ បងផ្លូវខាងឆ្វេង, ផ្លូវនោះទៅនាស្រុកយវមជ្ឈកគ្រាម មានផ្សារលក់សដូវ នូវផ្សារលក់ទឹកដូវ, ឯកើតផ្ទះខ្ញុំមានទឹកជ្រៅ ត្រពាំងមានដើមរដ្ឋូសនោះ ៤ មានផ្កានោះរីកនៅដើម ជាឯកើតផ្ទះខ្ញុំនោះហោង ៗ រីនាងអមរាបង្ហាញផ្លូវ

ពោធិសត្វនូវប្រការអម្បាលនោះហើយ, នាងយកថ្នាំងយាគូទៅជូនអា-ពុកនាងហោង ។

ឆដ្ឋបដបញ្ហា និដ្ឋិតោ វិប្រស្នាផ្ទៃកំបាំង បរិបូណ៌ចប់ ដោយនូវប្រការអម្បាលនេះឯងហោង ។

សោបិ តាយ កាជិតមគ្គេន តំ គេហំ គតោ ។ អថ នំ អមរាទេវិយា មាតា ទិស្វា មហាសត្តស្ស អាសនំ ទត្វា យាគុំ បរិស្សសិ សាមីតិ អាហ ។

ហៃសាធុសប្បុរសជនទាំងឡាយអើយ ! កាលនោះ, ព្រះពោធិសត្វចៅមហោសថអ្នកប្រាជ្ញ កាច់ដើរមកដោយផ្លូវដែលនាងអមរាសំដែងបង្ហាញ មកកាន់ផ្ទះនោះហោង ។ លំដាប់នោះ, នាងអមរាពិតពិលរមិលមើលពោធិសត្វទៅកាន់ផ្ទះអាត្មា ហើយឲ្យក្រាលកន្ទេលអង្គុយនៅហើយ, ម្ដាយនាងអមរាស្រដីថា ហៃអ្នកជាកូនរូបល្អមេត្រីសំដីពីរោះសោះសា មកកាន់អញជាមាតា, អ្នកអើយ ! ចូរអ្នកពិសានូវយាគូបំពែតអាត្មាអ្នកហោង ។ ព្រះពោធិសត្វឆ្លើយថា ហៃអ្នកមេអើយ ! អញខ្ញុំបានទឹកពីនាងជាប្អូនស្រីឲ្យបន្តិច, ម្ដាយនាងដឹងហើយថា អ្នកនេះមកប្រយោជន៍នឹងយកកូនអញហើយអេះ ! ។ ព្រះមហោសថអ្នកដឹងហើយគិតថា ត្រកូលសេដ្ឋីនេះស៊ុកាពជាក្សត្រ ពោធិសត្វដណ្ដឹងថា ហៃអ្នកមេអម្ចាស់ខ្ញុំអើយ ! អញខ្ញុំចេះផ្ទុលសំពត់ញាំងអ្នកមានសំពត់ដាច់ដាចច្រើនទេហ៎ ? ខ្ញុំនឹងផ្ទុលឲ្យអ្នក

ហោង ៗ រីម្តាយនាងអមកថា ហៃចៅអើយ! អញឥតបើមានទ្រព្យ
អ្វីជួលអ្នកឡើយ ៗ ពោធិសត្វថា អែតើនឹងជាឈ្នួលអញខ្ញុំមិនចង់
យកឈ្នួលនោះឡើយ, ចូរអ្នកយកនូវសំពត់ដាចមកអញខ្ញុំនឹងជុលឲ្យអ្នក
ទទេបានហោង, អញខ្ញុំមិនយកឈ្នួលអំពីអ្នកឡើយ ៗ រីម្តាយនាង
អមកឮពាក្យពោធិសត្វថាដូច្នោះហើយ, នាងយកសំពត់ចាស់ដាច់ដាច
មកឲ្យពោធិសត្វ ៗ រីពោធិសត្វសោត យកសំពត់ដែលគេនាំមកនោះ
ជុលឲ្យហើយស្រេច ៗ រីម្តាយនាងអមកថា នាបីហៅអំពើបំណោះ
សំរិទ្ធិនៃអ្នកដ៏មានបុណ្យហោង ៗ

លំដាប់នោះ, រីពោធិសត្វថា ហៃអ្នកមេអើយ! ចូរអ្នកស្រដីប្រាប់
ដោយចំណែកផ្លូវផងទាំងឡាយ ឲ្យឮសព្ទសាយដល់អ្នកផងទាំងឡាយៗ
រីម្តាយនាងអមក ទៅស្រដីប្រាប់គេសព្វអស់ទាំងក្នុងស្រុកនោះហោង ៗ
រីពោធិសត្វ ធ្វើនូវអំពើប៉ាក់ជុល សឹងកើតមានឧបករណ៍បានមាសនោះ
មួយពាន់ដំឡឹងតែមួយថ្ងៃនោះឯង ឲ្យម្តាយនាងអមកដណ្តាំបាយនាព្រឹក
ល្ងាច ៗ រីម្តាយនាងអមកថា ហៃអ្នកអើយ! អញដណ្តាំបាយប៉ុន្មាន? ៗ
រីពោធិសត្វថា អើយើងនឹងក្នុងផ្ទះនោះអម្បាល អ្នកប្រមាណដោយនោះ
ហោង ៗ រីម្តាយនាងអមកដណ្តាំបាយច្រើន រៀបនូវចំណីអាហារផង
ច្រើន ៗ រីនាងអមកល្ងាចហើយនាងមកអំពីព្រៃ ដ៏មានក្បាលទូលនូវបាច់
ទុស នៅចង្កេះក្រញ្ញៀតនូវស្លឹកឈើជាបន្ទែអន្ទក់ផងទាំងឡាយ, នាង

ដាក់ទុសនាទ្វារផ្ទះឯកើត, នាងវិលចូលទៅក្នុងទ្វារឯលិចវិញ, មួយសោតកាលឯល្ងាចអាពុកនាងអមកមកផងហោង ។ រីពោធិសត្វបរិភោគភោជនាហារមានរសពិសាផ្សេងៗ ។ រីម្តាយអាពុកនាងអមក បរិភោគភោជនាហាររួចហើយ នាងអមកយកទឹកលាងជើងដៃម្តាយអាពុករួចហើយ លាងជើងដៃពោធិសត្វស្រេចហើយ ទើបនាងបរិភោគឯក្រោយហោងៗ ម្ល៉ោះហើយ រីពោធិសត្វត្រេកត្រអាលនាងអមកយកជាប្រពន្ធអាត្មានៅត្រង់ឋាននោះ លុះបានពីរ-បីថ្ងៃហោង ។

លំដាប់នោះ, ពោធិសត្វ មានកាលសម័យថ្ងៃមួយ ក៏ព្រះអង្គទ្រង់ចង់ល្បងលនាងអមក ទើបមានបន្ទូលដូច្នេះថា ក ទ្ធេ ម្នាលនាងប្អូនស្រីសំឡាញ់បងអើយ! នាងអាយ! ចូរនាងយកអង្ករបានកន្ទះនាឡិចំអិនជាយាគូ ជានំ ជាបាយ ឲ្យបងអំពីព្រឹកហោង ។ រីនាងអមកយកអង្ករទៅស្រិត ដើមអង្ករនោះចំអិនជាយាគូ កណ្តាលអង្ករចំចិនជាបាយ ចុងអង្ករចំអិនជានំ, រីនាងអមកនាងប្រដាប់នូវចំណីភោជនាហារដ៏សមគួរផ្សំនូវបាយនោះហោង ។ នាងលើកមកឲ្យពោធិសត្វ នូវយាគូប្រដាប់សឹងមានឱជារសប្រសើរ ។ រីពោធិសត្វសោត យកយាគូនោះសោយស្រឿងមានរសនោះពីសាផ្សព្វផ្សាយទៅនាសរសៃទាំង ៧ ពាន់ ហើយពោធិសត្វថាដូច្នេះ ក ទ្ធេ ម្នាលមេអើយ! ម្តេចក៏មិនចេះស្ងួជណ្តាំដូច្នេះ ហើយជាប្រយោជន៍អ្វីឲ្យបង់អង្ករអញអម្បាលនេះ ម្ល៉ោះហើយពោធិសត្វ

ស្តោះទឹកមាត់ចុះមួយអន្ទើកក្នុងយាគូនោះ ហើយចោលទៅនាកណ្តាលដី ។ រីនាងអមរាទេវីនាងមិនខឹងឡើយ នាងថា សាមិ ម្នាលអ្នកអើយ! រីយាគូនេះអ្នកមិនពិសា អញ្ជើញអ្នកពិសានំវិញហោង នាងឲ្យនំពោធិ-សត្វវិញ ។ រីពោធិសត្វស្រដីដូចយាគូនាងមុននោះហោង ។ រីនាងអមរាថា សាមិ ម្នាលអ្នកអើយ! ចូរអ្នកហូបបាយវិញហោង, នាងលើកបាយឲ្យពោធិសត្វ. ពោធិសត្វផាត់បាយនោះចេញ ធ្វើដូចយាគូធ្វើដូចនំនោះហោង, ហើយថា ម្នាលមេអើយ! មេមិនចេះស្លដណ្តាំទឹងជាប្រយោជន៍អ្វីឲ្យបង់ទ្រព្យអញដូច្នោះ ។ រីពោធិសត្វធ្វើដូចជាទឹងច្របល់បាយនូវនំ-យាគូទាំង ៣ ប្រការជាមួយផងគ្នាចាក់ស្រោចអំពីក្បាលដកបស្រឡាបពេញអស់ទាំងខ្លួន ហើយពោធិសត្វថា ចូរមេចុះចេញទៅអង្គុយនាទ្វារនាយ ។ រីនាងអមរានាងមិនខឹងឡើយ នាងថា សាមិ ម្នាលអ្នកអើយ! អ្នកធ្វើដូច្នេះប្រពៃពេកហោង, នាងសំពះហើយចុះទៅធ្វើដោយបង្គាប់ពោធិសត្វនោះហោង ។ រីពោធិសត្វដឹងជានាងអមរាមិនខឹង សុភាពមានចិត្តប្រាសលែងកំហឹងនោះឆ្ងាយហើយមានបន្ទូលថា ម្នាលមេអើយ! ចូរមេមកឯណេះ ។ រីនាងអមរាឮហើយដោយពាក្យពោធិសត្វ នាងមកអង្គុយទៀបពោធិសត្វនោះហោង ។ រីពោធិសត្វសោត យកសំពត់រត្តកម្ពលមួយអន្ទើនូវមាសមួយពាន់ដំឡឹងមកហុចឲ្យទៅដៃនាងអមរា ហើយថា ភទ្ទេ ម្នាលនាងអើយ! ចូរនាងយកមួយ

អន្ទើនឹងក្តីស្រឡាញ់នាងហោង, ហើយចូរនាងងូតទឹកដំរះអាត្មា ហើយចូរនាងស្លៀកទូរសំពត់គ្រឿងតុបតែងមួលនោះ នាងមកកាន់អញហោង ៗ រីនាងអមរាធ្វើដោយបង្គាប់ពោធិសត្វហើយ រីទ្រព្យបង្កើតនៅនោះក្តី រីទ្រព្យទាំងអំពីនាងក្តី, រីពោធិសត្វទៅមហោសថអ្នកប្រាជ្ញអាចឲ្យទ្រព្យទាំងអម្បាលនោះ ឲ្យមកម្តាយឪពុកនាងអមរាហើយ ពោធិសត្វលោមលាអ្នកទាំងពីរ គឺមេក្មេក ឪក្មេក ហើយសូមយកនាងអមរាមកកាន់នគរអាត្មាហោង ៗ

រីពោធិសត្វ ឲ្យស្បែកជើងទូរជូនទៅដៃនាងអមរាហើយថា កល្យាណ ម្នាលនាងអើយ! ជូននេះក្តី ស្បែកជើងនេះក្តី ចូរនាងទទួលយកពាក់អាត្មានាងហោង ៗ នាងអមរា នាងទទួលយកជូនទូរស្បែកជើងនោះកាន់ដើរទៅដល់កណ្តាលវាល នាងយកជូននោះបេញអំពីក្បាលអាត្មាលុះដល់បានទឹកនាងពាក់ស្បែកជើងដើរទៅ ៗ រីពោធិសត្វយល់ហេតុប្រការដូច្នោះ ពោធិសត្វអ្នកដណ្តឹងថា កល្យាណ ម្នាលនាងអើយ! បទអ្វីដើរនោបានទឹកនាងពាក់ស្បែកជើង ដើរនោបានគោកនាងមិនពាក់ស្បែកជើងទៅហោង ? កល្យាណ ម្នាលនាងអើយ! ហេតុប្រការអ្វីដូច្នោះ? ៗ នាងអមរាឆ្លើយថា បពិត្រអម្ចាស់ខ្ញុំអើយ! ដើរនោបានគោកបន្លាផងសឹងបានយល់, រីបានទឹកផ្លូវគ្រប់បន្លាផងខ្ញុំពុំយល់ឡើយ, ហេតុនោះហោងទើបខ្ញុំពាក់ស្បែកជើង ខ្លាចអស់ផ្លូវទូរបន្លាផងនោះវាត្រូវជើងខ្ញុំ នឹងសោយ

ទុក្ខវេទនាច្រើនពេកហោង, នាងថា ហេតុនោះហោង ខ្ញុំពាក់ស្បែកជើងក្នុងបានទឹក ។ ពោធិសត្វស្តាប់ពាក្យនាងអមរាទេវីដូច្នោះហើយ អ្នករំពឹងថា វីកេ្មងស្រីនេះ មានប្រាជ្ញាជាអ្នកប្រាជ្ញហោង ហាលភាលចាំងតាំងយូ ពាក់ដូន ប្រយោជន៍ទំនងឲ្យអម្ពរបក់ដៅថ្ងៃនាង បងអ៊ីមិនធ្វើដូចគេនោះឡើយ ហេតុប្រការអ្វី? ។ នាងអមរាស្តាប់ហើយឆ្លើយថា បពិត្រអម្ចាស់ខ្ញុំអើយ! នាបីហៅចូលព្រៃ អញខ្ញុំខ្លាចឈើស្ងួតនូវឈើពុកផង វាធ្លាក់ចុះត្រូវក្បាល, ហេតុនោះហោង ទើបខ្ញុំធ្វើអំពើដូច្នេះ ។ ពោធិ-សត្វស្តាប់ពាក្យនាងអមរា ស្រដីហេតុប្រការទាំងពីរដំពូកនោះហើយ មានចិត្តត្រេកអរស្នេហាសរផងគ្នា នាងអមរាលីលាចូលទៅក្នុងព្រះនគរមិថិលានោះហោង ។

(នៅមានត)

វប្បធម៌ខ្មែរ

# លទ្ធិសាសនាជាមូលដ្ឋានវប្បធម៌

លោក លី · ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

---

បើកាលណាគេសង្កេតពុំបានល្អិតល្អន់ គេតែងសំគាល់ថាៈ លទ្ធិសាសនាគ្រាន់តែជាការប្រៀនប្រដៅពត់កាយវាចាចិត្ត ឲ្យត្រឹមត្រង់ទៅតាមគន្លងពាក្យឱវាទនៃបុគ្គលអស្ចារ្យណាមួយប៉ុណ្ណោះ ។ ប៉ុន្តែ បើយើងពិនិត្យឲ្យជ្រាលជ្រៅទៅទៀត យើងឃើញថា លទ្ធិសាសនាប្រាកដជាមែកធាង ឬមូលដ្ឋានយ៉ាងសំខាន់នៃវប្បធម៌របស់ជាតិនីមួយ ៗ ក្នុងទ្វីបលោកនេះ ។ ហេតុនេះហើយ បានជាប្រទេសខ្លះ ដែលទើបទទួលអារ្យធម៌ក្រោយគេ ហើយដែលពុំទាន់មានមូលដ្ឋានមាំទាំប្រាកដប្រជាខាងវប្បធម៌នៅឡើយ តែងតែម្នីម្នាស្រវាស្រទេញស្វែងរកចំឡង ដឹកនាំយកលទ្ធិសាសនាណាមួយពីប្រទេសគេប្រទេសឯង យកទុកដាក់ជាសាសនាប្រចាំជាតិខ្លួន ឲ្យខ្លួនបានគោរពប្រតិបត្តិ ឬទុកជាលក្ខគោលនៃជាតិខ្លួនតទៅ ។ មិនត្រឹមតែគោរពបូជាក្នុងប្រទេសប៉ុណ្ណោះ គេថែមទាំងរិះរកវិធី

ផ្កាយហើយ ប្រឹងប្រែងផ្សាយលទ្ធិសាសនានោះឲ្យសាយភាយលេចឮខ្ចរខ្ចាយ ទៅកាន់ប្រទេសដទៃ ៗ ទៀត ទោះបីជាត្រូវចំណាយប្រាក់កាសយ៉ាងណាក៏ដោយ ៗ

ប្រទេសខ្មែរយើង, ដូចយើងពោលក្នុងអត្ថបទមុន ៗ រួចមកហើយថាជាប្រទេសមួយមានវប្បធម៌យូរយារណាស់ហើយនោះ, រមែងតែទុកដាក់លទ្ធិសាសនាជាគោលចារិកនៃវប្បធម៌ជាតិជាដរាប ។ មើលចុះរឿងរ៉ាវអស់នេះ ពុំមែនជាការចិកចាំងអ្វីឡើយ បើយើងគ្រាន់តែបើកភ្នែកនឹកដល់ប្រវត្តិសាស្ត្រយើងបន្តិច យើងក៏ឃើញភ្លាមថា៖ កាលគ្រាមុនសម័យអង្គរ រហូតមកសម័យអង្គរ ខ្មែរយើងគោរពកាន់លទ្ធិព្រហ្មញ្ញសាសនាពាសពេញប្រទេស ។ ឥទ្ធិពលនៃសាសនានេះ បានជ្រាបចូលទៅគ្របដណ្ដប់រុំស្រោបលើទំនៀមទម្លាប់, សំដីភាសានិយាយស្ដី, ក្បួនខ្នាតតម្រាប់តម្រាផ្សេង ៗ ទាំងអក្ខរសេនៃសិល្បៈគ្រប់យ៉ាង ៗ ជាកស្ដុតាង, យើងឃើញនៅសល់ទំនៀមទម្លាប់សាសនានេះច្រើនណាស់ ក្នុងការរស់នៅរបស់ជនជាតិយើង រហូតដល់សព្វថ្ងៃនេះ មានការជឿវេទមន្ត, ការរៀបគ្រឿងពលីការក្នុងពិធីអ្វីមួយ ឬការរៀបចំលំនៅស្ថាន ឲ្យត្រូវតាមក្បួនខ្នាតជាដើម ។ គ្រឿងនេះ សុទ្ធសឹងជាទំនៀមទម្លាប់ដែលដិតជាប់នៅក្នុងជីវភាពខ្មែរយើងសព្វថ្ងៃ ទោះបីជាបច្ចុប្បន្នកាលនេះខិតខំលះបង់ទៅតាមជំនឿថ្មីបន្តិចៗម្ដងក៏ដោយ ក៏មិនងាយនឹងកាត់ចេញចោលឲ្យផុតពី

សន្តានចិត្តគាម ៗ ដែរ ។ ចំពោះសំដីភាសាដែលយើងនិយាយស្តីប្រា-ស្រ័យគ្នាទៅវិញទៅមកដល់ថ្ងៃនេះវិញ យើងឃើញថានៅមានសល់ដិតជាមកេរ្តិ៍ដំណែលពីលទ្ធិសាសនានោះច្រើនណាស់ គឺមានភាសាសំស្រ្កឹតទាំងស្រុងដែលសព្វថ្ងៃនេះ បានចូលលាយច្របល់ក្នុងភាសាយើងធម្មតាហើយដែលយើងពល់គ្នា លែងទាំងនឹកនាថាពាក្យដ៏ច្រើនទោះជាភាសាសំស្រ្កឹតដែលហូរចូលតាមរយៈលទ្ធិព្រហ្មញ្ញសាសនានេះផង ។ ហេតុបានជាយើងក្លួចយ៉ាងនេះ ព្រោះវិធីអានភាសាទាំងនោះ ច្រើនតែដួលទៅតាមសំដីខ្មែរយើងអស់ទៅហើយ ។ ចំណែកក្បួនខ្នាតគោលចារិកផ្សេង ៗ វិញ យើងរមែងជួបប្រទះបុព្វបុរសយើងបង្ក្រងឡើងដោយផ្តេកគោលគំនិតរបស់លោកទៅរកលទ្ធិសាសនានេះដែរ ដូចមានរឿងរ៉ាវធ្លាក់ដិតជាប់នៅប្រាសាទបុរាណជាភស្តុតាងស្រាប់ ។

ចំណេរកាលតមក គ្រាដែលប្រទេសយើងងាកបែរទៅគោរពបូជាលទ្ធិពុទ្ធសាសនាទាំងស្រុងទៅវិញ គោលគំនិតក្នុងការប្រព្រឹត្តទៅខាងផ្នែកទំនៀមទម្លាប់, ខាងពាក្យពេចន៍និយាយស្តី, ខាងវិជ្ជាក្បួនតម្រាផ្សេងៗ និងអក្សរសិល្បៈជាដើម យើងក៏មានការផ្លាស់ប្តូរបែរទៅរកនិន្នា-ការនៃពុទ្ធសាសនាវិញដែរ ។ ហេតុការណ៍ដែលប្តូរផ្លាស់មកនេះ ងាយនឹងពិនិត្យមើលភស្តុតាងណាស់ ដ្បិតមានលក្ខណៈយ៉ាងច្បាស់នៅសល់ដល់យើងសព្វថ្ងៃនេះទាំងអស់ ។

ដើម្បីទាញសតិអារម្មណ៍របស់អ្នកអានយើងឲ្យយល់ច្បាស់ គ្មានការសង្ស័យចំពោះការបកស្រាយនេះ យើងសុំសង្កត់ខ្លាំងទៅលើផ្នែកក្បួនខ្នាត ជាគោលចារិកនៃមុខវិជ្ជាសម្រាប់ជាតិយើងបន្តិចទៅចុះ ព្រោះថាក្បួនខ្នាតគម្ពីរសាស្ត្រទាំងនេះហើយ ដែលជាគ្រូបាអាចារ្យយើងពល់គ្នា, បានសេចក្ដីថា ការសិក្សារបស់យើងបង្កបង្កើតឲ្យមានប្រាជ្ញាស្មារតីមុតមាំ ឲ្យចេះត្រិះរិះសព្វទាំងបញ្ហាពក់ជ្រៅនោះ ក៏ដោយសារតែក្បួនខ្នាតគម្ពីរសាស្ត្រទាំងនេះឯង ។ ហេតុនេះ គម្ពីរសាស្ត្រដែលគេមើលមួយភ្លែតឃើញថារូបលទ្ធិសាសនានោះ ប្រាកដជាមគំនិតប្រាជ្ញានៃយើងទាំងអស់គ្នា ជាកុលបុត្រដំណាំវង្សត្រកូលពីបុព្វបុរស ដែលកសាងគោលចារិកទាំងនោះមក ។ និស្ស័យរបស់យើងបានមាំទាំ អាស្រ័យដោយការពត់ហាត់របស់គម្ពីរសាស្ត្រទាំងនោះឯង ។ បើដូច្នេះ ការបណ្ដុះនិស្ស័យក្នុងគំនិតបញ្ញាយើង ឲ្យមានសតិអារម្មណ៍ខ្ពស់, ឲ្យចេះឈានចាប់យកវិជ្ជាទំនើបនានា ដែលៈហៅថាអារ្យធម៌នោះហើយ ដែលយើងហៅថា "វប្បធម៌" ។ ដោយយើងឃើញវប្បធម៌ខ្មែរ សុទ្ធសឹងតែដុះពន្លកចេញមកពីគោលគំនិតលទ្ធិសាសនាដូចបានពោលរាប់រៀបមកយ៉ាងនេះ ទើបយើងឲ្យឈ្មោះថា " លទ្ធិសាសនាជាមូលដ្ឋាននៃវប្បធម៌ " ។

បើយើងពិនិត្យសង្កេតតាមគោលគំនិតសរុបវិញថា៖ លទ្ធិសាសនាជាមូលដ្ឋានសាមគ្គីធម៌ ។ បានជាពោលដូចនេះ ដ្បិតយើងធ្លាប់ឃើញ

មកហើយថា បើសញ្ជាតិណាមានអ្នកស្រុកកាន់លទ្ធិសាសនារួមគ្នា ហើយមានភាពមាំទាំផងនោះ, សញ្ជាតិនោះឯងរមែងមានសាមគ្គីជាក់លាក់ណាស់ ៗ ប្រសិនណាជាអ្នកដឹកនាំប្រាជ្ញាណែនាំតម្រង់ផ្លូវឲ្យទៅកាន់សេចក្ដីចំរើន ក៏ស្រួលណាស់ទៅទៀត ព្រោះមនុស្សទាំងនេះធ្លាប់មានគំនិតរួមគ្នា ធ្លាប់មានការទុកចិត្តគ្នាទៅវិញទៅមករួមមកហើយ ៗ ជាឧទាហរណ៍, យើងឃើញប្រទេសកម្ពុជាយើងស្រាប់ហើយ គឺដោយសារតែខ្មែរមានជម្រៅគំនិតជាប់លាប់ ដែលលទ្ធិសាសនាបានអប់រំអំពីបុរាណអន្លើងមក, ទើបសម័យដែលប្រទេសជាតិត្រូវធ្លាក់ទៅនៅក្រោមឱវាទអាណាព្យាបាលបរទេស ហើយបរទេសប្រាថ្នារំលត់រំលាយវប្បធម៌យើង ដើម្បីឲ្យវប្បធម៌គេគ្របដណ្ដប់នោះ ជនជាតិយើងពុំព្រមដួលទៅតាមឡើយ ៗ យើងនៅតែនាំគ្នាបម្រះនទៀលក្រាញរក្សាវប្បធម៌យើងឲ្យបានគង់វង្សរហូតមកដល់សម័យក្ដីស្នាន ដែលមានអគ្គសម្ដេចព្រះអគ្គមគ្គុទ្ទេសក៍យើងទ្រង់ដឹកនាំឲ្យទៅកាន់វឌ្ឍនធម៌, យើងក៏មានសាមគ្គីធម៌មាំមួនពួតកំឡាំងគ្នាដង្ហែតាមព្រះរាជនៈយោបាយ ត្រាតែប្រទេសជាតិបានឯករាជ្យសម្បូណ៌សប្បាយល្អណាស់ដុះដាលដូចសព្វថ្ងៃនេះ ៗ

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Basalte | *n. m.* | ថ្មពពុះ |
| Silex | *n. m.* | ថ្មដែកភ្លើង |
| Pierre à chaux | | ថ្មកំបោរ |
| Roche calcaire | | សិលាចុណ្ណីយ |
| Silice | *n. m.* | សៃកតា |
| Roche Silice | | សិលាសៃកតា |
| Silicium | *n. m.* | ស៊ីលិស្យូម |
| Améthyste | *n. f.* | ជម្ពូរ័ត្ន |
| Opale | *n. f.* | រតនោបល (–បុល) |
| Kaolin | *n. m.* | កៅឡាំង |
| Porcelaine | *n. m.* | ប៉រស៊័ឡែន |
| Gypse | *n. m.* | ថ្មម្នាងសិលា |
| Tourbe | *n. f.* | ឥន្ធនសិលា |
| Roche combustible | | ឥន្ធនីយសិលា |
| Granulite | *n. m.* | កណិកសិលា |
| Anthracite | *n. m.* | សិលាង្គារ |
| Pegmatite | *n. m.* | ប៊ូលកណសិលា |
| Syénite | *n. f.* | ខារសិលា |
| Diorite | | ចលសិលា |
| Amphibole | *n. f.* | អំភីប៊ូល |
| Roche microbithique | | សិលាសុខុមកណ |
| Trachyte | | កក្ខឡសិលា |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ប៉ាន់ - ខាត់ រៀបរៀង*

តមក

អតិមនោហរ គុ. ដែលជាទីជាប់ចិត្តក្រៃលែង, ប្រិមប្រិយក្រៃលែង។

អតិមន្យុ គុ. ដែលក្រេវក្រោធក្រៃលែង ។

អតិមត្យ គុ. ដែលធ្លាប់ក្រៃលែង, ដែលជាសត្វប្រសើរ ។

អតិមលិន គុ. ដែលកខ្វក់ក្រៃលែង, ដែលអាក្រក់ក្រៃលែង,

អតិមហាន្ត គុ. ធំក្រៃលែង, ។

អតិមាត្រ គុ. ដែលមានមាត្រាក្រៃលែង ។

អតិមាន ពុ. មានះក្រៃលែង ។ *អតិមានិទី* គុ. ដែលមានមានះ ក្រៃលែង ។ *អតិមានិតា* ស្ត្រី. ភាពនៃបុគ្គលមានមានះ; ក្រៃពេក ។

អតិមានុស គុ. ដែលជាមនុស្សក្រៃលែង, ដែលជាទិព្វ ។

អតិមាយ គុ. ដែលមានមាយាក្រៃលែង ។

អតិមាគិណ គុ. ដែលរកក្រៃលែង, ដែលស្ទះស្ទែងក្រៃលែង ។

អតិមុក្តក ពុ. ឈ្មោះវល្លិជាតិ, វល្លិជើមស្វាយ (?) ។

*(នៅមានត)*

# ដើមកំណើតប្រាសាទអង្គរ

## លោក ល្វីហ្វីណូត៍ រៀបរៀង

ក្រមការ ជុំ-ម៉ៅ ប្រែជាភាសាខ្មែរ

លោក ញ៉ែម-ទឹម ពិនិត្យ

និងកែសម្រួលជាថ្មី

(តនឹងចប់)

---

តទៅនេះ យើងសូមត្រឡប់ទៅអធិប្បាយអំពីបញ្ហាដ៏សំខាន់ខាងដើមវិញ គឺអំពីការកសាងអង្គរ ។ ខ្ញុំស្មានថា ដូចខ្ញុំបានពោលខាងដើមរួចមកហើយថា អង្គរធំនោះ កាលដើមជាទីក្រុងសម្រាប់ពុទ្ធសាសនាក្រោមការទំនុកបំរុងនៃលោកេស្វរៈដូចជាបន្ទាយឆ្មារដែរ ។ ប៉ុន្តែ ប្រហែលជាស្តេច ១ អង្គកាន់ពុទ្ធសាសនាបានសាង ឯស្តេចនោះប្រហែលជាមិនមែនយសោវរ្ម័ន ដែលកាន់សាសនាព្រះឥស្សូរនោះឡើយ ។ សេចក្តីសន្និដ្ឋាននេះ ខ្ញុំមិនភ្លេចទេ, ជួយគ្នាជាខ្លាំងនឹងសិលាចារឹកនៅស្រុកកក់ធំ តែឥឡូវ យើងត្រូវពិនិត្យមើលឲ្យបានពិតប្រាកដ ។

សិលាចារឹកនេះ ធ្វើក្នុងសកកាជ ៩៧៤ គឺក្នុងគ្រិស្តសកកាជ ១០៥២ គឺ ១៥០ ឆ្នាំ ក្រោយឆ្នាំដែលព្រះបាទយសោវរ្ម័ន ទ្រង់សោយទិវង្គត ។ សិលាចារឹកនេះ មិនមែនធ្វើសម្រាប់តែចុះសេចក្តីអ្វី ៗ ក្នុងជាន់នោះទាំងអស់ឡើយ ។ សេចក្តីក្នុងនោះ គឺស្រង់យកតាមប្រភពដើមមក ។ ឯ

ប្រកតនោះដូចខ្ញុំបានជំរាបរួចមកហើយ មានទំនងហាក់ដូចជាប្រាកដ គឺជាបែបពង្សាវតារនៃគ្រួសារ កត់ត្រារៀង ៗ ជាប់រហូតមកចំនួន ២៥០ ឆ្នាំ ៗ ប៉ុន្តែចំពោះការនេះ, យើងត្រូវគិតដល់គំនិតនិងប្រយោជន៍របស់បុរោហិតដែលបានតែងសេចក្ដីនោះ ៗ តាមការសំគាល់របស់យើង នៅឯបន្ទាយបាយ័ន គេយកព្រះឥស្សរជំនួសព្រះពុទ្ធ ៗ យើងមិនត្រូវឆ្ងល់ឡើយពីក្រុមហោតា គឺក្រុមសង្ឃការីដែលយល់ឃើញថា ជាការអាប់ឱនណាស់ដែលយកព្រះខ្លួនទៅដាក់ក្នុងទី ដែលគេសាងសម្រាប់ព្រះឯទៀត ៗ ក្នុងជំនាន់ស្រុកខ្មែរពីដើម រឿងនេះ ឃើញថាផ្ទុយនឹងទំនៀមទម្លាប់ទាំងអស់ ព្រោះគេមិនដែលកសាងបដិមាករឯណាមួយទៅដាក់ក្នុងប្រាសាទដែលគេបោះបង់ឡើយ តែការនេះ ជាការចាំបាច់ត្រូវតែធ្វើ ដោយហេតុមានប្រាសាទស្ដេចនៅកណ្ដាលនគរ ហើយការដែលបង្កើតឲ្យមានយ៉ាងដូច្នេះក៏មិនគួរដែរ ប៉ុន្តែគេយល់ថា អយ្យកោរបស់សាសនាសិវចូលចិត្តបំបិទបំបាំងសេចក្ដីដែលមិនល្អនេះឲ្យស្ងាត់ស្ងៀមទៅ ៗ យើងសូមបញ្ជាក់បន្ថែមថា ការដែលយើងពោលមកនេះគឺត្រូវមែន ព្រោះក្រោយមកក្នុងរជ្យស្ដេចកាន់ព្រះពុទ្ធសាសនា មានពាក្យសុំឲ្យសងព្រះវិហារនោះទៅសាសនាដើមវិញ ៗ សេចក្ដីអួតអាងរបស់ស្ដេចយសោវរ្ម័ន សេចក្ដីមានះនឹងគំនិតរបស់បុរោហិតនៃស្ដេចនេះក៏ត្រូវគ្នា ហើយតាំងខ្លួនថាជាអ្នកបានកសាងប្រាសាទអង្គរធំនឹងបាយ័ន ៗ ប៉ុន្តែ មានហេតុមួយ

នាំឲ្យមើលទៅលើសេចក្តីនេះទៀត គឺរូបគំនូរអំពីរឿងរ៉ាវព្រះពុទ្ធ ដែលធ្វើលំអទីក្រុងនោះ ៗ នៅលើកំពូលដំបូលមានព្រះពុទ្ធរូបតម្រៀបជាជួរទ្រទ្រង់ភ្នែនកុងក្បាងដែលលកខ្ពង់ តែរូបទាំងនោះគេរំលើងចោលអស់ ៗ នៅលើជញ្ជាំងទីងនៅលើសសរនៃប្រាសាទបាយ័ន គេឃើញមានរូបព្រះពុទ្ធជាច្រើន ហើយរូបទាំងនោះ គេបានកោសកាត់ឲ្យក្លាយកងទៅជាឫសីតាបសមានពុកមាត់ពុកចង្ការទៅវិញ ឬ ធ្វើទៅជាលិង្គ ឬ ធ្លាក់ជាបាច់ផ្កា ប៉ុន្តែ គេឥតសង្កេតឃើញមានការប្រើអំពើឃោរឃៅដល់ទីនោះទេ គឺគេធ្វើដោយពិនិត្យទីងដោយសេចក្តីព្យាយាមអត់ធ្មត់ត្រូវតាមទំនៀមទំលាប់នៃអ្នកកាន់អំណាចត្រួតត្រា ។ ការនោះប្រាកដជាធ្វើតាមបង្គាប់សេនាបតីម្នាក់ ដោយមានក្រសួងសាធារណការ ជាអ្នកចាត់ចែងការ ហើយដោយយកប្រាក់ឃ្លាំងទៅចំណាយ ។ គួរឲ្យសំគាល់ថា ក្នុងការកោសកាត់កែក្លាយរូបព្រះពុទ្ធនេះ គេឥតបានបំបាត់រូបលោកេស្វរៈចេញទេ ព្រោះពោធិសត្វនេះមានដៃជើងនិងក្បាលច្រើន ដូចជាព្រះនារាយណ៍ឬព្រះឥស្វរដែរ ហើយគេទុករូបទាំងនេះជំនួសព្រះឥស្វរ និងព្រះនារាយណ៍បានដោយងាយ ។ ឯប្រាសាទខ្លះនៅអង្គរ ដែលមានរូបព្រះពុទ្ធជាច្រើន ត្រូវគេកោសលុបចេញធ្វើឲ្យឃើញថា គេពុំបានប៉ះពាល់ដល់រូបព្រះពុទ្ធសក្យមុនីទេ ដូចជាចេញពីនគរទៅទ្រង់ផ្នួស ឬ ត្រង់ដែលកាត់ព្រះកេសា ហើយដែលរូបទាំងនេះ គេអាចនឹងកែប្រែធ្វើឲ្យទៅ

ជារូបទាក់ទងនឹងរឿងតាំងព្រហ្មញ្ញសាសនាវិញដោយងាយ ។

បើជួនណាឃើញថា ព្រះបាទយសោវរ្ម័ននេះ មិនមែនជាអ្នកសាងអង្គរធំនឹងបាយ័នឡើយ ចុះបើឃើញមានសេចក្តីអង្គុលីដាំងចារឹករបស់ស្តេចនេះនិយាយបញ្ជាក់ក៏ដោយ ។ ក្រៅពីសំគាល់ខាងផ្លូវសាសនានោះ យើងមានសំគាល់យ៉ាងត្រឹមត្រូវ គឺថាយើងមានប្រាសាទ ១ ដែលសាងក្នុងរជ្យស្តេចយសោវរ្ម័ន គឺប្រាសាទភ្នំបាខែង ដែលហៅថា យសោធរេស្វរៈ ។ បើមាននរណា ១ យកប្រាសាទនេះទៅប្រៀបទៀងប្រាសាទបាយ័ននោះ អ្នកនោះនឹងឃើញច្បាស់ភ្លាមថា ប្រាសាទទាំងពីរនេះមិនមែនជាស្នាព្រះហស្តនៃព្រះមហាក្សត្រតែមួយព្រះអង្គឡើយ ។

សព្ទនេះមិនមែនធ្វើត្រាប់ឲ្យដូចទេ គ្រាន់តែជាការជួយណែនាំប្រែចារឹកនោះចេញពីថ្ម ។

## សព្ទ

មឈប្រះបាទ បរមេស្វរ មកអំវីជ្វា បំក្រុងដំនៅ នគរឥន្ទ្របុរ ស្តេងអញ សិវកៃវល្យ ត កំស្រាង្គកុរុង ប៉ុរោហិត ត ប្រះបាទបរមេស្វរ · មឈប្រះបាទថ្វែងមកអំវី ឥន្ទ្របុរ មឈប្រះបាទបរមេស្វរក្រាំដំអាស្យ នគរហរិហរា-លយ មឈប្រះបាទបរមេស្វរ នៅក្រាំដំអាស្យ មហេន្ទ្របវ្វត មានព្រហ្មណាផ្នះ ហិរណ្យទាមព្រាដ្ឋសិទ្ធិវិទ្យា មកអំវី

ជនបទ បិព្រះចាឧបរមេស្វរ អញ្ជើញធ្វើរំដីលេហ លេង កាំបីកម្ពុជទេស នេះអាយត្ត តង្វាលើង លេងអាចតិ កម្រតេងផ្ទៃក្រោម ម្យ្យកុះតជា ចក្រាវត្តិ ព្រហ្មណាតោះ ធ្វើវិធីដោយព្រះវិធាសិខប្រតិស្ឋាកម្រតេង ជគតតភជ ព្រហ្មណាតោះប្រៀនព្រះវិធាសិខ នយោត្តរសម្មោហ សិរស្ថូន ស្យងមនស្វតមុខ ចុញបិសរសិរ បិប្រៀន ស្តេងអញ សិវកៃវល្យទុតិ ប្រើស្តេងអញ សិវកៃវល្យ គិតធ្វើវិធិធាកម្រតេងជគតភជ មនព្រះចាឧបរមេស្វរ ស្តុចវិងមកក្រុងឥអាយនគរហារិហរភលយ ព្រះកម្រតេង អញតភជតិធាមមកាឱកព្រះចាឧបរមេស្វរ ស្តុតនៅ នគរ ហារិហរភលយ ។

*បើថាព្រះបាទយសោវរ្ម័ន មិនមែនជាក្សត្រកសាងអង្គរធំនឹងបាយ័ន ទេ នោះយើងត្រូវរកអ្នកកសាងនេះឲ្យឃើញដោយស្រាវជ្រាវ តាមរឿង តាមដួរក្រសែស្តេចដែលគ្រងរាជ្យមុន ៗ ។*

*ព្រះបាទឥន្ទ្រវរ្ម័នជាព្រះបិតាស្តេចនេះ មិនត្រូវយកមកនិយាយឡើយ ដោយក្សត្រនេះកាន់សាសនាព្រះឥស្វរយ៉ាងមាំមួនណាស់ ហើយប្រាសាទទាំងប៉ុន្មានដែលទ្រង់បានសាងនោះ គឺសម្រាប់តែព្រះឥស្វរទាំងអស់ ។ ម្យ៉ាងវិញទៀត ព្រះបាទឥន្ទ្រវរ្ម័ននេះជាវង្សក្សត្រថ្មី មិនជាប់ទៅក្នុងវង្សមុនឡើយ ។*

វង្សក្រោយនេះមានតែស្តេចពីរព្រះអង្គ គឺព្រះបាទជ័យវរ្ម័នទី ២ បរមេស្វរ (សកកាជ ៧២៤ ទៅ ៧៩១ ត្រូវនឹងគ្រិស្តសកកាជ ៨០២ ដល់ ៨៦៩) នឹងព្រះរាជបុត្រគឺព្រះបាទជ័យវរ្ម័នទី ៣ វិស្ណុលោក ពីសកកាជ ៧៩១ ទៅដល់ ៧៩៩ ត្រូវនឹងគ្រិស្តសកកាជ ៨៦៩ ដល់ ៨៧៧ ។ ស្តេចនេះ កាន់សាសនាព្រះនារាយណ៍ (វិស្ណុ) ដូចមានព្រះបច្ឆាមរណនាមរបស់ព្រះអង្គជាសំគាល់ស្រាប់ ។

ព្រះបាទជ័យវរ្ម័នទី ៣ គ្រងរាជ្យបានតិចណាស់ ហើយមិនប្រាកដផងនឹងសំគាល់ថាជាអ្នកសាងអង្គរមិនបាន ។

រឿងក៏ប្រែផ្សេងទៅវិញកាលណា យើងឆាកមកសិក្សាពីព្រះបាទជ័យវរ្ម័នទី២ បរមេស្វរ គឺថាព្រះមហាក្សត្រអង្គនេះជាស្តេចមានឫទ្ធានុភាព ហើយជាអ្នកសាងទីក្រុងជាច្រើនផង ។

បារែកនៅស្តុកកក់ធំបានពណ៌នាពីស្តេចនេះ ដូចមានសេចក្តីតទៅនេះ៖ "ព្រះបាទបរមេស្វរយាងមកពីស្រុកជ្វា ដើម្បីគ្រងរាជ្យក្នុងឥន្ទ្របុរក្នុងវេលានោះមានគ្រួសារកែវល្បាំងរាជបុរោហិត ។ តពីនោះមក ព្រះបាទបរមេស្វរយាងទៅឯឥន្ទ្របុរ ហើយព្រះអង្គគង់ក្នុងទីក្រុងហរិហរាល័យ ទើបព្រះអង្គយាងទៅកសាងក្រុងអមរេន្ទ្របុរ ហើយទៅគង់ទោមហេន្ទ្របព៌ត ។ ក្នុងវេលានោះមានព្រាហ្មណ៍ ១ ឈ្មោះហិរណ្យទាម ជាអ្នកប្រាជ្ញក្នុងសិលវិទ្យា មកពីស្រុកជនបទបានចូលមកដល់ ព្រោះព្រះអង្គ

ទ្រង់ឲ្យគេទៅអញ្ជើញគាត់ឲ្យមកធ្វើពិធី ដើម្បីកុំឲ្យក្រុងកម្ពុជាទៅជាចំណុះស្រុកជ្វា ហើយអាចឲ្យមានស្ដេចចក្រពត្តិ ១ ព្រះអង្គសោយរាជ្យក្នុងនគរនេះ ។ ព្រាហ្មណ៍នេះបានរៀបពិធីតាមរបៀបព្រះវិនាសិខ ហើយប្រតិស្ឋានស្ដេចទេវរាជ ។ ព្រាហ្មណ៍នេះបានបង្រៀន ព្រះវិនាសិខ នយោត្តរ សម្មោហ សិរច្ឆេទ ដោយបានសូត្រធម៌ទាំងនេះតាំងពីដើមដល់ចប់ ដើម្បីសរសេរ និងបង្រៀនដល់ស្ដេងអញសិវកៃវល្យ រួចក៏បានបង្ហាប់ដល់សិវកៃវល្យឲ្យធ្វើពិធីទេវរាជ ។ វេលានោះព្រះបាទបរមេស្វរត្រឡប់ទៅគង់ឯក្រុងហរិហរាល័យវិញ ហើយបាននាំទេវរាជទៅទុកទីនោះផង ។ ព្រះអង្គទ្រង់សោយទិវង្គតក្នុងហរិហរាល័យ" ។

ព្រះរាជពង្សាវតារនេះ សរសេរគ្មានផិតផង់ឡើយ ប៉ុន្តែអាចនឹងស្រង់យកសេចក្តីដែលមានប្រយោជន៍បាន ។ បើតាមសិលាចារឹក ព្រះបាទជ័យវរ្ម័ន បានយាងមកពីស្រុកជ្វា ។ ប៉ុន្តែឈ្មោះស្រុកនេះមិនច្បាស់សោះ ។ សព្វថ្ងៃខ្មែរទាំងឡាយហៅឈ្មោះនេះ សំដៅស្រុកជ្វាទាំងមូល កាលក្នុងឆ្នាំ ៨០០ ទៅ ៩០០ គេគាប់ហៅស្រុកនេះថា ស្រុកស្រីវិជ័យ គឺជាខេត្រដែលមានលាតសន្ធឹងទៅទិសខាងត្បូង ឬបើមិនដូច្នេះទេ គឺទៅលើដីបន់កោះជ្វាទាំងមូល ហើយថាក្នុងឆ្នាំនោះ ស្ដេចស្រុកជ្វាបានលើកទ័ពមកវាយស្រុកខ្មែរ ប្រកបដោយជោគជ័យ ដូចមានរឿងរ៉ាវរបស់ អាប៊ុ-សាអ៊ីដហាសាន់នៅសិរាហ្វ៍និយាយថា មានស្ដេចខ្មែរ

មួយអង្គយាងមកពីរបន់បាននុង ហើយប្រហែលជាមានម្ចាស់ផែនដីស្រុកនោះជួយនង បានមកដណ្ដើមយកកាជូននគរខ្មែរ ប៉ុន្តែគ្មានសេចក្ដីអ្វីជាពិតសោះ ៗ ឯនគរនេះកាន់ពុទ្ធសាសនាទាំងអស់ ហើយជឿគោរពលោកេស្វរៈ ៗ ចាប់តាំងពីពេលនោះមក យើងមានសំអាងជាច្រើនសម្រាប់ពន្យល់អំពីដើមកំណើតអង្គរបាន ដោយយើងត្រូវពិនិត្យតាមរឿងរ៉ាវស្ដេចដែលមកកយយកស្រុកខ្មែរ ៗ

ស្ដេចខ្មែរនេះបានមកលុកលុយស្រុក ហើយក៏ដណ្ដើមយកបានក្រុងឥន្ទ្របុរ រួចពីនោះព្រះអង្គក៏យាងពីឥន្ទ្របុរទៅឯហរិហរាល័យ ៗ នៅទីនោះព្រះអង្គទ្រង់បានសាងទីក្រុង អមរេន្ទ្របុរ គឺបន្ទាយឆ្មា សាងលើមហេន្ទ្របវ៌ត គឺភ្នំគូលែន ហើយត្រឡប់មកឯហរិហរាល័យវិញ ទើបទ្រង់សោយទិវង្គតទៅ ៗ យើងសូមបន្ថែមថា: នៅវេលាដែលសាងអង្គរធំរួចហើយ យើងមិនដឹងជាគេឲ្យឈ្មោះអ្វីសោះ សតាសិលាមិនបានដាក់ឈ្មោះឲ្យយើងដឹង ព្រោះសតាសិលានេះចង់ធ្វើឲ្យគេយល់ថាការកសាងនេះ ជាស្នាព្រះហស្ដព្រះបាទយសោវរ្ម័នវិញ ការនេះបញ្ជាក់ឲ្យឃើញច្បាស់ថាប្រាសាទទាំងប៉ុន្មានដែលព្រះជ័យវរ្ម័នទី ២ បានកសាងនោះ សុទ្ធតែជាប្រាសាទសំរាប់ពុទ្ធសាសនាទាំងអស់ ហើយសម្រាប់ទុកឧទ្ទិសថ្វាយដល់លោកេស្វរៈ ៗ ចារឹកនៅស្ដុកកក់ធំនិយាយថា ស្ដេចនេះបាននាំព្រាហ្មណ៍ម្នាក់មកពីស្រុកមានឈ្មោះមិនប្រាកដហៅថាជនបទ មកបង្រៀនវិជ្ជា

ផ្សេងៗដល់បុរោហិតព្រះអគ្គិ ហើយព្រាហ្មណ៍នោះបង្កើតការគោរពដល់ទេវរាជដើម្បីកុំឲ្យស្រុកខ្មែរចំណុះស្រុកជ្វាទៀត ហើយឲ្យស្រុកខ្មែរនេះមានស្តេចចក្រពត្រាធិរាជ ១ ព្រះអង្គមកសោយរាជ្យ ។

រឿងនេះឃើញប្លែកតែឯង ប៉ុន្តែបើទុកជាប្លែកដូច្នេះក៏គង់តែចូលជាពង្សាវតារដែរ ។ គេអាចចាត់ទុកបញ្ជីរាយឈ្មោះក្បួនដែលបានរាប់របៀបនេះជាការពុំសូវសំខាន់ក៏បាន ព្រោះក្បួនម្យ៉ាងនេះចារឹកជាអក្សរតន្ត្រដែលគេមិនស្គាល់សោះនៅក្នុងស្រុកឥណ្ឌា ហើយដែលមានចំណងជើងប្លែកៗ គឺវិនាសិខ នយោត្តរ សម្មោហ សិរច្ឆេទ, ហើយម្យ៉ាងទៀតក្បួនទាំងនេះ មានលាយធម៌អាថ៌ខ្លះមន្តអាគមខ្លះ ដូចជាមាននៅជាច្រើនក្នុងសាសនាដែលក្រោយរៀវទៅ ។ ការសំខាន់នោះ គឺគោរពលិង្គ ដើម្បីចង់ឲ្យ[illegible]ខ្មែរបានឯករាជ្យខាងនយោបាយ គឺមិនមែនចង់បានឯករាជ្យខាងសាសនាទេ ។ ឯនាមចក្រពត្រានោះដ៏ថ្លៃណាស់ គឺជាធំម្ចាស់ផែនដីដែលមានស្តេចចំណុះជាច្រើន ហើយដែលឯងជាម្ចាស់ផែនដីគ្មានចំណុះនរណាមួយលើផែនដី ។ បើហៅឲ្យត្រូវតាមភាសាសម័យ គឺព្រះចៅអធិរាជ ។ ដែលព្រះបាទជ័យវរ្ម័នទី ២ ទ្រង់ឡើងគ្រងរាជ្យនោះ ព្រះអង្គនៅក្នុងអំណាចផែនដីជា (អាយត្ត) គឺជាចំណុះមហារាជនៅស្រីវិជ័យ ។ ឯការចំណុះនេះ បណ្តាលអំពីហេតុពីរយ៉ាង គឺមួយដោយមកពីប្រទេសខ្មែរធ្លាប់ចំណុះប្រទេសនោះពីដើមមក និងមួយទៀតដោយស្រុកខ្មែរច្បាំង

ចាញ់មហាកវីដែលពោលខាងលើនេះ ។ នេះគឺពោលតាមសេចក្ដីដំណាលរបស់អាម៉ុសាអ៊ីវ ។ ព្រះបាទជ័យវរ្ម័នទីពីរនេះតែងមានព្រះទ័យប្រាថ្នានឹងផ្ដាច់ចំណងប្រទេសព្រះអង្គ ឲ្យនៅក្រោមឱវាទប្រទេសគេនេះណាស់ ប៉ុន្ដែ តើដោយហេតុយ៉ាងណា បានជាការគ្រាន់តែគោរពព្រះ ១ ថ្មី អាចបណ្ដាលនាំឲ្យស្ដេចនេះសម្រេចព្រះទ័យដូច្នេះកើត ? យើងជឿថាសេចក្ដីនេះនឹងពន្យល់បាន គឺព្រះនេះដែលជាលិង្គ ឈ្មោះថាគម្រតេងជគតតកជនោះ មិនមែនជាឈ្មោះពិតប្រាកដដែលមាននិយាយក្នុងចារឹកនៅស្ដុកកក់ធំនោះទេ ។ ចារឹកគ្រាន់តែធ្វើឲ្យយើងដឹងថា ព្រះនោះបានថែរក្សាអំណាចម្ចាស់ផែនដីដែលទ្រង់បានសោយរាជ្យតៗ មក ។

គេអាចយកលិង្គនេះទៅធៀបនឹងលិង្គភទ្រេស្វរនៅស្រុកមីសឺន ដែលព្រះឥស្សរបានប្រទានមកឲ្យស្ដេច ដែលគ្រងរាជ្យជាដំបូងនៅស្រុកចម្ប៉ា ហើយគេចាត់ទុកថា កំណើតនៃរាជជាទុកាពរបស់រាជវង្សតៗគ្នា (សន្តតិរាជសោភទ្រេស្វរ) ។ ឯស្ដេចអង្គណាដែលគោរពដល់លិង្គដូច្នេះនោះបានទទួលនាមផ្ទាល់ពីស្ថានសួគ៌មក មិនមែនទទួលពីស្ដេចឯណាមួយឡើយ គឺបានជាស្ដេចចក្រពត្តិដោយអំណាចព្រះអាទិទេព ដោយហេតុនេះហើយបានជាព្រះបាទជ័យវរ្ម័នទី ២ ដែលតាំងខ្លួនជាឯករាជ្យ បានសាងរូបទេវរាជមួយអង្គដំកល់នៅក្នុងប្រាសាទព្រះអង្គ ដោយហេតុនេះតើយើងត្រូវជឿថាស្ដេចនេះបានបោះបង់ពុទ្ធសាសនាចោលទៅ ចូលសាសនាព្រះឥស្សរឬអ្វី?

ត្រង់នេះដូចជាគ្មានប្រយោជន៍ប៉ុន្មានទេ ព្រោះគេអាចទុកសាសនាចាស់សម្រាប់គោរពបានផង ហើយទៅបួជាព្រះថ្មីបានឥតទាស់អ្វីទេ ។

ស្តេចស្រុកខ្មែរទាំងឡាយតាមធម្មតា ច្រើនតែមានការអត់ធន់ណាស់ ហើយមិនគិតថាក្រែងមានខុសទេ ដោយគោរពព្រះឥសូរផង ព្រះពុទ្ធផងដូច្នេះ ។

ម្យ៉ាងវិញទៀត ពួកអាចារ្យរបស់ស្តេចក៏មានបញ្ញាចេះសម្រុះសម្រួល មិនឲ្យទាស់ទែងគ្នាបានព្រោះតែជំនឿផ្សេងគ្នានេះ ឯព្រះរាជបុត្រព្រះបាទជ័យវរ្ម័នទី ២ នោះក៏គោរពទេវរាជដែលជាសាសនាព្រះឥសូរដែរ ពិតមែនតែទ្រង់កាន់សាសនាព្រះនារាយណ៍ក៏ដោយ ។

សេចក្តីសន្និដ្ឋានទាំងប៉ុន្មានដែលបានពោលមកនេះ នាំយើ[illegible]ក់នៅមុខបញ្ហាមួយដែលគេស្មានថាបានដោះស្រាយរួចហើយ ។ ត្រូវតែយកមកសើរើវិញក្នុងវេលានេះ ។ នៅក្នុងបណ្តាប្រាសាទភាគច្រើនដែលស្តេចជ័យវរ្ម័នទី ២ បានសាងនោះ គេឃើញមានកំពូលមុខ ៤ ជាច្រើន ។ យើងបានពន្យល់មុននេះបន្តិចអំពីកំពូលនេះ ថាគេបានធ្វើតែទៅជាលិង្គមុខ ៤ វិញ ហើយសេចក្តីពន្យល់នេះក៏ត្រូវបានគេទទួលយល់តាម ។

សេចក្តីពន្យល់នេះត្រូវណាស់ បើប្រាសាទបាយ័ននិងប្រាសាទឯទៀតដែលមានសណ្ឋានប្រហែលគ្នា ជាថ្វីព្រះហស្តនៃព្រះបាទយសោវរ្ម័នដែលជាស្តេចកាន់សាសនាព្រះឥសូរ ហើយគោរពលិង្គ ។ ប៉ុន្តែ សេចក្តីពន្យល់

ទីងទៅជាពុំសូវសមទៅវិញ បើសិនជាកំពូលប្រាសាទទាំងនេះជាថ្វីព្រះហស្តរបស់ស្តេច ១ អង្គដែលកាន់ពុទ្ធសាសនាវិញ ។

តើមានខុសគ្នាយ៉ាងណាទៅ ប្រសិនបើរូបមុខ ៤ នោះជារូបរបស់លោកេស្វរវិញ ដោយហេតុថារូបដែលមានមុខច្រើនយ៉ាងនេះ មិនសូវក្រប៉ុន្មានទេ ។ ពិតមែនតែគំរូមុខនេះមិនជាសម្បូរប៉ុន្មានទេ តែថាក្នុងទីនេះយើងគួរគិតទៅដល់ទំនងការខាងការសង់វិញ ។ ម្យ៉ាងវិញទៀតគួរយល់ថា មុខ ៤ នេះជាមុខដែលឆាកទៅគ្រប់ទិសទាំងអស់ភ្លាម ៗ ដើម្បីឲ្យទិសពាសេញ្ញសាធុការប្រសើរជាជាងការដែលយល់ថា ជាក្បាលដែលមានមុខ ៤ នោះវិញ បានជាថាដូច្នេះ ព្រោះដូចជាមុខដែលមាននៅប្រាសាទបន្ទាយឆ្មានោះឃើញមានមុខផ្សេង ៗ មកជ្រៀតនៅជាកណ្តាលនៃមុខ ៤ នោះទៀត ហើយដូចជាមុខដែលមាននៅប្រាសាទស្ទឹង ជិតប្រាសាទព្រះខ័នខាងកើតនោះ ក៏ឃើញមានទំនងសំណង់អ៊ីមកជ្រៀតនៅបន្ទះមុខ ៤ នោះដែរ ។ ក្នុងការស្ថាបនាវត្តទាំងនេះ គេហាក់ដូចជាចង់ឲ្យឃើញតែមុខ ១ ជាប់ពីគេកុំឲ្យជាប់ទីងក្បាច់សិល្បៈខាងសំណង់ឯទៀត ។ តាមសេចក្តីយល់ឃើញរបស់ខ្ញុំគឺថា អង្គរធំទីងប្រាសាទកណ្តាលគឺប្រាសាទបាយ័ននោះ គឺស្តេចជ័យវរ្ម័នទី ២ បរមេស្វរ បានសាងក្នុងឆ្នាំ ៨៥០ គឺ ៥០ ឆ្នាំ មុនឆ្នាំដែលគេធ្លាប់ជឿមក ។ ប្រាសាទបាយ័នកាលដើមសាងឧទ្ទិសដល់ពុទ្ធសាសនា ហើយតមកស្តេចដដែលនេះបានផ្តូរ

ខ្ទិសដល់លិង្គវិញ ។ បន្ទាប់ពីការផ្លាស់ប្ដូរសាសនានេះមក រូបព្រះពុទ្ធទាំងឡាយនៅអង្គរធំគេក៏ត្រូវវាយចោល បើមិនព្រះបាទជ័យវរ្ម័ននេះឯងបានវាយចោល ក៏ស្ដេចអង្គណាមួយដែលសោយរាជ្យស្នងបានវាយចោល ហើយប្រាសាទបន្ទាប់បន្សំឯទៀតសម្រាប់សាសនាព្រះឥសូរ ក៏បានសាងបន្ថែមជាក្រោយនៅក្នុងទីបាយ័ន ។ ខ្ញុំមិនមានអ្នកថាសំអាងរបស់ខ្ញុំអាចបំបាត់នូវសេចក្ដីសង្ស័យ ហើយបំភ្លឺនូវការអាថ៌កំបាំងបានគ្រប់កន្លែងអស់នោះទេ ។ ដែលខ្ញុំចង់និយាយនោះ គឺថាក្នុងការដែលគេកំពុងស្រាវជ្រាវរកសព្វថ្ងៃនេះ សេចក្ដីយល់ឃើញរបស់ខ្ញុំហាក់ដូចជាឃើញពិតជាងសេចក្ដីឯទៀតក្នុងការដែលបានដឹងហើយ ។ បណ្ដាសេចក្ដីយល់ឃើញទាំងប៉ុន្មាន ការណ៍មួយដែលពុំអាចមានសន្ទុះសង្ស័យកើត គឺអំពីការដែលព្រះពុទ្ធសាសនាមានការរុងរឿងថ្កុំថ្កើងណាស់ ក្នុងជំនាន់ដំបូងនៃសិល្បៈបុរាណខ្មែរយើង ។ គឺព្រោះតែជឿព្រះពុទ្ធសាសនានេះហើយបានជាស្រុកខ្មែរកាលក្នុងឆ្នាំ ៩០០ មានសាងប្រាសាទដេរដាស ដូចជាប្រទេសបារាំងសែសក្នុងឆ្នាំ ១១០០ ដែរ ។ បណ្ដាប្រាសាទដែលពេលនេះ គេអាចកប់បញ្ចូលប្រាសាទខ្លះក្នុងជាន់ដើមដែលធ្វើពីថ្មបាយក្រៀមផង ដោយគ្មានទាស់ខុសទេ ។ ព្រះដែលលេចឮជាងគេក្នុងស្រុកខ្មែរក្នុងដើមសតវត្សរ៍ទី ៩ នោះ មិនមែនជាហរិហរសម័យបុរាណឬព្រះឥសូរក្នុងជំនាន់តមកឡើយ គឺជារូបលោកេស្វរដែលព្រះកក្រួដ

ស្រស់ញញឹម សន្ទឹងព្រះហស្តប្រកបដោយការញោចិត្ត ទៅជួយសម្រាល ការឈឺចាប់ ទីងទុក្ខភ័យរបស់មនុស្សលោក ជាតួអង្គពោធិសត្វដែលអ្នក កាន់ពុទ្ធសាសនាឲ្យនាមថាព្រះមហាករុណា ។ បន្ទាប់ពីពេលដែល ព្រហ្មញ្ញសាសនាមកលុកលុយសង្កត់សង្កិនអស់ពេល ៣ សតវត្សរ៍នោះ, ព្រះពុទ្ធសាសនាក៏បានកុំរុងរឿងឡើងវិញ ក្នុងរជ្យព្រះបាទជ័យវរ្ម័នទី ២ ដែលមានព្រះរាជអគបរ្យកិរិយាប្រហែលគ្នានឹងព្រះបាទជ័យវរ្ម័នទី ១ ព្រោះ ទ្រង់គឺជាអ្នកចម្បាំង ជាអ្នកសាងប្រាសាទនិងមន្ទីរព្យាបាលរោគដ៏ច្រើន ដូចគ្នា ។ បើដូច្នេះ ឃើញថាសម័យដែលរុងរឿងជាងគេក្នុងពង្សាវតារ ខ្មែរមានពីរដងហើយ គឺនៅក្នុងសម័យព្រះពុទ្ធសាសនាទាំងអស់ ។ ម្យ៉ាងទៀត គេអាចឲ្យយោបល់អំពីរឿងនេះបានថា សាសនាសព្វថ្ងៃនេះ ដែលប្រជាជាតិយើងស្រឡាញ់អស់ពីដួងចិត្ត មិនមែនទើបនឹងនាំយកពី ស្រុកក្រៅមកទេ ប៉ុន្តែ ដោយមានគណៈនិកាយច្រើនពេក ព្រះពុទ្ធ-សាសនាក៏តាក់ឬសនៅក្នុងសន្តាប់ដ៏ជ្រៅនៃប្រពៃណីជាតិ ។

## រឿងសាមកុក

# កណ្ឌទី ៤៥

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាសបើបានអាន<br>នឹងបេះឲបាយកលបំណាន<br>ទាំងមានសន្ដានស្នេហាជាតិ ។ |

ឯហ័នហៀននោះ កាលហាន់តុងនឹងគួនអ៊ូប្រាំងគ្នា ក៏ឈរសំឡឹងមើលពីលើសេមាបន្ទាយ ឃើញហាន់តុងបាញ់ធ្នូមិនដាក់ព្រួញក៏ចំងល់ណាស់ លុះហាន់តុងត្រឡប់ចូលមក ក៏បង្គាប់ទាហានឲ្យចាប់ហាន់តុងទៅសម្លាប់ ។ ហាន់តុងថា ដែលនឹងឲ្យសម្លាប់ខ្ញុំនោះដោយខុសពីទោសអ្វី?ៗ ហ័នហៀនថា កាលមុនដំបូងគួនអ៊ូលើកទ័ពមក ខ្លួនក៏ទទួលភាសាថានឹងយកជ័យជំនះឲ្យបាន នោះយើងចាំមើលខ្លួនធ្វើសឹកសង្គ្រាមតនឹងគួនអ៊ូដល់ ៣ ថ្ងៃហើយ ក៏មិនឃើញចាញ់ឈ្នះគ្នា កាលពីម្សិលមិញ ខ្លួនក្លែងធ្វើជាចាញ់គួនអ៊ូបែករត់មកម្ដងហើយ យើងក៏មិនយកទោស ដល់ថ្ងៃនេះ ខ្លួនបាញ់ធ្នូមិនដាក់ព្រួញ លុះឯក្រោយក៏បាញ់ត្រូវតែរំភាយមួក នេះគឺខ្លួន

ត្រូវគំនិតគប់គ្នានឹងគួនប៊ី គ្មានយកចិត្តឈឺក្ដៅនឹងប្រឹងធ្វើការឲ្យយើងតាមពិតត្រង់ បើយើងនឹងមិនសម្លាប់អ្នកចេញគ្រានេះទេ មនុស្សទាំងពួងក៏នឹងយករឿងតាមគ្នាតទៅ ៗ ទាហាននឹងទៅប្រឹក្សាទាំងពួងគិតគ្នានឹងសុំទោសហាន់គុន ៗ ហាន់ហៀនក៏និយាយទាំងទុក្ខ ប្រាថ្នានឹងមិនឲ្យអ្នកឯណាសុំទោសថាធ្វើសេចក្ដីខុស ទោសដល់អស់ជីវិតគិតនឹងសម្លាប់ចេញជាប្រាកដ បើនរណាសុំទោសនឹងយកទោសអ្នកនោះវិញដូចជាហាន់គុន ថាហើយក៏បង្គំទាហានឲ្យយកខ្លួនហាន់គុនទៅសម្លាប់ ៗ ទាហានក៏យកខ្លួនហាន់គុនទៅ ៗ

ខណៈនោះអ៊ុយអៀនជាពួកស្រុកងីអៀង កាលឡៅពីទៅច្បាំងឯស្រុកសុងយ៉ុងនោះ អ៊ុយអៀនប្រុងទៅនៅនឹងឡៅពីក៏មិនជួបប្រទះ ទើបត្រឡប់មកចូលធ្វើការនឹងហាន់ហៀន ហាន់ហៀនមិនបានស្គាល់ជាមនុស្សបេះដឹងមានថ្វីដៃឬមិនមានថ្វីដៃសោះ ក៏មិនបានជប់កៀងអ៊ុយអៀន នៅប្រើជាកូនទាហានធម្មតា ៗ លុះអ៊ុយអៀនដឹងថា ហាន់ហៀន ឲ្យចាប់ខ្លួនហាន់គុនទៅសម្លាប់ដូច្នោះ ក៏រត់តាមទៅចាប់ទាហាននោះសម្លាប់ចេញ ដណ្ដើមយកខ្លួនហាន់គុនមកបាន ហើយស្រែកប្រកាសនឹងពួកអ្នកស្រុកទាំងពួងថា ហាន់គុននេះជាចារកបង្អោលក្រុងស្រុកទៀងសា ហាន់ហៀននឹងឲ្យសម្លាប់ហាន់គុនចេញនោះ ក៏ដូចសម្លាប់បណ្ដារាស្ត្រទាំងពួងចេញ យើងដណ្ដើមទុកបានគ្រានេះ ព្រោះយើងប្រុងនឹងសម្លាប់ហាន់ហៀន

ចេញ  នរណានឹងចូលខាងយើងខ្លះ ។

ពួកអ្នកស្រុកទាំងអស់គ្នា  ក៏មានចិត្តឈឺក្ដៅស្អប់ហ៊ានហៀនណាស់ សឹងតែស្មោះស្ម័គ្រចូលទៅខាងអ៊ុយអៀនជាច្រើន  នាំគ្នាគិតទៅធ្វើអន្ត-រាយហ៊ានហៀន ។ ហាងគុងចេះតែឃាត់ហាមយ៉ាងម្ដេចក៏អ៊ុយអៀនមិនព្រមស្ដាប់  នាំយកពួកអ្នកស្រុកខ្មាន់ខ្មាប់  ចូលក្រលុកទៅដល់សេនបន្ទាយ ឃើញហ៊ានហៀនអង្គុយនិយាយនៅក្នុងទីនោះ  អ៊ុយអៀនក៏រត់តម្រង់ទៅយកដាវកាប់ហ៊ានហៀនដាច់ពាក់កណ្ដាលខ្លួន  ហើយក៏កាត់យកក្បាលឡើងសេះនាំទាហានទាំងពួងចេញទៅរកគួនអ៊ូឯបន្ទាយ ។ គួនអ៊ូឃើញហើយក៏ទទួលអំណរណាស់  ទើបលើកទាហានចូលទៅនៅក្នុងស្រុកទៀងសា ហើយប្រើទាហានទៅអញ្ជើញហាងគុង ។ ឃើញថា គួនអ៊ូមិនបានរាប់អានឲ្យតែទាហានទៅហៅដូច្នោះ  ក៏ប្រាប់ថាឈឺទៅមិនបាន  គួនអ៊ូក៏ធ្វើសំបុត្របកប្ដឹងទៅដល់ឡៅតី-ខុងបេង  តាមដែលបានខ្លួនអ៊ុយអៀននឹងហាងគុងក្នុងស្រុកទៀងសា ។

ឯឡៅតីនឹងខុងបេងដែលលើកទាហានតាមមកកណ្ដាលផ្លូវ  ឃើញទង់សសម្រាប់ហៅទាហានដែលហែពីមុខឡៅតីត្រឡប់មុខចូលគ្នារុំនឹងដង ហើយមានផ្អក ១ ហើរពីទិសខាងត្បូងស្រែកយូលជា ២ សំឡេង ហើយហើរទៅទិសឯជើង  ឡៅតីឃើញចំឡែកអស្ចារ្យក៏សួរសាកខុងបេងថា ដែលបង្កើតអាកេតដូច្នេះ  គួនអ៊ូទៅកាយស្រុកទៀងសានោះជាបានឬមិន

បានប្រការម្តេច ? ។ ខុនបេនក៏ចាប់យាមតាមតម្រាមើលដឹងក៏ឆ្លើយថា ឥឡូវគួនអ៊ីយកបានស្រុកទៀនសាហើយ បានទាំងទាហានឯកផង ពេលរសៀលថ្ងៃនេះនឹងភ្ជុំដំណឹង ។

លុះពេលថ្ងៃរសៀល បំរើគួនអ៊ីកាន់សំបុត្រមកដល់ ក៏ចូលទៅជួបនឹងឡៅតា-ខុនបេន ប្តឹងឲ្យការសព្វសេចក្តីហើយយកសំបុត្រនោះជូនឡៅតាមើលដឹងសេចក្តីក៏ត្រេកអរណាស់ នាំខុនបេនស្រួតលើកទាហានទៅដល់ស្រុកទៀនសា ។ គួនអ៊ីក៏ចេញមីម្នាមកទទួលអញ្ជើញឡៅតា-ខុនបេនចូលទៅក្នុងស្រុក ហើយប្រាប់រឿងដែលបានធ្វើការសង្គ្រាម នឹងហានគុននោះ ឲ្យឡៅតាស្តាប់គ្រប់ប្រការ ហើយប្រាប់ថា ឥឡូវខ្ញុំបានប្រើទាហានឲ្យទៅហៅហើយ ហានគុនមិនឃើញមក ប្រាប់ថាឈឺ ។

ឡៅតាឮដូច្នោះក៏គិតថា ហានគុនជាមនុស្សចាស់មានចិត្តមានះប្រកាន់ គួនអ៊ីឲ្យបំរើទៅអញ្ជើញទើបមិនមក ត្រូវតែយើងទៅដោយខ្លួនឯងទើបគួរ ហើយឡៅតាក៏ទៅរកហានគុនដល់ផ្ទះ ហានគុនឃើញឡៅតាទៅដល់ក៏មានចិត្តត្រេកអរណាស់ ចេញទៅទទួលឡៅតាក្រៅផ្ទះនាំចូលទៅ ឡៅតាក៏និយាយល្បួងលួងលោមហានគុនមកកាន់ទីនៅក្នុងខេត្រនោះ ។

ហានគុនអង្វរឡៅតាសុំយកសពហានខៀន ទៅបញ្ចុះតាមប្រពៃណីខាងក្រៅស្រុកនៅទិសឯកើត ។ គួនអ៊ីក៏នាំព្រួយខៀនចូលទៅគំនាប់ឡៅតាខុនបេន ហើយប្រាប់សេចក្តីគាប់ប្រសើររបស់អ៊ុយឆាខៀនឲ្យស្តាប់ ។ ខុន

បេនត្រហើយក៏បង្គាប់ទាហានឲ្យចាប់ខ្លួនអ៊ុយអៀនទៅប្រហារជីវិត ឡៅពីក៏ភ័យចិត្ត ទើបសួរខុងបេងថា អ៊ុយអៀនរិះគិតឧបាយសម្លាប់ហានហៀនចេញ ក៏មានសេចក្តីគាប់ប្រសើរដល់យើង ហេតុម្តេចលោកឲ្យយកទៅសម្លាប់វិញដោយឃើញទោសកំហុសពីអ្វី ? ។

ខុងបេងថា នរណាស៊ីបាយផឹកទឹកដេកសំណាក់អាស្រ័យនៅត្រង់ទីណា ហើយធ្វើចិត្តប្តូសប្រទូសរ៉ាយគេដែលមានឧបការគុណនៅទីនោះ ឈ្មោះថាជាមនុស្សអកតញ្ញូ នរណានៅកន្លែងដីប្រទេសណាហើយប្រព្រឹត្តគិតក្បត់លើកយកផែនដីប្រទេសនោះ ទៅឲ្យអ្នកដទៃក្រៅវិញ អ្នកនោះក៏ពេញជាមនុស្សអកតញ្ញូដូចគ្នា ដូចយ៉ាងអ៊ុយអៀននេះជាមនុស្សគ្មានកតញ្ញូសុចរិតត្រង់នឹងនាយចៅហ្វាយសោះ ទោះបីនឹងចិញ្ចឹមរក្សាទុកតទៅក៏មិនគួរ ម្យ៉ាងទៀតខ្ញុំពិគ្រោះមើលក្នុងលក្ខណៈអ៊ុយអៀននោះឃើញថាជាមនុស្សមិនស្មូតត្រង់នឹងអ្នកដ៏មានគុណ បើប្រសិនយើងនឹងរក្សាទុកជាគ្នាយូរទៅក៏នឹងគិតទុរយសជាប្រាកដ ។ ឡៅពីថា លោកមានប្រសាសន៍នោះគួរមែនហើយ តែវេលានេះបើយើងនឹងឲ្យសម្លាប់អ៊ុយអៀនចេញ យើងនឹងធ្វើការសង្គ្រាមតទៅមុខ អ្នកដែលនឹងប្រុងស្ម័គ្រមកនៅនឹងយើងផង ក៏ញញើតរោចិត្តលែងគិតប្រាថ្នានឹងមកទៀតហើយ ហេតុនេះខ្ញុំសុំឲ្យលោកអត់ទោសអ៊ុយអៀនទុកម្តងទៅចុះ ។

ខុនបេងព្នុជូឈ្មោះ ក៏យល់ឃើញត្រូវ ទើបលើកដៃចង្អុលមុខអ៊ុយអៀនហើយថា គ្រានេះយើងលើកទោសម្តងចុះ តាំងពីត្រឹមថ្ងៃនេះទៅមុខ ខ្លួនមិនត្រូវគិតខុសយេសអាក្រក់នឹងអ្នកមានគុណដូច្នេះទៀត បើខ្លួនមិនពងតាលមិនស្តាប់ពាក្យយើងប្រដៅ យើងនឹងកាត់ក្បាលខ្លួនចេញ ។ អ៊ុយអៀនក៏ទទួលពាក្យប្តេជ្ញាគ្រប់ប្រការ ហើយគំនាប់លាទៅកាន់ទីលំនៅ ។ ឯហងតុងក៏ចូលទៅជំរាបឡៅពីថា ឥឡូវឡៅក្លូនជាក្មួយឡៅពៀវនៅក្នុងស្រុកនេះ សុំឲ្យលោកហៅយកខ្លួនមកតាំងឲ្យធ្វើជាចៅហ្វាយស្រុកទើបស្រួល ព្រោះឡៅក្លូនជាពូជពង្សវង្សត្រកូលជាប់នឹងលោក ។ ឡៅពីព្នុជូឈ្មោះក៏សោមនស្សត្រេកអរ ប្រើទាហានទៅហៅខ្លួនឡៅក្លូនមកតាំងជាធំ គាំពាររក្សាបណ្តារាស្ត្រនឹងទាហាននៅក្នុងស្រុកតាមប្រក្រតី ។

ឡៅពីបានប្រាប់ប្រាមអាណាខេត្តទាំង ៤ ដំបន់ស្រេចហើយ បានទាំងទាហាននឹងទីប្រឹក្សាជាច្រើន ក៏នាំខុនបេង · គួនអ៊ូ · ជូឡុងលើកទ័ពត្រឡប់ទៅស្រុកកេងជីវិញ ទើបផ្លាស់ប្រែឈ្មោះដោយអីវកាំងចាត់កំពង់ស្រុកកេងជីឲ្យឈ្មោះជាកំពង់កាំងអ័នវិញ ឡៅពីក៏ប្រមូលសេនាទាហាននឹងសៀងអាហារទ្រព្យរបស់ មកបំណាយជាបៀវត្សរ៍សម្រាប់ខែ ។ ចាយឲ្យទាហាននឹងនាម៉ឺនមុខមន្ត្រីជាច្រើន ហើយចាត់ចែងឲ្យទាហានដែលមានថ្វីដៃទៅត្រួតត្រាក្បួនគយល្បាតគ្រប់អាត់កំពង់ទឹកទីដែនគ្រប់ជំរទំ ពុំបានធ្វេសប្រហែស ។

ឯដីវយើទៅនៅរក្សារបួសខ្លួនក្នុងស្រុកផសង់គុណ របួសនោះក៏សះជាគ្រាន់បើហើយ ទើបចាត់ឲ្យគាំឡេងទៅនៅរក្សាស្រុកចាំឡេង ឲ្យឡេងផងទៅនៅរក្សាស្រុកអ៊ីនអៀង ហើយបង្គាប់ថាឲ្យបំរុងប្រុងប្រៀបទាហានទីងទូកចម្បាំងទុកឲ្យព្រមបើមានសង្គ្រាមមកវេលាណា ក៏នឹងបានប្រើការដោយរហ័ស ហើយឲ្យឡោសុកនឹងទៀកៅលើកទាហានចេញទៅជួយជាកំឡាំងស៊ិនគួនឯស្រុកហ័បប៉ា ។

ឯស៊ិនគួនក៏លើកទ័ពទៅនៅស្រុកហ័បប៉ាជាយូរណាស់ បានតាំងច្បាំងនឹងទៀវលៀវជាង ១០ គ្រា ក៏មិនចាញ់មិនឈ្នះ ទើបថយមកតាំងពីចម្ងាយកំពែងស្រុកផ្លូវប្រហែល ៥០០ សិន (២០គី) លុះដឹងដំណឹងថាដីវយើប្រើឡោសុកនឹងទៀកៅលើកទាហានមកជួយ ក៏មានអំណរណាស់ឡើងសេះចេញទៅទទួលក្រៅបន្ទាយ ទាហានក៏នាំដំណឹងទៅប្រាប់ថាឡោសុកមកជាមួយដែរ ស៊ិនគួនឮដូច្នោះ ក៏ចុះពីលើសេះឈរចាំទទួលឡោសុក ។

ឡោសុកជិះសេះមកឃើញស៊ិនគួនឈរចាំនៅដី ក៏ចុះពីលើសេះពីចម្ងាយដើរចូលមកគំនាប់ស៊ិនគួន ។ ក៏ធ្វើជាតបគំនាប់ឡោសុកយ៉ាងសុភាព ហើយហៅថា អាចារ្យ ៗ ទាហានទាំងពួងឃើញដូច្នោះ ក៏មានសេចក្ដីកោតញញើតឡោសុកជាច្រើន ស៊ិនគួនបបួលឡោសុកជិះសេះម្នាក់ ១ ដើរទឹមគ្នាចូលទៅក្នុងបន្ទាយ ស៊ិនគួនឱនខ្សឹបប្រាប់ថា ខ្ញុំធ្វើ

សេចក្ដីលំអុតលំទុនលើកដំកើងអ្នកយ៉ាងដូច្នេះ អ្នកត្រូវចិត្តឬទេ? ។ ឡោសុកថា ខ្ញុំបាទមិនត្រូវចិត្តសោះ ។ ស៊ុនគួនសួរថា ហេតុម្ដេចបានជាអ្នកមិនត្រូវចិត្ត? ។ ឡោសុកថា ដែលត្រូវចិត្តខ្ញុំនោះ ខ្ញុំសុំឲ្យលោករិះគិតតាំងខ្លួនធ្វើធំឲ្យគ្រាតែបានទើបប្រពៃ ហើយត្រូវតាំងនៅក្នុងសត្យានុស័ត្យសុចរិតល្អ ដើម្បីនឹងទំនុកបំរុងអាណាប្រជានុរាស្ត្រឲ្យបានសេចក្ដីសុខក្សេមក្សាន្តអំណើះទៅមុខ ទើបឈ្មោះខ្ញុំមានល្បីល្បាញប្រាកដថាជាខ្ញុំរកជការជួយទំនុកបំរុងលោកឲ្យបានជាធំ ស៊ុនគួនឮដូច្នោះ ក៏ទះដៃអស់សំណើចដោយសប្បាយណាស់ ហើយនាំឡោសុកទៅបន្ទាយក៏ឲ្យរៀបចំតុលៀងអាហារព្រមទាំងសេនាធាហានទាំងពួង ហើយប្រឹក្សាគ្នានឹងលើកទៅរយយកស្រុកហ័បប៉ាឲ្យបាន ។ ទត្ឌពះបំរើសេះចូលមកប្រាប់ថា ទៀវលៀវឲ្យបំរើកាន់សំបុត្រមកជូនលោក ស៊ុនគួនក៏ឲ្យទាហាននោះចូលមក ហើយទទួលសំបុត្រមកមើលសេចក្ដីថា ស៊ុនគួនបានទាហានមកបំពេញថែមទៀតជាច្រើនហើយ ឲ្យលើកមកច្បាំងគ្នាទៀតចុះ ស៊ុនគួនឮដូច្នោះក៏ខឹងណាស់ថាយើទៀវលៀវនេះមើលងាយអញពេកណាស់តើ ! ព្រោះឃើញថាឡោសុកនឹងទៀតៅទើបមកដល់ បានជាប្រើទាហានឲ្យកាន់សំបុត្រមកនិយាយដៀមដាមចំអក ពេលព្រឹកស្អែកអញមិនយកទាហានថ្មីទៅទេគឺទ្បាំងទាហានចាស់ គឺល្មមចេញទៅច្បាំងនឹងទៀវលៀវ ឲ្យអស់ថ្វីដៃម្ដងចុះ ។ អ្នកកាន់សំបុត្រនោះក៏លាស៊ុនគួនត្រឡប់ទៅប្រាប់ទៀវលៀវ ។

លុះដល់ពេលយាម ៣ ប្លាយ ស៊ិនគួនក៏ឲ្យរៀបចំទាហានលើកចេញពីបន្ទាយសំដៅទៅច្បាំងនឹងទៀវលៀវ លុះលើកទៅដល់កណ្ដាលផ្លូវពេលស៊ីបាយព្រឹករួច ។ ទទួលកងទ័ពទៀវលៀវលើកមកជួបគ្នា ទាំងសងខាងក៏ឈប់ទ័ពប្រទល់គ្នា ស៊ិនគួនក៏តែងខ្លួនពាក់គ្រោះមាសមួកមាសឡើងជិះសេះកាន់លំពែង ឲ្យស៊ុងទៀមអមខាងស្ដាំ ឲ្យកែហ៊ួអមខាងឆ្វេង ហើយឲ្យទាហានវាយឃ្មោះគងទូងស្គរ ហើយស៊ិនគួនក៏ចេញទៅឈរមុខទាហាន ៗ ទៀវលៀវឃើញដូច្នោះ ក៏ឡើងសេះឲ្យលីទៀនអមខាងស្ដាំឲ្យង៉ក់ជិនអមខាងឆ្វេងកាន់លំពែងចេញមកហៅស៊ិនគួនឲ្យចូលមកច្បាំងគ្នា ៗ ស៊ិនគួនក៏បរសេះចូលទៅប៉ះច្បាំងនឹងទៀវលៀវ ៗ ថៃស៊ីដូឃើញដូច្នោះក៏បំផាយសេះដែកចូលទៅច្បាំងនឹងទៀវលៀវជំនួសស៊ិនគួនបាន ៨០ ក្បួន នៅមិនទាន់ចាញ់ឈ្នះ ៗ

ស៊ិនគួនបញ្ឈប់សេះមើលថៃស៊ីដូនឹងទៀវលៀវច្បាំងគ្នាក្នុងក្បួនអាវុធ ក៏កើតគិតស្រវឹងស្រពន់ស្មារតីទៅមិនបានរកខ្លួន លីទៀនក៏និយាយនឹងង៉ក់ជិនថា ដែលពាក់គ្រោះមាសជិះសេះនោះឈ្មោះស៊ិនគួនឬ ? បើយើងចាប់ខ្លួនបានក៏ដូចបានសងសឹកឲ្យមហាឧបរាជ ង៉ក់ជិនឮដូច្នោះគិតនឹងចង់បានសេចក្ដីគាប់ ក៏កាន់ដាវបំផាយសេះដម្រង់ទៅដល់ស៊ិនគួនលើកដាវឡើងនឹងកាប់ ស៊ុងទៀមនឹងកែហ៊ួឃើញគេនឹងកាប់ ក៏យកលំពែងខ្លួនរាំងទាំងសងខាង ផ្លូវលំពែងនោះត្រូវង៉ក់ជិន ១ បំផាយសេះរត់ទៅវិញ ស៊ុងទៀម

ក៏ដណ្តើមយកលំពែងពីដៃទាហាន ហើយបំផាយសេះតាមង៉ែកជិនទៅ លីទៀនឃើញស៊ុងខៀមដេញង៉ែកជិនជិតទាន់ ក៏លើកធ្នូឡើងបាញ់ត្រូវដើមទ្រូងស៊ុងខៀមធ្លាក់ពីលើសេះស្លាប់ ។

ថៃស៊ូជូឃើញដូច្នោះក៏ភ័យណាស់ លុះដោះដៃពីទៀវលៀវចេញ ក៏បំផាយសេះរត់ ទៀវលៀវបានចំណាប់ក៏ដេញទាហានតាមសន្ទុញចូលទៅក្នុងកងទ័ពស៊ុនគួន ទាហានស៊ុនគួនក៏បែកខ្ញាត់ខ្ញាយទៅ ទៀវលៀវក្រឡេកឃើញខ្លួនស៊ុនគួន ក៏បំផាយសេះដម្រង់ចូលទៅ ខណៈកាលស៊ុនគួនលើកទ័ពទៅនោះ ទៀកៅនៅក្នុងបន្ទាយមិនទុកចិត្តខ្លាចស៊ុនគួនអន្តរាយ ក៏លើកទាហានចេញមកបង្កប់កណ្តាលផ្លូវ លុះឃើញទៀវលៀវ ៗ ឃើញទាហានស៊ុនគួនចេញស្រមកពីសងខាងផ្លូវ គិតថានឹងដេញតាមទៅក៏ទឹកខ្លាច ទើបនាំទាហានវិលត្រឡប់មកវិញ ស៊ុនគួនក៏លើកទាហានចូលបន្ទាយ ហើយយំសោកាល័យស៊ុងខៀមជាច្រើន ។

(នៅមានត)

រឿងមនុស្សចិត្តប្រែប្រួល

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ រៀបរៀង

(តមក)

## ៣- រឿងស្រីដៃទន់[១]

កាលកន្លងរំលងទៅជាយូរអង្វែងហើយ ព្រះបរមពោធិសត្វសោយរាជសម្បត្តិក្នុងនគរពារាណសី មានព្រះរាជធីតា ១ អង្គ សព្វព្រះទ័យណាស់ ថែរក្សាឲ្យនៅក្នុងព្រះរាជវាំង មានព្រះរាជភាគិនេយ្យ ១ អង្គឲ្យនៅក្នុងព្រះរាជវាំងដែរ ។

ថ្ងៃមួយ ព្រះមហាក្សត្រិយ៍ស្ដេចចេញចុងព្រះរាជរោង ត្រាស់ប្រាប់អាមាត្យមុខមន្ត្រីទាំងពួងថា ខ្ញុំនឹងផ្សំផ្គុំធីតាឲ្យជាអគ្គមហេសីភាគិនេយ្យរបស់ខ្ញុំ ហើយបើឥតពីខ្ញុំទៅហើយ អ្នកទាំងពួងចូលអភិសេករាជធីតានឹងភាគិនេយ្យឲ្យសោយរាជ្យតទៅទៀតចុះ ។ ព្រះរាជឱង្ការនេះលេចឮល្បីសុះសាយទៅពេញព្រះនគរ ។ ឯព្រះរាជធីតានឹងព្រះរាជភាគិនេយ្យទាំងពីរអង្គក៏បានឮព្រះរាជឱង្ការនេះ ហើយមានព្រះទ័យប្រតិព័ទ្ធស្នេហាទៅវិញទៅមករកគ្នា ប៉ុន្តែមិនប្រព្រឹត្តកន្លងរាជប្រពៃណីទេ គ្រាន់តែស្រឡាញ់ដោយពាក្យសំដីប៉ុណ្ណោះ ។

ថ្ងៃក្រោយ ព្រះមហាក្សត្រិយ៍ផ្លាស់គំនិតគិតឃើញថ្មីទៀត ស្ដេច

(១) មុទុបាណិជាតក និបាតជាតករបស់ ព.ប. លេខ ៩/៦ ទំព័រ ១៩៧ ។

ចេញចុះព្រះរាជពេនគ្រាស់ប្រាប់អាមាត្យទាំងពួងថា សំដីដែលខ្ញុំប្រាប់អ្នកពល់គ្នាពីថ្ងៃមុនថា ខ្ញុំផ្សំផ្គុំរាជធីតានឹងកាត្តិនេយ្យនោះលើកចោលទៅចុះ កុំប្រកាន់យកជាការទៀត ដ្បិតខ្ញុំលែងផ្សំផ្គុំទៅវិញហើយ ខ្ញុំនឹងលើកធីតាឲ្យទៅក្សត្រិយ៍នគរឯទៀត ហើយរកធីតាដទៃឲ្យធ្វើជាមហេសីកាត្តិនេយ្យវិញ; ខ្ញុំធ្វើយ៉ាងនេះ ដើម្បីឲ្យពូជពង្សវង្សត្រកូលខ្ញុំរីកសាយកាយបានច្រើន គ្រាស់រួចយាងចូលក្នុងវិញប្រាប់រាជកាត្តិនេយ្យឲ្យចេញទៅនៅក្រៅវាំង ព្រះរាជទានដំណាក់ ១ ឲ្យគង់ ។ ឯព្រះរាជធីតាឲ្យគង់នៅក្នុងប្រាសាទជាមួយព្រះអគ្គជួចដើម ទ្រង់ចាំថែរក្សាណាស់ មិនទ្រង់បណ្តែតបណ្តោយឲ្យព្រះរាជធីតាយាងចេញទៅណារហេតរហូតតែ ១ អង្គឯងទេ បើរាជធីតាចង់យាងចេញទៅក្រៅវាំង ព្រះអគ្គក៏តាមជូនទៅដែរ ទ្រង់ឲ្យរាជធីតាផ្ទំក្នុងបន្ទប់ជិតជាប់ផ្ទាល់នឹងព្រះអគ្គ មិនឲ្យទៅផ្ទំកន្លែងណាឆ្ងាយពីព្រះនេត្រព្រះកាណ៌ទេ ។

បំណែកព្រះរាជធីតានឹងព្រះរាជកាត្តិនេយ្យទាំងពីរអង្គ ជាប់ព្រះទ័យអាឡោះអាល័យឥតក្លេច ព្រោះធ្លាប់នៅក្នុងវាំងតែងបានជួបគ្នារាល់ថ្ងៃលុះដល់ចេញទៅគង់ក្រៅវាំងនឹករលឹកគ្នាណាស់ ប៉ុន្តែរកឱកាសនឹងឲ្យជួបគ្នាពុំបាន ។ ថ្ងៃមួយ ព្រះរាជកាត្តិនេយ្យគិតឃើញឧបាយមួយ ទើបប្រើឲ្យស្រីម្នាក់ទៅហៅស្រីស្នំរបស់ព្រះរាជធីតាពីក្នុងវាំង មកជួបនឹងព្រះអង្គ ហើយប្រទានប្រាក់ឲ្យស្រីស្នំនោះជាច្រើនផ្តាំថា នាងឯងទៅទូល

ព្រះរាជធីតាផងថា ខ្ញុំនឹកណាស់ ចង់ជួបនឹងព្រះរាជធីតាជាពល់ថ្ងៃ សូមព្រះរាជធីតារកឱកាសយាងចេញមកជួបនឹងខ្ញុំនៅក្រៅវាំងផង ។

ស្រីស្នំ – ពរម្ចាស់ ! ចាំខ្ញុំម្ចាស់ទៅទូលស្ទើមើល បើព្រះរាជធីតាមានព្រះសវនីយ៍ដូចម្តេច ខ្ញុំម្ចាស់នឹងវិលមកក្រាបទូលវិញ ។ ស្រីស្នំទៅដល់ក្នុងវាំងឃើញព្រះរាជធីតាគង់នៅស្ងាត់តែ ១ អង្គឯង ចូលទៅទូលថា សូមព្រះរាជធីតាផ្ទំកើយភ្លៅខ្ញុំម្ចាស់ ។ នឹងរកចៃថ្វាយ ។

ព្រះរាជធីតាផ្ទំកើយភ្លៅនាងស្នំ ។ ចុចព្រះសិរនឹងក្រចកទ្រង់យល់ថា នាងស្នំនេះមិនមែនទមករកចៃឲ្យអញដោយគំនិតខ្លួនឯងទេ ប្រហែលជាព្រះរាជកាតិនេយ្យប្រើឲ្យមកនិយាយការអ្វីនឹងអញ បានជាមកចុចក្បាលអញយ៉ាងនេះ ទើបត្រាស់សួរថា នាងដែលទៅជួបនឹងព្រះរាជកាតិនេយ្យឯក្រៅវាំងឬទេ ?

ស្រីស្នំ– មែនម្ចាស់! ខ្ញុំម្ចាស់ទៅជួបហើយទើបនឹងវិលមកដល់ ។

ព្រះរាជធីតា – ចុះព្រះអង្គបានផ្តាំផ្ញើមកខ្ញុំថាម៉េចដែរ ។

ស្រីស្នំ– មែនម្ចាស់ ! ផ្តាំដែរ ថាទ្រង់រលឹកនឹកព្រះនាងណាស់ សូមព្រះនាងខ្មៀតរកឱកាសយាងចេញទៅជួបម្តងនៅដំណាក់ក្រៅវាំង ។

ព្រះរាជធីតាជ្ញាប់ជ្រាបថា ព្រះរាជកាតិនេយ្យមានប្រាជ្ញាឈ្លាសវៃណាស់ អាចដោះស្រាយអាថ៌ប្រស្នាដ៏ល្អិតសុខុមបាន ទើបព្រះនាងប្រាប់ស្រីស្នំថា នាងចាំស្តាប់ចម្រៀងខ្ញុំឲ្យចាំ ហើយយកទៅច្រៀង

ថ្វាយព្រះរាជកាតិនេយ្យចុះ ព្រះអង្គនឹងជ្រាបសេចក្ដីពីខ្ញុំជាមិនខាន ទើបព្រះនាងច្រៀងជាប្រស្នាពាក្យកាព្យថា :

បទពាក្យ ៧:

ខ្ញុំម្ចាស់នឹកណាស់ពុំមានល្ហែ ចង់តែឃើញភក្ត្រវរលំលោ
ខំរកឱកាសឲ្យជួបគ្នា គ្រាំគ្រាក្នុងទ្រូងស្ទើរនឹងបែក ។ សព្វថ្ងៃ
ព្រះវររាជបិតា ថែទាំរក្សាយ៉ាងចំឡែក ការពាររាំងរាត្រីអនេក
មិនឲ្យប្អូនបែកពីព្រះអង្គ ។ ពេលយប់ផ្ទំគ្រែជាប់ជិតគ្នា មិន
ឲ្យឃ្លាតឃ្លាតាមបំណង បេញក្រៅចូលក្នុងសោយឬស្រង់
ព្រះអង្គតែងតាមជាប់ប្រកិត ។ ហេតុនេះសូមទ្រង់រើសរកអ្នក
បាតដៃត្រជាក់សាប់ទន់ល្អិត ដំរីបង្ហាត់បានដូចចិត្ត ឲ្យដើរ
ឬបិតឥតផ្អើលភ្ញាក់ ។ វេលារាត្រីងងឹតឈប់ ផ្គរភ្លៀងទាំង
យប់បេះតែធ្លាក់ បើព្រមអង្គ ៤ នេះជាក់លាក់ ប្អូននឹងឃើញ
ភក្ត្រព្រះអង្គហើយ ។

ស្រីសុំស្ដាប់ចម្រៀងព្រះរាជធីតាចាំច្បាស់ហើយថ្វាយ បង្គំលាចេញទៅក្រៅវាំង ចូលទៅច្រៀងថ្វាយព្រះរាជកាតិនេយ្យសព្វគ្រប់ឥតខ្វះ ។

ព្រះរាជកាតិនេយ្យសប្បាយព្រះទ័យណាស់ ទ្រង់ឈ្វេងយល់ប្រស្នា

ព្រះរាជធីតាថា ត្រូវរកក្មេងប្រុសអាយុដំណាលព្រះនាង បាតដៃទន់ត្រជាក់ដូចព្រះហស្តព្រះនាងឲ្យបានម្នាក់ ត្រូវរកដំរី ១ ដែលហ្វឹកហ្វឺនបានបទហើយ បើខែនោះថ្ងៃ ១៤ ឬ ១៥ កើតងងឹតឈឹងសូន្យហើយមានភ្លៀងធ្លាក់យ៉ាងធំ ផ្គររន្ទះលាន់ឮខ្លាំងក្នុងវេលាពេត្រី ១៤ ឬ ១៥ កើត ឲ្យនាំយកក្មេងប្រុសដៃទន់នោះជិះដំរីជាមួយបរសំដៅ ទៅទទួលព្រះរាជ-ធីតាពីប្រាសាទក្នុងវាំង ទៅដល់ហើយឲ្យលបមើលព្រះនាង បើឃើញព្រះនាងឈរត្រង់ណា ឲ្យបរដំរីចូលទៅត្រង់នោះចុះ មុខជាជួបនឹងព្រះនាងហើយ ។ ឯប្រស្នាដែលព្រះនាងប្រៀងនោះខ្លី ៗ មាន ៤ ប្រការ គឺក្មេងប្រុសដៃទន់ម្នាក់ ១ ដំរីបង្ហាត់បានបទ ១ យប់ខាងរនោច ១៤ ឬ ១៥ កើត ១ ភ្លៀងធ្លាក់ធំ ១ ។

ព្រះរាជកាតិនេយ្យយល់ប្រស្នា ៤ ប្រការនេះច្បាស់ហើយឲ្យស្រីស្នំនោះត្រឡប់ទៅទូលព្រះរាជធីតាវិញ ហើយទ្រង់ឲ្យរកក្មេងប្រុសបានម្នាក់មានបាតដៃទន់, ទាំងអាយុក៏ដំណាលគ្នានឹងព្រះរាជធីតា ទ្រង់ប្រទានប្រាក់ឲ្យទ្រមាក់ដំរីព្រះទីនាំងខំបង្ហាត់ដំរីឲ្យបានបទ ។ លុះដល់ថ្ងៃ ១៥ កើត មានភ្លៀងធ្លាក់យ៉ាងធំ ក្នុងពេលកណ្ដាលអធ្រាត្រងងឹតសូន្យព្រះរាជកាតិ-នេយ្យនាំក្មេងប្រុសដៃទន់ជិះដំរីបរទាំងកំពុងភ្លៀងធំសំដៅទៅព្រះរាជវាំង ។

ចំណែកព្រះរាជធីតាជ្រាបច្បាស់ថា ព្រះរាជកាតិនេយ្យពិតជាទៅទទួលព្រះនាងនៅពេលយប់នោះមិនខាន ព្រោះថ្ងៃ ១៥ កើត មានភ្លៀងធំ

កណ្ដាលអគ្រាត្រត្រូវតាមប្រស្នា ទើបព្រះនាងធ្វើឧបាយកលទូលព្រះវេរពជបិតាថា ខ្ញុំម្ចាស់ក្ដៅស្អុះណាស់ សូមចេញទៅស្រង់ទឹកភ្លៀងនៅទីវាលខាងក្រៅប្រាសាទ ។

ព្រះវេរពជបិតា – កុំនាង! ខ្លាចក្រែងមានគ្រោះថ្នាក់ដល់ខ្លួន ព្រោះយប់ងងឹតម្ចាត់ណាស់ បើចង់ស្ងួតទឹកភ្លៀង បិតាជូនទៅ គ្រាស់ហើយដឹកព្រះហស្តព្រះពជធីតា ឲ្យចេញទៅឈរនៅរបៀងប្រាសាទក្បែរបង្អួចទ្រង់ឈរកៀងប្រាសាទលូកឈោងចាប់ព្រះហស្តព្រះពជធីតាម្ខាងជាប់ ទុកតែព្រះហស្តម្ខាងឲ្យជុសក្អុល ។

ពេលនោះ ព្រះពជកាគិនេយ្យបរដើរទៅឈរឈប់អែបក្បែរព្រះពជ-ធីតា ១ ហុចព្រះហស្តម្ខាងឲ្យព្រះពជកាគិនេយ្យដោះគ្រឿងមាសពេជ្រយកទៅបំពាក់ដៃក្មេងប្រុស រួចព្រះនាងហុចដៃក្មេងប្រុសនោះទៅឲ្យព្រះវេរបិតាចាប់ ។ ព្រះវេរបិតាចាប់ដៃក្មេងម្ខាងជាប់ហើយលែងព្រះហស្តព្រះនាងម្ខាងទៀត ព្រះនាងបានរួចព្រះហស្តទាំងពីរហើយដោះអស់គ្រឿងមាសពេជ្រពីព្រះអង្គទៅបំពាក់ខ្លួនក្មេងប្រុស រួចព្រះនាងគេចចេញឡើងគង់លើដំរីជាមួយព្រះពជកាគិនេយ្យបរចេញទៅឯដំណាក់ ជួជាមួយព្រះពជកាគិនេយ្យកុងកត្រើនោះឯង ។

ចំណែកព្រះមហាក្សត្រិយ៍ចាប់ដៃក្មេងប្រុសម្ខាងជាប់សំគាល់ថា ជាព្រះពជធីតាព្រោះដៃទន់ហើយប៉ុនគ្នា ថែមទាំងងងឹតទគរូបកេក្មេងមិនច្បាស់

ផង កំដឹកដៃក្មេងនោះឲ្យចូលទៅដេកលើគ្រែព្រះរាជធីតា រួចព្រះអង្គបិទទ្វារជិតផុំទៅ ៗ លុះព្រឹកឡើង ស្រាប់តែទតឃើញក្មេងប្រុសដេកលើគ្រែ ទ្រង់ខឹកខ្ញាល់ណាស់ហៅក្មេងនោះមកសួរ ក្មេងក្រាបទូលហេតុរឿងរ៉ាវគ្រប់ប្រការ ទ្រង់តូចព្រះទ័យយ៉ាងខ្លាំងពិចារណាថា ឱហ្ន៎! គួរឲ្យអស្ចារ្យណាស់ ! សូម្បីអញចាប់ដៃស្រីជាប់ម៉ឹងហើយក៏នៅតែរក្សាការពារស្រីទុកមិនគង់ដែរ យីអើ ! ពួកស្រី ៗ លំបាករក្សាណាស់តើ ទើបទ្រង់លាន់ព្រះឱស្ឋថា ៖

**បទកាកគតិ:**

ជាតិស្រីទាំងឡាយ ទោះប្រុសខ្វល់ខ្វាយ ឲ្យបាយបំណី
ឲ្យរបស់ទ្រព្យ រាប់មិនអស់ក្ដី ក៏រក្សាស្រី នោះទុកមិនគង់ ៗ
ផ្សិតស្រីចិត្តជាប់ បើប្រែក្រឡាប់ ក្រឡាស់លិចលង់ ជាប់
នឹងប្រុសណា ដោយកាមាភិសង្គ កើតចិត្តទ្រនង់ វែងស្ដាប់
ខេបា ៗ ស្ញប់ញីត ស្លាប់ជះជីតគិត ខ្លាចក្ដីមរណា ឲ្យ
តែសម្រេច សេចក្ដីប្រាថ្នា ព្រោះលោភតណ្ហា មិនចេះឆ្អែត
ឆ្អន់ ៗ សេចក្ដីប្រាថ្នា មានបីប្រការ ចិត្តស្រីមិនស្រាន់
មួយសេពមេថុន ពីរមានអាសន្ន សម្រាលកូនគន់ បីគ្រឿង
តែងខ្លួន ៗ

ព្រះមហាក្សត្រិយ៍ លាន់ព្រះឱស្ឋយ៉ាងនេះហើយ ស្ដេចយាងចេញចុះព្រះពជពេងត្រាស់ពន្យល់ពួកមុខមន្ត្រីផងរាំងផង ឲ្យដឹងអំពីរឿងស្រីថា យើងរាល់គ្នាជាប្រុសគួរតែតក់ស្លុតចិត្តខ្លាចស្រី ៗ ឲ្យណាស់ ព្រោះដ្បិតប្រុសមិនអាចនឹងហាមប្រាមឃាត់ទាំងរាំងរក់ចិត្តស្រីបានទេ ទោះខំ-យាយលួងលោមផ្អែមល្ហែមក្ដី ឲ្យប្រាក់មាសច្រើនដប់ប៉ុន្មានក្ដី បើចិត្តស្រីបាក់ទៅត្រង់ណាហើយ មុខជាទៅត្រង់នោះតាលតែបានមិនខាន គ្មានប្រុសណាទប់ល្បះទេ អម្បាលខ្ញុំជាបិតាពាល់ដៃកូនស្រីជាប់ហើយ ម្ដេចក៏នៅតែកូនស្រីនេះរកឧបាយកលគេចចេញទៅតាមប្រុសបាន ៗ ធម្មតាចិត្តស្រី ៗ មិនចេះឆ្អែតឆ្អន់នឹងរបស់ ៣ យ៉ាងអស់មួយជីវិត គឺការសេពមេ-ថុន ១ ការសម្រាលកូន ១ ការតាក់តែងខ្លួន ១ ៗ ប្រុសណាវង្វេងស្មា-រតីមិនប្រុងប្រយ័ត្នខ្លួន ចេះតែបណ្ដោតបណ្ដោយឲ្យផុងខ្លួនទៅក្នុងអំណាចស្រីហើយ ប្រុសនោះទោះបីមានកំឡាំងខ្លាំងយ៉ាងណា ក៏ត្រឡប់ទៅជាខ្សោយវិញដែរ ទោះបីមានភ្នែកភ្លឺក៏ទុកដូចជាខ្វាក់ ទោះបីមានគំនិតប្រាជ្ញាឈ្លាសវៃក៏បែរជាល្ងង់ខ្លៅវិញ ហេតុនេះ ប្រុសអ្នកសេពគប់នឹងស្រី ត្រូវតែសង្កេតឲ្យដឹងចិត្តស្រីវៀចឬត្រង់ល្អឬអាក្រក់ ដ្បិតចិត្តស្រីដែលស្មោះត្រង់ល្អនឹងប្ដី ក៏ស្មោះត្រង់ណាស់រហូតដល់ស៊ូស្លាប់ខ្លួន មិនមែនសុទ្ធតែចិត្តអាក្រក់ក្បត់ប្ដីគ្រប់រូបស្រី ៗ ទេ ដូចដើមឈើដុះក្នុងព្រៃ ដើមខ្លះ

វៀច ដើមខ្ទះត្រង់ ។ ហេតុនេះ បានជាមានស្រីខ្ទះគ្រប់លក្ខណ៍ ស្រីខ្ទះខាតលក្ខណ៍ ។

ព្រះបរមពោធិសត្វជាព្រះមហាក្សត្រិយ៍ ទ្រង់ត្រាស់ទូន្មានអស់នាម៉ឺនមុខមន្ត្រីដូច្នេះហើយ ទ្រង់ប្រើរាជអាមាត្យឲ្យទៅហៅព្រះរាជធីតានឹងព្រះរាជភាគិនេយ្យ ឲ្យចូលមកគាល់ ដោយទ្រង់មានព្រះរាជហឫទ័យមេត្តាករុណាកាត់ពោលមិនដាច់ ទ្រង់ផ្សំផ្គុំព្រះរាជធីតាឲ្យជាមហេសីព្រះរាជភាគិនេយ្យស្រេចហើយ ទ្រង់តាំងព្រះរាជភាគិនេយ្យក្នុងដំណែងជាព្រះមហាឧបរាជ ។ លុះចំណេរបីរកាលមក ព្រះបរមពោធិសត្វជាព្រះវររាជបិតាទិវង្គត់ទៅ ព្រះមហាឧបរាជទទួលសោយរាជសម្បត្តិ តព្រះរាជវង្សមក ។

រឿងស្រីដៃទន់ ចប់តែប៉ុណ្ណោះ ។

(នៅមានត)

# ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសជប៉ុន

លោក រ៉ូបារ្ត្រ ប៉ែរត៍

អតីតសាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ប្រទេសកម្ពុជា

បាននិពន្ធកាលពីឆ្នាំ ១៩៥៩ - ៦០

លោក ញ៉ែម.ទឹម ប្រែសម្រួល

---

ប្រទេសនេះ បើហៅតាមភាសាជប៉ុនថា នីបប៉ុង ប្រែថា ប្រទេសនៃថ្ងៃរះ ។

ប្រទេសជប៉ុនមានទំហំ ៣៧០.០០០ គ.ម², ជាប្រទេសប្រកបដោយកោះច្រើនអនេក, ហើយបណ្តាកោះទាំងនោះ, មានតែកោះ ៤ទេ ដែលសំខាន់ជាងគេ គឺ:

– នៅទិសខាងជើង : កោះហុកកៃដូ (Hokkaïdo) និងកោះហុងដូ ( Hondo ) ដែលជាកោះធំជាងគេ ។

– នៅទិសខាងត្បូង : កោះគ្យូ - ស៊្យូ (Kiou - Siou ) ។

– នៅទិសអាគ្នេយ៍ : កោះស៊ីកុក (Sikok) ។

ប្រទេសជប៉ុនជាប្រទេសទើបតែនឹងកកើតឡើងក្នុងជំនាន់ថ្មីៗ ហើយមួយភាគធំនៃប្រទេសមានសុទ្ធតែជួរភ្នំ ហើយច្រើនតែភ្នំភ្លើងផង ។ ដូច្នេះ បើសិនជាភ្នំភ្លើង ១៦៥ បានរលត់អស់ទៅ, នៅមាន ៥០ ទៀតកំពុងតែឆេះ ។ ភ្នំភ្លើងដែលល្បីជាងគេជាងគេគឺត្រង់ទៅកណ្តាលកោះហុងដូ គឺភ្នំភ្លើងហ្វូយស៊ី.យ៉ាម៉ា (Fuji-yama) មានកំពស់ ៣.៧៧៨ ម. គឺជា

កំពូលខ្ពស់បំផុត ។

ប្រទេសជប៉ុនស្ថិតនៅលើដំបន់មួយមិនស្ថិតស្ថេរ គឺជាតំបន់ជាប់គ្នានឹងខ្សែរ័ណ្ឌនៃសមុទ្រប៉ាស៊ីហ្វិក ។ ការរញ្ជួយដីតែងមានជាញឹកញយៗក្នុងមួយឆ្នាំ ៗ មានការរញ្ជួយដីយ៉ាងតិចណាស់ក៏ជាងមួយរយដងដែរ ។ ក្នុងរយៈ ៦ ឆ្នាំតែងមានការរញ្ជួយដីយ៉ាងខ្លាំងម្តង ហើយការរញ្ជួយដីដ៏ខ្លាំងអស្ចារ្យជាងគេគឺកាលពីឆ្នាំ ១៩២៣ ។ ក្នុងឆ្នាំនោះ, នៅក្នុងរាជធានីតូក្យូ នឹងនៅយ៉ូកូហាម៉ា មានមនុស្សចំនួន ១០០.០០០ នាក់ត្រូវស្លាប់ នឹងផ្ទះចំនួន ៥០០.០០០ ខ្នង ត្រូវបាក់បែកខ្ទេចខ្ទីអស់ ។

ប្រទេសជប៉ុនពុំសូវមានវាលរាបស្មើទេ វាលរាបស្មើមានទំហំទាំងអស់ចំនួនតែ ៧០.០០០ គម² ហើយជាវាលតូច ៗ ស្ថិតនៅតាមមាត់សមុទ្រប៉ាស៊ីហ្វិក ។ វាលដែលធំជាងគេ គឺវាលតូក្យូ ។

អំពីឆ្នេរសមុទ្រ — ប្រទេសជប៉ុន នឹងប្រទេសអង់គ្លេសជាប្រទេសមានឆ្នេរសមុទ្រ លាតសន្ធឹងវែងជាងគេទាំងអស់ក្នុងសាកលលោក បើគិតតាមទំហំផ្ទៃដីនៃប្រទេស ។ ឆ្នេរសមុទ្រប៉ែកខាងលិចក្រងេតក្រងោតណាស់, ចំណែកឯឆ្នេរសមុទ្រប៉ែកខាងកើតវិញល្អណាស់ គឺជាកន្លែងមួយដ៏សំខាន់ សម្រាប់ប្រកបជីវភាពសមុទ្រនៅក្នុងសមុទ្រក្នុង ដែលស្ថិតនៅចន្លោះនៃកោះបីខាងត្បូង ។

# អំពីធាតុអាកាសនិងរុក្ខជាតិ

ប្រទេសជប៉ុនជាប្រទេសប្រកបដោយខ្យល់រដូវ ៗ នៅសិសិររដូវ (រដូវត្រជាក់ខ្លាំង= ( hiver ) ខ្យល់បក់ពីដីគោកទៅសមុទ្រ គឺពីទិសពាយព្យទៅទិសអគ្នេយ៍ៈ ខ្យល់ត្រជាក់ហើយស្ងួត ៗ នៅវស្សានរដូវវិញ (រដូវក្តៅ= ( été ) ខ្យល់បក់ពីសមុទ្រទៅកាន់ដីគោក គឺពីទិសអគ្នេយ៍ទៅទិសពាយព្យៈ ខ្យល់ក្តៅបន្តិច ៗ ហើយសើម ៗ ចាប់ពីខែឧសភាទៅខែវិច្ឆិកា, ភ្លៀងធ្លាក់យ៉ាងជោគជាំ គឺមិនដែលតិចជាង ១ ម. ឡើយ មានតែពី ១ ម.៥០ ឡើងទៅ ៗ នៅក្រុងតូក្យូៈ ខែមករា ៣ អង្សា, កក្កដា ២៥ អង្សា ; ភ្លៀង ១ ម. ៥០ ៗ

ប្រទេសជប៉ុនសម្បូណ៌ដោយរុក្ខជាតិផ្សេងៗ មានរុក្ខជាតិសម្រាប់ស្រុកមិនត្រជាក់ពេក-ក្តៅពេក ទាំងរុក្ខជាតិសម្រាប់ស្រុកក្តៅ ៗ ឈើជាតែមានតម្លៃណាស់នៅស្រុកជប៉ុន, សម្រាប់សង់ផ្ទះទាំងធ្វើជាគ្រឿងកម្មករ ... ឧស្សាហកម្ម ៗ គេសង្កេតឃើញអាកាសធាតុ ៣ យ៉ាង ខុសគ្នាក្នុងប្រទេសជប៉ុន :

ក)- ធាតុអាកាសនៃកោះហុក្កៃដូ (ឬកោះយ៉េសូ)

នៅសិសិររដូវ ធាតុអាកាសត្រជាក់ណាស់ ឯវស្សានរដូវវិញមិនជាក្តៅទេ ព្រោះកោះស្ថិតនៅតាមខ្សែទឹកត្រជាក់ ៗ នៅលើកោះនោះគេឃើញមានដើមឈើមានស្លឹកធំៗ និងពិសេសស្ពៃច្រើនណាស់ ៗ ជាយូរ

ណាស់មកហើយ ប្រជារាស្ត្រជប៉ុនមិនព្រមទៅនៅលើកោះនោះ ព្រោះកោះនោះមានធាតុអាកាសខុសពីកន្លែងដែលខ្លួនធ្លាប់រស់នៅមក ។

ខ)- ធាតុអាកាសកោះហុនស៊ូ (ឬកោះនីបប៉ុន) គឺជាកោះមានធាតុអាកាសមិនត្រជាក់ពេកមិនក្តៅពេក ។ នៅសិសិររដូវ ធាតុអាកាសបែបត្រជាក់ស្ងួត, ឯវស្សានរដូវ ធាតុអាកាសក្តៅល្មម អាចឲ្យធ្វើដំណាំស្រូវបានដោយស្រួល ។ នៅខាងត្បូងក្រុងតូក្យូ គេមានដាំតែ, មន និងរុក្ខជាតិស្រុកក្តៅ ។

គ)- ធាតុអាកាសនៃកោះពីរខាងត្បូង គឺជាធាតុអាកាសនៃប្រទេសក្តៅ, គ្មានសិសិររដូវទេ ។ គេសង្កេតឃើញរុក្ខជាតិផ្សេង ៗ ដូចជា ឬស្សី, ចេក, ដូង, កប្បាស, អំពៅ ។

## អំពីប្រជាជនជប៉ុន

ប្រជាជនជប៉ុនមានដើមកំណើតកាត់ចិន និងឥណ្ឌូណេស៊ី ៗ មកទល់នឹងឆ្នាំ ១៨២០ ចំនួនប្រជាជនជប៉ុនបានស្ថិតនៅនឹង ។ ប៉ុន្តែតាំងពីឆ្នាំនោះមក, ប្រជាជនជប៉ុនស្រាប់តែកើនចំនួនយ៉ាងឆាប់រហ័សក្រៃលែងគួរឲ្យខ្លាច ។ កាលពីឆ្នាំ ១៨២០ ប្រជាជនជប៉ុនមានចំនួន ៣០.០០០ ០០០ នាក់, សព្វថ្ងៃមានចំនួន ៩០ ០០០ ០០០ នាក់ ។ ការកើនចំនួននេះបណ្តាលមកអំពីការបាត់ឃ្លាតសង្គ្រាមក្នុងស្រុករវាងគ្នាឯង និងការលែងអត់បាយ, អំពីការហាមឃាត់មិនឲ្យសម្លាប់ទារក ( ទារកឃាត ) និង

អំពីការឃោសនានៃព្រះចៅអធិរាជ ដើម្បីបន្ថែមកំឡាំងនៃប្រទេស ។

ប្រជាជនជប៉ុនកើតច្រើនជាងស្លាប់ ។ គេសំគាល់ឃើញមនុស្សកើត ៣០% (៣០ ភាគរយ) ក្នុងមួយឆ្នាំ ដោយប្រទេសជប៉ុនជាប្រទេសមួយ ដែលមានមនុស្សស្លាប់តិចជាងគេក្នុងសាកលលោក ។

តាប់តាំងពីឆ្នាំ ១៩៤៦ មក, ក្រោមឥទ្ធិពលនៃសហរដ្ឋអាមេរិក នយោបាយថ្មីមួយក៏បានធ្វើឡើង គឺមធ្យោបាយបន្ថយចំនួនមនុស្សកើត ដោយប្រើថ្នាំកុំឲ្យមនុស្សមានផ្ទៃពោះ ហើយជាពិសេសគឺការពន្លូតកូនតាមច្បាប់ (នៅស្រុកជប៉ុនមានច្បាប់អនុញ្ញាតឲ្យស្ត្រីមានផ្ទៃពោះពន្លូតកូនបាន) ។ នយោបាយនេះ បានផ្តល់លទ្ធផលយ៉ាងប្រសើរ ហើយការកើតក៏បានថយចំនួនពាក់កណ្តាលមកវិញ គឺកាលពីដើមមានមនុស្សកើតចំនួន ៣.០០០ ០០០ (បីលាន) នាក់ក្នុងមួយឆ្នាំ ឥឡូវមានតែមួយលានប្រាំសែននាក់ទេ (១៥០០.០០០) ។ នយោបាយនេះជាការចាំបាច់ណាស់ ព្រោះប្រជាជនបានកើនរហ័សជាងស្បៀងអាហារសម្រាប់ចិញ្ចឹមមនុស្សក្នុងប្រទេស ហើយកំពស់ជីវភាពអាចនឹងធ្លាក់ចុះបានដោយងាយ ។ មួយចំណែកទៀត ប្រទេសដទៃទៀតបានប្រកែកមិនព្រមទទួលប្រជាជនជប៉ុនឲ្យរស់នៅក្នុងប្រទេសគេទេ ។ ឯពេលឧស្សាហកម្មក្នុងប្រទេសទៀត ក៏ពុំអាចផ្តល់ការងារដល់យុវជនជប៉ុនឲ្យបានគ្រប់គ្នាឡើយក្នុងមួយឆ្នាំ ។ ។

ប្រទេសជប៉ុនជាប្រទេស ដែលមានប្រជាជនចូលចិត្តរស់នៅក្នុងទីក្រុងណាស់ ។ ៦០ ភាគរយនៃប្រជាជនបានរស់នៅក្នុងទីក្រុងធំ ៗ, ហើយមានទីក្រុង ៦ ដែលមានប្រជាជនច្រើនជាង ១ លាននាក់ គឺ:

១– តូក្យូ : មានប្រជាជន ៨ លាននាក់ គឺជាទីក្រុងធំសម្បើម ហើយជាពជធានីនយោបាយនឹងសេដ្ឋកិច្ចនៃប្រទេស ។ ទីក្រុងមានចែកជាសង្កាត់ ៗ មានសង្កាត់រៀបចំតាមគំរូអឺរុប ដូចជាសង្កាត់សម្រាប់ធនាគារ សង្កាត់សម្រាប់ការងារជំនួញ និងសង្កាត់រៀបចំតាមរបៀបប្រពៃណីជាតិជប៉ុនខ្លួនឯង ។ សង្កាត់ខាងក្រោយនេះមានផ្ទះតូច ៗ ហើយសង់តែមួយជាន់ទេ ។

២)– យ៉ូកូហាម៉ា : មានប្រជាជន ១ លាន ៦ សែននាក់ ជាកំពង់ផែទីពីរនៃប្រទេស, ជាកន្លែងសំខាន់មួយ ខាងសង់នាវា និងជាកន្លែងឧស្សាហកម្មខាងធ្វើស្ពូត្រ ។

នៅលើដៃសមុទ្រក្នុង, មានទីក្រុងធំពីរស្ថិតនៅជិត ១ គ្នា គឺ :

៣)– អូសាកា : មានប្រជាជន ៣ លាននាក់, ជាមជ្ឈដ្ឋានដ៏សម្បើមមួយខាងឧស្សាហកម្មធ្វើកប្បាស ។

៤)– កូបេ : មានប្រជាជន ១ លាននាក់ ជាកំពង់ផែទី ១ នៃប្រទេស ហើយជាកន្លែងឧស្សាហកម្មមួយយ៉ាងសម្បើមខាងធ្វើនាវា ។

៥)– ណាកូយ៉ា : មានប្រជាជន ១ លាន ៣ សែននាក់

គឺជាកន្លែងឧស្សាហកម្មមួយយ៉ាងសំខាន់ ខាងធ្វើកប្បាសនឹងពេមចៀម ។

៦)- គាវ្យូតូ: ជាទីក្រុងមួយតែឯង ដែលស្ថិតនៅឆ្ងាយពីសមុទ្រ មានប្រជាជន ១ លាន ១ សែននាក់ ជាអតីតកជធានីប្រវត្តិសាស្ត្រមួយ ដែលព្រះចៅអធិកជបានគង់នៅមុនសម័យមៃស៊ី(Ere Meiji) សម័យដែលប្រទេសជប៉ុនបានចំរើន នឹងជាកន្លែងទេសចរណ៍មួយយ៉ាងមនោរម្យ ។

## សកម្មភាពសេដ្ឋកិច្ចនៃប្រទេសជប៉ុន

អំពីកសិកម្ម.-

ក)- របៀបដាំដំណាំ - កសិកម្មជប៉ុនស្ថិតនៅជាមុខរបរមួយយ៉ាងសំខាន់ក្នុងប្រទេស ។ ៨០ ភាគរយនៃផលិតផលកសិកម្មបានរ៉ប់រងដល់អាហារសម្រាប់ចិញ្ចឹមប្រជាជនក្នុងប្រទេស:ចំនួននេះឃើញថាសំខាន់ណាស់ ព្រោះផ្ទៃប្រទេសពុំសូវមានកលកបស្មើទេ ។ ដីទាំងឡាយដែលអាចដាំដុះបាន គឺសុទ្ធតែមានធ្វើរបរកសិកម្មទាំងអស់ សូម្បីតែដីនៅនឹងភ្នំតូចៗ ក៏គេរុករានធ្វើរបរទាំងអស់ គឺជារបរកសិកម្មវិទ្យាសាស្ត្រ ព្រោះពាក់កណ្ដាលនៃដីដែលអាចដាំបាន សុទ្ធតែធ្វើឡើងដោយការបាចទឹកបញ្ចូលស្រែ ។ ក្នុងការធ្វើដំណាំនេះ គេបានប្រើជីយ៉ាងសម្បើម គឺមានទាំងជីដែលធ្វើចេញពីរោងឧស្សាហកម្មផង ។ ស្រែទាំងឡាយសុទ្ធតែបានទទួលការថែទាំយ៉ាងហ្មត់ចត់ គឺការថែទាំតាមរបៀបសិល្បៈខាងថែសួន ហើយនៅខាងត្បូងតូក្យូ គេធ្វើរបរពីរដងក្នុងមួយឆ្នាំ ។ ប៉ុន្តែ ក្រៅអំពីការគ្នុរពស់ចេញ, កិច្ចការទាំងអស់សុទ្ធតែធ្វើនឹងកំឡាំងមនុស្ស ។

(នៅមានត)

# តាមឯកសារទំនៀមទម្លាប់ខ្មែរ

## រឿងព្រេងភ្នំបាណន់

## នៅខេត្តបាត់ដំបង

កាលបើយើងធ្វើដំណើរទៅតាមដងស្ទឹងសង្កែ ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង យើងនឹងឃើញភ្នំមួយឈ្មោះ ភ្នំបាណន់ នៅខាងលិចស្ទឹង ខាងជ្រុងអគ្នេយ៍ទីក្រុងបាត់ដំបង ចម្ងាយប្រហែលជាង ១០ គីឡូម៉ែត្រ ពីទីក្រុងនេះ ។ ភ្នំនេះជាភ្នំស័ក្តិសិទ្ធិមួយសម្រាប់អ្នកស្រុកធ្វើពិធីការបូជា តាំងពីបុរាណកាលមក ។

ប្រវត្តិនៃភ្នំនេះ មានដូចតទៅ ៖ តាមចាស់ៗ ពោលថា កាលពីព្រេងនាយ មានសេដ្ឋីម្នាក់មានកូនស្រីមួយឈ្មោះនាងរំសាយសក់ នាងនោះចេះតែឈឺដោយជម្ងឺរាំងរដូវជាយូរឆ្នាំ ។ ក្រោយមកមានតាបសម្នាក់ឈ្មោះ តាក្រាម បានទទួលមើលជម្ងឺនាងនោះលុះត្រាតែជាសះស្បើយ ។ កាលបើជាហើយ មហាសេដ្ឋីជាឪពុកនាងក៏បានផ្សំផ្គុំឲ្យជាភរិយាតាបសនោះ ។ តាបសបង្ហាត់បង្រៀនឲ្យនាងចេះមន្តអាគមផ្សេងៗជាច្រើនមុខ មានមន្តហៅខ្យល់ព្យុះជាដើម ។

តាបសនិងភរិយារស់នៅក្នុងរូងភ្នំមួយហៅថា ព្រះធិតា ឬ ប្រធិតា (តាមសំដីអ្នកស្រុក) ។ រូងភ្នំនោះនៅខាងត្បូងភ្នំបាណន់សព្វថ្ងៃ

ដែលកាលនោះភ្នំបាណន់គេហៅថា ភ្នំប្រាសាទ នៅឡើយ ។

ខាងក្រោយមក មានព្រះរាជបុត្រស្ដេចមួយព្រះអង្គព្រះនាម ចៅរាជកុល មកសុំរៀនមន្តវិជ្ជាផ្សេង ៗ ពីតាគ្រាម ។ តាបសសុខចិត្តបង្ហាត់បង្រៀនព្រះរាជបុត្រនេះលុះត្រាតែចេះ ប៉ុន្តែហាមព្រះរាជកុមារមិនឲ្យមើលប្រពន្ធគាត់សោះ ដោយគាត់ខ្លាចចៅរាជកុលស្រឡាញ់ប្រពន្ធគាត់ ព្រោះនាងរំសាយសក់រូបល្អណាស់ ។

គង់ជាយូរខែក្រោយមក ពេលមួយជួនជាតាបសមិននៅ ចៅរាជកុលទៅលួចមើលប្រពន្ធគាត់ ឃើញរូបនាងល្អឆើត ក៏កើតសេចក្ដីប្រតិព័ទ្ធ លួចសាកសួរចិត្តនាង ៗ ស្រឡាញ់ ចៅរាជកុល ដែរ ក៏ទទួលព្រម ។

ថ្ងៃមួយ តាបសចូលទៅក្នុងព្រៃ ដើម្បីរកវត្ថុផ្សេង ៗ អ្នកទាំងពីរបានឱកាសល្អ ក៏នាំគ្នាជិះសំពៅរត់ចោលតាបសទៅ ។

កាលតាបសត្រឡប់មកពីព្រៃវិញ ពុំឃើញមានមនុស្សនៅក្នុងរូងភ្នំនោះ គាត់ក៏ដឹងថា ចៅរាជកុល និងភរិយាគាត់ពង្រត់គ្នា គាត់តាមទៅដល់មាត់សមុទ្រ បានឃើញសំពៅ ចៅរាជកុល និងនាងរំសាយសក់ ឃ្លាតឆ្ងាយដល់ទៅកណ្ដាលសមុទ្រទៅហើយ ។ ខឹងណាស់ តាបសក៏សែកមន្តវិជ្ជាហៅខ្យល់ព្យុះ ដើម្បីបំផ្លាញសំពៅនៅកណ្ដាលសាគរ ។ ប៉ុន្តែ ដោយនាង រំសាយសក់ ចេះមន្តវិជ្ជា

ដែរ ក៏ធ្វើឲ្យខ្យល់បក់ផាត់ខ្យល់កំណាចនោះផុតអស់ទៅ ។ តាមសឈី ចិត្តខ្លាំងពេកក៏ដួលស្លាប់នៅក្នុងសមុទ្រនោះឯង ។

អ្នកទាំងពីរដឹងហេតុដូច្នោះ ក៏នាំគ្នាត្រឡប់សំពៅមកកាន់រូងភ្នំប្រធិតាវិញ នៅរួមសុខទុក្ខជាមួយគ្នា ។

ខាងក្រោយមក, ចៅរាជកុល នឹកចង់ត្រឡប់ទៅស្រុកវិញ ក៏លាប្រពន្ធសន្យាថានឹងត្រឡប់មកវិញពុំខាន ។ ប៉ុន្តែ ដល់ពេលដែល ចៅរាជកុល ត្រឡប់មករកនាង រំសាយសក់ វិញ នាងប្រពន្ធដើមខឹងណាស់ ក៏ប្រើក្រពើរបស់នាងឈ្មោះ អាជធំ ឲ្យទៅឃាំងផ្លូវ កុំឲ្យ ចៅរាជកុល ទៅវិញបាន ។ ឯនាង រំសាយសក់ លុះក្រឡេកឃើញសំពៅប្តីរៀបលិច ក៏បន់ទេវតាដែលនៅរក្សា ភ្នំប្រាសាទ ថា "សូមឲ្យតែជួយប្តីខ្ញុំឲ្យរួចពីគ្រោះថ្នាក់ចុះ ខ្ញុំនឹងថ្វាយភ្នំនេះ" ។ ការបន់នោះ ក៏បានសម្រេចដូចសេចក្តីប្រាថ្នា ។ ចាប់តាំងពីនាងបន់នោះ មកគេហៅ ភ្នំប្រាសាទ នោះថា ភ្នំចាណាដ់ វិញ ។

កាលណាបើយើងចូលទៅក្នុងរូង ភ្នំចាណាដ់ យើងនឹងឃើញរូងនោះ មានដំបូលខាងលើរាងកោងដូចដំបូលទូក ។ នៅជញ្ជាំងរូងនោះ មានកន្លែងទឹកស្រក់ ១ មានគម្រងរាងដូចក្បាលបុកអង្ករ ទំហំប្រហែលជាប៉ុនល្អី ។ រូងភ្នំនោះ មានទំហំប្រហែល ១២ ម៉ែត្រ ៤ ជ្រុង ជញ្ជាំងថ្ម ពុំមានចម្លាក់អ្វីទេ ប៉ុន្តែនៅខាងត្បូងគម្រងទឹកស្រក់ជញ្ជាំងមានព្រះពុទ្ធរូប

ប្រាក់បែកជាច្រើន ៗ ពន្លឺព្រះអាទិត្យចូលទៅបំភ្លឺក្នុងរូងភ្នំនោះ តាមប្រហោងមួយនៅពីលើដំបូល ៗ គេចូលទៅក្នុងរូងនោះតាមផ្លូវមួយតូចងងឹតសូន្យ ៗ បើគេចង់ចូលទៅក្នុងនោះ គេត្រូវអុជចន្លុះបំភ្លឺផ្លូវ ហើយត្រូវដើរជាជួរបន្តគ្នាទើបអាចចូលទៅដល់កន្លែងទឹកស្រក់នោះបាន ៗ

តាមអ្នកស្រុកភ្នំបាណន់នោះនិយាយថា ជួនកាលតម្រងថ្មនោះមានទឹកពេញ ជួនកាលមានទឹកតែត្រឹមពាក់កណ្ដាលទេ គេថាបើតម្រងថ្មមានទឹកពេញ ជាប្រផ្នូលឲ្យអ្នកស្រុកបានផលស្រូវបរិបូណ៌, បើទឹកកន្លះអ្នកស្រុកធ្វើស្រូវពុំសូវបានផលទេ ៗ

ទឹកដែលគេឃើញនៅតម្រងនោះថ្លាថ្លង់ ហើយជនទាំងឡាយដែលទៅដល់ទីនោះ មិនដែលខានក្បង់ទឹកនោះមកលុបលាងក្បាលទេ ដើម្បីសុំសេចក្ដីសុខសប្បាយ ៗ

រាល់ឆ្នាំគេតែងមានធ្វើពិធីបូជានៅភ្នំបាណន់នេះ ៗ ចំពោះពេលចូលឆ្នាំថ្មី, គេធ្វើខាងលើភ្នំ នូវពិធីបុណ្យទាំងឡាយ មានពិធីពូនភ្នំខ្សាច់នឹងនិមន្តលោកឆាន់ជាដើម ហើយមានរបាំប្រដាល់នឹងមានចែកទានជាប្រាក់ឬសំលៀកបំពាក់ដល់អ្នកក្រផង ៗ

នៅថ្ងៃទី ១ ជាថ្ងៃចូលបុណ្យ គេតែងធ្វើពិធីបួងសួងសុំឲ្យទេវតាថ្មីជួយអ្នកស្រុកឲ្យបានសេចក្ដីសុខសប្បាយ ៗ បើកាលណាគេភ្លេចធ្វើពិធីបួងសួងនេះ មុខជាមានភ្លៀងធ្លាក់នៅពេលចូលឆ្នាំ ៣ ថ្ងៃ ហើយ

អ្នកស្រុកនឹងកើតជម្ងឺពេញទាំងភូមិ ។

ពិធីបួងសួងនោះ មានស្លាធម៌ បាយសី ហើយក្អែងលេងបទបួងសួង ។

តាមអ្នកស្រុកនិយាយថា: កាលពីដើម តែកាលណាក្អែងលេងបទបួងសួង គេមើលទៅក្នុងស្រះតាសែន ដែលនៅជិតជើងភ្នំបាណន់នោះ ឃើញក្រពើងើបជាច្រើន ។ ស្រះនោះពីដើមជ្រៅ ប៉ុន្តែឥឡូវនេះរាក់ទេ ហើយនៅពេលបួងសួងគេក៏មិនឃើញក្រពើងើបទៀតឡើយ ។

ពិធីនោះជួនកាលអ្នកកជការធ្វើ ជួនកាលអ្នកស្រុកនាំគ្នាធ្វើ ។

# ជាតិ · សាសនា · ព្រះមហាក្សត្រ

## ព្រះកុណាសម្ប័ទនៃសម្តេចព្រះមហាសុមេធាធិបតី
## សង្ឃនាយកគណៈមហានិកាយ

---

ដូចយើងបានជំរាបអស់លោក - អ្នកស្រាប់ហើយនៅក្នុងទស្សនាវដ្តីយើងលេខ ១៥ ថា: កាលពីក្នុងអឌ្ឍមាសទី ១ នៃខែឧសភា សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ បាននិមន្តចេញដំណើរទៅកាន់ក្រុងប៉ារីស ដើម្បីព្យាបាលព្រះរោគព្រះនេត្រ ក្រោមព្រះបរមរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋព្រមទាំងព្រះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ហូតដល់អឌ្ឍមាសទី ២ នៃខែកក្កដានេះ ទើបនិមន្តត្រឡប់មកវិញ ។

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ព្រះអង្គមានរោគបាំងស្បែកនៅព្រះនេត្រទាំងសងខាង ហើយលោកគ្រូពេទ្យ គីយូម៉ាត់ (គ្រូពេទ្យនៅក្រុងប៉ារីស) បានព្យាបាលដោយការវះបានជាហើយ គឺសម្តេចអាចទតឃើញបានទាំងអស់ ស្រាប់តែលេចព្រះរោគមួយផ្សេងទៀតមកយាយីព្រះអង្គ គឺគ្រុនក្តៅដែលបណ្តាលមកពីមានទឹកដក់នៅក្នុងសួត ។

ប៉ុន្តែលោកសាស្ត្រាឡឺមែរ បានខំយកចិត្តទុកដាក់ព្យាបាលយ៉ាងតឹងរ៉ឹង លុះត្រាតែសម្តេចបានប្រកបដោយសភាពសុខស្រួលបួលឡើងវិញ នៅមានតែគ្រុនក្តៅបន្តិចបន្តួច ឥឡូវសម្តេចបានឆាន់ចង្ហាន់ដឹងឱជារសដូច

ដើមឡើងវិញហើយ ។ ដូច្នេះ, សម្តេចក៏ត្រូវបាននិមន្តមកកាន់ប្រទេសកម្ពុជាវិញ តាមអាកាសយានអែរហ្វ្រង់នៅថ្ងៃ ២២ កក្កដា ១៩៦១នេះ ។

ក្នុងឆ្នាំឆ្លូវត្រីស័ក ព.ស. ២៥០៤ នេះ សម្តេចព្រះសង្ឃនាយក មានព្រះជន្មាយុ ៧៨ ឆ្នាំហើយ ។ តាំងពីបឋមវ័យរហូតមកដល់បច្ឆិមវ័យនេះ ព្រះអង្គសុទ្ធតែធ្វើប្រយោជន៍ដល់សង្គមជាតិខ្មែរ ដោយឧត្តមគតិព្រះពុទ្ធ-សាសនា មានអប់រំមហាជនឲ្យយល់ផ្លូវលោកផ្លូវធម៌ជាដើម ដែលចាត់ទុកជាវិធានការមួយ ជួយសម្រាលអម្រែកព្រះរាជរដ្ឋាភិបាល ក្នុងការតម្រង់ផ្លូវបណ្តាពុទ្ធ ឲ្យស្គាល់នូវឧត្តមប្រយោជន៍ប្រទេសជាតិ ។ គ្រប់កាលៈទេសៈសម្តេចព្រះសង្ឃនាយក តែងមានព្រះហឫទ័យញុំាងសង្គមមនុស្សឲ្យតាំងនៅក្នុងទីត្រជាក់ត្រជុំ, ឲ្យស្គាល់នូវតម្លៃនៃត្រៃសរ-ណាគមន៍ គឺជាតិ-សាសនានិងព្រះមហាក្សត្រ ដែលជាគោលចារិករបស់ប្រទេស ។ ឯចំណែកការគ្រប់គ្រងសង្ឃក្នុងព្រះរាជអាណាចក្រ ក៏មានរបៀបរៀបរយសមរម្យជាសមណៈ គ្មានចលនាអ្វីនាំឲ្យព្រះរាជបល្ល័ង្កជាអគ្គពុទ្ធសាសនូបត្ថម្ភនិងព្រះរាជរដ្ឋាភិបាលព្រួយបារម្ភឡើយ ។

ព្រះគុណសម្បត្តិមួយទៀត, សម្តេចព្រះសង្ឃនាយកបានតែងសៀវ-ភៅច្បាប់ក្បួនជាច្រើន ឧទាហរណ៍ដូចជា វចនានុក្រមខ្មែរ ជាដើម ដែលសព្វថ្ងៃក្លាយទៅជាគ្រូ ជាមេគន់និតក្នុងកិច្ចសិក្សាភាសាខ្មែរ ។ តាំងនេះចាត់ទុកជាសម្តេចបានបណ្តុះវិជ្ជានធម៌ ឲ្យចាក់ឫសយ៉ាងជ្រៅទៅ

លើជាតិ ជាគុណសម្បត្តិគ្មាននរណាទឹងអាចបំភ្លេចបានឡើយ ។

មាត្រាទី ៨ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា បានចែងថា "ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ" ។ ដូច្នេះហើយបានជាអង្គសម្ដេចព្រះសង្ឃនាយកជាមេពុទ្ធបរិស័ទនឹងជាបង្គោលព្រះពុទ្ធសាសនា ព្រះអង្គបានចំកាន់នឹងពង្រីកពុំដែលរបូតពីព្រះហស្ដសោះ ។

ដោយសម្ដេចបានបំពេញនូវព្រះគុណសម្បត្តិដូច្នេះហើយ បានជាព្រះអង្គបានទទួលព្រះបរមរាជូបត្ថម្ភពីសម្ដេចព្រះមហាក្សត្រិយានី ជាព្រះមាតាជាតិ នឹងពីសម្ដេចព្រះប្រមុខរដ្ឋ ព្រមទាំងពីព្រះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមសុំនិមន្តទៅព្យាបាលព្រះរោគនោះ ដើម្បីកុំឲ្យនៅញាំញីព្រះកាយសម្ដេចតទៅទៀត ។

ព្រះរាជូបត្ថម្ភមួយយ៉ាងទៀតក៏ជាក់ស្ដែងណាស់ដែរ គឺនៅថ្ងៃទី ២២ កក្កដា ឆ្នាំ ១៩៦១ នេះ ជាថ្ងៃដែលព្រះអង្គទ្រង់កំណត់ទុកជាស្រេចថានឹងធ្វើសមាជជាតិលើកទី ១១ ប៉ុន្តែដោយថ្ងៃនេះ ជាថ្ងៃព្រះនិវត្តនៃសម្ដេចព្រះសង្ឃនាយក, ក៏សម្ដេចព្រះប្រមុខរដ្ឋព្រះអង្គទ្រង់ពន្យាពេលអង្គារជាតិនេះទៅធ្វើនៅថ្ងៃបន្ទាប់វិញ, ហើយសម្ដេចព្រះប្រមុខរដ្ឋជាព្រះបិតាជាតិយើង ក៏ព្រះអង្គបានទ្រង់សព្វព្រះរាជហឫទ័យស្ដេចយាងទៅបំពេញព្រះបដិសណ្ឋារៈកិច្ច ចំពោះសម្ដេចព្រះសង្ឃនាយកផងដែរ ។

យើងសូមបញ្ជាក់ថា: នៅថ្ងៃទី ២២ កក្កដា ឆ្នាំ ១៩៦១ នោះ

តាំងពីម៉ោង ៦ ព្រឹកនៅចំណតអាកាសយានពោធិចិនតុង ពោរពេញកកស្រទាប់ដោយពុទ្ធបរិស័ទទាំងគ្រហស្ថ ទាំងបព្វជិត មន្ត្រី-រាជការ ទាហាន ស៊ីវិល បានទៅរង់ចាំទទួលធ្វើបដិសណ្ឋារកិច្ចចំពោះសម្តេចព្រះសង្ឃនាយក គណៈមហានិកាយ ។

ចំណែកខាងព្រះសង្ឃ យើងសង្កេតឃើញជាអាទិ៍ គឺមន្ត្រីសង្ឃគណៈមហានិកាយដែលជារាជាគណៈ ឋានានុក្រម សមុហ៍ បាឡាត់ ចៅអធិការ សមណនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មេគណ អនុគណនៃខេត្តនានា ព្រមទាំងអន្តេវាសិកទាំងឡាយមានចំនួនជាច្រើនពាន់អង្គ ។

ចំណែកខាងគ្រហស្ថគឺៈ សមាជិកនៃសភាទាំងពីរ សមាជិករាជរដ្ឋាភិបាល នឹងមន្ត្រីអគ្គរាជការ ទាហាន ស៊ីវិល ព្រមទាំងប្រជាពលរដ្ឋគ្រប់ឋានៈ មានចំនួនជាច្រើនពាន់នាក់ ។

បដិសណ្ឋារកិច្ចនេះបានរៀបចំឡើងជាផ្លូវការ ដោយមានរបៀបរៀបរយជាទីបំផុត ។

នៅម៉ោង ៨ គត់ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់បានស្តេចយាងតាមឧទ្ធមាគចក្រពីក្រុងព្រះសីហនុ ដល់ចំណតអាកាសយានពោធិចិនតុង ដើម្បីរង់ចាំទទួលសម្តេចព្រះមហាសុមេធាធិបតី ដោយព្រះប្រិយូបត្ថម្ភដ៏ខ្ពង់ខ្ពស់ ។ ខណៈនោះ ព្រះអង្គទ្រង់បានថ្វាយបង្គំព្រះសង្ឃហើយទ្រង់

ទទួលនូវការក្រាបថ្វាយបង្គំអំពីសំណាក់អគ្គទូត និងឥស្សរជន ព្រមទាំងប្រជាពលរដ្ឋជាកូនចៅព្រះអង្គក្នុងបរិយាកាសដ៏សែនរីករាយជាទីបំផុត ។

ម៉ោង ៨,៥០ នាទី អាកាសយានដែលនាំដំណើរសម្ដេចព្រះមហាសុមេធាធិបតី បានមកដល់ ពុទ្ធបរិស័ទទាំងឡាយបានលើកដៃថ្វាយបង្គំសម្ដេចគ្រប់ៗ គ្នា ។ ឱកាសនោះសម្ដេចសង្ឃនាយកបាននិមន្តចុះអំពីអាកាសយានដោយមានព្រះពោធិវង្ស និងព្រះគ្រូសំសុត្តា ព្រមទាំងលោកវេជ្ជបណ្ឌិតផៅ-ហូ បាននិមន្ត បានអញ្ជើញមកជាមួយផង ។

ដោយសម្ដេចព្រះមហាសុមេធាធិបតី ព្រះអង្គពុំអាចគង់លើរថយន្តទៀតដែលទៅទទួលនៅជណ្ដើរអាកាសយានបាន ទើបសម្ដេចព្រះប្រមុខរដ្ឋ ទ្រង់បានក្រាបព្រះអង្គដោយផ្ទាល់ព្រះហស្ត ចូលមកកាន់ព្រះពន្លាពិសេស ។

ក្រោយនោះ សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់បានថ្វាយបង្គំសាកសួរអំពីព្រះសុខភាព និងទ្រង់ព្រះសណ្ដាប់ព្រះសង្ឃថានិវត្តិនៃសម្ដេចព្រះមហាសុមេធាធិបតី ដែលព្រះអង្គមានព្រះពុទ្ធដីកាស្វាគមន៍ ចំពោះពុទ្ធបរិស័ទទាំងឡាយ ដែលបាននិមន្ត បានអញ្ជើញទទួលព្រះអង្គ ហើយដែលបានធ្វើបុណ្យផ្សេងៗ ឧទ្ទិសកុសល ទៅប្រគេនព្រះអង្គ ដោយសេចក្ដីជ្រះថ្លានិងកតញ្ញូតាដ៏ជ្រាលជ្រៅ ។

ជាទីបញ្ចប់ សម្ដេចព្រះមហាសុមេធាធិបតី ព្រះអង្គមានព្រះពុទ្ធ-

ដីកាថ្លែងអំណរព្រះមហាករុណាទិគុណ ចំពោះសម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត ដែលទ្រង់បានឧបត្ថម្ភដល់ការព្យាបាលព្រះពេតនេះ នឹងចំពោះសម្ដេចព្រះប្រមុខរដ្ឋ ដែលព្រះអង្គទ្រង់បានយកព្រះរាជហឫទ័យទុកដាក់ជួយឧបត្ថម្ភដោយព្រះរាជមេត្រាបាយគ្រប់ប្រការ ។

លំដាប់តមក សម្ដេចព្រះមហាសុមេធាធិបតី បានប្រគេនភារៈការថ្លែងនេះដល់ព្រះពោធិវង្សឲ្យថ្លែងជំនួស ព្រោះព្រះអង្គមានព្រះកាយពលទន់ខ្សោយ ដោយមានអាការពេតថ្មីចូលមកទៀតទៀន ។ ព្រះពោធិវង្សក៏បានមានព្រះពុទ្ធដីកា រៀបរាប់អំពីអាការពេតចាស់-ថ្មី ដោយសព្វគ្រប់ ហើយបានថ្វាយព្រះរាជកុសលចំពោះសម្ដេចព្រះមហាក្សត្រិយានី ចំពោះសម្ដេចព្រះប្រមុខរដ្ឋ ចំពោះព្រះវិញ្ញាណក្ខន្ធជាទីរលឹក នៃព្រះមហាកាព្វនគោដ្ឋ ព្រមទាំងចំពោះពុទ្ធបរិស័ទទាំងឡាយ ។

ពេលនោះសម្ដេចព្រះប្រមុខរដ្ឋ ព្រះអង្គថ្វាយបង្គំលាព្រះសង្ឃ បានទ្រង់ព្រះនិវត្តមកកាន់ព្រះរាជតំណាក់វិញ ដោយទ្រង់មានព្រះរាជធុរៈជាការចាំបាច់ ។

ចំណែកសម្ដេចព្រះមហាសុមេធាធិបតី ព្រមដោយសង្ឃគ្រប់ព្រះអង្គក៏បាននិមន្តហកអាកាសយានដ្ឋាន តាមរថយន្តត្រះមកកាន់វត្តឧណ្ណាលោមដោយសុវត្ថិភាព ។

៨

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៣ លេខ ៨ ខែសីហា

ព.ស. ២៥០៤ គ.ស. ១៩៦១

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ៣៣ លេខ ៨ ខែសីហា

ព.ស. ២៥០៤ គ.ស. ១៩៦១

ភ្នំពេញ

# គណៈប្រតិភូខ្មែរ
# ខាងពុទ្ធសាសនាដែលទៅប្រជុំនៅប្រទេសជប៉ុន
# បានអញ្ជើញត្រឡប់មកវិញហើយ

---

នៅពេលរសៀល ថ្ងៃទី ១៣ សីហា ១៩៦១ នេះ នៅចំណតអាកាសយានពោធិចិនតុង មានការរង់ចាំទទួលគណៈប្រតិភូខ្មែរ ដែលមានសហជីវិន ស៊ិន-បុប្ផគោ រដ្ឋលេខាធិការក្រសួងធម្មការជាប្រធាន សហជីវិន ប៉ាយ-ល្មុត និងសហជីវិន គួច-គីឡេង ជាសមាជិក ដែលត្រូវអញ្ជើញត្រឡប់មកពីប្រទេសជប៉ុន ។

ក្នុងចំណោមអស់លោកដែលទៅរង់ចាំទទួល យើងសង្កេតឃើញជាអាទិ៍គឺលោក ច័ន្ទ-សុខ នាយកការិយាល័យ, លោកលឹម-ឆ្លួនសេង នាយខុទ្ទកាល័យក្រសួងធម្មការ, លោក តែ-ម៉េងហាប់ អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ លោក យៀង-ឆឹម អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងបុគ្គលិកក្រសួងធម្មការ និងក្រុមគ្រួសារជាច្រើនទៀត ។

នៅវេលាម៉ោង ៣ រសៀល អាកាសយានប្រតិកម្មបានដឹកនាំដំណើរគណៈប្រតិភូមកដល់ចំណតអាកាសយានពោធិចិនតុង ។

តាមពត៌មាន ដែលគណៈប្រតិភូបានឲ្យការណ៍ថា ដំណើរដែលទៅកាន់ប្រទេសជប៉ុននេះ ដើម្បីទៅរួមប្រជុំខាងផ្នែកអ្នកកាន់សាសនាទូទៅ

ឆ្លងទៅក្របម្ខាង . . .

P.K _ 1
1961_ 8

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា    បញ្ជីរឿង    ទំព័រ

- វិបារណកថា អំពីគោលសំខាន់នៃព្រះពុទ្ធសាសនា (ត) លោក ផល-ទិត្យ រៀបរៀង ៨៣៧
- ពុទ្ធចរិតៈ ថ្លែងអំពីព្រះជីវប្រវត្តិ នៃព្រះគោតម (តចប់) លោក គួច-គីឡេង ប្រែ . ៨៤៦
- លោកុត្តរាភិសម័យ (ត) អ្នកឧកញ៉ា ព.សាន អតីតរដ្ឋមន្ត្រី រៀបរៀង . . ៨៥១
- ព្រះអភិធម្មបិដក គម្ពីរព្រះយមក (ត) លោក ប៊ូ-ប៉ូ រៀបរៀង . . . ៨៦២
- មធុរសវាហិនី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះ ញ.ឈឹង ពិនិត្យ . . ៨៧៣
- មហោសថជាតក(ត)លោកអ៊ុម-ភានចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្សកឹម-ទួរពិនិត្យ. ៨៧៩

ផ្នែកអក្សរសាស្ត្រ

- វប្បធម៌ខ្មែរ (ត) លោក លី-ធាមតេង រៀបរៀង . . . ៨៩២
- ពាក្យខ្មែរប្រែពីបរទេស (ត) ដោយគណៈកម្មការវប្បធម៌ . . . . . ៨៩៧
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ជាំង-ខាត់ រៀបរៀង . . . ៨៩៨
- រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែ . . . . ៨៩៩
- រឿងមនុស្សចិត្តប្រែប្រួល (តចប់) លោក ប៊ូ-ប៉ូ រៀបរៀង . . ៩១០
- រឿងព្រេងបិន លោកវ៉ៃ-ទិក រៀបរៀង . . . . . . . . . . ៩២១
- ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសជប៉ុន(ត)លោកហ្សូហ្សមបែរតំ រៀបរៀង លោកញ៉ែមទឹមប្រែ ៩២៤
- អនាគតសមាជទី ៦ នៃពុទ្ធិកសមាគមពិភពលោក សហាជីវិន សួរ ណៃរ រៀបរៀង ៩៣១
- វុឌ្ឍជាតិល្អនឹងអំពៅ ដោយភិក្ខុ ចាប់-គឹល ប្រឡងជាប់លេខ ២ ខាងទំនៀមទម្លាប់ ៩៤៣

ផ្នែកកំណត់និងប្រវត្តិការណ៍

- សេចក្ដីរាយការណ៍សង្ខេបអំពីសន្និសីទនៅប្រទេសជប៉ុន លោកញ៉ែម-ទឹម ប្រែ . ៩៤៩

មួយឆ្នាំ មាន ១២ សៀវភៅ ជាថ្លៃជាវ ២៣០ រ០០

33e Année — No 8 — Août 1961

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## Sommaire

### Partie religieuse

Page

— Editorial " Les principes du Bouddhisme " ( suite ) par *M. PHAL-TITH* . . . 837
— Buddha carita (suite et fin) traduit par *M. KUOCH-KY LENG* 846
— Lokkuttara Bhisamaya par l'Okhna *TEA-SAN* . . . . . 851
— Prah Abhidhamma pitaka (Kampi Prah Yámaka) (suite) par *M. BOU-PO* . . . . . 862
— Madhurasavahini (suite) traduit par Samdech Prah Dhammalikhita *LOUIS-EM*, revu et corrigé par Vèn. *NHÉAN-CHHOEUN* . . . . 873
— Mahosatha Jataka (suite) relevé du manuscrit sur feuilles de latanier par *M. IM-PHON*, revu et corrigé par Vèn. *KEM-TO* . . . . 879

### Partie littéraire

— La Culture Khmère (suite) par *M. LY-THEAM-TENG* . . 892
— Activités de la Commission Culturelle (suite) . . . . . . . . . . 897
— Dictionnaire Sanscrit-Khmèr (suite) par Vèn. *PANG-KHAT* . . 898
— Histoire de Sam-Kok (suite) traduite par l'Oknha *NOU-KAN* . . . . . . 899
— L'homme au coeur changeant (suite et fin) par *M. BOU-PO* . . 910
— Légendes populaires de la Chine par *M. RAY-BUC* . . . . 920
— Géographie économique du Japon (suite) par *M. ROSEMBERT* traduite par *M. NHEM-KHEM* . 924
— Le 6 ème Congrès de l'Association Mondiale des Bouddhistes par *M. SO-NEM* . . . 931
— Le Papayier et la canne à sucre par le bonze *THAC-NGEL* (texte primé par la Commission des Mœurs et Coutumes) . . . 943

### Notes et chroniques

— Rapport succinct de la Conférence religieuse au Japon . . 949

Prix d'abonnement annuel (comprenant 12 numéros): 23o/oo

ផ្នែកសាសនា

វិចារណកថា

# អំពីគោលសំខាន់នៃពុទ្ធសាសនា

លោក ផល-ទិត្យ នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ព្រះមុនីកោសល សួរ-ហាយ ពិនិត្យ

(តមក)

---

ហេតុទៀត គឺហាត់ពត់តាមវិធីចិត្តសាស្ត្រ ដើម្បីលះហេតុនូវកម្មល្អនោះ ឲ្យអស់ពីសន្តានទៅទៀត ។ លុះលះហេតុបានទាំងកម្មល្អ ទាំងកម្មអាក្រក់ (បុញ្ញ បាប ឬបាបៈ) យ៉ាងនេះហើយ លោកក៏បាននាមថ្មីឡើងថា អរិយបុគ្គលទីណាក្រុមព ៗ សូមបញ្ជាក់ថា អ្នកដែលលះ កម្មល្អ និង កម្មអាក្រក់បាននេះ មិនមែនអស់ការកំរើកខ្លួន (កាយវិញ្ញត្តិ) កំរើកវាចា (វចីវិញ្ញត្តិ) កំរើកចិត្ត (មនោវិញ្ញត្តិ) ទេ ទាំងការកំរើក (វិញ្ញត្តិ) របស់លោកនោះ ក៏មានវិញ្ញាណ (មនោ-ចិត្ត) នៅបង្គាប់បញ្ជាដែរ, ប៉ុន្តែ បានជាលោកមិនមាន កម្ម ទៅវិញនោះ ព្រោះ វិញ្ញាណ (មនោ-ចិត្ត) របស់លោកជាធម្មជាតបរិសុទ្ធលែងត្រូវការជាប់ប្រឡាក់ដោយ កម្មល្អ និង អាក្រក់ ទៀតហើយ, ប្រៀបដូចជាស្លឹកឈូក ដែលមិនជាប់ប្រឡាក់តំណក់ទឹក ឬដូចគ្រាប់ស្ពៃមិនជាប់លើចុងដែកយ៉ាងស្រួចបាន ដូច្នោះ ៗ ការប្រតិបត្តិហ្វឹកហ្វឺន

ចិត្តឲ្យលែងប្រឡាក់ដោយ កម្ម ល្អនិង កម្ម អាក្រក់ ដែលខ្ញុំពណ៌-នាមកនេះ គ្រាន់តែជាការរាប់តាមដំហានទេ ឯការប្រឹងឈានវិញ មិនមែនស្រួលដូចនិយាយឡើយ ត្រូវចាយពេល អស់ការនឿយហត់ច្រើនហើយលំបាកក្រៃលែងលំបាកផង ៗ ក្នុងទីនេះ ខ្ញុំមិនបានរៀបរាប់តាមកម្មវិធីហ្វឹកហាត់ចិត្តឲ្យគ្រប់សព្វទេ ខ្ញុំសូមពណ៌នាចំពោះតែចិត្តដែលថាពមិនជាប់ប្រឡាក់ដោយ កម្ម ប៉ុណ្ណោះ ដើម្បីបញ្ជាក់ឲ្យឃើញថា ចិត្តដូចម្តេច ដែលមិនជាប់ប្រឡាក់ដោយ កម្ម ល្អនិង កម្ម អាក្រក់?

ពួកបុថុជ្ជន គឺមនុស្សធម្មតាទូទៅដូចជាយើងគ្រប់គ្នានេះ កាលនឹងធ្វើអ្វីមួយ តែងតែធ្វើដោយចិត្ត ២ យ៉ាងគឺ:

១– ដោយចិត្តល្អ (ចិត្តបុណ្យ- កុសលចិត្ត) ដែលជាឈ្មោះនៃកម្មល្អ,

២– ដោយចិត្តអាក្រក់ (ចិត្តបាប- អកុសលចិត្ត) ដែលជាឈ្មោះនៃកម្មអាក្រក់ ៗ ឯអរិយបុគ្គលជាខីណាស្រពវិញ លោកធ្វើដោយចិត្តតែមួយប៉ុណ្ណោះគឺ កិរិយាចិត្ត ៗ ចិត្តល្អ ជាហេតុឲ្យកើតការកំរើកល្អ, ការកំរើកល្អ ជាហេតុឲ្យកើតកម្មល្អ, កម្មល្អជាហេតុឲ្យកើតផលល្អ ៗ ចិត្តអាក្រក់ ជាហេតុឲ្យកើតការកំរើកអាក្រក់, ការកំរើកអាក្រក់ជាហេតុឲ្យកើតកម្មអាក្រក់, កម្មអាក្រក់ជាហេតុឲ្យកើតផលអាក្រក់ ៗ ឯ កិរិយា-ចិត្ត វិញ ក៏ជាហេតុឲ្យកើតការកំរើកគ្រាន់តែជា កិរិយា គឺគ្រាន់តែ

ធ្វើធ្វើទៅប៉ុណ្ណោះ ហើយវាមិនអាចឲ្យកើតទៅជាកម្មឡើយ កាលបើវាមិនកើតទៅជា កម្ម ហើយ, ផល គ្រប់បែបក៏គ្មានដែរ ។

ចុះហេតុអ្វី បានជាការកំរើកដែលប្រកបដោយ កិរិយាចិត្ត មិនអាចឲ្យកើតទៅជា កម្ម ?

បានជាមិនអាចឲ្យកើតទៅជា កម្ម ព្រោះថា កិរិយាចិត្ត នេះ វាជាចិត្តអស់សេចក្តីត្រូវការ ដោយល្អនឹងអាក្រក់ទៅហើយ គឺបើវាបង្គាប់បញ្ជាឲ្យធ្វើអ្វីៗ ក៏គ្រាន់តែឲ្យធ្វើធ្វើទៅ ដើម្បីឲ្យត្រូវតាមសភាពពិតពលោក ប៉ុណ្ណោះ ឥតមានចង់បាន ផល ដែលចេញពីការធ្វើរបស់ខ្លួនឡើយ ។

មែនពិត, ចិត្តរបស់មនុស្សបុថុជ្ជនយើងនេះ កាលណាវាបង្គាប់បញ្ជាកាយ - វាចា ឲ្យធ្វើអ្វី វាសុទ្ធតែចង់បាន ផល ពីការធ្វើនោះទាំងអស់ បើទុកជាមិនចង់បាននេះ ក៏ចង់បាននោះ ជាការពិតប្រាកដណាស់ ។ យើងមិនបាច់និយាយទៅផ្នែកខាងចិត្តអាក្រក់ទេ ព្រោះចិត្តអាក្រក់ សុទ្ធតែមានប្រាថ្នាទើបធ្វើអាក្រក់បាន ដូចជាវាលួចគេក៏ព្រោះតែចង់បានទ្រព្យ វាបៀតបៀនគេ ក៏ព្រោះតែចង់បានជ័យជំនះលើគេជាដើម ។ ឯផ្នែកខាងចិត្តល្អវិញក៏ដូចគ្នា គឺសុទ្ធតែឃើញប្រយោជន៍អ្វីមួយហើយទើបចុះធ្វើ មិនមែនធ្វើដោយឥតប្រាថ្នាទេ ។ អ្នកខ្លះនិយាយថា "ខ្ញុំខំប្រឹងធ្វើល្អដល់គេនេះ ខ្ញុំឥតចង់បានអ្វីទេ" យ៉ាងនេះ តើពិតជាមិនចង់បានមែនឬ ? ពិតជាមិនមែនទាល់តែសោះ ព្រោះថា បើមិនចង់បានទ្រព្យសម្បត្តិពីគេ

ក៏គង់បង់បានទ្រព្យសម្បត្តិ ពីអ្នកដទៃទៀតដែរ ឬបើមិនបង់បានទ្រព្យសម្បត្តិពីអ្នកដទៃទៀតទេ ក៏គង់បង់បានសម្បត្តិឯឋានសួគ៌ឋានព្រហ្មដែរ ឬក៏បើទុកជាមិនបង់បានសម្បត្តិឯឋានសួគ៌ស្ថានព្រហ្មទេ ក៏គង់បង់បានកិត្តិយសមានការទទួលស្គាល់ — ការកោតសរសើរ — សេចក្តីស្រឡាញ់ សេចក្តីពេញចិត្តពីអ្នកផងទាំងពួងដែរ, ដែលថាមិនបង់បាននោះ ជាការមិនពិតតាលតែសោះ ៗ

ចំណែកអរិយបុគ្គលជាខីណាស្រវវិញ ទោះលោកគ្មាត់ធ្វើអាក្រក់ដោយឥតចេតនាក៏លោកគ្មានប្រាថ្នា ឬទោះលោកធ្វើល្អ ក៏គ្មានប្រាថ្នាដែរ គឺលោកលែងត្រូវការអ្វីទាំងអស់ក្នុងពិភពលោកនេះទៅហើយ ប្រៀបដូចទឹកដែលពេញពាង, បើទុកជាគេយកទឹកឯទៀតទៅចាក់បន្ថែមក្នុងពាងនោះក៏គ្មានប្រយោជន៍ដែរ ព្រោះទឹក ក៏មិនអាចដក់នៅខ្ពស់ជាងមាត់ពាងទៅទៀតបានទេ គឺបានសេចក្តីថា ព្រះខីណាស្រពលោកធ្វើការកំ-រើក ក៏ធ្វើគ្រាន់តែជាកាយវិការ តាមសភាពធម្មតារបស់លោកប៉ុណ្ណោះ ៗ ដូចជាការបរិភោគ ប្រើប្រាស់បច្ច័យ, ក្នុងគម្ពីរលោកប្រៀបទុកថា ដូចជាស្ត្រីជាមាតានៃទារកម្នាក់ បានពកូនតូចជាទីស្រឡាញ់ស្មើដោយជីវិតនោះដើរកៀសខ្លួនកាត់ផ្លូវកន្តារ (ដាច់ស្រយាល) លុះអស់ស្បៀងរកអ្វីស៊ីមិនបានក៏ស៊ីសាច់កូនដែលស្លាប់នៅក្នុងដៃ ហើយប្រឹងធ្វើដំណើរតទៅទៀត ៗ គេអាចសួរថា ស្ត្រីនោះមានចំណង់បង់ស៊ីដុំសាច់កូនខ្លួន

ឬទេ ? តាមពិតគ្មានបិត្តម្តាយណាចង់ហែកស៊ីកូនតូចដែលជាទីស្រឡាញ់ របស់ខ្លួនយ៉ាងនេះទេ ប៉ុន្តែ ក្នុងកាលៈទេសៈដែលក្តាយប្រឹងលេបផុំសាច់ កូនស្ងួនជាទីស្រឡាញ់ដូច្នេះ ចិត្តគាត់គ្មានចង់ទាល់តែសោះ គាត់ប្រឹង លេបទាំងទឹកភ្នែក ដើម្បីដោះស្រាយបញ្ហាជីវិត ឲ្យបិតបេរទឹងធ្វើដំណើរ ឲ្យដល់ត្រើយនៃគោលដៅតែប៉ុណ្ណោះ យ៉ាងណាមិញ, ចិត្តព្រះខីណាស្រព ដែលបរិភោគប្រើប្រាស់ចតុប្បច្ច័យនោះ ក៏គ្រាន់តែដោះស្រាយបញ្ហាជីវិត ឲ្យតាំងនៅតាមសភាពធម្មតារបស់លោកប៉ុណ្ណោះ ឥតមានចិត្តជាប់ចំពាក់ ដោយចំណង់ណាមួយ ក៏យ៉ាងនោះដែរ ។ មួយទៀត ដូចអ្នករទេះយក ខ្លាញ់ទៅលាបភ្លៅរទេះ, ភ្លៅរទេះ គ្មានចិត្តចង់បានខ្លាញ់មកលាបទេ ប៉ុន្តែបើម្ចាស់រទេះមិនលាបវា ក៏វាមិនអាចវិលទៅបានស្រួលឡើយ យ៉ាង ណាមិញ, ព្រះខីណាស្រព បរិភោគប្រើប្រាស់ចតុប្បច្ច័យគ្រាន់តែញ៉ាំង ដំណើរជីវិតភាពឲ្យប្រព្រឹត្តទៅដោយស្រួលតែប៉ុណ្ណោះ ដោយឥតមានចិត្ត ជាប់ចំពាក់ក្នុងបំណងបន្តិចបន្តួចសោះ ក៏យ៉ាងនោះដែរ ។ ម្យ៉ាងទៀត សោតប្រៀបដូចបុរសលង់ទឹកដែលជិតតែនឹងផុតសង្ឃឹមទៅហើយ ស្រាប់ តែឃើញសាកសពមួយហើមស្តឹងអណ្តែតមកក្បែរ ក៏ប្រវាតោងបណ្តែត ខ្លួនបានរំដោះពីការលង់ទឹករហូតដល់ត្រើយជាសុខស្រួល ។ តើបុរស នោះ ចង់តោងខ្មោចណាស់ទៅឬ ? គ្មានទេ ! គ្មានចង់ទាល់តែសោះ! ប៉ុន្តែគ្រោះថ្នាក់មកដល់ហើយ សុខចិត្តប្រវាតោងខ្មោចទាំងឥតចង់សោះ

ឲ្យរួចតែជីវិតប៉ុណ្ណោះ យ៉ាងណាមិញ ព្រះខីណាស្រពបរិភោគប្រើប្រាស់បច្ច័យគ្រាន់តែរំដោះជីវិតតាមសភាពលោកិយតែប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។

ចុះបើលោកគ្មានចិត្តជាប់ចំពាក់ដោយសេចក្តីប្រាថ្នា ដែលជាចិត្តឧត្តុង្គឧត្តមពិសេសជាងចិត្តមនុស្សធម្មតា យ៉ាងនេះហើយ តើ កម្មល្អ និង កម្មអាក្រក់ អាចចូលមកធ្វើអន្តរាគមន៍ក្នុងសន្តានចិត្តលោក ដូចម្តេចបាន ?

តាមធម្មតា កម្មល្អ កាលណា ជ្រៀតជ្រែកទៅនៅជាមួយនឹងជនណា រមែងនាំជននោះឲ្យបានសេចក្តីសុខក្សេមក្សាន្ត ដូចជាថ្នាំកែរោគដូច្នោះ ។ ចុះបើមនុស្សគ្មានជម្ងឺឈឺថ្កាត់អ្វីបន្តិចបន្តួចសោះ តើថ្នាំមានប្រយោជន៍អ្វីសម្រាប់មនុស្សនោះ ហើយមនុស្សនោះ គ្មានជម្ងឺអ្វីបន្តិចសោះ តាំងដឹងថាថ្នាំក៏គ្មានប្រយោជន៍សម្រាប់ខ្លួនទេ តើចង់បានថ្នាំនោះមកធ្វើអ្វី ? មួយទៀត បើទុកជាមានកាលៈទេសៈខ្លះ ដែលបត្រូវតែលេបទានមិនបាន ក៏ថ្នាំនោះគ្មានបានជាប្រយោជន៍អ្វីដល់អ្នកមិនឈឺនោះដែរ យ៉ាងណាមិញ, ព្រះខីណាស្រពក៏យ៉ាងនោះដែរ គឺលោកជាអ្នកឥតជម្ងឺ លោកជាជម្ងឺដាច់ស្រឡះទៅហើយ លោកបានសេចក្តីសុខក្សេមក្សាន្តយ៉ាងបរិបូណ៌ហើយ បានជាលោកគ្មានសេចក្តីប្រាថ្នាចង់បាន កម្មល្អ ដែលទុកដូចជាថ្នាំកែរោគនោះ ហើយបើទុកជាកាលៈ

ទោសៈខ្លះដែលលោកធ្វើពារទៅលើ កម្មល្អ, ក៏ កម្មល្អ នោះគ្មាន ផលប្រយោជន៍អ្វីដល់លោកដែរ ព្រោះលោកមានសេចក្តីសុខក្សេមក្សាន្ត ដូចជាពាងពេញទ្រៀបដោយទឹកទៅហើយ ។

៦ កម្មអាក្រក់ វិញ ក៏ដូចគ្នា គឺកាលណាវាចូលទៅជ្រៀតជ្រែកក្នុងមនុស្សណា តែងតែធ្វើមនុស្សនោះឲ្យនឹងទុក្ខក្តៅផ្សា ដូចជាថ្នាំពិសដែលប្រឡាក់ដៃមានដំបៅ ឬមានមុខរបួសដូច្នោះ ។ ចុះបើបាតដៃ គ្មានមុខរបួស ឬដំបៅទេ តើថ្នាំពិសអាចពេលពលបង្កើតសេចក្តីទុក្ខឈឺចាប់បានឬទេ? មិនអាចឲ្យឈឺចាប់បានទេ ព្រោះវាមិនអាចជ្រាបចូលស្បែកបាតដៃបាន យ៉ាងណាមិញ, ព្រះខីណាស្រពលោកទុកដូចជាបុគ្គលមានដៃឥតមុខរបួស ឬដំបៅទៅហើយ, កម្មអាក្រក់ដែលដូចជាថ្នាំពិស មិនអាចធ្វើឲ្យលោកទទួលផលក្តៅផ្សាបាន ក៏យ៉ាងនោះដែរ ។ សេចក្តីនេះ សមនឹងព្រះពុទ្ធដីកាក្នុងខុទ្ទកនិកាយថា

បាណម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ
នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។

ប្រសិនបាតដៃ ឥតមានដំបៅ កាន់ថ្នាំពិសទៅ ដោយបាតដៃបាន
ថ្នាំពិសមិនពេល ដៃដំបៅគ្មាន ដូចបាបមិនមាន ដល់អ្នកមិនធ្វើ ។

(ខែ) បុគ្គលកាលប្រាថ្នាដឹកនាំ លូកដៃកាន់ថ្នាំពិសក្តៅផ្សា
ប្រសិនបាតដៃបែកប្រេះនា មានជារបួសឬដំបៅ ។

ថ្នាំពិសទឹងពេលយ៉ាងធុតឆាប់ ឲ្យដៃចុកចាប់ឈឺផ្សាក្ដៅ
ព្រោះវាអាចជ្រួតជ្រាបចូលទៅ ធ្វើសាច់ឲ្យក្ដៅផ្សាមិនខាន ។
តែបើបាតដៃល្អបរិសុទ្ធ ដំបៅដាច់មុតអ្វីក៏គ្មាន
ទោះកាន់ថ្នាំពិសទាំងប៉ុន្មាន គេអាចកាន់បានឥតព្រួយភ័យ ។
ព្រោះថាថ្នាំពិសប៉ុសកែវពុល វាមិនអាចរុលចូលស្បែកដៃ
ដែលគ្មានដំបៅជាទោសពៃរ៍ រឿងនេះឧបមេយ្យបានយ៉ាងណា ។
រីឯបុគ្គលមានចិត្តខ្ពស់ កា[illegible]លស្រេចអស់ក្ដីប្រាថ្នា
ទោះនឹងធ្វើកិច្ចការមេត្តា ហៅថាធ្វើកម្មក៏មិនបាន ។
បើគ្មានកម្មហើយក្ដីអាក្រក់ ក៏មិនអាចដក់គង់សន្ដាន
ព្រោះលោកឥតកម្ម[illegible]ចូលប្រាណ រឿងនេះប្រៀបបានដូច្នោះដែរ ។

ពណ៌នាប៉ុណ្ណោះនេះ រួមសេចក្ដីមក អាចបញ្ជាក់បានថា ពិតមែនតែការកំរើក ដែលមានចិត្ត (វិញ្ញាណ មនោ) នៅបង្គាប់បញ្ជា ប៉ុន្តែការកំរើកដែលប្រកបដោយចិត្ត (វិញ្ញាណ-មនោ) ជាកិរិយា (កិរិយាចិត្ត) មិនអាចឲ្យកើតទៅជាកម្មបានទេ ។ ឯការកំរើកដែលជាដំណើរឲ្យកើតទៅជាកម្មនោះ បានចំពោះតែការកំរើកប្រកបដោយចិត្តល្អ (កុសល-ចិត្ត) និងចិត្តអាក្រក់ (អកុសលចិត្ត) តែប៉ុណ្ណោះ ។ ដូច្នេះការកំរើករបស់មនុស្សដែលមានចិត្ត (វិញ្ញាណ-មនោ) នៅបង្គាប់បញ្ជានោះ គួរចែកជា ២ យ៉ាងទៀតគឺ

១ ការកើតរបស់មនុស្ស ដែលប្រកបដោយ កិរិយាចិត្ត នៅបង្គាប់បញ្ញា បានដល់ការកើតរបស់ពួកព្រះអរហន្តខីណាស្រព ,

២– ការកើតរបស់មនុស្ស ដែលប្រកបដោយ កុសលចិត្ត នឹង អកុសលចិត្ត នៅបង្គាប់បញ្ញា បានដល់ការកើតរបស់ពួកមនុស្សបុថុជ្ជនសាមញ្ញ ដូចជាពួកយើងសព្វថ្ងៃនេះ ។

បណ្ដាការកើតទាំងពីរបែបនេះ ការកើតទី ១ មិនអាចជាដំណើរឲ្យកើតទៅជា កម្ម បានទេ ព្រោះថា ចិត្ត ពិសេស ដែលគេបានអប់រំដល់ទីបំផុត លែងឲ្យទាក់ទងនឹងកម្ម បានហើយ ។ ឯការកើតទី ២ វិញ ទើបជាការកើតឲ្យកើតទៅជា កម្ម បាន, ហើយ កម្មនេះឯង ជាបញ្ហាដែលត្រូវដោះស្រាយក្នុងទីនេះ ព្រោះវាជាទីដែលអាចបណ្ដុះវិញ្ញាណ (មនោ-ចិត្ត) ឲ្យកើតទៅក្នុងភពថ្មីទៀត ។

(នៅមានត)

# ថ្លែងពីព្រះជីវប្រវត្តិនៃព្រះគោតម

លោក គួច-គីឡេង ប្រែរៀបរៀង

(តនិងចប់)

---

គាថាទី ៦:- ព្រឹកឡើងព្រះសិទ្ធត្ថកុមារយាងទៅដល់អាស្រមរបស់តាបសម្នាក់ ហើយទ្រង់ដោះគ្រឿងអលង្ការប្រគល់ទៅឲ្យឆន្នអមាត្យរួចប្រាប់ថាឲ្យត្រឡប់ទៅព្រះរាជធានីវិញចុះ ប៉ុន្តែឆន្នអមាត្យប្រកែកពុំព្រមត្រឡប់ ដោយហេតុថា ព្រះអង្គមិនស្តេចយាងទៅផ្ទះផង តែថាព្រះអង្គបង្ខិតបង្ខំឲ្យទាល់តែទៅបាន ៗ ទ្រង់ផ្ញើជាប់ជាមួយនឹងឆន្នអមាត្យទៅផ្ទះផងនូវសារលិខិតដល់ព្រះវរបិតានិងបិយមហាជនរបស់ព្រះអង្គ ៗ ព្រះអង្គទ្រង់កាត់ព្រះកេសាដោយព្រះខាន់ដ៏មុត ហើយគ្រវែងចោលទាំងដុំទៅឰដ៏អាកាស ៗ ទេវតាក៏ទទួលយកទៅដំកល់ទុកសម្រាប់ជាទីសក្ការបូជា ៗ ទេវតាស្រាប់តែតំណែងខ្លួនជាពនេចរម្នាក់យកចីវរមកថ្វាយព្រះអង្គ ៗ ក៏ទទួលហើយចូលទៅកាន់អាស្រមបទទៅ ៗ

គាថាទី ៧:- ពេលដែលចូលកាន់អាស្រមបទនោះ ព្រះសិទ្ធត្ថសមណៈ បានពត៌មានពីអ្នកនៅក្នុងទីនោះថា តាបសទាំងនោះបានប្រតិបត្តិកម្មដ្ឋាន ដើម្បីគ្រាន់តែទៅកាន់ស្ថានទេវលោក បន្ទាប់ពីលោកនេះ

ទៅប៉ុណ្ណោះ ។ ធម៌នេះពុំបានញ៉ាំងព្រះទ័យព្រះគោតមឲ្យយល់ព្រមផងទេ ព្រោះគោលបំណងរបស់ព្រះអង្គពុំមែនចង់ទៅទេវលោកទេ គឺចង់យកជ័យជំនះខាងការកើតស្លាប់ ។ ការទៅកាន់ទេវលោកព្រះសិទ្ធត្ថសមណៈគិតពុំឃើញដោយច្បាស់ថា "គ្រាន់តែជាការផ្លាស់បំណងមួយទៅបំណងមួយប៉ុណ្ណោះ" ។ ព្រះអង្គក៏ចាកចេញពីទីនោះ ហើយយាងទៅជួបនឹងតាបសម្នាក់ទៀតឈ្មោះអាឡារៈទៅ ។

គាថាទី ៨:- ប្រជាពលរដ្ឋ, ព្រះមាតាចុងព្រះអង្គ ព្រះវរបិតានឹងព្រះអគ្គមហេសី លុះឃើញតែនាយសារថីនឹងសេះអាជានេយ្យវិលត្រឡប់ទៅវិញដោយពុំឃើញព្រះអង្គសោះដូច្នេះ ក៏ទ្រហោយំទ្រហឹងឡើងទាំងអស់គ្នា ។ នាយករដ្ឋមន្ត្រីនៃព្រះបាទសិរីសុទ្ធោទនៈ នឹងឆន្នអមាត្យសុំខ្លួនដើរស្វែងរកព្រះសិទ្ធត្ថកុមារ ដើម្បីនឹងសុំយាងមកពជធានីវិញ ។

គាថាទី ៩:- រដ្ឋមន្ត្រីនឹងឆន្នអមាត្យក៏ចេញដំណើរទៅស្វែងរកអស់កន្លែងជាច្រើន បានឃើញព្រះអង្គនៅក្នុងអាស្រមបទលោកតាអាឡារៈ ។ ពជទូតទាំងនោះ បានសុំអង្វរព្រះអង្គដោយវិធីច្រើនបែបច្រើនយ៉ាង សូមព្រះអង្គត្រឡប់មកកាន់ពជធានីចាស់វិញ តែព្រះអង្គពុំទទួលសោះ ហើយពជទូតទាំងនោះក៏ត្រឡប់មកវិញ ដោយក្រៀមក្រំស្រងូតស្រងាត់ ។

គាថាទី ១០:- កាលដែលព្រះគោតម ស្តេចយាងទៅកាន់ក្រុង

រាជគ្រឹះ ព្រះចៅពិម្ពិសារបានទតតាមបន្តិចក៏ឃើញព្រះអង្គហើយស្តេចយាងដោយផ្ទាល់ព្រះអង្គ ទៅជួបនឹងព្រះរិជិតមាររនៅឯគុហាខាងក្រៅទីក្រុង ។ ព្រះចៅផែនដីទ្រង់បានសន្ទនាជាមួយនឹងព្រះចៅសាសនាអស់កាលជាយូរ ហើយទ្រង់សាកសួរទៅទៀត អំពីហេតុដែលព្រះអង្គលះបង់ព្រះរាជអាណាចក្រចោល ។

គាថាទី ១១:- ព្រះបិតានៃលោកបានឆ្លើយថ្វាយព្រះពរតបនឹងសំនួររបស់ព្រះមហាក្សត្រយ៉ាងពិស្តារ ។ ព្រះនរបតីក៏ទ្រង់និមន្តទុកឲ្យហើយថា បើព្រះអង្គបានទទួលលទ្ធផលតាមបំណងហើយសូមមេត្តាប្រោសនិមន្តទៅកាន់ទីក្រុងខ្ញុំព្រះករុណាកុំខាន ។

គាថាទី ១២ :- ព្រះគោតមបានស្តេចយាងទៅជួបនឹងអាឡារតាបសហើយពិភាក្សាជាមួយនឹងតាបសនោះយ៉ាងវែង អំពីទ្រឹស្តីដែលអាឡារតាបសនោះបង្ហាត់បង្រៀន ។ ប៉ុន្តែ ព្រះវីរសាក្យមុនីទ្រង់ពុំបានទទួលយល់ស្របតាមទេ ដោយហេតុថា ការបង្រៀនជាបែបព្រហ្មញ្ញដែលនិយាយតែពីព្រលឹង (soul) នោះពុំទាន់ប្រប្បូនទេ ។

បន្ទាប់ពីនោះទៅ ព្រះសាក្យគោតមស្តេចយាងទៅរកតាបសម្នាក់ទៀតនាមឧទក: ដែលបង្រៀនកម្មដ្ឋានព្រលឹងដូចអាឡារតាបសនោះដែរ ។ ព្រះអង្គក៏ពុំទទួលយល់តាមទៀត ហើយស្តេចយាងចេញពីទីនោះសំដៅទៅគយាសីសប្បទេស ។ ក្នុងទីនោះព្រះអង្គបានជួបបញ្ចវគ្គិយ-

ភិក្ខុនៅត្រង់មាត់ច្រាំងស្ទឹងនេរញ្ជរា ដែលកំពុងតែស្គឹងស្គាំង ឲ្យបានរួចជាកទុក្ខតូចនិងទុក្ខធំ ។ ព្រះប្រមុខជាតិសាក្យមួយអង្គើដោយភិក្ខុទាំង ៥ អង្គនោះទ្រង់អធិដ្ឋានតាំងព្រះវ័យ ធ្វើទុក្ករកិរិយាឲ្យអស់រយៈកាល៦ ឆ្នាំ ។ ប៉ុន្តែភិក្ខុទាំង៥នោះរត់ចោលព្រះអង្គ ដែលព្រះអង្គទ្រង់តាំងព្យាយាមពុំទាន់នឹងគ្រប់ឆ្នាំផង; រីឯព្រះអង្គក៏ឥតបានសម្រេចព្រះសម្ពោធិញ្ញាណ ។ ព្រះលោកនាថទ្រង់យល់ច្បាស់ថា ការតឹងរឹងហួសពេកជាហេតុនាំឲ្យខូចការ ហើយក៏បន្ធូរសាយព្រះក្រិយាតាមធម្មតាវិញ ទ្រង់ធ្វើទៅតាមការពិសោធន៍ដែលព្រះអង្គធ្លាប់បានធ្វើហើយ នៅក្រោមដើមជម្ពូព្រឹក្សកាលនៅជាយុវកុមារនៅឡើយ ។ គោលបំណងដែលព្រះអង្គទ្រង់យកជ័យលើគូសត្រូវគឺមរណភាពនោះឯង ដែលមានពលភាពស្មើរតែតទល់ពុំបាន ។ ព្រះអង្គស្តេចយាងចេញទៅបិណ្ឌបាត ។ ទេវតាក៏និមិត្តខ្លួនជានាយគោបាលចុះមកថ្វាយមធុបាយាស ដល់ព្រះអង្គរាល់ៗថ្ងៃ ។ បញ្ចសហជីវិនភិក្ខុ លុះបានឃើញព្រះអង្គទ្រង់លះបង់តបធម៌ដូច្នេះហើយ ក៏លះបង់ព្រះអង្គចោល ។ ព្រះដ៏ជាទីគោរពសរសើរ លុះទ្រង់បានទទួលសុខភាពបរិបូណ៌ដូចដើមវិញហើយ ក៏នៅតែតានតឹងពីបញ្ហាសព្វញ្ញុតញ្ញាណ ទ្រង់គង់ក្រោមដើមពោធិព្រឹក្ស អធិដ្ឋានយ៉ាងដាច់ខាតថា "បើមិនសម្រេចគោលបំណងតាមប្រាថ្នាទេ អញនឹងមិនក្រោកឡើងជាដាច់ខាត" ។

គាថាទី ១៣ :- មារាធិរាជដែលជាមេអធម្មពល លុះបានដឹងច្បាស់ថា សមណគោតមនឹងផុតចាកកណ្ដាប់ដៃអាណានិគមក្នុងលោកនេះដូច្នេះហើយ ក៏ឆ្លៀតឱកាសប្រើឧបាយកលក្រខ្វក់ជាច្រើនបែបច្រើនយ៉ាង ដើម្បីបំផ្លិចបំផ្លាញគ្រោងការណ៍របស់ព្រះអង្គ ដោយយកបរិវារកញ្ញាជានុយ ប៉ុន្តែមារាធិរាជចាញ់ព្រះអង្គជាស្វ័យប្រវត្តិ ហើយរត់ចាកពីទីនោះទៅ ។ ពពួកទេវតាក៏បង្អុរបុប្ផាពីលើស្ថានសួគ៌ចុះមក លើព្រះវិជិតមារជានិមិត្តរូបនៃជ័យជំនះរបស់ព្រះអង្គ ។

គាថាទី ១៤:- គាថានេះថ្លែងពីសិទ្ធត្ថសមណៈបានត្រាស់ដឹងអនុត្តរ-សម្មាសម្ពោធិញ្ញាណ ។ បន្ទាប់ពីបានផ្ចាញ់មារាធិរាជមកព្រះលោកាចារ្យទ្រង់ចូលកាន់ឈានយ៉ាងតឹងរ៉ឹង បានទទួលលទ្ធផលដ៏ប្រពៃក្នុងការជ្រាបច្បាស់នូវកំណើតពីអតីត, យល់ច្បាស់នូវកំណើតបច្ចុប្បន្នរបស់សត្វលោក និងជ្រាបច្បាស់នូវហេតុដែលសត្វលោកសោយទុក្ខ និងផលដែលសត្វ-លោកសោយសុខ ព្រោះតែផលនៃអំពើដែលខ្លួនបានធ្វើហើយ ។

## ភាគទី ២

# លោកុត្តរធម៌

អ្នកឧកញ៉ា ធា.សាឆ អតីតរដ្ឋមន្ត្រី រៀបរៀង

(តមក)

---

ឯលោកុត្តរធម៌ ប្រែថា ធម៌សម្រាប់ចម្លងសត្វ ឲ្យឆ្លងចេញរួចចាក លោកគឺចាកមនុស្សលោក ទេវលោក និងព្រហ្មលោក ។ ឯលោកុត្តរធម៌នេះ គឺសំដៅមគ្គ ៤ ផល ៤ និងនិព្វាន, ពីព្រោះមគ្គ ផល និព្វាន នេះលោកចាត់ទុក ៖

១– ជា វិមោក្ខធម៌ គឺធម៌អាចញាំងសត្វឲ្យរួចចាកកិលេសដែលជាគ្រឿងសៅហ្មងនៃចិត្ត ។

២– ជា មោក្ខធម៌ គឺធម៌អាចញាំងសត្វឲ្យរួចចាកកងទុក្ខមានជាតិទុក្ខជាដើម ។

៣– ជា លោកនិស្សរណធម៌ គឺធម៌ជាគ្រឿងរលាស់ខ្លួនឲ្យរួចចេញចាកលោក ។

គឺការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វាននេះហើយ ដែលហៅថា លោកុត្តកកិសម័យ ។

បើដូច្នេះគប្បីចោទសួរថាតើមគ្គ ៤ ផល ៤ និងនិព្វាននោះគឺជាអ្វីទៅ

បានជាបណ្ឌិតលោកចាត់ទុកថាជាលោកុត្តរធម៌ គឺធម៌អាចចម្លងសត្វឲ្យឆ្លងចេញរួចផុតចាកត្រៃលោកបាននោះ? ។

ចំពោះសំនួរនេះខ្ញុំសូមឆ្លើយដំរាបថា មគ្គ ៤ ផល ៤ នោះមិនគឺអ្វីទេ គឺពិតជានាមនៃមគ្គចិត្ត ៤ នឹងផលចិត្ត ៤ ដែលប្រព្រឹត្តទៅក្នុងលោកុត្តរភូមិនោះឯង ។ ឯមគ្គចិត្ត ៤ នោះជាលោកុត្តរចិត្តដែលលះសំយោជនៈ ១០ តាមលំដាប់មគ្គដាច់ស្រឡះដោយសមុច្ឆេទប្បហានហើយ ផលចិត្ត ៤ នោះជាលោកុត្តរចិត្តដែលរួចចាកសំយោជនៈ ១០ តាមលំដាប់ផលដោយនិស្សរណវិមុត្តិ ដូចខ្ញុំបានអធិប្បាយបញ្ជាក់នៅផ្នែកលោកុត្តរចិត្តពីខាងដើមនេះសព្វគ្រប់ស្រាប់ ។

ដោយហេតុនេះទើបមគ្គ ៤ នោះគឺ :

**សោតាបត្តិមគ្គ** ជានាមនៃមគ្គចិត្តទី ១ ដែលលះសក្កាយទិដ្ឋិ វិចិកិច្ឆា នឹងសីលព្វតបរាមាស ។

**សកទាគាមិមគ្គ** ជានាមនៃមគ្គចិត្តទី ២ ដែលលះសំយោជនៈ ៣ ដូចខាងលើនេះ នឹងនឿយណាយចំពោះកាមរាគនឹងបដិឃៈទៀត ។

**អនាគាមិមគ្គ** ជានាមនៃមគ្គចិត្តទី ៣ ដែលលះសំយោជនៈ ៥ គឺ ៣ ដូចខាងលើនេះ នឹង ២ ទៀតគឺ កាមរាគនឹងបដិឃៈ ។

**អរហត្តមគ្គ** ជានាមនៃមគ្គចិត្តទី ៤ ដែលលះសំយោជនៈ ១០ គឺ៥ ដូចខាងលើនេះ នឹង ៥ ទៀតគឺរូបរាគ, អរូបរាគ, មានះ, ឧទ្ធច្ចៈនឹងអវិជ្ជា ។

ចំណែកឯផល ៤ នោះគឺ៖

សោតាបត្តិផល ជានាមនៃផលចិត្តទី១ដែលរួចចាកសំយោជនៈ ៣ គឺសក្កាយទិដ្ឋិ, វិចិកិច្ឆា និងសីលព្វតបរាមាស ។

សកទាគាមិផល ជានាមនៃផលចិត្តទី ២ដែលរួចចាកសំយោជនៈ ៣ ដូចខាងលើនេះហើយទៀយណាយបំពោះកាមរាគ និងបដិឃ:ទៀត។

អនាគាមិផល ជានាមនៃផលចិត្តទី ៣ ដែលរួចចាកសំយោជនៈ ៥ គឺ ៣ ខាងលើនេះ និង ២ ទៀតគឺ កាមរាគនិងបដិឃៈ ។

អរហត្តផល ជានាមនៃផលចិត្តទី ៤ ដែលរួចចាកសំយោជនៈ ១០ គឺ ៥ ដូចខាងលើនេះ និង ៥ ទៀតគឺ រូបរាគ, អរូបរាគ, មានះ, ឧទ្ធច្ចៈនិងអវិជ្ជា ។

អាស្រ័យហេតុនេះ ទើបការត្រាស់ដឹងមគ្គ ៤ និងផល ៤ នោះគឺសំដៅការសម្រេចឡើងនៃមគ្គចិត្ត ៤ និងផលចិត្ត ៤ ដូចបានអធិប្បាយខាងលើនោះឯង ។

បើដូច្នេះតើនិព្វានតោះគឺជាអ្វីទៅ ?

រីឯនិព្វានសព្ទនេះ គឺគ្រាន់តែជានាមនៃបរមសុខដូចមគ្គនិងផលជានាមនៃមគ្គចិត្តនិងផលចិត្តនោះដែរ ។

ដើម្បីងាយយល់នូវអត្ថរសនៃនិព្វាននោះ ខ្ញុំសូមបញ្ជាក់ថា អរហត្ត-

ផលគឺផលចិត្តទី ៤ ដែលរួចចាកសំយោជនៈ ១០ នោះជាលោកុត្តរចិត្ត· រួចផុតចាកកំដៅភ្លើងកិលេស ហើយតាំងនៅជាសុខុមាលភាព លែងស្គាល់សេចក្តីក្តៅក្រហល់ក្រហាយ, សេចក្តីអន្ទះអន្ទែង នឹងសេចក្តីស្រេកឃ្លាននូវអារម្មណ៍ ៥ ទៀតហើយ ។

បើដូច្នេះឃើញថានិព្វានគឺបរមសុខ ដែលសម្រេចកើតមានឡើង ដោយការត្រាស់ដឹងនូវអរហត្តផលជាមូលហេតុ ពីព្រោះអរហត្តផលដែលស្ថិតនៅឆ្ងាយពីកំដៅភ្លើងកិលេស តែងតែផ្តល់ឲ្យព្រះអរហន្តនូវអានិសង្ស ១ ជាពិសេស គឺបរមសុខនោះឯង ។

ប៉ុន្តែនិព្វានគឺបរមសុខនោះមាន ២ ប្រការគឺ ៖ ឧបាទិសេសនិព្វាន គឺបរមសុខដោយរួចផុតចាកកំដៅភ្លើងកិលេស ១ នឹងអនុប្បាទិសេសនិព្វាន គឺបរមសុខដោយរួចផុតចាកទាំងកំដៅភ្លើងកិលេស[1] នឹងកំដៅភ្លើងទុក្ខ[2]ផង ១ ។

ឯឧបាទិសេសនិព្វាន គឺបរមសុខដោយរួចចាកកំដៅភ្លើងកិលេស នោះត្រូវទុកជាបរមសុខក្នុងបច្ចុប្បន្ន ពីព្រោះព្រះអរហន្តគប្បីបានសម្រេចនូវបរមសុខ គឺឧបាទិសេសនិព្វាននោះនៅក្នុងបច្ចុប្បន្ន គឺនៅខណៈដែលព្រះអរហន្តអង្គនោះ បានធ្វើឲ្យជាក់ច្បាស់នូវវិមោក្ខគឺការរួចចាកកិលេស ៣ ប្រការដែលជាគ្រឿងបញ្ឆាក់ឲ្យដឹងថាកិលេស ឬ ភ្លើងកិលេសរលត

---

១ ឯភ្លើងកិលេស គឺរាគៈទោសៈមោហៈ ។ ២ ឯភ្លើងទុក្ខ គឺជាតិ,ជរា, ព្យាធិ នឹងមរណៈ ។

អស់ពីខន្ធសន្តានទៅហើយ ។ ត្រង់នេះហើយលោកសន្មតថាព្រះអរហន្ត បានធ្វើនិព្វានសច្ឆិកិរិយា គឺកិរិយាជាក់ច្បាស់នៃនិព្វានឲ្យកើតប្រាកដឡើងហើយ ។

រីឯវិមោក្ខ ៣ ប្រការនោះគឺ៖

សុញ្ញតវិមោក្ខ គឺការរួចចាកកិលេសដោយសូន្យគ្មានកិលេស ១,

អនិមិត្តវិមោក្ខ គឺការរួចចាកកិលេសដោយគ្មានអ្វីជាគ្រឿងសំគាល់ជាកិលេស ១,

អប្បណិហិតវិមោក្ខ គឺការរួចចាកកិលេសដោយគ្មានអ្វីជាទីតាំងនៃកិលេស ១, ។

ដោយហេតុនេះ ទើបឧបាទិសេសនិព្វានគឺបរមសុខក្នុងបច្ចុប្បន្ននោះ ជាបរមសុខប្រកបដោយសុខយ៉ាងសុខុមក្រៃលែង មាន៥ប្រការជាដើមគឺ៖

១- អនាសវសុខ គឺសុខដោយគ្មានអាសវៈដែលជាកិលេសដេកត្រាំក្នុងសន្តានចិត្ត ។

២- និរាមិសសុខ គឺសុខដោយគ្មានអាមិស គឺគ្មានលាយឡំដោយកាមគុណ ។

៣- ចេតសិកសុខ គឺសុខខាងផ្លូវចិត្ត ។

៤- ឯកន្តសុខ គឺសុខតែមួយយ៉ាងគ្មានលាយឡំដោយទុក្ខ ។

៥– សន្តិសុខ  គឺសុខយ៉ាងស្ងប់ស្ងាត់ក្រៃលែង ។

រីឯអនុបាទិសេសនិព្វាន គឺបរមសុខដោយរួចផុតចាកភ្លើងកិលេស នឹងភ្លើងទុក្ខផងនោះ ត្រូវទុកជាបរមសុខទៅអនាគត ពីព្រោះព្រះអរហន្ត គប្បីសម្រេចបរមសុខគឺអនុបាទិសេសនិព្វាននោះនៅពេលខាងមុខ គឺនៅពេលដែលព្រះអរហន្តអង្គនោះរំលត់ខន្ធ ដោយអាយុក្ស័យចូលកាន់បរិនិព្វាន ។

ដោយហេតុនោះ ទើបអនុបាទិសេសនិព្វាន គឺបរមសុខទៅអនាគតនោះ ត្រូវចាត់ទុកជាបរមសុខយ៉ាងសុខុមក្រៃលែង ប្រកបដោយបរមសុញ្ញ ២ ប្រការ គឺសុញ្ញដោយកិលេសរលត់អស់គ្មានសេសសល់ ១ នឹងសុញ្ញដោយបញ្ចក្ខន្ធរលត់អស់ ១ ។

គឺបរមសុញ្ញប្រកបដោយសុញ្ញ ២ ប្រការនេះហើយ ដែលជាមូលហេតុនឹងញ៉ាំងព្រះអរហន្តអង្គនោះ ឲ្យបានដល់នូវអវសានជាតិទាំងពេញ រួចផុតចាកត្រៃលោក លែងត្រឡប់វិលកើតវិលស្លាប់ក្នុងត្រៃភពទៀត ។

អាស្រ័យហេតុនេះ ទើបលោកចាត់ទុកមគ្គ ៤ ផល ៤ នឹង និព្វានជាលោកុត្តរធម៌ គឺធម៌អាចចម្លងសត្វឲ្យឆ្លងចេញរួចផុតចាកលោកបានដោយប្រការដូច្នេះឯង ។

សរុបសេចក្តីទៅឃើញថា មគ្គ ផល និព្វាន គ្រាន់តែជានាមសម្រាប់ហៅមគ្គចិត្ត ៤, ផលចិត្ត ៤ នឹងបរមសុខដែលសម្រេចឡើងដោយមគ្គចិត្ត

និងផលចិត្តនោះឯង តប៉ុណ្ណោះ ។

ដោយហេតុនោះហើយបានជា មគ្គ ផល និព្វាននោះធ្វើឲ្យពុទ្ធបរិ-ស័ទភាគច្រើនមានសេចក្ដីងឿងឆ្ងល់ពន់ពេក ដោយទឹកគិតមិនយល់ថា តើមគ្គ ផល និព្វាននោះគឺជាអ្វីប្រាកដសោះ, ព្រោះបានដឹងតែនាមមិនដែលបានឃើញនូវរូបនៃមគ្គផលនិព្វាននោះដូចម្ដេចសោះ ។

ខ្ញុំសង្ឃឹមទុកជាមុនថា រូបភាពមគ្គផលនិព្វានដែលខ្ញុំទើបនឹងកកាយរកឃើញនោះ មុខតែនឹងញាំងអស់លោកឲ្យលែងទឹកគិតសង្ស័យថា និព្វានជាឋានព្រហ្មលោក ឬថាជាឋានមានវិមាន ឬមានគ្រឿងទៀតហើយ, ពីព្រោះរូបមគ្គផលនិព្វានមានលក្ខណៈគ្រប់គ្រាន់ហើយជាក់ច្បាស់ គួរឲ្យវិនិច្ឆ័យថាត្រឹមត្រូវពិតមែន ។

ម្យ៉ាងទៀត ខ្ញុំសូមលើកយកព្រះពុទ្ធតម្រាស់មួយអន្លើដែលថា ៖

" និព្វានំ បរមំ សុខំ " បរមសុខគឺនិព្វាន ។

" និព្វានំ បរមំ សុញ្ញំ " បរមសុញ្ញគឺនិព្វាន ។

មកចុះផ្សាយនៅទីបញ្ចប់នេះ ដើម្បីទុកជូនអស់លោកអ្នកដែលអានសៀវភៅលោកុត្តរកិសម័យនេះ ពិនិត្យនឹងពិចារណាឲ្យកាន់តែបានដឹងច្បាស់តទៅទៀតតាមត្រូវការចុះ ។

# លោកុត្តរកិសម័យ

## ភាគទី ៣ បដិបទា

ឯបដិបទាដែលអាចញ៉ាំងការត្រាស់ដឹងមគ្គ ៤ ផល ៤ ពោលគឺមគ្គចិត្ត ៤ ដែលលះសំយោជនៈ១០ ដាច់ស្រឡះដោយសមុច្ឆេទប្បហាន និងផលចិត្ត ៤ ដែលរួចចាកសំយោជនៈ១០ ផុតស្រឡះដោយនិស្សរណវិមុត្តិឲ្យសម្រេចឡើងបាននោះ គឺសំដៅអដ្ឋង្គិកមគ្គដែលប្រកបដោយអង្គ ៨ មានអង្គសម្មាទិដ្ឋិជាដើមនិងអង្គសម្មាសមាធិជាទីបំផុតនោះឯង ពីព្រោះអដ្ឋង្គិកមគ្គនោះ ជាភាវេតព្វធម៌ដែលអរិយបុគ្គលគប្បីចំរើនឲ្យសម្រេចគ្រប់អង្គទាំង ៨ ដើម្បីនឹងបំពេញត្រៃខន្ធគឺសីលខន្ធ, សមាធិខន្ធនិងបញ្ញាខន្ធឲ្យពោរពេញទៅដោយគុណផ្សេង ៗ ដែលលោកចាត់ទុកជាគ្រឿងអាផុតកំដៅខន្ធសន្តានឲ្យរីងហួតស្ងួតចាកកពភាទិក្កិលេស គឺសំយោជនៈ ១០ នោះឯង ។

រីឯត្រៃខន្ធគឺទាំង ៣ នោះមានគុណធម៌ផ្សេង ៗ ដូចតទៅនេះគឺ ៖

**សីលខន្ធ** គឺគុណសីលមានកាយសុចរិត ៣ វចីសុចរិត ៤ និងមនោសុចរិត ៣ ។

**សមាធិខន្ធ** គឺគុណសមាធិមានអប្បនាសមាធិ និងឈានចិត្ត ៨

**បញ្ញាខន្ធ** គឺគុណបញ្ញាមានវិបស្សនាញាណ ១០ ។

ឯសីល សមាធិ និងបញ្ញានេះ ដែលនឹងសម្រេចកើតឡើងជាខន្ធ

បុគ្គលបានដោះ ក៏ត្រូវអាស្រ័យការចំរើនកម្មដ្ឋាន ២ គឺ សមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ពីព្រោះការចំរើនសមថកម្មដ្ឋាន មានការចំរើនឈានជាទីបំផុតតែងផ្តល់ឲ្យយោគាវចរនូវសមាធិ និងឈានចិត្ត ៨ មានរូបជ្ឈានចិត្ត ៤ ជាដើម ហើយការចំរើនវិបស្សនាកម្មដ្ឋាន ក៏រមែងតែហុចនូវវិបស្សនាញាណ ១០ ពុំខានឡើយ ។

គឺសមាធិចិត្ត, ឈានចិត្ត ៨ និងវិបស្សនាញាណ ១០ នោះហើយដែលជាគ្រឿងដុតកំដៅពេលខន្ធសន្តាន ឲ្យរីងហួតស្ងួតបាកកតាទិក្កិលេសអស់ទៅបាន ពីព្រោះឈានចិត្តដែលសម្បយុត្តដោយអង្គឯកគ្គតា និងឧបេក្ខាតែងតែតាំងនៅជាកណ្តាលជានិច្ច ព្រងើយកន្តើយមិនអើពើមិនសោមនស្ស មិនទោមនស្សចំពោះឥដ្ឋានិដ្ឋារម្មណ៍ ហាក់ដូចជាមិនបិទធក្ខារមិនឲ្យរាគៈ ទោសៈ ចូលមកកើតកង់ខន្ធសន្តានបាន ហើយធ្វើឲ្យខន្ធសន្តាននោះរីងស្ងួតបាកកតាទិក្កិលេសនោះអស់ទៅ ។

រីឯវិបស្សនាញាណ គឺញាណដែលដឹងច្បាស់នូវដំណើរនៃសង្ខារធម៌ទៅតាមការពិតនោះ ក៏រមែងតែប្រឆាំងពក់ព័ន្ធមិនឲ្យមោហៈ និងសក្កាយទិដ្ឋិចូលមកកើតក្នុងខន្ធសន្តានបាន ហើយធ្វើខន្ធសន្តាននោះឲ្យរីងហួតដុតបាកសក្កាយទិដ្ឋិ និងវិចិកិច្ឆាអស់ទៅ ។

កាលបើឈានចិត្ត ៨ និងវិបស្សនាញាណ ១០ កើតមានបរិបូណ៌ក្នុងខន្ធសន្តាន ក៏ជាបច្ច័យតាក់តែងវិសុទ្ធិ គឺសេចក្តីបរិសុទ្ធិ ៩ ប្រការដែល

ជាសមុដ្ឋាននៃការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វានឲ្យសម្រេចឡើងជាលំដាប់ ។

ឯវិសុទ្ធិ ៩ ប្រការនោះ គឺ៖

១– សីលវិសុទ្ធិ បរិសុទ្ធនៃសីល

២– ទិដ្ឋិវិសុទ្ធិ បរិសុទ្ធនៃការយល់ឃើញត្រូវ

៣– កង្ខាវិតរណវិសុទ្ធិ បរិសុទ្ធនៃការឆ្លងរួចចាកសេចក្តីសង្ស័យ

៤– មគ្គាមគ្គញាណទស្សនវិសុទ្ធិ បរិសុទ្ធនៃការឃើញច្បាស់នូវមគ្គដែលជាសម្មាមគ្គត្រឹមត្រូវ ។

៥– បដិបទាញាណទស្សនវិសុទ្ធិ បរិសុទ្ធនៃការឃើញច្បាស់នូវបដិបទាដែលអាចញុំាងការត្រាស់ដឹងមគ្គផលនិព្វាន ឲ្យសម្រេចឡើងបាន ។

៦– ញាណទស្សនវិសុទ្ធិ បរិសុទ្ធនៃការដឹងច្បាស់ទៅតាមការណ៍ពិត ។

៧– ចិត្តវិសុទ្ធិ បរិសុទ្ធនៃចិត្ត

៨– បញ្ញាវិសុទ្ធិ បរិសុទ្ធនៃបញ្ញា

៩– វិមុត្តិវិសុទ្ធិ បរិសុទ្ធនៃការរួចចាកកិលេស

រីឯវិធីសម្រាប់ចំរើនកសិណ ចំរើនវិបស្សនា និងចំរើនឈានដែល

នឹងមានដំណើរប្រព្រឹត្តទៅដូចម្ដេចនោះ ខ្ញុំនឹងធ្វើអត្ថាធិប្បាយពន្យល់តាម
សមត្ថភាព ដែលខ្ញុំអាចនឹងធ្វើទៅបានដូចមានតទៅនេះ ។

## ក- សមថកម្មដ្ឋាន

ឯសមថកម្មដ្ឋាននេះមាន ៤០ យ៉ាង ចែកចេញជា ៧ពួកគឺ៖
កសិណ ១០ - អសុភ ១០ - អនុស្សតិ ១០ អប្បមញ្ញា ៤ - អរូប ៤ -
អាហារបដិកូលសញ្ញា ១ ធាតុវវត្ថាន ១ ។

ការចំរើនសមថកម្មដ្ឋាន គឺសំដៅការចំរើនកសិណជាដើម នឹងការ
ចំរើនឈានជាទីបំផុត ។

### ១- អំពីកសិណ

ឯកសិណសព្ទនេះ មានសេចក្ដីអធិប្បាយក្នុងសៀវភៅពុទ្ធគុណ
បញ្ជាក់មួយអន្លើថា ៖

"ចិត្តឯណាដែលក្រពស់ប្រព្រឹត្តវិលវល់នៅតែក្នុងកន្លែងមួយ ព្រោះ
ហេតុនោះ បានជាចិត្តនោះឈ្មោះថា កសិណ "

" ឯមណ្ឌលគឺវង់មូលមានទំហំ ១ ចំអាម ៤ ធ្នាប់ក្ដី និមិត្តដែលតាំង
ឡើងក្នុងមណ្ឌលនោះក្ដី សមាធិចិត្តដែលមណ្ឌលនោះជាអារម្មណ៍ក្ដី ក៏
ហៅថាកសិណដែរ " ។

បើសិនជាលើកយក បឋវីកសិណ មកធ្វើជាអារម្មណ៍ មកធ្វើជា-
ឧទាហរណ៍នោះ សេចក្ដីបញ្ជាក់ដូចខាងលើនេះ នាំឲ្យយល់បានដូច្នេះគឺ៖

(នៅមានត)

# គម្ពីរព្រះយមក:

លោក ប៊ូ-ប៉ូ ប្រែរៀបរៀង

(តមក)

---

សុត្តំ សជ្ឈាយិត្វា និសិន្នេសុ កាលភិក្ខុទាំងឡាយអង្គុយសូធ្យាព្រះសូត្រ ភិក្ខុមួយអង្គសួរថា ព្រះសូត្រប្រាកដដល់លោកទាំងឡាយយ៉ាងណា ? ភិក្ខុនោះប្រាប់ថា ព្រះសូត្រនេះប្រាកដដល់ខ្ញុំដូចជាទឹកហូរធ្លាក់ពីកំពូលភ្នំ ។ អង្គឯទៀតប្រាប់ថា ព្រះសូត្រប្រាកដដល់ខ្ញុំដូចជាព្រៃ ។ អង្គឯទៀតប្រាប់ថា ព្រះសូត្រប្រាកដដល់ខ្ញុំដូចជាដើមឈើមានមែកត្រដាក់ប្រកបដោយស្លឹក នឹងផ្លែគបរិបូណ៌ ។ ឯកំ ឯវ សុត្តំ ព្រះសូត្រតែមួយ ប្រាកដដល់ភិក្ខុទាំងឡាយផ្សេង ៗ គ្នាដូច្នេះ ដោយសញ្ញានៃភិក្ខុទាំងឡាយនោះផ្សេង ៗ គ្នា មិនដូចគ្នា មានឧបមាយ៉ាងណា ។ ឯកំ ឯវ កម្មដ្ឋានំ ព្រះកម្មដ្ឋានតែមួយតែនិមិត្តប្រាកដឡើងនោះផ្សេង ៗ គ្នា មិនដូចគ្នាទេ មានឧបមេយ្យដូច្នោះ ។ ចាប់ដើមអំពីនិមិត្តកើតប្រាកដឡើង នីវរណធម៌ទាំងប្រាំមានកាមច្ឆន្ទនីវរណៈជាដើម ក៏ខ្ចាត់ចេញពីចិត្តនៃព្រះយោគាវចរ ។ លុះព្រះយោគាវចរសង្កត់សង្កិននីវរណៈធម៌ទាំងប្រាំបានហើយ កិលេសខាងក្នុងក៏ស្ងប់ស្ងាត់ សតិក៏នឹងកើតមានឡើងប្រាកដ ចិត្តក៏នឹងតាំងនៅមាំមួន

ល្អ មិនគម្រើកញាប់ញ័រ ៗ ឯនិមិត្តនោះ កិច្ចគប្បីកំណត់ទុកក្នុងចិត្ត កុំគប្បីពិចារណាដោយលក្ខណៈ គប្បីរក្សាទុកឲ្យល្អបីដូចជាខត្តិយអគ្គមហេសីដែលទ្រង់ព្រះគភ៌បរមចក្រពត្តិ ៗ ពុំនោះសោត ព្រះយោគាវចរ គប្បីរក្សានូវនិមិត្តនោះទុក ឲ្យដូចជាអ្នកស្រែរក្សានូវពូជនៃស្រូវដំណើប ឲ្យគង់នៅ គប្បីវៀរលែងនូវទីកន្លែងមិនសប្បាយ ៧ កន្លែង, សេពនូវទីសប្បាយ ៧ កន្លែង មានអាវាសនាំឲ្យបានសប្បាយជាដើម ហើយគប្បីរក្សានិមិត្តទុក កាលរក្សានូវនិមិត្តទុកល្អហើយ ញុំាងនិមិត្តឲ្យចំរើនឡើង ឲ្យដុះដាលឡើង ដោយអំណាចកំណត់ទុកក្នុងចិត្ត ហើយគប្បីការនាញុំាងអប្បនាឈានឲ្យបរិបូណ៌ ហើយប្រព្រឹត្តនូវសេចក្ដីព្យាយាមឲ្យស្មើ កុំឲ្យធូរតឹងជួនស្រាលជាងគ្នា ហើយគប្បីចំរើននូវចតុត្ថជ្ឈាន, បញ្ចមជ្ឈានក៏នឹងបង្កើតក្នុងនិមិត្តដោយលំដាប់ លុះចតុត្ថជ្ឈាននោះស្ទាត់ជំនាញដោយវសីប្រាំប្រការហើយ គប្បីកំណត់នូវនាមនឹងរូប ដោយព្រះត្រៃលក្ខណញ្ញាណ គឺពិចារណានូវបញ្ចសង្ខារដោយ អនិច្ចំ, ទុក្ខំ, អនត្តា ៗ ហេតុអ្វីបានជាឲ្យព្រះយោគាវចរធ្វើយ៉ាងនេះ ព្រោះហេតុថា ព្រះយោគាវចរអ្នកបំពេញវិធីចំរើនអានាបានស្សតិកម្មដ្ឋាននោះ កំណត់នូវនាមនឹងរូបហើយ ទើបចំរើននូវព្រះវិបស្សនា ព្រោះហេតុកិច្ចនោះតាំងទុកនូវព្រះវិបស្សនា ពិចារណាឃើញដោយព្រះត្រៃលក្ខណញ្ញាណ នឹងឃើញនូវទីកើត, ទីរលត់នៃខ្យល់អស្សាសៈបស្សាសៈថា ករជកាយនឹងចិត្តនេះ

ជាទីកើតនៃខ្យល់ដង្ហើមចេញចូល ហើយឃើញទីរលត់ថា ករជ្ឈកាយនឹងចិត្តនេះរលត់ហើយ ខ្យល់ដង្ហើមចេញចូលក៏លែងកើត ក្នុងលំដាប់នោះ ប្រាជ្ញចាកសេចក្ដីសង្ស័យក្នុងធម៌វិសេសៗ ឡើងទៅ ដរាបដល់ព្រះអរិយមគ្គព្រះអរិយផល ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ដែលពោលមកទាំងនេះដោយអំណាចនៃបុគ្គលដែលមានបុញ្ញកសនា នឹងបានសម្រេចព្រះអរិយមគ្គព្រះអរិយផលក្នុងជាតិនោះ មានសតិតាំងមាំហើយ ក៏នឹងបានសម្រេចដូចសេចក្ដីប្រាថ្នា បើមានបារមីនៅពុំទាន់ចាស់ក្លា តែមានសតិតាំងមាំក្នុងការធ្វើបរិកម្មភាវនា ក៏អាចការពារនូវអន្តរាយបាន នឹងជាឧបនិស្ស័យបច្ច័យទៅក្នុងបរភពខាងមុខ កាំមដ្ឋិ បង នឹងបាច់ស្រដីទៅថ្វីដល់លោកដែលមានបារមីចាស់ក្លា តាំងសតិក្នុងកម្មដ្ឋានភាវនា គ្រាន់តែបុគ្គលមានសតិតាំងមាំ មិនបានរៀនក្នុងការចំរើនមន្ត ដែលអាចារ្យប្រាប់ ក៏អាចការពារអន្តរាយអំពីចោរបាន នឹងលើកអតីតនិទានមកបញ្ជាក់ឲ្យឃើញច្បាស់, សេចក្ដីថា ៖

មានដំណាលថា មានបុរសម្នាក់នៅក្នុងនគរពារាណសី ទៅរៀនវិជ្ជាឯក្រុងតក្កសិលា ។ អាចារ្យប្រាប់សិល្បសាស្ត្រទាំងឡាយឲ្យចាំមិនបាន ។ តែបុរសនោះប្រកបដោយវត្តប្រតិបត្តិអាចារ្យ ។ ទើបចងមន្តមួយបទឲ្យដោយសេចក្ដីករុណា មន្តនោះថា ឃដេសិ កឹ ការណា ឃដេសិ អហំបិ តំ ជានាមិ បុរសនោះរៀនចាំស្ទាត់ហើយ

លាអាចារ្យត្រឡប់មកផ្ទះវិញ ខំស្វាធ្យាយសូត្រទឹកព្រៃកជានិច្ច មិនឲ្យលោះខាន ។

ថ្ងៃមួយ ព្រះមហាក្សត្រត្រាច់យាងត្រួតត្រាសង្កេតមើលអាណាប្រជារាស្ត្រក្នុងពេលរាត្រី គង់ឈរនៅត្រង់ស្រមោលផ្ទះបុរសនោះ ។ ពេលនោះ មានចោរមកប្រុងលួចទ្រព្យរបស់បុរសនោះៗ ក្រោកឡើងសូត្រព្រៃកមន្តនោះ ចោរបានឮក៏ភ័យរត់ចេញទៅ ។ លុះព្រឹកឡើងព្រះមហាក្សត្រត្រាស់បង្គាប់ឲ្យចាប់ចោរនោះយកទៅធ្វើទោស ហើយបង្គាប់ឲ្យបុរសនោះចូលមកគាល់ សួរជ្រាបសេចក្តីហើយសុំរៀនមន្តពីបុរសៗក៏ព្រមបង្រៀនថ្វាយ ។ ចំណែកសេនាបតីរបស់ព្រះអង្គ យុបយិតសមគំនិតនឹងខ្ទាន់ព្រះកេស ប្រាប់ឲ្យផ្តាច់ព្រះជន្មព្រះមហាក្សត្រនៅវេលាដែលចំរើនព្រះកេសាថ្វាយ ។ ព្រះរាជាចំរើនការនាបរិកម្មមន្តនោះឥតដាច់ពីព្រះឱស្ឋ ។ ខ្ទាន់ព្រះកេសក៏ភ័យតក់ស្លុតទទួលសារភាពសូមជីវិតហើយ ក្រាបទូលតាមការពិតថា អំពើនេះ ជាគំនិតរបស់សេនាបតី ។ ព្រះរាជាត្រាស់ឲ្យហូតងារសេនាបតីចេញ ហើយទ្រង់ព្រះមេត្តាប្រោសព្រះរាជទានដំណែងសេនាបតីឲ្យបុរសជាអាចារ្យអ្នកបង្រៀនមន្តព្រះអង្គ ។ បុរសនោះបានទីជាសេនាបតី ។ ឯព្រះមហាក្សត្រពុំបានក្ស័យព្រះជន្មនឹងអំពើក្បត់ ព្រោះព្រះអង្គមិនភ្លេចស្វាធ្យាយចំរើនមន្តជានិច្ច គឺទ្រង់ប្រកបព្រះអង្គទុកក្នុងអប្បមាទ ទាល់តែបានសម្បត្តិនិងបានព្រះជន្មប្រាកដដូច្នេះ ។ ហេតុនោះ

បានជាព្រះមានព្រះភាគទ្រង់ចប់អមោហោ បញ្ចប់ក្នុងមូលនៃកុសលក្នុងមូលយមកៈ ក្នុងគម្ពីរព្រះយមកៈនេះ ។

## អកុសលមូល

យេ កេចិ អកុសលា ធម្មា សព្វេ តេ អកុសលមូលា, យេ វា បន អកុសលមូលា សព្វេ តេ ធម្មា អកុសលា ។ យេ កេចិ អកុសលា ធម្មា សព្វេ តេ ធម្មា អកុសលមូលេន ឯកមូលាតិ ។

លំដាប់នេះ ទីនវិសជ្ជនាក្នុងមូលយមកៈចំណែកអកុសលតទៅ តាមដំណើរសេចក្តីថា កតមា ព្រះមានព្រះភាគកាលព្រះអង្គត្រាស់ទេសនាក្នុងមូលនៃកុសលចប់ហើយ ក្នុងលំដាប់នោះទើបទ្រង់ត្រាស់ទេសនាក្នុងមូលនៃអកុសលជាលំដាប់តទៅ ទ្រង់ត្រាស់បុច្ឆាថា យេ កេចិ អកុសលា ធម្មា ធម៌ទាំងឡាយណា ដែលជាអកុសល ធម៌ទាំងឡាយទាំងពួងនោះឬជាមូលនៃអកុសល ធម៌ទាំងឡាយដែលជាមូលនៃអកុសលនោះឬឈ្មោះថា អកុសលធម៌ ? ព្រះអង្គទ្រង់ត្រាស់បុច្ឆាដូច្នេះហើយ ទើបទ្រង់ត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា អាមន្តា អើ ! ធម៌ទាំងឡាយដែលជាអកុសលនោះ ឈ្មោះថាជាមូលនៃអកុសល, ធម៌ដែលជាមូលនៃអកុសលនោះ ឈ្មោះថា អកុសល ។ ព្រះអង្គត្រាស់ដូច្នេះហើយ ទើប

ទ្រង់ត្រាស់បុច្ឆាតទៅទៀតថា កតមេ ធម្មា ធម៌ទាំងឡាយដែលជាមូលនៃអកុសលនោះ មានប៉ុន្មានប្រការ? ទើបទ្រង់ត្រាស់វិសជ្ជនាថា ធម៌ទាំងឡាយដែលជាមូលនៃអកុសលនោះ មានបីប្រការ គឺ លោភោ ១, ទោសោ ១, មោហោ ១ ។ ធម៌បីប្រការនេះឯង ឈ្មោះថាជាមូលនៃអកុសល ។ អកុសលធម៌ទាំងឡាយនេះ ជាឫសជាគល់ជាមូលជាទីតាំងនៃអកុសល ។ អកុសលទាំងឡាយនឹងកើតឡើងបាន ក៏តែងអាស្រ័យនូវធម៌ទាំងបីប្រការនេះ បើគ្មានធម៌បីប្រការនេះជាទីតាំងទេ អកុសលទាំងឡាយក៏មិនអាចនឹងកើតឡើងឯង ៗ បានឡើយ រុក្ខោ វិយ មូលំ ប្រៀបដូចដើមឈើនឹងស្មៅវល្លិ៍ទាំងពួង បើគ្មានឫសជាទីតាំងទេ ក៏មិនអាចនឹងដុះលូតលាស់ឡើងបាន ។ ធម្មតារុក្ខជាតិទាំងឡាយ បើទុកជាដុះលូតលាស់ឡើងដោយសារគ្រាប់ នឹងធំខ្ពស់ជាដីមដង់ហូតដល់មានមែកធាងចេញផ្កាមានផ្លែ បើមានតែគម្រាំងដើមមួយប៉ុណ្ណោះក៏ដុះឡើងមិនបាន ត្រូវតែមានឫសចាក់ចុះជ្រៅទៅក្នុងផែនដី ទើបអាចដុះជាដើមធំខ្ពស់ឡើងបាន យថា មានឧបមាដូចម្ដេច ? អកុសលធម៌ទាំងឡាយនឹងកើតមានឡើងបាន ក៏តែងអាស្រ័យនូវមូលបីប្រការគឺលោភោ, ទោសោ នឹង មោហោ មានឧបមេយ្យដូច្នោះ ។ ហេតុនោះ ធម៌បីប្រការនេះ ទើបបានឈ្មោះថាមូលនៃអកុសល ព្រោះហេតុជាទីតាំងនៃអកុសល ដូចមានសេចក្ដីអធិប្បាយអំពី លោភោ តទៅនេះ៖

## លោភអកុសលមូល

លុព្ភតីតិ លោភោ លោភនោះរមែងញ៉ាំងចិត្តឲ្យប្រាថ្នាឲ្យគន្លង់ របរតជាប់ស្អិតនៅក្នុងកិលេសកាមនិងវត្ថុកាម មានសេចក្ដីប្រាថ្នាចង់បានទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជារបស់ខ្លួនជាគ្រឿងមុខ មក្កដាលេបោរិយ លោភមានឧបមាដូចស្វាជាប់ជ័រស្អិត ទឹងរើបម្រះខ្លួនឲ្យរួចរបូតពីជ័រចេញដោយកម្រ ។ អបរិច្ចាគលក្ខណោ លោភមានការមិនបានលះបង់នូវទ្រព្យសម្បត្តិរបស់ខ្លួនជាលក្ខណៈ ។ លោភបើមានតែបន្តិចបន្តួច ក៏ល្មមនឹងហាមឃាត់កំចាត់បង់បាន បើមានច្រើនខ្លាំងក្លាឡើងហើយ មិនងាយនឹងកំចាត់ចេញឡើយ តែងទន់ទាញអ្នកមានលោភច្រើននោះ ឲ្យបានសោយទុក្ខវេទនាជាពន្លឹក ។ បើអ្នកណាមានចិត្តលោភខ្លាំងក្លាហួសប្រមាណហើយ អ្នកនោះនឹងបានសេចក្ដីវិនាសក្នុងបច្ចុប្បន្ន គឺនឹងត្រូវពិដ៍ខណ្ឌអំពីសំណាក់នៃព្រះមហាក្សត្រ លុះទៅដល់អនាគតជាហេតុនឹងឲ្យកើតក្នុងទុគ្គតិមានអបាយជាដើម ។

សម្ដេចព្រះមានព្រះភាគទ្រង់ទេសនាថា យំ សហតេ ជរំ លោភ បើចូលៈទៅគ្រប់សង្កត់បុគ្គលណា បុគ្គលនោះរមែងប្រព្រឹត្តនូវការដែលមិនគួរប្រព្រឹត្ត ។ មនុស្សលោករមែងប្រកបដោយបឹងវិញ្ញុៈយោគទុក្ខ គឺទុក្ខព្រោះការបែកបាក់ព្រាត់ប្រាសចាកញាតិមិត្រ ដែលជាទីស្រឡាញ់ពេញចិត្ត ព្រោះហេតុតែលោភខ្លាំងពេក ។ បុរា ឆធី ស៊ីងតាំងពងមាន

វេលាស្រេកស្រេតខ្វះខាតទឹក មានវេលាពេញពោរផេតខ្វះកន្ទះ ។ ឯលោកវិញគ្មានវេលាណាទីងពោរពេញទេ មានតែខ្វះកន្ទះជានិច្ច ។ លោកចង់បានតែកាមទីងកិលេសកាមផ្សេង ៗ កាលបានមកដូចចិត្តប្រាថ្នាហើយក៏នៅតែគិតចង់បានរបស់ដទៃថែក ។ ទៅទៀត លុះបានរបស់នេះមកហើយ នៅតែនឹកចង់បានរបស់នោះទៀត មិនចេះអស់មិនចេះហើយ ។ បុគ្គលធ្វើអទិន្នាទាន ក៏ព្រោះតែកើតមានចិត្តលោភបណ្ដាលឲ្យគ្រោងទីងនឹងញាតិមិត្រ ដូចមានរឿងក្នុងព្រះបាលី មានសេចក្ដីដំណាលថា ៖

ព្រះមហាក្សត្រមួយព្រះអង្គ មានព្រះរាជឱរសពីរព្រះអង្គហើយទ្រង់ទិវង្គតទៅ ។ បំណែកព្រះរាជកុមារជាព្រះជេដ្ឋា ត្រូវសោយរាជសម្បត្តិតពីព្រះវររាជបិតា ប៉ុន្តែព្រះអង្គប្រកែកពុំព្រមទទួលរាជសម្បត្តិនេះ ទ្រង់លើកប្រគល់ឲ្យព្រះរាជកនិដ្ឋាសោយរាជ្យតទៅ ហើយព្រះអង្គឯងយាងចេញពីព្រះរាជធានីទៅសំណាក់អាស្រ័យនៅក្នុងស្រុកមួយ ដែលគាំងនៅឆាអាណាខេត្រទគរនេះ ។

គេ សញ្ញា ធិតា មនុស្សទាំងឡាយក្នុងត្រកូលនោះ ដឹងថាព្រះរាជកុមារជាព្រះរាជឱរសនៃព្រះមហាក្សត្រ ហើយត្រូវជាព្រះជេដ្ឋានៃព្រះមហាក្សត្រដែលទើបសោយរាជ្យថ្មី ក៏នាំគ្នាទំនុកបំរុងថែរក្សាមិនឲ្យព្រះកុមារនោះធ្វើការងារអ្វីឡើយ ។

អបរភាគេ លុះចំណេរមកខាងក្រោយ មនុស្សទាំងឡាយទូលព្រះ

រាជកុមារថា មយំ ទាសេម ខ្ញុំព្រះអង្គរាល់គ្នាបានទំនុកបម្រុងថែរក្សាព្រះអង្គមកជាយូរខែឆ្នាំហើយ សូមព្រះអង្គជួយសង្គ្រោះដល់អស់យើងខ្ញុំខ្លះផង សូមផ្ញើព្រះរាជសាសន៍ទៅថ្វាយព្រះមហាក្សត្រជាព្រះកនិដ្ឋារបស់ព្រះអង្គ ឲ្យបន្ធូរបន្ថយពន្ធលោះលាសួយ(១) ដល់យើងខ្ញុំខ្លះផង ។ ព្រះរាជកុមារក៏ផ្ញើព្រះរាជសាសន៍ទៅថ្វាយព្រះមហាក្សត្រ តាមពាក្យអ្នកស្រុកសុំ ។ ព្រះមហាក្សត្រទ្រង់យល់ព្រមព្រះរាជទានតាមព្រះរាជសាសន៍នោះឥតជំទាស់ ព្រោះសុំតែមនុស្សក្នុងត្រកូលមួយឬគ្រួសារមួយដែលព្រះរាជកុមារជេដ្ឋាទៅគង់នៅជាមួយនោះ ។

លុះចំណេរយូរមក ព្រះរាជជេដ្ឋាផ្ញើព្រះរាជសាសន៍ទៅសុំឲ្យបន្ថយសួយគ្រប់មនុស្សពេញមួយស្រុកនោះ ។ ព្រះមហាក្សត្រក៏ទ្រង់ព្រះរាជទានតាមសុំ មិនឲ្យទាស់អធ្យាស្រ័យ ។ ក្រោយមកទៀតសុំនាទីសេនាបតីជាធំ ព្រះរាជាក៏ព្រមព្រះរាជទានតាមសុំ ។ កន្លងមកមិនយូរប៉ុន្មានសុំទីជាឧបរាជ ព្រះរាជកនិដ្ឋាក៏ព្រះរាជទាន ។

ព្រះរាជជេដ្ឋានោះ សូម្បីបានទីជាឧបរាជហើយក៏មិនទាន់អស់លោភពិសន្តាន នៅតែចង់បានជាធំ គឺសោយរាជសម្បត្តិទៀត ទើបលើករេហ៍ពលសកលយោធាទៅចោមព័ទ្ធនគរ ហើយផ្ញើលិខិតទៅថ្វាយព្រះមហាក្សត្រមានសេចក្តីថា រជ្ជំ វា យុទ្ធំ វា ទេហិ ព្រះមហាក្សត្រ

១ ក្នុងសម័យបុរាណហៅប្រាក់បង់ពន្ធគ្រប់ចំពូក ឬ វត្ថុទ្រ ដែលត្រូវដាក់ឃ្លាំងហ្លួងថា សួយ ។

ដែលជាព្រះកនិដ្ឋាចូរឲ្យរាជសម្បត្តិដល់យើងឬ ឬមួយនឹងច្បាំងគ្នា ក៏តាមតែសព្វព្រះរាជហឫទ័យចុះ ។

ចំណែកព្រះមហាក្សត្របានជ្រាបសេចក្តីលិខិតនោះហើយ ក៏ទ្រង់ទោមនស្សតូចព្រះរាជហឫទ័យថា "កាលពីដំបូង ព្រះជេដ្ឋាប្រកែកពុំព្រមទទួលរាជសម្បត្តិ លើកប្រគល់ឲ្យអាត្មាអញសោយរាជ្យស្នងព្រះវររាជបិតា ហើយដាច់ព្រះទ័យចេញទៅគង់នៅក្នុងជនបទ ផ្ញើព្រះរាជសាសន៍មកសុំរបស់អ្វី ៗ អាត្មាអញចេះតែឲ្យរបស់នោះ ៗ គ្រប់មុខតាមសុំ មិនជំទាស់ឲ្យខុសអធ្យាស្រ័យ លុះដល់មកគ្រានេះចង់បានរាជសម្បត្តិទៀត បើអាត្មាអញធ្វើសង្គ្រាមក៏បានដែរ ប៉ុន្តែ ជយោ មេ ភវិស្សតិ បើអាត្មាអញច្បាំងឈ្នះមុខជាអ្នកប្រាជ្ញតិះដៀលអញ ឯព្រះជេដ្ឋាក៏ចងពៀរវេរានឹងកើតទោសមានកម្មពៀរនឹងគ្នាទៅភពខាងមុខទៀត បើអាត្មាអញច្បាំងចាញ់ហើយព្រះជេដ្ឋាក៏បានសោយរាជ្យ បណ្តាពួកបរិស័ទរបស់អញនឹងវិនាសបាត់បង់ជីវិតអស់ជាច្រើន ឯការសង្គ្រាមតែងមានសេចក្តីទុក្ខលំបាកដូចគ្នា ទាំងពីរខាង តែងស្លាប់ដូចគ្នា ទាំងពីរខាង នឹងកើតការទុច្ចរិតមានអបាយភូមិជាខាងមុខ; ណ្ហើយចុះ! កុំធ្វើឲ្យអ្នកប្រាជ្ញតិះដៀលអញផងកុំធ្វើឲ្យមានទោសមានពៀរទាំងបច្ចុប្បន្ននឹងអនាគតផង" ៗ ព្រះមហាក្សត្រទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបផ្ញើព្រះរាជសាសន៍តបទៅវិញថា "សូមអញ្ជើញព្រះជេដ្ឋាស្តេចយាងចូលមកសោយសិរីរាជសម្បត្តិ តាម

ព្រះរាជហឫទ័យចុះ" ។

ចំណែកព្រះជេដ្ឋា ហេតុតែលុះទៅក្នុងអំណាចលោភចេតនាខ្លាំងពេក គ្មានសេចក្ដីអៀនខ្មាសសោះ ក៏បានសោយរាជសម្បត្តិគតិព្រះរាជ-កនិដ្ឋាវៀងទៅ ។

ឯលោភនេះ បើមានខ្លាំងក្លាក្នុងចិត្តអ្នកណាហើយ ជាហេតុធ្វើចិត្តអ្នកនោះឲ្យកាត់កាល់ញាតិទំនងមិត្រជាទីស្រឡាញ់ចោលចេញ គិតតែពីខាងមានខាងបានសម្បត្តិអ្នកដទៃមកជារបស់ខ្លួនម្យ៉ាងប៉ុណ្ណោះ ។ ហេតុនេះ អ្នកមានបញ្ញាគួរតែខំកំចាត់បង់លោភសង្កត់សង្កិនលោភកុំឲ្យកើតមានក្នុងចិត្តខ្លាំងពេក ។

ប្រការមួយទៀត អ្នកណាមានចិត្តលោភលន់ពន់ប្រមាណ អ្នកនោះត្រូវគិតភយន្តរាយ ដែលនឹងកើតមានដល់ខ្លួនគិតឲ្យតែពីខាងបានប៉ុណ្ណោះ ដូចជាកូនប្រុសស្រីរបស់ដូនចាស់ដកម្នាក់ សូមនាំយករឿងនេះមកសំដែងបញ្ជាក់ឲ្យយល់ច្បាស់អំពីទោសរបស់លោភដូចតទៅនេះ ៖

(នៅមានត)

មធុរសភា ហ៉ាណី

## សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឺន ពិនិត្យ

( តមក )

---

### ចោរសហាយវត្ថុកថា

សំដែងរឿងនិទានបុរសជាសំឡាញ់នឹងចោរតទៅទៀត ដោយករបាលីថា. អញ្ញាតរំ ភគវតិ បរិនិព្វុតេ ដូច្នេះជាដើម ។

អធិប្បាយជាសេចក្ដីថា: កាលព្រះមានព្រះភាគជាម្ចាស់នៃយើងទ្រង់ចូលព្រះបរមនិព្វានទៅហើយ ។ កាលនោះ ក្នុងជម្ពូទ្វីបនេះ មានមនុស្សកំសត់ម្នាក់នៅក្នុងទេវទហនគរ បានត្រាច់ទៅកាន់ស្រុកជនបទមួយ ហើយបាននៅសំណាក់អាស្រ័យក្នុងផ្ទះត្រកូលជាសំឡាញ់នាស្រុកជនបទនោះឯង ។

ឯមនុស្សទាំងឡាយដទៃក៏បានឲ្យបាយទឹកបរិភោគ ចិញ្ចឹមរក្សាទុកក្នុងជនបទនោះ ។ ពីនោះមក បុរសបានធ្វើមិត្តសន្ថវស្និទ្ធស្នាលជាមួយនឹងមនុស្សទាំងឡាយនៅក្នុងស្រុកនោះ យ៉ាងក្រៃលែង ប៉ុន្តែគាត់ពុំដែលទៅកាន់ទឹកដែនដទៃឡើយ ។ លុះនៅបានប្រមាណជាពីរបីថ្ងៃខាងក្រោយមកបុរសនោះក៏ប្រព្រឹត្តធ្វើនូវចោរកម្មលួច ឆក់ទ្រព្យគេមកសម្រេចកិច្ចចិញ្ចឹមជីវិតខ្លួនក្នុងទីនោះ ។

ខាងក្រោយមកទៀត រាជបុរសទាំងឡាយចាប់បុរសអ្នកលួចនោះនាំយកទៅថ្វាយព្រះមហាក្សត្រិយ៍ ព្រះអង្គក៏ត្រាស់បង្គាប់ពេជ្ឈឃាដថា អ្នកទាំងឡាយត្រូវចងបុរសនេះឲ្យមាំហើយនាំយកទៅដាក់ក្នុងគុកទៅ ។

ឯពេជ្ឈឃាដទាំងឡាយ ក៏បានទទួលព្រះរាជឱង្ការហើយចងបុរសនោះនាំយកទៅឯផ្ទះគុកដាក់ច្រវាក់ទុកក្នុងទីនោះ ហើយចាត់គ្នីគ្នាឲ្យនៅចាំរក្សាដ៏មាំមួន ទើបត្រឡប់មកកាន់ផ្ទះខ្លួនទីទៃវិញហោង ។

កាលបើបុរសអ្នកលួចនោះបាននៅក្នុងផ្ទះគុក កន្លងទៅអស់វេលា ១២ ឆ្នាំហើយ ក្រោយពីនោះមកមានមនុស្សម្នាក់ទៀតនៅក្នុងបច្ចន្តគ្រាមធ្លាប់ជាមិត្រសំឡាញ់នៃបុរសដែលជាប់គុកនោះឯង បានធ្វើដំណើរមកកាន់ទេវទហនគរដោយកិច្ចអ្វីមួយ, ក៏បានដើរទៅជិតផ្ទះគុកនោះ ហើយបានឃើញបុរសជាសំឡាញ់កំពុងជាប់ទោសដូច្នោះ មានចិត្តអាណិតអាសូរញាប់ញ័រយ៉ាងខ្លាំង ទើបទ្រហោយំបម្រះទនៀលសួរថា: ម្នាលសំឡាញ់មានគុណស្មើ! តើអ្នកមានអំពើកំហុសដូចម្តេចបានជាគេយកអ្នកមកដាក់គុកដូច្នេះ ?

ឯចោរនោះ លុះបានស្តាប់ពាក្យសួរហើយ ក៏និយាយប្រាប់ដំណើរនោះថា: អើ! សំឡាញ់អើយ ខ្ញុំបានមកជាប់នៅក្នុងផ្ទះគុករងទុក្ខវេទនាកន្លងទៅយ៉ាងនេះអស់វេលា ១២ ឆ្នាំហើយ សំឡាញ់អើយ; កាលយូរលង់ប៉ុណ្ណោះ ខ្ញុំនៅតែសេចក្តីទុក្ខលំបាកយ៉ាងធំ ពុំដែលបាន

បរិភោគភោជនឆ្អែតផល់មួង ការដែលបានបរិភោគម្ដងៗ នោះ គឺពុំដែល
បានភោជនល្អឆ្ងាញ់ពិសាឡើយ បានតែភោជនអាក្រក់ស្មោកគ្រោកជា
និច្ច, ប្រសិនបើខ្ញុំបានដើរចេញទៅស្វែងរកអាហារបរិភោគឲ្យបាន
ឆ្អែតហើយត្រឡប់មកវិញដកបណា សូមសំឡាញ់មេត្តាជួយរកឧបាយ
ដោះខ្ញុំឲ្យបានរួចអំពីគុកនេះ ចេញទៅរកអាហារបរិភោគដកបនោះឯង ។

ឯអ្នកបញ្ជូនគ្រាមជាសប្បុរសនោះ លុះបានស្ដាប់ពាក្យសំឡាញ់អង្វរ
ករដូច្នោះហើយក៏ពោលជាបទព្រះគាថាដូច្នេះថា:

រូបេន កិន្នុ គុណសីលវិវជ្ជិតេន
មិច្ឆាលយស្ស កឹ តវស្ស សិយា កិមត្ថំ
ឆាជាតិចាតវិកេន ច ធនេន កឹ វា
មិត្តេន កឹ ព្យសនកាលបរាមុខេន ។

អធិប្បាយថា : ប្រយោជន៍អ្វីដោយរូបខ្ញុំទីធ៍រូបអ្នកដែលប្រាសចាក
គុណធម៌ទីធ៍សីលធម៌ (នេះ) ប្រយោជន៍អ្វីដល់អ្នកដែលនៅអាស្រ័យគន្ធគុក
(នេះ) ប្រយោជន៍អ្វីដោយទ្រព្យសម្បត្តិដែលមិនបានបរិច្ចាគធ្វើបុណ្យមាន
ឲ្យទានជាដើម(នេះ) ប្រយោជន៍អ្វីដោយកាលដែលដល់នូវសេចក្ដីវិនាស
កន្ទានមុខព្រោះប្រាសចាកមិត្ត (នេះ)! លុះបញ្ជូនគ្រាមបុរសជាសំឡាញ់
បានពោលគាថាយ៉ាងនេះហើយ ក៏និយាយផ្ទួនទៅនឹងសំឡាញ់អ្នកនេ

គ្រោះថា៖ អ្នករងគ្រោះជាសំឡាញ់អើយ ! ការនេះប្រពៃហើយ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នកពិត ៗ លុះថាហើយក៏ដើរចូលទៅកាន់សំណាក់នៃអមាត្យអ្នករក្សាហើយនិយាយអង្វរករសូមទោសថា៖ បពិត្រលោកទាំងឡាយដ៏ចំរើនអើយ! ប្រសិនបើបុរសដែលជាប់ទោសនោះ បានដើរទៅស្វែងរកបាយបរិភោគឆ្អែតបរិបូណ៌ហើយ វិលត្រឡប់មកវិញដរាបណា ខ្លួនខ្ញុំសូមធ្វើជាអ្នកធានាបុរសនោះក្នុងទីនេះដរាបនោះ សូមលោកនាយទាំងឡាយលែងបុរសនោះឲ្យចេញទៅស្វែងរកអាហារបរិភោគចុះ ៗ

ចំណែកឯអមាត្យអ្នកឆ្មាំទាំងឡាយក៏ពោលតបវិញថា៖ ម្នាលបុរសដ៏ចំរើន ! យើងទាំងឡាយមិនអាចនឹងហ៊ានលែងបុរសនេះឡើយ ក្នុងពេលបុរសនោះចេញទៅមិនទាន់វិលត្រឡប់មកវិញដរាបណា បើអ្នកសុខចិត្តឲ្យយើងដាក់ច្រវាក់អ្នកដរាបនោះ ទើបយើងអាចហ៊ានលែងបុរសនេះបាន បើអ្នកមិនឲ្យយើងដាក់ច្រវាក់អ្នកទេ យើងពុំអាចហ៊ានលែងបុរសនេះបានឡើយ ៗ សំឡាញ់ជាសប្បុរសនោះបានស្តាប់ហើយក៏ទទួលព្រមហើយឲ្យដោះច្រវាក់អំពីជើងនៃបុរសអ្នកទោសជាសំឡាញ់នោះ យកមកដាក់ជើងរបស់ខ្លួនវិញ រួចហើយក៏ចូលទៅនៅក្នុងផ្ទះគុកជាជំនួសបុរសជាសំឡាញ់នោះទៅ ៗ

ចំណែកឯជនជាអសប្បុរសនោះ លុះបានរួចអំពីចំណងគឺច្រវាក់ហើយ ក៏ដើរចេញទៅស្វែងរកអាហារ កាលបើបានអាហារបរិភោគ

ឆ្អែតហើយ ក៏ពុំបានត្រឡប់មកកាន់ទីផ្ទះគុកនោះវិញឡើយ គឺដើរចេញទៅកាន់ទីដទៃទៅ ។

អហោ នុយើងទាំងឡាយអើយ ! គួរខ្លាចគួរដឹងនូវអំពើរបស់បុគ្គលជាឥតកតញ្ញូដ៏អាក្រក់ពន់ពេកណាស់, ព្រោះហេតុដូច្នោះ បានជាព្រះគន្ថរចនាចារ្យលោកពោលជាបទព្រះគាថាដូចនេះថា :

ភារិយ្យោ យថា សោណ្ណោ ធវល្ដោ វិសមំ សមំ

បញ្ញាយតេភសាធុស្ស ឯវំ មធសិ សម្ភវំ ។

អធិប្បាយថា: បឹងធំមានទឹកពេញពោរពាស តែថាទីដីខាងក្នុងបឹងរាបស្មើក្ដី ពុំរាបស្មើក្ដី នោះពុំប្រាកដឡើយ មានឧបមាយ៉ាងណា អំពើកោងកាចកើតឡើងក្នុងចិត្តនៃបុគ្គលជាអសប្បុរស គេពុំបានឃើញច្បាស់ មានឧបមេយ្យយ៉ាងនោះឯង ។

ភាសន្តិ មុខតោ ឯកំ ចិន្តេន្តិ មនសា បរំ

កាយេនេកំ ករោន្តិ បកតាយំ អសាធុនំ ។

អសប្បុរសទាំងឡាយតែងពោលពាក្យដោយមាត់មួយយ៉ាង គិតដោយគំនិតដទៃមួយយ៉ាង ធ្វើកម្មដោយកាយមួយយ៉ាង នេះជាធម្មតារបស់បុគ្គលជាអសប្បុរសទាំងឡាយដោយពិត ។

តេសំ យោ ភារំ បដិញ្ញា សោរ បណ្ឌិតជាតិកោ

ពហុស្សុតោបិ សោយេវ បរចិត្តវិទូបិ សោ ។

មួយទៀតបុគ្គលណាបានដឹងច្បាស់នូវសេចក្ដីប្រព្រឹត្តវៀចវេរ នឹងការស្មោះត្រង់នៃជនជាអសប្បុរសទាំងនោះ បុគ្គលនោះឯងបានឈ្មោះថាជាអ្នកប្រាជ្ញ ទាំងបានឈ្មោះថាជាពហូស្សូតដោយពិត, ព្រោះបុគ្គលនោះបានដឹងបានស្គាល់នូវចិត្តនៃបុគ្គលដទៃនោះឯង ។

ក្រោយពីនោះមក ជនជាសប្បុរសដែលបានទទួលទោសជំនួសសំឡាញ់នោះក៏បាននៅក្នុងផ្ទះគុកប្រមាណ ១២ ឆ្នាំ ហើយតែងមានសេចក្ដីស្រេកឃ្លានបៀតបៀនជានិច្ច ពុំដែលបានដើរចេញទៅស្វែងរកអាហារបរិភោគឲ្យឆ្អែតដល់ម្ដងឡើយ, គឺពប់ថ្ងៃដែលបានបរិភោគនោះតិចពន់ពេក ឯថ្ងៃដែលមិនបានបរិភោគនោះច្រើនក្រៃលែង ម្ល៉ោះហើយមានរូបកាយស្គមថមថយកម្លាំង នៅតែស្បែកនឹងឆ្អឹង សោយទុក្ខលំបាកឥតទីពឹងឡើយ ។

លុះកន្លងទៅបាន ១២ ឆ្នាំ, កាលនោះព្រះរាជបុត្រារបស់ព្រះបរមក្សត្រិយ៍ក៏បានប្រសូតចេញចាកផ្ទៃព្រះមាតាមកដោយសិរីសួស្ដីដ៏ប្រសើរ ។ ចំណែកឯព្រះបរមក្សត្រិយ៍ ព្រះអង្គបានទតឃើញព្រះភក្ត្រាព្រះរាជបុត្រហើយ ក៏មានព្រះរាជហឫទ័យសោមនស្សជ្រះថ្លា ត្រាស់បង្គាប់ឲ្យសេវកាមាត្យទាំងឡាយដោះលែងអ្នកទោសទាំងអស់ចេញ អំពីផ្ទះគុកក្នុងកាលនោះឯង ។

(នៅមានត)

មហោសធជាតក

# លោក អ៊ុម-ភគ បម្លងពីសាស្ត្រាស្លឹករឹត

*ព្រះពុទ្ធវង្ស គឹម - តួរ ពិនិត្យ*

( តមក )

---

ពោធិសត្តោ តំ វីមំសនត្ថាយ តំ ទោវារិកស្ស គេហេ ឋបេត្វា ទោវារិកកិរិយាយ អាចិក្ខិត្វា អត្តនោ ឯវ· សធំ គន្ត្វា បុរិសេ អាមន្តេត្វា ។ បេ ។ បពិត្រអើយ ! ឮដំកាលនោះកូរ , ពោធិសត្វនឹងចង់ល្បងលនាងអមរា ទើបមានព្រះបន្ទូលថា កន្ទេ ម្នាលនាងដ៏ជាភរិយាទេវីស្រីសំឡាញ់ស្ងួនបងអើយ ! នាងអើយ ! ឥឡូវនេះបងនឹងផ្ញើទុកនាងនៅនាផ្ទះនាយទ្វារនេះសិនហោង បងនឹងចូលទៅមុន ម្ល៉ោះហើយ ក៏ចៅមហោសធអ្នកប្រាជ្ញ អាចលីលាយាត្រា ទៅដល់ផ្ទះអាត្មា ហើយស្រដីទៅនឹងបុរសម្នាក់ថា ហៃបុរសអើយ ! អញបាននាំយកនូវស្រីម្នាក់មកផ្ញើទុកនាទ្វារផ្ទះអ្នកចាំទ្វារនោះ, ចូរព្រះវស្តង យកនូវមាសមួយពាន់ដំឡឹង ទៅឲ្យស្រីនោះលងមើល , បុរសនោះទៅធ្វើដោយនូវពាក្យបង្គាប់ពោធិសត្វ ហើយថា អម្ម ហៃនាងអមរាអើយ ! ចូរនាងទៅនៅនឹងអញ ។ ឲ្យមាសមួយពាន់ដំឡឹង ។ នាងអមរា នាងមិនប្រាថ្នាស្រឡាញ់ចង់បានមាសនោះឡើយ នាងថា មាសមួយពាន់ដំឡឹង មិនស្មើល្អងធូលីជើងប្ដីខ្ញុំនេះ

ឡើយ ។ បុរសនោះត្រឡប់មកសំដែងប្រាប់ចៅមហាសេដ្ឋីកម្រាដ្ឋ, ចៅមហាសេដ្ឋីកម្រាដ្ឋអាចប្រើ បុរសដទៃទៅទៀត ជាគំរប់បី-បួនដងក្តី រីនាងអមរា នឹងបានមានចិត្តប្រាថ្នាដល់តិចតួចនោះឥតគង់មានឡើយ ។ បុរសនោះវិលមកប្រាប់ពោធិសត្វ ព្រះអង្គប្រើឲ្យបុរសនោះទៅចាប់ដៃនាងអមរានាំចូលមកឰដ៏ឋាននេះ នាងមកដល់យល់ពោធិសត្វចិតនឹងឥស្សរសម្បត្តិមានសិរីសួស្តី នាងក៏ពុំស្គាល់ជាពោធិសត្វឡើយ ស្មានជាព្រះមហាក្សត្រ នាងសើចហើយយំវិញ ។ រីពោធិសត្វព្រះអង្គជ្រាបនូវប្រការទាំងពីរដំពូកនោះហើយ មានបន្ទូលដណ្ដឹងថាហៃនាងអើយ ! អម្បាញ់មិញនាងសើចឥឡូវនេះនាងយំវិញ តើហេតុដំណើរដូចម្តេច ? ចូរនាងប្រាប់មកឲ្យបានដឹង ។ ទើបនាងអមរាឆ្លើយថា បពិត្រអម្ចាស់អើយ ! ខ្ញុំមើលឥស្សរសម្បត្តិអម្ចាស់ច្រើនហេតុអំពើកុសលផលបុណ្យអំពីមុននាយអម្ចាស់បានសាងមក ទើបបានសម្បត្តិទាំងនេះ ហេតុនោះបានជាខ្ញុំសើចអរនឹងផលអម្ចាស់បានសាងអំពីមុនច្រើនមកហើយ, ឥឡូវនេះ ខ្ញុំយំវិញ ហេតុអម្ចាស់រកទដណ្តើមកូនអ្នកដទៃគេក្នុងព្យាបាល ហើយអម្ចាស់នឹងទៅសោយទុក្ខវេទនានៅឯនរកនាយ ហេតុនោះខ្ញុំយំវិញហោង ។

សោ តំ វីមំសិត្វា តស្សា បរិសុទ្ធភាវំ ញត្វា . . . .

រីពោធិសត្វលងនាងអមរា ដឹងសុភាពបរិសុទ្ធហើយ ក៏ពោធិសត្វប្រើ

បុរសនោះថា ម្នាលព្រះស្តែងអើយ ! ចូរអ្នកនាំនាងនេះទៅទុកនាឋានដែលវិញ ទើបបុរសនោះធ្វើតាមបង្គាប់ពោធិសត្វ, រីពោធិសត្វអ្នកយកកៀសអាត្មាជាអ្នកប៉ាក់ផុលវិញទៀត ទៅដេកសំកន្ទុជាមួយនឹងនាងនោះហោង, លុះព្រឹកឡើង ពោធិសត្វចូលទៅកាន់ត្រកូលស្តេចនាព្រឹកនោះឯង, ពោធិសត្វសំដែងប្រាប់នាងឧទុម្ពរទេវីជាអគ្គមហេសី ទេពីនៃព្រះបាទវិទេហរាជ ៗ នាងទូលស្តេចជ្រាបហើយ ឲ្យប្រដាប់គ្រឿងតាំងតួងប្រយោជន៍នឹងឲ្យទទួលពោធិសត្វ នូវនាងអមក ឲ្យឡើងជិះលើរទេះដ៏ប្រសើរ នាំមកផ្ទះព្រះមហោសថអ្នកប្រាជ្ញ នឹងបរិវារនោះច្រើន ឲ្យរណ្តាប់ជាមង្គលប្រសើរហោង ៗ

រាជា ពោធិសត្តស្ស សហស្សមូលំ បណ្ណាការំ បេសេសិ ។ ទោវារិកោ អាទឹ កត្វា សកលនគរវា-សិនោ បណ្ណាការេ បដ្ឋយឹសុ ។ ក្នុងកាលនោះ, ស្តេចឲ្យជូននូវគ្រឿងបណ្ណាការដល់ពោធិសត្វជាដើម គឺមាសមួយពាន់ដំឡឹង, អ្នកចាំទ្វារក្តី អស់អ្នកនគរនោះក្តីក្ដី ស្តេចនឹងជូននូវគ្រឿងបណ្ណាការផងមកពោធិសត្វ នូវនាងអមកហោង នាងក៏ទទួលយកគ្រឿងបណ្ណាការដែលស្តេចឲ្យជូននោះ, នាងក៏បង្វែបែងជាភាគពីរ, ភាគមួយឲ្យនាំទៅថ្វាយបញ្ចូលឃ្លាំងស្តេចវិញហោង, ភាគមួយនោះ នាងឲ្យជូនគ្រឿងបណ្ណាការផងទៅអស់អ្នកនគរទាំងឡាយ សឹងចងជាមិត្តយកចិត្ត

ជាមេត្រី ៗ ចាប់ដើមអំពីកាលសម័យថ្ងៃនោះទៅ ព្រះបរមពោធិសត្វ ក៏នៅរួមសមគ្គសំវាសជាមួយនាងអមរាទេវីនោះ ដោយការព្រមព្រៀងគ្នា វញ្ញា អត្តញ្ញូ ធម្មញ្ញូ អនុសាសិ ហើយព្រះអង្គទ្រង់ណែនាំ ប្រៀនប្រដៅនូវអាថិធម៌ដល់ព្រះមហាក្សត្រតរៀងទៅ ៗ

អមរទេវី បរិយេសនំ និដ្ឋិតំ រឿងស្រដីសរសើរដំណើរ ដំណាលអំពីចំណោះប្រាជ្ញាពោធិសត្វកាលស្វែងរកនាងអមរាទេវី នាំយកមកជាភរិយានោះវិញ ក៏ស្រេចដោយនូវប្រការអម្បាលនេះហោង ៗ

អថេកទិវសំ សេនកោ ឥតរេ តយោ អត្ត-
នោ សន្តិកំ អាគតេ ទិស្វា តេ អាមន្តេត្វា អម្ភោ
មយំ គហបតិបុត្តស្ស មហោសធស្ស ឆប្បហោម
លំដាប់នោះ, មានកាលសម័យថ្ងៃមួយ, អាចារ្យទាំងបីមកអំពីលំនៅអាត្មា យល់ហើយស្រដីនឹងអាចារ្យសេនកថា ហៃអាចារ្យសេនកអើយ! យើង ឥតអំណាចស្មើនឹងចៅមហោសថកូនគហបតីសិរិវឌ្ឍកសេដ្ឋីនោះឡើយ, ឥឡូវនេះ ចៅមហោសថនាំប្រពន្ធអំពីណាមក មានប្រាជ្ញាឈ្លាសវៃក្រពេកដោយខ្លួនឯង, អ្នកទាំងបីថាបើដូច្នោះហើយ តើយើងនឹងរកឧបាយកលធ្វើចៅមហោសថកណ្ដាលជំនុំស្ដេចនូវប្រការដូចម្ដេច?ៗ អាចារ្យសេនកថា បើអ្នកពុំដឹង មាលអ្នកទាំងឡាយអើយ! កុំបីអ្នកបារម្ភឡើយ, អញមានឧបាយកលមួយ ៗ អាចារ្យទាំងបីថា ហៃអាចារ្យ

អើយ ! គលឧបាយនោះតើដូចម្តេច ? ៗ រីអាចារ្យសេនកស្រដីថា អញទៅលួចយកនូវចុឡាមណីរតន៍ស្តេច ហើយអញឲ្យនាំទៅទុកនៅផ្ទះអញ; អាចារ្យបុក្កុស ; ចូរព្រះស្តែងទៅលួចនូវសុវណ្ណមាលាមាស នាំមកទុកនៅផ្ទះ, អាចារ្យកាមិន្ទ ចូរព្រះស្តែងទៅលួចសំពត់រត្តកម្ពល: អាចារ្យទេវិន្ទ ចូរព្រះស្តែងទៅលួចសុពណ្ណបាទុកមាស នាំមកទុកនៅផ្ទះយើងទីទៃ ៗ ហើយយើងកុំឲ្យអ្នកឯណាដឹងឡើយ , ហើយយើងធ្វើឧបាយកលមួយទៀត គឺយើងរកខ្ញុំស្រីមួយម្នាក់ ៗ ៗ ម្នាក់ ៗ ឲ្យទុកដាក់នូវទ្រព្យឲ្យកំបាំង ហើយឲ្យទៅលក់ឯផ្ទះមហោសថកូនគហបតីសេដ្ឋី នោះហោង ៗ រីអាចារ្យទាំងបីទទួលយកពាក្យអាចារ្យសេនកហើយ ធ្វើដោយបង្គាប់នោះស្រេច , រីឯអាចារ្យសេនកយកចុឡាមណីរតន៍មកទុកក្នុងទឹកក្អមមួយ បន្ទើឲ្យដៃស្រីមួយឲ្យយកទៅទុកលក់ ហើយផ្តាំថា បើអ្នកដទៃឯណាមួយគេនឹងទិញយក មេកុំបីលក់ឲ្យឡើយ បើមានមនុស្សអំពីមហោសថក្តី ឬក៏មកដល់ផ្ទះប្រពន្ធមហោសថឯងក្តី ឲ្យមេលក់ឲ្យទៅហោង ៗ រីមេស្រីនោះ ទទួលយកពាក្យអាចារ្យសេនកស្រេចហើយ យកទឹកក្អមទៅដល់ផ្ទះមហោសថអ្នកប្រាជ្ញ ហើយស្រដីថា ហៃអ្នកផ្ទះអម្ចាស់ខ្ញុំអើយ ! ចូរអ្នកទិញទឹកក្អមទុកពិសា ហើយរ៉ដើរចូលទៅនាទ្វារផ្ទះហៅមហោសថហោង ៗ អមរាទេវី ទ្វារេ ឋិត្វា តស្ស ភរិយំ ទិស្វា . . . រីនាងអមរាទេវី, កាលនោះនាង

បិតនៅនាទ្វារផ្ទះអាត្មា នាងយល់នូវអំពើស្រីមួយនោះពុំដើរទៅទឹងទៀត ឡើយ, នាងរំពឹងគិតថា វិអាថ៌ប្រស្នានេះ សូម្បីមានឯងមិនទេឡើយ នាងប្រើខ្ញុំស្រីទាំងឡាយឲ្យទៅប្រាប់ ឲ្យមេស្រីនោះថយចេញទៅលក់ទឹង ទៀត, រីស្រីនោះក៏មិនទៅទឹងទៀតឡើយ ; ឯនាងអមកានាងយល់មេស្រី នោះពុំដើរទៅទឹងទៀតហើយ, នាងឲ្យហៅមកកាន់ផ្ទះនាងហើយនាង ផ្ដឹងថា ហៃក្មេងក្រមុំព្រហ្មចារីសំដីពីរោះអើយ! មេតើឈ្មោះអ្វី? ។ រីមេនោះប្រាប់ថា អម្ចាស់ខ្ញុំឈ្មោះមេតាសី ខ្ញុំស្រីអ្នកអាចារ្យសេនក ប្រើខ្ញុំមកលក់ក្អមទឹកនោះហោង ។ នាងអមកាផ្ដឹងឈ្មោះម្ដាយអាពុក មេនោះ ។ ប្រាប់ថា ម្ដាយខ្ញុំឈ្មោះ (មារ) អាពុកខ្ញុំឈ្មោះ (នកអន្ទូល) ដោយខ្ញុំសំគាល់យសគាត់ខ្ពស់ធំប្រដាង ពោះធំកំប៉ោង ហើយក្បាល ទំពែកផង នោះហោងអាពុកខ្ញុំ ។ រីនាងអមកាធ្វើសំបុត្រសន្មតកត់ជា ចំណាំ ថ្ងៃព្រហស្បតិ៍ពេញបូណ៌មីខែពិសាខ អាចារ្យសេនកប្រើខ្ញុំមក ជូនគ្រឿងប្រដាប់ដល់មកផ្ទះចៅមហោសថនោះហោង, នាងយកហើយ នាងឲ្យដំណើរមេនោះទៅផ្ទះអាចារ្យសេនកវិញហោង ។ បុក្កុសោបិ សុវណ្ណមាលំ សុមនបុប្ផចង្កោដកេ ឋបេត្វា តំ បុប្ផេហិ ឆាទេត្វា បេសេសិ ។ កាមិន្ទោបិ កម្ពលំ បណ្ណបច្ឆិយំ ឋបេត្វា បណ្ណេហិ ឆាទេត្វា បេសេសិ ។ ទេវិន្ទោ សុវណ្ណបាទុកំ យវកលាបន្តរេ ឋបេត្វា

បរិសេសិ ។ រីអាចារ្យបុក្កុសយកសុវណ្ណមាលាមាសទុកក្នុងប្រអប់ដាក់ផ្កាភ្ញីប្រើជូនមកផ្ទះចៅមហោសថ ។ អាចារ្យកាមិន្ទយកសំពត់រត្តកម្ពលទុកក្នុងកញ្ជើហើយយកបន្ទាស្រស់ដាក់លើ ប្រើជូនមកផ្ទះចៅមហោសថអ្នកប្រាជ្ញ ។ អាចារ្យទេវិន្ទ យកសុពណ៌បាទុកមាសចងទុកក្នុងស្រូវកណ្តាប់ ហើយប្រើជូនមកដល់ផ្ទះចៅមហោសថអ្នកប្រាជ្ញ ។ រីនាងអមរទទួលយកគ្រឿងប្រដាប់បណ្ណាការទាំងនោះហើយនាងស្រាយតែងប្រាប់ឈ្មោះអាត្មា ខ្ញុំស្រីទាំងអម្បាលនោះ សរសេរត្រាឈ្មោះទុកក្នុងសំបុត្រដូចយើងសំដែងហើយបង្ហាញពោធិសត្វ គឺព្រះមហោសថអ្នកប្រាជ្ញអាចយកទុកទៅហោង ។

តេបិ ចត្តារោ បណ្ឌិតា រាជកុលំ គន្ត្វា កឹ ទេវ ចុឡ្ឌមណឹ ន បិលន្ធថាតិ អាហំសុ ។ រាជា បិលន្ធិស្សាម អាហរថាតិ អាហ ។ តេ គន្ត្វា តត្ថ ចុឡ្ឌមណឹ អទិស្វា ឥតរានិ តីណិបិ ន បស្សឹសុ យេវ ។ អថ តេ ចត្តារោបិ ទេវ តុម្ហាកំ អាករណានិ មហោសធស្ស គេហេ វសន្តិ សោ តានិ សយំ វលញ្ជេតិ បដិសត្តុ តេ មហារាជ គហបតិបុត្តោតិ តំ បរិភិន្ទឹសុ ។ រីអាចារ្យទាំង ៤ ឡើងទៅគាល់ស្តេចវិទេហរាជ ហើយធ្វើជាទូលថា ទេវ បពិត្រអម្ចាស់ខ្ញុំអើយ ! សព្វថ្ងៃ

រៀងមក ព្រះអង្គទ្រង់នូវគ្រឿងប្រដាប់ចុឡាមណីរ័តន៍ នូវមកុដអាភម អន្ទាមព្រះស្បូវង៍មណីរ័តន៍, ឥឡូវនេះ បទអ៊ុំក៏ស្តេចពុំទ្រង់ឡើយ ៗ តំ សុត្តា កជា អាឃា ស្តេចស្តាប់អាចារ្យទាំង ៤ ទូលនូវប្រការអម្បាលនោះហើយ, ស្តេចប្រើបំរើទៅយកអស់គ្រឿងប្រដាប់ចុឡាមណី-រ័តន៍មកស្តេចនឹងទ្រង់, អាមាត្យទៅរកចុឡាមណីរ័តន៍ពុំយល់នូវគ្រឿងប្រដាប់ទាំង ៤ ប្រការនោះឡើយ ក៏ត្រឡប់មកទូលស្តេច ស្តេចក្រោធពិរោធក្រៃពេក ៗ អាចារ្យទាំង ៤ ទូលថាដូច្នេះ ទេវ បពិត្រអម្ចាស់អើយ ! វិច្ឆមអម្ពរគ្រឿងប្រដាប់នោះ ដូចទៅនៅនាផ្ទះ ចៅមហោសថនាយនោះហើយមិនទេឡើយ, បូរអម្ចាស់ឲ្យទៅសួរពតិមានប្រការយ៉ាងណា នូវមហោសថនោះឃើញហោង, បពិត្រមហារាជអើយ ! ព្រះមហោសថកូនគហបតីនោះ សឹងជាមិត្តទ្រុស្តអម្ចាស់; បូរអម្ចាស់ឲ្យចាមចាប់ចៅមហោសថនោះ ធ្វើទុក្ខធ្វើទោសដោយនូវព្រះរាជទណ្ឌនោះហោង ៗ

លំដាប់នោះ, រីអស់មនុស្សម្នាមហាជនផង ឮពាក្យអាចារ្យទាំង ៤ នាក់ចូលទូលស្តេចដូច្នោះហើយ សឹងនាំគ្នាទៅសំដែងប្រាប់ព្រះមហោ-សថ ៗ ឯព្រះមហោសថសោតវិញគិតថា អញនឹងទៅឲ្យស្តេចយល់ស្តេចខ្ញាល់នឹងអញ បើដូច្នោះ អញមិនឲ្យយល់ខ្លួនអញឡើយគួរអញនឹងរត់ចៀសចេញកុំឲ្យស្តេចឃើញអញហោង, ម៉្លោះហើយចៅមហោ-សថឲ្យប្រាប់នាងអមរា ដ៏ជាភរិយាឲ្យជាដំណឹង ហើយយកសំពត់

តាស់ដំជាមន្ទិលស្មៀកកៀសពុំឲ្យគេស្គាល់គ្នា ហើយចេញទៅអំពីនគរ បវរកជបាទពិមានៈស្ដួចវិទេហរាជដ៏ជាធំប្រសើរហោង, ហើយដើរចេញ ទៅដោយនាទិសទក្ខិណាយវមជ្ឈកគ្រាម ហើយក្លែងខ្លួនធ្វើជាអ្នកស្ងួន ឆ្មាំង, រីអ្នកនគរទាំងឡាយបានឮថា ចៅមហោសថអ្នកប្រាជ្ញវត់ចៀស ចេញ ហើយជាគោលាហលវិលវល់មួយអន្លើទៅវិញទៅមកក្រែពេក ហោង ។ ក្នុងកាលនោះ, រីអាចារ្យទាំង៤នាក់ មានអាចារ្យសេនក ជាដើម ដឹងសុភាពជាចៅមហោសថវត់បាត់ហើយ ក៏ក្រោកដោះឡើង ទះទ្រូងទះស្មាអរឯងស្រដីថា ម្នាលអ្នកទាំងឡាយអើយ! ឥតនឹងចៅ មហោសថហើយ យើងកុំគិតបារម្ភឡើយ, ម្ល៉ោះហើយយើងមិនឲ្យ អ្នកទាំងឡាយទីទៃ ៗ ដឹងឡើយ ហើយយើងឲ្យជូននូវគ្រឿងបណ្ណាការ ឲ្យនាងអមរា ហើយយើងនឹងយកជាភរិយាសង្ហារយើងហោង ។ អា-ចារ្យទាំង ៤ សឹងធ្វើដោយគំនិតនោះហើយ, នាងអមរាទទួលយកគ្រឿង បណ្ណាការដែលអាចារ្យទាំង ៤ ឲ្យជូនមកនោះ ហើយនាងផ្ដាំថា ឲ្យ អាចារ្យសេនក មកពីល្ងាចព្រះអាទិត្យអស្ដង្គតលិចបាត់ស្មើងនឹងវេលា ថ្មើរនេះ ឲ្យគាត់មកកាន់អញហោង នាងឲ្យដំណើរទៅហើយ ហៅ អស់ខ្ញុំស្រីទាំងឡាយឲ្យជីករណ្ដៅមួយ ហើយឲ្យចាក់បំពេញនូវលាមក ស្មើនឹងទឹក, ឯមាត់រណ្ដៅបង្គន់នោះគ្របនូវក្ដារយន្តហើយក្រាលកន្ទេល គ្របពីលើ ហើយឲ្យរណ្ដាប់ទឹកអប់ត្រឡប់នូវគន្ធពិដោរស្រេចហើយ,

តស្មឹ បទោសកាលេ សេនកោ អត្តានំ អលង្ករិត្វា ចានក្ករសកោដ្ឋំ កុញ្ចិត្វា ពោធិសត្តស្ស គេហំ អាគមាសិ ៗ សោ ទ្វារេ ឋត្វា អត្តនោ អាគតភាវំ ជានាបេត្វា ឯកសបរិត្តហំ អមរទេវិយា អារោចា-បេសិ ៗ សា តស្ស វចនំ សុត្វា ឯហីតិ អាហ ៗ សោ គន្ត្វា តស្សា សន្តិកេ អដ្ឋាសិ ៗ ក្សណនោះ, អាចារ្យសេនក ធ្វើដោយបណ្តាំពាក្យនាងអមរា ហើយរៀបចំមកមុនពេលនោះបន្តិច ឲ្យទៅប្រាប់នាងអមរាថា អញនាំអាត្មាមកដល់ហើយ នាងអមរាថា អើជាហើយ ឲ្យគាត់មកហោង ៗ អាចារ្យសេនកទៅកាន់សំណាក់នាងអមរាទៅដោយចំណង់ចិត្ត, លំដាប់នោះ, នាងអមរាថានឹងអាចារ្យសេនកនូវពាក្យដូច្នេះថា ហៃអ្នកអើយ! ឥឡូវនេះ អញលុះដោយនូវអំណាចអ្នកហើយ ចូរអ្នកធ្វើដូច្នេះ អ្នកទៅដួតទឹកកក់សិតសក់ជំរះអាត្មាឲ្យជ្រះស្រះមន្ទិលក្អែលញើសសិនឡើងអ្នកមកហោង ៗ រីអាចារ្យសេនកស្តាប់ពាក្យនាងអមរាហើយថា ហៃនាងអើយ ! សាធុពីរោះ ៗ ពេកហោង, ម្នោះហើយអាចារ្យសេនកដោះឡើង ចេញទៅអង្គុយនឹងធ្វើដោយពាក្យនាងអមរាបង្គាប់នោះ, រីអស់ខ្ញុំស្រីរបស់នាងអមរា ក៏នាំគ្នានឹងយកទឹកស្រោចកក់ ក៏រះជាន់ក្តារយន្តនោះ ឰដ៏កាលនោះ រជួស់គន្លឹះក្តារយន្តនោះ របូតអាចារ្យសេនកធ្លាក់ចុះទៅក្នុងរណ្តៅនោះ

ហោង, ឯអាចារ្យទាំង ៣ នាក់នោះ សឹងដើរមកដោយលំដាប់គ្នា ដូចដំណើរនិយាយពីអាចារ្យសេនកមុននោះហោង, រីសូម្បីអ្នកទាំង ៤ នោះឋិតនៅក្នុងរណ្ដៅដំពៅបង្គន់លាមកនោះឋិតជិតគ្នា បើនឹងអង្គុយប្រមាណទឹមមាត់ ឯក្បាលប្រជុំគ្នា ហើយអាត្មាអាចារ្យសេនកប្រាប់ស្ដាប់ថា នរណានេះ, អាចារ្យបុក្កុសថា នរណានេះ រីអាចារ្យសេនកសោត ថាទៅវិញទៅមកនឹងអាចារ្យបុក្កុស ហើយស្រដីថា យើងធ្វើដូចម្ដេចឥឡូវនេះ? ៗ អាចារ្យបុក្កុសថា វើយ អ្នកអើយ! កុំស្រដីខ្លាំងពេក, អំពើនោះសោត យើងខ្មាសអស់មហាជនទាំងឡាយណាស់ហោង ម្ល៉ោះហើយកុំស្រដីខ្លាំងពេក ៗ អាចារ្យទាំង ៤ នាក់នោះ សឹងឋិតនៅក្នុងរណ្ដៅបង្គន់នោះអស់មួយរាត្រីនោះហោង ៗ

រីនាងអមរាបញ្ចោះអ្នកប្រាជ្ញទាំង ៤ នាក់នោះឲ្យការជាអាក្រក់មានសភាពជាបង្ហូរដូច្នេះហោង, លុះព្រឹកឡើង នាងឲ្យអូសចេញហើយបង្គាប់អស់មហាជនទាំងឡាយ ឲ្យយកពួរទៅចងអ្នកប្រាជ្ញទាំង ៤ នាក់អូសឡើងអំពីក្នុងរណ្ដៅបង្គន់នោះ ហើយឲ្យងូតទឹក, ឲ្យកោរក្បាល, ហើយឲ្យដុសនឹងឥដ្ឋឲ្យចេញឈាម ហើយឲ្យត្រាំអង្ករដាល់ជាម្សៅឲ្យកូរជាបបរឲ្យរាប់ ឲ្យលាបស្រឡាបអំពីក្បាលអាចារ្យទាំង ៤ នាក់អស់ទាំងខ្លួនស្រេចហើយ ឲ្យយកសំឡីថ្ពបញ្ចីល្អិត ឲ្យផ្ដិតអស់សព៌ាង្គកាយឲ្យដាក់ច្រុងរុំនឹងកន្ទេលចងខ្សែភ្ជាប់ហើយ នាងអមរាយកគ្នាឲ្យសែងទៅ

មួយអន្លើនឹងនាង យកទៅថ្វាយស្ដេចទតអ្នកទាំង ៤ នោះ, នាងបិតនៅ ហើយទូលស្ដេចថា បពិត្រមហារាជអើយ! អញ្ជើញម្ចាស់រមិលមើលដង្វាយទាំងឡាយនេះហោង, រីកន្ទេលរុំអ្នកទាំង ៤ នោះ នាងឲ្យលើកទៅដាក់ទៀបខាងព្រះបាទវិទេហរាជ ។ ស្ដេចឲ្យបើកនូវដង្វាយនោះហើយ ទ្រង់ទតព្រះនេត្រទៅឃើញអ្នកប្រាជ្ញទាំង ៤ នាក់ មានអាចារ្យសេនកជាដើមមានពណ៌ដូចជាស្វាស ហើយព្រះអង្គគង់ស្ងៀមនៅ ។

លំដាប់នោះ, រីអស់បណ្ដាមហាជនផងទាំងឡាយ លុះឃើញអាចារ្យទាំង ៤ នោះដូច្នោះហើយ ក៏នាំគ្នាសើចនូវសំណើចដ៏ខ្លាំងគងរំពងឡើង, សូម្បីអ្នកទាំង ៤ នោះខ្មាសគេច្រើនយ៉ាងណាក៏ដោយ ៗ ពេលនោះនាងអមរាទេវីទូលថា ទេវ បពិត្រអម្ចាស់អើយ! រីសភាពប្ដីខ្ញុំនេះមិនជាចោរឡើយ, បពិត្រអម្ចាស់អើយ! ព្រះមហោសថពុំជាទោសសត្រូវអ្វីនឹងអម្ចាស់, នាងអមរាទូលទៀតថា បពិត្រអម្ចាស់អើយ! រីអ្នកទាំង ៤ នាក់នេះ សឹងជាចោរពិតហោង ; ឯអាចារ្យសេនកគាត់ជាចោរលួចចុឡាមណីកែវអម្ចាស់, អាចារ្យបុក្កុសគាត់ជាចោរលួចសុវណ្ណ-មាលាអម្ចាស់, អាចារ្យកាមិន្ទគាត់ជាចោរលួចសំពត់កម្ពលអម្ចាស់, អាចារ្យទេវិន្ទគាត់ជាចោរលួចសុវណ្ណបាទុកអម្ចាស់, រីអ្នកទាំង ៤ នេះប្រើឲ្យផ្ញើទៅដល់អញខ្ញុំ ៗ យកអំពីដៃខ្ញុំស្រីក ឈ្មោះដូច្នេះ, មានកំណត់ថា ថ្ងៃដូច្នេះ ខែដូច្នេះ ឆ្នាំដូច្នេះ, ចូរអម្ចាស់រមិលមើលគង់

សំបុត្រអញខ្ញុំ ហើយសូមអញ្ជើញអម្ចាស់ទទួលយកព្រះរាជទ្រព្យវិញ ហោង, នាងថា បពិត្រមហារាជអើយ! វីអ្នកទាំង ៤ នាក់នេះ ឲ្យអម្ចាស់ទទួលយកជាចោរហោង, នាងធ្វើអ្នកទាំង ៤ នាក់ ឲ្យដល់នូវវិប្បការលំបាកពិការជាច្រើននូវប្រការអម្បាលនោះហើយ នាងថ្វាយបង្គំព្រះមហាក្សត្រត្រឡប់លីលាមកកាន់ផ្ទះអាត្មានាងវិញហោង ។ លំដាប់នោះ, ស្ដេចមិនសន្និះសង្ស័យកុងសុភាពពោធិសត្វរតនោះឡើយ, ហេតុពុំមានអ្នកប្រាជ្ញក្រៃលែងនោះនឹងតែងចំរើន, ទើបស្ដេចពុំមានបន្ទូលនឹងអ្នកប្រាជ្ញទាំង ៤ នោះដល់តិចឡើយ, ហើយទើបស្ដេចមានបន្ទូលប្រើអាមាត្យទាំង ៤ ឲ្យងូតទឹកហើយបញ្ជូនទៅផ្ទះអាត្មាទីទៃ ៗ ហោង ។

ចត្តាពេ បណ្ឌិតចោរា ឆដ្ឋិតា ។ នេះនឹងស្រដីពីអ្នកប្រាជ្ញទាំង ៤ ជាចោរលួចព្រះរាជទ្រព្យស្ដេចនេះមិញ កំសុះបចោយនូវប្រការអម្បាលនេះហោង ។

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

## វប្បធម៌ខ្មែរ

# វប្បធម៌ផ្ដិតជាប់ក្នុងប្រវត្តិសាស្ត្រ

លោក លី · ធាមតេង

សមាជិកក្រុមអភិបាល សមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

---

កាលណា គេពោលពីវប្បធម៌ គេតែងតែនឹកឃើញដល់ប្រវត្តិសាស្ត្រនៅពេលជាមួយគ្នានោះដែរ ព្រោះប្រវត្តិសាស្ត្រនេះ ជាជម្រុកផ្ទុកនូវកេរ្តិ៍ខ្មាត ឬ ហេតុការណ៍គ្រប់បែបគ្រប់យ៉ាងនៃវប្បធម៌យើង ឬ បើពោលឲ្យឆាយស្ដាប់ជាងនេះបន្តិចទៅទៀតថា ៖ ដើម្បីសិក្សាឲ្យបានយល់ច្បាស់ប្រាកដអំពីវប្បធម៌ គេត្រូវតែសំគីឈ្វេចឈ្វេសង្កេតក្នុងប្រវត្តិសាស្ត្រឲ្យបានល្អិតល្អន់ជាមុនសិន ។ ប្រវត្តិសាស្ត្រជាកញ្ចក់ ឬ កែវថតចុះជាប់នូវរឿងរ៉ាវរបស់ជាតិតាមយុគតាមសម័យ ដែលមានមកជាហូរហែតាមរយៈសតវត្សដែលកន្លងផុតទៅ ។

បើពោលពីសារៈសំខាន់របស់ប្រវត្តិសាស្ត្រដូចនេះ នាំឲ្យយើងភ្ញាក់ចិត្តនឹកឃើញដល់ប្រវត្តិសាស្ត្រជាតិយើង ដែលជាជាតិមួយមានរឿងរ៉ាវពង្សាវតារជាអង្វែងមកយូរឆ្នាំ យូរសតវត្សហើយថា ៖ តើប្រវត្តិសាស្ត្រ

យើងសព្វថ្ងៃស្ថិតនៅឯណាខ្លះ? មានចងជាក្បួនគ្រប់គ្រាន់សព្វគ្រប់ហើយឬនៅ? ឯការសិក្សារបស់កុលបុត្រ-ធីតាយើង ត្រូវចេះប្រវត្តិសាស្ត្រជាតិខ្លួនឬទេ? សំនួរទាំងអម្បាលម៉ាននេះ នាំឲ្យយើងសញ្ជឹងរិះរកចំឡើយ ដើម្បីជាការត្រិះរិះពិចារណារបស់អ្នកអានទស្សនាវដ្ដីយើងដូចតទៅ ៖

ជាយូរឆ្នាំមកហើយ ប្រវត្តិសាស្ត្រពុំទាន់មានជាក្បួនជាក្រាំងគម្ពីរមូលមត់នៅឡើយ ៗ ឯការកត់កយនេះ ពុំមែនកើតឡើងដោយចាស់ព្រឹទ្ធាចារ្យយើងឥតគំនិតនោះទេ គឺបណ្ដាលមកពីហេតុភេទស្រុកទេសចេះតែបង្ខិតបង្ខំឲ្យយើងបាត់បង់ឯកសារ នឹងដានជាក់លាក់ដែលជារឿងរ៉ាវក្នុងប្រវត្តិសាស្ត្រយើង ៗ ដូច្នេះ រឿងរ៉ាវទាំងនោះ នៅចាំត្រឹមតែលើមាត់មនុស្សណាដែលបានជួបប្រទះព្រឹត្តិការណ៍នោះ ៗ ៗ លុះជនទាំងនោះស្លាប់បាត់បង់ទៅ រឿងរ៉ាវក៏បាត់រូបឆោមច្បាស់លាស់ទៅជាមួយដែរ នៅសល់តែស្រមោលខ្លះក្នុងស្មារតីរបស់អ្នកដែលចងចាំជាដំណ ៗ មកនឹងពុំមានភាពពិតអះអាងឲ្យជាប់ខាតបានផង ៗ ក្រៅពីនេះ មានឯកសារជាទិដ្ឋានុរូបខ្លះនៅលើចារឹកថ្ម គឺមានចារជាអក្សរលើផ្ទាំងសិលា ទីងឆ្លាក់រូបភាពលើផ្ទាំងជញ្ជាំងប្រាសាទនានា មានប្រាសាទអង្គរធំ, អង្គរវត្ត នឹងបន្ទាយស្រីជាដើម ៗ រូបភាពទាំងនោះ សម្ដែងពីជីវភាពរស់នៅរបស់អ្នកស្រុកយើង ( អង្គរធំ ) នឹង ព្រឹត្តិការណ៍សង្គ្រាមព្រមទាំង

ជំនឿក្នុងលទ្ធិសាសនាណាមួយ សំរាប់ជាកស្តុតាងឲ្យយើងសព្វថ្ងៃយល់បានថា កាលសម័យនោះ ៗ យើងមានការរស់នៅបែបណា? មានជំនឿអ្វីខ្លះ? មានសង្គ្រាម ឬទេ? ពិធីបរពលប្រព្រឹត្តទៅដូចម្តេច? ៗ ប៉ុន្តែឯកសារទាំងនេះ ពុំទាន់បានជាពិតមានគ្រប់គ្រាន់សព្វគ្រប់ទេ ព្រោះច្រើនតែមានត្រង់នេះ ឥតត្រង់នោះ ពោះ ៗ តាមការយល់ ឬ តាមមនោគតិអ្នកចារ ឬ អ្នកឆ្លាក់ ៗ ហេតុហ្នឹងហើយ បានជាយើងយល់ថា នៅខ្វះចន្លោះច្រើនអន្លើទៀត ដែលយើងត្រូវតែដឹង ត្រូវការចង់ដឹងយ៉ាងប្រាកដប្រជាគ្រប់ពេលគ្រប់សម័យ ក្នុងប្រវត្តិស្រុកទេសយើង ៗ

បំណោរតមក នៅក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះអង្គ-ចន្ទ ព្រះអង្គបានប្រជុំអ្នកកត់ត្រាឲ្យប្រមូលនូវរឿងរ៉ាវខ្លះ ៗ កត់ត្រាទុកដោយគោលៗ ឡើង ៗ លុះមកដល់រជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមា-ធិបតីព្រះអង្គ-ឌួង កំណត់ហេតុទាំងនេះ ក៏បានរួបរួមជាក្រាំងជាសៀវ-ភៅមួយឡើង គ្រាន់ជាគ្រឿងបំភ្លឺរហូតមកដល់សព្វថ្ងៃនេះ ៗ

មានឯកសារមួយពួកទៀត កើតបានជារូបរាងឡើងដោយមតិជនជាតិបរទេស ដែលគេធ្វើដំណើរមកកាន់ប្រទេសយើងកាលពីសម័យមុន ហើយគេបានកត់ត្រាហេតុការណ៍ស្រុកទេសយើង ដើម្បីផ្សាយឲ្យទៅក្នុងប្រទេសគេ មានជាតិចិន, ជាតិពរទុគេស៍ និង អេស្ប៉ាញ៉ុល ជាអាទិ៍ ៗ ពិតមែនតែឯកសារទាំងនេះ ពុំហួរហែសព្វគ្រប់ តែអ្នក

ប្រាជ្ញជាតិបារាំង សម័យដែលធ្វើជាអាណាព្យាបាលស្រុកយើង គេបានបង្កើតជាមន្ទីរស្រាវជ្រាវមួយ ដើម្បីប្រមូលរាវរកឯកសារពីគ្រប់ប្រភពដែលស្ដីពីប្រទេសយើង ហើយបោះពុម្ពផ្សាយឲ្យកូនចៅខ្មែររៀនសូត្រតាមគេរៀបចំតែងនោះ ៗ ប៉ុន្តែ មកដល់បច្ចុប្បន្នកាលនេះ ជាសម័យដែលយើងត្រូវពិនិត្យសិក្សាពីវប្បធម៌យើងឡើងវិញដោយខ្លួនយើង ហេតុនេះក្បួនខ្នាតខាងប្រវត្តិសាស្ត្រ ក៏ត្រូវសើរើរៀបចំឡើងវិញដោយខ្លួនយើងដែរ ដើម្បីរាវរកឫសគល់ច្បាស់យកមកផ្សាយឲ្យកុលបុត្រ-ធីតាយើងទៅក្រោយ ៗ រៀនសូត្រយ៉ាងច្បាស់ពីធាតុពិត ៗ របស់មាតុភូមិជាទីស្រឡាញ់របស់យើង ។ ឯការកសាងក្បួនខ្នាតប្រវត្តិសាស្ត្រនេះ ពុំអាចធ្វើឡើងដោយកំឡាំងឯកជនបានឡើយ ដ្បិតខ្វះមធ្យោបាយសំរាប់បំពេញកិច្ចការទាំងនោះឲ្យជាក់លាក់ ។ ដូច្នេះ ត្រូវតែធ្វើដោយកំឡាំងរួបរួមអ្នករិះស្រាវជ្រាវច្រើនរូប ដោយប្រមូលយកឯកសារពីប្រភពសំខាន់ ៗ ទាំងប្រាំគឺ ៖ ១– សិលាចារឹក, ២ ព្រះរាជពង្សាវតារខ្មែរដែលមាននៅពុទ្ធសាសនបណ្ឌិត្យស្រាប់, ៣ ឯកសារចិន, ឯកសារជាតិពរទុគេស៍ នឹង អេស្ប៉ាញ៉ុល, ៥– រឿងព្រេងដែលនៅប្រចាំភូមិពាសពេញក្នុងប្រទេសយើង ។ កាលណាគណៈកម្មការស្រាវជ្រាវបានឯកសារទាំងនេះមកហើយ គណៈកម្មការអាចផ្ទៀងផ្ទាត់ដោយប្រៀបធៀបហេតុការណ៍មួយ នឹង ហេតុការណ៍មួយទាល់តែរកឃើញការពិត

ហើយបង្កើតឡើងវិញ ដោះពុម្ពផ្សាយឲ្យបានទូទៅក្នុងប្រទេសយើង ជាពិសេសក្នុងមជ្ឈដ្ឋានសិក្សានានា ។

ហេតុទាំងប៉ុន្មាន ដែលពោលមកហើយខាងលើនេះ គ្រាន់តែបញ្ជាក់ចំពោះមតិយើងដែលយល់ថា៖ វប្បធម៌យើងពិតជាផ្អឹតជាប់នៅក្នុងប្រវត្តិសាស្ត្រ ។ គឺថាបើសិក្សាពីវប្បធម៌ខ្មែរ ត្រូវសិក្សាពីប្រវត្តិសាស្ត្រខ្មែរជាបឋម បើត្រូវការចាំបាច់ក្នុងការសិក្សាពីប្រវត្តិសាស្ត្រយ៉ាងនេះ ប្រវត្តិសាស្ត្រក៏ត្រូវតែមានភាពជាក់លាក់ឡើងដែរ ដើម្បីគ្រោលបំភ្លឺវប្បធម៌ជាតិឲ្យមានរស្មីប្រាលរន្ទាលឡើងក្នុងសន្តានចិត្តជនជាតិយើង ។ មូលហេតុទាំងនេះឯង ដែលជាបញ្ហាមួយជាកាតព្វកិច្ចថា : ប្រវត្តិសាស្ត្រយើងក៏ត្រូវតែកសាងឡើងជាការចាំបាច់ដែរ ។

(នៅមានត)

# ពាក្យខ្មែរប្រែចេញពីបរទេស

## ដោយគណៈកម្មការវប្បធម៌

(តមក)

| | | |
|---|---|---|
| Calamité | *n. f.* | វិបត្តិភ័យ |
| Calamiteux | *adj.* | មានវិបត្តិភ័យ |
| Sinistre | *n. m.* | ជាបគ្រោះ |
| Malheur | *n. m.* | អភមង្គល |
| Exploitation | *n. f.* | អាជីវកម្ម, ទោហនកម្ម |
| Compte d'exploitation | | គណនីទោហនកម្ម |
| Compte de résultat ou de profit et de perte | | គណនីលទ្ធផលឬគុណប្រយោជន៍និងការខាតបង់ ។ |
| Plus-value | *n. f.* | អធិកលាភ |
| Compte financier | | គណនីហេរញ្ញិក |
| Compte d'actif, du passif | | គណនីសកម្ម, អកម្ម |
| Aval | *n. m.* | រូបិយបដិភោគ |
| Avaliste | *n. m.* | រូបិយបដិភោគី |
| Profit brut | | គុណប្រយោជន៍ ដុល |
| Profit net | | គុណប្រយោជន៍ សុទ្ធ |
| Ne varietur | | អបរិណាម |
| Roche stratifiée | | សិលាស្តរិត |
| Fossile | | ជាសាណីភូត |
| Spath d'Islande | | ស្ប៉ាត |
| Gneiss | *n. m.* | ញ៉ែស |

(នៅមានត)

# វចនានុក្រមសំស្ក្រឹត.ខ្មែរ

*ព្រះមហា ម៉ាន់ - ខាត់ រៀបរៀង*

តមក

---

អតិមុត្តិ ស្រ្តី. កិរិយារួចក្រៃលែង ។

អតិមុខរ គុ. ដែលនិយាយច្រើន ។

អតិមុគ្ធ គុ. ដែលផ្លូវជ្រើមក្រៃលែង, ដែលផ្លូវច្របល់ ។

អតិមុទិ ធាតុ. រួចក្រៃលែង ។

អតិមូឍ គុ. ដែលឆ្កួតក្រៃលែង ។

អតិមូត្យ គុ. ដែលមានមូត្យក្រៃលែង, (ដែលរួចពីមូត្យ)

អតិមូទ៑ ធាតុ. បំផ្លាញក្រៃលែង ។

អតិមូទ៑ហ្ទ៑យតា ស្រ្តី. ភាពនៃបុគ្គលមានហឫទ័យទន់ភ្លន់ក្រៃលែង។

អតិមោក្ស បុំ. កិរិយារួចក្រៃលែង, មោក្ខធម៌ដ៏ប្រសើរ ។

អតិយត្ន បុំ. សេចក្តីព្យាយាមដ៏ក្រៃលែង ។

អតិយន្ត្រណា ស្រ្តី. សេចក្តីបង្ក្រៀតបង្កល់ក្រៃលែង ។

អតិយឝ ឬ អតិយឝស៑ គុ. ដែលមានយសក្រៃលែង ។

(នៅមានត)

## កណ្ឌទី ៤៥

ទុកញ៉ាំវិបុលពជសេនា ឆ្លូ-កិន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ៗ

ទៀវហៀនទីប្រឹក្សាក៏និយាយនឹងស៊ុនក្វនថា ដែលជាហេតុដូច្នេះព្រោះលោកលើកកំពស់ខ្លួនមើលងាយមិនខ្លាចដល់សឹកសត្រូវ មិនស្រូវរាំងការពាររក្សាខ្លួន ឯប្រពៃណីការសង្គ្រាមនេះគួរនឹងប្រើទាហានដែលមានថ្វីដៃខ្លាំងពូកែចេញច្បាំងជាមុន មិនត្រូវមេទ័ពនឹងចេញច្បាំងដោយខ្លួនឯងជាមុនទេ ខ្លួនលោកជាធំមិនសមនឹងមិនពិគ្រោះមើលការគួរឬមិនគួរប្រញាប់តែចេញទៅតច្បាំងនឹងទៀវលៀវ ដែលត្រឹមតែជានាយទាហានប្លាខជាមានសេចក្ដីថ្លស់ការខូចខាតទាហានឯកយ៉ាងនេះ គួរឲ្យស្ដាយណាស់ស៊ុនក្វនទទួលខ្លួនថា ខ្ញុំធ្លោយខ្លួនខុសហើយ អ្នកនិយាយនោះត្រូវណាស់ ការដែលថ្លស់ធ្លោយដូច្នេះ ព្រោះយើងគិតខុសដោយខ្លួនឯង ៗ

ខណៈនោះ ថៃស៊ីជួក៏ចូលមកជំរាបស៊ុនគួនថា កោតេងបាវខ្ញុំបាទមានបងប្អូនឈ្មោះ “ អាវ៉េតា ” ជាមនុស្សឃ្លាលសេះរបស់ទៀវលៀវ អាវ៉េតាគ្មានទោសខុសពីអ្វីសោះ ទៀវលៀវយកខ្លួនទៅធ្វើទោស អាវ៉េតាមានសេចក្ដីខឹងក្ដៅក្រហាយឲ្យមនុស្សមកប្រាប់ខ្ញុំបាទថា ពេលយប់នេះ អាវ៉េតានឹងគិតសម្លាប់ទៀវលៀវចេញ ហើយដុតភ្លើងឡើងជាសំគាល់ ខ្ញុំបាទនឹងសុំទាហានលើកទៅធ្វើការជាមួយនឹងអាវ៉េតា មុខជានឹងសងសឹកជំនួសស៊ុនខៀមបាន ។

ស៊ុនគួនសួរថា ឥឡូវកោតេងនៅឯណា ថៃស៊ីជួថា កោតេងបន្ទំជាទាហានទៀវលៀវចូលទៅក្នុងស្រុកហ័បប៉ាហើយ ស៊ុនគួនឮដូច្នោះក៏មានអំណរណាស់ ទើបចាត់ទាហាន ១ ពាន់ឲ្យថៃស៊ីជួ ជួកាត់កិនក៏និយាយនឹងថៃស៊ីជួថា ទៀវលៀវនោះមានជម្រេះប្រាជ្ញានឹងថ្វីដៃខ្លាំងពូកែណាស់មុខជាមិនធ្វេសប្រមាទ អ្នកត្រូវរិះគិតឲ្យល្អិតល្អ កុំអាលមើលងាយទៀវលៀវនោះឡើយ ថៃស៊ីជួមិនបានឆ្លើយតបថាម្ដេច ក៏លាស៊ុនគួនលើកទាហានចេញតាកបន្ទាយទៅ ។

ឯកោតេងដែលបន្ទំជាទាហានទៀវលៀវ ចូលទៅក្នុងស្រុកហ័បប៉ានោះ ក៏និយាយនឹងអាវ៉េតាថា ថ្ងៃមិញយើងឲ្យមនុស្សទៅប្រាប់ថៃស៊ីជួ ថៃស៊ីជួផ្ដាំមកថា ពេលយប់នេះនឹងលើកទាហានមកចាំខាងក្រៅកំផែងស្រុក ការខាងក្នុងនេះអ្នកនឹងរិះគិតប្រការម្ដេច អាវ៉េតាថា ទីលំនៅដែល

ខ្ញុំស្នាក់នៅនេះ ជិតទៀបកន្លែងទៀវលៀវណាស់ ពេលយប់នេះខ្ញុំនឹងយកភ្លើងដុតគំនរចម្បើងឲ្យឆេះភ្លឺឡើង បើកាលណាភ្លើងឆេះហើយឲ្យអ្នកស្រែកថា សត្រូវចូលស្រុកបានហើយ ពួកអ្នកស្រុកទាំងអស់គ្នាមិនទាន់ដឹងការគេនឹងភ្ញាក់ផ្អើលច្របូលច្របល់កែវកវឡើង បើទៀវលៀវនឹងមកលត់ភ្លើង ខ្ញុំនឹងលបចាក់ទៀវលៀវឲ្យស្លាប់ កោគេងឮដូច្នោះក៏យល់ឃើញត្រូវ ។

ឯទៀវលៀវកាលដែលត្រឡប់ចូលទៅក្នុងស្រុកហ័បប៉ាវិញ ក៏ត្រួតត្រាតក្បាទាហានទាំងអស់ឲ្យយាមល្បាតហើយបង្គាប់ថា ពេលយប់នេះអ្នកពល់គ្នាកុំបីប្រមាទ ឲ្យរិះគិតការពាររក្សាខ្លួនឲ្យមែនទែន ត្រូវតែពាក់គ្រោះសៀតអាវុធដេកគ្រប់គ្នា ទាហានទាំងពួងឆ្លើយថា កាលពីថ្ងៃដែលយើងមានជ័យជំនះ ស៊ុនគួនបែកបាក់ទៅហើយ លោកនឹងឲ្យរង់រក្សាដោយហេតុអ្វី ? ទៀវលៀវថា ធម្មតាអ្នកដែលជានាយកងនាយទ័ពនឹងធ្វើការសង្គ្រាមនោះ បើចាញ់ក៏កុំអាលតូចចិត្តណាស់ បើបានជ័យជំនះក៏កុំអាលត្រេកត្រអាលណាស់ កាលពីថ្ងៃដែលយើងបានជ័យជំនះហើយ បើប្រមាទធ្លោយក្រែងស៊ុនគួនមានចិត្តគិតក្ដៅឃើញថាយើងភ្លើតភ្លើន ក៏នឹងលើកទាហានមកបោមវាយ យើងនឹងមិនអន្តរាយទេឬ ហេតុនេះបានជាយើងហាមប្រាមអ្នកពល់គ្នាឲ្យប្រុងប្រយ័ត្នដោយហេតុនេះ ។

ខណៈកាលទៀវលៀវកំពុងនិយាយនឹងទាហាននោះ ក៏ឃើញភ្លើង

ឆេះឡើងក្នុងខាងក្រោយបន្ទាយហើយស្រែកថា សត្រូវចូលស្រុកបានហើយ ពួកអ្នកស្រុកទាំងពួងក៏ភ្ញាក់ផ្អើលច្រួលច្របល់វរវឹកសន្ធឹកណាស់ ទៀវលៀវឃើញដូច្នោះក៏តក់ស្លុតក្នុងចិត្តទើបឡើងសេះនាំទាហាន ៤ នាក់ចេញទៅឈរទទឹងផ្លូវ ទាហានស្រែកថា ឮសំឡេងជិតណាស់មកហើយមុខជាសត្រូវនឹងចូលមកដល់ ទៀវលៀវថាមិនទាន់ឃើញអ្វីជាបំឡែកទេ វាធ្វើក្លែងដូច្នេះប្រាថ្នានឹងឲ្យមនុស្សទាំងអស់គ្នាភ្ញាក់ផ្អើលទេ ហើយទៀវ-លៀវក៏ប្រាប់ទាហានទាំងពួងថា បើនរណាផ្អើលវឹកវរនឹងឲ្យកាត់ក្បាលចេញ ឲ្យនាំគ្នាចាប់ខ្លួនឈ្មោះណាជាដើមហេតុឲ្យបាន ប្រហែល ១ ម៉ោងលើទៀនក៏ចាប់ខ្លួនកោតេងនឹងអាវចោមកឲ្យទៀវលៀវ ៗ សួរសាកដឹងសេចក្តីហើយ ក៏ឲ្យទាហាននាំខ្លួនកោតេងនឹងអាវចោទៅប្រហារជីវិត ៗ ទទួលសំឡេងទាហាន វាយឈ្មោះគងទូងស្គរហ៊ោកញ្ច្រៀវអឺងកងក្រៅស្រុក ទៀវលៀវក៏និយាយនឹងទាហានទាំងពួងថា កងទ័ពស៊ុនគួនលើកមកចាំធ្វើការតាមសញ្ញាកោតេងហើយ យើងត្រូវគិតត្រួតកលស៊ុនគួនឲ្យបានវិញ ទៀវលៀវ ក៏ឲ្យទាហានយកភ្លើងដុតឡើងក្នុងស្រុក ហើយបើកទ្វារចេញស្រែកថា សម្លាប់សត្រូវចូលស្រុកបានហើយ ៗ

ថៃស៊ូជូឮដូច្នោះក៏សំគាល់ថា កោតេងនឹងអាវចោធ្វើការសម្រេចហើយក៏បំផាយសេះជ្រែកមកមុខទាហានៈទៅក្នុងស្រុក ទៀវលៀវឲ្យយកធ្នូបាញ់បម្រុះចូលមកទាំងសងខាងផ្លូវ ត្រូវថៃស៊ូជូជាច្រើនអន្លើ ថៃស៊ូជូ

ក៏យំណាស់គឺញាក់សេះត្រឡប់ទៅវិញ ទៀវលៀវក៏ឲ្យនឹកជិនដេញពីក្រោយថៃស៊ិជូទៅដល់មុខបន្ទាយស៊ុនគួន, ឡុកស៊ុនទឹងតាំងសិតឃើញជូបោះក៏លើកទាហានចេញមកជួយថៃស៊ិជូ លីទៀនទឹងនឹកជិនដេញកាប់សម្លាប់ទាហានថៃស៊ិជូស្លាប់ជាច្រើន ហើយឃើញឡុកស៊ុន តាំងសិតចេញមកជួយថៃស៊ិជូ លីទៀនទឹងនឹកជិនក៏លើកទាហានត្រឡប់ចូលទៅស្រុកវិញ ឡុកស៊ុនទឹងតាំងសិតក៏នាំថៃស៊ិជូចូលទៅក្នុងបន្ទាយ ស៊ុនគួនឃើញថៃស៊ិជូ ត្រូវរបួសព្រួញឈឺចាប់ជាទម្ងន់ជាច្រើនអន្លើ ឃើញថាទឹងមិនរស់ជីវិត ក៏នឹកអាណិតណាស់ ៗ

ទៀវលៀវនិយាយនឹងស៊ុនគួនថា យើងលើកទ័ពមកគ្រានេះ ឃើញខូចខាតទាហានច្រើនណាស់ គ្រានេះថៃស៊ិជូក៏ពិការធ្ងន់ទៅទៀត សុំឲ្យលើកទ័ពត្រឡប់ទៅស្រុកយើងសិនចុះ ទឹងបានរិះគិតការគេទៅទៀត ស៊ុនគួនក៏យល់ឃើញត្រូវ ទើបចាត់ឲ្យទាហានរៀបចំទូកចម្បាំងលើកទ័ពត្រឡប់ទៅស្រុកឡាំស៊ី លុះទៅដល់ថៃស៊ិជូក៏រឹតឈឺធ្ងន់ចុះ ស៊ុនគួនក៏ឲ្យទៀវជៀវទៅសួរថៃស៊ិជូ ៗ និយាយនឹងទៀវជៀវថាកើតមកជាកូនប្រុស ទោះបីនឹងស្លាប់ក្នុងទីសង្គ្រាមសឹក ក៏មិនត្រូវនឹកស្តាយអាយុជីវិត ត្រូវតែគិតធ្វើការឲ្យពេញដៃជើង ឥឡូវខ្លួនយើងមកអស់អាយុក៏ពុំនឹងពេញពាលដូច្នេះ ថៃស៊ិជូថាតែប៉ុណ្ណោះក៏ដាច់ខ្យល់ស្លាប់ កាលថៃស៊ិជូស្លាប់

នោះទើបបានអាយុ ៤១ ឆ្នាំ ស៊ិនគួនដឹងថាថៃស៊ីជួស្លាប់ក៏នឹកអាណិត អន្ទោចពន់ប្រមាណណាស់ ទើបឲ្យតែងការសពនាំទៅកប់ទុកនៅជើងភ្នំប៉ាក់ក្លួ ហើយយកថៃស៊ីអៀងជាបុត្រថៃស៊ីជួមកធ្វើការជំនួសបិតា ។

ឯឡៅពីនៅស្រុងកេងជីវ ឮថាស៊ិនគួនលើកទ័ពទៅវាយស្រុកហាប-ប៉ា បរាជ័យនឹងឡេវលៀងត្រឡប់លើកទ័ពមកស្រុកឡាំស៊ី ក៏ហៅខុងបេងមកប្រឹក្សា ខុងបេងថា កាលពីយប់មិញខ្ញុំមើលឫក្សឃើញផ្កាយ ១ ដួងធ្លាក់ចុះមកខាងទិសឯជើងភៀងឯលិច ឃើញថានឹងខូចវង្សរបស់លោកម្នាក់ជាប្រាកដ ទទួលទាហានមកប្រាប់ឡៅពីថា ឡៅគីជាបុត្រឡៅតៀវដែលឈឺនោះស្លាប់ទៅហើយ ឡៅពីឮដូច្នោះ ក៏យំសោកាល័យឡៅគី ខុងបេងក៏និយាយនឹងឡៅពីថា ការដែលកើតមកហើយរមែងជាគូគានឹងសេចក្ដីស្លាប់គ្រប់ ៗ រូបកាយ គេយើងទាំងឡាយនឹងចៀសចាកមិនបានទេ លោកនឹងមកសោកយំដូច្នេះ រោគក៏នឹងបង្កើតឡើង កិច្ចការដែលយើងនឹងគិតធ្វើតទៅនោះក៏ជាច្រើនណាស់ សុំឲ្យលោករះគិតចាត់ទាហានឲ្យទៅនៅរក្សាស្រុកសុងយ៉ុងជំនួសឡៅគីចុះ ។

ឡៅពីក៏ប្រើគួនអ៊ូឲ្យទៅរៀបចំសពឡៅគី ហើយឲ្យនៅរក្សាស្រុកសុងយ៉ុង ឡៅពីក៏និយាយនឹងខុងបេងថា ឥឡូវឡៅគីស្លាប់ហើយ មុខជាស៊ិនគួននឹងឲ្យមកទារយកស្រុកកេងជីវជាប្រាកដ លោកនឹងរះគិតកែខយ៉ាងដូចម្ដេច ខុងបេងថា លោកកុំព្រួយរវល់ជាទុក្ខឡើយ ការនោះជាភ្នាក់

ការរបស់ខ្ញុំនឹងទទួលជាធុរៈ លុះកន្លងមក ១៥ ថ្ងៃ មានទាហានមកប្រាប់ឡៅពីថា ស៊ិនគួនឲ្យឡេឡាសុកមកសួរដំណឹងឡៅតី ខុនបែងក៏បបួលឡៅពីចេញទៅទទួលឡេឡាសុកចូលមកដល់ទីលំនៅ គំនាប់គ្នាហើយឡេឡា-សុកក៏ថាស៊ិនគួនឮថាឡៅតីអនិច្ចកម្ម បានជាប្រើខ្ញុំឲ្យយកធូបទៀនមកសួរជាដំណឹងសពតាមទំលាប់រាប់អាន កាលខ្ញុំនឹងមកនោះដីវយ៉ក៏បានឲ្យពរមកដល់លោកផង ឡៅពីនឹងខុនបែងឮដូច្នោះ ក៏ក្រោកឡើងគំនាប់ទទួលយកធូបទៀន ហើយអញ្ជើញឡេឡាសុកឲ្យបរិភោគអាហារ ខណៈកាលកំពុងសេពសុក ឡេឡាសុកក៏សួរឡៅពីថា ពីដើមលោកបានមានប្រសាសន៍នឹងខ្ញុំថា បើឡៅតីអស់ព្រេងសំណាងហើយ នឹងបង្វិលស្រុកកេងជីវឲ្យស៊ិនគួនវិញ ឥឡូវឡៅតីអនិច្ចកម្មហើយ លោកនឹងបង្វិលស្រុកឲ្យខ្ញុំថ្ងៃណា នឹងបានចាត់អ្នកពជការឲ្យមកឈររក្សាតទៅ ឡៅពីថា អញ្ជើញអ្នកពិសារក្រយាស្រាបាយឲ្យសប្បាយចិត្តសិនចុះ រឿងសឹមប្រឹក្សាគ្នាជាក្រោយ ឡេឡាសុកដំរាស់នឹងឡៅពីមិនបានក៏ស្ងៀមចាំតែបរិភោគអាហារ លុះយូរបន្តិចឡេឡាសុកក៏ឡើងនិយាយទៅឡៅពីទៀត ឡៅពីមិនឆ្លើយថាម្តេច ៗ

ខុនបែងធ្វើជាខឹងនិយាយនឹងឡេឡាសុកថា អ្នកជាមនុស្សមានដម្រេះប្រាជ្ញាដឹងការរាក់ជ្រៅ បើនៅៈស្ងៀមនឹងឲ្យយើងបើកមាត់និយាយផងបានឬ ? កាលគ្រាព្រះចៅហ៊ានកោចានោះ ទ្រង់ក៏មានព្រះទ័យអាសូរករុណា

អស់អាណាប្រជារាស្ត្រទាំងពួង ទើបបានសោយរាជសម្បត្តិព្រះរាជ-វង្សរៀងមក លុះដល់ព្រះចៅហៀនគេសព្វថ្ងៃនេះ ផែនដីក៏នៅមិនទាន់រាបទាប ព្រោះនាម៉ឺនខែត្រខណ្ឌទាំងពួងដែលមានសក្តិកំឡាំងប្រហែលគ្នា ក៏នៅមិនទាន់រួបរួមជួយគ្នាទំនុកបំរុងព្រះចៅហៀនគេសោះ បណ្តា-អាណាខែត្រទាំងអស់ ក៏សឹងតែប្រទូស្តគ្នាមិនចំណុះចូលទៅខាងណាឡើយពីជាចៅហ្វាយខ្ញុំ ក៏ជាពូជព្រះរាជវង្សជាប់លោហិតមកពីព្រះចៅ "ហៅគេងគេ" បាន ២៤ ជួរក្សត្រិយ៍ លុះដល់ឡើយពី ៗ ក៏ជាប់ព្រះចៅហៀនគេ ប្រាកដនោះត្រឹមតែផែនដី ១ ដុំប៉ុនស្រុកគេងដីវប៉ុណ្ណោះ នឹងយកទុកជាទីស្នាក់អាស្រ័យមិនបានឬ ឯស៊ិនគួនចៅហ្វាយអ្នកជាពូជកូយំស្រុកដីតងទេតើ ឥឡូវបានជាធំក្នុងស្រុកកាំងតាំង មានស្រុកទៅ ៦ ដំបន់ ទាំងពលទាហានក៏មាំមួនច្រើនណាស់នៅមិនទាន់ឆ្អែតចិត្តទេឬ ? បានជាឲ្យមកទាស្រុកគេងដីវទៀត មួយទៀតកាលចូឆូលើកទ័ពទឹកទ័ពគោកមករាយស្រុកកាំងតាំងនោះ ឡើយពីក៏បានលើកទាហានទៅជួយច្បាំងជាមាំមួន ទាំងខ្លួនខ្ញុំក៏បានជួយហៅខ្យល់ឲ្យស៊ិនគួន ទើបមិនបានជាអន្តរាយ បើខ្ញុំមិនទៅជួយ កុំថាតែបុត្រីនាងកៀវកុកឡោប៉ុណ្ណោះ ទោះភរិយាបុត្ររបស់អ្នកនឹងជាមិត្តភក្តិរបស់ចូឆូទាំងអស់ ៗ

ឡោស៊ុកឮដូច្នោះក៏មិនបានតបថាប្រការម្តេច ស្ងៀមនៅយូរណាស់ ក៏ឆ្លើយផ្ទាល់តបទៅខុងបេងថា ឯស្រុកគេងដីវនេះជាធុរៈចំពោះលើខ្លួនខ្ញុំ

ផង ដែលលោកមានប្រសាសន៍ប្រៀបធៀបដូច្នេះមិនត្រូវផ្លូវសេចក្តីសោះ ខុងបេងគឺសួរឡោស៊ុកថា ហេតុម្តេចបានជាអ្នកថាមិនត្រូវផ្លូវសេចក្តីឡោ-ស៊ុកថា កាលគ្រាឡើតពីបានសេចក្តីលំបាក បែកទ័ពពីបូបូនៅស្រុកស៊ុងយ៉ុងនោះ ខ្ញុំក៏បាននាំលោកទៅជួបនឹងស៊ុនគួន ខ្ញុំក៏បានខ្ចីស្រុកកេងជីវឲ្យលោក លុះជីវយីលើកទ័ពមកច្បាំងគិតនឹងយកស្រុកកេងជីវវិញ ខ្ញុំក៏បាននិយាយឃាត់ទាំងកំងកមិនឲ្យជីវយីលើកមក បានជាខ្ញុំមកជួបនឹងលោក ។ នឹងឡើតពីក៏បាននិយាយប្តេជ្ញាថា បើឡើតគឺអស់បុណ្យវាសនាកាលណា នឹងបង្វិលស្រុកកេងជីវឲ្យស៊ុនគួនវិញ ខ្ញុំក៏បានរ៉ាប់រងធានា ឥឡូវលោកបែរជាខុសអំពីពាក្យមុន ខ្ញុំនឹងយកសេចក្តីត្រង់ណាទៅដោះសានឹងស៊ុនគួនបាន ឯជីវយីនឹងស៊ុនគួន ក៏រាប់អានលោកនឹងឡើតពីថា មានពាក្យសត្យពិតត្រង់ បើខ្ញុំទៅប្រាប់តាមពាក្យលោកនិយាយ ស៊ុនគួនក៏មិនជឿស្តាប់ ត្រឡប់យកទោសខ្ញុំវិញ ទោះបីខ្លួនខ្ញុំនឹងស្លាប់មិញ ខ្ញុំក៏-មិនស្តាយជីវិត តែនៅគិតបរិវិតក្កថា មុខជាស៊ុនគួននឹងឡើតពីប្រែទៅជាសត្រូវនឹងគ្នា បើឡើតពីនឹងស៊ុនគួនជាខ្មាំងសត្រូវនឹងគ្នាហើយ លោកក៏អស់បានសេចក្តីសុខ មនុស្សអ្នកស្រុកទាំងអស់ក៏នឹងសើចដំនៀលថា លោកជាអ្នកមានដម្រេះប្រាជ្ញាមកបែរជា ត្រឡប់ត្រឡិនមិនពិតត្រង់ បានជាកើតហេតុដូច្នេះ ។

ខុងបេងថា អ្នកកុំនិយាយថ្មី ខ្ញុំនឹងខ្លាចអ្វីដំណួចជីវិតជីវយីប៉ុណ្ណោះ

ព្រោះជាក្មេងតូចណាស់ សូម្បីបូចូទឹងលើកមករាប់រយម៉ឺន ម្តេចខ្ញុំមិនខ្លាច តែខ្ញុំឃើញអ្នកមានសេចក្តីរងក្រែងខុស ខ្ញុំក៏រះគិតទឹងឡោពីសរសេរជា-សំបុត្រសញ្ញាផ្ញើទៅស៊ុនគួន ថាទឹងខ្ចីស្រុកកេងជីវទុកជាទីស្នាក់អាស្រ័យសិន តទៅមុខ បើឡោពីទៅច្បាំងបានស្រុកណា សឹមបង្វិលស្រុកកេងជីវឲ្យវិញ តើអ្នកទឹងយល់ឃើញដូចម្តេច ។

ឡោសុកក៏សួរថា លោកវាយបានស្រុកណាទើបទឹងបង្វិលស្រុកកេងជីវឲ្យវិញ ខុងបេងថា ខ្ញុំគិតទឹងទៅវាយយកស្រុកហ៊ូគោ តែឃើញថាជាស្រុកចំទឹងយកដោយរហ័សឆាប់ពុំបាន ឯស្រុកសៃឈួននោះសោតឡៅជៀងចៅហ្វាយស្រុកជាមនុស្សល្ងង់អាប់ឥតប្រាជ្ញា ខ្ញុំទឹងឲ្យឡោពីទៅវាយយកដែរ បើបានស្រុកសៃឈួនហើយ ទើបខ្ញុំទឹងបង្វិលស្រុកកេងជីវឲ្យវិញ ឡោសុកឮដូច្នោះក៏អារម្មណ៍ចិត្តខុងបេង ព្រមទទួលពាក្យតាមដែលខុងបេងនិយាយគ្រប់ប្រការ ។

ខណៈនោះឡោពីក៏សរសេរសំបុត្រតាមពាក្យដែលខុងបេងថា នោះដាក់ឈ្មោះខុងបេងជានាយប្រកាន់ទទួលធានា ខុងបេងក៏និយាយទឹងឡោ-សុកថា ខ្លួនខ្ញុំជាពួកម៉ាករបស់ឡោពីបុះឈ្មោះជាអ្នកធានា មុខជាស៊ុនគួនមិនសុខចិត្តទឹងសុំឈ្មោះអ្នកដាក់បុះក្នុងសំបុត្រជាធានាផង ទើបស៊ុនគួនអស់សង្ស័យ ឡោសុកថា ឯខ្លួនខ្ញុំរាប់អានឡោពីថាជាមនុស្សមានចិត្ត

មេត្តាកប់អានដោយសុចរិតពិតត្រង់ បើចង់ចុះឈ្មោះខ្ញុំផងក៏បាន ឡៅពីក៏សរសេរចុះឈ្មោះឡៅស៊ុកជាអ្នកធានាខាងចុងក្រដាស ហើយប្រគល់សំបុត្រនោះទៅឲ្យឡៅស៊ុក ៗ ទទួលសំបុត្រហើយក៏លាឡៅពី - ខុនបេងទៅវិញ ៗ ឡៅពី·ខុនបេងក៏តាមជូនដំណើរឡៅស៊ុកទៅដល់ទូក កាលឡៅស៊ុកនឹងចេញទូកទៅនោះ ខុនបេងក្លែងនិយាយថា បើអ្នកទៅដល់ស៊ីនគួនហើយ ចូរជួយនិយាយឲ្យល្អផង ដើម្បីនឹងឲ្យចៅហ្វាយយើងទាំង ២ ប្រក្រតីនឹងគ្នាតទៅ កុំឲ្យចូច្ចូកមើលងាយប្រមាថយើងបាន បើអ្នកមិនធ្វើតាមពាក្យខ្ញុំនិយាយទេ ទោះបីស្រុកកាំងតាំងនឹងអាណាខែត្រងទៀត ខ្ញុំក៏នឹងរកយដំណើមយកទាំងអស់ ៗ

---

(នៅមានត)

រឿងមនុស្សពិតប្រែប្រួល

# ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ រៀបរៀង

(តចប់)

---

នាងរស់ អង្គុយប៉ះខោបណ្ដើរស្ដាប់អាពុកនឹងកូនសន្ទនាគ្នាបណ្ដើរ ឮកូនបេះតែប្រកែកដូច្នោះ តឹងចិត្តពេកឆ្លើយថា ណ្ហើយគេហ៍! ឈប់និយាយទៅ កុំបង្ខំចិត្តវា បើវាមិនតាមយើងជាម៉ែឪទេ ស្រេចនឹងវាចុះ បុរាណលោកថា "ឆំមិនដែលធំជាងឆាឡៀ" ឥឡូវ បើធំជាងនាឡ្យើហើយ នៅទទូចនិយាយធ្វីទៀត ព្រឹកស្អែកឲ្យវាទៅធ្វើចំការឯថ្នុគទៅ ។

ព្រឹកឡើង នាងរស់រៀបអង្ករត្រើងៀត ឲ្យជីប្រែយកទៅចំការផ្ដាំថា ថ្ងៃត្រង់ឯងដាំបាយបរិភោគនៅចំការចុះ ល្ងាចចាំមកបាយឯផ្ទះ ដ្បិតភូមិថ្នុគឆ្ងាយពីភូមិកោះរះ លំបាកទៅមក ។

ជីប្រែ— ទឹមគោអូសនង្គ័លនៅភ្ជួរដីចំការនៅខាងត្បូងវត្តថ្នុគ តាំងពីព្រលឹមដល់ថ្ងៃត្រង់ទើបឈប់ដាំបាយអាស្រ័យ ថ្ងៃបន្តិចភ្ជួរតទៅទៀត រហូតដល់ថ្ងៃរសៀលទាបលែងភ្ជួរបររគោមកផ្ទះវិញ ។ ជីប្រែទៅធ្វើចំការរាល់ថ្ងៃរហូតដល់កាស់ដីរួចស្រេច ប្រាប់ម្ដាយឲ្យយកគ្រាប់ពោតពូជទៅដាំ លុះពោតដុះលូតលាស់បែកគុម្ពល្អលិចមាន់ហើយ ជីប្រែទៅដម្រះស្មៅពោតរាល់ថ្ងៃ ។

នាងប្រួល នៅជម្រះស្មៅពោតក្នុងចំការព្រំជាប់គ្នា នឹងចំការដីប្រែ ជួនកាលជួយដាំបាយឲ្យដីប្រែផង ហើយឲ្យម្ហូបចំណីដីប្រែជាញយ ៗ អ្នកទាំងពីរស្គាល់គ្នាយ៉ាងជិតស្និទ្ធដូចបងប្អូនបង្កើត ពេលឈប់ជម្រះស្មៅ បរិភោគបាយរួច អង្គុយនិយាយគ្នាលេងពីនេះពីនោះ ក្រោមដើមរាំង ខ្យល់បក់មកល្ហើយត្រសៀក ។

នាងប្រួលសួរដីប្រែថា ម៉ែឪបង គាត់រកផ្ទះសំបែងឲ្យបងហើយ ឬនៅ ? ។

ដីប្រែ — ប្អូនកុំសួរពីរឿងនេះ បងមិនចង់ឲ្យឮទេ បងស្មាលា ហើយប្អូន ៗ មួយទៀត ប្អូនកុំមកអង្គុយនិយាយលេងជាមួយបងញយៗ ពេក ក្រែងប្ដីសីប្អូនប្រចែប្រច័ណ្ឌនឹងបង ។

នាងប្រួល — ចា៎ស! មិនអីទេ បង! ប្ដីខ្ញុំគាត់ចែកស្ថានទៅ ជិត ១ ឆ្នាំហើយ តាំងពីអាប្រមក់នេះទើបនឹងកើតបាន ១ ខែ ខ្ញុំមាន តែកូនប្រុស ១ នេះទេ ។

ដីប្រែ — បើដូច្នោះ ប្អូនមិនចង់បានប្ដីសីទៀតទេឬអី គ្រាន់បានជា គ្នាជួយធ្វើការរកស៊ី ៗ ដីប្រែនិយាយត្រង់ ៗ តាមស្និទ្ធ គ្មានចិត្តប្រាថ្នា នាងប្រួលបន្តិចសោះ ព្រោះខ្លួនតាំងចិត្តថា លែងយកប្រពន្ធហើយ ។

នាងប្រួល - ចា៎ស! ខ្ញុំមិនយកប្ដីទៀតទេ បង! ខ្ញុំរាងចាលហើយ ធ្វើម្ដេចបានជាជ្រុលខ្លួនទៅយកប្ដី ១ ឆ្នាំបានកូន ១ នេះ ទទួលគាត់បែក

ស្ពានទៅ ឥឡូវខ្ញុំស៊ូទ្រាំធ្វើរបរចិញ្ចឹមខ្លួនតែម្នាក់ឯងទៅចុះ ទំរាំដល់ស្លាប់, នាងប្រុលមាត់ថាម្យ៉ាង ឯចិត្តគិតទៅម្យ៉ាង គិតថា បងប្រែនេះអាយុដំណាលប្ដីអញដែរ ហើយជាអ្នកចេះដឹងច្រើនផង ទាំងចិត្តថ្លើមក៏ស្លូតត្រង់ល្អ ល្មមអញទីពឹងបាន ប៉ុន្តែ កុំអាលធ្វើឲ្យគាត់ដឹងខ្លួនថាអញស្រឡាញ់គាត់ ។

ដីប្រែ – ជឿពាក្យសំដីនាងប្រុលស្លុង ស្ទាប់ចិត្តឫកថា នាងនេះមិនចង់បានប្ដី ដូចអញមិនចង់បានប្រពន្ធដែរ តាំងពីពេលនោះមករឹតតែជឿទុកចិត្តនាងប្រុលលើសពីមុន ៗ ។

កន្លងពីនោះមកពីរបីថ្ងៃ ពេលរសៀលទាប នាងប្រុលឈប់ជម្រះស្មៅហៅចៅប្រែទៅអង្គុយលេងលើខ្ទមខ្លួនប្រាប់ថា បងប្រែ! ថ្ងៃនេះយើងកុំប្រញាប់ទៅផ្ទះពីថ្ងៃពេក យើងនៅឲ្យដល់ព្រលប់ធំចាំទៅ ព្រោះតែដល់ថ្ងៃលិចហើយ ហ្វូងក្អែកចូលមកស៊ីពោតយើងរាល់យប់ យើងនៅចាំដេញក្អែកសិន ថាៈ ក្ដើរដាំបាយបណ្ដើរ ។

ចៅប្រែ – ដេកកើយមែករាំង ១ កំណាត់ លើខ្ទមរបស់នាងប្រុលនិយាយគ្នាលេងចាំបាយឆ្អិន ។

នាងប្រុល – និយាយបន្ទុយថា ខ្ញុំគិតថាមិនយកប្ដីទេ ប៉ុន្តែ បងឃើញស្រាប់នឹងភ្នែក មកឯព្រៃបាត់ឯផ្ទះ គ្មានគ្នាជាទីពឹង លំបាកចិត្តរាល់ថ្ងៃ យប់ដេកតែម្នាក់ឯង ភ័យខ្លាចក្រែងចោរលួចនឹងសត្រូវប្រមាថ

មើលឆាយ គិតសព្វៗ ទៅមិនគួរនៅម្នាក់ឯងទេ ឈឺចាប់យប់អធ្រាត្រ បានអ្នកណាជួយមើល ដូចបងឯងក្តី ខ្ញុំក្តី មកនៅធ្វើចំការក្នុងព្រៃគោកតែម្នាក់ឯង បើមានធុរៈចុកពោះ ឬ ពស់ចឹក ឬ ខ្លាមកកំហែង តើនឹងបានអ្នកណាជួយ នេះកុំបានបងនៅជាមួយគ្រាន់ជាគ្នា កុំអីខ្ញុំកំព្រាស្លាប់ក្នុងចំការតែម្នាក់ឯងហើយ ។

ចៅប្រែ– សម្ងំស្តាប់សំដីនាងប្រុលដល់ត្រង់នេះទន់ចិត្តនឹកអាណិតនាងប្រុលព្រួចៗក្នុងពោះឆ្លើយថា មែនហើយ ប្អូន! គួរតែប្អូនយកប្តីទៀតទៅ កុំនៅម្នាក់ឯងយ៉ាងនេះលំបាកណាស់ តាមបងឃើញសព្វថ្ងៃ បងក៏នឹកអាណិតប្អូនណាស់ដែរ បានជាសុខចិត្តនៅកំដរដល់ព្រលប់ ។

នាងប្រុល– ដឹងថាចៅប្រែទន់ចិត្តអាណិតខ្លួនហើយ យល់ថាចិត្តមនុស្សប្រុសស្រីបើអាណិតហើយមុខជាស្រឡាញ់ៗ កើតក្រោយអា-ណិត ដូច្នេះត្រូវអញធ្វើឲ្យបងប្រែស្រឡាញ់ទៀតនៅពេលនេះ ទាន់បានឱកាសល្អ ទើបនាងឆ្លើយថា លាក់បាំងអី បង! តាមលំបាកសព្វថ្ងៃនេះ នឹកចង់បានប្តីដែរ ប៉ុន្តែ ខ្លាចក្រែងប៉ះទៅលើប្រុសចិត្តអាក្រក់ប្រសិនបើប្រុសចិត្តល្អដូចបងឯង ខ្ញុំប្រថុយហើយ មាត់តែថា ដៃលូកចាក់ក្រឡៀកចៅប្រែៗ លូកចាក់ក្រឡៀកនាងប្រុល ចាក់ទៅ ចាក់មកជាប់ដៃប្រឡែងគ្នាមួយសន្ទុះ ហាក់តែសព្វខ្លួន ប៉ុន្តែ នាងប្រុលមិន

ឲ្យជ្រុលដល់ទីជម្រៅទេ បណ្តោយតែក្រៅៗ ដើម្បីការពារកេរ្តិ៍ស្រី ។

ចៅប្រែ — កើតចិត្តស្រឡាញ់នាងប្រួល ដោយសារសាច់ប្រុស នឹងស្រីប៉ះទង្គិចគ្នា ដូចចាស់ទុំលោកថា "ស្ករជិតស្រមោច , ក្អែកកាជិតពងមាន់" ។ ពេលនេះ ចិត្តចៅប្រែប្លែកពីថ្ងៃមុនៗ កើតមោហ៍បាំងភ្លេចសំដីរបស់ខ្លួនជាន់ដើមអស់ ច្បាប់ទម្លាប់ដែលធ្លាប់ចេះដឹងមកក៏រលត់សូន្យ ដូចចាស់ទុំលោកថា "ចេះមិនឈ្នះចង់ ត្រង់មិនឈ្នះឆាល់" ចៅប្រែស្ទុះទៅឱបកនាងប្រួលកំពុងដួសបាយជាប់ហើយសួរថា ប្អូនសុខចិត្តយកបងធ្វើប្តីទេ បើប្អូនសុខចិត្តបងក៏ព្រមយកប្អូនធ្វើប្រពន្ធដែរ ។

នាងប្រួល — នៅស្ងៀម បណ្តោយឲ្យចៅប្រែឱបកមួយស្របក់ ទើបឆ្លើយថា បើបងស្រឡាញ់ប្អូនយកធ្វើប្រពន្ធ ប្អូនក៏ព្រមយកបងធ្វើប្តីដែរ ប៉ុន្តែ ពេលនេះ សូមបងអាណិតខ្ញុំ កុំអាលវីវរអី ចាំបងទៅផ្ទះជំរាបម៉ែឪ ឲ្យម៉ែឪមកស្តីដណ្តឹងខ្ញុំរៀបសែនព្រេនមេបាចាស់ទុំរួចចាំយើងនៅរួមសុខ-ទុក្ខជាមួយគ្នាកុំឲ្យខុសច្បាប់ ។

អ្នកទាំងពីរបរិភោគបាយលើខ្ទម រួចនាំគ្នាទៅផ្ទះរៀងខ្លួនៗ ចៅប្រែទៅផ្ទះនៅឃុំកោះរះ ។ ឯនាងប្រួលទៅផ្ទះនៅឃុំថ្គ ។

នាងរស់ — ម៉េចក៏បាត់ដល់ថ្ងៃនេះ កូន ! ម្តាយចេះតែអង្គុយចាំមើលផ្លូវ ក្រែងជាមិនជា ឯងរួចបាយហើយឬនៅ?

*ចៅប្រែ — បាទ! រួចហើយ ម៉ែ ។*

*នាងរស់ — ចុះឯងអាស្រ័យបាយនៅផ្ទះអ្នកណា?*

*ចៅប្រែ — នៅខ្ទមនាងប្រួល ។ ចេះតែឃាត់ខ្ញុំឲ្យនៅកំដរ ។*

*នាងរស់ — សំឡឹងមើលមុខកូនឃើញប្លែកជាងសព្វថ្ងៃ នឹកសង្ស័យក្នុងចិត្តណាស់ តែមិនសួរដេញដោលតទៅទៀត ខ្លាចក្រែងកូនអៀនខ្មាស ។*

*ចៅប្រែ — ចូលដេកមិនសុខមិនសាប់សោះ ចេះតែទន្ទឹងឲ្យភ្លឺឆាប់ ព្រោះចិត្តនឹកទៅនាងប្រួលឥតភ្លេច ធ្វើភ្នែកភ្លឹះៗ រហូតដល់មាន់រងាវគុះ ទើបលក់ទៅ យល់សប្តិឃើញបានចិញ្ចៀនប្រាក់ ១ វង់ ដាំត្បូងពេជ្រភ្លឺរន្ទាល នឹកត្រេកអរណាស់ទៅ និយាយមមើមមាយស្រែកច្រៀងថា៖*

ពាក្យ ៨

ផ្គរលាន់ខែចេត្រកើតហេតុយ៉ាងធំ កង្កែបស្រែកយំលើប៉ុងឈើទាល ក្រពើលង់ទឹកស្លាប់ពាសពេញវាល ទឹកក្តៅរោលរាលពេញទាំងសមុទ្រ ។ ចិត្តអញស្អប់ស្រីឥតអ្វីប្រៀបឡើយ លុះបានកៀកកើយកើតចិត្តស្រយុត អាល័យរលឹកនឹកយ៉ាងបំផុត ក្តីស្នេហ៍មកដុតឲ្យខ្ញុំខានដេក ។ ថ្ងៃរះពីឯលិចភ្លឺបិញ្ចែង នឹកកាលប្រឡែងលេងបាក់ក្រឡេក ចាប់ទៅចុបមកកើតក្តីជម្រែក នាំចិត្តឲ្យត្រេកត្រអាលនឹងស្រី ។

នាងរស់  កំពុងតែអង្គុយនៅកន្ទុយជើងក្រាន  បបរតាំងពីយប់ងងឹតមិនទាន់ភ្លឺ  ឲ្យកូនស្រស់ស្រូបព្រឹកព្រហាមមុនទៅចំការ  ឮសូរកូនមមើច្រៀងយ៉ាងច្បាស់ខំផ្ទៀងស្តាប់យល់ថា  ដីប្រែច្បាស់ជាជាប់ចិត្តស្រឡាញ់ស្រីណាហើយ  បានជាដេកមមើយ៉ាងនេះ  នឹកត្រេកអរណាស់  ចូលទៅដាស់ប្តីក្នុងមុងខ្សឹបៗថា តេហ៍អើយ! ក្រោកឡើងស្តាប់ដីប្រែវាមមើៗ

អ្នកកើត - ចុះវាមមើថាម៉េចខ្លះ ?

នាងរស់ – វាថានឹកកាលប្រឡែងនឹងស្រីណាស់  ប្រហែលជាវាទៅដេកជាមួយមេណាហើយ  បានជាល្ងាចមិញទាល់យប់ទើបវាមកដល់ផ្ទះ  ៗ

អ្នកកើត – ណ្ហើយតេហ៍ ! មេណាក៏ដោយឲ្យតែវាស្រឡាញ់យកធ្វើប្រពន្ធទៅចុះ ព្រោះពីដើមវាស្បថស្បែថាលែងយកប្រពន្ធមួយជាតិ អញព្រួយចិត្តនឹងវាណាស់ ឥឡូវបើវាព្រមយក  យើងត្រេកអរទៅ  ៗ

នាងរស់ – ត្រេកអរម៉េចនឹងរួច  តេហ៍ !  បើស្រីមេម៉ាយកូនមួយស្លាប់ប្តី  ៗ

អ្នកកើត - យី ! ឯងមិនទាន់ដឹងទេ ! បុរាណថា  "មេម៉ាយកូន ១ ល្អលើសក្រមុំ" ព្រោះវាបែកសាច់ឈាមដោយសារត្រូវដីជាតិ ណ្ហើយឯងកុំមាត់កអីដូចចាស់ទុំថា "កកកំបាយមេម៉ាយកំស្រី" បើវាទៅលើនាងប្រួលមែន  សំណាងវាហើយ  ដ្បិតនាងប្រួលអញស្គាល់ពូជអម្បូរវាអស់ហើយ

ក៏មានមារយាទល្អណាស់ ទាំងរូបរាងក៏ល្អមិនចាញ់ស្រី ៗ ឯទៀតទេ ក្រមុំមិនសូវមិនសាចាញ់ក៏ស្រឡះ គ្រាន់តែក៏ទាល់ក្រជាងគេបន្តិចប៉ុណ្ណោះ ផ្ទះបើក៏ធ្វើទុកឲ្យស្រាប់ ដីភូមិកេរ្តិ៍ពីម៉ែឪក៏មក ទាំងចំការពោតក៏មានដែរ បើក៏ព្រមយកដីប្រែធ្វើប្តីស្រួលហើយ ដ្បិតចំការពោតព្រំដីជាប់គ្នា យើងឲ្យចំការនោះទៅក៏ចុះ ៗ

នាងសៅ – ស្តាប់ចូលចិត្តនៅស្ងៀម ថយចេញទៅជួបបរជាក់បានឲ្យដីប្រែ ៗ ហុតបបរប្អូននិយាយខ្សឹប ៗ ប្រាប់ម្តាយមិនហ៊ានឲ្យឪពុកឮថា ម៉ែថ្ងៃនេះ ខ្ញុំមិនទៅចំការទេ សូមម៉ែទៅស្តីដណ្តឹងនាងប្រុសឲ្យខ្ញុំ ៗ ពេញចិត្តនាងនេះហើយ បើគេព្រមព្រៀងសូមម៉ែកំណត់ពេលសែនព្រេនមេបាឲ្យគេឆាប់ ៗ ទៅ កុំនៅយូរ ព្រោះពោតយើងឯចំការជិតទុំហើយ ៗ

នាងសៅ – ទទួលថាអើ ! ចាំអញទៅស្តីដណ្តឹងគេឲ្យ តែថប់ក្រែងនាងប្រុសប្រកែក ព្រោះឯងរូបអន់បន្តិច ៗ នាងសៅចំអន់កូនលេងលមើលចិត្ត រួចចេញទៅក្រៅដំណាលប្រាប់ប្តីតាមសំដីកូនសព្វគ្រប់ ៗ

អ្នកកើត – អស់សំណើចឃឹក ៗ លាន់មាត់ថា ពីដើមក៏ស្បថស្បែថាលែងយកប្រពន្ធមួយជាតិ ឥឡូវស្រាប់តែតឿនម៉ែក៏ឲ្យសែនព្រេនឆាប់ ៗ ដ្បិតពោតជិតទុំ ទុំអី អញដឹងចិត្តក៏ហើយ ៗ

ហេតុតែចិត្តម៉ែឪមិនប្រកាន់ទឹងទិងសំដីកូន បណ្តើរគ្នាជយទៅឯ

យុំថ្មុគតាំងព្រលឹមអុរ ដល់ផ្ទះនាងប្រុល ឈររេកនៅមុខផ្ទះអ្នកក្រហែមពីរបីដង ។

នាងប្រុលកំពុងរៀបដំណើរទៅចំការ ឮសូរសំដីនៅមុខផ្ទះ អើតទៅឃើញអ្នកតាំងពីរក៏យល់ហេតុភ្លាម ស្រែកថា អញ្ជើញឡើងមកលោកពូ, មីង ។

អ្នកកើត, នាងរស់ឡើងលើផ្ទះសំពះសួរយាយប្រឹង ( មេម៉ាយអំពី-តាប្រេង ) ជាដំបូងនាងប្រុលថា ជម្រាបសួរធំ! ធំសុខសប្បាយជាទេ ឬអី ?

យាយប្រឹង — អើ! ធំជាទេក្មួយ ! ចុះក្មួយតាំងពីរនាក់មានការអ្វី បានជានាំគ្នាមកផ្ទះធំតាំងព្រហាមស្រាង ៗ យ៉ាងហ្នឹង ប្រាប់ធំឲ្យត្រង់មកមើល ។

នាងរស់ — លើកស្លាម្លូនឹងនំពីរកញ្ចប់ជូនទៅយាយប្រឹងរួចជម្រាបថា សូមទោសធំទៅចុះ លោកប៉ាំងអី មកនេះមានការណ៍បន្តិច ខ្ញុំរកពឹងអ្នកជិតខាងមិនទាន់ មកផ្លាស់ខ្លួនពីរនាក់ក្ដីប្រពន្ធកែម្ដង សូមធំកុំប្រកែកប្រ-កាន់ទោសក្មួយចុះ នាងប្រុលនៅជាមេម៉ាយ ឬមួយគេមានថ្កុះហើយ? ដ្បិតដីប្រកូនប្រុសច្បងរបស់ខ្ញុំវាពេញចិត្ត វាប្រើខ្ញុំឲ្យមកសាកសួរធំ ។

យាយប្រឹង— មិនអីទេក្មួយ ! ធំមិនប្រកាន់អ្វីទេ ! មីប្រុលវានៅមេ-ម៉ាយទៅទៀត ធំក៏ពេញចិត្តនឹងចៅប្រែដែរ ព្រោះធ្លាប់ឃើញវាមកលេង

ផ្ទះធំញឹកញាយ ស្តាប់សំដីសំដៅជាអ្នកចេះដឹងគួរសម ប៉ុន្តែ ធំមិនហ៊ានការកាត់ចិត្តម៉ៅទៅទេ ចាំសួរពាំមើលសិន ៗ យាយប្រឹងបែរមុខទៅរកនាងប្រួលសួរថា ម៉េចចិត្តទៅ ៗ ពូស្រាប់ហើយ ស្រេចលើចិត្តទៅចុះ យាយមិនដឹងទេ ព្រោះមានពាក្យចាស់ទុំលោកថា “ ក្រមុំដណ្តឹងម្តាយ មេម៉ាយដណ្តឹងចិត្ត ” ៗ បើតាមយោបល់យាយថា គួរទៅផ្ញើខ្លួនប្រាណទៅលើជីប្រែចុះ ព្រោះខ្លួនឯងកំព្រាឥតម៉ែឪ ហើយជីប្រែគេក៏អ្នកចេះដឹងចិត្តស្លូតបូតល្អផង ៗ

នាងប្រួល - ខ្ញុំមិនប្រកែកទេ ខ្ញុំយល់ស្របតាមចិត្តយាយហើយ សូមយាយសម្រេចការជាមួយពូកើតមីងសៅឲ្យស្រេចទៅចុះ ៗ

រាប់ពីថ្ងៃដែលប្រឹក្សាគ្នាមកបានប្រាំថ្ងៃ គេឮសូរភ្លេងមង្គលការចៅ-ប្រែនឹងនាងប្រួលពិរោះរងំ ញាតិមិត្រជិតឆ្ងាយបរិភោគបាយនំចំណីដោយរីករាយ និយាយគ្នាពីចិត្តចៅប្រែដែលប្រកែកថា មិនយកប្រពន្ធសោះអស់មួយជីវិត ៗ

អ្នកកើតទៀតយកឱកាសនេះ ប្រាប់កូនទាំងពីររូបឲ្យចាំកុំភ្លេចអំពីរឿងមនុស្សចិត្តប្រែប្រួល ៗ

ចប់

រឿងព្រេងចិន

លោក ប៉ាយ-ប៊ុត្ត ប្រែរៀបរៀង

## រឿងព្រេងចិនមាន ៩ យ៉ាងគឺ៖

១ រឿងអស្វារោហ៍ "កញ្ចាញ់ចេក" ( Le cavalier Rainette)

២– រឿងសេះឈើ (Le cheval de bois)

៣- រឿងជក់ទិព្វ (Le pinceau ma ique)

៤– រឿងវីរជនម្នាក់នាមសីកាល (L'histoire du Héros chégal)

៥ - រឿងលោកឡៅសានទឹងចៅក្រម (Lao San et le magistrat)

៦– រឿងព្រះនាងម៉ឹងគីយាង - នីយូ (Meng kiang Niu )

៧ រឿងបឹងនៃរុក្ខជាតិអូលីវីយេ (Le lac des Oliviers)

៨ រឿងបែងចំណែក ( Le partage )

៩– រឿងផ្សេងៗនៃលោកណាសឺឌីនអាវ៉ាន់ទី (Quelques histoires de Nasrdin Avanti)

ដំបូង, ខ្ញុំទឹងពណ៌នាអំពីរឿងអស្វារោហ៍ "កញ្ចាញ់ចេក" (Le cavalier Rainette; រឿងនេះជារឿងព្រេងប្រទេសទីបេ ។

១– រឿងអស្វារោហ៍ "កញ្ចាញ់ចេក" នៅលើគីរីដ៏មានសភាពខ្ពស់ជាប់សទឹមស្ថិតនៅឆ្ងាយដាច់ស្រយាល, មានជនពីរនាក់ជាស្វាមីភរិយារស់នៅទីនោះ ធ្វើចម្ការមួយដាំអ្វីមិនសូវដុះទេ, ដាំបានតែថ្លៅ

នឹងជំឡូងបាក់ឯបន្តិចបន្តួច, អ្នកទាំងពីររស់នៅដោយលំបាកពន់ពេក ។

លុះអ្នកទាំងពីររស់នៅជាមួយគ្នាជាយូរឆ្នាំ, ហើយដល់ខ្លួនចាស់ជរា, ក៏មានចិត្តព្រួយឥតឧបមាដោយខ្លួនគ្មានបុត្រធីតាមួយសោះឡើយ ។ ថ្ងៃមួយ អ្នកទាំងពីរក៏ពោលទួញពាក្យថា " ឱ! បើសិនណាជាយើងមានបុត្រម្នាក់ យើងនឹងសប្បាយចិត្តយ៉ាងណាទៅ, បុត្រយើងដល់យើងចាស់ជរា ក៏នឹងរកស៊ីចិញ្ចឹមជួសយើង ក៏ធ្វើការជួសយើងក្នុងពេលកំណែននៃស្ដេចត្រាញ់មួង ។ ក៏នឹងទៅកាប់ឧសឯភ្នំជួសយើង ដែលយើងទុព្វលភាពខ្នងកោង យើងនឹងអាចសម្រាកកាយសប្បាយចិត្តអាំងភ្លើងនៅគេហដ្ឋាន . . ." ។

មានកាលមួយថ្ងៃ អ្នកទាំងពីរក៏បានទៅបន់ទេវតាក្នុងទន្លេ សូមឲ្យបានបុត្រមួយដូចបំណង, ក្នុងពេលដែលកំពុងបន់នោះ ចិត្តអ្នកទាំងពីរក៏មានចិត្តគួចយ៉ាងខ្លាំងដូចគ្នា, មិនយូរប៉ុន្មាននាងជាភរិយាក៏មានគភ៌ ។ លុះកាលគន្លងមកបាន ៧ ខែ, នាងជាភរិយាក៏ប្រសូតបុត្រ តែមិនមែនទារកដូចធម្មតាទេ, គឺសត្វកញ្ចាញ់ចេកតូច មានភ្នែកធំ ។

ស្វាមីក៏ពោលថា ឱ! នាងគួរឲ្យឆ្ងល់ពេកណាស់, មិនមែនទារកដូចមនុស្សធម្មតាទេ ដែលនាងឯងឆ្លងទន្លេនេះ គឺកញ្ចាញ់ចេកមានភ្នែកធំ នាងឯងត្រូវតែយកវាទៅបោលឯក្រៅទៅ, កុំទុកឲ្យវានៅទីនេះធ្វើអ្វី ។

នាងជាភរិយាដល់ឮសព្ទពាក្យបុរសជាប្តីនាងដូច្នោះ ក៏គិតក្នុងចិត្តថា :

"ឱ! ទេវតានេះមិនព្រមតាមពាក្យដែលយើងបន់សោះ, ទេវតាលោកឲ្យកញ្ចាញ់ចេកមួយ, មិនមែនទារកដូចមនុស្សជាតិធម្មតាទេ ! តែបើទុកជាកញ្ចាញ់ចេកក៏ដោយ ក៏កញ្ចាញ់ចេកនោះកើតពីខ្លួនអញ, មិនត្រូវអញយកទៅបោះបោលទេ ។ សត្វកញ្ចាញ់ចេកតែងរស់នៅក្នុងទឹកត្រពាំង ឥឡូវនេះមានត្រពាំងខាងក្រោយគេហដ្ឋាន, គួរបោះបោលក្នុងទឹកត្រពាំងនេះចុះ ដើម្បីឲ្យវាមានជីវិតរស់នៅបាន" ។

បុរសក៏យកកញ្ចាញ់ចេកនោះ កាន់នឹងដៃចេញពីគេហដ្ឋានទៅ ។ ក្នុងពេលនោះ, កញ្ចាញ់ចេកដែលស្ថិតនៅក្នុងបាតដៃបុរសក៏ពោលថា :

" ឱ! មាតាបិតាអើយ , កុំយកខ្ញុំទៅបោលក្នុងត្រពាំងសោះឡើយ, ខ្ញុំជាកូនមនុស្សជាតិពិតប្រាកដ ចូរទុកខ្ញុំឲ្យរស់នៅជាមួយមនុស្សចុះ, ដល់ខ្ញុំចំរើនវ័យវឌ្ឍនាការពេញរូបរាងពេញកង ខ្ញុំនឹងធ្វើភូមិនេះឲ្យបានចំរើនថ្កុំថ្កើងរុងរឿងឡើង, ខ្ញុំនឹងតម្កើងជីវភាពមនុស្សដែលស្ថិតនៅភូមិនេះឲ្យមានឋានៈដ៏ឧត្តុង្គឧត្តមតទៅអនាគត" ។

បុរសក៏ភ្ញាក់ស្មារតីឡើងពោលទៅកាន់ភរិយាថា :

" ឱនាង! ជាការប្លែកណាស់, កញ្ចាញ់ចេកនេះចេះនិយាយ" ។

នាងជាភរិយាក៏តបទៅស្វាមីវិញថា អើកញ្ចាញ់ចេកនេះចេះពោល

ពាក្យពិរោះពិសាណាស់ដែរ ។

ពិតមែនហើយ ជីវភាពនៃមនុស្សដែលស្ថិតនៅទីនេះ ត្រូវតែប្រែកែតាមលំនាំតទៅ បើជីវភាពនេះស្ថិតនៅក្នុងស្ថានការណ៍ដ៏លំបាកដូច្នេះ យើងនឹងទទួលមរណភាពដោយទុក្ខភ័យមិនខាន! កញ្ញាញ៉ូវេចកដែលបេះពោលពាក្យបែបនេះមិនមែនកញ្ញាញ៉ូវេចកធម្មតាទេ, យើងត្រូវទុកជីវិតឲ្យកញ្ញាញ៉ូវេចកនេះរស់នៅជិតយើងចុះ ។

ស្វាមីនឹងភរិយាដែលមានចិត្តប្រកបដោយព្រហ្មវិហារធម៌, ក៏រក្សាកញ្ញាញ៉ូវេចកនោះទុកជាមួយនឹងខ្លួន ហើយក៏បានជួយឧបត្ថម្ភចិញ្ចឹមបីបាច់ថែរក្សាឲ្យដូចជាកូនមនុស្សដូច្នោះ ។

ដល់បីឆ្នាំកន្លងមក កញ្ញាញ៉ូវេចកដល់ឃើញស្វាមីនឹងភរិយាធ្វើការលំបាកពន់ពេក, ក៏ពោលពាក្យថា :

"មាតា! ស្អែកសុំលោកមាតាធ្វើនំបុ័ងមួយឲ្យខ្ញុំ ហើយសុំដាក់ទៅក្នុងថង់ ឬ ស្បោងឲ្យខ្ញុំព្រោះខ្ញុំនឹងទៅកាន់ប្រាសាទដែលស្ថិតនៅខាងចុងជ្រោះក្នុងឯណោះដើម្បីនឹងសូមព្រះនាងព្រះអគ្គធ្វើករិយា ។ ព្រះអង្គទ្រង់មានព្រះរាជបុត្រីមានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយពអគ្គ ។ ខ្ញុំនឹងទៅរកកូនប្រសាស្រីមួយមានសមត្ថភាពគ្រប់គ្រាន់ ល្មមជួយធ្វើការបាន" ។

(នៅមានត)

# ភូមិសាស្ត្រសេដ្ឋកិច្ចប្រទេសជប៉ុន

លោក រ៉ូហ្សមបែរត៍

អតីតសាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ប្រទេសកម្ពុជា

បាននិពន្ធកាលពីឆ្នាំ ១៩៥៩ - ៦០

លោក ញ៉ែម.ទឹម ប្រែសម្រួល

( តមក )

---

ដីដែលគេធ្វើការយកផលនោះមានទំហំតូច ៗ ហើយចែកជាកង់ ៗ ។ កាលពីឆ្នាំ ១៩៤៦ សហរដ្ឋអាមេរិកបានតម្រូវឲ្យធ្វើការកែទម្រង់ដីមួយយ៉ាងសំខាន់ ។ ដីទាំងឡាយដែលម្ចាស់ដីមិនបានដាំដំណាំដោយខ្លួនឯងត្រូវរាជការទិញយក ហើយចែកឲ្យទៅអ្នកគ្មានដី តែជាអ្នកធ្លាប់ដាំដំណាំលើដីនោះ ។ សព្វថ្ងៃនេះ ២ ភាគ ៣ (២/៣) នៃប្រជារាស្ត្រជប៉ុនសុទ្ធតែមានដីផ្ទាល់ខ្លួនឯង តែតាមធម្មតាម្នាក់ ៗ មានដីមិនលើសពី ១ ហិកតាឡើយ ។

ផលិតផលកសិកម្មដែលសំខាន់ៗ — ពាក់កណ្តាលនៃផ្ទៃដីដែលដាំដំណាំបានមានធ្វើសុទ្ធតែស្រូវ ។ ដំណាំស្រូវនេះបានឲ្យផលយ៉ាងច្រើន គឺ ៣៣ កាំងតាល់ (១ កាំងតាល់ ១០០ គីឡូក្រាម) ក្នុងមួយហិកតា ។ ផលនេះបានមកពីការប្រើជីនិងការបូមទឹកបញ្ចូលស្រែ ។ ប្រទេសជប៉ុនជាប្រទេសលេខ ៣ ក្នុងសាកលលោកខាងផលស្រូវ ។ ក្នុងមួយឆ្នាំ ៗ ប្រទេសជប៉ុនធ្វើអង្ករបាន១២ លានតោន

ប៉ុន្តែចំនួននេះក៏មិនគ្រប់គ្រាន់នឹងចិញ្ចឹមប្រជាជនជប៉ុនទេ, ប្រទេសជប៉ុនត្រូវតែទិញស្រូវពីប្រទេសក្រៅថែមទៀត ។

កាលមុនឆ្នាំ ១៩៣៩, ក្នុងប្រទេសជប៉ុនមានការចិញ្ចឹមដង្កូវនាងជាច្រើន, ហើយប្រទេសជប៉ុនជាប្រទេសលេខ ១ ក្នុងសាកលលោកខាងការនាំសូត្រចេញទៅលក់ឯបរទេស ។ ប៉ុន្តែ សូត្រកើតពីធម្មជាតិនេះបានជួបប្រទះនូវការវិបត្តិមួយយ៉ាងខ្លាំង ព្រោះត្រូវការប្រជែងជើងគ្នាជាមួយនឹងព្រែធ្វើដោយជាតិសូ (rayonne) នឹងនីឡុង ។ សព្វថ្ងៃនេះសូត្រធម្មជាតិបានថយចំនួន ៥ ដង, ហើយផលិតផលសូត្រ បានចុះពី ៣៣.០០០តោន មក ១០.០០០តោន ។ សូត្រកើតពីដង្កូវនាងនៅមានធ្វើតែនៅកន្លែងត្រង់កណ្តាលកោះហុងដូតែប៉ុណ្ណោះ ។

អំពីដំណាំបន្ទាប់បន្សំ.– ជួនកាលនៅខាងជើង ជួនកាលនៅខាងត្បូងប្រទេសជប៉ុន នៅសិសិរដូវ, គេមានដាំស្រូវសាលី, ស្រូវអាវែន (សម្រាប់ធ្វើអាហារសេះ), អ័រហ្ស៍, មីយេ ។

ដំណាំសម្រាប់ឧស្សាហកម្មពុំសូវសំខាន់ប៉ុន្មានទេ ។ នៅតំបន់ខាងត្បូងនៃប្រទេសគេមានធ្វើកប្បាស បានផលមិនគ្រប់គ្រាន់នឹងសេចក្តីត្រូវការទេ ទឹងដាំដើមតែបានផល ៥០០.០០០ តោនក្នុងមួយឆ្នាំ ។ គេមានការលំបាកនឹងចំរើនផលខាងកសិកម្មណាស់ ។ មានតែមធ្យោបាយមួយ គឺការបាចទឹកបញ្ចូលទៅលើដីណា ដែលពុំទាន់មានទឹកទេ

ទើបអាចបង្កើនផលិតផលកសិកម្មបាន ។ ប៉ុន្តែការនេះត្រូវចំណាយលុយជាច្រើនដែលពលករជប៉ុនពុំអាចចាត់ចែងការបានភ្លាម ៗ ។

អំពីការនេសាទត្រី.– កាលពីឆ្នាំ ១៩៣៩, ប្រទេសជប៉ុនជាប្រទេសលេខ ១ ខាងនេសាទត្រី ប៉ុន្តែការនេសាទជប៉ុនបានត្រូវខូចខាតជាធំណាស់ក្នុងពេលចម្បាំង ហើយនៅឆ្នាំ ១៩៤៥ ប្រទេសជប៉ុនបរាជ័យត្រូវបាត់បង់ទីប្រជុំកោះជាច្រើនដែលសុទ្ធតែសម្បូរត្រី ។ សព្វថ្ងៃនេះប្រទេសជប៉ុនបានធ្លាក់មកជាប្រទេសទី ២ ក្នុងសាកលលោកខាងផលត្រីបន្ទាប់ពីប្រទេសអង់គ្លេស ។ ក្នុងមួយឆ្នាំ ៗ ប្រទេសជប៉ុនចាប់ត្រីបានចំនួន ៤ លានតោន ។ មានមនុស្សចំនួន ១ លាន ៤ សែននាក់ (១.៤០០.០០០ នាក់) បានប្រកបរបរនេសាទ ហើយប្រជាជនជប៉ុនម្នាក់ ៗ អាស្រ័យត្រីអស់ចំនួន ៣០ គីឡូក្នុងមួយឆ្នាំ ។ ផ្ទុយទៅវិញប្រជាជនជប៉ុនម្នាក់ ៗ អាស្រ័យសាច់អស់តែ ២ គីឡូក្រោមទេក្នុងមួយឆ្នាំ ។ ត្រីនេសាទបាន មួយចំណែកសម្រាប់ធ្វើជាអាហារ, មួយចំណែកទៀតសម្រាប់ធ្វើជី ។ ការនេសាទដែលបានឲ្យលទ្ធផលល្អនេះ គឺបណ្ដាលមកពីឆ្នេរសមុទ្រផតចុះផតឡើង ទីឯមកពីសមុទ្រមានត្រីច្រើន ។ ប៉ុន្តែសព្វថ្ងៃនេះ ដោយប្រជាជនជប៉ុនគេរបរនេសាទច្រើនពេក, ឆ្នេរសមុទ្រស្ទើរតែនឹងចង់ក្រត្រី ។ ហេតុនេះហើយបានជាប្រជាជាតិជប៉ុនមានបំណងចង់ឲ្យសហភាពសូវៀតអនុញ្ញាតឲ្យប្រជាជនជប៉ុន ចាប់ត្រី

នៅក្នុងទឹកដិតកោះសាក្កាលីនបានផង ។

អ៊ិតី ឧស្សាហកម្ម .– សម្បត្តិធម្មជាតិពុំសូវសម្បូណ៌ទេក្នុងប្រទេសជប៉ុន ។ ឯកេងឧស្សាហកម្មធំ ៗ ដែលបានកើតមានចំរើនឡើងក្នុងប្រទេសនេះ គឺដោយសារតែការខំប្រឹងធ្វើការនៃប្រជាជនជប៉ុនតែប៉ុណ្ណោះ ។ ឧស្សាហកម្មជប៉ុនមានការប្លែកពីគេត្រង់ថា ឧស្សាហកម្មជាតិមានចែកជាកេងជាងតូច ។ ស្ថិតនៅពាយពាសពេញ, ទោះបីនៅទីជនបទក៏ដោយ ។ កេងការតូចៗនេះ មួយ ។ មានកម្មករដប់ប្លាយនាក់ ហើយធ្វើការដើម្បីសហគ្រាសធំៗ, គឺជាអ្នកទទួលការតពីគេ ។ កេងជាងតូច ។ នេះធ្វើគ្រឿងទៅអ៊ីមួយយ៉ាងពិតប្រាកដ រួចផ្ញើទៅសហគ្រាសធំដើម្បីធ្វើការតំឡើង ឧបមាដូចជានៅក្នុងកេងឧស្សាហកម្មធ្វើទោចក្រយានមានកេងជាងតូច ។ ជាច្រើនធ្វើការសម្រាប់កេងឧស្សាហកម្មធំ គឺមួយធ្វើត្បូ, មួយធ្វើប្រពក់ , មួយទៀតធ្វើឈ្នាន់ ។ល។ របស់ទាំងនេះនឹងយកទៅតំឡើងនៅក្នុងសហគ្រាសធំ ។ មធ្យោបាយនេះមានប្រយោជន៍នឹងប្រមូលក្រុមកម្មករនៅស្រុកស្រែ ឲ្យចូលមកភ្ជួតដៃធ្វើការជាមួយនឹងកេងចក្រធំ ។ ហើយកម្មករនៅស្រុកស្រែស៊ីឈ្នួលថោកផង ។ ប៉ុន្តែចំពោះកេងឧស្សាហកម្មណា ដែលត្រូវការសម្ភារៈសំខាន់និងដើមទុនយ៉ាងធំនោះ , ការប្រមូលកម្មករឲ្យបំពេញមុខងារនៅត្រង់កន្លែងតែមួយជាការចាំបាច់ (la concentration) ឧបមាដូចជានៅក្នុងកេងឧស្សាហកម្មស្ង

ដែក, រោងឧស្សាហកម្មធ្វើនាវា, រោងចក្រធ្វើក្រដាស, និងរោងឧស្សាហកម្មគីមីជាដើម ។ ចំពោះឧស្សាហកម្មទាំងនេះ គេអាចហៅថាសហជីពពួកផលិតករដើម្បីតំឡើងថ្លៃទំនិញ (trust) ក៏បាន ដែលជប៉ុនហៅថាហ្សៃបាតស៊ុយ (zaibatsu) ។ សហជីពដែលសំខាន់ជាងគេមានពីរគឺមីតស៊ុយ (Mitsu) និងមីតស៊ុយប៊ុស៊ី (Mitsubishi) ។

ប៉ុន្តែ នៅពេលដែលប្រទេសជប៉ុនស្ថិតនៅក្រោមការកាន់កាប់នៃសហរដ្ឋអាមេរិក , សហរដ្ឋអាមេរិកបានចាត់វិធានការរំលាយសហជីពពួកផលិតករដើម្បីតំឡើងថ្លៃទំនិញនេះ តែដោយសារសង្គ្រាមត្រជាក់ នយោបាយនេះក៏ត្រូវគេបោះបង់ចោលទៅ ហើយសហជីពពួកផលិតករជប៉ុនដើម្បីតំឡើងថ្លៃទំនិញក៏កើតឡើងវិញដែរ ។

- ប្រភពនៃថាមពល : ប្រទេសជប៉ុនមានដុំលោហធាតុ (gisement) ធ្យូងថ្មពីរកន្លែង ប្រកបដោយគុណភាពអន់ ពុំអាចយកមកធ្វើជាកូក (coke) បានទេ (កូកគឺជាឧស្ម័នយកចេញពីធ្យូងសម្រាប់ប្រើការដូចជាដុតស្លលោហធាតុដើម្បីធ្វើដែកថែប) ។ ដុំលោហធាតុនេះ មួយស្ថិតនៅខាងជើងក្យូ-ស្យូ, មួយទៀតនៅខាងត្បូងហុកកៃដូ ។ ផលិតកម្មទាំងអស់បានចំនួន ៤៧ លានតោន ។

-

ប្រទេសជប៉ុនមានប្រេងកាតបន្តិចបន្តួចដែរ នៅត្រង់ទិសពាយព្យនៃកោះហុងដូ ។ ក្នុងមួយឆ្នាំៗ គេយកប្រេងកាតបានចំនួន ៣៥០.០០០ តោន ។ ចំពោះអគ្គិសនីវិញ, ប្រទេសជប៉ុនសម្បូរណាស់ ។ ស្ទឹងទាំងឡាយមានបណ្តោយខ្លីៗទេ, ប៉ុន្តែ មានច្រាំងធំចោតៗ ។ ៩/១០ នៃអគ្គិសនីបានមកពីការអគ្គិសនី (hydro électrique) ។ កន្លែងការអគ្គិសនីដែលសំខាន់ជាងគេ ហៅថាបឹង ប៊ីវ៉ា (lac Biva) , នៅខាងក្រោយអូសាកា ។

–សម្បត្តិនៃអណ្តូងរ៉ែ ប្រទេសជប៉ុនមិនសូវសម្បូររ៉ែទេ គឺប្រទេសនេះគ្មានដែកសោះ ប៉ុន្តែ មានស្ពាន់ខ្លះ ( ១០០.០០០ តោន) ។ ផ្ទុយទៅវិញ ប្រទេសថ្ងៃរះសម្បូរខាងស្ពាន់ធ័រ ។ ដូច្នេះ គេសង្កេតឃើញថាវត្ថុដើមក្នុងប្រទេសជប៉ុន ពុំអាចញុំាងប្រទេសនេះឲ្យបង្កើតឧស្សាហកម្មធំៗបានទេ ។ ប៉ុន្តែ ដោយគំរូល្អ, ប្រទេសជប៉ុនសម្បូរកម្មករធ្វើការណាស់, ហើយកម្មករទាំងនោះសោតជាមនុស្សស្លូតៗ ងាយស្តីប្រដៅ ហើយស៊ីប្រាក់ឈ្នួលថោកផង ។ អំពើទាំងនេះជាប្រពៃណីរបស់ជាតិគេ ។ ឧទាហរណ៍:ក្រុមកម្មករមួយពួកដែលគួរចង់ដឹង គឺកម្មករដែលធ្វើការក្នុងរោងចក្រវាយនភណ្ឌ (indudrie textile) ។ ៨០ ភាគរយនៃកម្មករដែលធ្វើការក្នុងរោងចក្រនោះសុទ្ធតែជាស្រីគេទ ហើយសុទ្ធតែជាកញ្ញាមានអាយុយ៉ាងតិចត្រឹម ២០ ឆ្នាំ ។ គេជ្រើសរើសកម្មការិនីទាំង

នោះចូលធ្វើការដោយដាប់កិច្ចសន្យាការងារ ហើយនាងកញ្ញាទាំងនោះត្រូវនៅទទួលសំណាក់ក្នុងកន្លែងមួយ ដែលម្ចាស់ឧស្សាហកម្មបានសង់នៅក្បែរកន្លែងធ្វើការនោះ ដើម្បីកុំឲ្យកម្មការិនីទាំងនោះខាតពេលដើរទៅ-មកធ្វើការ ។ នៅក្នុងកន្លែងសំណាក់នោះ មានកន្លែងសម្រាប់ទទួលទានដំណេក (dortoir) កន្លែងសម្រាប់ញុំាបាយ ។ មិនតែប៉ុណ្ណោះ, គេមានទាំងបង្រៀនកម្មការិនីឲ្យចេះវិជ្ជាមេផ្ទះខ្លះទៀតផងៗក្នុងមួយអាទិត្យកញ្ញាទាំងនោះអាចចេញទៅលេងក្រៅបាន តែចំពោះថ្ងៃខ្លះប៉ុណ្ណោះ ។ ម្ចាស់ឧស្សាហកម្មឥតបើកប្រាក់ឈ្នួលទាំងនោះ ។ ប្រាក់ឈ្នួលទាំងនោះគេទឹងបើកឲ្យទាំងអស់នៅពេលណាដែលកិច្ចសន្យាការងារបានផុតរលត់ ទ៏ងនៅពេលណាដែលនាងកញ្ញាណាមួយត្រូវការឈប់ធ្វើការ ដើម្បីយកគូស្រករ ។ ដូច្នេះ ប្រាក់ឈ្នួលធ្វើការរបស់នាងចាត់ទុកជាទ្រព្យខាងស្រី (dot) ក្នុងពេលរៀបអាពាហពិពាហមង្គល ។

ឧស្សាហកម្មជប៉ុនប្រកបដោយគ្រឿងប្រដាប់យ៉ាងទំនើប ទឹងរបៀបរៀបចំសម្រាប់ដំនួញយ៉ាងប្រសើរក្រៃលែង ។ ដូច្នេះ ប្រទេសជប៉ុនមានរោងចក្រធំ ៗ សំខាន់ជាងគេទាំងអស់ក្នុងទ្វីបអាស៊ី ។

(នៅមានត)

# អនាគតសមាជទី ៦ នៃពុទ្ធិកសមាគម ពិភពលោកនៅក្រុងភ្នំពេញ

សហជីវិន ស្រូ. ណៃភាម រៀបរៀង

---

ឆ្នាំទី ១៩៦១ នៃគ្រិស្តសករាជ ដែលត្រូវនឹងឆ្នាំទី ២៥០៤ នៃពុទ្ធសករាជ ជាឆ្នាំដែលប្រទេសកម្ពុជាបានទទួលមហាកិត្តិយសចំពោះមុខសាកលលោក គឺការស្វែងរកសន្តិភាពជូនមាតុប្រទេស ជូនប្រទេសជិតខាង នឹងជូនសាកលលោក ។ ការដែលសម្តេចព្រះនរោត្តមសីហនុ ជាព្រះប្រមុខរដ្ឋកម្ពុជាដ៏តូចនេះ បានទ្រង់យាងទៅបើកសម័យប្រជុំសន្និសីទនាក្រុងហ្សឺណែវ ស្តីអំពីបញ្ហាលាវ, ការដែលព្រះអង្គបានទាញមហាអំណាចជាគូប្រឆាំងឲ្យចូលមកអង្គុយជិតគ្នា, ការដែលព្រះអង្គបានបង្រួបបង្រួមបងប្អូនលាវនាក្រុងហ្សូរិច, ការដែលព្រះរាជបញ្ញាញាណ បានធ្វើឲ្យភ្លើងសង្គ្រាមនៅលាវ ដែលបំរុងនឹងឆេះឆាប ពាលដាលគ្រប់ទិសទី បានរលត់ទៅវិញ ការទាំងនេះជាព្រឹត្តិការណ៍វិសាមញ្ញមួយនៃប្រវត្តិសាស្ត្រអន្តរជាតិ ។

តែឆ្នាំ ១៩៦១ នេះ គឺពិតជាឆ្នាំដែលប្រទេសកម្ពុជាត្រូវទទួលកិត្តិយសធំមួយផ្សេងទៀត ដោយព្រះមហាករុណាធិគុណ នឹងព្រះរាជូបត្ថម្ភក៏ចំពោះព្រះពុទ្ធសាសនា នៃអង្គសម្តេចព្រះប្រមុខរដ្ឋដែលជាប្រធាននៃសង្គមរាស្ត្រនិយម ។ ព្រះអង្គបានទ្រង់អនុញ្ញាតជាលើកទី ២ ឲ្យធ្វើ

សមាជទី ៦ នៃពុទ្ធិកសមាគម ក្នុងខែវិច្ឆិកា ខាងមុខនេះ នៅក្រុងភ្នំពេញ ។ សន្និសីទអន្តរជាតិនេះ ត្រូវរួមប្រជុំប្រទេសដែលកាន់ពុទ្ធនិយម ចំនួនប្រមាណជា ៤១ ប្រទេសគឺ :

១– ប្រទេស អូទ្រីស (Autriche)

២– – អង់គ្លេស (Angleterre)

៣– – អាឡឺម៉ាញខាងលិច (Allemagne de l'Ouest)

៤– – អូស្ត្រាលី (Australie)

៥– – ភូមា (Birmanie)

៦– – លង្កា (Ceylan)

៧– – កូរ៉េខាងជើង (Corée du Nord)

៨– – កូរ៉េខាងត្បូង (Corée du sud)

៩– – កាណាដា (Canada)

១០– – ដាណឺម៉ាក់ (Danemark)

១១– – អេស្តូនី (Estonie)

១២– – បារាំង (France)

១៣– – ហ្វាំងឡង់ (Finlande)

១៤– – ហុងគ្រី (Hongrie)

១៥– – ហុងកុង (Hongkong macao)

១៦- ប្រទេសឥណ្ឌា (Inde)

១៧- — អ៊ីតាលី (Italie)

១៨- — ឥណ្ឌូណេស៊ី (Indonésie)

១៩- — ហ្វីលីពីន (Philippine)

២០- — ជប៉ុន (Japan)

២១- — លាវ (Laos)

២២- — លីទុយអានី (Lituanie)

២៣- — លិតូនី (Lettonie)

២៤- — ម៉ុងហ្គោលីក្រៅ (Mongolie extérieure)

២៥- — ម៉ុងហ្គោលីក្នុង (Mongolie intérieure)

២៦- — ម៉ាឡេស៊ី (Malaisie)

២៧- — ណេប៉ាល (Népal)

២៨- — ន័រវែស (Norvège)

២៩- — នូវែលហ្សេឡង់ (Nouvelle zélande)

៣០- — ប៉ាគីស្ថាន (Pakistan)

៣១- — ចិនប្រជាមានិត (Chine populaire)

៣២- — ស៊ុយអែត (Suède)

៣៣- — តង់ហ្គានីអ៊ុកា (Tanganyika)

៣៤– ប្រទេសថៃឡង់ដ៍ (Thailande)

៣៥– – ឆេកូស្លូវ៉ាគី (Tchécoslovaquie)

៣៦– – តៃវ៉ាន់ (Taivan)

៣៧– – សហរដ្ឋអាមេរិក (Etats Unis)

៣៨– – សហភាពសូវៀត (U.R.S.S.)

៤៩– – វៀតណាមខាងជើង (Aietnam Nord)

៤០– – វៀតណាមខាងត្បូង (Vietnam Sud)

រាជរដ្ឋាភិបាល ក្រោមព្រះបញ្ញាដ៏ខ្ពង់ខ្ពស់នៃសម្តេចសហជីវិន កំពុងចាត់ចែងរៀបចំសន្និសីទនេះដោយសកម្ម ៗ បានតាំងគណៈកម្មាធិការធំមួយ ដែលមានសម្តេចប៉ែន នុត ជាប្រធាន ។ គណៈកម្មាធិការនេះបានប្រជុំគ្នាធ្វើការជាច្រើនលើកហើយ ក្រោមអធិបតីភាពនៃសហជីវិនទេព-ផន រដ្ឋមន្ត្រីទី ១ ស្តីទី (ដែលពេលសម្តេចឯកឧត្តមមិននៅ) ហើយបានតាំងគណៈកម្មការរងជាច្រើន មានមុខការត្រូវប្រតិបត្តិដាច់ ៗ មុខ ៗ

សមាជទី ៦ នេះ នឹងយកសាលសន្និសីទធំនៅមុខព្រះបរមរាជវាំងជាទីប្រជុំ ។ រាជការមានសមត្ថកិច្ចកំពុងសំអិតសំអាងសាលសន្និសីទគុបតែងទីលានទទៀនជិតខាង និងបំរុងចំណតរថយន្ត ឲ្យជាទីមនោរម្យជូនគណៈប្រតិភូតាំងឡាយ ដែលនឹងចូលមកដល់ ។

យើងជឿជាក់ថា: ក្នុងពិធីដ៏ឧឡារិកខាងមុខនេះបញ្ជាក់ថា គ្រហស្ថ

ដែលជាសមាជិកនៃអនាគតសមាជទី ៦ ខាងពុទ្ធសាសនា មុខជានឹងលើក យកនូវបញ្ហាសំខាន់ ៗ ខ្លះមកពិភាក្សាវែកញែក រិះរកមធ្យោបាយដោះស្រាយជាពុំខាន ។

ព្រះធម៌គោលគឺទស្សនវិជ្ជាដ៏ទូលំទូលាយ ដែលព្រះសក្យមុនីគោតមបានក្រាយទុកមកជាប្រាសាទ ជាមហាប្រាសាទនៃសីលធម៌ ។ យើងយល់ថា ប្រជាជាតិសាកលលោកអាចស្រង់យកពីក្នុងព្រះធម៌នេះដោយអន្លើ ៗ នូវចំណុចខ្លះ ដើម្បីជាមាគ៌ានៃការប្រកបការងារ ជាមាគ៌ានៃការរស់នៅ, ជាមាគ៌ានៃការទាក់ទងរវាងមនុស្សនឹងមនុស្ស, ប្រជា-ជាតិនឹងប្រជាជាតិ, រដ្ឋនឹងរដ្ឋ ។

ព្រះធម៌នេះ កាលបើយកទៅប្រៀបធៀបនឹងទ្រឹស្តីដទៃ ១ឃើញថាមានលក្ខណៈវិសេសវិសាលឥតគណនា, ជាសច្ចធម៌ (ធម៌សំដែងអំពីសេចក្តីពិត) ជាយុត្តិធម៌ ( ធម៌សំដែងអំពីសេចក្តីត្រូវ) ប្រសិនបើបានផ្សាយហើយបានជ្រួតជ្រាបគ្រប់ល្ហម ព្រះធម៌នៃព្រះសម្មាសម្ពុទ្ធ អាចនឹងកំចាត់បង់ដោយភាគច្រើន នូវចិត្តឃោរឃៅអាក្រក់ឬស្យាមច្ឆិរិយចិត្ត (ចិត្តកំណាញ់ស្អប់ជន) នឹងបង្កើតឲ្យមានពិត ១ នូវមេត្តាធម៌ករុណាធម៌, មុទិតាធម៌, គោលគឺព្រហ្មវិហារធម៌ ដែលជាលំនៅនៃចិត្តដ៏ប្រសើរ ។

ព្រះធម៌នេះនាំឲ្យវៀរចាកផុតពីសេចក្តីវិនាស ព្រោះលោក អាចសម្លាប់អាត្មានិយមដែលជាមូលដ្ឋាននៃមោហៈ (សេចក្តីវង្វេង) នៃទោសៈ

(សេចក្ដីក្ដៅក្រហាយមានវិប្បដិសារីជាដើម) និងតែងតែជាឆ្អក់នៃភ្លើងរាគ និងភ្លើងសង្គ្រាម ។ ប្រទេសលាវ, វៀតណាម, កូរ៉េ, គុយបា, អង់គូឡា, កុងហ្គោ, កូវ៉ែត, អ៊ីរ៉ាក់, រុស្ស៊ី, និងសហរដ្ឋអាមេរិក ជាឧទាហរណ៍ស្រាប់ ។

ដោយព្រះពុទ្ធសាសនា ជាសាសនាផ្សាយនូវសេចក្ដីកប់អាន, សេចក្ដីអាណិត ទៅរកសព្វសត្វ ពុំប្រកាន់ជាន់ថ្នាក់, វណ្ណៈ បក្សពួក ។ ដោយព្រះពុទ្ធសាសនា ជាសាសនាផ្សាយអំណរទៅរកសព្វសត្វ ដែលបានសេចក្ដីសុខ-ចំរើន គឺមានអំណរនឹងគេបានសុខ-ចំរើន ។ ព្រះពុទ្ធសាសនា អាចទុកជាមាគ៌ាសំរាប់សាកលលោក ឈានទៅចាប់យកសន្តិភាពបាន ។

អាស្រ័យដោយការយល់បែបនេះហើយ បានជាកាលសម្ដេចព្រះប្រមុខរដ្ឋ កំពុងគង់នៅឯក្រុងហ្សឺណែវ មានវិញ្ញូជនបរទេសមួយរូបបានផ្ញើចុតហ្មាយមួយច្បាប់ទៅថ្វាយ សុំឲ្យព្រះអង្គបង្គាប់ទៅមហាប្រទេសទាំងឡាយ ឲ្យទទួលយកគោលនៃពុទ្ធនិយម ដើម្បីដោះស្រាយការវិវាទអន្តរជាតិ និងដើម្បីសន្តិភាពនៃពិភពលោក(១) ។

កម្លាំងនៃព្រះពុទ្ធសាសនា ស្ថិតនៅត្រង់ការពុំប្រឆាំងនឹងលទ្ធិ ឬទ្រឹស្ដីដទៃទៀតទាំងអស់ ទោះជាចំពោះលទ្ធិមូលធននិយម ក៏ដូចជាចំពោះលទ្ធិសង្គមនិយម ឬ រួមសម្បត្តិនិយមដែរ ។ ហើយជាពិសេស

---

១– សូមរង់ចាំអានចុតហ្មាយនេះ នៅលេខក្រោយ ។

ពុំដាស់ទីងសេចក្តីចំរើននៃលោកឡើយ ព្រោះព្រះធម៌ជាគ្រឿងអប់រំបញ្ញា, អប់រំចិត្ត (Développement de l'Intelligence, éducatoin de la volonté) ។ កាលណាបញ្ញាបានចំរើន, ចិត្តមានកម្លាំងបរិបូណ៌ ចិត្តនឹងនុះបានឈ្នះលើរូបកាយ, លើតណ្ហាហើយ (Discipliner la volonté) បញ្ញានឹងចិត្តនោះ ធ្វើឲ្យមនុស្ស ឲ្យលោកទទួលសេចក្តីចំរើន ទទួលសុភមង្គលដូចប្រាថ្នាពុំខាន ។

ដូចអស់លោកបានជ្រាបស្រាប់ ព្រះពុទ្ធសាសនាជាទ្រឹស្តីជាទស្សនវិជ្ជា ល្អប្រពៃយ៉ាងនេះក៏ដោយ ។ នៅតែបានទទួលស្គាល់បរាជ័យ បានស្គាល់សេចក្តីវិនាសដ៏ធ្ងន់ធ្ងរជាទីបំផុត ក្នុងដំណើរវង្វេងកាត់សតវត្សរ៍តាំងឡាយ ដែលកន្លងទៅហើយនេះ ។ អ្នកទស្សនវិទូជាច្រើន បានរិះរក ហើយបានចង្អុលបង្ហាញនូវដើមហេតុដ៏ច្បាស់លាស់នៃបរាជ័យនេះ ។ យើងសូមលើកយកតែហេតុខ្លះ មកជូនអស់លោកជាពុទ្ធមាមកជនទុកជាទីពិចារណាផ្ទាល់ ៗ តទៅ ។

ហេតុធំបំផុត ដែលនាំឲ្យព្រះពុទ្ធសាសនាកេយរៀវខ្ចាតចេញអំពីប្រទេសឥណ្ឌាដែលជាប្រទេសកំណើតក្តី ដែលនាំឲ្យពុទ្ធនិយមពុំបានលូតលាស់ទាន់កាលសម័យក្តី ក្នុងពិភពលោកក្តី មានពីរយ៉ាង :

១ ការជ្រៀតជ្រែកនៃវត្ថុធាតុផ្សេង ៗ (Subversion d'éléments divers ) ។

២ ការខ្វះការរៀបចំ ខ្វះសហការ (Manque d'organisation, manque de coopération) ។

ក)- ការជ្រៀតជ្រែកនៃវត្ថុធាតុផ្សេងៗ តាមប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនា ដែលត្រូវបានខ្ចាត់ខ្ចាត់ចេញពីប្រទេសឥណ្ឌា មានដើមហេតុមកពីការជ្រៀតជ្រែកនៃជនបរទេស ។ ជនទាំងនេះ ដែលមានជោគជ័យ បានចូលមកកតក្បាតជិះជាន់ប្រទេសឥណ្ឌា បានបង្ខំឲ្យអ្នកស្រុកយកអារ្យធម៌តាមខ្លួន ឲ្យបោះបង់ព្រះពុទ្ធសាសនា ទៅប្រតិបត្តិតាមជំនឿខ្លួនវិញ ។ ជនបរទេសនេះ តែងខំយករហស្ប្រាយគ្រប់បែបយ៉ាង ដើម្បីបំបិទចិត្ត-គំនិតអ្នកស្រុក ឲ្យប្រែប្រួលឃ្លាតវាតពីមាគ៌ាដ៏ប្រពៃ ដែលខ្លួនធ្លាប់ដើររៀងមក ។ ចំពោះការជ្រៀតជ្រែកនេះ ខេមរពុទ្ធសាសនិកជនយើងក៏គួរប្រមើលមើលយ៉ាងហ្មត់ចត់ ។ ការប្រុងប្រយ័ត្នគ្រប់បែបយ៉ាង ពុំមែនជាការលើស, ពុំមែនជាការឥតប្រយោជន៍ ឬ នាំឲ្យខូចប្រយោជន៍ណាឡើយ ។ ការប្រហែសធ្វេស, ការទុកចិត្តហួសប្រមាណ នឹងនាំមកនូវគ្រោះថ្នាក់ នូវសេចក្ដីវិនាស ( Le trop de confiance attire le danger) ។

មាត្រា ៨ នៃរដ្ឋធម្មនុញ្ញព្រះរាជអាណាចក្រយើង បានចែងថា .

សេរីភាពខាងជំនឿត្រូវបើកឲ្យមានបរិបូណ៌ ។ សេរីភាពក្នុងការប្រតិបត្តិខាងផ្លូវសាសនា ក៏ត្រូវបើកឲ្យមានដូច្នេះដែរ បើនឹងបន្ថយខ្វះបាន

តែត្រង់ណាដែលវៀរពុំបាន ដើម្បីកុំឲ្យខូចសេចក្ដីស្ងប់រៀបរយ ដល់មហាជន ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ; ប្រែជាភាសាបារាំងថា :

«La liberté de conscience est absolue. Il en est de même que pour celle des cultes qui ne subit d'autres restrictions que celle qui sont nécessaires pour que l'ordre puplic ne puisse être troublé.

Le bouddhisme est la religion de l'Etat»

បើយើងយកអត្ថបទនៃមាត្រានេះមកត្រិះរិះមើល ក៏យើងនឹងយល់មិនខាន ។

ប្រទេសកម្ពុជាយើង ជាប្រទេសដែលមានអធ្យាស្រ័យល្អជិតពេក ព្រោះការដែលតាំងព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ក៏គប្បីផ្ដល់ចំពោះសាសនានេះនូវបុព្វសិទ្ធិនានាជាអតិបរមា មានបង្ខំខាងផ្លូវជំនឿជាដើមៗ យើងបានឃើញពិតថា ទោះជាប្រជាពលរដ្ឋភាគច្រើន បើមែនខ្មែរសឹងតាំងអស់ (លើកលែងតែបងប្អូនដែលកាន់ខាងសាសនាឥស្លាមនឹងសាសនាកាតូលិក) ដោយមានព្រះមហាក្សត្រជាប្រមុខ ស្រឡាញ់នឹងគោរពជំនឿនេះយ៉ាងណាក៏ដោយ ក៏ខ្មែរពុំបង្ខំឲ្យខ្មែរគោរគគិត ឬឲ្យជនបរទេសអ្នកដទៃសាសន៍ ស្រឡាញ់គោរពព្រះពុទ្ធសាសនាតាមឡើយ ។ ទុកសេរីភាពបរិបូណ៌ ខាងផ្នែកជំនឿនេះ ( អ្នកណាចង់ជឿក៏ជឿទៅ ) ហើយអនុញ្ញាតឲ្យប្រតិបត្តិខាងផ្លូវសាសនា ដ៏បរិបូណ៌ថែមទៀត ។

ហើយជាពិសេសបំផុត ដែលបង្ហាញនូវការពុំប្រកាន់ដ៏បរិសុទ្ធរបស់យើង ពិតមែនតែរដ្ឋធម្មនុញ្ញបានបង្អុលអំពីលក្ខណៈនៃព្រះពុទ្ធសាសនា គឺប្រជា-ជាតិយើងពុំដែលយកផ្លូវជំនឿជាគោលក្នុងការតែងតាំងវរជន ឲ្យកាន់មុខតំណែង ឲ្យកាន់អគ្គការធំរបស់រដ្ឋឡើយ ។

ការដែលយើងធ្វើល្អទាំងនេះ ពុំប្រាថ្នាអ្វីក្រៅពីការស្វែងរកសេចក្តីសុខដុមជនរួមជាតិរបស់យើង ដូនជនានុជន ដែលចូលមកជ្រកកោនក្រោមម្លប់ព្រះបារមីនៃព្រះមហាក្សត្រយើង ។ យើងពុំប្រាថ្នាជ្រៀតជ្រែកក្នុងជំនឿអ្នកដទៃ តែយើងពុំត្រូវការឲ្យអ្នកដទៃជ្រៀតជ្រែកក្នុងជំនឿរបស់ជាតិយើងដែរ ។

មិនមែនដូច្នោះទេ ក្នុងបច្ចុប្បន្នកាលនេះ ពុទ្ធសាសនិកខ្មែរដែលបានពិចារណាក្នុងបញ្ហានេះ មានសេចក្តីបារម្ភជាច្រើនចំពោះដំណើរឯកភាពនៃសាសនារបស់ជាតិ (Unité de religion) ។ ឯកភាពដ៏វិសេសនេះដែលជាកេរ្តិ៍មត៌ករបស់បុព្វបុរសនៃយើង ជាគ្រឹះមួយក្នុងចំណោមគ្រឹះទាំងឡាយដែលបានទ្រទ្រង់ នឹងទ្រទ្រង់តទៅនូវជាតិមាតុប្រទេស ពុំឲ្យសាបសូន្យ ។ ការបារម្ភនេះកើតមកដោយបានសង្កេតសកម្មភាពខ្លាំងនៃអ្នកដឹកនាំសាសនាផ្សេង ៗ ហើយសកម្មភាពនេះមានសភាពកាន់តែប្លែក ៗ ឡើង ចាប់តាំងពីការឃោសនាតាមគ្រប់ច្រកល្ហកនៃជនបទ មានទាំងចូលដល់ទីវត្តអារាមព្រះសង្ឃពុទ្ធសាសនិកជនក៏មាន ដោយប្រើមធ្យោបាយ

ផ្សេង ៗ មានប្រើគន្ថខ្មែរ ប្រើឃោសនស័ព្ទ ការបញ្ចាំងភាព-យន្តអំពីសាសនា ហេតុដល់ការដឹកនាំទង់ទាញយុវជន ដែលជាយុវជនអនាគតខ្មែរដោយហេតុស្រាបាយគ្រប់បែបយ៉ាង ៗ សាសនិកជនខ្លះចេះភាសាខ្មែរយើងស្ទាត់ជំនាញណាស់ បានឆ្លើយថា ខ្លួនស្រឡាញ់ខ្មែរពិតអាណិតខ្មែរណាស់ បានជាចំជួយដឹកនាំខ្មែរខាងផ្លូវជំនឿ ឲ្យបានស្គាល់ខ្លឹមសារនៃ " អេវ៉ង់ហ្ស៊ីល " ឬនៃ " ប៊ិប " របស់ព្រះយេស៊ូ ឬដើម្បីឲ្យព្រះអាទិទេពដែលមានមហិទ្ធិឫទ្ធិបង្កបង្កើតលោក គាប់ស្រោបស្រង់ខ្មែរបានផង ហើយអ្នកសាសនិកនេះបញ្ជាក់ថា គ្រាន់តែបញ្ចុះបញ្ចូលឲ្យជឿទេតើ ពុំមែនធ្វើនយោបាយទេ ។

យើងពុំចាំបាច់អធិប្បាយទេ អំពីលក្ខណៈយ៉ាងណា បានហៅថាធ្វើនយោបាយ ឬក៏ពុំធ្វើនយោបាយ ៗ ម្យ៉ាងទៀត យើងក៏ពុំរែករញែកឲ្យវែងជាងនេះទៅទៀតទេ អំពីសកម្មភាពហួសអំណាចច្បាប់នៃបេសក-សាសនិកជនបរទេសទាំងនោះ ។

## ការខ្វះការរៀបចំ

ព្រះធម៌ជាវត្ថុដ៏មានបែងល្អិតល្អន់ក្រៃលែង តែនៅខ្វះរបៀបរៀបរយខាងការប្រតិបត្តិ ខាងការចាត់តាំងឲ្យមានរបៀបក្នុងពិភពលោកទៀង ៗ នគរ ប្រជាជាតិដែលកាន់ព្រះពុទ្ធសាសនានីមួយ ៗ មានអធិ-បតេយ្យដាច់ ៗ ពីគ្នា ពុំមានចំណង ហើយពុំប្រកបសកម្មភាពក្នុងការ

ផ្សាយព្រះធម៌ឲ្យសមល្មមសោះ ។

ចុះពុទ្ធិកសមាគមពិភពលោក មិនគឺអង្គការដែលរៀបចំមកដើម្បីឲ្យមានការរៀបរយ មានចំណងមានប្រកបសកម្មភាពស្របៗ គ្នានេះហើយ តើម្តេចក៏ថាគ្មានទៀត ? ការពិតពុទ្ធិកសមាគមនេះក៏ដោយ ដែលទើបមកហាក់រៀបចំផ្តើមមហាសន្និបាតនៅក្រុងភ្នំពេញថ្ងៃមុខនេះ ក៏ពុំមានការចាត់តាំងរៀបចំឲ្យបានហ្មត់ចត់ មានការទាក់ទងរវាងគ្នានិងគ្នា ឲ្យហូរហែមានសកម្មភាពយ៉ាងណាៗនោះ ក៏ទេដែរ ។

អាស្រ័យដោយហេតុដែលយើងបានរៀបរាប់មក យើងថ្លែងសេចក្តីសង្ឃឹមយ៉ាងមុតមាំចំពោះសមាជទី ៦ ជាសាកលនៃពុទ្ធសាសនានេះថា មុខជានឹងសម្រេចដោះស្រាយបញ្ហាសំខាន់ៗ ណាមួយពុំខាន ហើយយើងសូមជូនពរសព្ទសាធុការឲ្យសមាជសាកលនេះ ទទួលនូវជោគជ័យជាអតិបរមា ដើម្បីសេចក្តីចំរើននៃមនុស្សជាតិ ។

# រុក្ខជាតិល្ហុងដំងអំពៅ

ដោយភិក្ខុ ហ៊ាប់-ងឹល

សិស្សប្រម្រុងថ្នាក់ទី ៣ (ក) នៃពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត

( ប្រឡងជាប់លេខ ២ ខាងវំទៀមទម្លាក់ )

---

## រុក្ខជាតិល្ហុង

តាមការសង្កេតមើលនូវរុក្ខជាតិល្ហុង ដែលមានដុះនៅវត្តពោធិវង្ស (បុងតែ) ឃុំលៀងហ្វា ស្រុកបូរីថាញ់ ( សម្ដេច ) ខេត្តព្រះត្រពាំង នឹងបានពិនិត្យមើលនូវចម្ការដាំល្ហុងធំៗឯទៀត ព្រមទាំងធ្លាប់បានមើលឯកសារខ្លះទៀត ឃើញថា :

ល្ហុងជារុក្ខជាតិមួយមានសភាពទន់ ហើយដើមគ្មានមែកខ្នែងសាខា ដើមមូលវែងមានភាពមិនរាបស្មើ នៅខាងក្នុងដើមមានប្រហោង នៅខាងចុងមានស្លឹកដុះចេញជាកញ្ចុំធំៗ, ស្លឹកមួយ ៗ មានប្រវែងប្រហែល ៣០ សម ទទឹងប្រហែល ១៥ សម មានផ្កាទាំងល្ហុងឈ្មោលទាំងញី ផ្កាញីមានពងខែកដូចផ្ចិត ហើយមានខ្នាតធំៗ ។ ផ្កាឈ្មោលមានខ្នាតតូចជាងផ្កាញី ហើយទងវែងសំយុងចុះទៅក្រោម ។ ផ្កាវីកមានស្រទាប់ពណ៌សុទ្ធ ហើយគេសរលៀង ។ ដើមល្ហុងឈ្មោលឥតមានផ្លែទេ តែបើកាលដើមវានៅតូច គេកាត់ចុងចោលម្ដង ខ្លះហៅថាក្រៀវល្ហុង

ផ្លែដូច្នេះល្ហុងឈ្មោលក៏មានផ្លែដែរ តែផ្លែតូចៗ ភ្ជាប់នឹងទងផ្កាជាចង្កោមៗ ហើយផ្លែមូលៗ ដូចផ្លែត្របែក ផ្លែនេះគេមិនសូវប្រើការទេ ។ ដូន កាលនៅដើមជាមួយគ្នានេះ មានទាំងផ្លែឈ្មោលមានទាំងផ្លែញីផង ។ ផ្កាធ្លាក់កេសរចេញ បណ្ដាលបានជាផ្លែ ។ ផ្លែល្ហុងមានខ្នាតតូច-ធំ តាមពូជរបស់វា ។ ល្ហុងមានពូជច្រើនណាស់ ពូជខ្លះផ្លែវែង ខ្លះផ្លែខ្លី ខ្លះទៀតធំមូល ដូចជាល្ហុងមួយបែបដែលមានដុះនៅវត្តពោធិវង្ស (កម្ពុជាក្រោម) មានទំហំប៉ុនក្អមទឹក ។ ល្ហុងនេះគេហៅថា ល្ហុងបៀងហ្វា ពីព្រោះគេយកពូជមកពីខេត្តបៀងហ្វា នៅខាងលើក្រុងព្រៃនគរ ។ ព្រះតេជព្រះគុណវត្តនេះ កាលបើផ្លែល្ហុងទុំ តែងឲ្យក្មេងដាក់អង្រែក ដើម្បីរែកទៅប្រគេនទៅអធិការគ្រប់តែវត្តនៅក្នុងឃុំនោះ គឺល្ហុងមួយប្រគេនមួយវត្ត អាចឲ្យលោកឆាន់បាន ៧-៨ អង្គ ។

ល្ហុងនេះ កាលពីឆ្នាំ ១៩៥៦ ព្រះតេជព្រះគុណវត្តនេះ ឲ្យមេឃុំយកទៅតាំងពិព័រណ៍សេដ្ឋកិច្ច នៅខេត្តព្រះត្រពាំង បានជាប់លេខ ២ ។ មិនយូរប៉ុន្មាន មានល្បីល្បាញកេរ្តិ៍ឈ្មោះល្ហុងវត្តនេះ បណ្ដាលឲ្យអ្នកស្រុកជិតខាងមកសុំពូជយកទៅដាំ តែអ្នកខ្លះយកទៅដាំប៉ះនឹងដីដែលគ្មានជីជាតិ ក៏ត្រូវងាប់អស់ ខ្លះយកទៅដាំនៅលើដីមានជីជាតិល្អ នឹងប៉ះខ្យល់អាកាសច្រើនក៏បានដុះល្អឡើង ។

របៀបដាំល្ហុង — ល្ហុងជារុក្ខជាតិចូលចិត្តដុះនៅទីដីណាដែល

មានដីជូរឡាយនឹងខ្សាច់ផង នឹងដុះតាមដើមភ្នំ ឬ បរិវេណពាម ដែលទឹកលិចមិនដល់ ហើយដីនោះស្អិតបន្តិច ១ ផង ព្រោះពូជល្ហុងមិនសូវត្រាំនឹងទឹកលិចទេ បើយើងដាំឲ្យទឹកលិច ឬ ដីមានទឹកលិចជោគជាំ ល្ហុងច្រើនតែត្រូវខ្យល់បក់រលើងគល់ ពុំនោះនឹងញ៉ាររៀវស្រពោនមិនល្អឡើយ ។

ល្ហុងត្រូវដាំរើសរកចំការណា ដែលមានដីជូរ នឹងដីមានជីជាតិអាសូត (Azote) ច្រើនផង ពុំនោះនឹងដាក់ជីលាមកគោក្របីក៏បាន ។ ធ្វើដូច្នេះ ល្ហុងអាចផ្តល់ផ្លែមកបានធំ ៗ ល្អ ហើយមានរសជាតិផ្អែមផង ។

ល្ហុងគេច្រើនដាំនៅរដូវមានភ្លៀងជាដំបូង គឺជាខែឧសភា, មិថុនា, កក្កដា. ។ គេដាំល្ហុងគ្រាប់ គឺគេយកគ្រាប់ទៅបណ្តុះ កូនឲ្យបានកំពស់ប្រវែង ២០ ស ម-ឬ ១ ចំអាម ទើបគេដកយកទៅដាំនៅក្នុងចំការ ។ ធ្វើដូច្នេះ ជាការពិបាកណាស់ ព្រោះបើចំការធំ ១ ដល់ទៅ ៣-៤ គីឡូ. ម៉ែត្រ ធ្វើមិនងាយហើយទេ ។ ត្រូវយកគ្រាប់ទៅព្រោះក្នុងចំការវិញជាការងាយជាង ។ ការយកគ្រាប់នេះ គេអាចយកបានទាំងគ្រាប់ស្រស់ ទាំងគ្រាប់ស្ងួត ។ នៅក្នុងចំការ គេជីករណ្តៅប្រវែង ៣ ម៉ែត្រ ពីមួយទៅមួយ រួចគេដាក់គ្រាប់ ៤ ឬ ៦ គ្រាប់ទៅក្នុងរណ្តៅ ប្រយោជន៍ការ-ពារ ក្រែងត្រូវល្ហុងឈ្មោល គេនឹងដកចោលវិញ ។ នៅគ្រប់តែរណ្តៅ ត្រូវឲ្យមានទឹកសើមជានិច្ច ទំរាំកូនល្ហុងចាក់ឫសបានស្រួលបួល

សិន ៗ នៅដីណាមានដីជាតិល្អ ល្ហុងអាចផ្ដល់ផ្លែក្នុងរវាង ៦ ខែ ឬ ៨ ខែប៉ុណ្ណោះ ។

ផលប្រយោជន៍នៃល្ហុង -- ផ្លែល្ហុងជាផ្លែឈើម្យ៉ាងមានវីតាមីន (vitamine) គេយកអាស្រ័យបានទាំងខ្ចី ទាំងចាស់ ទាំងទុំទៀតផង ។ ផ្លែនៅខ្ចីគេយកទៅស្លកកូរ ស្លបង់ប្រហុល-ស្លកគ្រឿងម្ទេស អាស្រ័យសម្លនេះទៅធ្វើឲ្យចេញញើសស្រួលខ្លួន ទាំងចេញទឹកនោមផង ។ ផ្លែចាស់ ៗ ល្មមយកទៅចិតជាបន្ទះ ៗ ស្រុសហើយផ្សំនឹងទឹកជ្រលក់ ឬ យកទៅកោសជាចំរៀកតូច ៗ ច្របល់នឹងសាច់បង្គារ ឬ កំពឹស ។ ផ្លែល្ហុងទុំគេយកទៅបរិភោគនៅពេលបាយរួច ឬ ដាក់ត្រាំនឹងទឹកកក បរិភោគទៅឲ្យ [illegible] ឆាប់រំលាយអាហារ និងមានវីតាមីនទៀតផង ។ ឯផ្កាល្ហុងឈ្មោលក៏គេមិនចោលដែរ គេបេះផ្កានេះ យកទៅស្រុសឲ្យស្រពោនដើម្បីបញ្ចេញជាតិល្វីង រួចគេរកទឹកគ្រឿងមកផ្សំនឹងវា បង្កើតបានជាម្ហូប ១ មុខថ្មីទៀត ទទួលទានជាមួយបាយ ដើម្បីដោះពាល់ពេលគ្រាក្រម្ហូបម្ហាល ។

ផលប្រយោជន៍នៃជ័រល្ហុង -- តាមសេចក្ដីដំណាលថា : នៅសម័យបុរាណ ពួកខ្លះយកជ័រល្ហុងបោកគក់ខោអាវជំនួសសាប៊ូ ព្រោះល្ហុងជារុក្ខជាតិមានជ័រច្រើន ។

នៅសម័យបច្ចុប្បន្ន ពួកបច្ចេកទេសពិសោធមើលដឹងថា ល្ហុងជាវត្ថុធាតុមានប្រយោជន៍សំខាន់ណាស់ ៗ ទឹក ឬ ជ័រល្ហុង អាចជួយបំផ្លាញ

ព្រានទៅក្នុងពោះយើងបាន ។ បើកាលណាគេត្រូវការស្ងោរសាច់ឲ្យបានផុយឆាប់ គេត្រូវដាក់ជ័រនេះបន្តិចទៅ ទើបសាច់ឆាប់ផុយល្អ ។

**របៀបយកជ័រល្ហុង** ... ដើម្បីយកជ័រល្ហុងឲ្យបានស្រួលល្អ មិនឲ្យខូចផ្លែ យើងត្រូវទុកផ្លែឲ្យធំសិន ហើយយើងត្រូវឆូតផ្លែណាដែលចាស់គួរសមហើយ ។ តែកុំឲ្យចាស់ហួសពេកដែរ ព្រោះកាលបើចាស់ហួសពេក ល្ហុងនឹងផ្ដល់ជ័រមិនបានល្អ ។ ជ័រកាលណាយើងយកទៅអប់ នឹងមានពណ៌ដូចស្ករត្នោតហើយស្អិត យើងនឹងលក់ទៅមិនបានថ្លៃផង ។ បើយើងឆូតផ្លែចាស់ល្មមនោះ យើងនឹងបានទទួលនូវជ័រដ៏ល្អៗ ។ វិធីយកជ័រនេះ តាមឯកសារខ្លះប្រាប់ថា ត្រូវយកបន្ទះឫស្សី ធ្វើមុខឲ្យមុតទាំងសងខាងដូចកាំបិតយកទៅឆូតផ្លែល្ហុង មិនត្រូវយកប្រដាប់អ្វីដែលធ្វើអំពីលោហធាតុទេ ព្រោះលោហធាតុទាំងនេះ ធ្វើឲ្យជ័រមានពណ៌ខ្មៅ, ជាពិសេសជ័រល្ហុងកាលបើប៉ះនឹងលោហធាតុ ធ្វើឲ្យលោហធាតុមានច្រេះ ។

ការយកជ័រឲ្យបានល្អ គេមិនត្រូវឆូតឲ្យជ្រៅពេកទេ ពីព្រោះកាលបើប៉ះដល់សាច់ល្ហុង បណ្ដាលឲ្យជ័រមានពណ៌ខ្មៅ ត្រូវឆូតផ្លែល្ហុងពីលើចុះមកក្រោមធ្វើឲ្យស្រាលដៃ កុំឲ្យប៉ះនឹងសាច់វា ។ ជ័រចេញហើយ គេត្រូវយកបំពង់ឫស្សី ឬ ចានទៅត្រងពីក្រោម ដូចជារបៀបយកជ័រកៅស៊ូដែរ ។ តែប្រយ័ត្នកុំឲ្យធូលី ឬ សម្រាមចូលឲ្យសោះ ព្រោះនាំឲ្យខូចគុណភាពជ័រ ។

របៀបធួតយកជ័រនេះ គេត្រូវធ្វើនៅពេលព្រឹកចាប់តាំងពីម៉ោង ៦ ដល់ម៉ោង ៩ ឬ ១០ ព្រោះពេលព្រឹកត្រជាក់ បណ្ដាលឲ្យមានជ័រច្រើន ឬបើរដូវភ្លៀងជ័រតែងតែចេញច្រើនណាស់ទៀត ។

ការយកជ័រទៅប្រើការផ្សេង ៗ .— ជ័រល្ហុងដែលបានមកនេះ គេយកទៅដាក់លើកញ្ចក់ រួចគៀសឲ្យរាបស្មើតាមផ្ទៃកញ្ចក់ ធ្វើឲ្យមានកម្រាស់ប្រហែល ១សម ៩០ ។ កញ្ចក់នេះ ត្រូវជូតឲ្យស្អាតជានិច្ច មុននឹងយកទៅប្រើការ ។

ការធ្វើឲ្យមានផ្ទៃរាបស្មើ ៗ តាមកញ្ចក់នេះ ប្រយោជន៍ដល់ពេលយកជ័រទៅហាលថ្ងៃ ឬអប់ធ្វើឲ្យជ័រស្ងួតព្រមគ្នា ។ កាលបើធ្វើដូច្នេះបាន ហើយត្រូវយកទៅដាក់សំដិលខ្យល់ ២ ឬ ៣ ថ្ងៃ ទើបជ័របានស្ងួតល្អ ។ បើគេប្រើដោយឆ្នាំងអប់វិញ ជ័រនឹងអាចស្ងួតបានយ៉ាងឆាប់ រវាង ៦ ឬ ៧ ម៉ោងប៉ុណ្ណោះ ហើយផ្ដល់ជ័រមកបានល្អផង ។

ម្យ៉ាងទៀត នៅពេលយកជ័រចេញពីកញ្ចក់ ត្រូវពាក់ស្រោមដៃ ការពារកុំឲ្យជ័រកាត់ដៃ ។ ដើម្បីទុកជ័រនេះ ឲ្យបានយូរឆ្នាំ ត្រូវយកជ័រនេះ ទៅដាក់ក្នុងបំពង់ ឬកែវបិទឲ្យជិត កុំឲ្យខ្យល់ចូលបាន ។ ធ្វើដូច្នេះ អាចទុកបាន ៣ ឬ ៤ ឆ្នាំ ។

· ជ័រល្ហុងនេះ គេទុកយកទៅប្រកបការធ្វើថ្នាំផ្សេង ៗ ដូចជាថ្នាំព្រូនក្នុងពោះវៀនជាដើម ។ ចប់ រុក្ខជាតិល្ហុង

(នៅមានត)

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## សេចក្ដីរាយការណ៍សង្ខេប

ស្ដីអំពីសន្និសីទសាកលលោកនៃអ្នកកាន់សាសនាទាំងឡាយ ដើម្បីសន្តិភាព
ដែលបានធ្វើនៅក្រុង ក្យូតូ (ប្រទេសជប៉ុន) ពីថ្ងៃ ២៥-៧-៦១ ទៅទល់នឹងថ្ងៃ ២៨.៧.៦១
និងអំពីបូជនីយសចរណ៍កាត់តាមប្រទេសជប៉ុន

លោក ញ៉ែម-ទឹម ប្រែពីភាសាបារាំងមកជាភាសាជាតិ

---

កាលពីថ្ងៃ ១៩ មីនា ១៩៦១, គេបានបង្កើតអង្គការមួយនៅក្នុងប្រទេសជប៉ុនឲ្យឈ្មោះថា "សន្និសីទសាកលលោកនៃអ្នកកាន់សាសនាដើម្បីសន្តិភាព" ។ អង្គការនេះបង្កើតឡើងឥតសំដៅទៅលើសាសនាណាទេ, គឺសំដៅតែទៅរកសន្តិភាពសាកលលោកតែមួយប៉ុណ្ណោះ ។

តាមគោលការណ៍ សន្និសីទត្រូវបើកធ្វើពីថ្ងៃ ២៥ កក្កដា ទៅថ្ងៃ ២៨ កក្កដា ១៩៦១ រួមមានធ្វើបូជនីយសចរណ៍ ដើម្បីសន្តិភាព កាត់តាមប្រទេសជប៉ុន ក្នុងរយៈពេលមួយខែ ។

តាមសេចក្ដីអញ្ជើញនៃព្រះសង្ឃព្រះនាម ស.អយគាវ៉ា និងអ្នកស្រី (ហា.ណ្សាមីយ៉ា), ដែលជាប្រធាននៃគណៈកម្មាធិការរបស់អង្គការខាងលើនេះ ប្រទេសកម្ពុជាយើង ដែលតែងតែមានសេចក្ដីពេញចិត្តនឹងចូលរួមធ្វើបាតុកម្មដើម្បីសន្តិភាព, ក៏បានចាត់គណៈប្រតិភូមួយឲ្យចូល

ទៅរួមប្រជុំមហាបាតុកម្មនោះ ។ ឯគណៈប្រតិភូប្រទេសកម្ពុជាមានសមាសភាពដូចតទៅនេះ ៖

សហជីវិន ស៊ិុន-ប៊ុយហោ, រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនសិក្សាធិការប្រធាន ។

សហជីវិន វ៉ាយ-ល្មុត តំណាងរាស្ត្រ, ប្រធាននៃពុទ្ធិកសមាគមពិភពលោកមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ សមាជិក ។

សហជីវិន គួច-គីឡេង សាស្ត្រាចារ្យនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ សមាជិក ។

គណៈប្រតិភូបានចេញពីភ្នំពេញ ទៅថ្ងៃ ២២.៧.៦១ ម៉ោង ១០ និង ៣០នាទី ហើយបានទៅដល់តូក្យូ នៅថ្ងៃជាមួយគ្នា ពេលម៉ោង ២១ និង ៣០នាទី ។ នៅពេលចុះពីអាកាសយាន, គណៈប្រតិភូយើងបានទទួលការគួរសមពីឯ ឧ. ស៊ិម.វ៉ា, ឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំប្រទេសជប៉ុន និងអំពីគណៈកម្មាធិការ ខាងការរៀបចំបដិសណ្ឋារកិច្ច តាមពិធីការយ៉ាងស្រួល គឺមានវាយស្គរជានិមិត្តរូបនៃជនជាតិជប៉ុន ដែលកាន់ព្រះពុទ្ធសាសនា, ព្រមទាំងសូរទះដៃជាច្រើនផង និងមានបាចផ្កាក្រដាសជាច្រើនមកលើគណៈប្រតិភូយើង ។ល។

គណៈប្រតិភូយើងបានទៅសំណាក់នៅក្នុងសណ្ឋាគារមួយ ។

នៅថ្ងៃ ២៤-៧-៦១ គណៈប្រតិភូបានធ្វើដំណើរចេញពីរាជធានី តូក្យូ តាមរថភ្លើងតម្រង់ទៅទីក្រុង ក្យូតូ ។ នៅទីនោះ គណៈប្រតិភូយើង បានទៅសំណាក់នៅក្នុងក្យូតូ-សណ្ឋាគារ ។

នៅថ្ងៃ ២៥ ៧-៦១, ចាប់ពីម៉ោង ៨ ទៅ មានការប្រជុំយ៉ាង ឱឡារិក ដើម្បីបើកទ្វារសន្និសីទ ។

ក្រោយពីការសូត្រធម៌យ៉ាងវែង និងក្រោយពីសុន្ទរកថា ជាពិធីការ តាមរបៀបធម្មតានៃអ្នកចាត់ចែងធ្វើសន្និសីទ ដើម្បីសំដែងសេចក្តីរីករាយ ដល់គណៈប្រតិភូទាំងឡាយ ដែលបានអញ្ជើញទៅរួមធ្វើសន្និសីទ,គណៈ ប្រតិភូផ្សេង ៗ ក៏ឡើងថ្លែងការតាមលំដាប់អក្សរ ។ សេចក្តីថ្លែងការទាំង ប៉ុន្មាន បានចម្លងចូលក្នុងសៀវភៅមួយ ដែលមានឈ្មោះថា: "សន្និសីទ សាកលលោកនៃអ្នកកាន់សាសនា ដើម្បីសន្តិភាព ពីថ្ងៃ ២៥-២៨ កក្កដា ១៩៦១ ក្យូតូ-ជប៉ុន" ។

នៅថ្ងៃ២៦-៧-៦១ នៅពេលព្រឹក ជាពេលបើកប្រជុំ បង្កើតគណៈ កម្មការបួន មានការៈសិក្សាពិនិត្យនូវបញ្ហាទាំងឡាយ ដែលមានទាក់ ទងទៅនឹងសន្តិភាព, ហើយជាពិសេស អំពីបញ្ហាបន្ថយសព្វាវុធទូទៅ អំពីការអន្តរាយបណ្តាលមកពីគ្រាប់បែកបរមាណូ អ៊ីដ្រូសែន និងអំពី បំបាត់អាវុធប្រល័យលោក (Dénucléarisation) ។

ប្រទេសកម្ពុជាយើងបានចូលក្នុងគណៈកម្មការទីបួន ។ នៅថ្ងៃ

ដដែលនោះ ពេលប្រជុំបានបើកនៅម៉ោង ១៣ និង ៤៥ នាទី; នៅពេលនោះ គេឃើញអ្នកតំណាងសមាគមផ្សេង ៗ និងអង្គការផ្សេង ៗ ក្នុងប្រ-ទេសជប៉ុនឡើងថ្លែងការ, សមាគមនៃពួកអ្នកកាន់សាសនាគ្រិស្តដើម្បីសន្តិភាព, ពុទ្ធិកសមាគមនៃប្រទេសជប៉ុន, អ្នកតំណាងយុវជនកាតូលិក, សមាគមនិស្សិតអ្នកកាន់ព្រះពុទ្ធសាសនា ។ល។

នៅវេលាល្ងាចនៃថ្ងៃដដែលនោះ, លោកចៅហ្វាយក្រុងក្យូតូ បានរៀបចាត់ចែងធ្វើបដិសណ្ឋារកិច្ចចំពោះគណៈប្រតិភូទាំងអស់ នៃសន្និសីទនៅក្នុងសណ្ឋាគារក្យូតូ ។

នៅថ្ងៃ ២៧ ៧·៦១ ពីម៉ោង ៩ ទៅម៉ោង ១២, គណៈប្រតិភូប្រទេសកម្ពុជា បានចូលរួមប្រជុំពិនិត្យកិច្ចការ ដែលគណៈកម្មាធិការទីបួនត្រូវបំពេញ ។

ប្រតិភូទាំងឡាយដែលបានចូលរួមប្រជុំ បានបញ្ចេញយោបល់ផ្សេង ៗ ដែលគេអាចបំប្រួញឲ្យខ្លីមកមានដូចតទៅនេះ៖

–ការបង្កើតចលនាប្រឆាំងនឹងការប្រើគ្រាប់បែកបរមាណូ, ដោយអនុវត្តន៍តាមគោលការណ៍របស់សាសនានៃប្រទេសនីមួយ ៗ ។

– ការបំបាត់ចោលនូវមូលដ្ឋានយោធា

– ការបន្ថយសព្វាវុធទៅ

គណៈប្រតិភូប្រទេសកម្ពុជា បានទាញសម្បជញ្ញៈគណៈកម្មាធិការអំពីគោលបំណងនៃសន្និសីទនេះ ដែលផ្អែកលើមូលដ្ឋានសាសនា ហើយគាំទ្រពេញទំហឹងនូវការបន្ថយសព្វាវុធទូទៅ ដោយយោងយកតាមគោលការណ៍ ដែលអង្គការសហប្រជាជាតិបានកំណត់ទុកមក នឹងគាំទ្រនូវបេក្ខជនភាពនៃប្រទេសចិនប្រជាមានិត ក្នុងការសុំចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ។ ប្រទេសកម្ពុជា ក្នុងឋានៈជារដ្ឋអព្យាក្រឹត, សូមអំពាវនាវដល់រដ្ឋបុរសនៈយោបាយអ្នកដឹកនាំប្រទេសទាំងឡាយ សូមឲ្យលោកទាំងនោះ រើសយកនយោបាយអព្យាក្រឹតពិតប្រាកដទៀងទាត់មកអនុវត្តន៍ ។ ប្រទេសកម្ពុជាសូមផ្សាយសេចក្តីអត់ឱន នឹងភាតរភាព ។

នៅថ្ងៃ ២៨-៧-៦១, សហជីវិន ស៊ុឆ-ប៊ុឃកោ ជាប្រធាននៃគណៈប្រតិភូយើង បានត្រូវគេជ្រើសតាំងជាប្រធានកិត្តិយសនៃសម័យប្រជុំ ។

ក្រោយពីបានឈរស្ងៀមស្ងាត់អស់ពេលចំនួនមួយនាទី គោរពដល់វិញ្ញាណក្ខន្ធនៃអ្នករងគ្រោះនៅក្រុងហ៊ីរ៉ូហ្ស៊ីម៉ា, នឹងស្តាប់សេចក្តីរាយការណ៍ដោយសង្ខេបរបស់គណៈកម្មាធិការទាំងបួន នឹងសមាគមស្ត្រី, ព្រមទាំងការធ្វើអន្តរាគមន៍ខ្លះ នៃបណ្តាគណៈប្រតិភូផ្សេង ៗ ទីប្រជុំក៏បានជ្រើសតាំងគណៈកម្មាធិការតែងសេចក្តីមួយ ផ្តើមកត់ត្រាចម្លងឲ្យ

បានត្រឹមត្រូវនូវសេចក្ដីសម្រេចចិត្តជាអវសាន (សូមអាន សេចក្ដីសម្រេចចិត្តជាអវសាននេះ នៅលេខក្រោយ) ។ អត្ថបទដែលគណៈកម្មការតែងសេចក្ដីបានផ្ញើមក បានត្រូវគេអនុមតិទទួលយល់ព្រមជាឯកច្ឆន្ទ ក្រោយពីមានការកែតម្រូវខ្លះពីគណៈប្រតិភូប្រទេសកម្ពុជា និងប្រទេសយូហ្គោស្លាវី ។

នៅម៉ោង ១៤ ទៅម៉ោង ១៧, គេមានធ្វើពិធីបិទសម័យប្រជុំនៃសន្និសីទនៅក្នុងសាលមហោស្រពមួយនៃសាលាក្រុងក្បែត ។

នៅលើវេទិកាមួយ ដែលលំអទៅដោយក្លួផ្កាផ្សេងៗ សមាជិកនៃគណៈកម្មការខាងការរៀបចំធ្វើសន្និសីទ បានឡើងថ្លែងសុន្ទរកថាដ៏វែងជាបន្តបន្ទាប់គ្នា ។ សេចក្ដីថ្លែងការណ៍បានទទួលការទះដៃអបអរសាទរជាខ្លាំងពីទីប្រជុំ ។

(នៅមានត)

ក្នុងពិភពលោក ។ ក្នុងការប្រជុំនេះ ក្រោយដែលមានថ្លែងការរៀងរាល់ប្រទេសរួចហើយ គណៈប្រតិភូគ្រប់ប្រទេស ដែលទៅរួមប្រជុំនៅទីនោះ បានធ្វើសេចក្ដីសម្រេចចិត្តមួយ សុំឲ្យអ្នកកាន់អំណាចគ្រប់ប្រទេសតូចធំក្នុងពិភពលោក គិតគូរឲ្យមានសន្តិភាពសាកលលោកឡើង ។

គណៈប្រតិភូយើងបានបញ្ជាក់ថា នៅក្នុងសេចក្ដីសម្រេចចិត្តរួមនេះ គេបានថ្លែងសរសើរដល់ប្រទេសជាច្រើន មានប្រទេសកម្ពុជាយើងជាដើម ដែលនិយមកាន់អព្យាក្រិត ។ ព្រោះអព្យាក្រិតភាពនេះ ជាមូលដ្ឋាននៃសុខសន្តិភាពក្នុងសាកលលោក ។

សូមអញ្ជើញអាននៅក្នុងផ្នែកកំណត់ ទីនប្រវត្តិការណ៍នៃទស្សនាវដ្ដីនេះ នឹងបានជ្រាបនូវពត៌មានយ៉ាងពិស្ដារ ។

---

# ព្រះអំណោយនៃសម្ដេចព្រះប្រមុខរដ្ឋ

---

កាលពីពេលព្រឹកថ្ងៃទី ៧ សីហា ១៩៦១, សម្ដេចសហជីវិនជាព្រះប្រមុខរដ្ឋ ទ្រង់ព្រះបរមពជានុញ្ញាត ឲ្យព្រះភិក្ខុនាម យ៉-ថៃ ហ៊ា ជាអាហារូបករណិកនៃផែនការ "កូឡុំបូ" ចូលគាល់ដើម្បីចំរើនព្រះពរលាព្រះអង្គ ទៅបំពេញវិជ្ជានៅប្រទេសសេរីលង្កា (សៃឡង់) ។ សម្ដេចសហជីវិនទ្រង់បានស្ដេចប្រគេនបច្ច័យ ៤ ០០០ʳ០០ ជាជំនួយដល់ការចំណាយផ្សេង ៗ ក្នុងការរៀបចំដំណើរចំពោះព្រះភិក្ខុអង្គនេះ ។